

ច្បាប់អន្តរជាតិបង្កើតរចនាសម្ព័ន្ធ និងធ្វើនិយ័តកម្មទំនាក់ទំនងអន្តរជាតិ។ វាជាគ្រោងឆ្អឹងនៃទំនាក់ទំនងអន្តរជាតិ និងប្រើសម្រាប់ជាវិធានល្បែង ដើម្បីជានាកិច្ចសហប្រតិបត្តិការ និងការប្រកួតប្រជែងរវាងរដ្ឋនិងរដ្ឋ។ វាញ៉ាំងឱ្យមានការចរចារវាងផលប្រយោជន៍ខុសៗគ្នា និងប្រើជាឧបករណ៍សម្រាប់អង្គការអន្តរជាតិ ដូចជាអង្គការសហប្រជាជាតិ(ONU) និងសហភាពអឺរ៉ុប។ ច្បាប់អន្តរជាតិសាធារណៈកំណត់វិធានដែលអនុវត្តបានចំពោះភាពទីទៃពីគ្នានៃលម្ហជាតិ និងលម្ហអន្តរជាតិ ធានាភាពរៀបរយនៃការផ្លាស់ប្តូរសេដ្ឋកិច្ច ដោះស្រាយជម្លោះរវាងរដ្ឋ។

ក្នុងសៀវភៅនេះ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន មិនត្រឹមតែនាំអ្នកអានឱ្យស្គាល់ទំនាក់ទំនងច្បាប់អន្តរជាតិជុំវិញសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគប៉ុណ្ណោះទេ តែក៏នាំអ្នកអានទៅមើលដំណើរកកើត និងរបៀបអនុវត្តច្បាប់នៅតាមស្ថាប័នរដ្ឋ អង្គការអន្តរជាតិ និងអង្គការតំបន់ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងវិភាគទានដល់សន្តិភាព និងការអភិវឌ្ឍរបស់ពិភពលោក។

ISBN: 978 99950 99 03 9

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

នីតិអន្តរជាតិសេដ្ឋកិច្ច

# នីតិអន្តរជាតិ
# សេដ្ឋកិច្ច



ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ឧបត្ថម្ភបោះពុម្ពផ្សាយដោយ
សាកលវិទ្យាល័យជាតិគ្រប់គ្រង

២០១៧

សហការជាមួយ
គ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា

Sipar

# នីតិអន្តរជាតិ
# សេដ្ឋកិច្ច

*រចនាទំព័រ និងសម្រួលអត្ថបទដោយអង្គការSipar*

*© ហង់ជួន ណារ៉ុន*
*រក្សាសិទ្ធិគ្រប់យ៉ាង*

*បោះពុម្ពនៅកម្ពុជាដោយរោងពុម្ព អេស អេច*

# នីតិអន្តរជាតិ

# សេដ្ឋកិច្ច

ដោយ បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**២០១៧**

*អង្គហេតុ និងគំនិតដែលលើកឡើងក្នុងសារណានេះគឺជាមតិផ្ទាល់របស់អ្នកនិពន្ធ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា ឬឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិឡើយ។*

# មាតិកា


ពាក្យបំព្រួញ និងអក្សរកាត់ ............................................................ ១១
សេចក្តីផ្តើម ............................................................ ១៥

**ជំពូក១ - ការវិវត្តនៃនីតិអន្តរជាតិ** ............................................................ ១៧
ផ្នែកទី១ - ការអភិវឌ្ឍជាប្រវត្តិសាស្ត្រ ............................................................ ១៧
ផ្នែកទី២ - លទ្ធិនៃនីតិអន្តរជាតិ ............................................................ ៣៣

**ជំពូក២ - ប្រភពនៃច្បាប់អន្តរជាតិ** ............................................................ ៣៥
ផ្នែកទី១ - កំណាកំណើតនៃច្បាប់អន្តរជាតិ ............................................................ ៣៥
ផ្នែកទី២ - ប្រភពចម្បង ............................................................ ៣៨
ផ្នែកទី៣ - ប្រភពបន្ទាប់បន្សំ ............................................................ ៤៥
ផ្នែកទី៤ - ចរិតលក្ខណៈគតិយុត្តចម្បងនៃច្បាប់អន្តរជាតិ ............................................................ ៤៩

**ជំពូក៣ - រដ្ឋ** ............................................................ ៦១
ផ្នែកទី១ - កំណាកំណើតរដ្ឋ ............................................................ ៦១
ផ្នែកទី២ - រដ្ឋជាប្រធានចម្បងនៃច្បាប់អន្តរជាតិ ............................................................ ៦៣
ផ្នែកទី៣ - គោលការណ៍ជាសារវន្តដែលគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ ............................................................ ៦៦
ផ្នែកទី៤ - ទ្រឹស្តីនៃសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋ ............................................................ ៧៧
ផ្នែកទី៥ - សមត្ថកិច្ចរបស់រដ្ឋ ............................................................ ៨១
ផ្នែកទី៦ - ការទទួលស្គាល់រដ្ឋ ............................................................ ៨៣
ផ្នែកទី៧ - ការស្នងរដ្ឋ ............................................................ ៨៧
ផ្នែកទី៨ - ទំនួលខុសត្រូវអន្តរជាតិរបស់រដ្ឋ ............................................................ ៨៩
ផ្នែកទី៩ - ដែនកំណត់នៃអធិបតេយ្យភាពរបស់រដ្ឋ ៖ អភ័យឯកសិទ្ធិ
និងប្រព្រឹត្តកម្មបុគ្គលឯកជន ............................................................ ៩៣





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជំពូក៤ - អង្គការអន្តរជាតិ** ........ ១០៩
ផ្នែកទី១ - ការបង្កើតអង្គការអន្តរជាតិ ........ ១០៩
ផ្នែកទី២ - ច្បាប់អង្គការសហប្រជាជាតិ ........ ១១៥

**ជំពូក៥ - ច្បាប់សន្ធិសញ្ញា** ........ ១២១
ផ្នែកទី១ - ការចុះសន្ធិសញ្ញាអន្តរជាតិ ........ ១២១
ផ្នែកទី២ - សិទ្ធិបម្រុងសម្រាប់សន្ធិសញ្ញាពហុភាគី ........ ១២៤
ផ្នែកទី៣ - សុពលភាពនៃការសន្យាតាមអនុសញ្ញា ........ ១២៦
ផ្នែកទី៤ - អានុភាពនៃសន្ធិសញ្ញា ........ ១២៨
ផ្នែកទី៥ - ជីវិតនៃសន្ធិសញ្ញា ........ ១៣០
ផ្នែកទី៦ - អវសាន្តនៃការសន្យាតាមអនុសញ្ញា ........ ១៣២

**ជំពូក៦ - អង្គការមិនមែនរដ្ឋាភិបាល បុគ្គលឯកជន និងនីតិបុគ្គល** ........ ១៣៧
ផ្នែកទី១ - អង្គការមិនមែនរដ្ឋាភិបាល ........ ១៣៧

**ជំពូក៧ - នីតិអាស៊ាន** ........ ១៤១
ផ្នែកទី១ - សេចក្តីផ្តើមទូទៅ ........ ១៤១
ផ្នែកទី២ - ប្រវត្តិនៃការអភិវឌ្ឍស្ថាប័នអាស៊ាន ........ ១៤៥
ផ្នែកទី៣ - យន្តការដោះស្រាយអធិករណ៍របស់អាស៊ាន ........ ១៤៨
ផ្នែកទី៤ - ស្ថាប័នរបស់អាស៊ាន ........ ១៦១
ផ្នែកទី៥ - ក្របខ័ណ្ឌគតិយុត្តដែលកែលម្អមួយចំនួន ........ ១៦៧
ផ្នែកទី៦ - សេរីភាវូបនីយកម្មដោយជម្រើស និងវិវឌ្ឍបន្តិចម្តងៗ ........ ១៦៩
ផ្នែកទី៧ - សហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ និងក្រៅតំបន់ ........ ១៧៨
ផ្នែកទី៨ - កិច្ចសហប្រតិបត្តិការផ្នែកនយោបាយសន្តិសុខ ........ ១៨៨
ផ្នែកទី៩ - នយោបាយកិច្ចសហប្រតិបត្តិការសង្គមវប្បធម៌ ........ ១៩៦


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជំពូក៨** - **នីតិអង្គការពាណិជ្ជកម្មពិភពលោក** ....................................................២០៧
ផ្នែកទី១ - រចនាសម្ព័ន្ធគតិយុត្ត និងស្ថាប័នអង្គការពាណិជ្ជកម្មពិភពលោក..........២០៧
ផ្នែកទី២ - យន្តការដោះស្រាយអធិករណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក ....២២១
ផ្នែកទី៣ - ការពង្រឹងវិន័យ ......................................................................... ២២៣
ផ្នែកទី៤ - គោលការណ៍គ្រឹះ និងដំណើរការនៃកិច្ចព្រមព្រៀងផ្សេងៗ
របស់អង្គការពាណិជ្ជកម្មពិភពលោក.............................................២២៥
ផ្នែកទី៥ - ការពង្រឹងច្បាប់ស្តីពីពាណិជ្ជកម្មទំនិញ ពីកិច្ចព្រមព្រៀងទូទៅ
ស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៤៧ ទៅកិច្ចព្រមព្រៀងទូទៅ
ស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ ........................................ ២៣២

**ជំពូក៩** - **ច្បាប់ស្តីពីវិនិយោគទុនបរទេស** ...............................................................២៤៥
ផ្នែកទី១ - សេចក្តីផ្តើមនៃនីតិវិនិយោគ ........................................................២៤៦

**ជំពូក១០** - **ច្បាប់បារាំងស្តីពីវិនិយោគ**.......................................................................២៥៧

**ជំពូក១១** - **ច្បាប់វិនិយោគអន្តរជាតិ**...........................................................................២៦៩

**ជំពូក១២** - **នីតិនៃវិវាទអន្តរជាតិ**...............................................................................២៧៥
ផ្នែកទី១ - កាតព្វកិច្ចនៃការដោះស្រាយជម្លោះដោយសន្តិវិធី ............................២៧៦
ផ្នែកទី២ - ការប្រកួតប្រជែងនៃវិធីដោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធី........២៧៩

**ជំពូក១៣** - **ចលនាទូទៅនៃយុត្តាធិការភាវូបនីយកម្ម នៅក្នុងនីតិអន្តរជាតិ**......... ២៨៩
ផ្នែកទី១ - ចរិតលក្ខណៈរបស់យុត្តាធិការភាវូបនីយកម្មនៃនីតិអន្តរជាតិ...............២៨៩
ផ្នែកទី២ - លក្ខណៈវិនិច្ឆ័យចាំបាច់របស់យុត្តាធិការអន្តរជាតិ.............................២៩៧

**ជំពូក១៤** - **ស្ថានភាពស្ថាប័ន និងចរិតលក្ខណៈអង្គការនៃយុត្តាធិការអន្តរជាតិ**......៣០១
ផ្នែកទី១ - ស្ថានភាពស្ថាប័ន ......................................................................៣០១
ផ្នែកទី២ - ចរិតលក្ខណៈអង្គការ..................................................................៣០៥



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជំពូក១៥** - **យុត្តាធិការជាកាតព្វកិច្ច និងយុត្តាធិការតាមការព្រមព្រៀង** ............... ៣១៩
ផ្នែកទី១ - មូលដ្ឋានគ្រឹះនៃយុត្តាធិការ ............................................................ ៣១៩
ផ្នែកទី២ - យុត្តាធិការជាកាតព្វកិច្ច .............................................................. ៣២៥
ផ្នែកទី៣ - យុត្តាធិការជាកាតព្វកិច្ច ឬយុត្តាធិការតាមការព្រមព្រៀង
ទៅតាមឋានៈអ្នកទទួលការជំនុំជម្រះ .............................................. ៣២៩

**ជំពូក១៦** - **សមត្ថកិច្ច និងភាពអាចទទួលយកបាននៅចំពោះមុខ**
**យុត្តាធិការអន្តរជាតិ**...................................................................... ៣៣៥
ផ្នែកទី១ - សមត្ថកិច្ច ..................................................................................... ៣៣៥
ផ្នែកទី២ - ភាពអាចទទួលយកបាន................................................................... ៣៤១

**ជំពូក១៧** - **ធាតុបង្កើត និងការស៊ើបសួររបស់តុលាការ ៖ ការធានានីតិវិធី** ................. ៣៤៥
ផ្នែកទី១ - លក្ខណៈសាធារណៈនៃនីតិវិធី ....................................................... ៣៤៥
ផ្នែកទី២ - ភាពល្បីល្បាញនៃនីតិវិធី............................................................... ៣៤៦
ផ្នែកទី៣ - សមធម៌នៃនីតិវិធី.......................................................................... ៣៤៧

**ជំពូក១៨** - **ផ្លូវឧបាស្រ័យ**.......................................................................... ៣៤៩
ផ្នែកទី១ - តុលាការយុត្តិធម៌អន្តរជាតិ............................................................ ៣៤៩
ផ្នែកទី២ - តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ .................................................... ៣៥២
ផ្នែកទី៣ - យុត្តាធិការព្រហ្មទណ្ឌ.................................................................... ៣៥២
ផ្នែកទី៤ - អង្គដោះស្រាយវិវាទនៃអង្គការពាណិជ្ជកម្មពិភពលោក ....................... ៣៥៦

ឯកសារយោង .............................................................................................. ៣៦១
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន.................................................................... ៣៦៩
ស្នាដៃរបស់អ្នកនិពន្ធ ...................................................................................... ៣៧១

# ពាក្យបំព្រួញ និងអក្សរកាត់

## ១. ឯកសារបោះពុម្ពផ្សាយ

| | |
|---|---|
| *ADM* | ទិនានុប្បវត្តិនៃនីតិសមុទ្រ |
| *AFDI* | ទិនានុប្បវត្តិបារាំងស្តីពីនីតិអន្តរជាតិ |
| *RCADI* | កម្រងឯកសារបង្រៀនរបស់បណ្ឌិត្យសភានីតិអន្តរជាតិ |
| *RGDIP* | ទស្សនាវដ្តីទូទៅស្តីពីនីតិសាធារណៈអន្តរជាតិ |
| *SFDI* | សមាគមបារាំងដើម្បីនីតិអន្តរជាតិ |

## ២. ស្ថាប័ន និងផ្សេងៗ

| | |
|---|---|
| *ACIA* | កិច្ចព្រមព្រៀងពេញលេញថ្មីនៃអាស៊ានស្តីពីវិនិយោគ |
| *ADB* | ធនាគារអភិវឌ្ឍអាស៊ី |
| *ADMM* | កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិ |
| *ADPIC ( TRIPS)* | កិច្ចព្រមព្រៀងស្តីពីការការពារច្បាប់កម្មសិទ្ធិបញ្ញាដែលទាក់ទិននឹងពាណិជ្ជកម្ម |
| *AEM* | កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ច |
| *AFAS* | កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម |
| *AFMM* | កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន |
| *AFTA* | កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន |
| *AGCS ( GATS)* | កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម |
| *AIA* | កិច្ចព្រមព្រៀងក្របខ័ណ្ឌតំបន់វិនិយោគអាស៊ាន |
| *ALENA ( NAFTA)* | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង |
| *AMF* | កិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ |
| *AMM* | កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស |
| *ANC* | បណ្ណសារដ្ឋានជាតិកម្ពុជា |
| *APC* | ជំនួយសម្រាប់ពាណិជ្ជកម្ម |
| *ARF* | វេទិកាតំបន់អាស៊ាន |
| *ASEAN* | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| *ASED* | កិច្ចប្រជុំរដ្ឋមន្ត្រីអប់រំអាស៊ាន |

| | |
|---|---|
| *ATIGA* | កិច្ចព្រមព្រៀងថ្មីស្ដីពីពាណិជ្ជកម្មទំនិញអាស៊ាន |
| *ATV* | កិច្ចព្រមព្រៀងស្ដីពីវាយនភណ្ឌ និងសម្លៀកបំពាក់ |
| *BM (WB)* | ធនាគារពិភពលោក |
| *CCI* | សភាពាណិជ្ជកម្មអន្តរជាតិ |
| *CDI* | គណៈកម្មការច្បាប់អន្តរជាតិ |
| *CEDH* | តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស |
| *CEPT* | កិច្ចព្រមព្រៀងស្ដីពីអត្រាពន្ធគយរួមអនុគ្រោះ |
| *CIADH* | តុលាការអន្តរ-អាមេរិកាំងទទួលបន្ទុកសិទ្ធិមនុស្ស |
| *CIJ ( ICJ )* | តុលាការយុត្តិធម៌អន្តរជាតិ |
| *CIRDI* | តុលាការមជ្ឈត្តការរបស់ធនាគារពិភពលោក |
| *CJCE* | តុលាការយុត្តិធម៌សហគមន៍អឺរ៉ុប |
| *CMB* | អនុសញ្ញាទីក្រុងម៉ុងតេហ្គោបេយ៍ |
| *CNPA* | អាជ្ញាធរជាតិប្រេងកាតកម្ពុជា |
| *CNUDCI* | គណៈកម្មការនៃអង្គការសហប្រជាជាតិទទួលបន្ទុកច្បាប់ពាណិជ្ជកម្មអន្តរជាតិ |
| *CNUDM* | សន្និសីទអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ |
| *CPA* | តុលាការមជ្ឈត្តការអចិន្ត្រៃយ៍ |
| *CPI* | តុលាការអចិន្ត្រៃយ៍អន្តរជាតិ |
| *CPJI ( CPIJ )* | តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ |
| *DPI* | នីតិឯកជនអន្តរជាតិ |
| *FAO* | អង្គការស្បៀងអាហារ និងកសិកម្ម |
| *FMI (IMF)* | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| *GATT* | កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម |
| *GDP* | ផលិតផលក្នុងស្រុកសរុប |
| *GRC* | រាជរដ្ឋាភិបាលកម្ពុជា |
| *IAE* | កិច្ចព្រមព្រៀងស្ដីពីការត្រួតពិនិត្យទំនិញមុនពេលផ្ទុក |
| *IAI* | កិច្ចផ្ដួចផ្ដើមសមាហរណកម្មអាស៊ាន |
| *ICO* | កិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គការពលកម្មពិភពលោក |
| *IDE* | ការវិនិយោគផ្ទាល់ពីបរទេស |
| *IUCN* | សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ |

| | |
|---|---|
| *JDZ* | តំបន់អភិវឌ្ឍរួមគ្នា |
| *MEPC* | យន្តការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម( *MEPC* |
| *MFN* | ឋានៈជាតិទទួលបានការអនុគ្រោះខ្លាំង |
| *MIC* | កិច្ចព្រមព្រៀងស្តីពីវិធានការវិនិយោគទាក់ទិននឹងពាណិជ្ជកម្ម |
| *MNCs* | ក្រុមហ៊ុនពហុជាតិ |
| *NOEI* | សណ្តាប់ធ្នាប់សេដ្ឋកិច្ចអន្តរជាតិថ្មី |
| *OACI* | អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ |
| *OEPC* | អង្គភាពពិនិត្យនយោបាយពាណិជ្ជកម្ម |
| *OIC* | អង្គការពាណិជ្ជកម្មអន្តរជាតិសម្រាប់ពាណិជ្ជកម្ម |
| *OIT* | អង្គការពលកម្មអន្តរជាតិ |
| *OMPI* | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| *ONG ( NGO )* | អង្គការមិនមែនរដ្ឋាភិបាល |
| *ONU* | អង្គការសហប្រជាជាតិ |
| *ORD* | អង្គភាពដោះស្រាយវិវាទ |
| *OSCE* | អង្គការដើម្បីសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប |
| *OTAN ( NATO )* | អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង |
| *OTC* | កិច្ចព្រមព្រៀងប្រឆាំងនឹងការលក់បន្ធូចថ្លៃ កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម |
| *OUA* | អង្គការសហភាពអាព្រិច |
| *PLI* | កិច្ចព្រមព្រៀងស្តីពីនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល |
| *PNUD (UNDP)* | កម្មវិធីអភិវឌ្ឍសហប្រជាជាតិ |
| *RPK* | សាធារណរដ្ឋប្រជាមានិតកម្ពុជា |
| *SEATO* | អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍( សេអាតូ) |
| *SEOM* | កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន |
| *SMC* | ឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ |
| *SPS* | វិធានការអនាម័យ និងភូតគាមអនាម័យ |
| *SWAP* | កិច្ចសន្យាផ្តល់ឥណទាន *SWAP* |
| *TAC* | សន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ |
| *TANU* | តុលាការរដ្ឋបាលរបស់អង្គការសហប្រជាជាតិ |

| | |
|---|---|
| *TBI* | សន្ធិសញ្ញាទ្វេភាគីស្តីពីការលើកស្ទួយ និងការការពារការវិនិយោគ |
| *TIDM* | តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ |
| *TPIY* | តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់យូហ្គោស្លាវី |
| *TPR* | តុលាការឧក្រិដ្ឋកម្មសម្រាប់រ៉្វាន់ដា |
| *UE ( EU )* | សហគមន៍អឺរ៉ុប |
| *WTO (OMC)* | អង្គការពាណិជ្ជកម្មពិភពលោក |
| *ZEE* | តំបន់សេដ្ឋកិច្ចផ្តាច់មុខ |
| *ZOPFAN ( SEANWFZ )* | តំបន់គ្មានអាវុធនុយក្លេអ៊ែរនៅអាស៊ីអាគ្នេយ៍ |

# សេចក្ដីផ្ដើម

**នីតិអន្តរជាតិ** សិក្សានូវធម្មនិយាមគតិយុត្តដែលគ្រប់គ្រងទំនាក់ទំនងរវាងប្រជាជាតិនានា។ នីតិអន្តរជាតិបានបែកមែកសាខាតាមវិស័យផ្សេងៗដែលពាក់ព័ន្ធនឹងទំនាក់ទំនងរវាងប្រជាជាតិអធិបតេយ្យទាំងនោះ។ **នីតិអន្តរជាតិសេដ្ឋកិច្ច** គឺជាធម្មនិយាម គតិយុត្តដែលគ្របដណ្ដប់ទំនាក់-ទំនងសេដ្ឋកិច្ចរវាងប្រទេសនានាក្នុងសកលលោក មានជាអាទិ ទំនាក់ទំនងពាណិជ្ជកម្ម វិនិយោគ ការដោះស្រាយវិវាទ សមាហរណកម្មក្នុងតំបន់។ល។

សៀវភៅ **នីតិអន្តរជាតិសេដ្ឋកិច្ច** នេះ គឺជាកម្រងមេរៀនសង្ខេប ដែលអ្នកនិពន្ធបានចងក្រង និងកត់ត្រាទុក នៅពេលរៀនមុខវិជ្ជា **នីតិអន្តរជាតិសាធារណៈ និងប្រៀបធៀប** តាមកម្មវិធីសញ្ញាបត្រទ្វេនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសកលវិទ្យាល័យលីយ៉ុងទី២។ មេរៀនទាំងនេះគ្របដណ្ដប់មុខវិជ្ជាផ្សេងៗដូចជា ការវិវត្ត និងប្រភពនៃនីតិអន្តរជាតិ រដ្ឋ នីតិអនុសញ្ញា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល នីតិអាស៊ាន នីតិអង្គការពាណិជ្ជកម្មពិភពលោក នីតិវិនិយោគអន្តរជាតិ និងយន្តការដោះស្រាយជម្លោះក្នុងនីតិអន្តរជាតិ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងផ្ដល់ព័ត៌មានដែលមានសារៈប្រយោជន៍ដល់និស្សិតដែលសិក្សាមុខវិជ្ជា **នីតិអន្តរជាតិសាធារណៈ និងប្រៀបធៀប** ក៏ដូចជាមុខវិជ្ជាពាក់ព័ន្ធ ដទៃទៀត និងបង្កើតឱ្យមានកិច្ចពិភាក្សាបែបស្ថាបនា ដើម្បីជាគុណប្រយោជន៍ដល់ពុទ្ធិ និងការកសាងធនធានមនុស្សនៅកម្ពុជា។

ធ្វើនៅភ្នំពេញ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# ជំពូក១
# ការវិវត្តនៃនីតិអន្តរជាតិ

*ដើម្បីពិនិត្យការវិវត្តនៃនីតិអន្តរជាតិ ជាបឋមយើងត្រូវពិនិត្យមើលការវិវត្តជាប្រវត្តិសាស្ត្រនៃនីតិអន្តរជាតិ(ផ្នែកទី១) បន្ទាប់មកត្រូវវិភាគលទ្ធិនៃនីតិអន្តរជាតិ(ផ្នែកទី២)។*

## ផ្នែកទី១
## ការអភិវឌ្ឍជាប្រវត្តិសាស្ត្រ

### ១- ការលេចឡើងនៃរដ្ឋ និងនីតិអន្តរជាតិ
### ១.១- ពីសម័យក្រិចបុរាណដល់សម័យយុគកណ្តាល

*ទំនាក់ទំនងកុងស៊ុល និងការទូតរវាងសហគមន៍ផ្សេងៗ ព្រមទាំងសន្ធិសញ្ញាសម្ព័ន្ធមិត្ត ឬសន្ធិសញ្ញាសន្តិភាពបានកើតឡើងតាំងពីយូរលង់ណាស់មកហើយ។ សញ្ញាណមូលដ្ឋាននៃច្បាប់អន្តរជាតិមួយចំនួន ដូចជាសន្ធិសញ្ញាព្រំប្រទល់មានអត្ថិភាពរាប់ពាន់ឆ្នាំមកហើយ។[១] នៅសម័យក្រិចបុរាណ(អំឡុងពេល២០០ឆ្នាំ នៅក្នុងវប្បធម៌ក្រិច ពីសតវត្សរ៍ទី៥ដល់សតវត្សរ៍ទី៤មុនគ្រិស្តសករាជ) អំណាចពិសិដ្ឋនៃសន្ធិសញ្ញាត្រូវបានលើកឡើង ដូចជាសន្ធិសញ្ញាជាច្រើនត្រូវបានចុះហត្ថលេខា ដើម្បីភ្ជាប់រដ្ឋទីក្រុង។ សន្ធិសញ្ញានេះត្រូវបានមើលឃើញថាផ្តល់សិទ្ធិឱ្យពលរដ្ឋនៃរដ្ឋ និងជានាការការពារដល់ភ្នាក់ងារការទូត។[២] ប្រទេសក្រិចមានឥទ្ធិពលមួយយ៉ាងធំទៅលើពួករ៉ូម៉ាំង ដែលប្រព័ន្ធគតិយុត្តមានអានុភាពយ៉ាងធំសម្បើមទៅលើទ្វីបអឺរ៉ុបខាងលិច។*

*នីតិរ៉ូម៉ាំងជាប្រព័ន្ធគតិយុត្តរបស់ទីក្រុងរ៉ូមបុរាណ ហើយវឌ្ឍនកិច្ចគតិយុត្តរួមមានយុទ្ធ-សាស្ត្រជាងមួយពាន់ឆ្នាំមកហើយ។ មុននឹងសាធារណរដ្ឋរ៉ូម៉ាំងត្រូវបានបង្កើតនៅឆ្នាំ៥០៩ មុនយុគសម័យយើងនេះ ពួករ៉ូម៉ាំងដំបូងៗរស់នៅទៅតាមច្បាប់បវេណី(iusជាភាសាឡាតាំង)ដែលត្រូវបានបញ្ជូនបន្តពីជំនាន់មួយទៅជំនាន់មួយ។ ច្បាប់នេះអនុវត្តតែចំពោះពលរដ្ឋរ៉ូម៉ាំងទេ*

---

[១] *A solemn treaty was signed around 2100BC between the rulers of Lagash and Umma, the city-states in Mesopotamia. It defined the boundary to be respected by both parties (SHAW (M.),* International Law, *6th Edition Cambridge, Cambridge University Press, p. 15.*

[២] *SHAW (M.), ibid.*

ដូច្នេះវាជាiusរដ្ឋប្បវេណី ឬជាច្បាប់រដ្ឋប្បវេណី។ នៅឆ្នាំ៥១០ មុនគ្រិស្តសករាជជាមួយនឹងការបណ្តេញស្តេច Tarquin le Superbe សាធារណរដ្ឋរ៉ូម៉ាំងត្រូវអភិវឌ្ឍឡើងដូចជារដ្ឋទីក្រុងខ្សោយមួយ។

ពលរដ្ឋនៃទីក្រុងរ៉ូមត្រូវបានបែងចែកចេញជាពីរថ្នាក់ ៖ អភិជនដែលជាថ្នាក់ពួកវរជនដែលដឹកនាំសង្គមរ៉ូម៉ាំង និងប្រជានិករដែលជាប្រជាជនរួមទូទៅ។ បុគ្គលជាអភិជនមួយក្រុមដែលហៅថាមន្ត្រីមានសមណសក្តិ ជាអ្នកដែលបានធ្វើសេចក្តីសម្រេច និងបានវិនិច្ឆ័យទៅលើបញ្ហាច្បាប់បវេណី។ អភិជនមានទំនោរទៅរកការស្វែងរកអត្ថប្រយោជន៍ខ្លះនៅក្នុងសេចក្តីសម្រេចតុលាការដែលធ្វើឡើងដោយមន្ត្រីមានសមណសក្តិ។ ភាពទោមនស្សបានរីករាលដាលធំឡើងជាមួយនឹងភាពផ្តាច់ការនៃសេចក្តីសម្រេច។ ភាពទោមនស្សនេះបានកើតឡើងនៅក្នុងសម័យសាធារណរដ្ឋដែលនាំឱ្យមានរង្គោះរង្គើនៅក្នុងសណ្តាប់ធ្នាប់សង្គម ដូចជាពួកប្រជានិករបានរំដើបរំជួល ដើម្បីទទួលបានសមភាពនយោបាយ និងសង្គម។ ពួកប្រជាកសិករត្រូវសង្កត់សង្កិនដោយច្បាប់សរសេរ ដើម្បីឱ្យពួកគេអាចប្រមើលមើលជាមុននូវសេចក្តីសម្រេចដែលធ្វើឡើងដោយពួកអភិជនមានសមណសក្តិ។

នៅឆ្នាំ៤៥១មុនគ.ស គណៈកម្មាធិការមានសមាជិកដប់រូប ហៅថា décemvirs ត្រូវបង្កើតឡើង ដើម្បីសរសេរច្បាប់ជាលើកទីមួយ។ ការងារដែលពួកគេបានធ្វើឡើងនៅឆ្នាំ៤៤៩មុនគ.ស គឺតារាងបញ្ជីទាំងដប់ពីរ បានផ្តល់ធនធានជាឯកសារដល់ច្បាប់បវេណីដែលមានចំណាស់រាប់រយឆ្នាំមកហើយ និងបានក្លាយជាមូលដ្ឋានគ្រឹះនៃនីតិរ៉ូម៉ាំង។ តារាងបញ្ជីទាំងដប់ពីរផ្តោតទៅលើវិស័យច្បាប់ជាច្រើន មិនត្រឹមតែច្បាប់រដ្ឋប្បវេណីដែលអនុវត្តដោយផ្ទាល់ចំពោះពលរដ្ឋទេ តែមានទាំងវិស័យដទៃទៀតដូចជាច្បាប់សាធារណៈ និងច្បាប់សាសនាដែលអនុវត្តចំពោះសំណង់និងស្ថាប័នសង្គមធំៗ។ តារាងបញ្ជីទាំងដប់ពីរគ្រាន់តែបានបំប្លែងច្បាប់បវេណីដែលបានបង្កើតឡើង (ius)ទៅជាទម្រង់សរសេរមួយ(lex)។ ក្នុងខណៈពេលដែលតារាងបញ្ជីទាំងដប់ពីរត្រូវបានបំផ្លាញនៅក្នុងការឈ្លានពានរបស់ពួកសែលទិកនៅសតវត្សរ៍ទី៤មុនគ.ស មរតករបស់ពួកគេនៅខ្លាំងក្លា ហើយខ្លឹមសារមួយភាគធំគឺគេបានស្គាល់នៅឡើយ។

ទាក់ទងនឹងប្រភពច្បាប់សរសេរ តារាងបញ្ជីទាំងដប់ពីរ(ឆ្នាំ៤៥១ មុនគ្រិស្តសករាជ)ជាលក្ខន្តិកៈមួយផង(lex) និងជាក្រមមួយផង។ សេចក្តីប្រកាសរបស់ព្រះចៅអធិរាជមានកម្លាំងជាច្បាប់(Lex)។ ច្បាប់«ដាច់ខាត»ត្រូវបានអភិវឌ្ឍដោយបញ្ញត្តិរបស់ចៅក្រម ជាពិសេសរបស់ប្រេទ័រ(ចៅក្រម)ក្រុង។ មុខងារប្រចាំថ្ងៃរបស់ប្រេទ័រ គឺផ្តល់សំណងជួសជុលក្នុងករណីបុគ្គល។

នៅឆ្នាំ២៧២មុនគ្រិស្តសករាជ បន្ទាប់ពីសម័យកាលនៃការវាតទីទឹកដីមក ឆន្ទៈរបស់ទីក្រុងរ៉ូមទៅលើប្រទេសអ៊ីតាលីស្ទើរតែពេញលេញ។ នៅក្នុងសង្គ្រាមឆ្នាំ២៦៤-២៤១មុនគ្រិស្តសករាជ និង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឆ្នាំ២១៨-២០១ Carthageដែលជាគូប្រជែងមួយសម្រាប់តំបន់មេឌីទែរ៉ាណេខាងលិច និងកណ្តាល នៅទីបំផុតក៏ត្រូវបានផ្តួលឱ្យចុះចាញ់។ បន្ទាប់មកទៀត ទីក្រុងរ៉ូមមានសង្គ្រាមជាមួយបូព៌ាប្រទេស។ ការរាតទីទឹកដីនៅសតវត្សរ៍ទី២មុនគ.ស បានប្រែមុខមាត់របស់ប្រទេសអ៊ីតាលីដែលមានអាជីវកម្មកសិកម្មតូចៗដែលជាកម្មសិទ្ធិរបស់កម្មសិទ្ធិករធំៗ ជាមួយនឹងពួកទាសករ។

ក្នុងច្បាប់រ៉ូម៉ាំង មានច្បាប់ខុសគ្នាបីប្រភេទ។ ច្បាប់ទីមួយគឺ ius civile ពោលគឺបណ្តុំនៃច្បាប់ដែលតាំងពីដើមមកអនុវត្តចំពោះពលរដ្ឋរ៉ូម៉ាំង និង praetores urbani ពោលគឺជាបុគ្គលដែលមានសមត្ថកិច្ចទៅលើកិច្ចការដែលញ៉ាំងឱ្យមានការចូលរួមរបស់ពលរដ្ឋ។ Praetores peregrini ជាបុគ្គលដែលមានសមត្ថកិច្ចទៅលើកិច្ចការដែលពាក់ព័ន្ធនឹងពលរដ្ឋ និងជនបរទេស។ ពាក្យ «ច្បាប់រដ្ឋប្បវេណី»ទៅតាមន័យនៃលទ្ធិគតិយុត្តដែលមានមូលដ្ឋានពីពួករ៉ូម៉ាំងគឺចេញមកពីពាក្យ ius civile។ នេះជាអ្វីដែលយើងចង់បង្ហាញថាជា«នីតិវិជ្ជមាន»នាពេលបច្ចុប្បន្ននេះ។ នៅតាមវិទ្យាស្ថាននានា គេសរសេរថា ៖ «សមូហភាពនីមួយៗដែលគ្រប់គ្រងដោយច្បាប់ និងបវេណីប្រើប្រាស់ច្បាប់ផ្ទាល់របស់ខ្លួនមួយភាគ( ច្បាប់រដ្ឋប្បវេណី និងជាអាទិច្បាប់របស់រដ្ឋ) និងច្បាប់រួមទូទៅសម្រាប់មនុស្សជាតិទាំងមូល»។ មានការបែងចែកផ្សេងទៀតរវាង«ច្បាប់សរសេរ» ជាច្បាប់ដែលគេហៅថា leges ឬlex និងបណ្តុំគំនិត equitas របស់ពួករ៉ូម៉ាំងដែលជាប្រភពនៃពាក្យ «សមធម៌»។ គឺជាការសម្រេចរបស់តុលាការនៅក្នុងស្ថានភាពជាក់លាក់មួយដែលជួយកែលម្អអានុភាពនៃច្បាប់សរសេរ។

ដោយហេតុតែសាធារណរដ្ឋរ៉ូម៉ាំងបានរីកធំ និងបន្ទាប់មកប្រែក្លាយទៅជាអាណាចក្រមួយ មេដឹកនាំប្រទេសនេះបានប្រឈមទៅនឹងបញ្ហាប្រឈមកាន់តែច្រើននៅក្នុងការដឹកនាំប្រជាជនមួយដែលកាន់តែមានភាពចម្រុះជាតិពន្ធ។ បញ្ហាគតិយុត្ត និងជម្លោះបានកើតឡើងដោយខានមិនបាន មិនត្រឹមតែនៅក្នុងចំណោមពលរដ្ឋរ៉ូម៉ាំងទេ ថែមទាំងជាមួយនឹងបុគ្គលមិនមែនពលរដ្ឋដែលរស់នៅ ឬធ្វើដំណើរឆ្លងកាត់ទឹកដីរបស់ខ្លួនដែលច្បាប់ ius civile មិនអនុវត្តចំពោះជនទាំងនេះទេ។ ទាំងនេះបាននាំឱ្យមានការតាក់តែងច្បាប់ ius gentium («ច្បាប់របស់ជាតិ ឬច្បាប់អន្តរជាតិ») និងច្បាប់ius naturale («ច្បាប់ធម្មជាតិ»)។

Ius naturale គឺជាច្បាប់ធម្មជាតិ។ Ius naturale គឺជាបណ្តុំគំនិតមួយដែលត្រូវបានអភិវឌ្ឍឡើងដោយអ្នកច្បាប់នៃប្រទេសក្រិចបុរាណ ដើម្បីពន្យល់ថាហេតុអ្វីមនុស្សហាក់ដូចជាគោរពតាមច្បាប់មួយចំនួន។ ចម្លើយរបស់ពួកគេគឺថា «ច្បាប់ធម្មជាតិ» ដែលបានបញ្ជ្រាបចូលទៅក្នុងគ្រប់ភាវៈទាំងអស់មានអត្ថន័យរួមមួយ។ វារួមមានរាល់អ្វីៗដែលហួសពីអំណាចតែងច្បាប់របស់មនុស្ស។ គំនិត«ច្បាប់ធម្មជាតិ»ដែលអភិវឌ្ឍចេញពីច្បាប់ ius naturale រួមមានបណ្តុំគំនិតសិទ្ធិមនុស្សជាមូលដ្ឋានរបស់មនុស្សដែលមិនអាចដកហូតចេញដោយច្បាប់មនុស្សបាន។ សៀវភៅរបស់ស៊ីសេរ៉ុង

(១០៦-៤៣មុនគ្រិស្តសករាជ)[៣] បានជះឥទ្ធិពលទៅលើការអភិវឌ្ឍនៃច្បាប់ ius naturale ហើយច្បាប់ចុងក្រោយនេះក៏បានជះឥទ្ធិពលបន្តទៅលើលទ្ធិធម្មជាតិនៃច្បាប់វិហារសាសនាកាតូលិករ៉ូម៉ាំងនៅយុគសម័យកណ្តាល និងក៏ជាអ្វីដែលត្រូវគេបានពណ៌នាថាជាទ្រឹស្តីដែលត្រូវបាន«ផ្សឹកជាគ្រហស្ថ»ធម្មជាតិនៃច្បាប់។ នៅក្នុងសៀវភៅ Legibus ស៊ីសេរ៉ុងបានសរសេរថា ៖

«ច្បាប់បរិសុទ្ធគឺជាហេតុផលត្រឹមត្រូវដែលស្របទៅនឹងធម្មជាតិ និងផ្សព្វផ្សាយនៅក្នុងចំណោមមនុស្សទាំងអស់។ ច្បាប់នេះនៅថេរ និងមិនប្រែប្រួល និងត្រូវអំពាវនាវឱ្យមនុស្សបំពេញមុខងាររបស់ពួកគេទៅតាមសិក្ខាបទនៃច្បាប់នេះ និងរារាំងពួកគេកុំឱ្យប្រព្រឹត្តកំហុសដូចមានចែងក្នុងបញ្ញត្តិនៃច្បាប់នេះ...។»

*Jus gentium* ដែលហៅថាច្បាប់របស់ជាតិគឺជាអង្គនៃច្បាប់ដែលអនុវត្តចំពោះរាល់បុគ្គលជនបរទេស ជនមិនមែនពលរដ្ឋ និងពលរដ្ឋ និងត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍ និងការពិចារណារួមដែលសង្គមមានអារ្យធម៌ និងមនុស្សជាតិទទួលយកដើម្បីរស់នៅ និងចែករំលែក។ ទាំងនេះសុទ្ធសឹងជាច្បាប់ដែលមានប្រភពដើមពីមនុស្ស ប៉ុន្តែ «ដូចគ្នាទៅនឹងមនុស្សជាតិទាំងអស់»។ Jus gentium ត្រូវបានចាត់ទុកថាជាទិដ្ឋភាពមួយនៃច្បាប់ធម្មជាតិ (jus naturale) ដោយផ្ទុយគ្នាទៅនឹងច្បាប់រដ្ឋប្បវេណី (ius civile)។

ច្បាប់នៃការលក់ត្រូវបានចែងនៅក្នុងកម្រងសៀវភៅច្បាប់ (មាតិកាទីXXII De consensu obligatione) របស់ Justinien។ ពួករ៉ូម៉ាំងគឺជាអ្នកជំនួញប៉ិនប្រសប់ ជាសហគ្រិន និងបានបង្កើតអាណាចក្រពាណិជ្ជកម្មមួយដែលទាមទារច្បាប់ធ្វើនិយ័តកម្មអន្តរការណ៍របស់ពួកគេ។ សម្រង់ខាងក្រោមនេះយោងទៅដល់ច្បាប់កាតព្វកិច្ច ៖ «កាតព្វកិច្ចត្រូវបង្កើតឡើងដោយការព្រមព្រៀងរបស់គូភាគីតែប៉ុណ្ណោះនៅក្នុងកិច្ចសន្យាលក់ ជួល ទទួលឱ្យបម្រើការងារ ភាពជាដៃគូ និងអាណត្តិ។ ក្នុងករណីទាំងនេះ គេនិយាយថា កាតព្វកិច្ចមួយត្រូវធ្វើឡើងដោយការព្រមព្រៀងសាមញ្ញធម្មតារបស់គូភាគី ព្រោះមិនចាំបាច់សរសេរទាំងអស់ ហើយក៏មិនចាំបាច់មានវត្តមានរបស់គូភាគី ហើយក៏មិនចាំបាច់ពោលថា រាល់អ្វីដែលឯកភាពប្រគល់ឱ្យធ្វើមានភាពបង្ខិតបង្ខំដោយកិច្ចសន្យាទេ ប៉ុន្តែគឺគ្រាន់តែការព្រមព្រៀងគ្នាធម្មតារបស់បុគ្គលដែលមានអន្តរការណ៍រវាងគ្នានឹងគ្នាគឺគ្រប់គ្រាន់ហើយ»។

ច្បាប់រ៉ូម៉ាំងបានបន្សល់ទុកនូវមរតកជាច្រើន។ បន្ទាប់ពីការរំលាយអាណាចក្ររ៉ូម៉ាំងនៅប៉ែកបស្ចិម ក្រមរបស់ Justinien នៅជាធរមាននៅក្នុងអាណាចក្រប៉ែកបូព៌ាដែលគេស្គាល់នៅសម័យកាលទំនើបថាជាអាណាចក្របីហ្សង់ស៍(៣៣១-១៤៥៣)។ ប្រព័ន្ធច្បាប់ដែលត្រូវបានចងក្រងជាក្រម ពោលគឺ Corpus Juris Civilis បានជះឥទ្ធិពលទៅលើពិភពច្បាប់រដ្ឋប្បវេណី

[៣] មេធាវីនៅតុលាការ និងជាអ្នកនយោបាយ មុនគ្រិស្តសករាជ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មួយផ្នែកធំ។ ច្បាប់រ៉ូម៉ាំងក៏សំដៅដល់ប្រព័ន្ធគតិយុត្តដែលត្រូវបានអនុវត្តនៅប៉ែកភាគច្រើននៃអឺរ៉ុបខាងលិចរហូតដល់ចុងសតវត្សរ៍ទី១៨។ នៅប្រទេសអាល្លឺម៉ង់ ការអនុវត្តច្បាប់រ៉ូម៉ាំងនៅមានដំណើរការខ្លាំងនៅក្រោមរបបទេពអាណាចក្ររ៉ូម៉ាំងអាល្លឺម៉ង់(៩៦៣-១៨០៦)។ ដូចនេះ ច្បាប់រ៉ូម៉ាំងបានប្រើជាមូលដ្ឋានសម្រាប់ការអនុវត្តគតិយុត្តនៅក្នុងអឺរ៉ុបដែនដីទ្វីបខាងលិចទាំងមូល។

សព្វថ្ងៃនេះ បណ្តុំគំនិតដែលជាប់ជាមួយលំដាប់គតិយុត្តដែលស្ថិតនៅក្នុង ius naturale និង ius gentium ដែលមានគោលដៅពង្រីកខ្លួនហួសពីព្រំដែនជាតិនោះ គឺជាមូលដ្ឋានគ្រឹះនៃច្បាប់សិទ្ធិមនុស្ស និងច្បាប់អន្តរជាតិនៅក្នុងពិភពលោកទាំងមូល។ ចំពោះពួករ៉ូម៉ាំង ច្បាប់បានអភិវឌ្ឍជាវិទ្យាសាស្ត្រមួយ ហើយសព្វថ្ងៃនេះ យើងកំពុងសរសេរវិទ្យាសាស្ត្រច្បាប់។ សព្វថ្ងៃនេះ យើងកំណត់ ius gentium ថាជា«ច្បាប់អន្តរជាតិ»។ វិធាននៃការទូត និងវិធាននៃស្ថានភាពទំនាក់-ទំនងត្រូវបានគ្រប់គ្រងដោយ ius gentium។ ច្បាប់ស្តីពីការអនុវត្តពាណិជ្ជកម្មក៏ត្រូវបានបង្កើតនៅក្នុង ius gentium - អ្វីដែលយើងហៅថា «ច្បាប់អន្តរជាតិឯកជន» នៅពេលសព្វថ្ងៃនេះ។ ច្បាប់អន្តរជាតិទំនើប រួមទាំងច្បាប់សមុទ្របានទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីទិដ្ឋភាពនៃច្បាប់រ៉ូម៉ាំងនេះ។

អ្នកច្បាប់ Gaius បានឱ្យនិយមន័យ ius gentium ថាដូចជា«ហេតុផលធម្មជាតិបានបង្កើតរវាងប្រជាជនទាំងអស់» ៖ ប្រជាជននីមួយៗ(Populus)ដែលត្រូវគ្រប់គ្រងដោយច្បាប់ និងបវេណី (leges និងmores) គោរពតាមនីតិកម្មផ្ទាល់ពិសេសរបស់ខ្លួនមួយភាគ និងម្យ៉ាងទៀតគោរពតាមច្បាប់រួមគ្នារបស់មនុស្សជាតិទាំងមូល។ សូមឱ្យច្បាប់សម្រាប់ប្រជាជនមួយដែលត្រូវបានបង្កើតសម្រាប់ពួកគេមានភាពដោយឡែកផ្ទាល់ខ្លួន និងហៅថា ius civile (ច្បាប់រដ្ឋប្បវេណី) ថាជាច្បាប់ពិសេសនៃរដ្ឋ(Civitas)នេះ នៅក្នុងពេលដែលច្បាប់ដែលហេតុផលធម្មជាតិបង្កើតរវាងមនុស្សទាំងអស់ត្រូវតាមដានគោរពដោយប្រជាជនស្រដៀងគ្នាទាំងអស់ និងត្រូវបានហៅថា ius gentium (ច្បាប់របស់មនុស្ស ឬពិភពលោក) ថាជាច្បាប់ដែលគោរពដោយមនុស្សជាតិទាំងមូល។ ដូចនេះ ប្រជាជនរ៉ូម៉ាំងគោរពច្បាប់ពិសេសផ្ទាល់ខ្លួនមួយភាគ និងច្បាប់រួមរបស់មនុស្សជាតិទាំងមូលមួយភាគ។«ស៊ីសេរ៉ុងបែងចែករវាងអ្វីដែលមានសរសេរ និងអ្វីដែលមិនមានសរសេរ ប៉ុន្តែបញ្ជាក់អះអាងដោយ ius gentium ឬ mos maiorum»ដែលជាទម្លាប់មានតាំងពីដូនតាមក។ នៅក្នុងសៀវភៅដែលមានចំណងជើងថា De officiis ស៊ីសេរ៉ុងចាត់ទុក ius gentium ថាជាច្បាប់កាតព្វកិច្ចមួយដែលខ្ពស់ជាងមនុស្សដែលមានសីលធម៌ដោយបង្ខំ ហួសពីការទាមទាររបស់ច្បាប់រដ្ឋប្បវេណី។ ឧទាហរណ៍ បុគ្គលម្នាក់ដែលរស់នៅនិរទេសខ្លួនបានបាត់បង់ឋានៈផ្លូវច្បាប់ថាជាពលរដ្ឋរ៉ូម៉ាំងហើយ ប៉ុន្តែត្រូវរក្សាការអភិរក្សជាមូលដ្ឋានដែលគេពង្រីកដល់មនុស្សគ្រប់រូបនៅក្រោមរបប ius gentium។

ដោយវិស័យច្បាប់ទាំងនេះកាន់តែស្មុគស្មាញ នៅពាក់កណ្តាលទីពីរនៃសតវត្សរ៍ទីបីមុន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រិស្តសករាជ ក្រុមអ្នកជំនាញវិជ្ជាជីវៈថ្មីមួយដែលបង្កើតឡើងតាមច្បាប់ រួមមានអ្នកច្បាប់ផង បានលេចឡើង ដើម្បីផ្តល់សណ្តាប់ធ្នាប់ទៅលើប្រព័ន្ធរូបមន្តគតិយុត្ត និងសេចក្តីសម្រេចនានា។ អ្នកច្បាប់បានផ្តោតទៅលើការបកស្រាយ និងការបង្កើតមតិយោបល់ផ្លូវការអំពីច្បាប់ ដូចដែលពួកមន្ត្រីមានសមណសក្តិធ្លាប់បានធ្វើតាំងពីដំបូង។ សំណេរវិទ្យាសាស្ត្រជាច្រើនជំនាន់របស់អ្នកច្បាប់ធំៗត្រូវបានរក្សាតាមច្បាប់រ៉ូម៉ាំងនៅសម័យរ៉ូម៉ាំងបុរាណ។

Justin ជាទាហានចំណាស់ម្នាក់កើតពីគ្រួសារកសិករមួយ និងបានឡើងកាន់កាប់រាជបល្ល័ង្កនៅឆ្នាំ៥១៨នៃគ្រិស្តសករាជ។ ក្មួយ និងកូនប្រុសចិញ្ចឹមរបស់គាត់គឺ Justinien ដែលបានទទួលការអប់រំល្អបំផុតតាមដែលអាចធ្វើទៅបាននៅកុងស្តង់ទីណូប។ Justinien បានឡើងសោយរាជ្យនៅឆ្នាំ៥២៧នៃគ្រិស្តសករាជ។ នៅក្រោមរជ្ជកាលរបស់អធិរាជ Justinien (៥២៧-៥៦៥តាមការសន្មត) ទឹកដីដ៏ធំៗរបស់អាណាចក្ររ៉ូម៉ាំងនៅអឺរ៉ុប អាហ្វ្រិចខាងជើង ខាងកើតត្រូវបានបែងចែកតាមនយោបាយ និងវប្បធម៌នៅក្នុងអាណាចក្របស្ចិម និងបូព៌ា ឬក្នុងអាណាចក្រប៊ីហ្សង់ស៍អស់ជាច្រើនសតវត្សរ៍។ Justinien បានបំបាត់ភាពប្រឈមដោយរក្សាបាននូវការត្រួតត្រា និងបង្កើតជាមនោសញ្ចេតនាឯកភាពគ្នាមួយ។

វិធីមួយនៃវិធីជាច្រើនដែល Justinien បានព្យាយាមប្រើប្រាស់ដើម្បីធ្វើឱ្យមានឯកភាពនៅក្នុងអាណាចក្រគឺការធ្វើតាមច្បាប់។ សញ្ជាតិរ៉ូម៉ាំងត្រូវបានពង្រីកដល់អាណាចក្រនៅក្រៅប្រទេសអ៊ីតាលីនៅសតវត្សរ៍ទី៣នៃគ្រិស្តសករាជ ដែលធ្វើឱ្យអ្នករស់នៅមានភាពឆ្ងាយពី«ពលរដ្ឋទីក្រុងរ៉ូម» និងនៅក្រោមលក្ខខណ្ឌនៃច្បាប់រដ្ឋប្បវេណី។

ព្រះអង្គបញ្ជាឱ្យអគ្គអ្នកច្បាប់ដកស្រង់ផ្នែកល្អបំផុត និងទទួលយកបានបំផុតចេញពីអត្ថបទរ៉ូម៉ាំងមុនៗ ដើម្បីធ្វើការចងក្រងជាកម្រង។ កម្រងនេះជួនកាលត្រូវបានគេហៅថា «ក្រមរបស់ Justinien» ប៉ុន្តែជាក់ស្តែង ក្រមគ្រាន់តែជាធាតុមួយប៉ុណ្ណោះ។ តាមពិត កម្រងរបស់ Justinien ផ្សំផ្គុំឡើងដោយធាតុបីខុសៗគ្នាគឺ សេចក្តីបំព្រួញ(Digesta) ក្រមក្បួន(Codex) សៀវភៅច្បាប់(Institutiones)។

សេចក្តីបំព្រួញ(ឆ្នាំ៥៣៣)បានប្រមូល និងសង្ខេបនូវរាល់ឯកសារសំណេររបស់អ្នកច្បាប់បុរាណអំពីច្បាប់ និងយុត្តិធម៌។ អត្ថបទដែលមានពីមុនមកប្រហែលត្រូវបានបំផ្លាញនៅក្នុងអាណាចក្រទាំងមូល ក្នុងគោលបំណងលុបបំបាត់កំហុសឆ្គងឱ្យអស់។

Justinien បញ្ជាឱ្យអ្នកច្បាប់របស់ទ្រង់រៀបចំសៀវភៅមួយក្បាលសម្រាប់និស្សិតច្បាប់ដែលគេហៅថាសៀវភៅច្បាប់ Justinien ដែលត្រូវបានបំពេញបន្ថែមនៅឆ្នាំ៥៣៣នៃគ្រិស្តសករាជ។ សៀវភៅច្បាប់គឺជាស្នាដៃតូចមួយដែលសង្ខេបខ្លីពីសេចក្តីបំព្រួញ។ សៀវភៅច្បាប់បានក្លាយទៅជាសៀវភៅច្បាប់ដែលត្រូវបានគេអានច្រើនជាងគេបំផុតជាងពេលណាៗទាំងអស់ ហើយមាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឥទ្ធិពលខ្លាំងក្លាណាស់។ នៅបច្ចុប្បន្ននេះ និស្សិតច្បាប់នៅក្នុងប្រទេសជាច្រើនត្រូវអានសៀវភៅច្បាប់នេះ។

ក្រម(ឆ្នាំ៥៣៤)បានបង្ហាញនូវអត្ថបទចុងក្រោយនៃរាល់ច្បាប់ចក្រពត្តិ ច្បាប់ពិតៗរបស់អាណាចក្រដោយរាប់ទាំងធម្មនុញ្ញចក្រពត្តិ នីតិកម្ម និងសេចក្តីប្រកាសនានា។

សៀវភៅទីបួន la Novella (Novelles) មិនស្ថិតនៅក្នុងគម្រោងរបស់ Justinien ទេ ប៉ុន្តែត្រូវបានបង្កើតឡើងដោយឡែកដោយអ្នកច្បាប់នៅឆ្នាំ៥៥៦ ដើម្បីធ្វើបច្ចុប្បន្នភាពក្រមក្បួនជាមួយនឹងច្បាប់ថ្មីៗដែលត្រូវបង្កើតឡើងក្រោយឆ្នាំ៥៣៤ និងដើម្បីសង្ខេបរដ្ឋធម្មនុញ្ញផ្ទាល់របស់ Justinien។

សេចក្តីបំព្រួញ សៀវភៅច្បាប់ និងក្រមក្បួនដែលជាទូទៅគេស្គាល់ថាជា Corpus Juris Civilis ជា«អង្គនៃនីតិ» ឬនៃច្បាប់របស់ Justinien បានក្លាយជាមូលដ្ឋានគ្រឹះនៃច្បាប់របស់ទ្វីបអឺរ៉ុប។

ច្បាប់រ៉ូម៉ាំងស្តីពី«វត្ថុ» («res») ស្តីពីទ្រព្យសកម្មសេដ្ឋកិច្ចនៅក្នុងច្បាប់ស្តីពីកម្មសិទ្ធិ(«វត្ថុ» នៅក្នុងន័យចង្អៀត) ត្រូវបានបំបែកជាច្បាប់ឧត្តពធិការ និងច្បាប់កាតព្វកិច្ច។ នៅពេលបច្ចុប្បន្ននេះ ការបំបែកច្បាប់នេះគឺជាធាតុសំខាន់នៃច្បាប់រដ្ឋប្បវេណីទំនើប។

នៅក្នុងយុគសម័យកណ្តាល(ពីសតវត្សរ៍ទី៥ដល់សតវត្សរ៍ទី១៥) តុលាការពាណិជ្ជកម្មត្រូវបានបង្កើតឡើងនៅក្នុងទ្វីបអឺរ៉ុបទាំងមូល ដើម្បីដោះស្រាយវិវាទនៅក្នុងពិព័រណ៍ផ្សេងៗ។ ការអនុវត្តជាពាណិជ្ជកម្មទាំងនេះបានបង្កើតជាមូលដ្ឋានសម្រាប់ច្បាប់ពាណិជ្ជកម្មអន្តរជាតិ។

ច្បាប់សមុទ្ររបស់ Rhodes (Lex Rhodia) ត្រូវបានដាក់ឱ្យប្រើប្រាស់នៅសតវត្សរ៍ទី៦ និងឈរលើច្បាប់សមុទ្រជាបវេណីដែលមានប្រភពចេញមកពី Rhodes នៅក្នុងបុរាណកាល។ ច្បាប់នេះបានដឹកនាំពាណិជ្ជកម្ម និងនាវាចរណ៍នៅក្នុងអាណាចក្របៃហ្សង់ស៍ពីដើមសតវត្សរ៍ទី៧ដល់សតវត្សរ៍ទី១២។ ដំណោះស្រាយផ្តោតទៅលើទំនួលខុសត្រូវនៃតម្លៃទំនិញដែលបាត់បង់ ឬខូចខាត។ ការបាត់បង់នាវាកណ្តាមានកម្រិតខ្ពស់នៅពេលមានព្យុះ នៅពេលដែលនាវាកណ្តាទាំងអស់ ឬមួយភាគត្រូវបោះទម្លាក់ចូលសមុទ្រដើម្បីសង្គ្រោះនាវា។ បរិមាណទំនិញដ៏ច្រើនក៏ត្រូវបាត់បង់ដោយការប្លន់ពីពួកចោរសមុទ្រដែរ។ ចាប់ពីសតវត្សរ៍ទី៧មក មានគ្រោះថ្នាក់កើនឡើងដោយការវាយប្រហារតាមសមុទ្រដោយចោរសមុទ្រអារ៉ាប់ និងស្លាវ។ ដូចនេះ ច្បាប់សមុទ្រត្រូវបានប្រើដូចជាទម្រង់ផ្តល់ជំនួយមួយ ដោយចែកតម្លៃដើមនៃការបាត់បង់រវាងនាវាវិចារី ម្ចាស់នាវាកណ្តា និងអ្នកធ្វើដំណើរ។

នៅយុគសម័យកណ្តាល មានសំណុំមួយនៃច្បាប់ស្តីពីការដឹកនាំអភិភាពយុទ្ធការី។ មិនមានរដ្ឋទេ ប៉ុន្តែមានក្រុមសហគមន៍ផ្សេងៗដែលដឹកនាំដោយអភិជនសក្តិភូមិ។ វាជារចនាសម្ព័ន្ធមជ្ឈការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលបានលេចឡើងបន្តិចម្តងៗនៅអឺរ៉ុបចន្លោះឆ្នាំ១១០០ និង១៣០០ ហើយទើបនឹងបានបំពេញចរិតលក្ខណៈផ្ទាល់នៃរដ្ឋទំនើបមួយក្រោយឆ្នាំ១២៥០ប៉ុណ្ណោះ។

យុគសម័យអាជីវកម្ម(ពីសតវត្សរ៍ទី១៥ដល់១៧)ត្រូវបានដឹកនាំដោយប្រទេសព័រទុយកាល់ និងអេស្ប៉ាញ។ ការបែងចែកឥទ្ធិពលគឺជាភាពចាំបាច់ ដើម្បីចៀសវាងជម្លោះរវាងពួកអេស្ប៉ាញ និងពួកព័រទុយកាល់។ កិច្ចព្រមព្រៀងមួយត្រូវបានរកឃើញនៅឆ្នាំ១៤៩៤ ជាមួយនឹងសន្ធិសញ្ញា Tordesillas ដែល«បែងចែក»ពិភពលោករវាងមហាអំណាចទាំងពីរ។ តាមរយៈសន្ធិសញ្ញានេះ ពួកព័រទុយកាល់«បានទទួល»ទឹកដីទាំងអស់នៅខាងក្រៅអឺរ៉ុបខាងកើត នៅខាងកើតខ្សែមួយដែលវត់ចម្ងាយ២៧០លីយើ(១លីយើ = ៤គ.ម) នៅខាងលិចកោះកាបវែរត៍(ជាកោះរបស់ព័រទុយកាល់រួចទៅហើយ) និងបណ្តាកោះដែលត្រូវបានរកឃើញដោយគ្រីស្តុហ្វ កូឡុំ នៅក្នុងការធ្វើដំណើរទីមួយរបស់គាត់(ដែលត្រូវបានទាមទារសម្រាប់អេស្ប៉ាញ)ដែលហៅថាជាសន្ធិសញ្ញា Cipangu និង Antilia (គុយបា និងហ៊ីស្ប៉ាញ៉ូឡា)ដែលនេះផ្តល់ដល់ពួកគេនូវការត្រួតត្រាទៅលើអាព្រិចអាស៊ី និងភាគខាងកើតនៃអាមេរិកខាងត្បូង(ប្រេស៊ីល)។ ប្រទេសអេស្ប៉ាញបានទទួលទឹកដីទាំងអស់នៅខាងលិចខ្សែបន្ទាត់នេះដែលជាទឹកដីដែលគេនៅសឹងតែមិនស្គាល់សោះនៅឡើយ ហើយជាចម្បងហាក់លេចចេញដូចជាភាគខាងលិចនៃទ្វីបអាមេរិក ព្រមទាំងបណ្តាកោះនៃមហាសមុទ្រប៉ាស៊ីភិច។ នេះគឺជាដើមដំបូងនៃច្បាប់ស្តីពីការកំណត់ព្រំដែនសមុទ្រ។

រដ្ឋដំបូងៗនៃប្រទេសអង់គ្លេស បារាំង និងអេស្ប៉ាញបានកើតឡើងនៅសតវត្សរ៍ទី១៥។ សហគមន៍ផ្សេងៗគ្នានៅអឺរ៉ុប និងនៅទឹកន្លែងដទៃទៀតត្រូវបានពង្រឹងជាបណ្តើរៗ និង«បានចូលប្រឡាក់ប្រឡូក»នៅក្នុងរដ្ឋ។ ទំនាក់ទំនងខ្ពស់មួយកម្រិតទៀតរវាងរដ្ឋអធិបតេយ្យបាននាំឱ្យមានការបង្កើតសហគមន៍អន្តរជាតិមួយនៃរដ្ឋអធិបតេយ្យ។

សតវត្សរ៍ទី១៦ត្រូវបានកត់សម្គាល់ជាខ្លាំងដោយការអភិវឌ្ឍជាថ្មីនៃច្បាប់អន្តរជាតិ។ សន្ទុះកើនឡើងនៃរដ្ឋទំនើបជាបច្ច័យនាំឱ្យមានការតាក់តែងលទ្ធិអធិបតេយ្យភាព។ នៅក្នុងសៀវភៅសាធារណរដ្ឋទាំងប្រាំមួយក្បាល(១៥៧៦) ហ្សង់ បូដាំង(Jean Bodin)បានច្រានចោលទស្សនៈលេចធ្លោដែលថា រាជាណាចក្រអឺរ៉ុបជាច្រើនគឺជាដែនឥទ្ធិពលរបស់ទីក្រុងវ៉ាទីកង់ ហើយដែលថា អំណាចចិត្តព្រលឹង(ជំនឿសាសនា)របស់ព្រះវិហារធំជាងអំណាចគ្រហស្ថរបស់រដ្ឋ។ តាមទ្រឹស្តីអធិបតេយ្យភាពរបស់បូដាំង មហាក្សត្រគឺស្ថិតនៅក្រោមច្បាប់អាទិទេព និងធម្មជាតិ ប៉ុន្តែនេះជាបញ្ហារបស់ព្រះអាទិទេព និងជាសតិសម្បជញ្ញៈរបស់មហាក្សត្រក្នុងការបកស្រាយ និងអនុវត្តច្បាប់អាទិទេព និងធម្មជាតិ។ បូដាំងបានទទូចដើម្បីកុំឱ្យមហាក្សត្រស្វែងរកឃើញច្បាប់ ប៉ុន្តែឱ្យធ្វើច្បាប់ និងឱ្យច្បាប់ទៅមនុស្ស។

ទស្សនវិទូជាតិអេស្ប៉ាញ ហ្វ្រង់ស៊ីស្កូ ដឺ វិចតូរីយ៉ា(១៤៨០-១៥៤៦)បានឱ្យតម្លៃថា ប្រជាជន

ឥណ្ឌាស្បែកក្រហម(នៅអាមេរិកឡាទីន)ត្រូវចាត់ទុកថាដូចជាជាតិ ហើយតាមច្បាប់អន្តរជាតិដែលមានមូលដ្ឋានលើច្បាប់ធម្មជាតិសាកល ត្រូវតែបញ្ចូលជនមិនមែនអឺរ៉ុបនៅក្នុងដែនអនុវត្តរបស់គាត់។

Francisco Suárez(១៥៤៨-១៦១៧)បានធ្វើឱ្យកត់សម្គាល់ថា លក្ខណៈចាប់បង្ខំនៃច្បាប់អន្តរជាតិគឺឈរនៅលើច្បាប់ធម្មជាតិ ដូចជាវិធាននៃសមិទ្ធកម្មកិច្ចព្រមព្រៀងដែរ។

នៅឆ្នាំ១៥៩៨ Alberico Gentili(១៥៥២-១៦០៨)បានបោះពុម្ពផ្សាយសៀវភៅមួយក្បាលមានចំណងជើងថា De Jure Belli ដែលបានពិនិត្យមើលច្បាប់សង្គ្រាម និងច្បាប់សន្ធិសញ្ញា។

## ១.២- សន្តិភាពWestphalie

នៅសតវត្សរ៍ទី១៧ បេះដូងអចិន្ត្រៃយ៍របស់រដ្ឋគឺការិយាធិបតេយ្យ ទោះជាយ៉ាងណាក៏ដោយ ដូចដែលJellinekបានកត់សម្គាល់អ៊ីចឹង គេត្រូវរង់ចាំការអនុម័តនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៧៩១ នូវក្រឹត្យបាពាំងដែលបង្កើតក្រសួងផ្សេងៗ ដើម្បី«គោលការណ៍នៃការបែងចែកការងារដើម្បីឱ្យការងារនេះត្រូវសម្រេចបានទាំងស្រុងដោយរដ្ឋបាលសាធារណៈ និងសម្រាប់រដ្ឋមន្ត្រីនៅក្នុងន័យច្បាប់រដ្ឋបាល។

មុនសន្តិភាពWestphalie(១៦៤៨) មានប៉ូលអំណាចពីរ ៖ សម្តេចប៉ាបដែលដឹកនាំព្រះវិហារកាតូលិក និងអធិរាជដែលដឹកនាំសន្តអាណាចក្ររ៉ូម៉ាំងអាល្លឺម៉ង់។ សង្គ្រាមសាមសិបឆ្នាំបានផ្ទុះឡើងនៅឆ្នាំ១៦១៨ ព្រោះតែហេតុផលសាសនារវាងប្រទេសកាតូលិក និងប្រូតេស្តង់។ សន្ធិសញ្ញាWestphalieនៅឆ្នាំ១៦៤៨[៤] បានបញ្ចប់សង្គ្រាម។ សន្ធិសញ្ញាដែលត្រូវបានទទួលស្គាល់ និងធ្វើ ឱ្យមានធម្មានុរូបតាមលទ្ធិប្រូតេស្តង់និយម បានទទួលស្គាល់អត្តិភាពរបស់រដ្ឋ ដោយឈរលើទ្រឹស្តីកាល់វិនិស្តនិយម និងទ្រឹស្តីលូតឺ (Luther) មានន័យថា រដ្ឋត្រូវបានទទួលស្គាល់ថាឯករាជ្យពីព្រះវិហារ។

ពីការបែកជាផ្នែកតូចៗនៃសន្តអាណាចក្ររ៉ូម៉ាំងអាល្លឺម៉ង់ និងការបាត់បង់អំណាចរបស់ព្រះវិហារកាតូលិកនៅសម័យបុនវុឌ្ឍិទៅដល់ប្រព័ន្ធសម្របសម្រួលមួយរវាងរដ្ឋអធិបតេយ្យឯករាជ្យដែលមានលក្ខណៈជាការដាក់រដ្ឋទាំងនេះនៅបន្តបន្ទាប់គ្នា ក្នុងនាមជាមហាក្សត្រដែលស្មើភាពគ្នា ពោលគឺសារតានៃរដ្ឋអធិបតេយ្យដែលយើងស្គាល់នៅសព្វថ្ងៃនេះ។ នេះបាននាំឱ្យមានជាស្ថាប័ននៃអធិបតេយ្យ និងសមភាពអធិបតេយ្យ។ Luis ១៤ បាននិយាយថា ៖ «រដ្ឋគឺខ្ញុំ»។

អាណាចក្ររ៉ូម៉ាំង ឬអាណាចក្រខ្មែរមិនអាចចាត់ទុកថា ជារដ្ឋបានទេ។ រដ្ឋទំនើបខុសពី «អាណាចក្រដ៏ធំ»ទាំងពីរនៃអតីតកាល ហើយ«ទីក្រុងជារដ្ឋ»ដ៏តូច និងយ៉ាងមានសនិទ្ធិពលក្រិច

[៤] ចុះហត្ថលេខារវាងប្រទេសស៊ុយអែត និងសន្តអាណាចក្ររ៉ូម៉ាំងអាល្លឺម៉ង់។ វាជាសញ្ញានៃការចាប់ផ្តើមសករាជនៃទំនាក់ទំនងអន្តរជាតិទំនើប និងច្បាប់អន្តរជាតិទំនើប។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានដូចខាងក្រោម[៥] ៖

• ការលេចឡើងនៃអង្គភាពនយោបាយ

• ការអភិវឌ្ឍស្ថាប័នអចិន្ត្រៃយ៍ដែលមិនផ្តោតលើបុគ្គល

• អាជ្ញាធរមួយដែលអាចផ្តល់ការវិនិច្ឆ័យស្ថាពរ និងការទទួលស្គាល់គំនិតដែលថា អាជ្ញាធរនេះត្រូវតែទទួលបាននូវភក្តីភាពជាមូលដ្ឋានរបស់ប្រជាជនខ្លួន

• ការទទួលបានដោយរដ្ឋនូវអំណាចខាងផ្លូវចិត្ត ដើម្បីរក្សារចនាសម្ព័ន្ធស្ថាប័ន និងឧត្តមានុភាពគតិយុត្តរបស់រដ្ឋ។

• ការលេចឡើងនូវការិយាធិបតេយ្យមជ្ឈការដែលបំលែងខ្លួនបន្តិចម្តងៗនៅក្នុងនាយកដ្ឋានរបស់ក្រសួង។

នៅសតវត្សរ៍ទី១៧ អ្នកច្បាប់ជាតិហូឡង់ *Hugo Grotius* បានឱ្យតម្លៃថា ច្បាប់ប្រទេសក៏បានបង្កើតវិធានគតិយុត្តសម្រាប់រដ្ឋអធិតេយ្យនៅអឺរ៉ុប ហើយដែលទើបតែនឹងចេញពីសង្គមយុគសម័យកណ្តាលនៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយអ្នកដទៃ។ សៀវភៅបុរាណឆ្នាំ១៦២៥ របស់ Grotius ច្បាប់សង្គ្រាម និងសន្តិភាព(*De Jure Belli ac Pacis*)ត្រូវបានទទួលស្គាល់យ៉ាងជំទូលាយថា ជាមូលដ្ឋាននៃច្បាប់ទំនើបរបស់ជាតិ។[៦] វាបានពន្យល់ថា គ្មានរដ្ឋអធិបតេយ្យណាមួយខ្លាំង ដើម្បីមិនត្រូវការផលប្រយោជន៍ច្បាប់ដែលឈរលើច្បាប់ធម្មជាតិ និងការយល់ព្រមជាវិជ្ជមានឡើយ។[៧]

*Emer de Vattel* (១៧១៤-១៧៦៧) មេធាវីជាតិស្វីស បានបង្ហាញនៅក្នុងសៀវភៅច្បាប់របស់មនុស្សរបស់គាត់អំពីលទ្ធិសមភាពរបស់រដ្ឋ នៅក្នុងច្បាប់អន្តរជាតិ។

## ១.៣- អាណានិគមនិយម

បដិវត្តន៍ឧស្សាហកម្មដែលបានកើតឡើងនៅអឺរ៉ុបនៅចុងសតវត្សរ៍ទី១៨ បានបង្កើតគម្លាតរវាងអឺរ៉ុប និងរដ្ឋមិនមែនអឺរ៉ុប។ ប្រទេសអឺរ៉ុបបានប្រើប្រាស់អាណានិគមនិយម ដើម្បីផ្គត់ផ្គង់វត្ថុធាតុដើម និងការលក់ផលិតផលដែលបានមកពីការផលិត។

ពួកអឺរ៉ុបបានដាក់អាណានិគមលើដែនដីអាមេរិកនៅសតវត្សរ៍ទី១៥។ ចាប់តាំងពីមានសញ្ញាដំបូងៗនៃការបះបោរច្បាស់ក្រឡែតនៅអាមេរិក អាស៊ីបានក្លាយទៅជាតំបន់មួយដែលគេចង់បាន។ នៅសតវត្សរ៍ទី១៨ ដំបូង ប្រទេសបារាំង និងបន្ទាប់មកប្រទេសអង់គ្លេសបានប៉ះពាល់ទៅលើប្រទេសឥណ្ឌាមួយភាគធំរហូតទាល់តែនៅឆ្នាំ១៧៧២ ទឹកដីភាគច្រើនរបស់ឥណ្ឌាបានក្លាយទៅ

---

[៥] *J. R. Strayer,* on the Mediaval Origins of the Modern State *(Princeton, N.J. : Princeton University Press, 1979) pp. 9-10.*

[៦] *JANIS (M.) and NOYES (J.),* International Law: Cases and commentary, *St. Paul, Thomson West, 2006, p.1.*

[៧] *ibid., p.35.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាអាណានិគមអង់គ្លេស។ នៅដើមសតវត្សរ៍ទី១៩ នៅពេលដែលការបះបោរតស៊ូបានជោគជ័យ ជ័យរបស់អាមេរិក ត្រូវបន្តដោយឯករាជ្យនៃអាមេរិកខាងត្បូង ពួកអឺរ៉ុបបានបែរទៅអាហ្វ្រិច ក្នុងពេលដែលនៅក្នុងពេលដំណាលគ្នានោះ មានការពង្រីងផលប្រយោជន៍របស់ពួកគេនៅអាស៊ី។ នៅសតវត្សរ៍ទី១៩ រដ្ឋមិនមែនអឺរ៉ុបត្រូវបានគេទុកចោលយ៉ាងឆ្ងាយ និងត្រូវបានដណ្ដើមយកបន្តិចម្ដងដោយរដ្ឋអឺរ៉ុប។

ទំនាក់ទំនងរបស់ប្រទេសទាំងពីរបានឈរលើកិច្ចព្រមព្រៀងចុះចាញ់ដែលសម្គាល់ដោយភាពនៅក្រៅដែនដី។ របបចុះចាញ់ត្រូវបានពង្រីងនៅក្នុងសតវត្សរ៍ទី១៧ និង១៨ ៖ សន្ធិសញ្ញាឆ្នាំ១៧៤០ រវាងបារាំង និងអាណាចក្រតួគី។ សន្ធិសញ្ញានេះចាប់បង្ខំឱ្យមានលក្ខខណ្ឌសម្រាប់និវេសនដ្ឋានរបស់ពួកអឺរ៉ុប(រួមទាំងអាណិកជនអាមេរិក)នៅលើទឹកដីនៃប្រទេសមិនមែនអឺរ៉ុប ៖

• ជនជាតិអឺរ៉ុបដែលជាអាណិកជនមួយផ្នែកទៅនឹងកិច្ចព្រមព្រៀងមិនអាចត្រូវបណ្ដេញចេញពីប្រទេសដោយគ្មានការយល់ព្រមពីកុលស៊ុលរបស់ពួកគេទេ។

• ពួកគេមានសិទ្ធិអនុវត្តសាសនាជាសាធារណៈតាមជំនឿគ្រីស្ដសាសនារបស់ពួកគេ។

• ពួកគេមានសេរីភាពធ្វើពាណិជ្ជកម្ម និងត្រូវបានរួចពីពន្ធនាំចូល និងនាំចេញមួយចំនួន។

• ការសងសឹកប្រឆាំងនឹងពួកគេត្រូវហាមឃាត់ ជាពិសេសនៅក្នុងករណីអសាធនភាព។

• សមត្ថកិច្ចដោះស្រាយវិវាទរវាងពួកអឺរ៉ុបគឺជាកុងស៊ុលរបស់ចុងចម្លើយ ឬរបស់ជនរងគ្រោះនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ(ហើយដូច្នេះ មិនមែនជាសមត្ថកិច្ចរបស់តុលាការដែនដីទេ) ចំណែកឯនៅក្នុងវិវាទរវាងជនជាតិអឺរ៉ុបម្នាក់ និងអាណិកជនម្នាក់របស់រដ្ឋដែនដី សមត្ថកិច្ចគឺប្រគល់ជូនចៅក្រមនៃរដ្ឋខាងក្រោយនេះ។

របបគតិយុត្តនេះមានចរិតលក្ខណៈបីគឺ ទីមួយ សិទ្ធិរបស់ជនជាតិអឺរ៉ុបអំពីភាពនៅក្រៅដែនដី។ ទីពីរ របបនេះមិនមែនផ្អែកលើមូលដ្ឋាននៃបដិការទេ។ ទីបី យ៉ាងហោចណាស់នៅសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩ រដ្ឋមិនមែនអឺរ៉ុបខ្វះមិនចាត់ទុកថា ការចុះចាញ់ជាការខូចប្រយោជន៍ដល់អធិបតេយ្យភាពរបស់ពួកគេទេ។

នីតិអន្តរជាតិបានដើរតួជាឧបករណ៍ច្បាំងដណ្ដើមយកទឹកដី។ នីតិអន្តរជាតិបានអនុញ្ញាតឱ្យរដ្ឋទទួលបានអធិបតេយ្យភាពលើដែនដីទាំងនេះ ទាំងដោយបញ្ចុះឋានៈដែនដីខាងក្រោយនេះថា ជាដែនដីគ្មានម្ចាស់ ពោលគឺដែនដីដែលមិនមែនជាកម្មសិទ្ធិរបស់បុគ្គលណាម្នាក់ និងទាំងដោយដកហូតកិត្តិនាមជាអន្តរជាតិពីសហគមន៍ក្នុងស្រុក ឬពីអ្នកដឹកនាំ។ ការកាន់កាប់ជាក់ស្ដែង និងការត្រួតត្រាតាមព្រឹត្តន័យនៅលើដែនដីមួយ(អមដោយចេតនាយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន) គឺគ្រប់គ្រាន់ហើយដើម្បីទទួលបានសិទ្ធិអធិបតេយ្យ។ លើសពីនេះទៀត ប្រសិនបើមេដឹកនាំក្នុងស្រុកប្រឆាំងនឹងការវាយដណ្ដើមរបស់អាណានិគម នីតិអន្តរជាតិបានផ្ដល់ឧបករណ៍


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីរ គឺសង្គ្រាម និងការចុះសន្ធិសញ្ញា។

នៅអឺរ៉ុប សង្គ្រាមបាននាំឱ្យមានការវិវត្តដល់នីតិអន្តរជាតិផង។ ប្រព័ន្ធសន្តិសុខរួមមួយត្រូវបានបង្កើត ដើម្បីកំហិតអំណាចនៅឆ្នាំ១៨១៥ បន្ទាប់ពីការចុះចាញ់របស់ណាប៉ូលេអុង ៖

• សេចក្តីប្រកាសជាគោលការណ៍

• សម្ព័ន្ធមិត្តយោធាដែលជាប្រព័ន្ធសន្តិសុខរួមមួយផ្អែកលើកិច្ចព្រមព្រៀងរបស់មហាអំណាចធំៗដែលមានគោលដៅបង្ការនិងបង្ក្រាបការវិលត្រលប់មកវិញនៃរបបបូណាប៉ាតនិយម មិនថានៅប្រទេសបារាំង ឬនៅទីដទៃទេ និង

• នីតិវិធីថ្មីមួយសម្រាប់ដោះស្រាយបញ្ហានយោបាយដែលប្រមូលផ្តុំជាការប្រជុំរបស់រាល់អធិបតីដែលពាក់ព័ន្ធដែលនៅក្នុងនោះ ពួកគេអាចពិភាក្សាពី«ឧត្តមប្រយោជន៍រួម» វិស័យការទូតពហុភាគីដែលផ្អែកទៅលើការប្រជុំកំពូលទៀងទាត់។

## ១.៤- នីតិអន្តរជាតិជាឧបករណ៍របស់រដ្ឋ

នៅឆ្នាំ១៧៨០ ទស្សនវិទូជាតិអង់គ្លេស Jeremy Bentham បានវិភាគច្បាប់របស់មនុស្សថាជា«ច្បាប់អន្តរជាតិ»។ ច្បាប់មានចរិតលក្ខណៈសំខាន់ពីរ ៖

• វិធាន និងគោលការណ៍អន្តរជាតិគឺជាផលិតផលនៃអរិយធម៌បស្ចិមប្រទេស និងរក្សាស្មាគស្មាមអឺរ៉ុបមជ្ឈមណ្ឌលនិយម មនោគមវិជ្ជាគ្រិស្តសាសនា និងស្មាគស្មាមនៃទស្សនវិស័យ«ទីផ្សារសេរី»មួយ។

• ធម្មនិយាម និងគោលការណ៍អន្តរជាតិត្រូវបានតាក់តែងជាចម្បងដោយមហាអំណាចធំៗ ឬរដ្ឋទំហំមធ្យមដែលបានវាយដណ្តើម ឬពង្រីកទឹកដីខ្លួន ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់របស់ពួកគេ។

o ការប្រើប្រាស់កម្លាំង៖គ្មានការទប់ទៅលើការគំរាមកំហែងឬការប្រើប្រាស់ហិង្សានៃសង្គ្រាមទេ។

o អំពីការការពារអាណិកជនតាមការទូត និងតាមផ្លូវតុលាការនៅបរទេស ៖ រៀងរាល់ពេលដែលពលរដ្ឋម្នាក់នៃរដ្ឋណាមួយអះអាងបញ្ជាក់ថា រដ្ឋាភិបាលបរទេសមួយបានប្រព្រឹត្តខុសច្បាប់ចំពោះខ្លួន ពលរដ្ឋនោះអាចស្នើសុំឱ្យរដ្ឋាភិបាលជាតិខ្លួនអន្តរាគម និងស្នើសុំសំណងជួសជុលសម្រាប់ទង្វើខុសច្បាប់ដែលលើកឡើងជាអន្តរជាតិ។

វិទ្យាស្ថាននីតិអន្តរជាតិគឺជាសមាគមមួយនៃសាស្ត្រាចារ្យចំណានៗដែលបង្កើតឡើងដោយក្រុមអ្នកជំនាញអឺរ៉ុប និងអាមេរិក ក្នុងឆ្នាំ១៨៧៣ នៅហ្គង់ដ៍(ប្រទេសបែលហ្ស៊ិក) ដើម្បីតាក់តែងវិធានទំនៀមទម្លាប់អន្តរជាតិ និងសន្ធិសញ្ញាអន្តរជាតិសំខាន់ៗ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទស្សនវិទូជាតិអាល្លឺម៉ង់ឈ្មោះHegelបានបញ្ចូលលទ្ធិនៃឆន្ទៈរបស់រដ្ឋ។ បុគ្គលគឺចំណុះឱ្យរដ្ឋ ពីព្រោះរដ្ឋតំណាង«ឆន្ទៈ»របស់ពលរដ្ឋគ្រប់រូប និងបានវិវត្តទៅរកឆន្ទៈខ្ពស់មួយ ហើយនៅលើឆាកអន្តរជាតិរបស់រដ្ឋ រដ្ឋមានអធិបតេយ្យ និងនៅខ្ពស់ជាងគេ។

ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏ធ្លាប់មានការប្រឹងប្រែងដើម្បីកំហិតការគ្របសង្កត់របស់មហាអំណាចដែរ។

• ខសំខាន់កាល់វ៉ូ (Calvo) ៖ អ្នកច្បាប់ជាតិអាហ្សង់ទីន C. Calvo (១៨២៤-១៩០៦) បានជជែកតវ៉ាដើម្បីឱ្យមានខសំខាន់មួយដែលចែងថា ក្នុងករណីមានជម្លោះដែលកើតចេញពីកិច្ចសន្យា ជនបរទេសអាចបោះបង់សិទ្ធិស្នើសុំការការពារតាមផ្លូវទូត និងតុលាការរបស់រដ្ឋដើមរបស់ខ្លួន និងអាចឯកភាពឱ្យជម្លោះត្រូវដោះស្រាយដោយតុលាការក្នុងស្រុកបាន។ ខសំខាន់Calvoបានព្យាយាមដាក់កំហិតអន្តរាគមន៍គតិយុត្ត និងនយោបាយរបស់បស្ចិមប្រទេសដែលជាញឹកញយបង្កើតទៅជាលេសដោះខ្លួន ឬឱកាសនៃប្រតិបត្តិការក្រៅប្រទេសដោយប្រដាប់អាវុធ សម្ពាធនយោបាយខ្លាំងក្លា ឬការជ្រៀតជ្រែកក្រោមរូបភាពផ្សេងៗ។

• លទ្ធិ Drago នៅដើមសតវត្សរ៍ទី២០ ៖ រដ្ឋមន្ត្រីការបរទេសប្រទេសអាហ្សង់ទីនឈ្មោះ Luis Maria Drago (១៨៥៩-១៩២១) បានផ្តល់ហេតុផលថា ប្រទេសមហាអំណាចមិនត្រូវប្រើប្រាស់កម្លាំងយោធា ដើម្បីស្នើសុំសំណងបំណុលពីប្រទេសក្រីក្រទេ។

## ២- សង្គ្រាមលោក និងនីតិអន្តរជាតិ

សង្គ្រាមលោកបានជះឥទ្ធិពលយ៉ាងធំសម្បើមទៅលើប្រព័ន្ធសន្តិសុខរួមរបស់រដ្ឋ។

## ២.១- សង្គមប្រជាជាតិ

ក្រោយសង្គ្រាមលោកលើកទី១ អឺរ៉ុបលែងដើរតួនាទីសំខាន់នៅក្នុងសហគមន៍ពិភពលោកទៀតហើយ។ កត្តាសំខាន់ៗគឺការឡើងខ្លាំងរបស់សហរដ្ឋអាមេរិក និងការលេចឡើងនូវសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតនៅឆ្នាំ១៩១៧។ សហភាពសូវៀតនេះបានអួតលើកឡើងនូវគោលការណ៍ដូចខាងក្រោម ៖

• ស្វ័យសម្រេចរបស់ប្រជាជន

• សមភាពពិតប្រាកដរបស់រដ្ឋ( ខុសពីសមភាពគតិយុត្តរបស់ពួកគេ)

• អន្តរជាតិនិយមបែបសង្គមនិយម

• ការច្រានចោលផ្នែកខ្លះៗនៃនីតិអន្តរជាតិ។

ក្រោយសង្គ្រាមលោកលើកទី១ អ្នកឈ្នះបានសម្រេចបង្កើតស្ថាប័នអន្តរជាតិមួយដែលមាន

គោលដៅបង្ការមិនឱ្យមានការវិលត្រលប់មកវិញនូវជម្លោះប្រដាប់អាវុធនៅលើពិភពលោកទាំងមូល។ សង្គមប្រជាជាតិ( Société des Nations ឬ League of Nations)ត្រូវបានបង្កើត។ ប្រព័ន្ធដែលបានបង្កើតឡើងនៅឆ្នាំ១៩១៩ ស្រដៀងខ្លាំងទៅនឹងប្រព័ន្ធដែលបានបង្កើតឡើងនៅឆ្នាំ១៦៤៨ ក្រោមទម្រង់ជាការដោះស្រាយជម្លោះនៅWestphalie។ ការប្រើប្រាស់កម្លាំងមិនត្រូវបានហាម-ឃាត់ទេ លើកលែងតែករណីមួយចំនួនតូចចេញ។ មានរយៈពេលកំណត់ដើម្បីពិចារណាបីខែមុននឹងទៅដល់ការធ្វើសង្គ្រាម។ ប្រសិនបើជម្លោះត្រូវដាក់ជូនក្រុមប្រឹក្សាសម្ព័ន្ធ ឬតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍( CPJI) ឬតុលាការមជ្ឈត្តការមួយ សង្គ្រាមអាចធ្វើបានតែក្នុងរយៈពេលបីខែ បន្ទាប់ពីសេចក្តីសម្រេចមជ្ឈត្តការ ឬតុលាការ ឬការចេញរបាយការណ៍របស់ក្រុមប្រឹក្សាប៉ុណ្ណោះ។

ប្រព័ន្ធសង្គមប្រជាជាតិមានគុណវិបត្តិធំៗ។ សង្គ្រាមមិនត្រូវបានហាមឃាត់ឡើយ និងគ្រាន់តែត្រូវបានដាក់កំហិតជារយៈពេលសម្រាប់ការពិចារណាប៉ុណ្ណោះ។ គ្មានប្រព័ន្ធរួមណាមួយដែលត្រូវបានបង្កើត ដើម្បីធ្វើឱ្យរដ្ឋមួយដែលបានរំលោភបំពានលើការហាមប្រាមជានីតិវិធីរបស់កតិកាគោរពច្បាប់ឡើយ។ សម្ព័ន្ធប្រជាជាតិរួម ឬក្រុមប្រឹក្សាគ្មានអំណាចបញ្ជូនកងទ័ពប្រឆាំងនឹងអ្នកឈ្លានពានទេ ពួកគេអាចផ្តល់អនុសាសន៍ជាការប្រើប្រាស់កម្លាំងសម្រាប់រដ្ឋជាសមាជិកបាន។ កតិកានេះគ្រាន់តែបានគ្រោងទុកនូវសកម្មភាពស្ម័គ្រចិត្តរួមពីសំណាក់បណ្តារដ្ឋ។ គ្មានបទប្បញ្ញត្តិណាមួយជានីតិវិធីដែលត្រូវបានធ្វើស្ថាប័នកម្មឡើយ និងមិនមានភាពផ្តាច់មុខនៃកម្លាំងដែលត្រូវផ្តល់ទៅឱ្យអង្គការរបស់សម្ព័ន្ធទេ។ បញ្ញត្តិនៃកតិកានៅតែជាច្បាប់សន្ធិសញ្ញា ដោយហេតុនេះវាមិនចាប់ចងរដ្ឋដែលនៅក្រៅសម្ព័ន្ធទេ( សហរដ្ឋអាមេរិច ព្រមទាំងប្រទេសអឺរ៉ុប និងអាស៊ីមួយចំនួនរួមទាំងប្រទេសអាល្លឺម៉ង់ សហភាពសូវៀត និងជប៉ុនផងដែរ)។ សម្ព័ន្ធបានក្លាយបន្តិចម្តងៗទៅជាឧបករណ៍នយោបាយរបស់ប្រទេសអង់គ្លេស និងបារាំងតែមួយមុខគត់។

សហរដ្ឋអាមេរិក និងបារាំងបានប្រឹងប្រែងដោះស្រាយកង្វះខាតច្បាស់ក្រឡែតនានារបស់សម្ព័ន្ធនេះ តាមរយៈការលើកតម្កើងកតិកាក្រុងប៉ារីសចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩២៨ ស្តីពីការហាមឃាត់សង្គ្រាម។ ទោះជាយ៉ាងនេះក្តី កតិកានេះមិនមានវឌ្ឍនកិច្ចច្រើនទេ ថ្វីបើជាលើកទី១ដែលសង្គ្រាមត្រូវបានហាមឃាត់( ទោះបីជាសព្វថ្ងៃការហាមឃាត់មានភាពដាច់ខាតក្តី) ហើយជាងនេះទៅទៀត គ្មានបញ្ញត្តិណាមួយសម្រាប់ជាយន្តការអនុវត្តទេ។ គុណូបការគួរឱ្យកត់សម្គាល់នៃកតិកានេះគឺថាកតិកានេះបានប្រកាសការហាមឃាត់សង្គ្រាមជាទូទៅ ហើយវាមានលក្ខណៈចាប់បង្ខំផងដែរចំពោះរដ្ឋដែលមិនមែនជាភាគីនៃកតិកា ដូចជាសហរដ្ឋអាមេរិកជាដើម។

ទោះជាយ៉ាងណាក្តី ដំណោះស្រាយជម្លោះដោយមជ្ឈត្តការ និងតាមផ្លូវតុលាការបានស្តែងចេញជាការរីកចម្រើន។ តុលាការយុត្តិធម៌អន្តរជាតិដែលបានបង្កើតឡើងនៅឆ្នាំ១៩២១ បាន

ប្រកាសសាលក្រមចំនួន៣២ និងយោបល់ពិគ្រោះចំនួន២៧។ រដ្ឋអឺរ៉ុបភាគច្រើនជឿមុតមាំថា មជ្ឈត្តការជាមធ្យោបាយល្អជាងគេដើម្បីដោះស្រាយជម្លោះ និងបង្ការការបំផ្ទុះសង្គ្រាម។

## ២.២- ការបង្កើតអង្គការសហប្រជាជាតិ

ក្រោយសង្គ្រាមលោកលើកទីពីរ សន្តិភាពបានក្លាយទៅជាគោលដៅសំខាន់បំផុតរបស់សហគមន៍អន្តរជាតិ។ ធម្មនុញ្ញសហប្រជាជាតិត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែមិថុនា និងបានចូលជាធរមាននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥។ អង្គការសហប្រជាជាតិ(ONU)ត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់គ្រោះថ្នាក់នៃសង្គ្រាម និងលើកតម្កើងដំណោះស្រាយដោយសន្តិវិធីនៃពល់ជម្លោះសំខាន់ៗរវាងរដ្ឋ និងរដ្ឋ។

ធម្មនុញ្ញហាមឃាត់ការប្រើប្រាស់ ឬការគំរាមប្រើប្រាស់កម្លាំង(មាត្រា២.៤) ហើយក្នុងពេលដំណាលគ្នា ក៏ផ្តល់អំណាចដល់ក្រុមប្រឹក្សាសន្តិសុខដើម្បីដាក់ទណ្ឌកម្ម និងចាត់វិធានការណ៍ដែលរួមមានការប្រើប្រាស់កម្លាំងប្រឆាំងនឹងរដ្ឋមួយដែលរំលោភលើការហាមឃាត់នេះ។

ប្រព័ន្ធសន្តិសុខរួមបង្កើតឡើងនៅឆ្នាំ១៩៤៥ មានភាពស្រដៀងគ្នាខ្លាំងទៅនឹងសាមគ្គីភាពអឺរ៉ុបចុះឆ្នាំ១៨១៥។ ដូចនៅក្នុងសកវាជក្រោយរបបណាប៉ូលេអុងដែរ នៅឆ្នាំ១៩៤៥ មហាអំណាចធំៗបានវិនិច្ឆ័យថា ជាការចាំបាច់ដែលត្រូវត្រួតត្រាលើកិច្ចការអន្តរជាតិ និងធ្វើសេចក្តីសម្រេចអំពីសកម្មភាពរួមមួយដែលត្រូវធ្វើ ក្នុងករណីមានការគំរាមកំហែងធ្ងន់ធ្ងរ ឬមានបទល្មើសចំពោះសន្តិភាព។ មហាអំណាចទាំងនេះបានបង្កើតក្រុមសមាជិកអចិន្ត្រៃយ៍មួយនៃក្រុមប្រឹក្សាសន្តិសុខ។ មាត្រា២៧.៣នៃធម្មនុញ្ញសហប្រជាជាតិចែងថា ក្រុមប្រឹក្សាសន្តិសុខមិនអាចអនុម័តសេចក្តីសម្រេចលើបញ្ហាអង្គហេតុនានាបានឡើយ ប្រសិនបើគ្មានការយល់ព្រមពីសមាជិកអចិន្ត្រៃយ៍ទាំងប្រាំ។ ជាមួយនឹងការបោះឆ្នោតយល់ស្របពីមហាអំណាចទាំងប្រាំ ប្រសិនក្រុមប្រឹក្សាសន្តិសុខឯកភាពថាមានការគំរាមកំហែងដល់សន្តិភាព មានការកាត់ផ្តាច់សន្តិភាព ឬមានអំពើឈ្លានពានក្រុមប្រឹក្សាសន្តិសុខនឹងអាចដាក់ទណ្ឌកម្ម ឬបញ្ជូនកងកម្លាំងប្រដាប់អាវុធរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងរដ្ឋមានកំហុសបាន។

តម្លៃថ្មីៗបានលេចចេញនៅក្នុងសហគមន៍អន្តរជាតិ និងត្រូវបានគេចាត់ទុកថាជាការការ-ពារពិសេសមួយ។ក្រោយសង្គ្រាមលោកលើកទី២ដើម្បីជាការឆ្លើយតបទៅនឹងឃាតកម្មទាំងដុលដោយពួកណាស៊ីទៅលើក្រុមជាតិពន្ធុ និងសាសនា(ជាពិសេសពួកជ្វីស និងស៊ីហ្គាន) និងការមើលងាយមើលថោកពេញទំហឹងចំពោះសិទ្ធិជាសារវន្តរបស់មនុស្សរាប់ពាន់នាក់ ទាំងនៅប្រទេសអាល្លឺម៉ង់ និងនៅទីដទៃ ក្រុមសម្ព័ន្ធមិត្តបានសម្រេចបង្កើតជាការធានាល្អបំផុតប្រឆាំងទៅនឹងឧក្រិដ្ឋកម្ម និងការរំលោភផ្សេងៗទៅលើសិទ្ធិមនុស្ស។ ទង្វើទាំងនេះបានជំរុញឱ្យអង្គការសហប្រជា-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាតិអនុម័តការហាមប្រាមជាទូទៅចំពោះរាល់ទម្រង់នៃការឈ្លានពាន។ តម្លៃថ្មីៗទាំងនេះបានញ៉ាំងឱ្យមានសន្ធិសញ្ញាអន្តរជាតិជាច្រើន ព្រមទាំងវិធានតាមទំនៀមទម្លាប់អន្តរជាតិមួយចំនួន។

មាត្រា១នៃអនុសញ្ញាក្រុងហ្សឺណែវទាំងបួនចុះឆ្នាំ១៩៤៩(ការការពារ«ជនរងគ្រោះដោយសង្គ្រាម»ទាំងនេះដែលមានដូចជាជនស៊ីវិល អ្នករបួស អ្នកជំងឺ ឈ្លើយសឹកសង្គ្រាម។ល។ ព្រមទាំងមាត្រា១.១នៃពិធីសារបន្ថែមទី១ឆ្នាំ១៩៧៧ទៅលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ស្តីពីជម្លោះប្រដាប់អាវុធអន្តរជាតិសុទ្ធសឹងជាចំណុចសំខាន់ៗដែលយើងត្រូវវិភាគវែងឆ្ងាយ។ បញ្ញត្តិទាំងនេះចែងថា រដ្ឋភាគីកិច្ចសន្យានីមួយៗសន្យានឹងគោរពអនុសញ្ញា(និងពិធីសារ)«នៅគ្រប់កាលៈទេសៈទាំងអស់»។

ក្រោយសង្គ្រាមលោកលើកទី២ លក្ខណៈរបស់សហគមន៍ពិភពលោកប្រែប្រួលទាំងស្រុង។

- ទីមួយ ប្រទេសអឺរ៉ុបខាងកើតបានក្លាយទៅជាប្រទេសសង្គមនិយម។
- ទីពីរ ប្រទេសក្រោមអាណានិគមជាច្រើនបានទទួលឯករាជ្យតាមផ្លូវនយោបាយ។

ក្រោយឆ្នាំ១៩៦០ សហគមន៍អន្តរជាតិមួយភាគធំផ្សំឡើងដោយប្រទេសតតិយលោក។ ជាមួយគ្នានឹងរដ្ឋសង្គមនិយម ប្រទេសតតិយលោកអាចប្រមូលសំឡេងភាគច្រើនក្នុងចំណោមសំឡេងពីរភាគបីយ៉ាងងាយស្រួលនៅក្នុងរាល់ការប្រមូលផ្តុំអន្តរជាតិ។

ជាមួយនឹងការគាំទ្រសកម្មរបស់រដ្ឋសង្គមនិយម ប្រទេសកំពុងអភិវឌ្ឍបានបង្កើតយ៉ាងរឹងមាំនូវឥទ្ធិពលរបស់ខ្លួនទៅលើមហាសន្និបាតអង្គការសហប្រជាជាតិ។ ពួកគេបានទាមទារឱ្យស្វ័យសម្រេច និងសមភាពពូជសាសន៍ប្រែក្លាយទៅជាគោលការណ៍គតិយុត្ត(នៅឆ្នាំ១៩៦៥ អនុសញ្ញាសហប្រជាជាតិស្តីពីការរើសអើងពូជសាសន៍ត្រូវបានអនុម័ត និងនៅឆ្នាំ១៩៦៦ កតិកាទាំងពីររបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស)។

ក្រោយពីមានការប្រឹងប្រែងយ៉ាងយូរ ក្រុមប្រទេសទាំង៧៧ តាមដែលគេអះអាង បានទទួលជោគជ័យក្នុងការធ្វើឱ្យមហាសន្និបាតអនុម័តសេចក្តីប្រកាសមួយ និងផែនការសកម្មភាពមួយស្តីពី «សណ្តាប់ធ្នាប់សេដ្ឋកិច្ចអន្តរជាតិថ្មី»(NOEI)។

ការដួលរលំសហភាពសូវៀតនៅឆ្នាំ១៩៨៩ និងការបែកបាក់បណ្តារដ្ឋសង្គមនិយមនៅពេលភ្លាមៗបន្ទាប់មក បាននាំឱ្យមានបម្រែបម្រួលនៅក្នុងពិភពលោក។ កងកម្លាំងមហាអំណាចបានធ្វើប្រតិបត្តិការតាមរយៈអង្គការសហប្រជាជាតិ នៅពេលផលប្រយោជន៍របស់ពួកគេត្រូវបានគំរាមកំហែង(អ៊ីរ៉ាក់ ១៩៩០-១ សូម៉ាលីឆ្នាំ១៩៩២ បូស្នី ហ៊ែកហ្សេកូវីនឆ្នាំ១៩៩២-៥)។ នៅពេលដែលការគាំទ្ររបស់អង្គការសហប្រជាជាតិមិនអាចទទួលបានភ្លាមៗ ក្រុមប្រទេសមហាអំណាចបានធ្វើប្រតិបត្តិការតាមរយៈអង្គការអូតង់(OTAN) (កូសូវ៉ូឆ្នាំ១៩៩៩)។ ពួកគេអនុប្បវាទមិនបានចាត់វិធានការណ៍យោធាទេ នៅពេលដែលផលប្រយោជន៍របស់ពួកគេមិនត្រូវពាក់ព័ន្ធ(ឧទាហរណ៍


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រទេសរវ៉ាន់ដាឆ្នាំ១៩៩៤ ប្រទេសសេរ៉ាឡេអូនឆ្នាំ២០០០។ល។) ឬពួកគេបានធ្វើប្រតិបត្តិការយោធាដោយគ្មានការអនុញ្ញាតពីអង្គការសហប្រជាជាតិ(ប្រទេសអ៊ីរ៉ាក់ ឆ្នាំ២០០៣-២០០៤)។

នាពេលបច្ចុប្បន្ននេះ គឺកាន់តែមានទំនោរទៅរកតំបន់ភាវូបនីយកម្ម។ ចរិតលក្ខណៈនៃការវិវត្តបែបទំនើបនៃនីតិអន្តរជាតិត្រូវទាមទារឱ្យមានការលើកឡើងក្បោះក្បាយ។ នៅក្នុងលំដាប់នៃការអភិវឌ្ឍមុនៗនៃអង្គភាពពិសេសនៃនីតិ មានច្បាប់មួយចំនួនបានកកើតឡើងជាបន្តបន្ទាប់ដូចជាច្បាប់សិទ្ធិមនុស្ស ច្បាប់មនុស្សធម៌ស្តីពីជម្លោះប្រដាប់អាវុធ ច្បាប់បរិស្ថាន ច្បាប់ពាណិជ្ជកម្មអន្តរជាតិ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ច្បាប់ស្តីពីទំនួលខុសត្រូវជាអន្តរជាតិរបស់រដ្ឋ។ ច្បាប់ទាំងនេះមានទំនោរបំពេញបន្ថែមទៅលើការបែងចែកគតិយុត្តដែលដាច់ៗគ្នា និងមិនលាយឡំគ្នាបាន។

ច្បាប់បរិស្ថានអន្តរជាតិ និងច្បាប់ពាណិជ្ជកម្មអន្តរជាតិកាន់តែមានចំណងទាក់ទងគ្នាឡើង។ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិកាន់តែទទួលឥទ្ធិពលពីច្បាប់ស្តីពីសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌។ ច្បាប់ស្តីពីទំនួលខុសត្រូវជាអន្តរជាតិរបស់រដ្ឋត្រូវទទួលឥទ្ធិពលពីច្បាប់ស្តីពីទំនួលខុសត្រូវព្រហ្មទណ្ឌជាឯកទត្តបុគ្គល។ ច្បាប់សមុទ្រត្រូវបានភ្ជាប់ទៅនឹងច្បាប់ស្តីពីការអភិវឌ្ឍ និងត្រូវចាត់ទុកថាជាមធ្យោបាយមួយដែលអាចទៅរួច ដើម្បីអនុគ្រោះដល់ការក្រោកឡើងនៃសេដ្ឋកិច្ចរបស់ប្រទេសក្រីក្រ។

# ផ្នែកទី២

## លទ្ធិនៃនីតិអន្តរជាតិ

តើអ្វីទៅជាគ្រឹះ(ទ្រឹស្តី)នៃនីតិ? តើហេតុអ្វីបានជាគេត្រូវគោរពតាមវិធានច្បាប់? មានវិធីសាស្ត្របីយ៉ាងក្នុងការគិតពីនីតិអន្តរជាតិ។ នីតិអន្តរជាតិអាចត្រូវចាត់ទុកថាជាតម្លៃ(ក្រោមទិដ្ឋភាពនៃសុពលភាព) ឬថាជាភាពជាក់ស្តែង។ គ្រឹះនៃនីតិអន្តរជាតិស្ថិតនៅក្នុងតម្លៃវិសេសវិសាលមួយ(ច្បាប់ធម្មជាតិ)នៅក្នុងទម្រង់នៃការប្រកាស និងទណ្ឌកម្មដោយអំណាច(បតិដ្ឋាននិយម) ឬនៅក្នុងប្រតិបត្តិការជាក់ស្តែងនៃវិធានមួយនៅក្នុងអង្គសង្គម(សង្គមវិជ្ជានិយម)។[៨] នេះក៏ជាលំដាប់លេចឡើងនៃលទ្ធិទៅតាមប្រវត្តិសាស្ត្រដែរ។

### ១- បតិដ្ឋាននិយមគតិយុត្ត (Le positivisme juridique)

បតិដ្ឋាននិយមលេចឡើងនៅចុងដើមសម័យទំនើប។ ក៏ប៉ុន្តែ ឆន្ទៈដែលថាដូចជាប្រភពនៃនីតិត្រូវបានស្នើសុំដោយអធិរាជរ៉ូម៉ាំង នៅពេលក្រោយមកទៀតនៅប៊ីហ្សង់ស៍(Byzance)។ បន្ទាប់

[៨] *CTRUYOL Y SERRA (A.),* « Doctrines sur le fondement du droit des gens », *Paris, Pedone, 2007, p.4.*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មក សាំង ប៉ូល(St. Paul)បានយល់ និងមើលឃើញថា ព្រះអាទិទេពគឺជាអ្នកធ្វើច្បាប់ដ៏មានអំណាច។ ការប្រយុទ្ធរវាងហេតុផល(ច្បាប់ធម្មជាតិ) និងឆន្ទៈ(ឆន្ទៈនិយម) គឺជាគូអមតៈនៃគំនិតគតិយុត្តរបស់បស្ចិមប្រទេស។[៩] សតវត្សរ៍ទី១៩បានស្គាល់ការកើនឡើងខ្លាំងនៃបតិដ្ឋាននិយម។ វិធាននៃនីតិអន្តរជាតិត្រូវបាន«ដាក់ចុះ»ដោយរដ្ឋ និងមានប្រភពមកពីឆន្ទៈរបស់រដ្ឋទាំងនេះ។ នៅក្នុងនិកាយបតិដ្ឋាននិយម មានចរន្តច្រើនដូចខាងក្រោម ៖

1- អ្នកអវត្ថោម័តនិយម(objectiviste)ត្រូវបានដឹកនាំដោយ G. Scelle។ រដ្ឋគោរពតាមកាតព្វកិច្ចរបស់ពួកគេ ដោយហេតុតែមានកំហិតសង្គម។ ច្បាប់ត្រូវកែទម្រង់ទៅតាមភាពចាំបាច់ និងការទាមទារនៃសណ្តាប់ធ្នាប់សង្គម។

2- អ្នកឆន្ទៈនិយមត្រូវដឹកនាំដោយ D. Anzilotti (ចរន្តធំជាងគេ)។ ចរិតលក្ខណៈបង្ខិតបង្ខំនៃនីតិអន្តរជាតិចេញមកពីឆន្ទៈរបស់រដ្ឋ។ លទ្ធិនេះត្រូវល្អជាងគេទៅនឹងអធិបតេយ្យភាពរបស់រដ្ឋ។

3- ចរន្តធម្មនិយាមនិយម ឬបញ្ញត្តិនិយមត្រូវដឹកនាំដោយ H. Kelsen (ចរន្តភាគតិច)។ ច្បាប់គឺជាសំណុំសាំញ៉ាំដែលមានឋានានុក្រម រដ្ឋត្រូវចាប់បង្ខំដោយបញ្ញត្តិចម្បងមួយដែលមិនអាចបង្ហាញតាមផ្នែកគតិយុត្តបាន ប៉ុន្តែដែលចាំបាច់ត្រូវចាប់បង្ខំទៅលើរដ្ឋ គឺគោលការណ៍ Pacta sunt Servanda។

## ២- លទ្ធិសង្គមវិជ្ជា

ទ្រឹស្តីសង្គមវិជ្ជាបានលេចឡើងនៅចុងសតវត្សរ៍ទី១៩។ «ទីណាមានសង្គម ទីនោះត្រូវមានច្បាប់»។ ជាកាតព្វកិច្ចដែលត្រូវគោរពតាមវិធានដែលតម្រូវដោយសណ្តាប់ធ្នាប់សង្គម។

## ៣- លទ្ធិនៃច្បាប់ធម្មជាតិ

ច្បាប់ធម្មជាតិលេចចេញតាំងពីសម័យបុរាណកាលមកម្ល៉េះ។ Anaximandre បានដាក់ជាឧបធារណ៍នូវលោកធាតុមួយ(Cosmos)ដែលជាឧត្តមបញ្ញាមួយដែលស្តែងឡើងតាមភាវៈនៃលោកយើងនេះ។ បន្ទាប់មក លទ្ធិ Jusnaturaliste ត្រូវបានអភិវឌ្ឍឡើងដោយ La Stoa។

ពីសតវត្សរ៍ទី១៦ដល់សតវត្សរ៍ទី១៨ លទ្ធិដែលខ្លាំងគ្របដណ្តប់លើគេគឺលទ្ធិនៃច្បាប់ធម្មជាតិ។ តាម Hugo de Groot ដែលគេហៅទូទៅថា Grotius (១៥៨៣-១៦៤៥) ដែលជាអ្នកនិពន្ធសៀវភៅច្បាប់អន្តរជាតិពិតប្រាកដទីមួយ «វិធានច្បាប់អន្តរជាតិគឺជាវិធានច្បាប់ធម្មជាតិដែលមានប្រភពចេញមកពីធម្មជាតិមនុស្សដែលព្រះអាទិទេពចង់បាន ហើយដែលមានតាំងពីមុនរួចទៅហើយ និងត្រូវតែស្វែងរកឱ្យឃើញ»។[១០]

---

[៩] TRUYOL Y SERRA (A.), op. cit., p. 5.

[១០] MARTIN-BIDOU (P.), op. cit., p. 9.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក២
# ប្រភពនៃច្បាប់អន្តរជាតិ

## ផ្នែកទី១
## កំណកំណើតនៃច្បាប់អន្តរជាតិ

*តើអ្វីទៅជាប្រភពនៃច្បាប់អន្តរជាតិ? តាមមាត្រា៣៨នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិដែលមានបេសកកម្មដោះស្រាយជម្លោះដែលគេដាក់ជូនទៅតាមច្បាប់អន្តរជាតិតុលាការយុត្តិធម៌អន្តរជាតិបានកំណត់ប្រភពនៃនីតិអន្តរជាតិដូចខាងក្រោម ៖*

- *អនុសញ្ញាអន្តរជាតិទូទៅ ឬពិសេសដែលបង្កើតជាវិធានដែលត្រូវទទួលស្គាល់ដោយច្បាស់ក្រឡែតដោយរដ្ឋមានជម្លោះ។*
- *ទំនៀមទម្លាប់អន្តរជាតិ ដូចជាភស្តុតាងនៃការអនុវត្តទូទៅដែលគេទទួលស្គាល់ថាជាច្បាប់។*
- *គោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយរដ្ឋមានអារ្យធម៌។*
- *ក្រោមលក្ខខណ្ឌនៃបទប្បញ្ញត្តិនៃមាត្រា៥៩ គឺរាល់សេចក្តីសម្រេចរបស់តុលាការ និងលទ្ធិរបស់អ្នកនិពន្ធផ្សាយដែលមានស្នាដៃរបស់ប្រទេសជាតិផ្សេងៗថាដូចជាមធ្យោបាយជំនួយក្នុងការកំណត់វិធានច្បាប់។*

*ប្រសិនបើគូភាគីយល់ព្រម បទប្បញ្ញត្តិនេះមិនប៉ះពាល់ដល់សមត្ថភាពរបស់តុលាការក្នុងការវិនិច្ឆ័យបែប ex aequo et bono ឡើយ។*

### ទ្រឹស្តីអំពីប្រភពលើកឡើងនូវបញ្ហាខាងក្រោម ៖

*តើច្បាប់ត្រូវបានបង្កើតឡើងដូចម្តេច ហើយវាលេចឡើងនៅក្នុងប្រភេទណាខ្លះ? តើវិធានមួយត្រូវបានទទួលស្គាល់ជាវិធានគតិយុត្តដោយអង្គភាពសង្គមមួយយ៉ាងដូចម្តេច?*

- *វិធីសាស្ត្រទីមួយនៃការបង្កើតច្បាប់អន្តរជាតិទាក់ទងទៅនឹងការបង្កើតច្បាប់ដោយស្ម័គ្រ-*

ចិត្តតាមរយៈការអនុម័តអនុសញ្ញាអន្តរជាតិ(តាមគំរូនីតិកម្ម)។ ដំណើរការនីតិកម្មបង្កើតបានជាព្រឹត្តិការណ៍បង្កើតច្បាប់។ នេះជាការបង្កើតច្បាប់អន្តរជាតិតាមរយៈអនុសញ្ញាអន្តរជាតិ។

- វិធីសាស្ត្រទីពីរទាក់ទងនឹងការបង្កើតច្បាប់នៅក្នុងអង្គភាពសង្គមតាមរយៈទំនៀមទម្លាប់។

ទោះជាយ៉ាងនេះក្តី ច្បាប់អន្តរជាតិទំនើបត្រូវកត់សម្គាល់ដោយការរាតទី និងឯកទេសកម្មកាន់តែខ្លាំងទៅៗរបស់វា។ របៀបកកើតនៃច្បាប់អន្តរជាតិក៏មានការវិវត្តដែរ។ សព្វថ្ងៃនេះ ច្បាប់អន្តរជាតិត្រូវបង្កើតឡើងនៅក្នុងវេទិកាជាច្រើន រួមទាំងនៅក្នុងដំណើរការពហុភាគីដ៏ច្រើនខុសៗគ្នា មានដូចជាតុលាការ និងអង្គភាពនានារបស់អង្គការអន្តរជាតិ។ លើសពីនេះទៅទៀត ទោះបីជារដ្ឋនៅតែជាអ្នកសម្រេចបឋមនៃច្បាប់អន្តរជាតិ រដ្ឋក៏មានការចូលរួមពីអ្នកចូលរួមដទៃទៀតដូចជាអង្គការអន្តរជាតិ ចៅក្រម ព្រមទាំងអង្គភាពនានាដែលជះឥទ្ធិពលលើកំណាកំណើតនៃច្បាប់អន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលឯកជនផង។ សកម្មភាពទាំងនេះមានភាពបែកខ្ញែកគ្នាជាមួយនឹងវិធានខុសៗគ្នាដែលអភិវឌ្ឍដោយអង្គភាពមួយចំនួនដែលមានការសម្របសម្រួលគ្នាតិចតួច និងផ្ទុះបញ្ហាំងពីគោលវិធីវិមជ្ឈការនៃការបង្កើតច្បាប់អន្តរជាតិ។

ដំណើរការនៃការបង្កើតច្បាប់អន្តរជាតិប្រព្រឹត្តទៅនៅក្នុង និងក្រៅអង្គការសហប្រជាជាតិដែលនាំឱ្យមានការអនុម័ត(ឬគ្មាន)នូវឧបករណ៍អន្តរជាតិសំខាន់ៗជាច្រើន និងឯកសារផ្សេងៗទៀត។ ទាំងនេះរួមមានការបង្កើតច្បាប់ពហុភាគីតាមរយៈដំណើរការអន្តររដ្ឋាភិបាលដែលមានដូចជាសន្និសីទការទូត និងអង្គភាពតាមអនុសញ្ញា ព្រមទាំងសកម្មភាពមួយចំនួនរបស់អង្គការសហប្រជាជាតិនៅក្នុងការតាក់តែងក្រម និងការអភិវឌ្ឍច្បាប់អន្តរជាតិជាបន្តបន្ទាប់ដោយអនុលោមទៅតាមមាត្រា១៣(១)(ក)នៃជម្មនុញ្ញអង្គការសហប្រជាជាតិ ព្រមទាំងសកម្មភាពរបស់គណៈកម្មការទី៦នៃមហាសន្និបាត និងគណៈកម្មការនីតិអន្តរជាតិ។

## តើអ្វីទៅជាវិភាគទាននៃសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិចំពោះការអភិវឌ្ឍនីតិអន្តរជាតិ?

មានដំណើរការពីរនៃការបង្កើតច្បាប់អន្តរជាតិតាមរយៈបញ្ញត្តិរបស់សហប្រជាជាតិ។[១១] ដូច្នេះ ការស្នើឱ្យមានការបែងចែកដំណើរការជាលំដាប់មួយដែលតាមរយៈនោះ ការបង្កើតច្បាប់អន្តរជាតិដោយបញ្ញត្តិសហប្រជាជាតិដែលជាដំណើរការប្រយោល។ នៅក្នុងករណីនេះ អានុភាពនៃការសម្រេច(Résolutions)ទាំងនេះស្តែងឡើងជាដំបូងនៅក្នុងលំដាប់គតិយុត្តរបស់សហប្រជាជាតិ ប៉ុន្តែជួនកាល រដ្ឋនានាឯកភាពផ្តល់អានុភាពគតិយុត្តក្រៅសហប្រជាជាតិដល់ការសម្រេចទាំងនេះ។ នេះគឺជាស្ថាប័នកម្មសាមញ្ញនូវដំណើរការបែបបុរាណនៃការបង្កើតច្បាប់អន្តរជាតិដោយបញ្ញត្តិរបស់សហប្រជាជាតិ។

---

[១១] *NORODOM (Anne-Thyda)*, « Typologie des résolutions de l'ONU créatrices de droit international général », *Quatrième conférence biannuelle de la Société européenne de droit international. 2-4 septembre 2010, p. 3.*

ច្បាប់នេះក៏អាចបង្កើតច្បាប់អន្តរជាតិទូទៅដោយផ្ទាល់ ទៅតាមដំណើរការមួយដែលយើងនឹងចាត់ទុកថាជាដំណើរការស្វ័យប្រវត្តិមួយ។ អានុភាពនៃសេចក្តីសម្រេចទាំងនេះគឺមានលក្ខណៈចាប់បង្ខំ ហើយខ្លឹមសារគតិយុត្តរបស់វាវិញគឺទូទៅនិងអរូបី។អានុភាពគតិយុត្តនៃសេចក្តីសម្រេចទាំងនេះចេញហួសផុតពីលំដាប់គតិយុត្តរបស់អង្គការសហប្រជាជាតិ ដើម្បីមានឥទ្ធិពលទៅលើលំដាប់គតិយុត្តអន្តរជាតិ ដោយរដ្ឋមិនចាំបាច់ប្រកាសដាក់លាក់នូវការយល់ព្រមរបស់ខ្លួនថាត្រូវចងដោយបទប្បញ្ញត្តិពិសេសទាំងនេះឡើយ។ ដូច្នេះ នេះគេហៅថាជាស្ថាប័នកម្មបែបស្មុគ្រស្មាញ។

## ការចងក្រងច្បាប់អន្តរជាតិជាក្រម

មាត្រា១៥នៃលក្ខន្តិកៈរបស់គណៈកម្មការនីតិអន្តរជាតិចែងថា ដើម្បីជាការងាយស្រួលសំនួនសេចក្តី«ការចងក្រងច្បាប់អន្តរជាតិជាក្រម»ត្រូវគេប្រើប្រាស់ ដើម្បីគ្របដណ្តប់លើករណីទាំងឡាយណាដែល«គេតាក់តែងប្រកបដោយភាពជាក់ច្បាស់ និងរៀបជាប្រព័ន្ធនូវវិធាននៃនីតិអន្តរជាតិនៅក្នុងវិស័យនានាដែលក្នុងនោះធ្លាប់មានការអនុវត្តធំធេងរបស់រដ្ឋ ទម្លាប់ពីមុនៗ និងគំនិតចេញពីលទ្ធិរួចហើយ»។

ដូច្នេះ សំនួនសេចក្តីនេះត្រូវបានឱ្យនិយមន័យ ដើម្បីញែកវាឱ្យដាច់ចេញពីសំនួនសេចក្តី«ការអភិវឌ្ឍច្បាប់អន្តរជាតិជាលំដាប់»ដែល«ដើម្បីជាការងាយស្រួល ត្រូវប្រើប្រាស់ដើម្បីគ្របដណ្តប់លើរាល់ករណីដែលគេត្រូវសរសេរអនុសញ្ញាអំពីប្រធានបទផ្សេងៗដែលពុំទាន់ត្រូវបានដោះស្រាយទៅតាមច្បាប់អន្តរជាតិ ឬដែលចំពោះប្រធានបទទាំងនោះឯង ច្បាប់ពុំទាន់ត្រូវបានអភិវឌ្ឍគ្រប់គ្រាន់នៅក្នុងការអនុវត្តរបស់រដ្ឋ»។

មាត្រា១៨នៃលក្ខន្តិកៈរបស់គណៈកម្មការនីតិអន្តរជាតិចែងថា ៖ «នៅក្នុងបណ្តុំនៃច្បាប់អន្តរជាតិ គណៈកម្មការស្វែងរកប្រធានបទសមស្របសម្រាប់ការចងក្រងជាក្រម ដោយគិតគូរទៅលើគម្រោងដែលមានស្រាប់នានា ទោះបីជាគម្រោងនោះមានប្រភពមកពីរដ្ឋាភិបាល ឬមិនមែនក៏ដោយ»។ មាត្រាដដែលនេះចែងថា ៖ «នៅពេលដែលគណៈកម្មការវិនិច្ឆ័យថាការចងក្រងប្រធានបទមួយជាក្រម ចាំបាច់ ឬគួរឱ្យចង់ធ្វើគណៈកម្មការដាក់អនុសាសន៍នានាជូនមហាសន្និបាត»។

នៅក្នុងវិធានការណ៍មួយធំទូលាយ ជម្រើសប្រធានបទដែលត្រូវចងក្រងជាក្រម អាស្រ័យទៅតាមអត្ថន័យដែលគណៈកម្មការឱ្យទៅលើពាក្យ«ការចងក្រងជាក្រម»ដោយផ្អែកទៅលើលក្ខន្តិកៈរបស់គណៈកម្មការ ការពិភាក្សាដែលបានធ្វើពីមុនមក និងបទពិសោធន៍នានាដែលទទួលបាននៅពេលសាកល្បងចងក្រងជាក្រមកាលពីមុនៗមក។

ទោះជាយ៉ាងនេះក្តី ច្បាប់អន្តរជាតិទំនើបត្រូវកត់សម្គាល់ដោយការរាតទី និងឯកទេសកម្ម

*កាន់តែខ្លាំងទៅៗរបស់វា។ របៀបកកើតនៃច្បាប់អន្តរជាតិក៏មានការវិវត្តដែរ។*

*នៅក្នុងការអនុវត្ត បន្ទាប់ពីការស្វែងរកវិធានតាមអនុសញ្ញា(កិច្ចឯកតោភាគីរបស់រដ្ឋ ឬសេចក្តីសម្រេចចាប់បង្ខំរបស់អង្គការអន្តរជាតិ) និងបន្ទាប់មក សម្រាប់វិធានទំនៀមទម្លាប់ក្នុងករណីដែលមានកង្វះខាត ឬមានច្បាប់មិនច្បាស់ ដំបូងតុលាការត្រូវស្វែងរកគោលការណ៍ទូទៅដែលត្រូវទៅនឹងសាខាណាមួយនៃច្បាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ។ យើងត្រូវតែឆ្លងបន្តិចម្តងជាលំដាប់ទៅមុខពីភាពដោយឡែកមួយទៅរកដំណោះស្រាយគតិយុត្តដែលទូទៅជាង ដោយអនុលោមទៅតាមគោលការណ៍ជាសារវន្តដែលតាមរយៈនោះ ច្បាប់ពិសេសត្រូវមានឧត្តមានុភាពទៅលើច្បាប់ទូទៅជានិច្ច។*[១២]

# ផ្នែកទី២

## ប្រភពច្បាប់

*ទំនៀមទម្លាប់ និងសន្ធិសញ្ញាគឺជាប្រភពសំខាន់ពីរនៃច្បាប់អន្តរជាតិ។ ប្រភពទាំងពីរនេះត្រូវបានចែងដោយវិធានមូលដ្ឋាន«តាមធម្មនុញ្ញ»ពីរនៃសហគមន៍អន្តរជាតិដែលស្ថិតនៅចំណុចកំពូលនៃលំដាប់គតិយុត្ត(Cosuetudo est servanda ដែលមានន័យថា ប្រធាននីតិអន្តរជាតិទាំងអស់ត្រូវតែប្រតិបត្តិតាមវិធានទំនៀមទម្លាប់ និង* Pacta Sunt servanda *ដែលមានន័យថា គូភាគីនៃកិច្ចព្រមព្រៀងអន្តរជាតិត្រូវតែគោរពកិច្ចព្រមព្រៀងទាំងនោះ)។*

### ១- ទំនៀមទម្លាប់អន្តរជាតិ

*ទំនៀមទម្លាប់គឺជាប្រភពឥតសរសេរមួយនៃច្បាប់អន្តរជាតិ និងមានលក្ខណៈស្វ័យប្រវត្តិនៅក្នុងកំណាកំណើតរបស់វា។ មានការពិភាក្សាវែកញែកតាមលទ្ធិដែលគួរចាប់អារម្មណ៍មួយដែលធ្វើឱ្យអ្នកឆន្ទៈនិយមប្រឆាំងនឹងអ្នកអន្តោម័តនិយម ទាក់ទិនទៅនឹងតួនាទីនៃការយល់ព្រមតាមនៅក្នុងកំណាកំណើតនៃទំនៀមទម្លាប់ និងនៅក្នុងភាពអាចជំទាស់បានរបស់វា។*

### ១.១- កំណាកំណើតនៃទំនៀមទម្លាប់អន្តរជាតិ

*កំណាកំណើតនៃទំនៀមទម្លាប់មួយទាមទារឱ្យមានការប្រជុំគ្នារវាងធាតុពីរ គឺធាតុសម្ភារពោលគឺការអនុវត្តរបស់រដ្ឋ និងធាតុចិត្តវិទ្យា ពោលគឺយោបល់ច្បាប់។*

---

[១២] *A. Cassese,* International Law, *New York, Oxford University Press, 2001, p. 194.*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***ជាតុសម្ភារ***គឺការអនុវត្ត។ នេះគឺជាអាកប្បកិរិយារបស់ប្រធាននៃនីតិអន្តរជាតិដែលមានរដ្ឋ ឬអង្គការអន្តរជាតិ ៖

• អាកប្បកិរិយាសកម្ម សម្ភារ ឬគតិយុត្តដែលចេញមកពីអង្គភាពដែលមានសមត្ថកិច្ច។

• អាកប្បកិរិយាអកម្ម ដូចជាអនុប្បវាទ ឬតុណ្ហីភាព(silence)។

• ទំនៀមទម្លាប់ទាំងនេះត្រូវបានធ្វើឡើងដដែលៗ  ការធ្វើឡើងដដែលៗនេះអាចឱ្យញែកអំពីការអនុវត្តដែលអាចក្លាយទៅជាទំនៀមទម្លាប់មួយ គ្រាន់តែមានការប្រើប្រាស់សាមញ្ញធម្មតា។

ការអនុវត្តត្រូវតែថេរ និងមានលក្ខណៈជាប្រព័ន្ធ(uniform) ឬឯកភាព។

• ភាពថេរទាមទារឱ្យមានការធ្វើដដែលៗនៅក្នុងរយៈពេលមួយ។ ប្រសិនបើទំនៀមទម្លាប់អាចកើតឡើងនៅក្នុងរយៈពេលមួយយ៉ាងខ្លី ការអនុវត្តត្រូវមានបង្កប់នូវភាពញឹកញាប់។[១៣]

• ការអនុវត្តមានឯកភាព  នៅពេលដែលអាកប្បកិរិយាត្រូវ  និងស្របគ្នា  មានន័យថាអាកប្បកិរិយាទាំងនេះត្រូវបានធ្វើឡើងដដែលៗដោយរដ្ឋច្រើន ហើយវាស្រដៀងគ្នា។

មានទំនៀមទម្លាប់តំបន់(ជាឧទាហរណ៍ប្រព័ន្ធអាមេរិកឡាទីនស្តីពីសិទ្ធិជ្រកកោននយោបាយ យោងតាមតុលាការយុត្តិធម៌អន្តរជាតិ នៅក្នុងសាលដីកាចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥១ ក្នុងរឿងក្តី Haya De La Torre នៅក្នុងកម្រងសាលដីកាឆ្នាំ១៩៥១ ទំព័រ៧១) និងទ្វេភាគីផងដែរ(ឧទាហរណ៍សិទ្ធិឆ្លងកាត់  យោងតាមតុលាការយុត្តិធម៌អន្តរជាតិនៅក្នុងសាលដីកាចុះថ្ងៃទី១២  ខែមេសា  ឆ្នាំ ១៩៦០ នៅក្នុងរឿងក្តីស្តីពីសិទ្ធិឆ្លងកាត់ទឹកដីឥណ្ឌានៅក្នុងកម្រងសាលដីកាឆ្នាំ១៩៦០ ទំព័រ៦)។

***ជាតុចិត្តវិទ្យា*** ៖ ការអនុវត្តត្រូវ«ទទួលស្គាល់ថាជាច្បាប់»។ ជាតុចិត្តវិទ្យា ឬបញ្ញានេះដែលគេហៅថា opinio juris sive necessitatis គឺចាំបាច់ខានមិនបានសម្រាប់ការបង្កើតទំនៀមទម្លាប់មួយ។ ជាតុនេះបង្ហាញពីចេតនារបស់រដ្ឋដែលត្រូវចងដោយវិធានច្បាប់មួយ។

លទ្ធិបុរាណចាត់ទុកថា បើតាមលំដាប់កាលប្បវត្តិ ការអនុវត្តលេចចេញមុនយោបល់ច្បាប់ (opinio juris)។ អ្នកនិពន្ធខ្លះប្រឈមទំនៀមទម្លាប់ដែលគេហៅថា «ប្រកបដោយគតិបណ្ឌិត» នេះទៅនឹងទំនៀមទម្លាប់«ព្រៃ» (R.-J. Dupuy) ដែលក្នុងនោះ ដំបូងគួរតែមាន«តម្រូវការច្បាប់» សិន បន្ទាប់មកទើបការអនុវត្តមកបញ្ចប់ដំណើរកំណាក់ណើតទំនៀមទម្លាប់។

តាមរយៈការរួបរួមគ្នា  ជាតុទាំងពីរនេះមិនត្រឹមតែអាចឱ្យទំនៀមទម្លាប់កើតឡើងបានទេ វាក៏អាចអនុញ្ញាតឱ្យគេ  ជាពិសេសចៅក្រមធ្វើអត្តសញ្ញាណទំនៀមទម្លាប់  និងធ្វើការបង្ហាញពីអត្ថិភាព និងខ្លឹមសារនៃទំនៀមទម្លាប់បានដែរ។

---

[១៣] នៅឆ្នាំ១៩៦៩ តុលាការអន្តរជាតិបានបញ្ជាក់ទាក់ទងទៅនឹងច្បាប់សមុទ្រថា «ការដែលអំពើមួយត្រូវបានប្រព្រឹត្តនៅក្នុងរយៈពេលមួយខ្លី មិនមែនជាឧបសគ្គចំពោះការកកើតឡើងនៃវិធានថ្មីមួយនៃច្បាប់អន្តរជាតិទំនៀមទម្លាប់ឡើយ»។ ប៉ុន្តែតុលាការបានបន្តថា «ជាការចាំបាច់ដែលក្នុងរយៈពេលខ្លីនេះ ទោះជាខ្លីយ៉ាងណាក្តី ការអនុវត្តរបស់រដ្ឋ រួមទាំងរបស់អ្នកដែលពាក់ព័ន្ធទាំងអស់ត្រូវមានភាពញឹកញាប់ និងមានឯកភាព» *(CIJ, arret du 20 fevrier 1969, Affaire de la delimitation du plateau continental de la mer du Nord, Rec. 1969, p. 43)*។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ១.២- ទំនៀមទម្លាប់អន្តរជាតិដែលត្រូវតែគោរព

*ទំនៀមទម្លាប់ត្រូវអនុវត្តចំពោះបណ្តារដ្ឋដែលបានចូលរួមក្នុងការបង្កើតវា។ សម្រាប់រដ្ឋដែលមិនបានចូលរួមបង្កើតទំនៀមទម្លាប់អន្តរជាតិ បញ្ហាគឺអានុភាពចាប់បង្ខំនៃវិធានដែលគេបានបង្កើតរួចទៅហើយ។*

*តើនៅក្នុងលក្ខខណ្ឌណាខ្លះដែលទំនៀមទម្លាប់ត្រូវអនុវត្តចំពោះរដ្ឋទីបី?*

*ប្រសិនបើរដ្ឋទាំងនេះមិនប្រាថ្នាឱ្យគេយកវិធានទំនៀមទម្លាប់មួយមកអនុវត្តចំពោះខ្លួនទេ រដ្ឋទាំងនេះត្រូវបង្ហាញការបដិសេធ នៅពេលដែលរដ្ឋទាំងនេះបង្ហាញខ្លួននៅលើឆាកអន្តរជាតិ ឬនៅពេលដែលរដ្ឋផ្សេងទៀតព្យាយាមប្រើទំនៀមទម្លាប់ចំពោះខ្លួនជាលើកទីមួយ។ ដូច្នេះការយល់ព្រមរបស់រដ្ឋចំពោះវិធានទំនៀមទម្លាប់គឺជាការសន្មតទុក។*

*រដ្ឋមួយដែលមិនបានបង្ហាញការជំទាស់របស់ខ្លួនឱ្យបានទាន់ពេលវេលា អាចត្រូវតម្រូវឱ្យប្រើវិធានទំនៀមទម្លាប់ ដោយគេចាត់ទុកថា ភាពស្ងាត់ស្ងៀមរបស់រដ្ឋនេះស្មើនឹងការយល់ព្រមលើវិធាននេះ ទាំងរដ្ឋនេះធ្លាប់មានពេលគ្រប់គ្រាន់ដើម្បីបង្ហាញការជំទាស់របស់ខ្លួន។ ទ្រឹស្តីជំទាស់ជាប្រចាំបង្ហាញពីតួនាទីនៃការយល់ព្រមក្នុងការអនុវត្តទំនៀមទម្លាប់ចំពោះរដ្ឋទី៣ដោយគោរពតាមទ្រឹស្តីឆន្ទៈនិយម។*

## ២- គោលការណ៍ទូទៅនៃនីតិ

*មាត្រា៣៨នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិមិនមានគោលដៅចង្អុលបង្ហាញប្រភពដែលបានរៀបរាប់ទេ ហើយក៏មិនត្រូវសំអាងជាដំបូងដែរ។*

*ជាទូទៅ គោលការណ៍ទូទៅមានប្រភពចេញមកពីនីតិវិធីរដ្ឋបាល ឬពីច្បាប់ ឬពីសញ្ញាណនៃទំនួលខុសត្រូវនិត្យានុកូលទូទៅ។ គោលការណ៍ខ្លះក្លាយមកពីធម្មជាតិនៃប្រព័ន្ធគតិយុត្តអន្តរជាតិ ឧទាហរណ៍សមភាពគតិយុត្តរបស់រដ្ឋ ឬការហាមប្រាមដែលបង្ខំទៅលើរដ្ឋមួយមិនឱ្យដឹកនាំសកម្មភាពផ្សេងៗលើទឹកដីរបស់រដ្ឋមួយទៀត។*

*នៅក្នុងករណីរោងចក្រ Chorzow[១៤] តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍(CPIJ)បានប្រកាសថា «ភាគីមួយមិនអាចយកកំហុសផ្ទាល់របស់ខ្លួនមកសំអាងទេ» ហើយ«រាល់ការរំលោភការសន្យាមួយនាំឱ្យមានកាតព្វកិច្ចសងសំណង»។ តុលាការអន្តរជាតិខ្លះបានអនុវត្តគោលគំនិតដាក់កំហិត។ តុលាការយុត្តិធម៌អន្តរជាតិ(CIJ)បានប្រើប្រាស់គោលការណ៍ Estoppel ដើម្បីហាមឃាត់មិនឱ្យមានការទាមទារឡើងវិញ(ប្រសិនបើរដ្ឋទទួលស្គាល់នូវកិច្ចព្រមព្រៀងដែលខុសពីន័យដើម ថ្ងៃក្រោយមិនអាចប្រកែកមិនទទួលស្គាល់ឡើយ)។[១៥]*

---

[១៤] *CPJI 1927, Ser. A, No. 9, 31.*

[១៥] *CIJ, Affaire du Temple de Preah Vihear, 1962, CIJ, §6 p. 33.*

នៅក្នុងរឿងក្តីស្តីពីខ្ពង់រាបបាតសមុទ្រនៃសមុទ្រខាងជើង[១៦] តុលាការយុត្តិធម៌អន្តរជាតិបានអនុវត្តសមធម៌ ឬគោលការណ៍សមធម៌នៅក្នុងការកំណត់ព្រំដែនសមុទ្រ។

## គោលការណ៍នៃសមភាពអធិបតេយ្យរបស់រដ្ឋ ៖

• «អង្គការសហប្រជាជាតិត្រូវបានបង្កើតដោយផ្អែកលើគោលការណ៍នៃសមភាពអធិបតេយ្យរបស់សមាជិកទាំងអស់» មាត្រា២ #១នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

• គោលការណ៍ដែលបានគូសបញ្ជាក់រួចហើយនៅក្នុង«សន្ធិសញ្ញាWestphalie» (១៦៤៨)។

• គោលការណ៍នេះចែងថា រដ្ឋទាំងអស់គឺស្មើគ្នានៅចំពោះមុខច្បាប់។

• រដ្ឋទាំងអស់ឯករាជ្យពីគ្នា ហើយមិនទទួលបញ្ជាពីរដ្ឋណាមួយឡើយ។

• អធិបតេយ្យក៏អនុញ្ញាតឱ្យរដ្ឋចូលប្រឡូកដោយផ្ទាល់តាមរយៈនិយាមនៃនីតិអន្តរជាតិ ៖ ផ្តល់សច្ចាប័នលើសន្ធិសញ្ញា ឬចូលជាសមាជិកនៃអង្គការអន្តរជាតិមួយ។ល។

## លក្ខណៈឆន្ទៈនិយមនៃនីតិអន្តរជាតិ ៖

• ជាទូទៅគឺរដ្ឋដែលជាប្រភពនៃវិធានច្បាប់ ៖ អនុសញ្ញា សន្ធិសញ្ញា។ល។

• គ្មានប្រព័ន្ធណាមួយដែលទាមទារឱ្យរដ្ឋបង្ខំចិត្តធ្វើតាមសេចក្តីសម្រេចអន្តរជាតិមួយដែលពួកគេបដិសេធឡើយ។

• គោលការណ៍មិនជ្រៀតជ្រែកនៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋមួយ។

• ការកំហិតនៃការគំរាមកំហែងបង្ខំ ៖ ទណ្ឌកម្មសេដ្ឋកិច្ច ពហិការ ការគំរាមប្រើកម្លាំង ដំណោះស្រាយជម្លោះដោយសន្តិវិធី។ល។

ម៉្យាងទៀត ផ្នែកផ្សេងៗនៃច្បាប់អន្តរជាតិប្រកាន់យកគោលការណ៍ពិសេសៗរបស់ខ្លួន(ច្បាប់សមុទ្រ ច្បាប់មនុស្សធម៌ ច្បាប់ទំនួលខុសត្រូវរបស់រដ្ឋ។ល។)។ គោលការណ៍ទាំងនេះជានិយាមគតិយុត្តទូទៅរួមនៃអង្គទាំងមូលរបស់នីតិដែលគ្រប់គ្រងវិស័យដោយឡែកមួយ។ ឧទាហរណ៍ សូមមើលមាត្រា២១នៃលក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ ក្នុងលក្ខខណ្ឌដែលតុលាការក៏ត្រូវតែអនុវត្តនូវគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិមនុស្សធម៌ ឬសេចក្តីសម្រេចរបស់តុលាការរដ្ឋបាលរបស់អង្គការពលកម្មពិភពលោកនៅក្នុងករណី Diallo ដោយលើកឡើងពី «គោលការណ៍ទូទៅនៃច្បាប់ដែលគ្រប់គ្រងមុខងារសាធារណៈអន្តរជាតិ»(កថាខណ្ឌទី២)។

គោលការណ៍ទាំងនេះដូចគ្នាទៅនឹងប្រព័ន្ធគតិយុត្តជាតិរបស់ប្រទេសភាគច្រើន និងត្រូវបានប្រើប្រាស់ដើម្បីបំពេញភាពខ្វះខាតគតិយុត្ត នៅក្នុងអង្គនៃនីតិអន្តរជាតិ។[១៧] គោលការណ៍

---

[១៦] *CIJ, affaire Plateau continental de la mer du nord, 1969, 3, §88ff.*

[១៧] *Cassese, op. cit., p. 190.*

ទាំងនេះមាន ៖ គោលការណ៍ប្រធានសក្តិ ប្រធានបទនៃការកាត់សេចក្តី ការមិនទទួលបាននូវសិទ្ធិក្នុងការកាត់សេចក្តី គោលការណ៍ដែលរដ្ឋធ្វើខុសត្រូវបង់សំណង។ រដ្ឋល្មើសត្រូវតែបង់សំណងមួយដែលក្នុងនោះ មាន damnum emergens និង lucrum។ (ការប៉ះប៉ូវនេះរួមបញ្ចូលទាំងការខាតបង់ដែលទទួលរង (Damnum emergens) ឧទាហរណ៍ដូចជាការចំណាយដែលប្រើប្រាស់នៅក្នុងការអនុវត្តកិច្ចសន្យា និងការបាត់បង់ប្រាក់ចំណេញ (Lacrum cessans) ឧទាហរណ៍ផលចំណេញសុទ្ធដែលកិច្ចសន្យាអាចនឹងបង្កើតឡើង។ (៣៥ ILR ១៨៦)

តុលាការកម្រនឹងប្រើប្រាស់គោលការណ៍នេះណាស់។ តាមពិតទៅ តុលាការពឹងផ្អែកទៅលើគោលការណ៍តក្កវិជ្ជាគតិយុត្ត និងយុត្តិសាស្ត្រជាទូទៅ។[១៨] ឧទាហរណ៍ គោលការណ៍ nemo judex in re sua ពោលគឺកាតព្វកិច្ចសំណងសម្រាប់អ្នកមានកំហុសជាអន្តរជាតិ ជាគោលការណ៍ដែលតាមនោះយើងមិនអាចឆ្លៀតប្រើឥរិយាបថខុសឆ្គងរបស់រដ្ឋមួយ នេះគឺគោលការណ៍ inadimplenti គឺមិនមែន adimplendum។ ក្រៅពីនេះ មានគោលការណ៍មួយចំនួនទាក់ទងនឹងការបកស្រាយសន្ធិសញ្ញា ដូចជាគោលការណ៍ Contra Proferentum។

**គោលការណ៍ Pacta sunt servanda ៖**

• ជាគោលការណ៍ដែលផ្អែកលើសញ្ញាណ«សុចរិត»

• វាគឺជាកាតព្វកិច្ចដែលរដ្ឋត្រូវគោរពវិធានច្បាប់អន្តរជាតិដែលរដ្ឋនោះបានឯកភាពជាមួយ

• គឺជាវិធានទំនៀមទម្លាប់មួយដែលត្រូវបានចងក្រងដោយមាត្រា២៦នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ៖ «រាល់សន្ធិសញ្ញាដែលមានធរមានចងភ្ជាប់គូភាគី និងត្រូវអនុវត្តដោយភាគីទាំងនេះដោយសុចរិត»។

**គោលការណ៍ Uti possedetis juris ៖**

• ជាគោលការណ៍ទូទៅនៃច្បាប់ដែលទាក់ទងទៅនឹងភាពមិនអាចរុះរើបាននៃព្រំដែនដែលបន្សល់ពីអាណានិគម។

• ជាការបម្រុងទុករបស់រដ្ឋមួយទៅលើការអនុវត្តនៃគោលការណ៍នេះចំពោះព្រំដែនភាគខាងត្បូងរបស់ខ្លួន នៅពេលចូលជាសមាជិកនៃអង្គការសហភាពអាព្រិច(OUA) (ឧទាហរណ៍ប្រទេសម៉ារ៉ុក)។

---

[១៨] *Cassese, op. cit., p. 192.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**គោលការណ៍ Rebuc sic stantibus ៖**

• *ជាគោលការណ៍ដែលចែងថា ខលក្ខខណ្ឌមួយនឹងមានន័យនៅក្នុងរាល់សន្ធិសញ្ញាដែល តាមរយៈនោះការប្រែប្រួលកាលៈទេសៈដែលមានស្រាប់នៅពេលចុះសន្ធិសញ្ញានឹងបណ្តាលឱ្យ មានអសុពលភាពរបស់វា។*

• *ការអនុវត្តគោលការណ៍អាចក្លាយទៅជាលេសមួយដែលអាចធ្វើឱ្យចុះខ្សោយនូវគោល-ការណ៍* «Pacta sunt servanda»។

• *ដូច្នេះ វាធ្វើឱ្យផុយស្រួយដល់កាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យា។*

• *អនុសញ្ញាទីក្រុងវីយែនមិនពិចារណាទៅលើ«ការប្រែប្រួលកាលៈទេសៈជាសារវន្ត»ទេ។*

• *ភាគីដែលគេបំភ្លេចត្រូវតែទាក់ទងជាមួយចៅក្រមអន្តរជាតិម្នាក់ ឬស្នើសុំឱ្យដៃគូរបស់ខ្លួន ធ្វើការពិនិត្យសន្ធិសញ្ញាឡើងវិញ។*

## ៣- កិច្ចឯកតោភាគី

*កិច្ចឯកតោភាគីគឺជាកិច្ចគតិយុត្តទាំងឡាយដែលធ្លាក់ទៅលើរដ្ឋមួយដែលធ្វើការអនុវត្តតែម្នាក់ឯង។ កិច្ចឯកតោភាគីនេះគឺជាប្រភពមួយនៃច្បាប់អន្តរជាតិ។*[១៩] *នេះគឺជាឆន្ទៈរបស់រដ្ឋដែលដើរតួយ៉ាងសំខាន់នៅក្នុងការបង្កើតវិធានច្បាប់។*

### ៣.១- អត្តសញ្ញាណកម្មនៃកិច្ចឯកតោភាគីរបស់រដ្ឋ

*កិច្ចឯកតោភាគីត្រូវបង្ហាញឱ្យច្បាស់ពីឆន្ទៈរបស់រដ្ឋ។ មិនមានលក្ខខណ្ឌទម្រង់ដើម្បីឱ្យ កិច្ចឯកតោភាគីរបស់រដ្ឋមានសុពលភាពឡើយ។*

• *កិច្ចឯកតោភាគីរបស់រដ្ឋអាចជាការប្រកាសផ្ទាល់មាត់ ឬសរសេរដែលចេញមកពីអាជ្ញាធរ មានសមត្ថកិច្ចដើម្បីចងចំណងដល់រដ្ឋ។*[២០]

• *កិច្ចឯកតោភាគីរបស់រដ្ឋអាចមានទម្រង់ជាអាកប្បកិរិយាសកម្ម ឬអកម្មផងដែរ ជាពិសេស គឺតុណ្ហីភាព(ភាពស្ងាត់ស្ងៀម)។ ការបកស្រាយពីតុណ្ហីភាពគឺជាប្រតិបត្តិការមួយដែលលំបាក ស្មុគ្រស្មាញដែលគិតគូរពីបរិបទនៃអាកប្បកិរិយា ដើម្បីស្វាបស្ទង់ស្វែងរកការបង្ហាញនូវឆន្ទៈរបស់ រដ្ឋក្នុងការសន្យា។*

• *តាមរយៈការទទួលស្គាល់ រដ្ឋមួយយល់ព្រមថា ស្ថានភាពគតិយុត្តមួយអាចត្រូវជំទាស់ នឹងខ្លួនបាន និងបង្កើតចំពោះខ្លួននូវអានុភាពគតិយុត្ត។*

---

[១៩] *CPJI, Arrêt du 5 avril 1933, រឿងក្តីស្តីពីលក្ខខន្តិកៈគតិយុត្តនៃតំបន់គ្រីនលែនដ៍ខាងកើត (Affaire du statut juridique du Groënland orienta)l (Norvege/Danemark), série A/B, n° 53.*

[២០] *ClJ, Affaire des essais nucléaires (Australie/France; Nouvelie-Zélande/ France), arrêt du 20 decembre 1974, Rec. 1974, p. 253.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

• ផ្ទុយទៅវិញ ការជំទាស់អាចអនុញ្ញាតឱ្យរដ្ឋការពារសិទ្ធិរបស់ខ្លួនបាន។ អវត្តមាននៃប្រតិកម្មរបស់ខ្លួនអាចមានតម្លៃស្មើនឹងការទទួលយល់ព្រម យោងទៅតាមកាលៈទេសៈនៃរឿងក្តី។[២១]

កិច្ចឯកតោភាគីនាំឱ្យមានការបង្កើតជាការសន្យាគតិយុត្តសម្រាប់រដ្ឋចារី។

• ការបោះបង់ ៖ រដ្ឋបោះបង់សិទ្ធិខ្លះ ឬបោះបង់មិនលើកឡើងនូវសិទ្ធិខ្លះ។ ការបោះបង់នេះត្រូវតែច្បាស់លាស់។

• ការសន្យា ៖ រដ្ឋមួយសន្យាចំពោះបណ្តារដ្ឋទីបីថាត្រូវមានឥរិយាបថណាមួយ នៅក្នុងស្ថានភាពជាក់លាក់ណាមួយ។ រដ្ឋអត្ថាគាហកនៃសិទ្ធិទីបីមិនចាំបាច់ធ្វើប្រតិកម្ម ឬទទួលយកសិទ្ធិទាំងឡាយណាដែលគេផ្តល់ឱ្យខ្លួនឡើយ។[២២]

កិច្ចឯកតោភាគីផ្សេងទៀតរបស់រដ្ឋគឺមានចំណងជាមួយនឹងសន្ធិសញ្ញាមួយ ឬទំនៀមទម្លាប់មួយ។ ការចូលជាធរមាន និងជីវិតរបស់សន្ធិសញ្ញាអន្តរជាតិត្រូវដាក់លក្ខខណ្ឌដោយការអនុម័តកិច្ចនានាដោយរដ្ឋ(ការផ្តល់សច្ចាប័ន ការចូលជាសមាជិក លក្ខខណ្ឌបម្រុង ការបដិសេធ)។ ឧទាហរណ៍ការទទួលស្គាល់យុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិដោយអនុលោមទៅតាមមាត្រា ៣៦ កថាខណ្ឌ២។

ទំនៀមទម្លាប់កើតឡើងដោយការធ្វើដដែលៗនូវស្ថានភាពពីមុនមក ដែលជាញឹកញយគឺជាកិច្ចឯកតោភាគីរបស់រដ្ឋ។

នៅក្នុងច្បាប់សមុទ្រ រដ្ឋកំណត់ប្រវែងទទឹងនៃសមុទ្រដែនដីរបស់ខ្លួនដោយឯកតោភាគី (ក្នុងលក្ខខណ្ឌដែលគោរពប្រវែងកំណត់១២ម៉ាយសមុទ្រ) ឬក៏កំណត់ប្រវែងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(នៅក្នុងប្រវែងកំណត់២០០ម៉ាយសមុទ្រ ដោយចេញពីខ្សែបន្ទាត់មូលដ្ឋាន)។

## ៣.២- វិសាលភាពនៃកិច្ចឯកតោភាគីរបស់រដ្ឋ

អានុភាពនៃកិច្ចឯកតោភាគីត្រូវដាក់លក្ខខណ្ឌដោយចរិតលក្ខណៈសាធារណៈរបស់វា។

---

[២១] នៅក្នុងរឿងក្តីស្តីពីការនេសាទ តុលាការយុត្តិធម៌អន្តរជាតិបានបញ្ជាក់ថា ខ្សែកំណត់ព្រំដែននៃតំបន់នេសាទរបស់ប្រទេសណ័រវេស៍ ត្រូវបានកំណត់ដោយរាជក្រឹត្យមួយឆ្នាំ១៩៣៥។ តុលាការសង្កេតឃើញថា ប្រព័ន្ធកំណត់ព្រំដែនរបស់ណ័រវេស៍ត្រូវបានអនុវត្តយ៉ាងទៀងទាត់ និងមិនជួបប្រទះទៅនឹងការជំទាស់ពីរដ្ឋដទៃទេ ។ តុលាការបានសង្កេតឃើញនូវ «ការអត់ឱនរបស់រដ្ឋបរទេសចំពោះការអនុវត្តរបស់ប្រទេសណ័រវេស៍»។ តុលាការបានពិនិត្យមើលលើឥរិយាបថរបស់ចក្រភពអង់គ្លេស និងបានកត់សម្គាល់ឃើញថា ចក្រភពអង់គ្លេសមិនបានបង្កើតជាលក្ខខណ្ឌបម្រុងទេ ហើយមិនអាចមិនទទួលស្គាល់រាជក្រឹត្យឆ្នាំ១៩៣៥ដែលថែមទាំងបណ្តាលឱ្យមានសំណើសុំការពន្យល់ពីសំណាក់ប្រទេសបារាំង។ តុលាការនឹងទាញហេតុផលចេញពីអវត្តមាននៃការជំទាស់របស់ចក្រភពអង់គ្លេសថា ប្រទេសណ័រវេស៍អាចយកប្រព័ន្ធកំណត់ព្រំដែនតំបន់នេសាទរបស់ខ្លួនទៅជំទាស់នឹងប្រទេសអង់គ្លេសបាន។ *(CIJ, Affaire des pecheries (Royaume-Uni/ Norvège), arrêt du 18 decembre 1951, Rec. 1951, p. 116).*

[២២] តុលារការយុត្តិធម៌អន្តរជាតិ ការពិនិត្យពីស្ថានភាព យោងតាមកថាខណ្ឌទី៦៣នៃសាលក្រមរបស់តុលាការចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៤ នៅក្នុងរឿងក្តីស្តីពីការសាកល្បងអាវុធនុយក្លេអ៊ែរ អធិបញ្ញាចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៥ *Nouvelle-Zelande/France; CIJ, Rec. 1974, § 46.*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

• កិច្ចអាចមានភាពជាក់ស្តែង និងមានគេដឹងឮគ្រប់គ្នា។[២៣]

• ការជូនដំណឹងដល់រដ្ឋដែលពាក់ព័ន្ធ ក៏អាចអនុញ្ញាតឱ្យកិច្ចបង្កើតអានុភាពបានដែរ។ ជាគោល កិច្ចឯកតោភាគីរបស់រដ្ឋបង្កើតអានុភាពចំពោះចារីរបស់វា(កិច្ចស្វ័យធម្មនិយាម-Actes autonormateurs)។ គោលការណ៍មួយក្នុងចំណោមគោលការណ៍មូលដ្ឋាននៃការបង្កើត និងអនុវត្តកាតព្វកិច្ចគតិយុត្តគឺគោលការណ៍សុទ្ធចិត្ត។[២៤] រដ្ឋត្រូវរក្សាការពារអាកប្បកិរិយាស៊ីចង្វាក់គ្នា និងមិនអាចកែប្រែការសន្យារបស់ខ្លួនទៅតាមការវិវត្តនៃផលប្រយោជន៍របស់ខ្លួនឡើយ។

• កិច្ចឯកតោភាគីអាចបង្កើតសិទ្ធិសម្រាប់រដ្ឋទីបីបាន(កិច្ចវិសមានធម្មនិយាម-Actes hétéronormateurs)។ ទោះជាយ៉ាងនេះក្តី កិច្ចទាំងនេះមិនអាចបង្កើតជាកាតព្វកិច្ចចំពោះពួកគេដោយគ្មានការព្រមព្រៀងពីពួកគេឡើយ។

# ផ្នែកទី៣

## ប្រភពបន្ទាប់បន្សំ

សេចក្តីសម្រេចជាកាតព្វកិច្ចរបស់អង្គការអន្តរជាតិ និងសេចក្តីសម្រេចរបស់តុលាការគឺជាប្រភពបន្ទាប់បន្សំនៃច្បាប់អន្តរជាតិ ពីព្រោះសេចក្តីសម្រេចទាំងនេះត្រូវបង្កើតឡើងដោយវិធានដែលកើតឡើងពីប្រភពចម្បង ដូចជាសន្ធិសញ្ញាដែលបានបង្កើតអង្គការអន្តរជាតិ ឬអង្គភាពតុលាការជាដើម។

### ១- សេចក្តីសម្រេចជាកាតព្វកិច្ចនៃអង្គការអន្តរជាតិ

អង្គការអន្តរជាតិ ដូចជាអង្គការសហប្រជាជាតិ ឬអង្គការអន្តររដ្ឋាភិបាលដូចជាអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ(OACI) អាចចេញសេចក្តីសម្រេចប្រតិបត្តិដែលអាចក្លាយជាប្រភពនៃច្បាប់អន្តរជាតិ។

[២៣] នៅក្នុងរឿងក្តីស្តីពីការនេសាទ តុលាការបានទទួចអំពីភាពដឹងឮនៃប្រព័ន្ធកំណត់ព្រំដែនតំបន់នេសាទរបស់ប្រទេសណ័រវេស៍ដែលចាំបាច់ត្រូវស្គាល់ដោយចក្រភពអង់គ្លេស «រដ្ឋជាប់ឆ្នេរសមុទ្រខាងជើងដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការនេសាទនៅក្នុងតំបន់ទាំងនេះដែលតាមប្រពៃណីមក ជាមហាអំណាចដែលមានការប្រុងប្រយ័ត្នចំពោះច្បាប់សមុទ្រ [...]» (CIJ, Rec. 1951, p. 116)។

[២៤] «ចរិតលក្ខណៈជាកាតព្វកិច្ចនៃការសន្យាអន្តរជាតិមួយដែលប្រតិបត្តិដោយការប្រកាសជាឯកតោភាគីគឺឈរទៅលើភាពសុទ្ធចិត្ត» (CIJ, Rec. 1974, § 49)។

## ១.១- វិភាគទាននៃច្បាប់អង្គការសហប្រជាជាតិចំពោះការអភិវឌ្ឍនៃនីតិអន្តរជាតិ

*មានដំណើរការបែបស្ថាប័នផ្សេងៗជាច្រើននៃការបង្កើតធម្មនិយាមនៃច្បាប់អន្តរជាតិទូទៅដោយសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។ ទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវផ្តល់នូវការបញ្ជាក់ពីដំណើរការនេះមួយចំនួន។*

*ដូច្នេះ មានសំណួរចោទឡើងអំពីអន្តរកម្មរវាងធម្មនិយាមពីរ គឺសណ្តាប់ធ្នាប់គតិយុត្តសហប្រជាជាតិ និងសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ។ គោលការណ៍ពីរអាចផ្ទុយគ្នា ចំពោះការបង្កើតធម្មនិយាមនៃច្បាប់អន្តរជាតិទូទៅដោយច្បាប់សហប្រជាជាតិ។*[២៥]

*ទីមួយ សណ្តាប់ធ្នាប់គតិយុត្តសហប្រជាជាតិគឺត្រូវកំណត់ព្រំដែន ពីព្រោះវាក្លាយចេញពីសន្ធិសញ្ញាបង្កើតអង្គការដែលធ្វើឡើងដោយរដ្ឋសមាជិកដើមដំបូង និងត្រូវកំណត់ចំពោះការគោរពគោលការណ៍ឯកទេសដែលស្ថិតនៅពីលើអង្គការអន្តរជាតិទាំងអស់។ ឧទាហរណ៍ ទោះជាច្បាប់សហប្រជាជាតិមិនគ្រប់គ្រង ឬគ្រប់គ្រងក្តី ច្បាប់អន្តរជាតិសេដ្ឋកិច្ច ឬច្បាប់វិនិយោគក៏ត្រូវស្ថិតនៅកាន់តែច្រើននៅក្រោមសមត្ថកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក ឬសមត្ថកិច្ចនៃមូលនិធិរូបិយវត្ថុពិភពលោក។*

*ការជំទាស់ទីពីរទៅនឹងអន្តរកម្មរវាងច្បាប់សហប្រជាជាតិ និងច្បាប់អន្តរជាតិទូទៅ ៖ ច្បាប់របស់អង្គការអន្តរជាតិមួយអាចបង្កើតជាច្បាប់អន្តរជាតិទូទៅបាន លុះត្រាតែច្បាប់នេះផ្អែកលើសន្ធិសញ្ញា និងគោរពទៅតាមគោលការណ៍អានុភាពមិនដាច់ខាត។*

*គេអាចកត់សម្គាល់បាននូវយន្តការស្ថាប័នពីរនៃការបង្កើតច្បាប់អន្តរជាតិដោយការសម្រេចរបស់អង្គការសហប្រជាជាតិ។ យន្តការទី១ គឺដំណើរការបង្កើតបន្តិចម្តងៗនៃច្បាប់អន្តរជាតិទូទៅដោយអនុសាសន៍គតិយុត្ត(* recommandations normatives*) និងផ្នែកក្រៅនៃមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខ។ យន្តការទី២ គឺដំណើរការបង្កើតដោយផ្ទាល់នៃច្បាប់អន្តរជាតិទូទៅដោយការសម្រេចចិត្តគតិយុត្ត និងខាងក្រៅនៃក្រុមប្រឹក្សាសន្តិសុខ។*[២៦] *នៅក្នុងក្របខ័ណ្ឌចង្អៀតនៃសេចក្តីសម្រេចទៅតាមប្រធានបទ និងខាងក្រៅនិងជាបន្ទាប់បន្សំ សេចក្តីសម្រេចតាមកាលៈទេសៈ និងប្រតិបត្តិ*[២៧] *ក្រុមប្រឹក្សាសន្តិសុខអាចនឹងបង្កើតដោយផ្ទាល់នូវធម្មនិយាមថ្មីៗនៃច្បាប់អន្តរជាតិទូទៅសម្រាប់រដ្ឋសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ ពោលគឺសម្រាប់រដ្ឋដែលមានអត្ថិភាព*

---

[២៥] *NORODOM, op. cit., p. 3.*

[២៦] *ibid., p. 7.*

[២៧] *ជាគោល គឺសេចក្តីសម្រេចតាមប្រធានបទដែលទាក់ទិនទៅនឹងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម( សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ១៣៧៣( ២០០១) ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០១) និងអាវុធប្រល័យលោក( សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ១៥៤០( ២០០៤) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ និងលេខ១៨១០( ២០០៨) ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨)ដែលប្រកាសអំពីកាតព្វកិច្ចជាក់លាក់ដែលហួសពីកាតព្វកិច្ចប្រុងប្រយ័ត្នធម្មតា និងមានដែនអនុវត្តជាបុគ្គលដែលកាន់តែធំទូលាយជាងដែនអនុសញ្ញាដែលអនុវត្តនៅក្នុងវិស័យនេះ* (*ibid., p. 10*). ។

ស្ទើរតែទាំងអស់នៅពេលបច្ចុប្បន្ននេះ។ អង្គការសហប្រជាជាតិបានបង្កើតដំណើរការ បង្កើតច្បាប់ក្រៅអំពីយន្តការបុរាណនានាដែលមានដូចជាអនុសញ្ញាអន្តរជាតិ ឬទំនៀមទម្លាប់។

ដំណើរការបង្កើតច្បាប់អន្តរជាតិកើតឡើងនៅខាងក្នុង និងក្រៅអង្គការសហប្រជាជាតិដែលបានដឹកនាំឱ្យមានការអនុម័ត(ឬគ្មាន)នូវឧបករណ៍អន្តរជាតិជាច្រើន និងឯកសារសំខាន់ៗដទៃទៀត។ ដំណើរការនេះរួមមានការបង្កើតច្បាប់ដោយដំណើរការអន្តររដ្ឋាភិបាលពហុភាគីដែលមានជាអាទិ សន្និសីទការទូត និងអង្គភាពសន្ធិសញ្ញា ព្រមទាំងសកម្មភាពមួយចំនួនរបស់អង្គការសហប្រជាជាតិនៅក្នុងការចងក្រងក្រម និងការអភិវឌ្ឍជាលំដាប់នៃច្បាប់អន្តរជាតិដោយអនុលោមតាមមាត្រា13(1) (a) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ បូករួមទាំងដំណើរការរបស់គណៈកម្មការទី៦នៃអង្គមហាសន្និបាត និងគណៈកម្មការច្បាប់អន្តរជាតិ។

## តើអ្វីទៅជាវិភាគទាននៃសេចក្តីសម្រេចអង្គការសហប្រជាជាតិចំពោះការអភិវឌ្ឍច្បាប់អន្តរជាតិ?

មានដំណើរការពីរនៃការបង្កើតច្បាប់អន្តរជាតិដោយនីតិកម្ម(ច្បាប់ក្លាយ)របស់ប្រទេសជាតិ។ យើងត្រូវបែងចែកនូវដំណើរការបន្តិចម្តងៗក្នុងការបង្កើតច្បាប់ដែលតាមរយៈនោះ ការបង្កើតច្បាប់អន្តរជាតិដោយច្បាប់សហប្រជាជាតិ មានលក្ខណៈប្រយោលពីដំណើរការដោយផ្ទាល់។ នៅក្នុងករណីដំណើរការបន្តិចម្តងៗ អានុភាពនៃសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេចឡើងទីមួយ នៅក្នុងប្រព័ន្ធគតិយុត្តរបស់សហប្រជាជាតិ ហើយជួនកាលរដ្ឋនានាត្រៀមខ្លួននឹងផ្តល់ទៅឱ្យសេចក្តីសម្រេចទាំងនេះនូវអានុភាពគតិយុត្តដែលអាចអនុវត្តក្រៅអង្គការសហប្រជាជាតិ។ នេះជាដំណើរការធម្មតា និងបុរាណនៃការបង្កើតច្បាប់អន្តរជាតិតាមរយៈនីតិកម្មរបស់អង្គការសហប្រជាជាតិ។ នេះជាអ្វីដែលយើងហៅថា ស្ថាប័នកម្មធម្មតា។

ច្បាប់នេះក៏អាចត្រូវបង្កើតដោយផ្ទាល់ចេញពីច្បាប់អន្តរជាតិទូទៅ នៅក្នុងដំណើរការមួយដែលយើងអាចហៅថាជាដំណើរការភ្លាមៗ។ សេចក្តីសម្រេចសំខាន់ៗគឺជាកាតព្វកិច្ច ហើយខ្លឹមសារជាធម្មនិយាមរបស់វាមានលក្ខណៈទូទៅ និងអរូបី។ អានុភាពគតិយុត្តនៃសេចក្តីសម្រេចទាំងនេះហួសផុតពីលំដាប់គតិយុត្តសហប្រជាជាតិ ដើម្បីឈានដល់ដោយផ្ទាល់ទៅរកលំដាប់គតិយុត្តអន្តរជាតិដោយមិនចាំបាច់ចាប់បង្ខំឱ្យរដ្ឋបង្ហាញនូវការព្រមព្រៀងច្បាស់ជាក់ស្តែងដែលស្តែងតាមរយៈបទប្បញ្ញត្តិច្បាប់ពិសេសឡើយ។ នេះជាអ្វីដែលយើងហៅថាស្ថាប័នកម្មស្មុគ្រស្មាញ។

មានដំណើរការបែបស្ថាប័នជាច្រើននៃការបង្កើតធម្មនិយាមនៃច្បាប់អន្តរជាតិទូទៅដោយសេចក្តីសម្រេចសហប្រជាជាតិ ប៉ុន្តែយើងចាំបាច់ត្រូវផ្តល់ការបញ្ជាក់លម្អិតមួយចំនួន។

បញ្ហានេះលើកឡើងនូវសំណួរអំពីអន្តរកម្មរវាងដំណើរការទាំងពីរ គឺសណ្តាប់ធ្នាប់គតិយុត្តសហប្រជាជាតិ និងសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ។ គោលការណ៍ពីរអាចផ្ទុយគ្នាទៅវិញ

*ទៅមកនៅអំឡុងពេលបង្កើតធម្មនិយាមនៃច្បាប់អន្តរជាតិទូទៅដោយអង្គការសហប្រជាជាតិ។*[២៨]

*ដំបូង សណ្តាប់ធ្នាប់គតិយុត្តរបស់អង្គការសហប្រជាជាតិគឺមានព្រំដែន ព្រោះវាមានប្រភពចេញមកពីសន្ធិសញ្ញាបង្កើតអង្គការដែលធ្វើឡើងដោយរដ្ឋសមាជិកកាលពីដំបូង និងត្រូវកំណត់នៅក្នុងគោលការណ៍ឯកទេសដែលដាក់ជូនដោយអង្គការអន្តរជាតិមួយ។ ឧទាហរណ៍ ច្បាប់សហប្រជាជាតិមិនដឹកនាំ ឬដឹកនាំច្បាប់សេដ្ឋកិច្ចអន្តរជាតិតិចតួច ហើយច្បាប់វិនិយោគស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក ឬសមត្ថកិច្ចនៃមូលនិធិរូបិយវត្ថុពិភពលោក។*

*ការជំទាស់ទីពីរទៅនឹងអន្តរកម្មរវាងច្បាប់សហប្រជាជាតិ និងច្បាប់អន្តរជាតិទូទៅ ៖ ច្បាប់របស់អង្គការអន្តរជាតិមួយអាចបង្កើតជាច្បាប់អន្តរជាតិទូទៅបាន លុះត្រាតែច្បាប់នេះផ្អែកលើសន្ធិសញ្ញា និងគោរពទៅតាមគោលការណ៍អានុភាពមិនដាច់ខាត។*

## ១.២- អង្គការអន្តរជាតិផ្សេងទៀត

*ក្រុមប្រឹក្សាអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិត្រូវបានអនុញ្ញាតឱ្យអនុម័តធម្មនិយាមទាក់ទិនទៅនឹងចរាចរណ៍តាមផ្លូវអាកាសដោយសំឡេងពីរភាគបីនៃរដ្ឋសមាជិក។*

## ២- សេចក្តីសម្រេចរបស់តុលាការ

*តាមរយៈសន្ធិសញ្ញាបង្កើតធម្មនុញ្ញរបស់ខ្លួន តុលាការអន្តរជាតិទទួលបានអំណាចចេញសេចក្តីសម្រេចដែលបានក្លាយទៅជាប្រភពនៃច្បាប់អន្តរជាតិ។ ឧទាហរណ៍សេចក្តីសម្រេចតុលាការដែលជាសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬតុលាការអន្តរជាតិស្តីពីនីតិសមុទ្រ(TIDM) ឬតុលាការមជ្ឈត្តការបានបង្កើតទៅជាប្រភពសំខាន់នៃច្បាប់ស្តីពីការកំណត់ព្រំដែនសមុទ្រ។*

---

[២៨] *ibid., p. 3.*

# ផ្នែកទី៤
# ចរិតលក្ខណៈគតិយុត្តច្បងនៃច្បាប់អន្តរជាតិ

## ១- ការវិភាគដោយប្រៀបធៀបរវាងសណ្តាប់ធ្នាប់គតិយុត្តជាតិ និងអន្តរជាតិ
### ១.១- វិធាននៃនីតិ
### ១.១.១- សណ្តាប់ធ្នាប់គតិយុត្តជាតិ

*សណ្តាប់ធ្នាប់គតិយុត្តជាតិរួមមានស្ថាប័នមជ្ឈការដែលទទួលខុសត្រូវលើ(១) ធ្វើច្បាប់ (២) ជម្រះយុត្តាធិការ និង(៣) ការអនុវត្តជម្មនិយាមគតិយុត្ត។ នៅក្នុងរដ្ឋ បុគ្គលគឺជាប្រធាននីតិចម្បង ហើយអង្គភាពគតិយុត្តដែលមានក្រុមហ៊ុន សាធារណៈ សមាគមឯកជនៗលៗ គឺជាប្រធាននៃនីតិបន្ទាប់បន្សំសុទ្ធសាធដែលមានតួនាទីមានដែនកំណត់នៅក្នុងការបង្កើត។*

### ១.១.២- សណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ

*ចរិតលក្ខណៈដំបូងនៃច្បាប់អន្តរជាតិគឺថាវិធានភាគច្រើនរបស់វា សំដៅដល់និយ័តកម្មនៃអាកប្បកិរិយារបស់រដ្ឋ មិនមែនឥរិយាបថរបស់បុគ្គលទេ។ អង្គការសហប្រជាជាតិគឺជាវិធាននីតិយ៉ាងសំខាន់។ អង្គការសហប្រជាជាតិបង្កើតច្បាប់ និងកាតព្វកិច្ចនៅលើឆាកអន្តរជាតិដែលអង្គការនេះត្រូវការពារ។*

### ១.២- អវត្តមាននៃអាជ្ញាធរកណ្តាលមួយ និងវិមជ្ឈការនៃមុខងារគតិយុត្ត
### ១.២.១- សណ្តាប់ធ្នាប់គតិយុត្តជាតិ

*ប្រព័ន្ធគតិយុត្តជាតិមានការអភិវឌ្ឍខ្លាំងណាស់។ មានយន្តការពិសេសមួយដែលទាក់ទិនទៅនឹង«ជីវិត»នៃសណ្តាប់ធ្នាប់គតិយុត្ត។ ការអភិវឌ្ឍទាំងនេះបានបណ្តាលឱ្យមានការលេចឡើងនូវក្រុមបុគ្គលមួយដែលមានអំណាចមានប្រសិទ្ធភាពនៅក្នុងសហគមន៍នៃរដ្ឋ។ រចនាសម្ព័ន្ធពិសេសមួយត្រូវបានបង្កើតឡើងដែលមានគោលដៅធ្វើស្ថាប័នកម្មដល់អំណាចមួយនេះ និងពង្រឹងទំនាក់ទំនងក្រុមដែលកាន់អំណាច និងសហការីរបស់ពួកគេ។*

*ទីមួយ ការប្រើប្រាស់កម្លាំងដោយសមាជិកនៃសហគមន៍ត្រូវបានហាមឃាត់ លើកលែងតែសម្រាប់ស្ថានភាពបន្ទាន់នានា ដូចជាស្វ័យការពារជាដើម។ អង្គការសហប្រជាជាតិជាអ្នកមានសិទ្ធិផ្តាច់មុខទៅលើការដាក់កំហិតជានិត្យានុកូល។*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទីពីរ អង្គភាពកណ្តាលដែលដើរតួក្នុងនាមសហគមន៍ទាំងមូលគឺទទួលខុសត្រូវលើមុខងារបុរាណសំខាន់ៗបីនៃរាល់ប្រព័ន្ធគតិយុត្ត( ការតាក់តែងច្បាប់ ការកំណត់អំពីច្បាប់ និងការអនុវត្តច្បាប់)។ អង្គភាពទាំងនេះត្រូវអនុវត្តអំណាចរបស់ខ្លួនសម្រាប់ជាប្រយោជន៍ដល់សហគមន៍ទាំងមូល មិនមែនសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់ខ្លួននោះទេ។

## ១.២.២- សណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ

នៅក្នុងសហគមន៍អន្តរជាតិ អំណាចត្រូវបំបែកជាផ្នែកតូចៗ និងរប៉ាត់រប៉ាយ។ ទំនាក់ទំនងរវាងរដ្ឋនៅមានភាពបណ្តោយច្រើន។ គ្មានរចនាសម្ព័ន្ធខ្សែទទឹងណាមួយបានរឹងមាំខ្លាំងទេ។

ម្យ៉ាងវិញទៀត នៅក្នុងសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ គ្មានយន្តការណាមួយដែលទទួលបន្ទុកបំពេញមុខងារទាំងបីទេ គឺការតាក់តែងច្បាប់ ការកំណត់ច្បាប់ និងការអនុវត្តច្បាប់។ មុខងារទាំងបីនេះត្រូវបានធ្វើវិមជ្ឈការទៅឱ្យស្ថាប័នផ្សេងៗ។ អង្គការសហប្រជាជាតិបានត្រឹមតែបំពេញមុខងារដែលរដ្ឋជាសមាជិកប្រគល់ឱ្យប៉ុណ្ណោះ។

នៅក្នុងច្បាប់អន្តរជាតិបុរាណ ការប្រើប្រាស់កម្លាំងជាការស្រេបច្បាប់ ទាំងសម្រាប់ធ្វើឱ្យមានការគោរពច្បាប់ និងទាំងសម្រាប់ការពារផលប្រយោជន៍សេដ្ឋកិច្ច នយោបាយ ឬផលប្រយោជន៍ផ្សេងទៀត។ ស្ថានភាពនៃទង្វើនេះបានអនុគ្រោះជាខ្លាំងដល់រដ្ឋមានអំណាចខ្លាំងៗនានា។

## ១.៣- ទំនួលខុសត្រូវសមូហភាព

នៅក្នុងលំដាប់គតិយុត្តជាតិ វាគឺជាទំនួលខុសត្រូវឯកត្តជន ៖ អ្នកដែលប្រព្រឹត្តបទល្មើសរដ្ឋប្បវេណីមួយ ឬរំលោភច្បាប់ត្រូវប្រឈមមុខនឹងទណ្ឌកម្ម។ គេត្រូវផ្តល់សំណងជំងឺចិត្ត ឬក្នុងករណីបទឧក្រិដ្ឋ អាចនឹងមានទណ្ឌកម្មព្រហ្មទណ្ឌ។ មានការលើកលែងខ្លះ។ ការលើកលែងទីមួយ គឺ«ទំនួលខុសត្រូវលើអំពើអ្នកដទៃ» ៖ មនុស្សម្នាក់ទទួលខុសត្រូវលើអំពើដែលប្រព្រឹត្តដោយបុគ្គលម្នាក់ដែលជាមួយបុគ្គលនេះ បុគ្គលមុនមានចំណងពិសេស( ឪពុក ឬម្តាយម្នាក់ក៏ជាអ្នកទទួលខុសត្រូវលើការខូចខាតដែលបង្កដោយកូនរបស់ខ្លួន) ក្រុមមួយទាំងមូលក៏ត្រូវទទួលខុសត្រូវលើអំពើដែលប្រព្រឹត្តដោយតំណាងម្នាក់ក្នុងនាមរបស់ក្រុម( ដូចនៅក្នុងទំនួលខុសត្រូវរដ្ឋប្បវេណីរបស់សហគ្រាសចំពោះទោសមជ្ឈិម)។

នៅក្នុងប្រព័ន្ធគតិយុត្តអន្តរជាតិ ភ្នាក់ងារម្នាក់របស់រដ្ឋអាចរំលោភច្បាប់អន្តរជាតិបាន។ យោធាម្នាក់អាចទទួលបញ្ជាពីមេបញ្ជាការដើម្បីហោះរំលោភចូលដែនអាកាសរបស់រដ្ឋជិតខាង ឬនាយនគរបាលម្នាក់រំលោភអភ័យឯកសិទ្ធិការទូតដោយការឃាត់ខ្លួនអ្នកការទូត ឬជនទុច្ចរិតម្នាក់។

នៅក្នុងករណីទាំងនេះ រដ្ឋដែលទទួលការខូចខាតមានសិទ្ធិ«សងសឹក»ទៅលើសហគមន៍



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាំងមូលរបស់ភ្នាក់ងាររដ្ឋខាងលើ ទោះបីជាសហគមន៍មិនបានប្រព្រឹត្ត និងបញ្ជាឱ្យប្រព្រឹត្តបទល្មើសក៏ដោយ។ ឧទាហរណ៍ រដ្ឋដែលបានក្លាយជាជនរងគ្រោះពីការបំពានជាអន្តរជាតិអាចស្នើសុំសំណងជាប្រាក់មួយចំនួន( ដែលនឹងត្រូវគិតគូរចេញពីរតនាគារសាធារណៈ) ឬនឹងប្រើប្រាស់វិធានការប្រឆាំង( ការសងសឹក)ទៅនឹងបុគ្គលដែលព្យាបាទ ក្រៅពីចារីពិតប្រាកដនៃបទល្មើស (ឧទាហរណ៍ការបណ្ដេញជនបរទេស ការព្យួរសន្ធិសញ្ញាពាណិជ្ជកម្ម និងសកម្មភាពផ្សេងៗទៀត)។ ក្នុងពេលដំណាលគ្នា ទំនួលខុសត្រូវសមូហភាពមានន័យថា រាល់សហគមន៍របស់រដ្ឋត្រូវទទួលខុសត្រូវលើរាល់ការរំលោភច្បាប់អន្តរជាតិដែលប្រព្រឹត្តដោយមន្ត្រីម្នាក់របស់រដ្ឋ។

**និន្នាការថ្មីពីរបានកែប្រែរូបភាពជាប្រពៃណី។**

ជាបឋម នៅក្បែរទំនួលខុសត្រូវរបស់រដ្ឋប្រពៃណី ចំពោះបទល្មើស«ធម្មតា»ទៅលើវិធានអន្តរជាតិ ចំណាត់ថ្នាក់មួយថ្មីនៃទំនួលខុសត្រូវរបស់រដ្ឋបានលេចឡើងចេញពីការរំលោភជាក់ស្ដែងទៅលើវិធានជាសារវន្តស្ដីពីតម្លៃសំខាន់ៗ( ទំនួលខុសត្រូវដែលហៅថា «ធ្ងន់ធ្ងរ»)។

ទីពីរ ត្រូវបានចាត់ទុកថា បទល្មើសធ្ងន់ធ្ងរដែលប្រព្រឹត្តឡើងដោយភ្នាក់ងាររបស់រដ្ឋនៅក្នុងកាលៈទេសៈពិសេស ឧទាហរណ៍ឧក្រិដ្ឋកម្មសង្គ្រាម ត្រូវតែនាំឱ្យមានទំនួលខុសត្រូវជាបុគ្គលពីសំណាក់ចារីនៃបទល្មើសនេះ។

## ១.៤- អវត្តមាននៃឋានានុក្រមនៅក្នុងនីតិអន្តរជាតិសាធារណៈ

ប្រព័ន្ធគតិយុត្តអន្តរជាតិមិនបានបែងចែកជាឋានានុក្រមទេ។ វិធានគតិយុត្តទាំងនេះសមមូលរវាងគ្នានឹងគ្នា។ ប្រភពនៃច្បាប់ក៏សមមូលរវាងគ្នានឹងគ្នាដែរ។ ប្រភពឥតសរសេរដូចជាទំនៀមទម្លាប់ ឬគោលការណ៍ទូទៅនៃច្បាប់មានតម្លៃដូចគ្នានឹងសន្ធិសញ្ញា និងអត្ថបទសរសេរ។ ឧទាហរណ៍ ទំនៀមទម្លាប់មួយអាចកែសម្រួលសន្ធិសញ្ញាមួយ ឬបញ្ច្រាស់មកវិញក៏បាន។

ប៉ុន្តែមានជាតុមួយចំនួននៃឋានានុក្រមកម្ម ៖

### ១.៤.១- Jus Cogens

( បញ្ញត្តិដែលត្រូវតែគោរព)

ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ វិធានទំនៀមទម្លាប់មួយបានវិវត្តនៅក្នុងសហគមន៍អន្តរជាតិដែលនេះមានអានុភាពធ្វើឱ្យនិយាមទូទៅមួយចំនួនមានតម្លៃគតិយុត្តដូចវិធានដទៃ និងគោលការណ៍ធំៗជាសារវន្តនៃច្បាប់អន្តរជាតិដែលរដ្ឋមិនអាចបដិប្បញ្ញត្តដោយកិច្ចព្រមព្រៀងអន្តរជាតិឡើយ។ បញ្ញើធម្មនិយាមបញ្ហានេះត្រូវបានហៅថា Jus Cogens ដែលគ្មានបដិប្បញ្ញត្តិណាមួយត្រូវបាន

អនុញ្ញាតឡើយ។[២៩] បើរដ្ឋចុះកិច្ចព្រមព្រៀងទាំងនេះ កិច្ចព្រមព្រៀងទាំងនេះក្លាយជាមោឃៈ និងមិនបានការ។ Jus Cogens គឺជាបណ្តុំនៃវិធានសណ្តាប់ធ្នាប់សាធារណៈដែលគេមិនអាចបដិប្បញ្ញត្តបាន ទោះជាតាមរយៈសន្ធិសញ្ញា(អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩)។ ឧទាហរណ៍ បទប្រល័យពូជសាសន៍ ឬការធ្វើទារុណកម្មត្រូវបានទទួលស្គាល់ថាស្ថិតនៅក្រោមគោលការណ៍ Jus Cogens។

នៅក្នុងការអនុវត្ត ការព្យាយាមប៉ុនប៉ងរបស់អ្នកច្បាប់ក្នុងការធ្វើចំណាត់ថ្នាក់វិធាន សិទ្ធិ និងកាតព្វកិច្ចមួយចំនួនដែលស្ថិតនៅក្នុងគោលការណ៍ Jus Cogens ឬបញ្ញត្តិដែលត្រូវតែគោរព មិនបានទទួលជោគជ័យឡើយ។ ទោះជាមានការព្រមព្រៀងស្ទើរតែទាំងស្រុងទៅលើអត្ថិភាពនៃប្រភេទធម្មនិយាម Jus Cogens ប៉ុន្តែមានការព្រមព្រៀងតិចតួចទៅលើខ្លឹមសារពិតប្រាកដនៃធម្មនិយាម។ ឧទាហរណ៍នៃធម្មនិយាម Jus Cogens មានដូចខាងក្រោម ៖ ការហាមមិនឱ្យប្រើប្រាស់កម្លាំង ច្បាប់ស្តីពីអំពើប្រល័យពូជសាសន៍ គោលការណ៍មិនប្រកាន់ពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងវិធានហាមឃាត់ពាណិជ្ជកម្មទាសករ ឬពាណិជ្ជកម្មមនុស្ស។

### ១.៤.២- Erga Omnes

(Erga Omnes គឺជាសំនួនសេចក្តីភាសាឡាតាំងដែលមានន័យដោយត្រង់ថា «ចំពោះមនុស្សទាំងអស់គ្នា» ឬ «សំដៅដល់មនុស្សគ្រប់គ្នា»)។

នៅក្នុងវាក្យសព្ទគតិយុត្ត វិធាន Erga Omnes នៃសិទ្ធិ និងកាតព្វកិច្ចគឺសំដៅដល់មនុស្សគ្រប់គ្នា។ ឧទាហរណ៍ សិទ្ធិកម្មសិទ្ធិគឺជាសិទ្ធិ Erga Omnes ហើយដូច្នេះ គឺអាចជំទាស់បានចំពោះរាល់បុគ្គលដែលបានប៉ះពាល់ទៅលើសិទ្ធិនេះ។ នៅទីនេះ សិទ្ធិ Erga Omnes (សិទ្ធិ)អាចបែងចែកដាច់ចេញពីច្បាប់មួយដែលផ្អែកលើកិច្ចសន្យាដែលមិនអាចជំទាស់បានទៅនឹងភាគីកិច្ចសន្យា។

នៅក្នុងច្បាប់អន្តរជាតិ វិធាននេះត្រូវបានប្រើប្រាស់ជាពាក្យគតិយុត្តដែលពណ៌នាពីកាតព្វកិច្ចដែលរដ្ឋចងចំពោះសហគមន៍រដ្ឋនៅក្នុងភាពជាទូទៅ។ កាតព្វកិច្ច Erga Omnes មួយមានអត្ថិភាពដោយហេតុតែមានប្រយោជន៍សាកល និងមិនអាចប្រកែកបាននៅក្នុងការធ្វើឱ្យបិតស្ថេរនូវសិទ្ធិជាសារវន្ត(និងការបង្ការមិនឱ្យមានការរំលោភទៅលើវា)។ ជាផលវិបាក គ្រប់រដ្ឋមានសិទ្ធិប្តឹងពីការរំលោភមួយ។ ឧទាហរណ៍នៃធម្មនិយាម Erga Omnes រួមមានការប្លន់ អំពើប្រល័យពូជសាសន៍ ទាសភាព ទារុណកម្ម និងការរើសអើងពូជសាសន៍។

ក៏មានកាតព្វកិច្ច Erga Omnes ដែលអនុវត្តចំពោះរដ្ឋសមាជិកទាំងអស់នៃសហគមន៍អន្តរជាតិ(ឬក្នុងករណីសន្ធិសញ្ញាពហុភាគី គឺគ្រប់រដ្ឋជាគូភាគីកិច្ចសន្យាទាំងអស់) ហើយមិនអាច

---

[២៩] *Ian Brownlie,* Principles of Public International Law *(5e éd., Oxford, 1998).*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រំលោភបាន ដូចជា Erga Omnes ប៉ុន្តែតុលាការយុត្តិធម៌អន្តរជាតិមិនបានទទួលស្គាល់ឧត្តមភាពរបស់វាទេ។[៣០]

កំណត់សម្គាល់ល្បីមួយក្នុងពេលជំនុំ(កំណត់សម្គាល់ដែលធ្វើឡើងដោយចៅក្រមម្នាក់) នៅក្នុងសាលដីកាតុលាការយុត្តិធម៌អន្តរជាតិចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧០ ស្តីពីរឿងក្តី Barcelona Traction, [(បែលហ្សិចទល់នឹងអេស្ប៉ាញ) (ជំហានទី២), CIJ Recueil 1970 3 នៅកថាខណ្ឌទី ៣៣]:

«៣៣. នៅពេលរដ្ឋមួយអនុញ្ញាតឱ្យមានការវិនិយោគនៅបរទេស ឬការវិនិយោគរបស់អាណិកជនបរទេស រូបវន្តបុគ្គល ឬនីតិបុគ្គល រដ្ឋនេះត្រូវតែផ្តល់ការការពារច្បាប់ដល់ពួកគេ និងត្រូវទទួលរ៉ាប់រងលើកាតព្វកិច្ចស្តីពីប្រព្រឹត្តកម្មដែលត្រូវផ្តល់ឱ្យពួកគេ។ ទោះជាយ៉ាងនេះក្តី កាតព្វកិច្ចទាំងនេះមិនមានភាពដាច់ខាត និងមិនមានខបម្រុងទុកឡើយ។ ជាពិសេសការបែងចែកជាសារវន្តត្រូវធ្វើឡើងរវាងកាតព្វកិច្ចរបស់រដ្ឋចំពោះសហគមន៍អន្តរជាតិទាំងមូល និងកាតព្វកិច្ចដែលកើតឡើងចំពោះរដ្ឋដទៃមួយទៀតនៅក្នុងវិស័យការពារការទូត។ តាមធម្មជាតិរបស់ពួកវា កាតព្វកិច្ចដំបូងទាក់ទងនឹងគ្រប់រដ្ឋទាំងអស់។ ផ្អែកលើសារៈសំខាន់នៃសិទ្ធិដែលពាក់ព័ន្ធ គ្រប់រដ្ឋទាំងអស់អាចត្រូវចាត់ទុកថាមានអត្ថប្រយោជន៍គតិយុត្តចំពោះការការពាររបស់ពួកគេ ទាំងនេះគឺជាកាតព្វកិច្ច Erga Omnes»។

## ២- សេរីភាពនៃអំពើរបស់រដ្ឋ

នៅក្នុងសណ្តាប់ធ្នាប់ជាតិ បុគ្គលឯកជនដែលជាប្រធានគតិយុត្តបឋម ទទួលបាននូវសេរីភាពដ៏ធំមួយនៅក្នុងប្រតិបត្តិការឯកជនរបស់ពួកគេ។ ពួកគេអាចចុះកិច្ចព្រមព្រៀងផ្សេងៗជាមួយនឹងបុគ្គលដទៃ អាចបង្កើតសហគ្រាស សមាគម និងអ្វីៗផ្សេងទៀតបាន។ សេរីភាពចុះកិច្ចសន្យាទូលំទូលាយរបស់ពួកគេមិនមានភាពដាច់ខាតទេ។ គេមិនអាចធ្វើប្រតិបត្តិការឯកជនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងសីលធម៌ឡើយ(ដូចជាកិច្ចសន្យាមួយដែលតាមរយៈនោះភាគីម្ខាងសន្យាប្រគល់សាច់ញាតិម្នាក់ឱ្យភាគីម្ខាងទៀត ដើម្បីជាគោលដៅពេស្យាចារជាដើម) ហើយបើប្រតិបត្តិការនេះកើតឡើង ប្រតិបត្តិការនេះត្រូវមានមោឃភាព និងមិនមានគេដឹងឮឡើយ។

គួរតែកត់សម្គាល់ថា ការបញ្ញាជាសាធារណៈជាតិរួមមានធម្មនិយាមដែលហាមឃាត់រូបវន្តបុគ្គលមិនឱ្យប្រើប្រាស់ខ្លួនប្រាណ ឬសេរីភាពរបស់ពួកគេទេ។ ដូច្នេះ កិច្ចសន្យាមួយដែលតាមរយៈនោះភាគីម្ខាងសន្យាកាត់ខ្លួនប្រាណរបស់ខ្លួន ឬប្រគល់អវយវៈណាមួយរបស់ខ្លួនទៅឱ្យភាគីទីបី គឺជាធម្មតាត្រូវតែផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ហើយជាផលវិបាក កិច្ចសន្យានេះត្រូវតែ

[៣០] *CIJ, 1995,* Timor Case-Orient *(Portugal / Australie), Rec. 1995, p. 102).*

មោឃៈ និងមិនមានការដឹងឮ។

ជាពិសេសទៅទៀត បុគ្គលឯកជនមិនត្រូវបានអនុញ្ញាតឱ្យបដិប្បញ្ញត្តតម្លៃជាសារវន្តមួយចំនួនដែលមានក្តីសង្ឃឹមខ្ពស់ថានឹងបញ្ចូលទៅក្នុងវិធានទាំងឡាយដែលគ្រប់គ្រងអាកប្បកិរិយាឧក្រិដ្ឋឡើយ។

ក៏ប៉ុន្តែ ប្រធាននៃសហគមន៍អន្តរជាតិទទួលបានសេរីភាពយ៉ាងធំទូលាយដើម្បីធ្វើសកម្មភាព។ នៅក្នុងច្បាប់អន្តរជាតិបុរាណ តាមពិតទៅសេរីភាពរបស់ពួកគេមិនមានឧបសគ្គទេ។ នៅក្នុងច្បាប់អន្តរជាតិទំនើប ការកំហិតគតិយុត្តមួយចំនួនត្រូវបានបង្កើតឡើង។

អនុលោមតាមច្បាប់ រដ្ឋបុរាណទទួលបានសមត្ថកិច្ចមួយធំទូលាយ ទាក់ទិននឹងការរៀបចំបង្កើតផ្ទៃក្នុងរបស់ខ្លួន។ សហគមន៍អន្តរជាតិមិនអាចលូកដៃនៅក្នុងវិធីរៀបចំប្រព័ន្ធនយោបាយរបស់រដ្ឋមួយបានឡើយ។ រដ្ឋទាំងអស់មានសេរីភាពបង្កើតរចនាសម្ព័ន្ធអំណាចផ្តាច់ការមួយ ឬគោរពគោលការណ៍ប្រជាធិបតេយ្យ អាចបង្កើតសភាមួយ ឬបង្កើតសភាដោយគ្មានសភាតំណាងណាមួយ អាចមានមហាក្សត្រមួយអង្គ ឬរដ្ឋាភិបាលតាមលទ្ធិប្រជាធិបតេយ្យ។

ក្រៅពីនេះ ច្បាប់អន្តរជាតិមិនអាចស្នើសុំឱ្យរដ្ឋមួយរៀបចំសណ្តាប់ធ្នាប់គតិយុត្តផ្ទៃក្នុងរបស់ខ្លួនទេ។ ជាករណីលើកលែងខ្លះ( ឧទាហរណ៍វិធានទំនៀមទម្លាប់អន្តរជាតិស្តីពីប្រព្រឹត្តកម្មជនបរទេស ឬអភ័យឯកសិទ្ធិដែលត្រូវផ្តល់ជូនអ្នកការទូតបរទេស) រដ្ឋគឺមានសេរីភាពយ៉ាងពេញលេញក្នុងការសម្រេចពីខ្លឹមសារ និងវិសាលភាពនៃនីតិកម្មផ្ទៃក្នុងរបស់ខ្លួន។ និយាយជាថ្មីម្តងទៀត ច្បាប់អន្តរជាតិទូទៅមិនបានទាក់ទិននៅក្នុងកិច្ចការបែបនេះទេ។

សណ្តាប់ធ្នាប់គតិយុត្តបានអនុញ្ញាតឱ្យរដ្ឋប្រើកម្លាំង តាមដែលខ្លួនប្រាថ្នា និងសម្រាប់មូលហេតុណាមួយដែលបានជ្រើសរើស។ រដ្ឋអាចនឹងចូលធ្វើសង្គ្រាម ឬប្រើប្រាស់វិធានការបង្ខំនៅពេលជិតមានសង្គ្រាម ឬចំពោះមូលហេតុដែលសិទ្ធិមួយរបស់រដ្ឋត្រូវបានរំលោភ ឬពីព្រោះរដ្ឋចាត់ទុកថា ក្នុងវិស័យនយោបាយ ឬសេដ្ឋកិច្ច វានឹងមានផលប្រយោជន៍ខ្លាំងក្នុងការវាយប្រហាររដ្ឋមួយទៀត( ឧទាហរណ៍ដើម្បីកាន់កាប់ទឹកដីជាឧបសម្ព័ន្ធមួយផ្នែក ឬទាំងមូល ឬដើម្បីបង្កើតរដ្ឋាភិបាលដែលស្ថិតនៅក្នុងសេវភាពនៃការបញ្ជារបស់ពួកគេ។ល។)។ ច្បាប់មានភាព«សប្បុរស»ខ្លាំងក៏ដើម្បីអនុញ្ញាតឱ្យរដ្ឋធ្វើអន្តរាគមន៍នៅក្នុងកិច្ចការផ្ទៃក្នុង និងអន្តរជាតិនៃសមាជិកដទៃរបស់សហគមន៍អន្តរជាតិ ទោះជាតាមសម្ពាធនយោបាយ ឬដោយគំរាមប្រើប្រាស់កម្លាំងក៏ដោយ នៅក្នុងគោលបំណងធ្វើឱ្យរដ្ឋរងគ្រោះពីការធ្វើអន្តរាគមន៍កែប្រែនយោបាយរបស់ខ្លួន។

លើសពីនេះទៀត នៅពេលរដ្ឋសន្យាគ្នានឹងដាក់វិវាទរបស់ពួកគេទៅឱ្យអាជ្ញាធរមជ្ឈត្តការរដ្ឋជាទូទៅត្រូវបានដកចេញពីកាតព្វកិច្ចដែលត្រូវដាក់ជម្លោះទាំងអស់ដែលកើតឡើងនៅក្នុង«ផលប្រយោជន៍ជាអាយុជីវិត»របស់ពួកគេទៅឱ្យតុលាការមជ្ឈត្តការដោះស្រាយ ហើយរដ្ឋនីមួយៗ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រក្សាសិទ្ធិនឹងសម្រេចថា តើករណីពិសេសណាដែលស្ថិតនៅក្នុងការដោះស្រាយប្រភេទនេះ។ សេរីភាពនៅក្នុងវិស័យសេដ្ឋកិច្ចធំទូលាយជាងនេះទៅទៀត។

អវត្តមាននៃការបង្ខិតបង្ខំគតិយុត្តក៏បានអនុញ្ញាតឱ្យរដ្ឋព្រមព្រៀងជាមួយរដ្ឋដទៃថា រដ្ឋមួយក្នុងចំណោមនោះនឹងត្រូវរលត់បាត់បង់។ រដ្ឋទាំងពីរអាចចុះកិច្ចព្រមព្រៀងដែលតាមរយៈនោះរដ្ឋមួយត្រូវបញ្ចូលទៅក្នុងរដ្ឋមួយទៀត ឬរដ្ឋទាំងនេះអាចរលាយចូលគ្នាតែមួយ ឬរដ្ឋមួយក្នុងចំណោមរដ្ឋទាំងពីរយល់ព្រមនឹងប្រគល់ទឹកដីខ្លួនមួយផ្នែកទៅឱ្យរដ្ឋមួយទៀត។ គ្មានវិធានបញ្ញាណាមួយហាមឃាត់ការបំបែករដ្ឋដោយខ្លួនឯង ឬការបំផ្លាញខ្លួនឯងទេ។

ចាប់តាំងពីសង្គ្រាមលោកលើកទីមួយមក សេរីភាពឥតព្រំដែនរបស់រដ្ឋត្រូវបានដាក់នៅក្រោមការដាក់កម្រិតកាន់តែច្រើនឡើយ។ មានកត្តាបីដែលពន្យល់ពីការអភិវឌ្ឍថ្មីៗនៅក្នុងវិស័យនេះ។

ជាបឋម ដែននៃបណ្ដាញសន្ធិសញ្ញាអន្តរជាតិមានការរាតទីយ៉ាងពេញទំហឹង។ ចាប់ពីពេលនេះតទៅ រដ្ឋភាគច្រើនសុទ្ធសឹងជាភាគីនៃសន្ធិសញ្ញាមួយចំនួនធំដែលជាន់ទៅលើប្រព័ន្ធគតិយុត្តជាតិ។ ហេតុដូចនេះ នៅពេលសព្វថ្ងៃនេះ សមាជិកភាគច្រើននៃសហគមន៍អន្តរជាតិត្រូវតែគោរពទៅតាមកាតព្វកិច្ចមួយចំនួនធំដែលកំហិតកម្រិតយ៉ាងខ្លាំងទៅលើសមត្ថកិច្ចរបស់ពួកគេទាំងនៅកម្រិតប្រព័ន្ធផ្ទៃក្នុងរបស់រដ្ឋ និងទាំងនៅក្នុងកម្រិតសេរីភាពនៅលើឆាកអន្តរជាតិ។ រដ្ឋជាច្រើនបានធ្វើការសន្យាផ្សេងៗនៅក្នុងវិស័យពាណិជ្ជកម្ម នយោបាយ និងសហប្រតិបត្តិការផ្នែកតុលាការនៅក្នុងវិស័យសិទ្ធិមនុស្ស និងវិស័យផ្សេងៗទៀត។

ហេតុផលសំខាន់ទីពីរ គឺចំនួនកើនឡើងនៃការដាក់កំហិតគតិយុត្តទៅលើសិទ្ធិប្រើប្រាស់កតិកាសញ្ញាជាធរមាន។ ច្បាប់នៃសម្ព័ន្ធប្រជាជាតិឆ្នាំ១៩១៩បានដាក់ការបង្ខិតបង្ខំជាច្រើនទៅលើរដ្ឋមួយចំនួន។ ជំនួយទាំងនេះបានដាក់កំហិតកម្រិតទៅលើអំណាចធ្វើសង្គ្រាមដល់ប្រទេសទាំងនេះ។ ធម្មនុញ្ញអង្គការសហប្រជាជាតិបានហាមឃាត់សមាជិករបស់ខ្លួនមិនឱ្យប្រើប្រាស់ ឬមិនឱ្យគំរាមប្រើប្រាស់កម្លាំងយោធាគ្រប់ប្រភេទ។

ទីបី នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ វិធានទំនៀមទម្លាប់មួយបានវិវត្តនៅក្នុងសហគមន៍អន្តរជាតិដែលមានអានុភាពធ្វើឱ្យធម្មនិយាមទូទៅមួយចំនួនមានតម្លៃគតិយុត្តដូចវិធានដទៃទៀត ហើយដែលរដ្ឋមិនអាចបដិប្បញ្ញត្តតាមរយៈកិច្ចព្រមព្រៀងអន្តរជាតិបានទេ។ បណ្ដុំធម្មនិយាមបញ្ញានេះត្រូវបានហៅថាវិធាន *Jus Cogens*។

## កាតព្វកិច្ចសហគមន៍ និងច្បាប់សហគមន៍

តម្លៃថ្មីៗបានលេចឡើងនៅក្នុងសហគមន៍អន្តរជាតិ និងត្រូវបានចាត់ទុកថាសមរម្យជាការការពារពិសេសមួយ។

ក្រោយសង្គ្រាមលោកលើកទីមួយ ដោយហេតុតែមានសម្ពាធមនោគមន៍វិជ្ជា និងនយោបាយនៃលទ្ធិសង្គមនិយម និងក៏ព្រោះតែបន្ទាប់ពីមានគ្រោះថ្នាក់ដោយសង្គ្រាម គេបានជឿថាស្ថានភាពរបស់កម្មករកាន់តែអាក្រក់ ហើយចំនួនកម្មករត្រូវបានចាត់ទុកថា ជាគុណូបការៈនៃក្ដីកង្វល់អន្តរជាតិមួយ។ ជាផលវិបាក អង្គការពលកម្មអន្តរជាតិ(OIT) ត្រូវបានបង្កើតឡើង ហើយអនុសញ្ញាអន្តរជាតិនានាសម្រាប់ការគាំពារកម្មករបានចាប់ផ្ដើមតាក់តែង និងអនុម័ត ហើយការអនុវត្តស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អង្គការពលកម្មអន្តរជាតិ។

ក្រោយសង្គ្រាមលោកលើកទីពីរ ជាប្រតិកម្មតបទៅនឹងការសម្លាប់រង្គាលទៅលើក្រុមជាតិពន្ធុ និងសាសនា(ភាគច្រើនជនជាតិជ្វីស និងស៊ីហ្គាន)ដោយពួកណាហ្ស៊ី និងការមើលងាយមើលថោកពេញទីចំពោះសិទ្ធិជាសារវន្តរបស់បុគ្គលរាប់ពាន់នាក់ទាំងនៅប្រទេសអាល្លឺម៉ង់ និងនៅកន្លែងដទៃ ក្រុមសម្ព័ន្ធមិត្តបានសម្រេចបង្កើតឱ្យមានការជានាល្អៗបំផុតប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងទៀត។ បញ្ហានេះបានជំរុញឱ្យអង្គការសហប្រជាជាតិអនុម័តបម្រាមឃាត់ទូទៅមួយចំពោះរាល់ទម្រង់នៃការរំលោភបំពាន។ តម្លៃថ្មីៗទាំងនេះបានបណ្ដាលឱ្យមានសន្ធិសញ្ញាអន្តរជាតិជាច្រើន ព្រមទាំងវិធានទំនៀមទម្លាប់អន្តរជាតិមួយចំនួន។

កាតព្វកិច្ចសហគមន៍មានចរិតលក្ខណៈទោលដូចខាងក្រោម ៖

• គឺជាកាតព្វកិច្ចការពារតម្លៃជាសារវន្ត(ដូចជាសន្តិភាព សិទ្ធិមនុស្ស ស្វ័យប្រណិធានរបស់ប្រជាជន ការការពារបរិស្ថាន។

• គឺជាកាតព្វកិច្ច Erga Omnes គឺសំដៅដល់រដ្ឋសមាជិកទាំងអស់នៃសហគមន៍អន្តរជាតិ (ឬនៅក្នុងករណីសន្ធិសញ្ញាពហុភាគី គឺរដ្ឋភាគីកិច្ចសន្យាទាំងអស់ផ្សេងទៀត)។

• កាតព្វកិច្ចទាំងនេះមានតាមពីក្រោយដោយសិទ្ធិសហសម្ព័ន្ធមួយដែលជាកម្មសិទ្ធិរបស់រដ្ឋទាំងអស់(ឬរបស់រដ្ឋភាគីកិច្ចសន្យាទាំងអស់ផ្សេងទៀតនៅក្នុងករណីនៃកាតព្វកិច្ចដែលបានចែងនៅក្នុងសន្ធិសញ្ញាពហុភាគី)។

• សិទ្ធិនេះអាចអនុវត្តដោយ(អំណាច)ផ្សេងទៀតទាំងអស់របស់រដ្ឋ ប្រសិនបើសិទ្ធិនេះត្រូវបានប៉ះពាល់ជាក់ស្ដែង ឬតាមផ្លូវចិត្ត ឬមិនប៉ះពាល់ដោយការរំលោភបំពាន។

• ច្បាប់ត្រូវអនុវត្តក្នុងនាមសហគមន៍អន្តរជាតិទាំងមូល(ឬសហគមន៍នៃរដ្ឋជាភាគីកិច្ចសន្យា) ដើម្បីរក្សាការពារតម្លៃជាសារវន្តនៃសហគមន៍នេះ(ឧទាហរណ៍ នៅពេលរដ្ឋមួយធ្វើការព្រមាន ឬជំទាស់ខ្លាំងក្លាទៅនឹងរដ្ឋដទៃមួយទៀត ដោយហេតុតែភាពព្រៃផ្សៃប្រព្រឹត្តដោយរដ្ឋចុងក្រោយនេះចំពោះអាណិកជនរបស់ខ្លួន ហើយទាមទារឱ្យបញ្ឈប់ភាពព្រៃផ្សៃទាំងនេះភ្លាមៗ រដ្ឋនេះគឺមិនមែនប្រតិកម្មដោយបំណងការពារផលប្រយោជន៍ផ្ទាល់ខ្លួន ឬដើម្បីចៀសវាងការខូចខាតដែលអាចនឹងកើតឡើងនៅពេលខាងមុខឡើយ គោលបំណងតែមួយគត់(ឬបឋម)របស់រដ្ឋនេះ គឺ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ការពារតម្លៃមនុស្សធម៌ក្នុងនាមសហគមន៍អន្តរជាតិទាំងមូល។) ដូច្នេះច្បាប់ទាំងនេះអាចចាត់ទុកថាជា«ច្បាប់របស់សហគមន៍»។*

## យុត្តាធិការកម្មនៃច្បាប់អន្តរជាតិ

*ការកើនឡើងចំនួនលំដាប់គតិយុត្តជាអន្ទើ ឬ(ស្ទើរតែ)ស្វយ័ត(ច្បាប់ពាណិជ្ជកម្ម ច្បាប់បរិស្ថាន-ល-)។ ការកើនឡើងនូវយុត្តាធិការជាតិ និងអន្តរជាតិដែលវិនិច្ឆ័យទៅលើបញ្ហានៃនីតិអន្តរជាតិសាធារណៈ។*

## វិធានចម្បង និងវិធានបន្ទាប់បន្សំ

*សម្រាប់អ្វីដែលជាវិធានចម្បង(មានន័យថាជាធម្មនិយាមស៊ីជម្រៅដែលដោះស្រាយអំពីប្រធានបទណាមួយ) វិសាលភាពរបស់វាជាគោលការណ៍ គឺគ្មានដែនកំណត់ឡើយ(លើកលែងតែឆន្ទៈតែមួយគត់របស់រដ្ឋដែលអនុម័ត ឬទទួលស្គាល់វិធានទាំងនេះចេញ)។*

## របបពហុភាគីនិយមដែលកើនឡើង និងផ្អែកលើប្រព័ន្ធសហប្រជាជាតិ ៖

*ជាប្រព័ន្ធមួយដែលផ្អែកច្រើនទៅលើច្បាប់អនុសញ្ញាដែលប្រើប្រាស់ច្បាប់ទំនៀមទម្លាប់សម្រាប់បញ្ហាជាសារវន្តខ្លះ និងដើម្បីបំពេញកង្វះខាតនៅក្នុងប្រព័ន្ធ។*

*វិធានបន្ទាប់បន្សំកំណត់នូវនីតិវិធីដែលតាមរយៈនោះ វិធានមួយក្លាយទៅជាវិធានចង្អៀតនៃច្បាប់ទំនៀមទម្លាប់ និងច្បាប់សន្ធិសញ្ញា-ល-។ អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ១៩៦៩ កំណត់និយមន័យនៃ«បច្ចេកវិទ្យាកិច្ចសន្យា»នៃសន្ធិសញ្ញាដោយផ្អែកលើច្បាប់ទំនៀម-ទម្លាប់។*

*ជារួម ច្បាប់អន្តរជាតិសាធារណៈគឺជា«វិធានដែលកំណត់សិទ្ធិ និងកាតព្វកិច្ចនានារបស់រដ្ឋនៅក្នុងទំនាក់ទំនងទៅវិញទៅមករបស់ពួកគេ។»*

## ច្បាប់ទន់(*Soft Law*)

*គេវែកញែករវាងធម្មនិយាមគតិយុត្ត និងធម្មនិយាមស្ទើរតែជាកាតព្វកិច្ច(«Soft Law» ជាតំបន់ប្រផេះមួយរវាងច្បាប់ និងភាពគ្មានច្បាប់(non-droit) ឬរវាងច្បាប់ដូចដែលមានបច្ចុប្បន្ន និងច្បាប់ដែលកំពុងវិវត្ត)។*

*ជាធម្មតា «Soft Law» ដែលមានដូចជាធម្មនិយាម ការសន្យា សេចក្តីប្រកាសរួម ឬសេចក្តីប្រកាសពីគោលនយោបាយ ឬចេតនា(សេចក្តីថ្លែងការណ៍សន្និសីទទីក្រុងហែលសាំងគីឆ្នាំ១៩៧៥*

សេចក្ដីប្រកាសទីក្រុងរីយ៉ូ) សេចក្ដីសម្រេចអនុម័តដោយអង្គមហាសន្និបាតនៃអង្គការសហប្រជាជាតិត្រូវបានបង្កើតនៅក្នុងអង្គការអន្តរជាតិ។ ច្បាប់នេះមិនដាក់ជាកាតព្វកិច្ចបង្ខំតាមផ្លូវគតិយុត្តឡើយ។ ប៉ុន្តែច្បាប់ទន់អាចកំណត់មូលដ្ឋាន ឬបង្កើតជាបុកសំណង់ សម្រាប់ការបង្កើតវិធានទំនៀមទម្លាប់ជាលំដាប់ ឬបទប្បញ្ញត្តិអនុសញ្ញា។ ក្នុងន័យម្យ៉ាងទៀត បន្តិចម្តងៗ «ច្បាប់ទន់»អាចបំលែងខ្លួនទៅជាច្បាប់មែនទែន។[៣១]

## តើតួអង្គណាខ្លះទទួលបាន «បុគ្គលភាពអន្តរជាតិ»?

បុគ្គលភាពគឺជាសមត្ថភាពដែលអាចធ្វើជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។ ជាទូទៅ រដ្ឋស្ថិតនៅចន្លោះបុគ្គល និងលំដាប់គតិយុត្តអន្តរជាតិ។ ទោះបីជាមានការលើកលែង(នៅក្នុងច្បាប់អន្តរជាតិស្តីពីសិទ្ធិរបស់បុគ្គល-ល-) ជានិច្ចកាល តែងតែមានការបែងចែករវាងប្រធានបឋម ឬដើមដំបូងនៃច្បាប់អន្តរជាតិ និងប្រធានបន្ទាប់បន្សំ ឬក្លាយ។ អង្គការអន្តរជាតិ ប្រជាជននៅក្រោមការត្រួតត្រារបស់អាណានិគម ឯកត្តជន-ល-។ គឺជាប្រធានក្លាយ ពីព្រោះសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេគឺក្លាយមកពីច្បាប់ដែលបង្កើតឡើងដោយរដ្ឋ។

***ឯកត្តជន ៖*** ជនរងគ្រោះពីការរំលោភបំពានដោយរដ្ឋមួយនូវសិទ្ធិដែលការពារដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិរដ្ឋប្បវេណី និងនយោបាយឆ្នាំ១៩៦៦ អាចប្តឹងទៅគណៈកម្មាធិការសិទ្ធិមនុស្ស ដើម្បីឱ្យពិនិត្យមើលបណ្តឹងរបស់ខ្លួន(លក្ខខណ្ឌ និងការប្រើប្រាស់ឧបាស្រ័យជាតិអស់)។

***ការអភិវឌ្ឍ«ជាបដិវត្តន៍»?*** បុគ្គលឯកជន-ល-។ ត្រូវបានដកចេញពីការបង្កើតវិធានានានៅកម្រិតផ្លូវការ(ប៉ុន្តែនៅកម្រិតមិនផ្លូវការវិញ ត្រូវតែទទួលស្គាល់អានុភាពរបស់អង្គការក្រៅរដ្ឋាភិបាល-ល-)។

## ៣- ការអនុវត្តនីតិអន្តរជាតិនៅក្នុងនីតិផ្ទៃក្នុង

ទំនាក់ទំនងរវាងច្បាប់អន្តរជាតិ និងលំដាប់គតិយុត្តផ្ទៃក្នុង។

## ៣.១- ការទទួលច្បាប់អន្តរជាតិនៅក្នុងលំដាប់គតិយុត្តផ្ទៃក្នុង

គេបែងចែកគោលវិធីទ្រឹស្តីចំនួនពីរ។ តាមទ្រឹស្តីទ្វិកនិយម សណ្តាប់ធ្នាប់គតិយុត្តផ្ទៃក្នុង និងសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិត្រូវបានញែកចេញពីគ្នា ហើយសណ្តាប់ធ្នាប់នីមួយៗគឺជាបណ្តុំស្វយ័តមួយ ហើយគ្មានចំណងណាមួយរវាងសណ្តាប់ធ្នាប់គតិយុត្តទាំងពីរនេះទេ។ ច្បាប់អន្តរជាតិគ្រប់គ្រងទំនាក់ទំនងរវាងបណ្តារដ្ឋ និងស្ថិតនៅក្នុងលំដាប់មួយដែលស្វយ័តទាំងស្រុង។ ទ្រឹស្តី

[៣១] *Cassese, op. cit., p. 196.*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះមិនបានផ្អែកលើអន្តរពាក់ព័ន្ធនិស្សរភាពកាន់តែច្រើនឡើងៗរបស់រដ្ឋ និងតួនាទីនៃច្បាប់ផ្ទៃក្នុងនៅក្នុងការអនុវត្តច្បាប់អន្តរជាតិ។ ធម្មនិយាមអន្តរជាតិត្រូវបានទទួលយកនៅក្នុងលំដាប់គតិយុត្តផ្ទៃក្នុងតាមរយៈកិច្ចមួយ គឺច្បាប់ ដើម្បីឱ្យធម្មនិយាមនេះអាចចូលទៅក្នុងលំដាប់គតិយុត្តរបស់រដ្ឋ។

ផ្ទុយទៅវិញ ទ្រឹស្តីឯកនិយម បញ្ជាក់ពីឯកភាពនៃសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ និងសណ្តាប់ធ្នាប់គតិយុត្តផ្ទៃក្នុងដោយទទួលស្គាល់អន្តរពាក់ព័ន្ធនិស្សរភាព(interdépendance)នៃសណ្តាប់ធ្នាប់ទាំងពីរ។ រដ្ឋធម្មនុញ្ញដែលប្រកាន់យកគោលវិធីឯកនិយមមិនទាមទារឱ្យមានកិច្ចណាមួយដើម្បីទទួលយកច្បាប់អន្តរជាតិនៅក្នុងសណ្តាប់ធ្នាប់គតិយុត្តផ្ទៃក្នុងទេ។ នៅពេលដែលទម្រង់បែបបទនៃការធ្វើការសន្យាដែលមានដូចជាការផ្តល់សច្ចាប័ន ការទទួលយកដែលមានចែងដោយច្បាប់អន្តរជាតិ និងទម្រង់បែបបទនៃការផ្សព្វផ្សាយសាធារណៈដែលគ្រោងទុកដោយរដ្ឋធម្មនុញ្ញត្រូវបានបំពេញរួច ធម្មនិយាមអន្តរជាតិដូចជាសន្ធិសញ្ញា ឬទំនៀមទម្លាប់ត្រូវក្លាយទៅជាសមាសភាគពេញលេញនៃសណ្តាប់ធ្នាប់គតិយុត្តផ្ទៃក្នុងហើយ។ មាត្រា៥៥នៃរដ្ឋធម្មនុញ្ញបារាំងចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៥៨ ក៏ទទួលយកគោលវិធីឯកនិយមដែរ។

## ៣.២- ភាពអនុវត្តបានដោយផ្ទាល់

ធម្មនិយាមមួយអាចត្រូវអនុវត្តបានដោយផ្ទាល់ ឬមានអានុភាពផ្ទាល់ នៅពេលដែលធម្ម-និយាមនេះបង្កើតឱ្យមានសិទ្ធិ ឬកាតព្វកិច្ចសម្រាប់បុគ្គលឯកជន។ គេក៏ហៅថា «ស្វ័យប្រតិបត្តិ» ដែរ។ អាជ្ញាធរផ្ទៃក្នុងនឹងអាចទាមទារឱ្យមានការអនុវត្តវិធានដោយបុគ្គលឯកជន។ បុគ្គលឯកជនទាំងនេះក៏អាចលើកពីការសន្យាបែប«ស្វ័យប្រតិបត្តិ»របស់រដ្ឋនៅចំពោះមុខចៅក្រមរដ្ឋបាល ឬតុលាការបានដែរ។

ភាពអនុវត្តបានដោយផ្ទាល់អាចធ្វើទៅបានតែនៅក្នុងប្រព័ន្ធដែលមាននិន្នាការឯកនិយមដែលយល់ព្រមទទួលយកធម្មនិយាមអន្តរជាតិដូចដែលមានស្រាប់ៗតែម្តងនៅក្នុងសណ្តាប់ធ្នាប់គតិយុត្តផ្ទៃក្នុង។ ប៉ុន្តែធម្មនិយាមទាំងអស់នៃច្បាប់អន្តរជាតិមិនមែនមានភាពអនុវត្តបានដោយផ្ទាល់ទាំងអស់នោះទេ។

• លក្ខខណ្ឌទីមួយគឺចេតនារបស់គូភាគី។ ត្រូវតែឱ្យគូភាគីនៃកិច្ចព្រមព្រៀងបានឯកភាពបង្កើតសិទ្ធិសម្រាប់បុគ្គលឯកជន។

• លក្ខខណ្ឌទីពីរទាមទារឱ្យធម្មនិយាមមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីឱ្យអនុវត្តផ្ទាល់បាន។

នៅក្នុងសាលដីកាមួយចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ តុលាការឧទ្ធរណ៍វិនិច្ឆ័យថា «ប្រសិនបើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិត្រូវអនុវត្តចំពោះរដ្ឋ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សមាជិកនៅប្រទេសបារាំង សេចក្តីសម្រេចទាំងនេះពុំមានអានុភាពផ្ទាល់ទេ លើកណាដែលសេចក្តីបង្គាប់ដែលសេចក្តីសម្រេចទាំងនេះដាក់ចេញ មិនត្រូវបានធ្វើឱ្យក្លាយទៅជាកាតព្វកិច្ច ឬសម្របសម្រួលនៅក្នុងច្បាប់ផ្ទៃក្នុងនោះ»។*[៣២]

## តម្រូវការការប្រែសម្រួលវិធានអន្តរជាតិភាគច្រើនទៅក្នុងច្បាប់ជាតិ

*វិធានអន្តរជាតិត្រូវតែអនុវត្តដោយរដ្ឋនៅក្នុងប្រព័ន្ធគតិយុត្តរបស់រដ្ឋ និងជាទូទៅត្រូវតែប្រែសម្រួលទៅជាច្បាប់ជាតិ។ រដ្ឋមានអធិបតេយ្យ និងមានអំណាចធ្វើសម្រេចពីវិធានការដែលរដ្ឋអាចកាន់កាប់សិទ្ធិ និងកាតព្វកិច្ចនានា។ ជាផលវិបាក នៅពេលដែលវិធានអន្តរជាតិត្រូវតែអនុវត្តនៅក្នុងរដ្ឋមួយ ឬដោយភ្នាក់ងារម្នាក់របស់រដ្ឋនៅក្នុងករណីភាគច្រើន វិធានទាំងនោះត្រូវដាក់បញ្ចូលទៅក្នុងច្បាប់ក្រុង។*

*ដូច្នេះ វាច្បាស់ណាស់ដែលថា វិធានអន្តរជាតិភាគច្រើនមិនអាចដំណើរការដោយគ្មានជំនួយបិតថេរ កិច្ចសហការ និងការគាំទ្ររបស់ប្រព័ន្ធគតិយុត្តជាតិឡើយ។ ដោយបំផ្លើសបន្តិច (ដោយសារតែគោលវិធីទ្វិកនិយមទាំងស្រុងរបស់គាត់) អ្នកនិពន្ធផ្សាយជាតិអាល្លឺម៉ង់ ឈ្មោះ* H. Triepel *បានសង្កេតឃើញនៅឆ្នាំ១៩២៣ថា ច្បាប់អន្តរជាតិគឺដូចជាសេនាប្រមុខម្នាក់ដែលមិនអាចបញ្ជាឧត្តមសេនីយ៍បាន។ គឺតាមរយៈពួកឧត្តមសេនីយ៍តែមួយគត់ដែលបញ្ជារបស់សេនាប្រមុខអាចទៅដល់កងទ័ព។ ប្រសិនបើពួកឧត្តមសេនីយ៍មិនបញ្ជូនបញ្ជាទៅដល់ពលទាហាននៅលើភូមិសាស្ត្រជាក់ស្តែងទេ សេនាប្រមុខនឹងចាញ់ការវាយប្រយុទ្ធ។*[៣៣]

---

[៣២] *Cass. Civ. re, 25 avril 2006, n° 02-17344, RGDIP 2006/4, p. 950.*

[៣៣] *HR (1923) à 106.*

# ជំពូកទី៣
# រដ្ឋ

## ផ្នែកទី១
## កំណកំណើតរដ្ឋ

*សន្ធិសញ្ញាWestphalieដែលបានបញ្ចប់សង្គ្រាមសាមសិបឆ្នាំនៅឆ្នាំ១៦៤៨ បានប្រឆាំងជាស្ពាពរទៅនឹងអធិរាជ និងសម្ដេចប៉ាប។ ជាញឹកញាប់ សន្ធិសញ្ញានេះត្រូវបានបង្ហាញថា ជាសំបុត្រកំណើតនៃច្បាប់អន្តរជាតិទំនើបជាមួយនឹងការលេចឡើងនៃរដ្ឋអធិបតេយ្យដែលស្មើគ្នានៅចំពោះមុខច្បាប់។*

### ១- ការបង្កើតរដ្ឋ

*រដ្ឋលែងនៅតែម្នាក់ឯងនៅក្នុងសង្គមអន្តរជាតិទៀតហើយ។ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលឯកជន រូបវន្តបុគ្គល ឬនីតិបុគ្គល បានក្លាយទៅជាប្រធាននៃនីតិបន្តិចម្ដងៗជាលំដាប់។ ទោះបីជាបែបនេះក្ដី រដ្ឋនៅតែរក្សាការគ្រប់គ្រងច្បាប់អន្តរជាតិ។*

*ប៉ុន្តែរដ្ឋនៅតែជាធម្មានរូបលើសលុបនៃសណ្ដាប់ធ្នាប់គតិយុត្តអន្តរជាតិដែលធ្វើពិពិធកម្ម និងកាន់តែមានភាពស្មុគស្មាញជាលំដាប់។*

*ការលេចឡើងក៏ដូចជាការរលត់បាត់នៃរដ្ឋមួយសុទ្ធសឹងជាព្រឹត្តិការណ៍ដែលនាំឱ្យមានផលវិបាកគតិយុត្ត។[៣៤] ព្រឹត្តិការណ៍ខាងក្រោមអាចនាំឱ្យមានការបង្កើតរដ្ឋថ្មីមួយ ៖*

*• អប្បគមន៍ ៖ ដែនដីមួយផ្នែករបស់រដ្ឋមួយត្រូវបំបែកចេញដោយទុកឱ្យរដ្ឋចាស់បន្តមានអត្ថិភាពនៅក្នុងព្រំដែនដែលកាន់តែតូចជាងមុន ដូចជាករណីប្រទេសម៉ុងតេណេក្រូដែលបានបែកចេញពីប្រទេសស៊ែរប៊ីនៅខែឧសភា ឆ្នាំ២០០៦ជាដើម។*

*• ការបាក់បែក ៖ មានការលេចឡើងរដ្ឋថ្មី និងការរលាយបាត់រដ្ឋចាស់។ គឺករណីសហភាព*

---

[៣៤] *MARTIN-BIDOU, op. cit., p. 11.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សូវៀតកាលពីឆ្នាំ១៩៩១ ប្រទេសយូកូស្លាវីនៅឆ្នាំ១៩៩២ និងឆេកូស្លូវ៉ាគីនៅឆ្នាំ១៩៩២។*

*• ការបង្រួបបង្រួមជាតិ ៖ រដ្ឋពីរធ្លាប់រួបរួមគ្នាហើយកាលពីមុនៗ គឺករណីនៃការបង្រួប-បង្រួមគ្នារបស់ប្រទេសអាល្លឺម៉ង់នៅឆ្នាំ១៩៩០ និងប្រទេសយេមែននៅឆ្នាំ១៩៩០។*

*• ការដកអាណានិគម ៖ «គោលការណ៍សមភាពនៃសិទ្ធិរបស់ប្រជាជន និងសិទ្ធិប្រជាជនក្នុងការសម្រេចលើជោគវាសនារបស់ពួកគេ»[៣៥] (មាត្រា១កថាខណ្ឌទី២នៃធម្មនុញ្ញអង្គការសហប្រជាជាតិបានអនុញ្ញាតឱ្យមានការដកអាណានិគមចេញពីទឹកដីជាច្រើនពីសំណាក់មហាអំណាចអាណានិគម)។*

## ២- កំណាកំណើត និងការទទួលស្គាល់

*បញ្ហានៃកំណាកំណើត ឬការបាត់បង់រដ្ឋមួយសំដៅដល់ការកំណត់អំពីអវត្តមាន ឬការលេចចេញជាថ្មី ឬទំនាក់ទំនងដែលបានភ្ជាប់អង្គភាពពាក់ព័ន្ធមួយទៅនឹងរដ្ឋមួយទៀត។ ដើម្បីឆ្លើយតបទៅនឹងភាពស្របទៅនឹងច្បាប់អន្តរជាតិនៃការប្រកាសឯករាជ្យជាឯកតោភាគីរបស់ប្រទេសកូសូវ៉ូ តុលាការយុត្តិធម៌អន្តរជាតិមិនបានវិនិច្ឆ័យសេចក្តីលើចំណុចដែលត្រូវដឹងថា «តើប្រទេសកូសូវ៉ូបាន ឬមិនបានទទួលគុណភាពជារដ្ឋនោះទេ» ហើយក៏មិនបានពិនិត្យ«សុពលភាព ឬអានុភាពគតិយុត្តនៃការទទួលស្គាល់ថាជារដ្ឋឯករាជ្យដោយរដ្ឋខ្លះដែរ»។[៣៦]*

*រដ្ឋនីមួយៗមានសេរីភាពធ្វើមូលវិចារណ៍ ឬវាយតម្លៃអភិមានះរដ្ឋដែលកំពុងកើតឡើង ៖ ប្រសិនបើអភិមានះនេះអសមត្ថភាពក្នុងការបង្កើតរដ្ឋទៅតាមផ្លូវគតិយុត្ត ការកើនឡើងនៃការទទួលស្គាល់ជាឯកត្តបុគ្គលចូលរួមវិភាគទានក្នុងការពង្រឹងភាពជាក់ស្តែងនៃអំណាចជាក់លាក់ណាមួយរហូតដល់ការទាមទារលក្ខន្តិកៈរដ្ឋ ស្ថិតនៅក្នុងព្រឹត្តិការណ៍មួយដែលទទួលបានដែលច្បាប់នឹងផ្តល់សច្ចាប័នឱ្យ។*

---

[៣៥] *គោលការណ៍នេះបានទទួលតម្លៃជាវិធានច្បាប់ទំនៀមទម្លាប់មួយ(MARTIN-BIDOU (P.), op. cit., p. 12.).* ។

[៣៦] *CIJ, « Conformité au droit international de la déclaration de l'indépendance du Kosovo », avis consultatif du 22 juillet 2010, §51.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី២
## រដ្ឋជាប្រធានចម្បង[៣៧]នៃច្បាប់អន្តរជាតិ

*តុលាការយុត្តិធម៌អន្តរជាតិបានគូសបញ្ជាក់នៅឆ្នាំ១៩៤៩ថា «នៅក្នុងប្រព័ន្ធគតិយុត្ត ប្រធាននៃនីតិគឺមិនមានលក្ខណៈដូចគ្នាទេ បើពិនិត្យមើលសារជាតុ និងវិសាលភាពនៃច្បាប់របស់ប្រធាននៃនីតិទាំងនោះ ហើយសារជាតុរបស់វាអាស្រ័យទៅនឹងតម្រូវការរបស់សហគមន៍»។[៣៨] ដូច្នេះគឺមានភាពខុសគ្នានៃប្រធាននីតិអន្តរជាតិ។*

*រដ្ឋគឺខុសពីប្រធានដទៃ ព្រោះគ្មានបុគ្គលណាផ្តល់បុគ្គលភាពគតិយុត្តដល់រដ្ឋទេ។ សាស្ត្រាចារ្យ រូសូ សរសេរថា រដ្ឋ «នៅពេលដែលវាមានអត្ថិភាពជាក់ស្តែងនោះ វាមានអត្ថិភាពតាមច្បាប់ហើយ»។*

*រដ្ឋគឺជាប្រធានដើម ឬដំបូង ឬចម្បងនៃច្បាប់អន្តរជាតិ ព្រោះនៅក្នុងសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ[៣៩] អត្ថិភាពរបស់រដ្ឋមិនអាស្រ័យទៅនឹងរដ្ឋណាមួយឡើយ ផ្ទុយពីអង្គការអន្តរជាតិដែលត្រូវបង្កើតឡើងដោយរដ្ឋ។*

*វាមិនមែនជាការចាំបាច់ដែលសហគមន៍អន្តរជាតិត្រូវមានជំហរ ដើម្បីបង្កើតរដ្ឋទេ តែការទទួលស្គាល់របស់សហគមន៍អនុញ្ញាតឱ្យរដ្ឋមានចំណងទំនាក់ទំនងជាមួយខ្លួនតែប៉ុណ្ណោះ។ អនុលោមតាមគោលការណ៍និរន្តរភាពរដ្ឋ អត្តសញ្ញាណរបស់រដ្ឋនឹងមិនត្រូវប៉ះពាល់ដោយបម្រែបម្រួលដែលនឹងអាចប៉ះពាល់រដ្ឋឡើយ។[៤០] រដ្ឋនៅមានជីវិតដដែល បន្ទាប់ពីមានការកែសម្រួលទឹកដី ឬក្រោយពីមានការកែប្រែរដ្ឋាភិបាលខ្លួនដូចជាបដិវត្តន៍មួយ។*

### ១- ទឹកដីរបស់រដ្ឋ

*ជាតុផ្សំរបស់រដ្ឋដែលក្នុងនោះមានទឹកដី ប្រជាជន និងរដ្ឋាភិបាលដែលការផ្តុំជាមួយគ្នា*

---

[៣៧] *A subject of the law is an entity capable of possessing international rights and duties and having the capacity to maintain its rights by bringing international claims (BROWNLIE (I.),* Principles of Public International Law, *Oxford, Oxford University Press, seventh edition, 2008, p. 57 ; Reparation for Injuries case, ICJ Reports (1949), p. 179).*

[៣៨] *CIJ, « Réparation des dommages subis au service des Nations Unis », avis consultatif du 11 avril 1949, Recueil des arrêts, avis consultatifs et ordonnances, 1949, p. 178.*

[៣៩] *En l'absence d'autorités extérieures et supérieures aux États, ils sont seuls à apprécier la signification et la portée des normes dont ils sont à la fois les auteurs et les destinataires. Les normes internationales sont relatives et ne sont opposables à un État que dans la mesure de son consentement : c'est l'opposabilité, un État n'est tenu à respecter que les normes internationales auxquelles il y a consenti et dans la mesure de ce consentement (MARTIN-BIDOU (P.), op. cit., pp. 7-8. ).*

[៤០] *MARTIN-BIDOU (P.), op. cit., p. 12.*

នឹងកំណត់លក្ខខណ្ឌនៃអត្ថិភាពរបស់រដ្ឋ«ជាជាបុគ្គលនៃច្បាប់អន្តរជាតិ»។[៦១]

ទឹកដីផ្សំបានជា«ឋានៈគតិយុត្តដែលនៅលើនោះរដ្ឋអនុវត្តសមត្ថកិច្ចរបស់ខ្លួន ហើយក៏ជាលំហមួយដែលនៅលើនោះ ប្រជាជនរបស់រដ្ឋរស់នៅដែរ»។[៦២] ទឹកដីរបស់រដ្ឋផ្សំឡើងពីធាតុចំនួនបីដែលនៅលើធាតុទាំងនោះ រដ្ឋអនុវត្តអធិបតេយ្យភាពរបស់ខ្លួន ៖

- **ដែនដីគោក** រួមមានដី ក្រោមដី បឹង និងទន្លេនានា។
- **ដែនដីសមុទ្រ ៖** រដ្ឋអនុវត្តអធិបតេយ្យនៅលើដែនទឹកផ្ទៃក្នុង និងសមុទ្រដែនដីរបស់ខ្លួន។ រដ្ឋក៏មាន«សិទ្ធិអធិតេយ្យ»នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងនៅលើខ្ពង់រាបបាតសមុទ្រដែរ។
- **លម្ហអាកាស ៖** លម្ហអាកាសស្ថិតនៅពីលើដែនដីគោក ដែនដីសមុទ្រ និងផ្តុំដោយលម្ហបរិយាកាស។ រដ្ឋអនុវត្តអធិបតេយ្យនៅក្នុងលម្ហអាកាស អាចធ្វើនិយ័តកម្ម និងហាមមិនឱ្យមានការចូល និងហោះពីលើទឹកដីរបស់ខ្លួន។

ទឹកដីគ្មានម្ចាស់ res nulliusមិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយឡើយ។ វិធីសាស្ត្រទទួលបានទឹកដីទាំងនេះគឺ ៖

- ការវាយដណ្តើម
- ការរកឃើញ
- ការកាន់កាប់ជាក់ស្តែង។

ព្រំប្រទល់ខណ្ឌរបស់ទឹកដីគឺព្រំដែន។[៦៣] ព្រំដែនអាចបែងចែកអធិបតេយ្យពីរ ឬលម្ហពីរដែលនៅលើនោះមានការអនុវត្តសមត្ថកិច្ចមិនដូចគ្នា។[៦៤] ព្រំដែនត្រូវកំណត់តាមរយៈកិច្ចព្រមព្រៀងរួមមួយដោយរដ្ឋជិតខាងគ្នានៅក្នុងសន្ធិសញ្ញាព្រំប្រទល់ ឬសន្ធិសញ្ញាព្រំដែន។ ការកំណត់ព្រំដែនដោយអនុសញ្ញាអាចត្រូវប្រើប្រាស់ ដើម្បីបែងចែកដែនដីគោក ឬដែនដីសមុទ្របាន។

ការជ្រើសរើសគំនូសព្រំដែនអាចស៊ីគ្នាជាមួយនឹងតថភាពធម្មជាតិមួយ(ព្រំដែនធម្មជាតិ)។ ចំពោះទន្លេមួយ ព្រំដែនដើរតាមទន្លេដែលមិនអាចធ្វើនាវាចរណ៍បាន(បន្ទាត់ទ្រូង ឬមេដ្យាន) ឬតាមបណ្តោយច្រាំងមួយ(ព្រំប្រទល់នៅច្រាំង) ឬនៅកណ្តាលជ្រលងដែលអាចធ្វើនាវាចរណ៍បាន(ជ្រលងទឹកជ្រៅ)។ ចំពោះភ្នំមួយ គឺយកខ្សែកំពូលភ្នំ ឬខ្សែបែងចែកទឹក។ ព្រំប្រទល់អាចជាព្រំប្រទល់សិប្បនិម្មិតដោយប្រកាន់យកខ្សែតារាសាស្ត្រមួយដូចជាខ្សែរណ្តៃ ឬខ្សែបណ្តោយនៅលើដីគោក។

ការកំណត់ព្រំដែនមានបីដំណាក់កាល ៖

---

[៦១] *Convention de Montevideo sur les droitset devoirs des États, du 26 décembre 1933.*

[៦២] *MARTIN-BIDOU (P.), op. cit., p. 15.*

[៦៣] *« Définir un territoireestdéfinirsesfrontières » (CIJ, Différend territorial Libye/Tchad, arrêt du 3 février 1994, Rec. 1994, §36, p. 20).*

[៦៤] *MARTIN-BIDOU (P.), op. cit., p. 17.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

• ការកំណត់ព្រំដែន ៖ ព្រំដែនត្រូវកំណត់ដោយប្រតិបត្តិការគតិយុត្តដែលសម្រេចនៅលើឯកសារនូវជម្រើសព្រំដែនធម្មជាតិ ឬសិប្បនិម្មិត និងគំនូសព្រំដែនជាក់លាក់។

• ការខណ្ឌសីមា ៖ ជាប្រតិបត្តិការបច្ចេកទេសជាក់ស្តែង ដើម្បីយកគំនូសព្រំដែនដាក់ទៅលើដីជាក់ស្តែង។

• ការបោះបង្គោលព្រំដែន ៖ ជាប្រតិបត្តិការមួយដើម្បីធ្វើឱ្យព្រំដែនមានរូបរាងជាក់ស្តែងនៅលើភូមិសាស្ត្រជាក់ស្តែងតាមរយៈការបោះបង្គោល ឬបង្គោលតម្រុយនៅលើដី។

## ២- ប្រជាជនរបស់រដ្ឋ

ប្រជាជនជាធាតុផ្សំសំខាន់របស់រដ្ឋ ពីព្រោះរដ្ឋមិនអាចមានអត្ថិភាពដោយគ្មានប្រជាជនឡើយ។[៦៥] ប្រជាជនត្រូវភ្ជាប់ជាមួយរដ្ឋដោយចំណងសញ្ជាតិមួយ។[៦៦] រដ្ឋមួយអាចផ្សំឡើងដោយប្រជាជនច្រើនប្រភេទ(ប្រទេសរុស្ស៊ី និងចិន)។

**ចំណងសញ្ជាតិ ៖**

«ច្បាប់អន្តរជាតិទុកសិទ្ធិឱ្យរដ្ឋនីមួយៗកំណត់ការផ្តល់សញ្ជាតិផ្ទាល់របស់រដ្ឋនោះ»។[៦៧] គេវែកញែកដូចខាងក្រោម ៖

• ការផ្តល់សញ្ជាតិពីកំណើត ៖ សញ្ជាតិត្រូវបានទទួលដោយសារតែបុត្តភាពរបស់កូនពោលគឺសិទ្ធិទទួលសញ្ជាតិតាមឈាម(*jus sanguinis*) ឬក៏ដោយសារតែទីកន្លែងកំណើតរបស់កូនពោលគឺសិទ្ធិទទួលសញ្ជាតិតាមកន្លែងកំណើត(*jus soli*)។

• ការទទួលបានសញ្ជាតិក្រោយពីកំណើត ៖ នេះដោយសារតែអាពាហ៍ពិពាហ៍ ឬសុំកូន ឬដោយសារតែសញ្ជាតូបនីយកម្ម។

• ការបាត់បង់សញ្ជាតិ ៖ ជាកិច្ចមួយរបស់រដ្ឋទៅតាមសំណើសុំរបស់បុគ្គល ឬដោយសារការប្រកាសដកសិទ្ធិដោយរដ្ឋ។

• និរបេតិជន ៖ ជាការបាត់បង់សញ្ជាតិខ្លួនរបស់បុគ្គលម្នាក់ ទាំងដោយមិនទទួលបានសញ្ជាតិមួយថ្មី។

• ពហុសញ្ជាតិ ឬការមានសញ្ជាតិច្រើន ៖ គឺការមានសញ្ជាតិពីរ។

ដើម្បីឱ្យសញ្ជាតិអាចត្រូវជំទាស់បាន ត្រូវតែមានចំណងជាក់ស្តែងនៃការភ្ជាប់គ្នារវាងបុគ្គល

---

[៦៥] *Le peupleou la nation sont des notions sociologiquesoupolitiques qui expriment le désir de vivre encommun, unehomogénéitéraciale, culturelle, religieuseoulinguistique.*

[៦៦] *MARTIN-BIDOU (P.), op. cit., p. 20.*

[៦៧] *CIJ, Affaire Notteböhm, arrêt du 6 avril 1955, Rec. 1955, p. 23.*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ម្នាក់ និងរដ្ឋ។[៤៨] គោលការណ៍សញ្ជាតិជាក់ស្តែងត្រូវបានអះអាងបញ្ជាក់នៅក្នុងសាលដីកា Nottebӧhm ឆ្នាំ១៩៥៥។

### ៣- រដ្ឋាភិបាលរបស់រដ្ឋ

រដ្ឋាភិបាលគឺជាអាជ្ញាធរនយោបាយដែលធ្វើឱ្យមានសណ្តាប់ធ្នាប់នៅក្នុងព្រំដែនដែលតំណាងឱ្យរដ្ឋ និងបង្ហាញពីឆន្ទៈនៅខាងក្រៅព្រំដែន។[៤៩] រដ្ឋាភិបាលដែលគេយល់ទៅតាមន័យទូលាយគឺផ្សំឡើងដោយអំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងតុលាការ។

ច្បាប់អន្តរជាតិមិនគិតគូរអំពីទម្រង់នៃរដ្ឋាភិបាលឡើយ[៥០] ប៉ុន្តែគិតគូរអំពីភាពជាក់ស្តែងរបស់រដ្ឋាភិបាល[៥១] មានន័យថាសមត្ថភាពក្នុងការរក្សាសណ្តាប់ធ្នាប់នៅលើទឹកដី ដោយមានការធ្វើឱ្យគេគោរពច្បាប់ និងគោរពការសន្យាអន្តរជាតិ[៥២]។

# ផ្នែកទី៣

## គោលការណ៍ជាសារវន្តដែលគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ

ក្នុងសណ្តាប់ធ្នាប់គតិយុត្តជាតិ រដ្ឋត្រូវគ្រប់គ្រងដោយរដ្ឋធម្មនុញ្ញដែលផ្តោតទៅលើគោលការណ៍ជាសារវន្តដែលគ្រប់គ្រងប្រព័ន្ធនយោបាយ។ ប៉ុន្តែសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិខុសពីគោលការណ៍ទូទៅនៃប្រព័ន្ធគតិយុត្តជាតិ ដោយរដ្ឋប្រតិបត្តិនៅលើគោលការណ៍បីយ៉ាង គឺសេរីភាព សមភាព និងប្រសិទ្ធភាព។ ចំណុចនេះបង្កើតបានជាកំពូលខ្ពស់បំផុតរបស់ច្បាប់អន្តរជាតិបុរាណ។ ទោះជាយ៉ាងនេះក្តី រដ្ឋត្រូវតែគ្រប់គ្រងដោយគោលការណ៍ជាសារវន្តមួយចំនួនដូចជាសមភាពអធិបតេយ្យរបស់រដ្ឋ ការមិនជ្រៀតជ្រែកនៅក្នុងកិច្ចការផ្ទៃក្នុង និងអន្តរជាតិរបស់រដ្ឋដទៃ ការហាមឃាត់មិនឱ្យគំរាមកំហែង ឬប្រើប្រាស់កម្លាំង ការដោះស្រាយជម្លោះដោយសន្តិវិធី ការគោរពសិទ្ធិមនុស្ស និងស្វ័យសម្រេចរបស់ប្រជាជន។

---

[៤៨] គឺករណីសញ្ជាតូបនីយកម្ម។

[៤៩] MARTIN-BIDOU (P.), op. cit., p. 25.

[៥០] សាធារណរដ្ឋ ឬរាជានិយម ប្រជាធិបតេយ្យ ឬផ្តាច់ការ ។

[៥១] សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការធានារក្សានូវរាល់មុខងាររបស់រដ្ឋ។

[៥២] MARTIN-BIDOU (P.), op. cit., p. 25.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១- សមភាពអធិបតេយ្យរបស់រដ្ឋ

ច្បាប់អន្តរជាតិបុរាណផ្អែកលើសំណុំនៃវិធានទាំងឡាយដែលការពារអធិបតេយ្យភាពរបស់រដ្ឋ និងការបង្កើតសមភាពផ្លូវការរបស់រដ្ឋទៅតាមផ្លូវច្បាប់។ ធម្មនុញ្ញអង្គការសហប្រជាជាតិបានប្រកាសពី«សមភាពអធិបតេយ្យរបស់សមាជិកទាំងអស់» (មាត្រា២ កថាខណ្ឌ១នៃធម្មនុញ្ញអង្គការសហប្រជាជាតិ)ថាជាគោលការណ៍មួយរបស់អង្គការ។ សមភាពអធិបតេយ្យគឺជាគោលការណ៍ទូទៅដែលក្តោបនូវសញ្ញាណពីរ គឺអធិបតេយ្យភាព និងសមភាពគតិយុត្ត។

## ១.១- អធិបតេយ្យភាព

គោលការណ៍អធិបតេយ្យរបស់រដ្ឋគឺជាបណ្តុំគំនិតគន្លឹះនៃច្បាប់អន្តរជាតិសាធារណៈ។ រដ្ឋក្នុងនាមជាប្រធានចម្បងនៃច្បាប់អន្តរជាតិសាធារណៈ គឺជាប្រធាននៃច្បាប់អន្តរជាតិតែមួយគត់ដែលមានអធិបតេយ្យពេញលេញ។ រដ្ឋគឺជា«សហគមន៍មួយដែលផ្សំឡើងដោយទឹកដីមួយ ប្រជាជនមួយដែលស្ថិតនៅក្រោមចំណុះអំណាចនយោបាយដែលរៀបចំមួយ និងស្តែងឡើងដោយអធិបតេយ្យភាព»។ គោលការណ៍នៃការមិនធ្វើអន្តរាគមន៍គឺជារូបភាពឆ្លុះបញ្ចាំងពីអធិប-តេយ្យភាពរបស់រដ្ឋ។

មានតែរដ្ឋតែមួយគត់ដែល«សម្គាល់ដោយអធិបតេយ្យភាព»។ នៅក្នុងច្បាប់ផ្ទៃក្នុង អធិប-តេយ្យភាពស្តែងឡើងដោយឧត្តមភាពនៃអំណាចសាធារណៈរបស់រដ្ឋទៅលើប្រធានដទៃទៀតនៃសណ្តាប់ធ្នាប់គតិយុត្តជាក់លាក់មួយ។ អធិបតេយ្យភាពគឺជាកេតនភណ្ឌជាសារវន្តរបស់រដ្ឋ។

គោលការណ៍សមភាពអធិបតេយ្យរបស់រដ្ឋ(មាត្រា២ កថាខណ្ឌ១នៃធម្មនុញ្ញអង្គការសហប្រជាជាតិ)៖

• អធិបតេយ្យភាពមានន័យថាឯករាជ្យភាព។ រដ្ឋអធិបតេយ្យមិនចំណុះឱ្យអាជ្ញាធរជាន់ខ្ពស់ណាមួយឡើយ។ អធិបតេយ្យភាពស្តែងឡើងដោយអវត្តមាននៃភាពចំណុះឱ្យគេ «ភាពដែលមិនចំណុះឱ្យ(នៅក្នុងន័យអនុកូលភាព) ប្រធានណាមួយ(ក្នុងន័យនីតិបុគ្គល)»។

• សមភាពអធិបតេយ្យរបស់រដ្ឋ គឺរដ្ឋទាំងអស់មានសិទ្ធិ និងកាតព្វកិច្ចដូចគ្នាទៅតាមច្បាប់អន្តរជាតិ។ លក្ខន្តិកៈរបស់រដ្ឋមិនខុសគ្នាទៅតាមទំហំអំណាច ឬទំហំទ្រព្យសម្បត្តិទេ។ វាគឺជាសមភាពគតិយុត្ត។ រដ្ឋនីមួយៗត្រូវគោរពអធិបតេយ្យរបស់រដ្ឋដទៃទៀត។

រដ្ឋគឺជាប្រធានដោយប្រយោលនៃច្បាប់អន្តរជាតិ។ រដ្ឋមានសមត្ថភាពធ្វើការសន្យាជាអន្តរ-ជាតិ និងចំណុះឱ្យវិធានអន្តរជាតិនានា។ «ច្បាប់អន្តរជាតិគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋឯករាជ្យ។ វិធានច្បាប់ដែលចងភ្ជាប់រដ្ឋ កើតមកពីឆន្ទៈរបស់រដ្ឋនីមួយៗ។ ដូច្នេះ គេមិនអាចសន្និដ្ឋានថាឯករាជ្យភាពរបស់រដ្ឋនីមួយៗមានកម្រិតបានឡើយ។

រដ្ឋមានបុគ្គលភាពគតិយុត្តអន្តរជាតិ។ រដ្ឋគឺជាពេជចក្រនៃសិទ្ធិ និងកាតព្វកិច្ចនៅក្នុងសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ។ អំពើ និងអាកប្បកិរិយារបស់អង្គភាពរបស់រដ្ឋគឺជាទំនួលខុសត្រូវផ្ទាល់របស់រដ្ឋ។ រដ្ឋមានសមត្ថភាពគតិយុត្តពេញលេញ។

សន្និសញ្ញានៃអំណាចធ្វើសេចក្តីសម្រេច ៖ រដ្ឋអាចបង្កើតកិច្ចគតិយុត្តអន្តរជាតិបាន និងមានសមត្ថភាពចុះកិច្ចសន្យាជាមួយរដ្ឋដទៃបានដែលបង្កើតបានជាកាតព្វកិច្ចគតិយុត្ត។

សិទ្ធិតាំងស្ថានទូត ៖ រដ្ឋអាចភ្ជាប់ទំនាក់ទំនងការទូត និងកុងស៊ុលជាមួយរដ្ឋដទៃទៀតបាន។

ការប្តឹងទៅតុលាការ ៖ រដ្ឋអាចប្តឹងទៅតុលាការ និងចូលរួមនៅក្នុងនីតិវិធីដោះស្រាយជម្លោះ។

ប៉ុន្តែត្បិតតែនៅក្នុងរដ្ឋសហព័ន្ធ ដូចជាប្រទេសអាល្លឺម៉ង់ និងសហរដ្ឋអាមេរិក សមត្ថកិច្ចយ៉ាងធំត្រូវបានប្រគល់ទៅឱ្យសមាជិករដ្ឋសហព័ន្ធក្តី រដ្ឋាភិបាលសហព័ន្ធនៅតែរក្សាការគ្រប់គ្រងអំណាចធម្មានុរូបពេញទំហឹង។ តុលាការយុត្តិធម៌អន្តរជាតិបានរំឭកថា «ការពិចារណាទៅលើច្បាប់ផ្ទៃក្នុង»តែមួយគត់ និងកម្រិតឧបាយដ៏ធំទូលាយដែលច្បាប់អាមេរិកផ្តល់ឱ្យសមាជិករដ្ឋសហព័ន្ធនៅក្នុងវិស័យព្រហ្មទណ្ឌមិនអាចដកសហរដ្ឋអាមេរិកចេញពីកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនបានឡើយ។

អធិបតេយ្យភាពរួមមានអំណាច និងសិទ្ធិផ្តាច់មុខ។

១- អំណាចអនុវត្តអាជ្ញាទៅលើបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី។ អំណាចនេះអាចចាត់ទុកថាដូចជាអត្ថសារៈនៃអធិបតេយ្យភាព។

អំណាចរបស់អាជ្ញាធរកណ្តាលរបស់រដ្ឋក្នុងការអនុវត្តមុខងារសាធារណៈទៅលើបុគ្គលឯកជនដែលតាំងនៅលើទឹកដីមួយ ត្រូវបានហៅថា «យុត្តាធិការ»។ ជាធម្មតា សមត្ថកិច្ចអាចស្តែងឡើងក្រោមទម្រង់ជាច្រើន ៖

• សមត្ថកិច្ចធ្វើបញ្ញត្តិ( ជាអំណាចធ្វើការប្រកាសពីការបញ្ជា ឬការអនុញ្ញាតស្របច្បាប់នានាដែលចងបុគ្គលឯកជន និងឧបករណ៍នានារបស់រដ្ឋនៅលើទឹកដីដែលជារបស់រដ្ឋ និងនៅក្នុងកាលៈទេសៈខ្វះ ឬជារបស់រូបវន្តបុគ្គលនៅបរទេសដែរ។

• សមត្ថកិច្ចធ្វើការកាត់សេចក្តី( ជាអំណាចវិនិច្ឆ័យលើវិវាទទាំងឡាយ តាមរយៈសេចក្តីសម្រេចបង្ខំ ឬបកស្រាយច្បាប់ដែលមានកម្លាំងជាកាតព្វកិច្ច ចំពោះរាល់បុគ្គល និងអង្គភាពដែលពាក់ព័ន្ធ) និង

• សមត្ថកិច្ចអនុវត្ត( មានន័យថាជាអំណាចធានាដោយមធ្យោបាយបង្ខំ ដើម្បីឱ្យការបញ្ជាគតិយុត្ត និងច្បាប់ត្រូវបានគោរព)។

ជាធម្មតា សមត្ថកិច្ចជាធម្មនិយាមលាតសន្ធឹងនៅលើដែនដីរបស់រដ្ឋមួយដែលមានអធិប-តេយ្យ។ ជាធម្មតា រដ្ឋអាចអនុម័តច្បាប់បង្ខំមួយដែលអាចអនុវត្តបានចំពោះបុគ្គល និងអង្គភាព

នានានៅលើទឹកដីរបស់រដ្ឋ។ ទោះជាយ៉ាងនេះក្ដី រដ្ឋក៏អាចអនុម័តច្បាប់ជាកាតព្វកិច្ចសម្រាប់អាណិកជនរបស់ខ្លួននៅបរទេស ព្រមទាំងដែលអាចអនុវត្តបានចំពោះទង្វើផ្សេងទៀត ឬអាកប្បកិរិយាដែលបានសន្យានៅបរទេស និងដែលចាត់ទុកថា អាចបង្កមហន្តរាយដល់រដ្ឋ( ឧទាហរណ៍ ការក្លែងរូបិយប័ណ្ណជាតិដោយជនបរទេស ឬអាណិកជននៅបរទេស ការរត់ពន្ធគ្រឿងញៀន និងទំនិញហាមឃាត់ដទៃទៀតពីបរទេសនៅលើទឹកដី)។ គេក៏អាចទៅកាន់តែឆ្ងាយដោយអនុម័តច្បាប់មួយដែលអាចអនុវត្តបានចំពោះកិច្ចដែលបានបំពេញរួចនៅបរទេសដោយជនបរទេសប្រឆាំងនឹងជនបរទេសដទៃទៀតបានដែរ។ ជាឧទាហរណ៍ ច្បាប់ក្រៅដែនដីនេះត្រូវបានអនុម័តក្នុងគោលបំណងអនុវត្តសមត្ថកិច្ចសាកលមួយក្នុងវិស័យភេរវកម្ម( សូមមើលជាឧទាហរណ៍ច្បាប់ពេញលេញរបស់សហរដ្ឋអាមេរិកឆ្នាំ១៩៨៦ស្ដីពីសន្តិសុខការទូត និងការប្រឆាំងភេរវកម្មដែលបញ្ជាក់ពីយុត្តាធិការរបស់អាមេរិកទៅលើការវាយប្រហារប្រឆាំងនឹងពលរដ្ឋអាមេរិកនៅបរទេស ឬការប្រឆាំងភេរវកម្មរបស់ប្រទេសអង់គ្លេស គឺច្បាប់ស្ដីពីឧក្រិដ្ឋកម្ម និងសន្តិសុខឆ្នាំ២០០១ដែលក្នុងនោះមាត្រា៦១ បញ្ជាក់ពីសមត្ថកិច្ចទៅលើបទល្មើសទាំងនេះថាជាការបង្កឱ្យផ្ទុះសង្គ្រាមនុយក្លេអ៊ែរដោយគ្មានការអនុញ្ញាត ការអភិវឌ្ឍឬការផ្ទេរអាវុធនុយក្លេអ៊ែរ ការជួយឬញុះញង់ឱ្យមានអំពើខុះទាក់ទិននឹងអាវុធនៅបរទេស) ឬនៃឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះថាជាអំពើប្រល័យពូជសាសន៍ឬទារុណកម្ម។ ទោះជាយ៉ាងនេះក្ដី ការអនុម័តច្បាប់មួយនេះមិនត្រូវប៉ះពាល់ដល់អធិបតេយ្យរបស់រដ្ឋផ្សេង ឧទាហរណ៍ដោយគ្រោងទុកនូវលទ្ធភាពធ្វើប្រតិបត្តិការនៅលើទឹកដីរបស់បរទេសឡើយ។

សហរដ្ឋអាមេរិកបានប្រកាសឱ្យប្រើច្បាប់ជាច្រើនដែលចែងពីទណ្ឌកម្មប្រឆាំងនឹងសហគ្រាសបរទេសដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មជាមួយនឹងរដ្ឋអរិភូតជាមួយសហរដ្ឋអាមេរិកដែលមានដូចជាច្បាប់ស្ដីពីប្រជាធិបតេយ្យគុយបាឆ្នាំ១៩៩២ (Cuban democracy act of 1992) ដែលហាមមិនឱ្យមានការផ្ដល់អាជ្ញាបណ្ណចំពោះប្រតិបត្តិការរវាងសាខានៅអឺរ៉ុបរបស់សហគ្រាសអាមេរិក ឬសហគ្រាសដែលនៅក្រោមការត្រួតត្រារបស់អាមេរិក និងគុយបា ឬក៏ច្បាប់Helms-Burton ចុះឆ្នាំ១៩៩៦ដែលអនុលោមតាមនោះ ទណ្ឌកម្មត្រូវបានគ្រោងទុកសម្រាប់សហគ្រាសបរទេសដែលបានទិញសម្បត្តិទ្រព្យដែលគេបានដកហូតពីប្រទេសគុយបានៅក្នុងបណ្ដាឆ្នាំ១៩៦០ ដោយកម្មសិទ្ធិករអាមេរិក និងច្បាប់ Amato ចុះឆ្នាំ១៩៩៦ដែលគ្រោងទុកនូវទណ្ឌកម្មប្រឆាំងនឹងសហគ្រាសបរទេសដែលចូលធ្វើជំនួញនឹងប្រទេសលីប៊ី និងអ៊ីរ៉ង់។ ប៉ុន្តែនៅពេលធ្វើការអនុវត្តភ្លាម ច្បាប់ទាំងនេះបានប៉ះពាល់ដល់គោលការណ៍ជាសារវន្តនៃច្បាប់អន្តរជាតិ និងជាពិសេសគោលការណ៍នៃការគោរពអធិបតេយ្យភាពរបស់រដ្ឋដទៃ។

សមត្ថកិច្ចដើម្បីវិនិច្ឆ័យសេចក្ដីគឺជាអំណាចទៅលើវិវាទដែលត្រូវប្រកាស។ ជាធម្មតា យុត្តា-

ធិការតុលាការនេះផ្អែកទៅលើគោលការណ៍ភាពជាដែនដី គោលការណ៍សកម្ម(ឬអកម្ម តែមិនញឹកញាប់ទេ)នៃសញ្ជាតិដែលរៀងគ្នាទៅលើសញ្ជាតិរបស់ចារី ឬសញ្ជាតិរបស់ជនរងគ្រោះ ឬគោលការណ៍គាំពារ(តុលាការដែលបង្កើតឡើងទៅលើសមត្ថកិច្ចដោះស្រាយបទល្មើសដែលទោះជាត្រូវបានប្រព្រឹត្តនៅបរទេស តែប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ជាតិ)។ នៅពេលថ្មីៗនេះ គោលការណ៍សាកលភាព(សមត្ថកិច្ចទៅលើបទល្មើសដែលប្រព្រឹត្តនៅបរទេសដោយជនបរទេសប្រឆាំងនឹងជនបរទេស)បានទទួលបានទម្រង់នៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិ។

សមត្ថកិច្ចធ្វើឱ្យគេប្រតិបត្តិ។ ជាធម្មតា អំណាចនេះត្រូវកំណត់ត្រឹមអំពើដែលប្រព្រឹត្តនៅលើទឹកដី។ ដូចដែលតុលាការអន្តរជាតិបានលើកឡើងនៅក្នុងរឿងក្តី Lotus យុត្តាធិការប្រភេទនេះ «មិនអាចអនុវត្តដោយរដ្ឋមួយនៅក្រៅដែនដីរបស់រដ្ឋទេ លើកលែងតែអនុលោមតាមវិធានអនុញ្ញាតមួយដែលមានប្រភពចេញពីច្បាប់អន្តរជាតិទំនៀមទម្លាប់ ឬចេញពីអនុសញ្ញាមួយ» (មាត្រា១៩)។

២- អំណាចប្រើប្រាស់ដោយសេរី និងចាត់ចែងទឹកដីដែលស្ថិតនៅចំណុះឱ្យយុត្តាធិការរបស់រដ្ឋ និងអំណាចអនុវត្តនូវរាល់សកម្មភាពដែលយល់ថាចាំបាច់ និងសំខាន់ចំពោះប្រជាជនដែលរស់នៅលើទឹកដីនោះ។ សន្តិសុខក៏សំខាន់ខ្លាំងដែរនៅក្នុងជីវិតរបស់ជាតិមួយ ក៏ដូចជាស្វ័យការពារដែលនៅក្នុងជីវិតរបស់បុគ្គលម្នាក់ដែរ។

៣ សិទ្ធិដែលគ្មានរដ្ឋដទៃណាមួយជ្រៀតជ្រែកនៅក្នុងទឹកដីរបស់រដ្ឋបានទេ(ដែលគេនាំគ្នាហៅថា *jus excludendi alios* ឬសិទ្ធិបដិសេធអ្នកដទៃចេញ)។ សហរដ្ឋអាមេរិកបានប្រឆាំងទៅនឹងសកម្មភាពដែលបានប្រព្រឹត្តនៅលើទឹកដីខ្លួនដោយប្រទេសបរទេសមួយតាមរយៈបុគ្គលឯកជន ឬដោយភ្នាក់ងារបរទេសដែលតែងខ្លួនជាបុគ្គលឯកជន។

៤- សិទ្ធិទៅលើអភ័យឯកសិទ្ធិនៃយុត្តាធិការរបស់តុលាការបរទេសចំពោះអំពើ ឬសកម្មភាពដែលប្រព្រឹត្តដោយរដ្ឋក្នុងគុណភាពជាអធិបតី និងនៃវិធានការប្រតិបត្តិដែលចាត់តាំងឡើងប្រឆាំងនឹងការប្រើប្រាស់ ឬការប្រើប្រាស់ដោយគ្រោងទុកនូវទ្រព្យសម្បត្តិសាធារណៈ ឬទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារសាធារណៈ។ (ក៏ប៉ុន្តែ បញ្ហានៃការកំណត់និយមន័យនៃប្រភេទអំពើ ឬសកម្មភាពទាំងនេះ ឬបញ្ហាធម្មជាតិសាធារណៈនៃទ្រព្យសម្បត្តិនៅមានភាពចម្រូងចម្រាស់នៅឡើយ)។

៥- សិទ្ធិចំពោះអភ័យឯកសិទ្ធិរបស់តំណាងរដ្ឋដែលបំពេញតួនាទីនៅក្នុងឋានៈផ្លូវការរបស់ពួកគេ(គេហៅថាជាអភ័យឯកសិទ្ធិមុខងារ)។

៦- សិទ្ធិចំពោះការគោរពជីវិត និងទ្រព្យសម្បត្តិរបស់អាណិកជនរបស់រដ្ឋ និងមន្ត្រីរាជការរបស់រដ្ឋនៅបរទេស។

អធិបតេយ្យភាពរួមបញ្ចូលនូវការការពារដោយទាហាននូវបូរណភាពទឹកដី ជាពិសេស

*ភាពមិនអាចកែប្រែបាននៃព្រំដែនការការពារដោយគយ និងនគរបាល។*

## ១.២- សមភាពគតិយុត្ត

*សមភាគគតិយុត្តទាមទារថា គ្មានសមាជិកណាមួយនៃសហគមន៍អន្តរជាតិអាចដាក់នៅក្នុងស្ថានភាពមួយចាញ់ប្រៀបគេឡើយ ៖ អ្វីទាំងអស់ត្រូវនៅក្នុងជំហរស្មើគ្នា។ ដូចដែល de Vattel បានប្រកាសតាំងពីឆ្នាំ១៧៥៨មកថា «មនុស្សតឿម្នាក់ក៏ដូចជាបុរសម្នាក់ និងយក្សម្នាក់ដែរ ហើយសាធារណរដ្ឋតូចមួយក៏មិនមែនរដ្ឋមួយមានអធិបតេយ្យតូចជាងរាជាណាចក្រដែលមានអំណាចជាងគេដែរ»។*

## ២- ការមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុង ឬកិច្ចការបរទេសរបស់រដ្ឋដទៃ

*គោលការណ៍មិនជ្រៀតជ្រែកក្នុងកិច្ចការរបស់រដ្ឋដទៃក៏ស្ថិតនៅក្នុងគំរូចាស់នៃសហគមន៍ពិភពលោកដែរ។ គោលការណ៍នេះជាគោលការណ៍មួយសំខាន់បំផុតតាមគំរូរបស់ Grotius។ ជាមួយនឹងគោលការណ៍សមភាពអធិបតេយ្យ គោលការណ៍មិនជ្រៀតជ្រែកត្រូវបានប្រឌិតឡើងដើម្បីធានាថា រដ្ឋនីមួយៗគោរពបុព្វសិទ្ធិជាសារវន្តរបស់សមាជិកដទៃនៃសហគមន៍។*

*គោលការណ៍នេះត្រូវបានលើកឡើងដោយវិធានទំនៀមទម្លាប់ពិសេសមួយចំនួន។*

*វិធានទីមួយគឺវិធានដែលហាមឃាត់រដ្ឋមួយមិនឱ្យជ្រៀតជ្រែកនៅក្នុងការរៀបចំផ្ទៃក្នុងរបស់រដ្ឋបរទេសមួយ។ រដ្ឋមួយមិនអាចសម្រេចថា អង្គភាពណារបស់រដ្ឋបរទេស មានសមត្ថភាពដើម្បីអនុវត្តកិច្ចណាមួយ និងមិនអាចហាមឃាត់ភ្នាក់ងារម្នាក់របស់រដ្ឋបរទេសមិនឱ្យរួចផុតពីសកម្មភាពមួយចំនួន ឬមិនឱ្យបំពេញកិច្ចណាមួយឡើយ។ វិធានមួយទៀតហាមមិនឱ្យរដ្ឋឈ្លានពានលើកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃឡើយ។ ដូច្នេះ ជាឧទាហរណ៍ រដ្ឋមួយមិនត្រូវអនុញ្ញាតឱ្យដាក់សម្ពាធទៅលើស្ថាប័នជាតិដោយឡែកនានារបស់រដ្ឋដទៃឡើយ( នីតិកម្ម អង្គភាពអនុវត្ត ឬអង្គចៅក្រម) ហើយក៏មិនអាចជ្រៀតជ្រែកនៅក្នុងទំនាក់ទំនងរវាងអាជ្ញាធរនានារបស់រដ្ឋាភិបាលបរទេស និងរបស់អាណិកជនរបស់រដ្ឋនោះផ្ទាល់ឡើយ។ ប៉ុន្តែវិធានមួយទៀតបង្គាប់ឱ្យធ្វើពហិការមិនញុះញង់ រៀបចំឬគាំទ្រជាផ្លូវការដល់ការរៀបចំសកម្មភាពដែលអាចបង្កមហន្តរាយនៅបរទេសនៅលើទឹកដីរបស់រដ្ឋនោះឡើយ។ ទោះជាយ៉ាងនេះក្តី រដ្ឋមិនដល់ថ្នាក់ហាមឃាត់នូវរាល់សកម្មភាពវិទ្ធង្សនា ជាពិសេសសកម្មភាពវិទ្ធង្សនាមួយប្រឆាំងនឹងរដ្ឋបរទេសដែលប្រព្រឹត្តឡើងដោយបុគ្គលឯកជនដោយគ្មានការអន្តរាគមន៍របស់រដ្ឋ។*

*វិធានទំនៀមទម្លាប់មួយទៀតចែងថា នៅរៀងរាល់លើកដែលសង្គ្រាមស៊ីវិលផ្ទុះឡើងនៅក្នុងប្រទេសបរទេសមួយ រដ្ឋមានកាតព្វកិច្ចធ្វើពហិការមិនជួយដល់ជនបះបោរ លើកលែងតែរដ្ឋ*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាំងនោះចាត់ទុកថា ខ្លួនមានលក្ខន្តិកៈជាចលនារំដោះជាតិ។

វិធានទាំងនេះនៅមានធរមានជានិច្ច។ ទោះជាហេតុនេះក្តី នៅសម័យកាលមុនឆ្នាំ១៩៤៥ រដ្ឋត្រូវបានអនុញ្ញាតឱ្យមិនគោរពទៅតាមវិធានទាំងនេះ ប្រសិនបើរដ្ឋរំពឹងថាផលប្រយោជន៍ខ្លួនមានឧត្តមានុភាពទៅលើវិធានទាំងនោះ។ បើរដ្ឋមួយធ្វើឱ្យគេពិចារណាទៅលើផលប្រយោជន៍របស់ខ្លួន នៅក្នុងការពិចារណាជាសំខាន់បំផុតជាស្របច្បាប់ រដ្ឋត្រូវបានអនុញ្ញាតឱ្យធ្វើអន្តរាគមន៍ដោយកម្លាំង ឬការគំរាមប្រើប្រាស់កម្លាំងនៅក្នុងកិច្ចការផ្ទៃក្នុង ឬបរទេសរបស់រដ្ឋមួយទៀត និងបង្ខំដាក់ឱ្យមានបន្ទាត់នយោបាយមួយ។

ការវិវត្តសំខាន់បីបានផ្តល់ជីវិតថ្មីមួយ និងអាថ្លានៃគោលការណ៍នេះ។

ជាបឋម ការបញ្ចូលនូវលក្ខខណ្ឌកំហិតស្របច្បាប់ដែលមានទ្រង់ទ្រាយធំៗទៅលើការប្រើប្រាស់ ឬការគំរាមប្រើប្រាស់កម្លាំង( ដែលបានផ្តល់ទៅឱ្យគោលការណ៍មិនជ្រៀតជ្រែកនូវអត្ថិភាពបែបបិតថេរ និងការកំណត់ព្រំដែនដែលច្បាស់ជាង)។

ទីពីរ គឺនិន្នាការកើនឡើងចំពោះកិច្ចសហប្រតិបត្តិការមួយដែលនេះជាអ្វីនាំឱ្យមានការវាតទីនៃអង្គការអន្តររដ្ឋាភិបាល និងបន្ថែមនូវលទ្ធភាពនៃអង្គការទាំងពីរនេះ ហើយរដ្ឋក៏លូកដៃនៅក្នុងផលប្រយោជន៍របស់រដ្ឋដទៃជាអន្តរជាតិដែរ។ ទាំងនេះនាំឱ្យមានភាពចាំបាច់ដែលមានទំនាក់ទំនងរបស់រដ្ឋក្នុងការកំណត់ឱ្យកាន់តែថ្លៃនូវវិស័យទាំងឡាយដែលរដ្ឋត្រូវបានអនុញ្ញាតឱ្យចៀសឆ្ងាយផុតពីការជ្រៀតជ្រែកពីខាងក្រៅទាំងអស់។

ការវិវត្តទីបី គឺការសាយភាយនៃលទ្ធិការពារសិទ្ធិមនុស្សជាមួយនឹងលទ្ធភាពសម្រាប់រដ្ឋដែលបានគោរព និងសម្រាប់បុគ្គលឯកជនក្នុងការដាក់សម្ពាធទៅលើរដ្ឋដទៃ ដើម្បីឱ្យស្របទៅតាមធម្មនិយាមពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្ស។

ដូច្នេះ គោលការណ៍មិនជ្រៀតជ្រែកបានទទួលតម្លៃជាសារវន្តនៃ«ស្ពាន»ដ៏រឹងមាំ និងចាំបាច់ខានមិនបានមួយរវាងរចនាសម្ព័ន្ធជាប្រពៃណីដែលផ្អែកទៅលើអធិបតេយ្យភាពនៃសហគមន៍អន្តរជាតិ និងនយោបាយ«ថ្មី»របស់រដ្ឋ។

បញ្ហាដែលចោទឡើងគឺត្រូវដឹងថា តើការហាមឃាត់មិនឱ្យមានការជ្រៀតជ្រែកនៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃក្តោបផងដែរឬទេទៅលើអន្តរាគមន៍នានាដែលមិនមានទម្រង់ជាការបញ្ជូន ឬការគំរាមកំហែងបញ្ជូនយន្តហោះយោធា ឬនាវាសង្គ្រាម ប៉ុន្តែវារួមបញ្ចូលនូវសម្ពាធសេដ្ឋកិច្ច ការបង្ខិតបង្ខំ ទាំងផ្នែកសេដ្ឋកិច្ចផងដែលនេះជាការប៉ះពាល់ដល់ការរំសាយកងទ័ពនយោបាយ ការញុះញង់ឱ្យប្រព្រឹត្ត ការបង្កឱ្យមាន និងហិរញ្ញប្បទានទៅលើវិបត្តិនៅក្នុងប្រទេសបរទេសមួយ។

យើងអាចចោទសួរខ្លួនឯងបានថា តើច្បាប់អន្តរជាតិហាមឃាត់ចំពោះការប្រើប្រាស់ដោយ

រដ្ឋមានអំណាចនូវទម្រង់ល្អិតល្អន់នៃការជ្រៀតជ្រែកដែលមានដូចជាការឃោសនាតាមវិទ្យុ ពហិការសេដ្ឋកិច្ចដោយបដិសេធចោលនូវជំនួយសេដ្ឋកិច្ច ឬជះឥទ្ធិពលទៅលើស្ថាប័នរូបិយវត្ថុ និងហិរញ្ញវត្ថុអន្តរជាតិ ដើម្បីគាបសង្កត់រដ្ឋដែលមានសេដ្ឋកិច្ចខ្សោយដែរឬទេ។

## ៣- ការហាមប្រាមមិនឱ្យគំរាមកំហែង ឬមិនឱ្យប្រើប្រាស់កម្លាំង

ការហាមមិនឱ្យគំរាមកំហែង ឬប្រើប្រាស់កម្លាំងត្រូវបានគ្រោងទុកនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ(មាត្រា២.៤)។ អង្គការសហប្រជាជាតិបានសម្រេចឯកភាពលើការគ្របដណ្តប់ទៅលើស្វ័យកំណត់បុព្វសិទ្ធិអធិបតេយ្យ ក្រោមទម្រង់ជាកាតព្វកិច្ចទៅវិញទៅមកក្នុងការធ្វើពហិការប្រើប្រាស់ ឬគំរាមប្រើប្រាស់កម្លាំង។

មាត្រា២.៤ជានានូវសំណើដូចខាងក្រោម ៖

ជាបឋម ការហាមប្រើកម្លាំង គឺជា«ការហាមដាច់ខាតគ្រប់ជ្រុងជ្រោយ»។ ការគំរាម ឬប្រើ-ប្រាស់កម្លាំងត្រូវបានហាមឃាត់នៅក្នុងគ្រប់កាលៈទេសៈ លើកលែងតែកាលៈទេសៈនានាដែលមានចែងនៅជំពូក៧(វិធានការបង្ខំរួម) មាត្រា៥១(ស្វ័យការពារ) មាត្រា៥៣(វិធានការប្រតិបត្តិដោយអង្គភាពតំបន់) និងនៅក្នុងបទប្បញ្ញត្តិផ្សេងទៀត(មាត្រា១០៦ និង១០៧ ស្តីពីអតីត«រដ្ឋជាសត្រូវ»ដែលលែងមានបច្ចុប្បន្នភាពតាំងពីពេលនោះមក)។

ទីពីរ មានតែកម្លាំងយោធាតែមួយមុខគត់ដែលត្រូវបានលើកឡើង។

ទីបី ការគំរាមកំហែង ឬការប្រើប្រាស់កម្លាំងនៅក្នុងទំនាក់ទំនងអន្តររដ្ឋត្រូវបានហាមឃាត់។ រដ្ឋសមាជិកត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់វិធានការបង្ខំ ដើម្បីបង្ក្រាបជនបះបោរនៅលើទឹកដីរបស់ពួកគេ ឬដើម្បីប្រយុទ្ធប្រឆាំងទៅនឹងចលនារំដោះដែលតស៊ូដើម្បីឯករាជ្យភាពនៅក្នុងទឹកដីដែលនៅចំណុះក្រោមការត្រួតត្រារបស់ដែនដីអាណានិគមដែលត្រូវចាត់ទុកដោយមហាអំណាចអាណានិគមថាជាសមភាគពេញលេញនៃទឹកដីរបស់ពួកគេផ្ទាល់នៅក្នុងលក្ខខណ្ឌដែលទឹកដីទាំងនោះនៅក្រោមអំណាចដាច់មុខរបស់ពួកគេ។

ក្រោយឆ្នាំ១៩៤៥ ការហាមឃាត់នៃមាត្រា២.៤ត្រូវបានបំលែងបន្តិចម្តងៗទៅជាវិធានទូទៅមួយនៃច្បាប់អន្តរជាតិ ដូច្នេះវាក៏ចងរដ្ឋមិនមែនសមាជិកដែរ។

ដោយហេតុតែតុលាការយុត្តិធម៌អន្តរជាតិបានបើកសវនាការនៅប្រទេសនីការ៉ាហ្គានៅឆ្នាំ១៩៨៦ (រឿងក្តី) (កថាខណ្ឌ១៩៥) វាចាំបាច់ត្រូវបែងចែក«ទម្រង់ធ្ងន់ធ្ងរបំផុតនៃការប្រើប្រាស់កម្លាំង(ការប្រើប្រាស់កម្លាំងដែលផ្សំបានជាការឈ្លានពានប្រដាប់អាវុធ)ពីទម្រង់ផ្សេងទៀតដែលមានទម្រង់ស្រាលជាង។ ជាឧទាហរណ៍ យោងតាមតុលាការអន្តរជាតិ «ជំនួយដល់ពួកឧទ្ទាមនៅក្រោមទម្រង់ជាផ្តល់អាវុធ ឬជាជំនួយកស្តុភារ ឬផ្សេងទៀត» អាចត្រូវចាត់ទុកថាជាការគំរាម

*កំហែង ឬការប្រើប្រាស់កម្លាំង។*

*កម្លាំងមិនត្រូវប្រើប្រាស់ក្នុងគោលដៅបង្ការការវាយប្រហារអច្ចាសន្នមួយដោយរដ្ឋមួយទៀត( គឺជាការវាយប្រហារមួយដែលគេសន្មតថាជាអច្ចាសន្ន)។ នេះជាបណ្តុំគំនិតនៃការការពារស្របច្បាប់ជាមុន។*

*កម្លាំងនៅក្នុងការការពារស្របច្បាប់មិនអាចត្រូវប្រើប្រាស់ដើម្បីរុញច្រានការវាយប្រហារប្រដាប់អាវុធដោយប្រយោលឡើយ។*

*ទឹកដីដែលជាកម្មសិទ្ធិរបស់រដ្ឋមួយមិនអាចជា«កម្មវត្ថុនៃលទ្ធកម្មដោយរដ្ឋមួយទៀតដែលជាលទ្ធផលនៃការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង( សេចក្តីប្រកាសឆ្នាំ១៩៧០ គោលការណ៍ ១ កថាខណ្ឌទី១០។ នៅក្នុងបុព្វហេតុគតិយុត្តនៃការកសាងជញ្ជាំងមួយ( នៅកថាខណ្ឌទី៨៧ និង១១៧)។*

*ទម្រង់ខ្ពស់បំផុតនៃការបង្ខិតបង្ខំសេដ្ឋកិច្ចដែលឈានដល់ជាការគំរាមកំហែងមួយដល់សន្តិភាពត្រូវបានហាមឃាត់។*

## ៤- ការដោះស្រាយជម្លោះដោយសន្តិវិធី

*ធម្មនុញ្ញអង្គការសហប្រជាជាតិបង្ខំឱ្យរដ្ឋសមាជិកដោះស្រាយជម្លោះអន្តរជាតិរបស់ពួកគេដោយសន្តិវិធី( មាត្រា២.៣)។ ជំពូក៦ ពង្រឹងកាតព្វកិច្ចនេះទាក់ទងទៅនឹងពល់វិវាទដែលអាចនឹងគំរាមដល់ការថែរក្សាសន្តិភាព និងសន្តិសុខ។ ក្រុមប្រឹក្សាសន្តិសុខអាចអញ្ជើញគូភាគីជម្លោះទាំងនេះឱ្យដោះស្រាយដោយវិធីសាស្ត្រសន្តិវិធី( ឬអាច«សិក្សា»នូវជម្លោះ ឬផ្តល់អនុសាសន៍ដល់គូភាគីទាក់ទិនទៅនឹងការជ្រើសរើសនីតិវិធី និងការដោះស្រាយជម្លោះ)។*

*វិធីទំនៀមទម្លាប់មួយបានវិវត្តនៅលើបញ្ហានេះ ដូចដែលសក្ខីភាពនៃសេចក្តីប្រកាសសហប្រជាជាតិស្តីពីទំនាក់ទំនងមិត្តភាពឆ្នាំ១៩៧០( សេចក្តីសម្រេចរបស់មហាសន្និបាតលេខ២៦២៥ ក្នុងមាត្រា២) និងសេចក្តីប្រកាសទីក្រុងម៉ានីលស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធីឆ្នាំ១៩៨២ ( សេចក្តីសម្រេចលេខ៣៧/១០របស់មហាសន្និបាត)។ តុលាការយុត្តិធម៌អន្តរជាតិបានអះអាងបញ្ជាក់នូវគោលការណ៍អាជ្ញានៅប្រទេសនីការ៉ាហ្គា( រឿងក្តី)។ តុលាការអន្តរជាតិបានទទូចដើម្បីឱ្យគោលការណ៍នេះត្រូវ«បំពេញបន្ថែម»ទៅលើគោលការណ៍ដែលមានលក្ខណៈហាមឃាត់ ក៏ដូចជាគោលការណ៍ដែលហាមឃាត់ការប្រើប្រាស់កម្លាំង និងទទូចសុំឱ្យ«ការគោរពគោលការណ៍»មានភាពជាសារវន្តនៅក្នុងពិភពលោកសព្វថ្ងៃនេះ»។ តុលាការបានបន្តដោយបញ្ជាក់ថា «គោល-ការណ៍នេះក៏មានលក្ខន្តិកៈជាច្បាប់ទំនៀមទម្លាប់» (កថាខណ្ឌទី២៩០ នៅក្នុងរឿងក្តីខ្ពង់រាបបាតសមុទ្រនៃសមុទ្រខាងជើង តុលាការអន្តរជាតិបានលើកឡើងរួចទៅហើយពីគោលការណ៍នេះ*

*ដោយមានការផ្តោតពិសេសទៅលើការអនុវត្តរបស់វាចំពោះការចរចា។ សូមមើលកថាខណ្ឌ៨៦-៧)។*

**ដែនអនុវត្តគោលការណ៍នេះ**

*ជាបឋម រដ្ឋត្រូវព្យាយាមដោះស្រាយជម្លោះរបស់ពួកគេដោយសន្តិវិធី និងដោយស្មោះត្រង់។ នៅក្នុងគោលដៅនេះ រដ្ឋត្រូវតែសាកល្បងវិធីសាស្ត្រ និងនីតិវិធីផ្សេងៗដែលមាន( ការចរចា សន្ទានកម្ម ការសម្រុះសម្រួល ការប្រើប្រាស់យន្តការមជ្ឈត្តការ ឬតុលាការ-ល-)។ តែទោះជាយ៉ាងណាក្តី រដ្ឋមិនចាំបាច់ជ្រើសរើសវិធីសាស្ត្រដោះស្រាយពិសេសណាមួយឡើយ( លើកលែងតែការដោះ-ស្រាយនេះត្រូវបានគ្រោងទុកនៅក្នុងសន្ធិសញ្ញាមួយ)។*

## ៥- ការគោរពសិទ្ធិមនុស្ស

*ផ្ទុយពីគោលការណ៍អធិបតេយ្យភាព និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងដែលជាសំនួនសេចក្តីមួយដូចនឹងគំរូរបស់ Grotius គោលការណ៍ដែលបង្ខំឱ្យមានការគោរពសិទ្ធិមនុស្សដូចជាការហាមឃាត់មិនឱ្យគំរាមកំហែង ឬប្រើប្រាស់កម្លាំងគឺត្រូវចំទៅនឹងដំណាក់កាលថ្មីនៃការអភិវឌ្ឍសហគមន៍អន្តរជាតិនៅសម័យក្រោយសង្គ្រាមលោកលើកទីពីរ។*

*គោលការណ៍គោរពសិទ្ធិមនុស្សប្រកួតប្រជែងនឹងគោលការណ៍ប្រពៃណីនៃសមភាពអធិប-តេយ្យនៃរដ្ឋ និងមិនជ្រៀតជ្រែក។ ដោយហេតុនេះហើយទើបគោលការណ៍នេះពិបាកនឹងសម្រុះសម្រួលជាមួយគោលការណ៍ពីរទៀត។*

*ការអនុម័តធម្មនុញ្ញអង្គការសហប្រជាជាតិ និងឧបករណ៍អន្តរជាតិជាសារវន្តដែលមានដូចជាសេចក្តីប្រកាសសាកលឆ្នាំ១៩៤៨ និងកតិកាសញ្ញាអន្តរជាតិពីរស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៦៦ បានមានឥទ្ធិពលមួយទៅលើសហគមន៍អន្តរជាតិដែលគ្មានរដ្ឋណាមួយនៅពេលបច្ចុប្បន្នជំទាស់នឹងគំនិតដែលថា សិទ្ធិមនុស្សត្រូវតែគោរពនៅគ្រប់ទីកន្លែងនៅក្នុងពិភពលោក។*

*គោលការណ៍ទូទៅមួយបានលេចឡើងជាលំដាប់ៗដោយហាមឃាត់ចំពោះការរំលោភ-បំពានច្បាស់ក្រឡែត និងទាំងដុលទៅលើសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត។*

*គោលការណ៍នេះមិនដាក់ជាកាតព្វកិច្ចដល់រដ្ឋឱ្យសម្របខ្លួនទៅតាមការធ្វើនិយ័តកម្មដោយឡែកអំពីសិទ្ធិមនុស្ស។ ផ្ទុយពីនេះ គោលការណ៍នេះទទូចសុំឱ្យរដ្ឋធ្វើអនុប្បវាទចំពោះការប៉ះពាល់ធ្ងន់ធ្ងរទៅលើសិទ្ធិជាសារវន្តមួយ( ឧទាហរណ៍សិទ្ធិមិនដាក់ទណ្ឌកម្ម ឬសិទ្ធិទទួលបានសវនាការមានសមធម៌ ឬសេរីភាពប្រឆាំងនឹងការឃាត់ខ្លួនដោយគ្មានហេតុផល) និងជាន់ឈ្លីទៅលើចង្កោមសិទ្ធិទាំងអស់( ឧទាហរណ៍សិទ្ធិរដ្ឋប្បវេណី និងនយោបាយជាសារវន្ត ឬសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌)។*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៦- ស្វ័យសម្រេចរបស់ប្រជាជន

លើកតម្កើងដោយបដិវត្តន៍បារាំង បន្ទាប់មកត្រូវបានគាំទ្រយ៉ាងខ្លាំងក្លាដោយឥស្សរជនរដ្ឋដែលមានដូចជាលេនីន និងវីលសុនជាដើម។

អនុលោមតាមគោលវិធីបុរាណនេះ សហគមន៍ពិភពលោកដែលរួមមានមហាពជកាន់អំណាចផ្តាច់ការ រដ្ឋអធិបតេយ្យដែលនៅក្នុងនោះ រដ្ឋនីមួយៗពាក់ព័ន្ធជាគោលដោយផលប្រយោជន៍នៃក្រុមវរជននយោបាយផ្ទាល់របស់រដ្ឋ។

ស្វ័យសម្រេចមានន័យថា ប្រជាជន និងរដ្ឋត្រូវតែមានសំឡេងនៅក្នុងទំនាក់ទំនងអន្តរជាតិ ៖ អំណាចអធិបតេយ្យលែងអាចចាត់ចែងអំណាចដោយសេរីទៀតហើយ ឧទាហរណ៍ដូចជាប្រគល់ ឬធ្វើទេសានុពន្ធន៍ទឹកដីដោយមិនបានគិតដល់ឆន្ទៈរបស់ប្រជាជនពាក់ព័ន្ធ តាមរយៈប្រជាសិទ្ធិ ឬប្រជាមតិជាដើម។ ប្រជាជនក៏ត្រូវមានតួនាទីនៅក្នុងការដឹកនាំកិច្ចការជាតិ និងអន្តរជាតិដែរ។ ដូច្នេះ ស្វ័យសម្រេចត្រូវបានតាំងឡើងជាគោលការណ៍ប្រជាធិបតេយ្យមួយដែលទាមទារឱ្យមានការយល់ព្រមពីរាស្ត្រនៅក្នុងរដ្ឋអធិបតេយ្យមួយ។

ជាក់ស្តែងសារពើនៃគោលការណ៍ទាំងនេះត្រូវបានសម្រេចឡើងដើម្បីបំផ្លាញគ្រឹះគោល-ការណ៍ប្រពៃណីដែលសង្គមអន្តរជាតិធ្លាប់បានផ្អែកលើចាប់តាំងពីកកើតមក ៖ នេះគឺការឡើងកាន់អំណាចតាមសន្តតិវង្ស ពោលគឺអត្តាវសនិយម( despotisme)។

ស្វ័យសម្រេចក៏បានបំបាត់ឧបជារណ៍មួយក្នុងចំណោមឧបជារណ៍ជាច្រើននៃមូលដ្ឋានរបស់សហគមន៍អន្តរជាតិបុរាណដែរ ៖ អធិបតេយ្យភាពទឹកដី។ អធិបតេយ្យភាពទឹកដីមានន័យថា ប្រធាននីតិអន្តរជាតិនីមួយៗត្រូវគោរពយ៉ាងពេញលេញនូវអាជ្ញាធរផ្សេងទៀតដែលអនុវត្តអំណាចនៅលើទឹកដីមួយ និងប្រជាជនដែលរស់នៅលើទឹកដីនោះ មិនថា ប្រជាជននោះបានទទួលឋានៈដែនដីដោយវិធីណាទេ( ទោះជាដោយការវាយដណ្តើមយក ការទទួលមរតកបែបតពូជ ឬការដូរស្មើគ្នាជាមួយមហាក្សត្រមួយអង្គទៀត)។

ស្វ័យសម្រេចលេចចេញដូចជាចាក់ឫសយ៉ាងមាំនៅក្នុងកម្រងនៃច្បាប់អន្តរជាតិនៅក្នុងតំបន់បី ៖ ពោលវាគឺជាធម្មនិយាមប្រឆាំងអាណានិគមនិយម ការហាមប្រាមមិនឱ្យកាន់កាប់ដោយយោធាបរទេស និងការទទូចសុំឱ្យក្រុមពូជសាសន៍ទាំងអស់មានសិទ្ធិពេញលេញទទួលបានរដ្ឋាភិបាល។

ការទទួលយកគោលការណ៍នៅក្នុងវិស័យច្បាប់មានលក្ខណៈជាជម្រើស និងមានដែន-កំណត់នៅក្នុងទស្សនៈជាច្រើន។ ជាពិសេស ច្បាប់អន្តរជាតិបច្ចុប្បន្នស្តីពីស្វ័យសម្រេចមិនបានគិតគូរពីការទាមទាររបស់ក្រុមជាតិពន្ធុ( មិនមែនបង្កើតជាក្រុមជាតិសាសន៍ទេ) និងរបស់ក្រុមជនជាតិភាគតិចសាសនា វប្បធម៌ ឬភាសាវិទ្យាជាតិ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី៤
# ទ្រឹស្ដីនៃសមត្ថកិច្ចផ្ដាច់មុខរបស់រដ្ឋ

*គោលការណ៍អធិបតេយ្យភាពរបស់រដ្ឋគឺជាសញ្ញាណគន្លឹះមួយនៃច្បាប់អន្តរជាតិសាធារណៈ។ រដ្ឋគឺសំដៅដល់«សមូហភាពមួយដែលផ្សុំឡើងដោយទឹកដីមួយ និងប្រជាជនដែលស្ថិតនៅក្រោមចំណុះនៃអំណាចនយោបាយមួយដែលមានរចនាសម្ព័ន្ធ និងដែលស្តែងឡើងដោយអធិបតេយ្យភាព»។*

*បណ្ដុំបញ្ហា ៖ តើគេអាចការពារអធិបតេយ្យភាពរបស់រដ្ឋនៅក្នុងច្បាប់អន្តរជាតិ ព្រមទាំងរក្សាបាននូវទ្រឹស្ដីនៃសមត្ថកិច្ចផ្ដាច់មុខរបស់រដ្ឋបានយ៉ាងដូចម្ដេចទៅនៅចំពោះមុខនៃការលេចឡើងនៃទស្សនាទានសាកលនៅក្នុងទំនាក់ទំនងអន្តរជាតិ?*

## ១- គោលការណ៍មិនជ្រៀតជ្រែក

***អធិបតេយ្យភាព****ប្រើសម្រាប់កំណត់ដែនឥទ្ធិពលរបស់រដ្ឋមួយចំពោះរដ្ឋទីបី និងអនុញ្ញាតឱ្យរដ្ឋបន្តរក្សាផលប្រយោជន៍របស់ខ្លួននៅក្នុងផ្ទៃប្រទេស និងនៅកម្រិតអន្តរជាតិ។*

*រដ្ឋគឺជាប្រធាននៃនីតិអន្តរជាតិសាធារណៈតែមួយគត់ដែលមានអធិបតេយ្យភាពពេញលេញ។ ជាបឋម អធិបតេយ្យភាពរួមបញ្ចូលនូវការការពារបូរណភាពទឹកដី ជាពិសេសភាពមិនអាចរំលោភបាននូវព្រំដែនរបស់រដ្ឋពីសំណាក់កងទ័ព គយ និងនគរបាល។ បន្ថែមពីនេះទៀតគឺ* មានឯករាជ្យភាពរបស់រដ្ឋ[៩៣] មានន័យថា *សេរីភាពរបស់រដ្ឋក្នុងការសម្រេចលើប្រព័ន្ធនយោបាយ វប្បធម៌ សេដ្ឋកិច្ច និងសង្គមទាំងដោយគ្មានទម្រង់នៃការជ្រៀតជ្រែកណាមួយពីសំណាក់រដ្ឋមួយទៀត*[៩៤]។ *«ច្បាប់អន្តរជាតិគឺមិនខ្វាយខ្វល់អំពីលក្ខខណ្ឌអនុវត្តអធិបតេយ្យភាពផ្ទៃក្នុង»។*[៩៥] *អធិបតេយ្យភាពរបស់រដ្ឋក៏ត្រូវបានបញ្ជាក់ផងដែរនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិថា ជាគោលការណ៍មូលដ្ឋាននៃទំនាក់ទំនងរវាងសហប្រជាជាតិ។ «អង្គការត្រូវបានបង្កើតឡើងនៅលើគោលការណ៍សមភាពអធិបតេយ្យនៃរដ្ឋសមាជិកទាំងអស់របស់អង្គការ»។*[៩៦] *ពាក្យថា សមភាពអធិបតេយ្យសំដៅដល់សមភាពគតិយុត្ត។*

---

[៩៣] *cf. la sentence arbitrale de Max Huber (CPA) dans l'affaire Ile de Palmas du 4 avril 1928.*

[៩៤] *cf. principe de non-ingérence, édit dans la résolution 2625 (XXV) de l'ONU et dans la Charte de l'ONU les art. 1 §2 et 2 §§4,7 ; CIJ, affaire Détroit de Corfou, décision du 9 avril 1949).*

[៩៥] *cf. Decaux, Emmanuel, Hypercours Droit international public, p. 197.*

[៩៦] *cf. Charte de l'ONU, article 2, § 1er.*

## ២- ទ្រឹស្តីសមត្ថកិច្ចដាច់មុខរបស់រដ្ឋ

*សមត្ថកិច្ចផ្តាច់មុខទាក់ទិនទៅនឹងបណ្តុំគំនិតនៃអធិបតេយ្យភាព។ វិស័យនេះត្រូវប្រើប្រាស់ដើម្បីបរិយាយពីសមត្ថកិច្ចដាច់មុខរបស់រដ្ឋដែលមានដូចជាវិស័យរូបិយវត្ថុ នយោបាយបរទេស ឬយោធា។ វិទ្យាស្ថានច្បាប់អន្តរជាតិនៅឆ្នាំ១៩៥៤បានកំណត់វិស័យនេះដូចតទៅ ៖ «សមត្ថកិច្ចផ្តាច់មុខគឺជាវិស័យនៃសកម្មភាពរបស់រដ្ឋដែលនៅក្នុងនោះសមត្ថកិច្ចរបស់រដ្ឋមិនមានពាក់ព័ន្ធដោយច្បាប់អន្តរជាតិ។ វិសាលភាពនៃសមត្ថកិច្ចនេះអាស្រ័យនឹងច្បាប់អន្តរជាតិ និងប្រែប្រួលទៅតាមការអភិវឌ្ឍនៃច្បាប់អន្តរជាតិ។ ការចុះកិច្ចសន្យាអន្តរជាតិមួយនៅក្នុងកិច្ចការដែលនៅក្រោមក្របខ័ណ្ឌនៃសមត្ថកិច្ចផ្តាច់មុខចំពោះភាគីមួយនៃកិច្ចសន្យានេះ គឺប្រានចេញលទ្ធភាពលើកយកភាពលើកលែងរបស់សមត្ថកិច្ចផ្តាច់មុខទៅប្រឆាំងនឹងរាល់បញ្ហាដែលទាក់ទងទៅដល់ការបកស្រាយ ឬការអនុវត្តកិច្ចសន្យាដែលបានពោលខាងលើ»។[៩៧]*

*ទ្រឹស្តីនៃសមត្ថកិច្ចផ្តាច់មុខព្យាយាមបង្ការ និងការពារសមត្ថកិច្ចរៀបចំផ្ទៃក្នុងរបស់រដ្ឋមួយប្រឆាំងទៅនឹងការជាន់ឈ្លីឈ្លានពានរបស់រដ្ឋ ឬអង្គការអន្តរជាតិដទៃទៀត។*

*ដូច្នេះ គេអាចកត់សម្គាល់ថា គ្មានសមត្ថកិច្ចផ្តាច់មុខតាមធម្មជាតិទេ ហើយថា «បញ្ហាដែលត្រូវដឹងថា តើសមត្ថកិច្ចណាមួយចូល ឬមិនចូលនៅក្នុងសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋមួយគឺជាបញ្ហាដែលមានការទំនាក់ទំនង ៖ បញ្ហានេះអាស្រ័យទៅនឹងការអភិវឌ្ឍទំនាក់ទំនងអន្តរជាតិ»។[៩៨]*

## ៣- ការវិវត្តយ៉ាងលឿននៅក្នុងទំនាក់ទំនងអន្តរជាតិបានធ្វើឱ្យទ្រឹស្តីសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋចុះខ្សោយ

*គេអាចសង្កេតឃើញអំពីការប៉ះពាល់ដល់អធិបតេយ្យភាព និងដល់សមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋ។ បច្ចុប្បន្ននេះ អធិបតេយ្យភាព និងសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋបានលើកឧបសគ្គនៃការអភិវឌ្ឍសំខាន់ចំនួនបួននៅក្នុងទំនាក់ទំនងអន្តរជាតិ។*

*១- ជាបឋម បាតុភូតនៃបំបែករដ្ឋមួយ(ករណីជាឧទាហរណ៍ ប្រទេសសេរ៉ា ឡេអូន សូម៉ាលី លីបេរីយ៉ា)ដែលស្តែងឡើងតាមរយៈការបែកតូចៗនៃអំណាចដែលទាមទារពីសំណាក់រដ្ឋទីបី(ឬបន្ទាប់ពីមានការស្នើសុំរបស់រដ្ឋដែលពាក់ព័ន្ធ) សេចក្តីសម្រេចស្រប ឬប្រឆាំងនឹងការជ្រៀតជ្រែកមួយ ដើម្បីបង្កើតសណ្តាប់ធ្នាប់ឡើងវិញជាវិធានការមួយដែលលែងប្រកាន់ខ្ជាប់ចំពោះការបកស្រាយម៉ឺងម៉ាត់នៃគោលការណ៍មិនជ្រៀតជ្រែក។*

*២- បន្ទាប់មកទៀត សាកលភាវូបនីយកម្ម និងតំបន់ភាវូបនីយកម្មនាំទៅដល់កិច្ចសហប្រតិបត្តិការរវាងរដ្ឋ(ឧទាហរណ៍ ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានការរៀបចំ)នាំទៅដល់*

---

[៩៧] *Daillier/Pellet, DIP, 7e édition, no 283.*

[៩៨] *cf. la CPJI dans l'affaire des décrets de nationalité en Tunisie et au Maroc du 7 février 1923.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការបង្កើតអង្គការមិនមែនរដ្ឋាភិបាលដែលនេះធ្វើឱ្យកើនឡើងនូវអន្តរាគមនិស្សរភាពរបស់សហគមន៍អន្តរជាតិ។

៣-លើសពីនេះ «នៅពេលបច្ចុប្បន្ននេះ ក្របខ័ណ្ឌគតិយុត្តនៃទំនាក់ទំនងអន្តរជាតិមិនកំណត់នៅក្នុងភាពទាំងមូលរបស់វាដោយច្បាប់សាធារណៈទេ»។ ជាឧទាហរណ៍ នៅក្នុងវិស័យរូបិយវត្ថុ និងហិរញ្ញវត្ថុ ប្រព័ន្ធឯកជនមានឧត្តមានុភាពទៅលើប្រព័ន្ធរូបិយវត្ថុអន្តរជាតិសាធារណៈនៅជុំវិញមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក(BIRD)ដែលត្រូវបានបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី២។ ចំណែកឯតំបន់ភាវូបនីយកម្មវិញ យើងត្រូវតែគិតដល់ការកសាងសហគមន៍អឺរ៉ុបជាមួយនឹងទីផ្សារតែមួយ គឺតំបន់អឺរ៉ូ និងសហប្រតិបត្តិការក្នុងវិស័យព្រហ្មទណ្ឌរបស់នគរបាល និងយុត្តិធម៌(ឧទាហរណ៍អឺរ៉ូប៉ូល)។

៤- ចុងក្រោយគេ ការលើកតម្កើងសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌ ជាពិសេសជាមួយនឹងការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ នាំឱ្យមានស្ថានភាពមួយដែលក្នុងនោះស្ថាប័នអន្តរជាតិមួយត្រៀមខ្លួននឹងដឹកនាំប្រព័ន្ធយុត្តាធិការជាតិដែលដូចនេះវាគំរាមដល់អភ័យឯកសិទ្ធដើមដំបូងរបស់ស្ថាប័ននេះ។ លើសពីនេះទៀត ទស្សនាទានសិទ្ធិមនុស្សមានវិសាលភាពសាកលដែលឆ្លងហួសពីក្របខ័ណ្ឌនៃអធិបតេយ្យភាពរបស់រដ្ឋ។ ការកាត់ទោសនៅពេលបច្ចុប្បន្នទៅលើអតីតនាយករដ្ឋមន្ត្រីនៃអតីតប្រទេសយូកូស្លាវី ស្លូបូដាន មីឡូសេវិចដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពីបទប្រល័យពូជសាសន៍នៅបូស្នី និងនៅកូសូវ៉ូដោយតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូកូស្លាវី សង្កត់ធ្ងន់លើការផ្តន្ទាទោសនេះ។

## ៤- ពី«ភាតព្វកិច្ចជ្រៀតជ្រែក»ឆ្ពោះទៅ«ទំនួលខុសត្រូវក្នុងការការពារ»?

ការដកសិទ្ធិមនុស្សចេញពីសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋបាននាំតួអង្គមួយចំនួន និងរដ្ឋមួយចំនួនស្នើឱ្យបង្កើតភាតព្វកិច្ច ឬសិទ្ធិជ្រៀតជ្រែកមួយ(ឬអន្តរាគមន៍) មនុស្សធម៌មួយដែលអនុលោមតាមនោះ រដ្ឋឬអង្គការមិនមែនរដ្ឋាភិបាល នឹងមានមូលដ្ឋានផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ប្រជាជនដែលកំពុងស្ថិតនៅក្នុងស្ថានភាពទុក្ខភ័យ។

ប្រសិនបើមានភាតព្វកិច្ចផ្តល់ជំនួយមនុស្សធម៌មួយ ភាតព្វកិច្ចនោះគឺច្រើនស្ថិតនៅក្រោមសីលធម៌ ជាងនៅក្រោមនីតិវិជ្ជមាន និងជាងនៅក្រោមគោលការណ៍ការពារសិទ្ធិមនុស្ស ហើយសិទ្ធិអភិវឌ្ឍផ្តល់ឱ្យសិទ្ធិនេះនូវសង្កតភាពគតិយុត្តមួយ។

គឺនៅក្នុងក្របខ័ណ្ឌនេះហើយដែលក្រុមប្រឹក្សាសន្តិសុខបានអនុម័តសេចក្តីសម្រេចលេខ ៦៨៨(ឆ្នាំ១៩៩១) ស្តីពីជំនួយដល់ប្រជាជនស៊ីវិលឃើឌនៅប្រទេសអ៊ីរ៉ាក់។ យើងក៏ត្រូវកត់សម្គាល់ថាប្រសិនបើវាទាមទារឱ្យប្រទេសអ៊ីរ៉ាក់សហការជាមួយអគ្គលេខាធិការនៅក្នុងគោលបំណងនេះ

ក្រុមប្រឹក្សាសន្តិសុខដាក់កំហិតដើម្បីទទួចឱ្យ«ប្រទេសអ៊ីរ៉ាក់អនុញ្ញាតឱ្យអង្គការមនុស្សធម៌អន្តរ-ជាតិចូលទៅជួយប្រជាជនដែលត្រូវការជំនួយភ្លាមៗ»។

ចំពោះអង្គមហាសន្និបាតវិញ ទៅតាមការផ្តួចផ្តើមគំនិតរបស់ប្រទេសបារាំង បានអនុម័តសេចក្តីសម្រេចបីដែលតាមរយៈនោះ អង្គមហាសន្និបាតអញ្ជើញ«រដ្ឋទាំងអស់ដែលត្រូវការជំនួយមនុស្សធម៌ដល់ជនរងគ្រោះមហន្តរាយធម្មជាតិ និងជនរងគ្រោះនៃស្ថានភាពបន្ទាន់ក្នុងកម្រិតដូចគ្នានេះដែលជាការបញ្ជិតបញ្ចៀងយ៉ាងសមរម្យចំពោះសង្គ្រាមស៊ីវិល ដើម្បីសម្រួលដល់ការប្រតិបត្តិដោយអង្គការមានសមត្ថកិច្ច(សេចក្តីសម្រេចលេខ៤៣/១៣១ និងសូមមើលសេចក្តីសម្រេចលេខ៤៥១០០ និង៤៦/១៨២)។ ទោះជាយ៉ាងនេះក្តី អង្គមហាសន្និបាតក៏បានទទូចផងដែរទៅលើអធិបតេយ្យរបស់រដ្ឋដែលមានការពាក់ព័ន្ធ និងតួនាទីបឋមដែលរដ្ឋមាន»។

តុលាការយុត្តិធម៌អន្តរជាតិកាន់តែទៅក្បោះក្បាយថែមទៀតនៅក្នុងសាលដីកាចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៦ ពីព្រោះតុលាការបានទទួលស្គាល់ថា «ការផ្តល់ជំនួយជាមនុស្សធម៌តែមួយគត់ទៅបុគ្គល ឬកងកម្លាំងដែលកំពុងស្ថិតនៅក្នុងប្រទេសមួយទៀត(...) មិនអាចត្រូវចាត់ទុកថាជាអន្តរាគមន៍ខុសច្បាប់ទេ» ប្រសិនបើជំនួយនេះបង្ហាញនូវចរិតលក្ខណៈមនុស្សធម៌តែមួយគត់ និងធ្វើឡើងដោយគ្មានការរើសអើង(កម្រងឆ្នាំ១៩៨៦ ទំព័រ១២៤-១២៥)។ នេះប្រហែលគឺជានិយមន័យដែលត្រឹមត្រូវ និងជាដែនកំណត់ដែលទទួលយកបាននៃច្បាប់ជំនួយមនុស្សធម៌យោងទៅតាមទស្សនគតិយុត្ត។

ស្ថានភាពនៅក្នុងអតីតប្រទេសយូហ្គូស្លាវីជាមួយនឹងបណ្តុំនៃឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ប្រទេសនេះជាមួយនឹងចរិតលក្ខណៈនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និងផ្ទៃក្នុងរបស់ប្រទេសនេះបានធ្វើឱ្យទ្រាំទ្រលែងបាននូវដែនកំណត់នៃគោលវិធីគតិយុត្តបុរាណ។ ផ្អែកលើឧបាស្រ័យក្នុងជំពូកទី៧នៃធម្មនុញ្ញ ព្រមទាំងលើការប្រកាន់ជំហររបស់តុលាការយុត្តិធម៌អន្តរជាតិនៅក្នុងអធិបញ្ញារបស់តុលាការនេះចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៣(សេចក្តីសម្រេចលេខ៨១៩របស់ក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៩៣) អង្គភាពចម្បងៗរបស់សហប្រជាជាតិបានប្រកាន់យកជំនួយមនុស្សធម៌ជាកម្មវត្ថុទីមួយនៃអន្តរាគមន៍រួមគ្នា និងជាយុត្តិកម្មនៃជំហរអន្តរប្រទេសនៅក្នុងតំបន់មួយចំនួន ព្រមទាំងទណ្ឌកម្មសេដ្ឋកិច្ច(សូមមើលសេចក្តីសម្រេចលេខ៧២៤របស់ក្រុមប្រឹក្សាសន្តិសុខចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩១ និងសេចក្តីសម្រេចបន្តបន្ទាប់)។ ប្រតិកម្មរបស់សហប្រជាជាតិនៅក្នុងកិច្ចការរបស់ប្រទេសសូម៉ាលី និងរវ៉ាន់ដាបង្ហាញនូវចរិតលក្ខណៈស្រដៀងគ្នានេះ។

# ផ្នែកទី៥
# សមត្ថកិច្ចរបស់រដ្ឋ

*រដ្ឋអនុវត្តសមត្ថកិច្ចពីរប្រភេទ គឺសមត្ថកិច្ចបុគ្គល និងសមត្ថកិច្ចដែនដី។*

## ១- សមត្ថកិច្ចបុគ្គល

*រដ្ឋអនុវត្តសមត្ថកិច្ចបុគ្គលទៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដោយឈរលើមូលដ្ឋាននៃឋានៈសញ្ជាតិ នៅលើទឹកដីរបស់រដ្ឋ ឬនៅលើទឹកដីរបស់រដ្ឋមួយទៀត ឬនៅក្នុងលំហអន្តរជាតិមួយដូចជានៅក្នុងលំហសមុទ្រជាដើម។*

*ការការពារការទូតជាស្ថាប័នមួយដែលអនុញ្ញាតឱ្យរដ្ឋមួយអាចធ្វើប្រតិកម្មចំពោះអាណិកជនរបស់ខ្លួន នៅពេលដែលជឿជាក់ថា ខ្លួនបានទទួលការខូចខាតដែលបង្កឡើងពីសំណាក់រដ្ឋមួយទៀត។[៥៩] ប៉ុន្តែ លក្ខខណ្ឌបីត្រូវតែបំពេញ ៖*

*• លក្ខខណ្ឌសញ្ជាតិ ៖ ចំណងជាក់ស្តែងនៃសញ្ជាតិមួយរវាងបុគ្គល និងរដ្ឋដែលធ្វើប្រតិកម្មចំពោះបុគ្គលនោះ។*

*• លក្ខខណ្ឌដៃស្អាតស្អំ ៖ បុគ្គលដែលទាមទារការការពារត្រូវតែមាន«ដៃស្អាតស្អំ» ពោលគឺបុគ្គលនេះមិនត្រូវចូលរួមចំណែកនៅក្នុងការបង្កើតការខូចខាតដែលខ្លួនទទួលរងឡើយ។*

*• គោលការណ៍ឧបាស្រ័យផ្ទៃក្នុងអស់លទ្ធភាព ៖ បុគ្គលឯកជនត្រូវប្រើប្រាស់ឧបាស្រ័យផ្ទៃក្នុងឱ្យអស់លទ្ធភាពជាមុនសិន។*

*«រដ្ឋត្រូវតែចាត់ទុកថា ជាម្ចាស់តែម្នាក់គត់ដែលនឹងសម្រេចថានឹងផ្តល់ការការពារ ថានឹងការពារនៅក្នុងកម្រិតណា និងបញ្ចប់ការការពារនោះនៅពេលណា។ នៅក្នុងន័យនេះ រដ្ឋមានអំណាចឆន្ទានុសិទ្ធិមួយដែលការអនុវត្តវាអាចអាស្រ័យទៅតាមការពិចារណា ជាការពិចារណាតាមនយោបាយ ជាពិសេសនយោបាយការបរទេសនៅក្នុងករណីនេះ»។[៦០]*

## ២- សមត្ថកិច្ចដែនដី

*រដ្ឋដំណើរការនៅលើទឹកដីទាំងជាវត្ថុមួយពោលគឺ le dominium មានន័យថា រដ្ឋអាចប្រគល់ដែនដីមួយចំណែកបាន និងមួយទៀតទាំងជាលំហមួយដែលមានប្រជាជនរស់នៅ ពោលគឺ l'imperium។*

---

[៥៩] *MARTIN-BIDOU (P.), op. cit., p. 32.*

[៦០] *CIJ, Barcelona Traction, l'arrêt du 5 février 1970, Rec. 1970, p. 40.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សមត្ថកិច្ចដែនដីគឺទូទៅ និងដាច់មុខ ៖

• សមត្ថកិច្ចទូទៅ ៖ រដ្ឋមានអធិបតេយ្យនៅក្នុងការជ្រើសរើសរចនាសម្ព័ន្ធនយោបាយនៅក្នុងការចាត់តាំងអំណាចសាធារណៈ រដ្ឋធម្មនុញ្ញ នគរបាល ការការពារជាតិ និងការរៀបចំសេដ្ឋកិច្ច។ អធិបតេយ្យភាពសេដ្ឋកិច្ចស្តែងឡើងតាមរយៈគោលការណ៍អធិបតេយ្យភាពអចិន្ត្រៃយ៍ទៅលើធនធានធម្មជាតិ។

• សមត្ថកិច្ចផ្តាច់មុខ ៖ រដ្ឋចាត់ចែងគ្រប់គ្រងការប្រើប្រាស់ទឹកដីតែម្នាក់ឯងគត់។ រដ្ឋនេះមិនអាចធ្វើប្រតិបត្តិការនៅលើទឹកដីរបស់រដ្ឋមួយផ្សេងទៀត ដោយគ្មានការយល់ព្រមពីរដ្ឋនេះទេ បើពុំនោះ វានឹងមានការប៉ះពាល់ដល់អធិបតេយ្យទឹកដីរបស់រដ្ឋនេះ។ គេសង្កេតឃើញមានសមត្ថកិច្ចផ្តាច់មុខពីរប្រភេទ ៖

១- សមត្ថកិច្ចជាធម្មនិយាម ៖ ជាអំណាចអនុម័តយកធម្មនិយាម។ ធម្មនិយាមទាំងនេះអាចមានវិសាលភាពក្រៅដែនដី នៅពេលដែលស្ថានភាពស្ថិតនៅក្រោមសមត្ថកិច្ចបុគ្គលរបស់រដ្ឋ។

២- សមត្ថកិច្ចអនុវត្ត ៖ ជាអំណាចដាក់ឱ្យអនុវត្តនូវធម្មនិយាមតាមរយៈវិធានការ កិច្ចប្រតិបត្តិតាមរយៈវិធីបង្ខិតបង្ខំ។ នៅពេលរដ្ឋធ្វើប្រតិបត្តិការនៅលើទឹកដីនៃរដ្ឋមួយទៀត រដ្ឋនេះនឹងរំលោភទៅលើចរិតលក្ខណៈផ្តាច់មុខនៃសមត្ថកិច្ចដែនដី។ មានតែរដ្ឋតែមួយគត់ដែលអាចលើកពីការរំលោភលើអធិបតេយ្យភាពដែនដីរបស់ខ្លួនដោយភ្នាក់ងារនៃរដ្ឋដទៃមួយទៀត។ ឧទាហរណ៍ កិច្ចការចាប់ជំរិតមនុស្សនៅបរទេសជាដើម។ រដ្ឋអាចបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការមួយ ជំនួយទៅវិញទៅមកនៅក្នុងផ្លូវតុលាការនៅក្នុងវិស័យរដ្ឋប្បវេណី និងព្រហ្មទណ្ឌដែលអាចអនុញ្ញាតឱ្យរដ្ឋជាចារីនៃធម្មនិយាមទាមទារឱ្យរដ្ឋដទៃប្រតិបត្តិតាមធម្មនិយាមនេះ(អនុសញ្ញាពីរ ឬពហុភាគី)។

សមត្ថកិច្ចផ្តាច់មុខជាអ្នកមានអធិបតេយ្យ រដ្ឋមានសមត្ថកិច្ចពេញលេញ និងភាពដាច់មុខនៃសមត្ថកិច្ចទាំងនេះនៅលើទឹកដីរបស់ខ្លួន។ រដ្ឋជាអ្នកកំណត់វិសាលភាព ទម្រង់បែបបទ និងគោលដៅនៃការអនុវត្តអំណាចរបស់រដ្ឋ។ រដ្ឋមានសេរីភាពក្នុងការដំណើរការនៅក្នុងសង្គមអន្តរជាតិ ដោយគ្រាន់តែគោរពសិទ្ធិរបស់រដ្ឋដទៃ និងកាតព្វកិច្ចដែលរដ្ឋយល់ព្រមនឹងអនុវត្ត។ រដ្ឋមិនអាចឆ្លើយតបនៅក្នុងតុលាការចំពោះទង្វើរបស់រដ្ឋ ប្រសិនបើរដ្ឋមិនបានទទួលយល់ព្រមទៅលើសមត្ថកិច្ចរបស់ចៅក្រម។ រដ្ឋនៅរក្សាឥទ្ធិពលទៅលើប្រធានផ្សេងទៀតនៃនីតិអន្តរជាតិដែលរដ្ឋជាអ្នកគ្រប់គ្រងការឈានឡើងខ្ពស់។

ទោះជាយ៉ាងនេះក្តី សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សមត្ថកិច្ចជាសាកលមួយអាចនឹងត្រូវទទួលស្គាល់។ អនុសញ្ញាខ្លះបង្កើតសមត្ថកិច្ចជាសាកលមួយសម្រាប់រដ្ឋដែលជាភាគីនៃអនុសញ្ញាទាំងនោះ ៖

• អនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ១៩៤៩ ស្តីពីច្បាប់មនុស្សធម៌នៅក្នុងជម្លោះ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រដាប់អាវុធ។

• អនុសញ្ញាចុះថ្ងៃទី២៧ មិថុនា ១៩៧៧ ដែលអនុម័តនៅក្នុងក្របខ័ណ្ឌនៃក្រុមប្រឹក្សាអឺរ៉ុបស្តីពីការបង្ក្រាបអំពើភេរវកម្ម។

• អនុសញ្ញាចុះថ្ងៃទី១៨ ធ្នូ ១៩៧៩ ស្តីពីការប្រឆាំងនឹងការចាប់ជំរិតជាចំណាប់ខ្មាំង

• អនុសញ្ញាចុះថ្ងៃទី១០ ធ្នូ ១៩៨៤ ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម។

ច្បាប់របស់បែលហ្ស៊ិកស្តីពី«សមត្ថកិច្ចជាសាកល»ពាក់ព័ន្ធទៅនឹងការបង្ក្រាបការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់អន្តរជាតិមនុស្សធម៌ ចុះថ្ងៃទី១០ កុម្ភៈ ១៩៩៩ ដែលបានសើរើឡើងវិញ (ច្បាប់ចុះថ្ងៃទី៥ សីហា ២០០៣) គ្រោងនូវទស្សនាទានមួយកាន់តែចង្អៀតដែលរក្សាទុកនូវលក្ខណៈវិនិច្ឆ័យភ្ជាប់ជាច្រើន។

# ផ្នែកទី៦

## ការទទួលស្គាល់រដ្ឋ

«ការទទួលស្គាល់រដ្ឋគឺជាកិច្ចមួយដែលតាមរយៈនោះរដ្ឋមួយប្រកាន់ជំហរចំពោះអត្ថិភាពនៃរដ្ឋមួយទៀតបាន។[៦១] ការទទួលស្គាល់មានលក្ខណៈជាការប្រកាស និងធ្វើឱ្យមានការសង្កេតលើអត្ថិភាពនៃរដ្ឋដែលបង្កើតមួយ។ ការប្រកាសនេះពុំមានវិសាលភាពបង្កើតរដ្ឋដែលមានអត្ថិភាពតាមបែបវត្ថុវិស័យទេ នៅពេលដែលមានធាតុផ្សំបីរួមគ្នា គឺទឹកដី ប្រជាជន និងរដ្ឋាភិបាល។ «ការទទួលស្គាល់ ឬការរលត់បាត់នៃរដ្ឋគឺជាបញ្ហាមួយដែលមានព្រឹត្តិការណ៍ជាក់ស្តែង។ [...]ការទទួលស្គាល់ដោយរដ្ឋដទៃមានអានុភាពជាការប្រកាសសុទ្ធសាធ»។[៦២]

### ១- កិច្ចឯកតោភាគី

ការទទួលស្គាល់អាចជាការទទួលស្គាល់ច្បាស់ក្រឡែត និងមានប្រភពចេញពីកិច្ចឱឡារិកមួយ។ ការទទួលស្គាល់ក៏អាចមានភាពវាទរហិត ឬតុណ្ហីភាពដែរ និងមានប្រភពចេញមកពីអាកប្បកិរិយារបស់អង្គភាពរដ្ឋ ដូចជាការចុះកិច្ចព្រមព្រៀងទ្វេភាគី ឬការបង្កើតទំនាក់ទំនងការទូតជាដើម។

ជាញឹកញយណាស់ ការទទួលស្គាល់គឺជាកិច្ចឯកតោភាគីដែលចេញមកពីឆន្ទៈតែមួយគត់របស់រដ្ឋមួយ។ ប៉ុន្តែក៏មានការទទួលស្គាល់រួមដែរ។ នៅឆ្នាំ១៩៩២ រដ្ឋជាសមាជិកនៃសហភាពអឺរ៉ុប

---

[៦១] MARTIN-BIDOU (P.), op. cit., p. 37.

[៦២] Commission d'arbitrage de la Conférence pour la paix en Yougoslavie, Avis n° 1 du 29 novembre 1991, RGDIP 1992, p. 264.

*បានទទួលស្គាល់ជាសមូហភាពនូវប្រទេសបូស្នីហ៊ែរសេហ្គូវីន ប្រទេសក្រូអាស៊ី និងប្រទេសស្លូវេនី។*

## ២- កិច្ចឆន្ទានុសិទ្ធិ

*ការទទួលស្គាល់គឺជាកិច្ចឆន្ទានុសិទ្ធិ។ រដ្ឋមានសេរីភាពទទួលស្គាល់ ឬមិនទទួលស្គាល់រដ្ឋដែលបង្កើតថ្មី។ ការទទួលស្គាល់មានវិសាលភាពមិនដាច់ខាត និងមានអានុភាពចំពោះតែរដ្ឋដែលទទួលស្គាល់ទេ។ ការទទួលស្គាល់អាចដឹកនាំដោយការពិចារណាទៅលើកាលានុវត្តភាពនយោបាយ។ រដ្ឋដែលទទួលស្គាល់ក៏អាចសម្រេចធ្វើការទទួលស្គាល់នៅក្រោមការគោរពលក្ខខណ្ឌមួយចំនួនបានដែរ។ ដូចជាករណីនៃការទទួលស្គាល់រដ្ឋដែលមានប្រភពចេញមកពីការបំបែកសហភាពសូវៀត និងយូកូស្លាវីជាដើម។ ប៉ុន្តែរដ្ឋមានកាតព្វកិច្ចមិនទទួលស្គាល់ស្ថានភាពមួយដែលកើតឡើងដោយការប្រើប្រាស់កម្លាំងប្រដាប់អាវុធដែលនេះជាផលវិបាកនៃគោលការណ៍ហាមប្រាមមិនឱ្យប្រើប្រាស់កម្លាំងនៅក្នុងទំនាក់ទំនងអន្តរជាតិ។*

## តួនាទីនៃឧត្តមភាពនៃការគ្រប់គ្រងពេញលេញ

*ច្បាប់អន្តរជាតិគិតគូរពីទំនាក់ទំនង និងកិច្ចប្រឹងប្រែងដែលមានស្រាប់ ដើម្បីបំលែងពួកវាទៅជាវិធានគតិយុត្ត។ ច្បាប់អន្តរជាតិផ្អែកមួយចំណែកធំទៅលើគោលការណ៍នៃភាពជាក់ស្តែង និងបានចែងថា មានតែការទាមទារ និងស្ថានភាពដែលមានប្រសិទ្ធភាពប៉ុណ្ណោះដែលអាចបង្កើតជាផលវិបាកគតិយុត្តបាន។*

*ហេតុដូចនេះ ប្រសិនបើរដ្ឋថ្មីមួយកើតចេញពីអប្បគមន៍ រដ្ឋនេះមានលទ្ធភាពអាចទាមទារសុំឋានៈអន្តរជាតិបានតែបន្ទាប់ពីឃើញជាក់ច្បាស់មិនអាចប្រកែកបានថា រដ្ឋនេះគ្រប់គ្រងទឹកដីដោយឡែកមួយ និងសហគមន៍មនុស្សដែលរស់នៅលើទឹកដីនោះតែប៉ុណ្ណោះ។ ការត្រួតត្រាទៅលើសហគមន៍រដ្ឋត្រូវតែមានភាពពិតប្រាកដ និងមានភាពយូរអង្វែងជាប់គ្នា។*

*ទោះជាយ៉ាងនេះក្តី ចាប់តាំងពីសង្គ្រាមលោកលើកទីមួយមក រដ្ឋមួយចំនួនបានប៉ុនប៉ងធ្វើឱ្យភាពស្របច្បាប់មានអានុភាពទៅលើកម្លាំង ឬលើអាជ្ញាពិតប្រាកដ និងសាមញ្ញ។ ក៏ប៉ុន្តែលទ្ធិ Stimson ឆ្នាំ១៩៣២ មិនទទួលស្គាល់ការផ្លាស់ប្តូរព្រំប្រទល់អន្តរជាតិដោយសារការប្រើប្រាស់កម្លាំង។*

## ៣- តួនាទីនៃការទទួលស្គាល់

*កិច្ចទទួលស្គាល់គ្មានអានុភាពគតិយុត្តណាមួយទៅលើបុគ្គលភាពអន្តរជាតិរបស់រដ្ឋឡើយ ៖ វាមិនផ្តល់សិទ្ធិ ហើយក៏មិនដាក់ជាកាតព្វកិច្ចទៅឱ្យរដ្ឋនេះដែរ។*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការទទួលស្គាល់រដ្ឋមានខ្លឹមសារបី ៖

• ជាបឋម នៅក្នុងផ្លូវនយោបាយ វាមានសារៈសំខាន់ណាស់ ពីព្រោះជាសក្ខីភាពនៃឆន្ទៈរបស់រដ្ឋទទួលស្គាល់ ដើម្បីផ្តួចផ្តើមឱ្យមានអន្តរកម្មអន្តរជាតិជាមួយរដ្ឋថ្មីនេះ។

• ទីពីរ វាស្តែងឱ្យឃើញថា រដ្ឋទទួលស្គាល់ចាត់ទុកថារដ្ឋថ្មីបំពេញនូវគ្រប់លក្ខខណ្ឌតឹកតាងជាក់ស្តែងដែលគេវិនិច្ឆ័យថាចាំបាច់ ដើម្បីក្លាយទៅជាប្រធានមួយនៃច្បាប់អន្តរជាតិ។

• ទីបី នៅពេលដែលការទទួលស្គាល់នេះផ្តល់រួចហើយ ការទទួលស្គាល់នេះហាមមិនឱ្យរដ្ឋទទួលស្គាល់កែប្រែជំហររបស់ខ្លួន និងបញ្ជាក់អះអាងថា អង្គភាពថ្មីមិនចាត់ចែងរដ្ឋមួយទេ (ជាសញ្ញាណ estoppel របស់ប្រព័ន្ធច្បាប់ Common Law ដែលតាមរយៈនោះ គណបក្សមួយត្រូវបានហាមឃាត់មិនឱ្យដោះសា ឬបដិសេធស្ថានភាពមួយ ឬទាមទារសិទ្ធិមួយដែលជាការបាត់បង់ប្រយោជន៍ដល់គណបក្សមួយទៀតទៅលើសិទ្ធិលើកឡើងពីឥរិយាបថនេះ បន្ទាប់ពីការដោះសាពីមុនការបដិសេធ ឥរិយាបថ ឬការទទួលស្គាល់ដោយគណបក្សមុន)។

ការទទួលស្គាល់អាចមានផលវិបាកគតិយុត្ត នៅពេលដែលការទទួលស្គាល់នេះត្រូវធ្វើឡើងដោយប្រញាប់បន្ទាន់ ជាពិសេសនៅពេលដែលរដ្ឋថ្មីនេះកើតចេញពីអប្បគមន៍របស់រដ្ឋដែលមានស្រាប់មួយ ឬចេញពីសង្គ្រាមស៊ីវិលមួយ។ ការទទួលស្គាល់ទុកជាមុនដែលជាការទទួលស្គាល់ដែលផ្តល់ឱ្យមុនមានលក្ខខណ្ឌកស្តុតាងសម្រាប់រដ្ឋមួយត្រូវបានបំពេញ អាចមានតម្លៃស្មើនឹងការជ្រៀតជ្រែកខុសច្បាប់នៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដែលពាក់ព័ន្ធ។

## ៤- លក្ខខណ្ឌនៃការទទួលស្គាល់

ការអនុវត្តរបស់រដ្ឋបានបង្ហាញថា នៅក្នុងរយៈពេលច្រើនឆ្នាំ លក្ខខណ្ឌជាកស្តុតាងរបស់រដ្ឋជាច្រើនដែលទាមទារឱ្យមានការទទួលស្គាល់នោះ បានប្រែប្រួលហើយ។ នៅក្នុងអតីតកាលវាគ្រប់គ្រាន់ទៅហើយដោយគ្រាន់តែរដ្ឋថ្មីមួយអនុវត្តការត្រួតត្រាជាក់ស្តែងទៅលើសហគមន៍មនុស្សមួយ និងទៅលើទឹកដីដែលសហគមន៍មនុស្សនេះរស់នៅ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ រដ្ឋខ្លះក៏បានចាប់ផ្តើមទាមទារថា រដ្ឋថ្មីមិនត្រូវប្រឆាំងទៅនឹងធម្មនិយាមជាសារវន្តខ្លះៗនៃសហគមន៍អន្តរ-ជាតិ(ដូចជាការហាមមិនឱ្យមានសង្គ្រាមដែលធ្លាប់តែជាការរំលោភសន្ធិសញ្ញាអន្តរជាតិ ឬជាការដាក់ឱ្យនៅក្រៅស្ថានភាពដែលមិនអាចធ្វើទុក្ខបុកម្នេញដល់ប្រទេសបរទេសមួយបាន)។ ប្រសិនបើតម្លៃទាំងនេះត្រូវបានរំលោកបំពាន រដ្ឋទាំងឡាយមិនអាចធ្វើការទទួលស្គាល់បានទេ ទោះបីជារដ្ឋថ្មីពិតជាកំពុងត្រួតត្រាប្រជាជន និងទឹកដីយ៉ាងម៉ឺងម៉ាត់ក៏ដោយ។

រដ្ឋដែលធ្វើការទទួលស្គាល់ក៏អាចជ្រើសរើសដាក់ការទទួលស្គាល់របស់ខ្លួននៅក្រោមការគោរពលក្ខខណ្ឌមួយចំនួនបាន។ ទោះជាយ៉ាងនេះក្តី ផលវិបាកមួយនៃគោលការណ៍ហាមប្រាម

មិនឱ្យប្រើប្រាស់កម្លាំងនៅក្នុងទំនាក់ទំនងអន្តរជាតិ រដ្ឋគឺមានកាតព្វកិច្ចមិនត្រូវទទួលស្គាល់ស្ថានភាពមួយដែលបង្កើតឡើងដោយការប្រើប្រាស់កម្លាំងប្រដាប់អាវុធឡើយ។ នៅពេលថ្មីៗនេះ រដ្ឋខ្លះ ជាពិសេសនៅអឺរ៉ុបខាងលិច ក៏បានចាប់ផ្តើមទាមទារឱ្យមានការគោរពសិទ្ធិមនុស្ស និងសិទ្ធិរបស់ជនជាតិភាគតិច ព្រមទាំងការគោរពព្រំដែនអន្តរជាតិដែលមានស្រាប់ ក៏ដូចជាលក្ខខណ្ឌផ្សេងទៀតនៃការផ្តល់ការទទួលស្គាល់ដែរ។ នេះគឺករណីនៃការទទួលស្គាល់រដ្ឋដែលមានប្រភពចេញមកពីការដួលរលំសហភាពសូវៀត និងប្រទេសយូកូស្លាវី។ បន្ទាប់ពីការដួលរលំបាក់បែកសហភាពសូវៀតនៅថ្ងៃទី១៦ ធ្នូ ១៩៩១ រដ្ឋមន្ត្រីការបរទេសនៃរដ្ឋជាសមាជិករបស់សហគមន៍អឺរ៉ុបបានអនុម័តសេចក្តីប្រកាសមួយស្តីពី«គោលការណ៍ដឹកនាំស្តីពីការទទួលស្គាល់រដ្ឋថ្មីនៅអឺរ៉ុបខាងលិចនិងនៅសហភាពសូវៀត»។[៦៣] នៅក្នុងសេចក្តីប្រកាសនេះមានបញ្ជាក់ពីលក្ខខណ្ឌចាំបាច់នានាសម្រាប់ការទទួលស្គាល់រដ្ឋថ្មីជាផ្លូវការនៅអឺរ៉ុបខាងលិច ៖

១- ការគោរពធម្មនុញ្ញអង្គការសហប្រជាជាតិ កិច្ចស្នាពរនៃទីក្រុងហែលស៊ីនគី និងធម្មនុញ្ញទីក្រុងប៉ារីស «ជាអាទិទាក់ទងទៅនឹងឧត្តមភាពនៃច្បាប់ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស»

២- ការធានាចំពោះសិទ្ធិរបស់ក្រុម និងជនជាតិភាគតិចជាតិពន្ធុ និងជាតិ

៣-ការគោរពភាពមិនអាចរំលោភបានទៅលើព្រំដែនទាំងអស់«ដែលអាចកែប្រែបានតែតាមរយៈមធ្យោបាយសន្តិវិធី និងដោយមានការព្រមព្រៀងរួមគ្នា»

៤- ការទទួលយកនូវការសន្យាសំខាន់ៗទាក់ទងទៅនឹងការទម្លាក់អាវុធ និងការមិនសាយភាយអាវុធនុយក្លេអ៊ែរ ព្រមទាំងសន្តិសុខ និងស្ថិរភាពតំបន់

៥- ការសន្យានឹងបង្កើតកិច្ចព្រមព្រៀងរួម ឬប្រសិនបើមាន គឺកិច្ចព្រមព្រៀងតាមរយៈការប្រើប្រាស់មជ្ឈត្តកម្ម សម្រាប់រាល់បញ្ហាដែលទាក់ទិនទៅនឹងការស្នងរដ្ឋ និងជម្លោះតំបន់។ លើសពីនេះទៅទៀត សេចក្តីប្រកាសនេះចែងថា «សហគមន៍ និងរដ្ឋជាសមាជិកមិនទទួលស្គាល់បណ្តារដ្ឋដែលជាលទ្ធផលនៃការឈ្លានពានឡើយ»។

រដ្ឋមួយ ទោះបីជាយ៉ាងហោចណាស់បង្ហាញពីការទាមទារជាប្រពៃណី ផ្អែកទៅលើប្រសិទ្ធភាពក្តី គឺមិនត្រូវបានទទួលស្គាល់ជានិច្ចកាលដោយសំឡេងភាគច្រើនដាច់ខាតពីសំណាក់សមាជិកនៃសហគមន៍អន្តរជាតិឡើយ។ ស្ថានភាពមិនប្រក្រតីនេះកើតចេញពីភាពប្រឈមគ្នានៃគោលការណ៍ផ្ទុយគ្នាពីរ គឺគោលការណ៍ចាស់ស្តីពីប្រសិទ្ធភាព និងគោលការណ៍ថ្មីស្តីពីការរក្សានូវប្រភពនៃភាពស្របច្បាប់នៃភាពជាក់ស្តែង និងស្ថានភាពដែលមានវិសមិតភាពជាមួយនឹងតម្លៃទូទៅនៃសហគមន៍ពិភពលោកនាពេលបច្ចុប្បន្ន។

[៦៣] *en 4 EJIL (1993), 74-7.*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី៧

## ការស្នងរដ្ឋ

*ការស្នងរដ្ឋ(Sucession)គឺជា«ការជំនួសរដ្ឋមួយដោយរដ្ឋមួយទៀត នៅក្នុងទំនួលខុសត្រូវទំនាក់ទំនងអន្តរជាតិនៃទឹកដីមួយ»។[៦៤] មានការផ្លាស់ប្តូររដ្ឋនៅលើទឹកដីមួយជាក់លាក់។*

### ១- ទិដ្ឋភាពផ្ទៃក្នុង

*ការស្នងរដ្ឋចោទជាបញ្ហាដល់ស្ថានភាពនៃប្រធាននៃនីតិផ្ទៃក្នុងរបស់រដ្ឋ។ ប្រជាជននឹងទទួលបានសញ្ជាតិរបស់រដ្ឋដែលបន្តវេន។ សិទ្ធិរបស់រូបវន្តបុគ្គល និងនីតិបុគ្គលមានការប៉ះពាល់។ ទាក់ទងនឹងទ្រព្យសម្បត្តិសាធារណៈ ទ្រព្យនៃដែនសាធារណៈ បណ្ណសារ រដ្ឋថ្មីបន្តវេនពីរដ្ឋចាស់។[៦៥]*

### ២- ទិដ្ឋភាពអន្តរជាតិ

*ការស្នងរដ្ឋក៏ចោទជាបញ្ហាដល់ទំនាក់ទំនងរបស់រដ្ឋថ្មីជាមួយរដ្ឋផ្សេងទៀត។ ទាក់ទិនទៅនឹងការស្នងរដ្ឋនៅក្នុងសន្ធិសញ្ញា[៦៦] គោលការណ៍គឺគោលការណ៍នៃភាពមិនអាចផ្ទេរបាន(គោលការណ៍ table rase ឬចាប់ផ្តើមជាថ្មី)។*

### ទម្រង់នៃការស្នង

*ការផ្លាស់ប្តូរនៅក្នុងទឹកដីនៃរដ្ឋមួយអាចប៉ះពាល់ដល់បុគ្គលភាពគតិយុត្តរបស់រដ្ឋនោះ។ ស្ថានភាពនេះកើតឡើងនៅពេល ៖*

*• ការរលាយ ៖ រដ្ឋមួយរលាយបាត់បង់ បន្ទាប់ពីមានការកាត់ផ្តាច់របស់វា(ការបែងចែក) ៖ ការបែកខ្ញែកនៃសហភាពសូវៀតនៅឆ្នាំ១៩៩១ ប្រទេសយូកូស្លាវីនៅឆ្នាំ១៩៩១ និងប្រទេសឆេកូស្លូវ៉ាគីនៅឆ្នាំ១៩៩២។*

*• ការរំលាយចូលគ្នាជាមួយរដ្ឋមួយឬច្រើន ឬនៅពេលដែលរដ្ឋមួយធ្វើសមាហរណកម្មជាមួយរដ្ឋមួយទៀតដែលរលាយបាត់បង់ដោយបុព្វហេតុនេះ។ ការរំលាយចូលគ្នានៃប្រទេសអេស៊ីប និងស៊ីរីនៅក្នុងសាធារណរដ្ឋអារ៉ាប់រួមនៅឆ្នាំ១៩៥៨(ដែលបានបន្តរហូតដល់ឆ្នាំ១៩៦១) ការរំលាយបញ្ចូលគ្នារវាងប្រទេសតង់កានីកា និងប្រទេសសង់ស៊ីបារ៍ ដើម្បីបង្កើតជាប្រទេស*

---

[៦៤] *Commission d'arbitrage de la Conférence pour la paix en Yougoslavie, Avis n° 1 du 29 novembre 1991, RGDIP 1992, p. 264.*

[៦៥] *La Convention de Vienne du 8 avril 1983 relative à la succession d'État en matière de biens, archives et dettes d'État n'est pas entrée en vigueur.*

[៦៦] *La Convention de Vienne du 22 août 1978 relative à la succession d'État en matière de traités est entrée en vigueur.*

តង់ហ្សានីនៅឆ្នាំ១៩៦៤ និងការរំលាយចូលគ្នានៃប្រទេសយ៉េមែនទាំងពីរនៅឆ្នាំ១៩៩០ និងសមាហរណកម្មនៃសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ នៅក្នុងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នៅឆ្នាំ១៩៩០។

• អប្បគមន៍(*Sécession*)ពីសំណាក់ប្រជាជន និងទឹកដីរបស់រដ្ឋ រដ្ឋបន្តមានអត្តិភាពក្នុងនាមជាប្រធាននៃនីតិ ប៉ុន្តែចំណែកដែលធ្វើអប្បគមន៍អាចទទួលឋានៈជារដ្ឋអន្តរជាតិ។ អប្បគមន៍របស់ប្រទេសបង់ក្លាដេសចេញពីប្រទេសប៉ាគីស្ថាននៅឆ្នាំ១៩៧១ ការទទួលឯករាជ្យពីសហភាពសូវៀតរបស់រដ្ឋប៉ៃលទិកចំនួនបី(ប្រទេសអេស្តូនី និងលេទ៉ូនីនៅឆ្នាំ១៩៩០ និងប្រទេសលីទុយ-អានីនៅឆ្នាំ១៩៩១)។ នៅពេលដែលរដ្ឋមួយជំនួសរដ្ឋមួយទៀតនៅលើទឹកដីមួយ បញ្ហាដែលចោទឡើងគឺថា តើមានការស្នងរដ្ឋឬទេ? តើសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋចាស់ត្រូវផ្ទេរទៅប្រធាននៃនីតិអន្តរជាតិថ្មីមួយទៀតឬទេ?

## ការស្នងសន្ធិសញ្ញា

បញ្ហានេះត្រូវគ្រប់គ្រងដោយវិធានទំនៀមទម្លាប់មួយចំនួនដែលនៅក្នុងវិធានការខ្លះត្រូវបានចងក្រងជាក្រមនៅក្នុងសន្ធិសញ្ញាពីរ ៖ អនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៧៨ ស្តីពីការស្នងរដ្ឋនៅក្នុងវិស័យសន្ធិសញ្ញា និងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៨៣ ស្តីពីការស្នងរដ្ឋទាក់ទិនទៅនឹងទ្រព្យសម្បត្តិរបស់រដ្ឋ បណ្ណសារ និងបំណុល(អនុសញ្ញានេះមិនទាន់ចូលជាធរមានទេ)។

នៅក្នុងការស្នងរដ្ឋនៅក្នុងសន្ធិសញ្ញា[៦៧] គោលការណ៍គឺគោលការណ៍មិនអាចផ្ទេរបាន (គោលការណ៍ table rase)។ អនុលោមតាមគោលការណ៍អានុភាពមិនដាច់ខាតនៃសន្ធិសញ្ញា សន្ធិសញ្ញានេះមិនអាចជំទាស់បានចំពោះរដ្ឋទីបីឡើយ(រដ្ឋបន្តវេន សន្ធិសញ្ញាត្រូវបានធ្វើឡើងដោយរដ្ឋមុន)។ មានការលើកលែងមួយចំនួន គឺ ៖

• រដ្ឋបន្តវេនមិនអាចត្រួតពិនិត្យការកំណត់ព្រំដែនឡើងវិញបានឡើយ(ទឹកដីមួយ ស្ទឹងមួយ សេរីភាពធ្វើនាវាចរណ៍ ឬការកំណត់ព្រំដែន)។ ដូច្នេះ«ការស្នងរដ្ឋមិនមានការប៉ះពាល់ដល់ព្រំដែនដែលបង្កើតឡើងដោយសន្ធិសញ្ញាមួយឡើយ»។[៦៨]

• រដ្ឋថ្មីត្រូវស្នើសុំចូលជាសមាជិកនៃអង្គការអន្តរជាតិ រដ្ឋថ្មីមិនទទួលអាសនៈបន្តពីរដ្ឋមុនឡើយ(លើកលែងប្រទេសរុស្ស៊ីដែលចូលជាសមាជិកអង្គការសហប្រជាជាតិ)។

ទាក់ទងទៅនឹងការស្នងសន្ធិសញ្ញា អនុលោមទៅតាមច្បាប់ទំនៀមទម្លាប់ ត្រូវធ្វើការវែក-ញែករវាងប្រភេទផ្សេងៗនៃសន្ធិសញ្ញា។

សន្ធិសញ្ញាទីមួយហៅថាសន្ធិសញ្ញាក្នុងស្រុកដែលដាក់កំហិតជាកាតព្វកិច្ច និងផ្តល់សិទ្ធិ

[៦៧] *La Convention de Vienne du 22 août 1978 relative à la succession d'État en matière de traités est entrée en vigueur.*

[៦៨] *Convention de Vienne du 22 août 1978, art. 11.*

ចំពោះទឹកដីដោយឡែកផ្សេងៗ( ឧទាហរណ៍ដូចជាការដោះស្រាយបញ្ហាព្រំដែន ការគ្រោងនូវសិទ្ធិធ្វងកាត់នៅក្នុងតំបន់ពិសេសខ្លះ ដាក់ជាតំបន់គ្មានយោធានូវដែនដីមួយ បង្កើតសិទ្ធិនេសាទនៅក្នុងតំបន់ទឹកមួយចំនួន ឬសិទ្ធិនាវាចរណ៍នៅក្នុងស្ទឹងពិសេសមួយចំនួន-ល-)។

ដោយហេតុតែសន្ធិសញ្ញាទាំងនេះផ្តល់សិទ្ធិដល់ដែនដីពិសេសមួយ ដើម្បីជាភាពសុខសាន្តនៃស្ថិរភាពអន្តរជាតិ សន្ធិសញ្ញានេះមិនត្រូវប៉ះពាល់ដោយទង្វើនៃការស្នងរដ្ឋតែមួយមុខគត់នោះឡើយ។ និយាយម្យ៉ាងទៀត សន្ធិសញ្ញាទាំងនេះចងរដ្ឋថ្មី( សូមមើលអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៧៨ មាត្រា១២)។

ទាក់ទិនទៅនឹងសន្ធិសញ្ញាដែលមិនមែនជាសន្ធិសញ្ញានៅក្នុងស្រុក ច្បាប់ទំនៀមទម្លាប់ដែលមានចងក្រងជាក្រមនៅក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៧៨ គ្រោងទុកនូវរបបគតិយុត្តខុសផ្លែកមួយ។ ចំពោះ«រដ្ឋដែលបានឯករាជ្យថ្មីៗ»( ដូចជារដ្ឋបន្តវេនតាមអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៧៨ មាត្រា២.១) គោលការណ៍ table rase (ចាប់ផ្តើមជាថ្មី) ត្រូវយកមកអនុវត្តដែលមានដូចជាគោលការណ៍ដែលតាមរយៈនោះ រដ្ឋថ្មីមិនត្រូវបានចងដោយសន្ធិសញ្ញាដែលមានជរមាននៅលើទឹកដីនៅក្នុងកាលបរិច្ឆេទនៃការស្នងរដ្ឋទេ។

# ផ្នែកទី៨

## ទំនួលខុសត្រូវអន្តរជាតិរបស់រដ្ឋ

រដ្ឋត្រូវតែគោរពការសន្យារបស់ខ្លួន។ ការរំលោភកាតព្វកិច្ច«ចម្បង»ទាំងនេះធ្វើឱ្យកើតនូវកាតព្វកិច្ចបន្ទាប់បន្សំមួយដែលកើតចេញពីការប្រតិបត្តិទំនួលខុសត្រូវអន្តរជាតិរបស់រដ្ឋ។ «គឺជាគោលការណ៍នៃច្បាប់អន្តរជាតិ ឬថែមទាំងជាទស្សនាទានទូទៅនៃច្បាប់ដែលថាពល់ការរំលោភកិច្ចសន្យាមួយភ្ជាប់កាតព្វកិច្ចដែលត្រូវធ្វើការជួសជុល»។[៦៩] គណៈកម្មការនីតិអន្តរជាតិបានអនុម័តសេចក្តីព្រាងមាត្រានានា[៧០]ស្តីពីទំនួលខុសត្រូវរបស់រដ្ឋចំពោះព្រឹត្តិការណ៍ខុសច្បាប់ជាអន្តរជាតិនៅឆ្នាំ២០០១ អង្គមហាសន្និបាតអង្គការសហប្រជាជាតិបានកត់ត្រាទុកនូវមាត្រាទាំងនេះហើយ។[៧១]

---

[៦៩] *CPJI, arrêt du 13 septembre 1928, Usine de Chorzow, Rec. Série A, n° 13, p. 29.*

[៧០] *« Tout fait internationalement illicite de l'État engage sa responsabilité internationale », Art. ler du projet d'articles sur la responsabilité internationale.*

[៧១] *Résolution 56/83 du 12 decembre 2001.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១- ហេតុការណ៍បង្កើត

ការទទួលខុសត្រូវរបស់រដ្ឋកើតឡើងនៅពេលមាន«ហេតុការណ៍ខុសច្បាប់អន្តរជាតិរបស់រដ្ឋ នៅពេលដែលអាកប្បកិរិយាមួយដែលជាអំពើ ឬជាការខកខានដែលផ្សំបានទៅជាការរំលោភកាតព្វកិច្ចអន្តរជាតិមួយរបស់រដ្ឋ»។ រដ្ឋជាជនរងគ្រោះត្រូវបង្ហាញថា អាកប្បកិរិយារបស់ចារីនៃហេតុការណ៍មិនត្រឹមត្រូវទៅនឹងខ្លឹមសារនៃកាតព្វកិច្ចអន្តរជាតិដែលមានប្រភពចេញមកពីអនុសញ្ញា ឬទំនៀមទម្លាប់។

ហេតុការណ៍បង្កើតខ្លះមានលក្ខណៈភ្លាមៗ(ការកម្ទេចអាកាសយានស៊ីវិលមួយដោយកងកម្លាំងរបស់រដ្ឋមួយទៀត) ហើយហេតុការណ៍បង្កើតផ្សេងទៀតលេចចេញឡើងជាបន្តបន្ទាប់គ្នា (ការឈ្លានពាន និងកាន់កាប់ប្រទេសគូវែតដោយប្រទេសអ៊ីរ៉ាក់ពីខែសីហា ឆ្នាំ១៩៩០ដល់ខែកុម្ភៈ ឆ្នាំ១៩៩១)។ ចុងក្រោយគឺហេតុការណ៍បង្កើតដែលហៅថាជាហេតុការណ៍បង្កើត«ចម្រុះ»។ ហេតុការណ៍ទាំងនេះត្រូវបង្កើតដោយចង្កោមនៃកិច្ចខុសច្បាប់ ហើយចាប់ផ្តើមនៅក្នុងហេតុការណ៍ទីមួយ ហើយ«បន្តយូរអង្វែង ល្គឹកណាដែលអំពើ ឬការប្រហែសខកខានទាំងនេះត្រូវបានធ្វើដដែលៗ ហើយនៅតែមិនត្រូវទៅនឹង»កាតព្វកិច្ចអន្តរជាតិរបស់រដ្ឋ(មាត្រា១៥)។

កិច្ចខុសច្បាប់ទាំងអស់មិនមានកម្រិតភាពខុសច្បាប់ដូចគ្នាទេ។កិច្ចខុសច្បាប់ដែលឧស្សាហ៍ជួបប្រទះទាក់ទងទៅនឹងកាតព្វកិច្ចទៅវិញទៅមករបស់រដ្ឋ ហើយនៅតែស្ថិតនៅក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងទ្វេភាគី។ ប៉ុន្តែ កិច្ចខុសច្បាប់ផ្សេងទៀតប៉ះពាល់ដល់សហគមន៍អន្តរជាតិទាំងមូល។ ករណីនៃ«ការរំលោភបំពានធ្ងន់ធ្ងរទៅលើកាតព្វកិច្ចដែលមានប្រភពចេញមកពីធម្មនិយាមបញ្ញានៃនីតិអន្តរជាតិទូទៅ «(ជំពូក៣ មាត្រា៤០ និង៤១)។ នេះជាការរំលោភបំពានធ្ងន់ធ្ងរទៅលើវិធាន Jus Cogens។

## ២- ការទម្លាក់ទោស

ការទម្លាក់ទោស ឬការដាក់បន្ទុកអំពីកិច្ចខុសច្បាប់មួយទៅលើរដ្ឋមួយគឺជាធាតុមួយនៃហេតុការណ៍ខុសច្បាប់ជាអន្តរជាតិ។ ចារីនៃកិច្ចគឺជាអង្គភាពមួយរបស់រដ្ឋ ជាភ្នាក់ងារម្នាក់របស់រដ្ឋ មិនថាមានតំណែងអ្វីនៅក្នុងឋានានុក្រមរដ្ឋទេ(ប្រធានាធិបតីនៃសាធារណរដ្ឋ រដ្ឋមន្ត្រីការបរទេស អភិបាលខេត្ត...) ឬក៏ជាអង្គភាពរួមមួយ។ ចារីនេះអាចអនុវត្តមុខងារនីតិប្រតិបត្តិ នីតិប្បញ្ញត្តិ ឬតុលាការ អាចជាអង្គភាពនៃរដ្ឋាភិបាលកណ្តាល ឬសមូហភាពដែនដីមួយរបស់រដ្ឋ។ កិច្ច ឬអាកប្បកិរិយាខុសច្បាប់របស់រដ្ឋក៏អាចជាអំពើនៃអង្គភាពមួយដែលមិនមែនជាអង្គភាពរបស់រដ្ឋ ប៉ុន្តែត្រូវបានផ្តល់នីតិសម្បទាឱ្យអនុវត្តបុព្វសិទ្ធិនៃអំណាចសាធារណៈ(មាត្រា៥)។ ចុងក្រោយគឺកិច្ចអាចដាក់បន្ទុកដល់រដ្ឋ ទោះបីជាអង្គភាពបំពានសមត្ថកិច្ចរបស់រដ្ឋ ឬប្រព្រឹត្តផ្ទុយទៅនឹង

បទបញ្ជាដែលបានទទួលក៏ដោយ(មាត្រា៧)។

ប៉ុន្តែ រដ្ឋមិនមែនជាអ្នកទទួលខុសត្រូវលើកិច្ចរបស់បុគ្គលឯកជនដែលមានសញ្ជាតិនៃរដ្ឋនេះទេ។ បុគ្គលឯកជនគឺជាប្រធាននៃនីតិផ្ទៃក្នុង ហើយមិនចង់ដោយផ្ទាល់ដោយកាតព្វកិច្ចអន្តរជាតិដែលការរំលោភត្រូវបានលើកឡើងនោះទេ។

ទោះជាបែបនេះក្តី មាត្រា៨នៃសេចក្តីព្រាងទាក់ទងទៅនឹង«អាកប្បកិរិយានៅក្រោមការដឹកនាំ ឬការត្រួតត្រារបស់រដ្ឋ»។ អាកប្បកិរិយារបស់បុគ្គលម្នាក់ ឬរបស់ក្រុមបុគ្គលមួយគឺអាចទម្លាក់ទោសទៅលើរដ្ឋបាន ប្រសិនបើជាក់ស្តែង បុគ្គលទាំងនេះធ្វើអំពើផ្អែកលើការណែនាំ ឬការបង្គាប់បញ្ជា ឬនៅក្រោមការត្រួតត្រារបស់រដ្ឋ។ នៅក្នុងករណីនេះ រដ្ឋអាចឃើញទំនួលខុសត្រូវរបស់ខ្លួនមានការពាក់ព័ន្ធ ដោយសារតែអាកប្បកិរិយារបស់បុគ្គលឯកជន។ ជាច្រើនលើកមកហើយយុត្តាធិការអន្តរជាតិបានមានឱកាសវិនិច្ឆ័យអំពីបញ្ហានេះ។[៧២] នៅក្នុងសាលដីកាឆ្នាំ២០០៧ តុលាការអន្តរជាតិប្រកាន់យកជំហរបែបចង្អៀត និងទាមទារឱ្យមានការត្រួតត្រាជាក់ស្តែង ពោលគឺត្រូវតែមានការបង្កើតការត្រួតត្រាកម្រិតខ្ពស់ពិសេសមួយរបស់រដ្ឋទៅលើបុគ្គល ឬអង្គភាពដែលពាក់ព័ន្ធ» (កថាខណ្ឌ៣៩២)។ បុគ្គលទាំងនេះត្រូវបានដាក់នៅក្រោម«អនិស្សរភាពទាំងស្រុង»របស់រដ្ឋ និង «ធ្វើអំពើនៅក្នុងនាមរបស់រដ្ឋ» (កថាខណ្ឌ៤០៦)។ នៅក្នុងរឿងក្តីនេះ តុលាការបដិសេធមិនដាក់បន្ទុកទៅលើសាធារណរដ្ឋសហព័ន្ធយូកូស្លាវីចំពោះអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តដោយ Republika Srpska (សាធារណរដ្ឋអាយ៉ងដែលបង្កើតឡើងនៅបូស្នីហ៊ែស៊ីកូវីននៅឆ្នាំ១៩៩២) និងដោយកងទ័ពរបស់ប្រទេសនេះនៅសេប្រេនីកាឡើយ។

## ៣- ការប្រតិបត្តិទំនួលខុសត្រូវអន្តរជាតិ

### ៣.១- ការខូចខាត

ការខូចខាតអាចធ្វើឱ្យគេកំណត់អត្តសញ្ញាណកម្មនៃជនរងគ្រោះ និងការរំលោភច្បាប់។ ដោយហេតុនេះក៏អាចឱ្យគេស្វែងរកឃើញនូវផលប្រយោជន៍គតិយុត្តនៃការតបតរបស់ជនរងគ្រោះពីការរំលោភបំពាន។

រដ្ឋមួយអាចលើកឡើងពីទំនួលខុសត្រូវរបស់រដ្ឋមួយទៀតដែលបានរំលោភកាតព្វកិច្ចអន្តរជាតិមួយ(ជាឯកត្តបុគ្គល ឬជាសមាជិកនៃក្រុមរដ្ឋ) ហើយប្រសិនបើការរំលោភនេះប៉ះពាល់ដល់រដ្ឋនោះ(មាត្រា៤២)។ ជនរងគ្រោះ ពោលគឺរដ្ឋខូចប្រយោជន៍ត្រូវបង្ហាញពីចំណងហេតុ និងផលរវាងហេតុការណ៍បង្កើត និងមហន្តរាយ។ និយាយម្យ៉ាងទៀត រដ្ឋត្រូវតែបង្ហាញឱ្យឃើញថាគឺការរំលោភកាតព្វកិច្ចអន្តរជាតិមួយដែលជាបុព្វហេតុនៃការខូចខាតរបស់ខ្លួន។

---

[៧២] *La CIJ a refuse d'imputer aux Etats-Unis les violations du droit humanitaire des contras nicaraguayens (CIJ, arret du 27 juin 1986, Rec. 86, § 115-116);*

ចំណងសហេតុធម៌អាចមានលក្ខណៈផ្ទាល់ ឧទាហរណ៍ដូចជាការវាយប្រហារនៅឆ្នាំ១៩៨៥ នៅអូកខ្លែន នៅប្រទេសនូវ៉ែលហ្សេឡង់ ទៅលើនាវារបស់អង្គការហ្គ្រីនភីសដែលមានឈ្មោះថា «Rainbow Warrior» ដោយភ្នាក់ងារសេវារបស់ប្រទេសបារាំង។ ចំណងហេតុនិងផលក៏អាចមានភាពប្រយោលដែរ នៅពេលដែលរដ្ឋខ្វះកាតព្វកិច្ចប្រុងប្រយ័ត្ន និងធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋមួយទៀត (ករណីនៃអាកប្បកិរិយារបស់អាជ្ញាធរអ៊ីរ៉ង់ នៅពេលមានការចាប់ស្ថានទូតអាមេរិកនៅទីក្រុងតេហេរ៉ង់ជាចំណាប់ខ្មាំង)។[៧៣]

ការខូចខាតអាចជាសម្ភារ ឬផ្លូវចិត្ត។ ការប៉ះពាល់ដល់សិទ្ធិមួយជាការខូចខាតគតិយុត្ត ឬផ្លូវចិត្តនឹងត្រូវអមជាមួយ ឬគ្មានដោយការខូចខាតសម្ភារ។

## ៣.២- ខ្លឹមសារនៃទំនួលខុសត្រូវ

ដោយហេតុតែការរំលោភបំពានច្បាប់ រដ្ឋទទួលខុសត្រូវត្រូវមានកាតព្វកិច្ចបន្ទាប់បន្សំដែលត្រូវធ្វើការជួសជុលមហន្តរាយដែលទទួលរងដោយជនរងគ្រោះ។[៧៤] ទំនួលខុសត្រូវនេះកើតឡើងលុះត្រាតែសិទ្ធិមួយត្រូវបានរំលោភ មិនមែនគ្រាន់តែមានការប៉ះពាល់ដល់ផលប្រយោជន៍មួយនោះទេ។ រដ្ឋទទួលខុសត្រូវត្រូវតែបញ្ចប់ការរំលោភបំពាន ប្រសិនបើការរំលោភនេះនៅបន្ត និងផ្តល់ការធានារ៉ាប់រងថាមិនធ្វើដដែលៗទៀត (មាត្រា៣០)។ នេះគឺជាកាតព្វកិច្ចបញ្ចប់ និងមិនប្រព្រឹត្តបន្តទៀត។ រដ្ឋត្រូវតែជួសជុលមហន្តរាយទាំងមូល (មាត្រា៣១ និង៣៤ដល់៣៩)។

សំណងជួសជុលអាចមានទម្រង់ផ្សេងៗជាទម្រង់ដាច់គ្នា ឬរួមគ្នា។ សំណងគឺជាការបង្កើតឡើងវិញនូវស្ថានភាពពីមុនមកវិញ។ រដ្ឋប្រព្រឹត្តត្រូវតែផ្តល់សោហ៊ុយជួសជុលលើការខូចខាតដែលទទួលរង[៧៥] (ការជួសជុលដោយសមមូល)។ ទម្រង់នៃការជួសជុលអាចជាការបំពេញចិត្ត[៧៦]។ វាអាចស្តែងឡើងតាមរយៈទណ្ឌកម្មលើបុគ្គលដែលជាអ្នកទទួលខុសត្រូវ ការបង់សំណងជំងឺចិត្តជាលក្ខណៈនិម្មិតរូប ឬតាមរយៈការវិនិច្ឆ័យដែលសង្កេតឃើញពីការមិនគោរពកាតព្វកិច្ចដោយរដ្ឋ ការប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋដទៃ និងប្រកាសទំនួលខុសត្រូវរបស់រដ្ឋជាសាធារណៈ។

---

[៧៣] *CIJ, arrêt du 24 mai 1980, Personnel diplomatique et consulaire des Etats-Unis à Teheran, Rec. 1980, p. 3.*

[៧៤] *CIJ, arret du 5 fevrier 1970, Affaire de la Barcelona Traction, Rec. 1970, p. 3, spé. p. 35-36, §§. 44-46.*

[៧៥] *Dans l'affarire du « Rainbow Warrior » la France s'est engagée à verser la somme de sept millions de dollars en réparation de l'ensemble des préjudices subis par la Nouvelle-Zelande (accord du 9 juillet 1986, RGDIP 1987, p. 1054).*

[៧៦] *Dans cette affaire la France a aussi presenté ses excuses officielles.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី៩

## ដែនកំណត់នៃអធិបតេយ្យភាពរបស់រដ្ឋ៖ អភ័យឯកសិទ្ធិ និងប្រព្រឹត្តកម្មបុគ្គលឯកជន

អភ័យឯកសិទ្ធិរបស់រដ្ឋមានគោលដៅជានាការគោរពអធិបតេយ្យរបស់រដ្ឋ នៅពេលដែលភ្នាក់ងារ ច្បាប់ ឬទ្រព្យសម្បត្តិរបស់រដ្ឋនោះមានទំនាក់ទំនងផ្ទាល់ជាមួយនឹងអធិបតេយ្យភាពដែនដីរបស់រដ្ឋមួយទៀត។ បើតាមន័យចំ អភ័យឯកសិទ្ធិរបស់រដ្ឋការពារទ្រព្យសម្បត្តិរបស់រដ្ឋនេះដែលស្ថិតនៅក្នុងទឹកដីបរទេសមួយ និងកិច្ចរបស់រដ្ឋនេះដែលត្រូវគេទាមទារនៅបរទេស។ ប៉ុន្តែ អភ័យឯកសិទ្ធិនេះលាតសន្ធឹងដល់តំណាងរដ្ឋ ទាំងភ្នាក់ងារការទូត និងកុងស៊ុល ហើយឱ្យចំឋានៈពិសេសវិញ គឺ«បុគ្គលមួយចំនួនដែលមានតំណែងខ្ពស់នៅក្នុងរដ្ឋ ដូចជាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ឬរដ្ឋមន្ត្រីការបរទេស»។[៧៧]

រដ្ឋទទួលបាននូវអភ័យឯកសិទ្ធិសម្រាប់ទ្រព្យសម្បត្តិ និងកិច្ចរបស់ខ្លួននៅបរទេស។ ទ្រព្យសម្បត្តិ និងកិច្ចទាំងនេះនៅផុតពីសមត្ថកិច្ចដែនដីរបស់រដ្ឋដទៃ។

រដ្ឋទទួលបានអភ័យឯកសិទ្ធិយុត្តាធិការនៅចំពោះមុខតុលាការរបស់រដ្ឋមួយទៀត សម្រាប់កិច្ចនៃអំណាចសាធារណៈ ឬសកម្មភាពដែលបំពេញនៅក្នុងក្របខ័ណ្ឌនៃបេសកកម្មសេវាសាធារណៈ។

ទ្រព្យសម្បត្តិរបស់រដ្ឋទទួលបានអភ័យឯកសិទ្ធិប្រតិបត្តិ គឺមិនអាចជាកម្មវត្ថុនៃវិធានការអនុវត្តដោយចាប់បង្ខំទេ។

សម្រាប់រដ្ឋខ្លួនឯង និងទ្រព្យសម្បត្តិរបស់រដ្ឋ រដ្ឋទទួលបាននូវសមត្ថកិច្ចរបស់តុលាការរបស់រដ្ឋមួយទៀត នៅក្រោមលក្ខខណ្ឌនៃបទប្បញ្ញត្តិនៃអនុសញ្ញានេះ។ គឺគ្មានបុរេវិនិច្ឆ័យ ឬការវិនិច្ឆ័យនៃវិធានការបង្ខិតបង្ខំដែលមានដូចជាការរឹបអូស ឬការឃាត់ទុកទ្រព្យសម្បត្តិរបស់រដ្ឋមួយអាចត្រូវធ្វើបាននៅក្នុងក្របខ័ណ្ឌនីតិវិធី នៅចំពោះមុខតុលាការមួយនៃរដ្ឋមួយទៀត(មាត្រា១៨ និង១៩)។

អធិបតេយ្យភាពរបស់រដ្ឋមិនមែនដាច់ខាតនោះទេ។ វិធានអន្តរជាតិជាច្រើនមានដែនកំណត់។ លើសពីវិធានសន្ធិសញ្ញា គឺមានការដាក់ដែនកំណត់ដល់អធិបតេយ្យរបស់រដ្ឋដោយវិធានទំនៀមទម្លាប់។ វាគឺជាផលវិបាកជាធម្មជាតិស្របច្បាប់នៃកាតព្វកិច្ចគោរពអធិបតេយ្យរបស់រដ្ឋដទៃ។

រដ្ឋមួយមិនអាចអនុវត្តអំណាចអធិបតេយ្យរបស់ខ្លួននៅលើ ឬជ្រៀតជ្រែកជាមួយនឹងសកម្ម-

[៧៧] *CIJ, arrêt du 14 février 2002, Mandat d'arrêt du 11 avril 2000, par. 51; Arrêt du 4 juin 2008, Certaines questions concernant l'entraide judiciaire en matière pénale, par. 17.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាពស្របច្បាប់ដែលធ្វើឡើងដោយរដ្ឋបរទេសនៅលើទឹកដីនៃរដ្ឋមុនឡើយ។ នេះវាកើតចេញពីគោលការណ៍ដែលបង្ខំឱ្យមានការគោរពទូទៅចំពោះឯករាជ្យ និងភាពថ្លៃថ្នូររបស់រដ្ឋបរទេស។ រដ្ឋមួយមិនអាចធ្វើកិច្ចដូចខាងក្រោមបានទេ ៖

១- ដាក់បង្ខំឆន្ទៈរបស់ខ្លួន ឬជ្រៀតជ្រែក ឬដាក់កំហិតលើមន្ត្រីរាជការរបស់រដ្ឋបរទេស។

២- បំផ្លាញកងកម្លាំងប្រដាប់អាវុធបរទេសដែលបោះមូលដ្ឋានស្របច្បាប់នៅលើទឹកដីរដ្ឋនោះ( លើកលែងតែត្រូវបានអនុញ្ញាតឱ្យធ្វើដូច្នេះដោយវិធាននៃសន្ធិសញ្ញា ឬការព្រមព្រៀងគ្នាសម្រាប់ករណីនេះផ្ទាល់)។

៣- បំពេញកិច្ចដែលបង្ខំ ឬដាក់កំហិតនៅលើនាវា ឬអាកាសយានយោធា ឬសាធារណៈបរទេស( ឧទាហរណ៍ នាវា ឬយាននោះអាចមិនគោរពច្បាប់នៅទីនោះ)។

៤- ដាក់រដ្ឋបរទេសនៅក្រោមសមត្ថកិច្ចនៃតុលាការរដ្ឋនេះ ចំពោះកិច្ចដែលបំពេញនៅក្នុងនាមជាអធិបតេយ្យរបស់រដ្ឋទាំងនេះ( លទ្ធិ«អភ័យឯកសិទ្ធិអធិបតេយ្យរបស់រដ្ឋ»)។

៥- ដាក់ភ្នាក់ងាររបស់រដ្ឋបរទេសនៅក្រោមសមត្ថកិច្ចនៃតុលាការរដ្ឋនេះ ចំពោះកិច្ចដែលបំពេញនៅក្នុងឋានៈផ្លូវការរបស់ពួកគេ។

## ១- អភ័យឯកសិទ្ធិរបស់រដ្ឋបរទេសនៃសមត្ថកិច្ចរបស់តុលាការ

លទ្ធិនៃអភ័យឯកសិទ្ធិរបស់រដ្ឋបរទេសស្តីពីយុត្តាធិការរបស់រដ្ឋផ្អែកនៅលើតក្កវិជ្ជាពីរ។ ទីមួយ រដ្ឋមិនត្រូវជ្រៀតជ្រែកចូលកិច្ចសាធារណៈរបស់រដ្ឋអធិបតេយ្យបរទេសដោយការគោរពឯករាជ្យនៃប្រទេសទាំងនេះ។ ទីពីរ អំណាចតុលាការមិនត្រូវជ្រៀតជ្រែកចូលការដឹកនាំនយោបាយការបរទេសដែលអាចដឹកនាំដោយអាជ្ញាធររដ្ឋាភិបាលជាតិ ឬបរទេស ដោយឈរលើគោលការណ៍បែងចែកអំណាច។

ជាឧទាហរណ៍ នៅក្នុងរឿងក្តីល្បីល្បាញរវាង Underhill និង Hernandez នៅឆ្នាំ១៨៩៧ តុលាការកំពូលរបស់អាមេរិកបានប្រកាសថា «រាល់រដ្ឋអធិបតេយ្យទាំងអស់ត្រូវគោរពឯករាជ្យភាពរបស់រាល់រដ្ឋអធិបតេយ្យផ្សេងទៀត ហើយតុលាការរបស់ប្រទេសមួយមិនអាចវិនិច្ឆ័យលើកិច្ចរបស់រដ្ឋាភិបាលរបស់រដ្ឋមួយទៀតនៅលើទឹកដីផ្ទាល់របស់រដ្ឋមុនទេ»...។ នៅឆ្នាំ១៨៨០ នៅក្នុងសភាប៊ែលហ្សិក តុលាការឧទ្ធរណ៍របស់ប្រទេសកូឡុំប៊ីបានប្រកាន់យកជំហរដូចគ្នានេះ។ តុលាការនេះបានវិនិច្ឆ័យថា ៖

«ជាផលវិបាកមួយនៃឯករាជ្យភាពដាច់ខាតរបស់អាជ្ញាធរអធិបតេយ្យនីមួយៗ និងបោរីភាពអន្តរជាតិដែលតម្រូវឱ្យរដ្ឋអធិបតេយ្យនីមួយៗគោរពឯករាជ្យភាព និងភាពថ្លៃថ្នូររបស់រដ្ឋអធិបតេយ្យផ្សេងទៀតទាំងអស់ដែលក្នុងនោះរដ្ឋនីមួយៗ និងមនុស្សគ្រប់គ្នាបដិសេធនឹងធ្វើការអនុវត្ត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមរយៈតុលាការខ្លួននូវសមត្ថកិច្ចដែនដីទៅលើបុគ្គលរបស់មហាក្សត្រ ឬបុគ្គលនៃឯកអគ្គរដ្ឋទូតរបស់រដ្ឋដទៃមួយ ឬទៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមួយដែលមានគោលដៅជាការប្រើប្រាស់ជាសាធារណៈ ឬទៅលើកម្មសិទ្ធិរបស់ឯកអគ្គរដ្ឋទូតម្នាក់ ប្រសិនបើមហាក្សត្រ ឯកអគ្គរដ្ឋទូត ឬទ្រព្យសម្បត្តិស្ថិតលើទឹកដីរបស់ខ្លួន និងនៅក្នុងលក្ខខណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែចំពោះការព្រមព្រៀងរួមគ្នា» (៣៣១)។

មួយសតវត្សរ៍ក្រោយមក នៅក្នុងរឿងក្ដីរវាង Buttes Gas and Oil Co. និង Marteau de la Chambre des Lords britannique លោក Wilberforce បានរំពឹងថា ប្រតិបត្តិការរបស់រដ្ឋអធិបតេយ្យបរទេសមិនមែនជាបញ្ហាដែលតុលាការក្រុងត្រូវវិនិច្ឆ័យនោះទេ (១០៧)។

## ២- លទ្ធិចង្អៀតនៃអភ័យឯកសិទ្ធិរបស់រដ្ឋបរទេសស្ដីពីយុត្តាធិការស៊ីវិល

នៅក្នុងអតីតកាល អភ័យឯកសិទ្ធិរបស់រដ្ឋបរទេសគឺមានភាពដាច់ខាត។ បន្ទាប់មក បន្តិចម្ដងៗ នៅចុងសតវត្សរ៍ទី១៩ ទស្សនបែបចង្អៀតមួយបានមានរូបរាងឡើង។ ការលើកលែងមួយត្រូវបានគ្រោងទុកចំពោះកិច្ចដែលប្រព្រឹត្ត juris gestionis ឬ jure privatorium ដែលត្រូវបានធ្វើដោយរដ្ឋបរទេសមួយនៅក្នុងលក្ខណៈជាឯកជនក្នុងនាមជានីតិបុគ្គលដែលស្ថិតនៅក្រោមច្បាប់ឯកជន។ និន្នាការថ្មីនេះបានកើតឡើងនៅក្នុងយុទ្ធសាស្ត្ររបស់ប្រទេសប៊ែលហ្ស៊ិក និងប្រទេសអ៊ីតាលី។

នៅក្នុងឆ្នាំ១៩៥៨ នៅក្នុងរឿងក្ដីរវាង Rahimtoola និង Nizam of Hyderabad លោក Denning បានកត់សម្គាល់ថា «នៅក្នុងប្រទេសមានអារ្យធម៌ទាំងអស់ ធ្លាប់មាននិន្នាការដែលបន្តិចម្ដងៗធ្វើឱ្យព្រះមហាក្សត្រអាចមានទំនួលខុសត្រូវនឹងត្រូវផ្ដន្ទាទោសដោយតុលាការរបស់ព្រះអង្គផ្ទាល់...។ មហាក្សត្របរទេសមិនត្រូវស្ថិតនៅក្នុងស្ថានភាពខុសពីនេះទេ( ទំព័រ៤១៨)។ នៅឆ្នាំ១៩៨១ នៅក្នុងវិធីសាស្ត្រដែលមានការតាក់តែងល្អលោក Wilberforce បានលើកឡើងនូវ 1 ° Congreso del Partido ទាក់ទិនទៅនឹងទ្រឹស្ដីចង្អៀតដែលមានខ្លឹមសារដូចខាងក្រោម ៖

វាចេញពីឆន្ទៈរបស់រដ្ឋក្នុងការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងធ្វើប្រតិបត្តិការជាមួយបុគ្គលឯកជននៅក្នុងច្បាប់ឯកជន។ វាហាក់ដូចជាមានមូលដ្ឋានគ្រឹះចម្បងពីរ ៖

១- ជាប្រយោជន៍នៅក្នុងផ្នែកយុត្តិធម៌ វាចាំបាច់សម្រាប់បុគ្គលដែលបានចុះហត្ថលេខាលើប្រតិបត្តិការនានាជាមួយរដ្ឋ ដើម្បីអាចអនុញ្ញាតឱ្យពួកគេលើកប្រតិបត្តិការទាំងនេះដាក់នៅចំពោះមុខតុលាការបាន។

២- ត្រូវបង្ខំរដ្ឋឱ្យឆ្លើយតបទៅនឹងសំណើដែលផ្អែកលើប្រតិបត្តិការមួយនេះដែលបានធ្វើឱ្យមានបញ្ហាប្រឈម ឬការអង្កេតទៅលើកិច្ចអធិបតេយ្យភាព ឬកិច្ចរដ្ឋាភិបាលរបស់រដ្ឋនេះ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*បើយោងទៅតាមឃ្លាដែលទទួលយកបាន វាមិនមែនជាការគំរាមសម្រាប់ភាពថ្លៃថ្នូររបស់រដ្ឋនេះ ហើយក៏មិនមែនជាការជ្រៀតជ្រែកណាមួយជាមួយនឹងមុខងាររព្រះមហាក្សត្រដែរ»( ៣០៧)។*

*នៅពេលបច្ចុប្បន្ននេះ រដ្ឋស្ទើរតែទាំងអស់អនុម័តយកលទ្ធិអភ័យឯកសិទ្ធិចង្អៀត។ លទ្ធិដែលមានឥទ្ធិពលខ្លាំងនៅពេលបច្ចុប្បន្ននេះ ចាត់ទុកថា កិច្ចដែលប្រព្រឹត្ត jure gestionis មានន័យថាជាប្រតិបត្តិការឯកជន ឬពាណិជ្ជកម្មត្រូវស្ថិតនៅក្រោមយុត្តាធិការបរទេស។ ប៉ុន្តែកិច្ចដែលប្រព្រឹត្តបែប jure impérialisme ពោលគឺប្រព្រឹត្តឡើងដោយរដ្ឋបរទេសនៅក្នុងឋានៈជាអធិបតី គឺស្ថិតនៅផុតពីយុត្តាធិការ។*

*ទោះជាយ៉ាងនេះក្តី ដោយទុកចោលនូវអ្វីដែលគេហៅថា «កិច្ចអធិបតេយ្យ» តើគេអាចកំណត់និយមន័យនៃកិច្ចដែលប្រព្រឹត្តដោយរដ្ឋបរទេសនៅក្នុងលក្ខណៈជាឯកជនបានយ៉ាងដូចម្តេច?*

*ស្របទៅតាមមាត្រា១០នៃសេចក្តីព្រាងរបស់គណៈកម្មការនីតិអន្តរជាតិឆ្នាំ១៩៩១ ស្តីពីអភ័យឯកសិទ្ធិយុត្តាធិការរបស់រដ្ឋ និងទ្រព្យសម្បត្តិរបស់រដ្ឋ រដ្ឋមិនទទួលបានអភ័យឯកសិទ្ធិយុត្តាធិការទេ នៅពេលដែលរដ្ឋចូលរួមនៅក្នុង«ប្រតិបត្តិការពាណិជ្ជកម្ម»មួយជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលបរទេសមួយ។ ស្របតាមមាត្រា២.១(c)នៃសេចក្តីព្រាងនេះ មធ្យោបាយសម្រាប់ «ប្រតិបត្តិការពាណិជ្ជកម្ម» គឺមាន ៖*

*១- រាល់កិច្ចសន្យា ឬប្រតិបត្តិការពាណិជ្ជកម្មសម្រាប់ការលក់ផលិតផល ឬការផ្តល់សេវាកម្ម។*

*២- រាល់កិច្ចសន្យាកម្ចី ឬប្រតិបត្តិការផ្សេងទៀតដែលមានលក្ខណៈហិរញ្ញវត្ថុរួមទាំងរាល់កាតព្វកិច្ចធានា ឬការផ្តល់សោហ៊ុយប៉ះប៉ូវដែលមានទំនាក់ទំនងទៅនឹងកម្ចី ឬប្រតិបត្តិការនេះ។*

*៣- រាល់កិច្ចសន្យា ឬប្រតិបត្តិការផ្សេងទៀតរបស់អ្នកឧស្សាហកម្ម ឬពាណិជ្ជកម្មម្នាក់ ឬរបស់អ្នកអាជីពក្នុងវិស័យពាណិជ្ជកម្មដែលមិនមានកិច្ចសន្យាការងាររបស់បុគ្គល។ សេចក្តីព្រាងមាត្រាទាំងនេះត្រូវបានអនុម័តនៅឆ្នាំ១៩៩១ នៅពេលអានជាលើកទីពីរ។*

## ៣- អភ័យឯកសិទ្ធិយុត្តាធិការរបស់រដ្ឋបរទេសនៅក្នុងវិស័យការងារ

*ការគោរពឯករាជ្យភាព និងអធិបតេយ្យភាពរបស់រដ្ឋបរទេសក៏តម្រូវមិនឱ្យរដ្ឋជ្រៀតជ្រែក ឬលូកដៃនៅក្នុងរចនាសម្ព័ន្ធផ្ទៃក្នុងរបស់រដ្ឋទាំងនោះទេ។ នៅឆ្នាំ១៩៩៧ នៅក្នុងរឿងក្តី Blaskic (Supoena) សាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូកូស្លាវីបានប្រកាសថា «វាជារឿងដែលគេស្គាល់ច្បាស់ហើយដែលថា ច្បាប់អន្តរជាតិទំនៀមទម្លាប់ការពារការចាត់តាំងផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យនីមួយៗ»។ តុលាការទុកឱ្យរដ្ឋអធិបតេយ្យនីមួយៗកំណត់រចនាសម្ព័ន្ធផ្ទៃក្នុងរបស់ខ្លួន ជាពិសេសឱ្យតែងតាំងបុគ្គលដែលបំពេញតួនាទីជាអង្គភាពរបស់រដ្ឋ ឬជា*

ភ្នាក់ងារ»(កថាខណ្ឌ៤១)។ ហើយជាបន្តទៀត រដ្ឋមួយមិនអាចអង្គុយលើអាសនៈដើម្បីធ្វើការវិនិច្ឆ័យទៅលើទំនាក់ទំនងការងាររវាងបុគ្គលឯកជន(ទោះជាបុគ្គលទាំងនេះជាអាណិកជន ឬមិនមែនអាណិកជននៃរដ្ឋក្នុងស្រុកនេះក្តី) និងរដ្ឋបរទេស។ ឧទាហរណ៍ នៅក្នុងរយៈពេលជាច្រើនឆ្នាំ តុលាការជាតិបានវិនិច្ឆ័យថា នៅរៀងរាល់ពេលដែលកិច្ចសន្យាការងារជាមួយអង្គភាព និងស្ថាប័នរដ្ឋបរទេស(ឧទាហរណ៍ ស្ថានទូត ស្ថានកុងស៊ុល មជ្ឈមណ្ឌលវប្បធម៌)មានទំនាក់ទំនងពាក់ព័ន្ធទៅនឹងមុខងារសាធារណៈរបស់រដ្ឋទាំងនេះ កិច្ចសន្យាទាំងនេះអាចមិនស្ថិតនៅក្រោមយុត្តាធិការនៃទឹកដីរបស់រដ្ឋវេទិកា។ ដូច្នេះ តុលាការទាំងនេះបានលើកឡើងយ៉ាងច្បាស់ពីការបែងចែកចាស់រវាងកិច្ចដែលប្រព្រឹត្ត jure gestionis និងកិច្ចដែលបំពេញតាមបែប jure imperii។

ការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិជាសារវន្តរបស់មនុស្សអាចលេចចេញតាមក្រោយបាន។ ជាការពិតណាស់ លទ្ធិដែលមានឥទ្ធិពលខ្លាំងស្តីពីសិទ្ធិមនុស្សបានចែងពីសិទ្ធិរបស់បុគ្គលឯកជនម្នាក់ៗក្នុងការប្រើប្រាស់ឧបាស្រ័យតុលាការដែលមានបើកឱ្យ ដើម្បីរក្សាការពារសិទ្ធិជាសារវន្តរបស់ខ្លួន។ បន្ទាប់ពីមានក្តីកង្វល់ថ្មីៗទាំងនេះមក ការបែងចែកបែបបុរាណបានប្រែក្លាយទៅជាទន់ភ្លន់បន្តិចម្តងៗ។

ទីមួយ តុលាការជាច្រើនបានសង្កត់ធ្ងន់ទៅលើចរិតលក្ខណៈឯកជននៃកិច្ចសន្យាការងារ។

ឧទាហរណ៍ តុលាការការងារទីក្រុងប្រ៊ុចសែលបានវិនិច្ឆ័យថា ទាំងការធ្វើ ឬការបញ្ចប់កិច្ចសន្យាការងារមួយដែលជាកិច្ចរបស់ស្ថានទូតបរទេស ក្នុងនាមជាបុគ្គលឯកជន គឺមិនមែនជាការអនុវត្តមុខងារសាធារណៈទេ ប៉ុន្តែគឺជាការបំពេញកិច្ចពាណិជ្ជកម្មធម្មតាមួយ (សូមមើល Royaume du Maroc v DR ទាក់ទិនទៅនឹងអាណិកជនព័រទុយហ្កាល់ដែលត្រូវបានប្រើប្រាស់ជាអ្នកបើកបរដោយស្ថានទូតប្រទេសម៉ារុកប្រចាំនៅទីក្រុងប្រ៊ុចសែល)។

ទីពីរ តុលាការជាច្រើនបានបង្កើតការបែងចែករវាងសកម្មភាពរបស់បុគ្គលដែលត្រូវប្រើដោយទីភ្នាក់ងារបរទេសដែលនៅបន្ទាប់បន្សំនៅក្នុងមុខងារសាធារណៈរបស់អង្គភាពបរទេស និងសកម្មភាពដែលទាក់ទងដោយផ្ទាល់ដោយការអនុវត្តមុខងារទាំងនេះ(បុគ្គលដែលបំពេញមុខងារសន្តិសុខ)។ ឬតុលាការបានបង្កើតជាការបែងចែកគ្នាមួយរវាងជម្លោះការងារដែលវិលនៅជុំវិញការប៉ះប៉ូវ ឬបញ្ហាបេតិកភណ្ឌ និងបញ្ហាដែលពាក់ព័ន្ធទៅនឹងអំណាចរបស់ទីភ្នាក់ងារបរទេស ដើម្បីបញ្ចប់កិច្ចសន្យាការងារមួយ។

ទីបី លិខិតូបករណ៍អន្តរជាតិមាននិន្នាការផ្តល់លក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងមានវត្តបំណងកាន់តែច្បាស់ ដើម្បីកំណត់ថា តើរដ្ឋបរទេសទទួល ឬមិនទទួលបាននូវអភ័យឯកសិទ្ធិយុត្តាធិការ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤- អភ័យឯកសិទ្ធិ និង Jus Cogens

*មានវិធានទំនៀមទម្លាប់នៃច្បាប់អន្តរជាតិដែលមានកម្លាំងគតិយុត្តពិសេស។ វិធានទាំងនេះមិនអាចត្រូវនិរាករណ៍ដោយសន្ធិសញ្ញា ឬវិធានទំនៀមទម្លាប់ទេ ហើយប្រសិនបើវិធានតាមអនុសញ្ញាត្រូវបានព្រមព្រៀង ឬវិធានទំនៀមទម្លាប់ចាប់ផ្តើមបានអត្ថិភាព វិធានទាំងនេះអាចត្រូវធ្វើឱ្យមិនមានសុពលភាពដោយវាផ្ទុយទៅនឹង Jus Cogens។ ដូច្នេះបញ្ហាដែលចោទឡើងគឺត្រូវដឹងថាតើអត្ថិភាពនៃបញ្ញត្តិចាប់បង្ខំអាចឃាត់ការអនុវត្តវិធានទូទៅស្តីពីអភ័យឯកសិទ្ធិយុត្តាធិការរបស់រដ្ឋ ហើយជាផលវិបាក តើវាអាចអនុញ្ញាតឱ្យតុលាការមួយរបស់រដ្ឋអាចធ្វើការវិនិច្ឆ័យសេចក្តីទៅលើកិច្ចដែលបំពេញដោយរដ្ឋបរទេសមួយក្នុងឋានៈផ្លូវការ និងសាធារណៈរបស់រដ្ឋនេះឬទេ។*

*បញ្ហានេះចោទឡើងនៅក្នុងរឿងក្តីមួយរវាងលោក Princz ប្រឆាំងនឹងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នៅមុខតុលាការឧទ្ធរណ៍អាមេរិក។*

*ដើមបណ្តឹង ដែលជាជនជាតិជ្វីសសញ្ជាតិអាមេរិក នៅពេលដែលនៅជាអនីតិជននៅឡើយ ត្រូវបានគេឃាត់ខ្លួនជាមួយនឹងគ្រួសារគាត់នៅឆ្នាំ១៩៤២ នៅប្រទេសអាល្លឺម៉ង់ ហើយបានរស់នៅក្នុងជំរុំប្រមូលផ្តុំជាច្រើនដែលនៅទីនោះ គាត់ និងគ្រួសារបានទទួលរងនូវប្រព្រឹត្តកម្មព្រៃផ្សៃ ហើយដែលមានតែដើមបណ្តឹងម្នាក់នេះគត់ដែលបានរួចរស់រានមានជីវិត។ បន្ទាប់ពីព្យាយាមអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីទទួលបានសំណងប៉ះប៉ូវ ឬសោធន គាត់បានប្តឹងសុំសំណងជំងឺចិត្តពីប្រទេសអាល្លឺម៉ង់នៅក្នុងតុលាការរដ្ឋអាមេរិក។ ប្រទេសអាល្លឺម៉ង់បានច្រានចោលពាក្យបណ្តឹងដោយឈរលើមូលដ្ឋានអភ័យឯកសិទ្ធិ ដោយអនុលោមតាមច្បាប់ស្តីពីអភ័យឯកសិទ្ធិអធិបតេយ្យនៅបរទេសរបស់អាមេរិកឆ្នាំ១៩៧៦។ នៅក្នុងខណៈដែលតុលាការអាមេរិកទទួលយកពាក្យបណ្តឹងរបស់ដើមបណ្តឹង តុលាការឧទ្ធរណ៍បានច្រានចោលដោយមូលហេតុថា ប្រទេសអាល្លឺម៉ង់មានសិទ្ធិចំពោះអភ័យឯកសិទ្ធិអធិបតេយ្យ។ នៅក្នុងយោបល់ដែលខុសពីមតិភាគច្រើនសមាជិកម្នាក់នៃតុលាការឧទ្ធរណ៍ គឺចៅក្រម Patricia Wald បានលើកឡើងថា (១) ប្រទេសអាល្លឺម៉ង់ពិតប្រាកដជាក់ស្តែងបានរំលោភវិធាន jus cogens ដោយបានទាញយកកម្លាំងការងាររបស់ Princz ពី l'IG Farben និងរោងចក្រ Messerschmidt និងដោយបានដាក់គាត់ឱ្យទទួលអំពើហិង្សារាងកាយ និងផ្លូវចិត្តដែលមិនអាចទទួលយកបាននៅអូស្វីត និងនៅជំរុំសមាជាស្ស។ (២) បើតាមនិយមន័យបញ្ញត្តិចាប់បង្ខំ jus cogens មិនអាចត្រូវនិរាករណ៍ទេ ហើយដូច្នេះពេលរដ្ឋមួយបង្កើតធម្មនិយាមមួយ ពោលគឺការជំនួសឆន្ទៈរួមរបស់សហគមន៍អន្តរជាតិទាំងមូលរដ្ឋមិនអាចបំពេញកិច្ចអធិបតេយ្យស្តីពីសិទ្ធិអភ័យឯកសិទ្ធិទេ។ (៣) អនុលោមតាមច្បាប់អន្តរជាតិរដ្ឋមួយបោះបង់សិទ្ធិទៅលើអភ័យឯកសិទ្ធិរបស់ខ្លួន នៅពេលដែលរដ្ឋនោះបំពានលើធម្មនិយាម*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*jus cogens*។ ចៅក្រម Wald បានសន្និដ្ឋានថា ច្បាប់ស្ដីពីអភ័យឯកសិទ្ធិអធិបតេយ្យបរទេសរបស់អាមេរិកត្រូវបកស្រាយថា រួមមាននូវគោលការណ៍ដែលតាមរយៈនោះរដ្ឋបរទេសមួយលះបង់សិទ្ធិស្ដីពីអភ័យឯកសិទ្ធិអធិបតេយ្យរបស់តុលាការសហរដ្ឋអាមេរិកដោយបំពានលើធម្មនិយាមនៃ *jug cogens* ( à 612-19)។

ម្យ៉ាងវិញទៀត បញ្ហានេះត្រូវបានលើកឡើងសារជាថ្មី នៅមុខតុលាការសិទ្ធិមនុស្សអឺរ៉ុបនៅក្នុងរឿងក្ដីរវាង *Al-Adsani* និងចក្រភពអង់គ្លេស។ បញ្ហាវិលជុំវិញការធ្វើទារុណកម្ម។ យោងតាមដើមបណ្ដឹង វិធានទូទៅដែលហាមឃាត់ចំពោះទារុណកម្ម ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងអនុសញ្ញា(មាត្រា៣) គឺស្ថិតនៅក្នុងវិធាន *jus cogens*។ ដូចនេះ រដ្ឋបរទេស ប្រសិនត្រូវបានទាក់ទាញឱ្យចូលនៅមុខយុត្តាធិការជាតិមួយ ចំពោះការសង្ស័យថា រំលោភវិធានទាំងនេះត្រូវហាមឃាត់មិនឱ្យលើកឡើងពីអភ័យឯកសិទ្ធិយុត្តាធិការទេ។ ប៉ុន្តែនៅឆ្នាំ២០០១ ជាមួយនឹងចៅក្រមដែលមានយោបល់ផ្ទុយនឹងមតិភាគច្រើន តុលាការអឺរ៉ុបបានវិនិច្ឆ័យថា ទោះបីជាមានសារជាតុបង្ខំចំពោះការហាមប្រាមក្ដី អភ័យឯកសិទ្ធិយុត្តាធិការចំពោះការធ្វើទារុណកម្មមិនអាចច្រានចោលបានទេ។

## ៥- អភ័យឯកសិទ្ធិប្រតិបត្តិរបស់រដ្ឋបរទេស

អភ័យឯកសិទ្ធិប្រតិបត្តិរបស់រដ្ឋបរទេសមានលក្ខណៈដូចគ្នានឹងអភ័យឯកសិទ្ធិយុត្តាធិការ។ ដូច្នេះ អភ័យឯកសិទ្ធិចាស់ក៏ត្រូវបានបង្កើតដោយឈរលើមូលដ្ឋាននៃការបែងចែករវាងកិច្ចឯកជន និងពាណិជ្ជកម្មរបស់រដ្ឋ (*jure gestionis*) និងកិច្ចដែលបំពេញនៅក្នុងនាមជាអធិបតី (*jure imperii*)។ ក្នុងករណីកិច្ចឯកជន អភ័យឯកសិទ្ធិត្រូវបានបដិសេធ។ ក៏ប៉ុន្តែ ក្នុងករណីកិច្ចពាណិជ្ជកម្មរបស់រដ្ឋ រដ្ឋបរទេសមានអភ័យឯកសិទ្ធិ។ នេះគឺជាភាពស្របគ្នារវាងអភ័យឯកសិទ្ធិយុត្តាធិការ និងអភ័យឯកសិទ្ធិប្រតិបត្តិ។

វិធានការបង្ខិតបង្ខំអាចចាត់ធ្វើឡើងប្រឆាំងនឹងទ្រព្យ ឬទ្រព្យសកម្មរបស់រដ្ឋបរទេសដែលប្រើសម្រាប់មុខងារឯកជន ពោលគឺប្រើប្រាស់សម្រាប់គោលដៅពាណិជ្ជកម្ម ត្រូវបានចាត់ទុកដោយតុលាការថា ជាផលវិបាក សមស្រប និងមិនអាចជៀសបាន ដោយហេតុថា តុលាការអាចធ្វើការវិនិច្ឆ័យទៅលើច្បាប់ជាសារវន្តនៅក្នុងវិវាទ ប៉ុន្តែពុំមានអំណាចចេញបញ្ជាបង្ខំឱ្យមានវិធានការដែលមានគោលដៅធ្វើឱ្យច្បាប់នេះចូលជាធរមានបានទេ។

ប៉ុន្តែ ទាំងនៅក្នុងវិធានការប្រតិបត្តិ ឬបង្ការ ទ្រព្យសម្បត្តិរបស់រដ្ឋបរទេសមិនអាចរឹបអូស ឬឃាត់ទុកប្រឆាំងទៅនឹងទ្រព្យសម្បត្តិរបស់រដ្ឋបរទេសមួយដែលប្រើសម្រាប់អនុវត្តមុខងារសាធារណៈឡើយ។

ជាធម្មតា តុលាការបានសម្រេចថាវិធានការប្រតិបត្តិអាចចាត់តាំងឡើងប្រឆាំងទៅនឹងគណនីធនាគារដែលជាកម្មសិទ្ធិរបស់រដ្ឋបរទេស ប៉ុន្តែក្នុងករណីគណនីដែលបើកដោយស្ថានបេសកកម្មការទូតបរទេស តុលាការរបស់រដ្ឋខ្លះមាននិន្នាការប្រកាន់យកថា គណនីទាំងនោះមានគោលដៅបំពេញមុខងារសាធារណៈរបស់រដ្ឋបរទេស។

## ៦- អភ័យឯកសិទ្ធិនៃអង្គភាពរបស់រដ្ឋបរទេស

រដ្ឋមួយមិនអាចស្នើសុំឱ្យមន្ត្រីពជការរបស់រដ្ឋបរទេសដែលធ្វើការលើទឹកដីខ្លួនធ្វើរបាយ-ការណ៍ស្តីពីកិច្ចដែលបំពេញនៅក្នុងការអនុវត្តមុខងាររបស់មន្ត្រីនោះឡើយ( លើកលែងនៅក្នុងករណីឧក្រិដ្ឋកម្មអន្តរជាតិ)។

សាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូកូស្លាវីបានអះអាងបញ្ជាក់សារជាថ្មីនូវគោលការណ៍នេះ និងបានកំណត់យុត្តិកម្មនៅក្នុងរឿងក្តី Blas1cic (subpoena) ដូចខាងក្រោម ៖

ច្បាប់ទំនៀមទម្លាប់អន្តរជាតិការពារការចាត់តាំងផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យនីមួយៗ និងទុកឱ្យរដ្ឋនីមួយៗកំណត់រចនាសម្ព័ន្ធផ្ទៃក្នុង ជាពិសេសទុកឱ្យរដ្ឋតែងតាំងបុគ្គលដែលត្រូវបំពេញតួនាទីជាភ្នាក់ងារ ឬអង្គភាពរបស់រដ្ឋ។ រដ្ឋអធិបតេយ្យនីមួយៗមានសិទ្ធិផ្តល់ជាបទបញ្ជាដល់អង្គ-ភាពរបស់រដ្ឋនេះ ទាំងចំពោះអ្នកដែលប្រតិបត្តិនៅកម្រិតផ្ទៃក្នុង និងអ្នកដែលប្រតិបត្តិនៅក្នុងទំនាក់ទំនងអន្តរជាតិ និងមានសិទ្ធិគ្រោងទុកនូវទណ្ឌកម្ម ឬវិធានការផ្សេងទៀត ក្នុងករណីមិនគោរពបទបញ្ជាទាំងនេះ។ ផលវិបាកនៃអំណាចដាច់ខាតនេះ គឺថា រដ្ឋនីមួយៗមានសិទ្ធិទាមទារថាកិច្ច ឬប្រតិបត្តិការដែលបំពេញដោយអង្គភាពមួយរបស់រដ្ឋ ត្រូវតែជាទំនួលខុសត្រូវរបស់រដ្ឋ ហើយអង្គភាពដែលពាក់ព័ន្ធនេះមិនអាចជាអ្នកទទួលខុសត្រូវនៃកិច្ច និងប្រតិបត្តិការទាំងនេះទេ។ វិធានទូទៅដែលកំពុងពិភាក្សានេះពិតជាត្រូវបានបង្កើតនៅក្នុងច្បាប់អន្តរជាតិ និងផ្អែកទៅលើសមភាពអធិបតេយ្យរបស់រដ្ឋ។[៧៨]

## ៧- អភ័យឯកសិទ្ធិរបស់ភ្នាក់ងារការទូត

ច្បាប់អន្តរជាតិទំនៀមទម្លាប់ផ្តល់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិជាច្រើនដល់ភ្នាក់ងារការទូត។ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងនេះត្រូវបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១ ហើយបទប្បញ្ញត្តិភាគច្រើននៃអនុសញ្ញានេះគឺសុទ្ធតែជាការប្រកាសនៃច្បាប់ទំនៀមទម្លាប់ ឬក៏បំលែងទៅជាច្បាប់ទូទៅហើយ។

[៧៨] *par en parem non habet imperium (§ § 41-2).*

វិធានទាំងនេះគ្រោងពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិពីរប្រភេទដែលត្រួតស៊ីគ្នា។ អ្នកការទូតទទួលបានអភ័យឯកសិទ្ធិមុខងារក្នុងនាមជាមន្ត្រីរាជការរបស់រដ្ឋ សម្រាប់កិច្ច និងប្រតិបត្តិការដែលធ្វើឡើងនៅក្នុងឋានៈផ្លូវការរបស់ពួកគេ។

• ប្រភេទមួយគឺរួមមានអភ័យឯកសិទ្ធិដែលពាក់ព័ន្ធទៅនឹងទីតាំង និងទ្រព្យសកម្មដែលប្រើប្រាស់ដោយភ្នាក់ងាររបស់រដ្ឋបរទេស សម្រាប់បំពេញបេសកកម្មរបស់ខ្លួន( នេះគឺជាអភ័យឯកសិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិ)។

• ប្រភេទមួយទៀតរួមបញ្ចូលនូវអភ័យឯកសិទ្ធិដែលគ្របដណ្តប់លើសកម្មភាពបុគ្គលរបស់មន្ត្រីរាជការនេះ( អភ័យឯកសិទ្ធិបុគ្គល)។ អភ័យឯកសិទ្ធិនេះផ្តល់ជូនសម្រាប់មន្ត្រីរាជការបរទេស ដើម្បីឱ្យផុតពីការជ្រៀតជ្រែកនៅក្នុងជីវិតឯកជនរបស់ពួកគេដែលនឹងអាចបង្កការលំបាកដល់ការបំពេញមុខងារផ្លូវការរបស់ពួកគេ( តាមប្រពៃណី អភ័យឯកសិទ្ធិទាំងនេះត្រូវបានសម្តែងជាមួយនឹងភាសិត ne impediatur legatio ដែលមានន័យថា អភ័យឯកសិទ្ធិទាំងនេះត្រូវបានផ្តល់ឱ្យ ដើម្បីសង្គ្រោះបេសកកម្មផ្លូវការដែលត្រូវរាំងស្ទះនៅក្នុងការងារ)។

ជាការពិតហើយ ក្នុងការលើកលែងខ្វះ អភ័យឯកសិទ្ធិយុត្តាធិការស៊ីវិលគឺចាំបាច់ណាស់ ដើម្បីធានាឯករាជ្យភាពទាំងស្រុងនៅក្នុងការបំពេញបេសកកម្ម ៖ ne impediatur legatio។

ក្នុងចំណោមអភ័យឯកសិទ្ធិការទូតពាក់ព័ន្ធនឹងទ្រព្យសម្បត្តិដូចខាងក្រោម គេសង្កេតឃើញដូចខាងក្រោមនេះ ៖

១- ទីតាំងរបស់ស្ថានបេសកកម្មការទូតបរទេសគឺមិនអាចរំលោភបំពានបានទេ។ ជាផលវិបាក មន្ត្រីរាជការនៃប្រទេសដែលទទួលស្ថានបេសកកម្មមិនអាចចូលក្នុងទីតាំងទាំងនេះដោយគ្មានការយល់ព្រមពីប្រធានបេសកកម្មឡើយ។ តំបន់ដែលមានបេសកកម្មបរទេសតាំងនៅ មិនស្ថិតនៅក្រោមអធិបតេយ្យបរទេសទេ ព្រោះវាមិនមែនជាទឹកដីបរទេសទេ វាគ្រាន់តែជាចំណែកមួយនៃទឹកដីរបស់រដ្ឋក្នុងស្រុក ប៉ុន្តែអង្គភាពប្រតិបត្តិនៃរដ្ឋនេះមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តអំណាចរបស់ពួកគេនៅក្នុងទីតាំងនេះ លើកលែងតែមានការអនុញ្ញាតច្បាស់លាស់ដោយប្រធានបេសកកម្មបរទេស( ដូច្នេះហើយទើប Grotius បាននិយាយថា ស្ថានបេសកកម្មការទូតបរទេសគឺសឹងតែជាទឹកដីមួយបន្ថែម ៖ នេះជាអ្វីដែលគេហៅថា ភាពក្រៅដែនដីរបស់ស្ថានបេសកកម្មមិនមែនមានន័យថា វាស្ថិតនៅលើទឹកដីដែលមិនស្ថិតនៅក្រោមអធិបតេយ្យរបស់រដ្ឋម្ចាស់ផ្ទះទេ។

២- ទ្រព្យសម្បត្តិរបស់ស្ថានបេសកកម្មការទូតគេចផុតពីការឆែកឆេរតាមបង្គាប់តុលាការ កំណែន ការរឹបអូស និងការប្រតិបត្តិគ្រប់បែបយ៉ាង។

៣- កញ្ចប់ការទូត ព្រមទាំងការប្រើប្រាស់សេវាបញ្ជូនសារ និងសារជាកូដបំភ័នអក្ខរៈ និងការទូតមិនអាចត្រូវរំលោភបំពានបានឡើយ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**អភ័យឯកសិទ្ធិបុគ្គលរួមមានដូចខាងក្រោម ៖**

*១- អភ័យឯកសិទ្ធិឃាត់ខ្លួន និងឃុំឃាំងខ្លួន។ ប្រសិនបើភ្នាក់ងារការទូតម្នាក់ប្រព្រឹត្តអំពើឧក្រិដ្ឋកម្មមួយ រដ្ឋម្ចាស់ផ្ទះអាចជូនដំណឹងដល់រដ្ឋបញ្ជូនភ្នាក់ងារថា ជននោះជាបុគ្គលដែលគេមិនស្វាគមន៍(persona non grata) (ដែលជាបុគ្គលដែលមិនទទួលយកបានសម្រាប់រដ្ឋតាំងស្ថានបេសកកម្ម)។ នៅក្នុងករណីបែបនេះ អនុលោមតាមមាត្រា៩នៃអនុសញ្ញាទីក្រុងវីយែន រដ្ឋបញ្ជូនអាចហៅភ្នាក់ងារការទូតនោះមកប្រទេសដើមវិញ ឬបញ្ចប់មុខងារភ្នាក់ងារនោះនៅក្នុងស្ថានបេសកកម្ម ឬប្រសិនបើរដ្ឋនេះបដិសេធមិនព្រម ឬមិនមានប្រតិកម្មតបនៅក្នុងរយៈពេលមួយសមស្រប រដ្ឋម្ចាស់ផ្ទះអាចបដិសេធមិនទទួលស្គាល់បុគ្គលពាក់ព័ន្ធថា ជាសមាជិកនៃស្ថានបេសកកម្មបាន។*

*២- អភ័យឯកសិទ្ធិយុត្តាធិការព្រហ្មទណ្ឌ។*

*៣- អភ័យឯកសិទ្ធិយុត្តាធិការរដ្ឋប្បវេណី និងរដ្ឋបាលរបស់រដ្ឋម្ចាស់ផ្ទះ( ប៉ុន្តែ ច្បាប់ទំនៀម-ទម្លាប់ដូចដែលមានចែងជាក្រមនៅមាត្រា៣១នៃអនុសញ្ញាទីក្រុងវីយែន ចែងថា មិនមានបុព្វសិទ្ធិយុត្តាធិការចំពោះសកម្មភាពពាក់ព័ន្ធនឹង ៖*

- *អគារឯកជនដែលស្ថិតនៅក្នុងរដ្ឋម្ចាស់ផ្ទះ «លើកលែងតែរដ្ឋនេះមានជាកម្មសិទ្ធិក្នុងនាមរដ្ឋតាំងស្ថានបេសកកម្ម ដើម្បីគោលដៅបេសកកម្ម»។*
- *ការស្នងមរតក «ដែលក្នុងនោះ ភ្នាក់ងារការទូតមានតួនាទីជាអ្នកប្រតិបត្តិមរតកសាសន៍ ជាអ្នកគ្រប់គ្រងទាយាទ ឬអ្នកទទួលអច្ច័យទាននៅក្នុងឋានៈឯកជន មិនមែនក្នុងនាមរដ្ឋបញ្ជូនទេ។*
- *«រាល់សកម្មភាពវិជ្ជាជីវៈ ឬពាណិជ្ជកម្មដែលអនុវត្តដោយភ្នាក់ងារការទូតនៅក្នុងរដ្ឋម្ចាស់ផ្ទះនៅក្រៅវិស័យមុខងារផ្លូវការ»។ វាច្បាស់លាស់ណាស់ទាក់ទិនទៅនឹងឧបាស្រ័យបីប្រភេទនេះ ហើយវានឹងមិនមានភាពយុត្តិធម៌ទេដែលអ្នកការទូតរួចផុតពីយុត្តាធិការក្នុងស្រុក ដោយហេតុតែពួកគេអាចប្រព្រឹត្តដោយសេរីបំផុតនូវសកម្មភាព ឬប្រតិបត្តិការដែលមិនពាក់ព័ន្ធនឹងមុខងារការទូតរបស់ពួកគេ។*

*ក្រៅពីនេះ ភ្នាក់ងារការទូតមិនរួចផុតពីនីតិវិធីរដ្ឋបាល ឬរដ្ឋប្បវេណី នៅរៀងរាល់ពេលដែលពួកគេដាក់រឿងក្តីនៅក្នុងសមត្ថកិច្ចតុលាការក្នុងស្រុកដោយស្ម័គ្រចិត្ត បន្ទាប់ពីបានផ្តួចផ្តើមនីតិវិធីនៅមុខតុលាការនេះទេ ដែលដូចនេះភ្នាក់ងារទាំងនេះលះបង់អភ័យឯកសិទ្ធិយុត្តាធិការរបស់ពួកគេ ហើយពួកគេមិនអាចលើកពីអភ័យឯកសិទ្ធិចំពោះបណ្តឹងតបមួយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបណ្តឹងប្រធាន ឬបណ្តឹងឧទ្ធរណ៍មួយទេ។*

*៤- ភាពមិនអាចរំលោភបានទៅលើនិវេសនដ្ឋានឯកជន ឯកសារ លិខិតឆ្លើយឆ្លង និង*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទ្រព្យសម្បត្តិរបស់ភ្នាក់ងារការទូត។

៥- ការលើកលែងពន្ធ និងអាករគ្រប់យ៉ាង ទាំងបាតិបុគ្គល និងភណ្ឌិត ថ្នាក់ជាតិ តំបន់ ឬក្រុង(លើកលែងតែចំពោះពន្ធប្រយោល និងអាករផ្សេងៗដែលមានចែងនៅមាត្រា៣៤ដែលមាន(ក) វិភាគទាន ឬ(ច) នៃអនុសញ្ញាទីក្រុងវីយែន។

ទោះបីជាយ៉ាងនេះក្ដី អភ័យឯកសិទ្ធិខាងលើមិនគ្របដណ្ដប់លើភ្នាក់ងារការទូតដែលមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះ ឬមាននិវេសនដ្ឋានអចិន្ត្រៃយ៍នៅទីនេះទេ(អនុលោមទៅតាមមាត្រា៣៨.១នៃអនុសញ្ញាទីក្រុងវីយែន)។ ហេតុផលនៃការលើកលែងនេះគឺថាពុំនោះទេ ភ្នាក់ងារការទូតនឹងទទួលបានអភ័យឯកសិទ្ធិគ្រប់យ៉ាង និងនឹងឆ្លៀតឱកាសដោយគ្មានការទទួលខុសត្រូវទាំងស្រុង។ ការលើកលែងនេះអនុវត្តចំពោះការបង់ពន្ធ និងអាករនៅក្នុងចំណោមជាតុផ្សេងទៀត។ ភ្នាក់ងារនេះក៏ជាម្ចាស់នៃអភ័យឯកសិទ្ធិយុត្តាធិការព្រហ្មទណ្ឌដែរ។

អភ័យឯកសិទ្ធិបាតិបុគ្គលខុសពីអភ័យឯកសិទ្ធិមុខងារក្នុងទស្សនៈខុសៗគ្នា ៖

១- ខុសពីអភ័យឯកសិទ្ធិមុខងារ អភ័យឯកសិទ្ធិបាតិបុគ្គលគ្របដណ្ដប់លើកិច្ចឯកជន និងប្រតិបត្តិការនានា។

២- អភ័យឯកសិទ្ធិបាតិបុគ្គលមិនមែនជាការលើកលែងពីសិទ្ធិសម្ភាររបស់ប្រទេសម្ចាស់ផ្ទះ ប៉ុន្តែគ្រាន់តែជាការលើកលែងសមត្ថកិច្ចតុលាការ និងការប្រតិបត្តិរបស់ទីភ្នាក់ងារប្រតិបត្តិប៉ុណ្ណោះ។

៣- អភ័យឯកសិទ្ធិបាតិបុគ្គលអនុវត្តរវាងរដ្ឋម្ចាស់ផ្ទះ និងរដ្ឋបញ្ជូន(ព្រមទាំងចំពោះរដ្ឋដែលភ្នាក់ងារការទូតឆ្លងកាត់ដោយចេញពីរដ្ឋម្ចាស់ផ្ទះ)។ ប៉ុន្តែ អភ័យឯកសិទ្ធិដែលតំណាងរដ្ឋបរទេសទទួលបាន សម្រាប់កិច្ចដែលបំពេញនៅក្នុងឋានៈផ្លូវការ គឺមានលក្ខណៈដាច់ខាត(លើកលែងតែជាមួយឧក្រិដ្ឋកម្មអន្តរជាតិ សូមមើលចំណុច៦.៨ខាងក្រោម) និងអាចលើកឡើងបានចំពោះគ្រប់រដ្ឋផ្សេងទៀតដែលជា erga omnes។

៤- អភ័យឯកសិទ្ធិបាតិបុគ្គលចប់នៅពេលបញ្ចប់មុខងារដែរ(ក្នុងពេលដែលអភ័យឯកសិទ្ធិមុខងារគឺមានភាពអចិន្ត្រៃយ៍)។

អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិបាតិបុគ្គលដែលជាធម្មតាអនុវត្តចំពោះភ្នាក់ងារការទូត ក៏ត្រូវអនុវត្តចំពោះសមាជិកគ្រួសាររបស់ភ្នាក់ងារការទូតដែរ ប្រសិនបើពួកគេមិនមែនជាអាណិកជនរបស់រដ្ឋម្ចាស់ផ្ទះទេ។

វិធានទំនៀមទម្លាប់ស្ដីពីឋានៈគតិយុត្តរបស់ភ្នាក់ងារកុងស៊ុលត្រូវបានចងក្រងជាក្រមនៅក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៣។ ភ្នាក់ងារកុងស៊ុលមិនមែនជាប្រេសិតការទូតទេ ៖ ពួកគេមិនទទួលបន្ទុកលើប្រតិបត្តិការរវាងរដ្ឋទាំងពីរទេ។ ពួកគេធ្វើសកម្មភាពដែលមានគោលដៅការពារផលប្រយោជន៍ពាណិជ្ជកម្ម និងផលប្រយោជន៍ផ្សេងទៀត ជាពិសេសជំនួយសម្រាប់អាណិក

*ជននៃរដ្ឋនេះ។*

*(ឧទាហរណ៍ ភ្នាក់ងារកុងស៊ុលអាចផ្តល់ជំនួយ ឬការណែនាំផ្សេងៗដល់អាណិកជនរបស់ខ្លួន នៅពេលពួកគេត្រូវបានឃាត់ខ្លួន ឬឃុំខ្លួននៅក្នុងរដ្ឋម្ចាស់ផ្ទះ តាមរយៈទំនាក់ទំនងជាមួយអ្នកដែលត្រូវឃុំខ្លួនដោយអាជ្ញាធរក្នុងស្រុក-ល-)។ ពួកគេក៏បំពេញមុខងារសារការីសំខាន់ៗផងដែរ (ឧទាហរណ៍ ធ្វើការបញ្ជាក់ ធ្វើនិត្យានុកូលកម្មហត្ថលេខា ធ្វើសច្ចាប្រណិធានដើម្បីធ្វើជាភស្តុតាងនៅក្នុងរឿងក្តីដោយចុះ ឬកត់ត្រាអាពាហ៍ពិពាហ៍ ទទួលបន្ទុកលើធនុះរបស់អាណិកជនរបស់ខ្លួន ធ្វើនិត្យានុកូលកម្មលើស្ទុំកូន ចុះបញ្ជីកំណើត និងមរណភាព-ល-)។*

## ៨- អភ័យឯកសិទ្ធិរបស់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងសមាជិកជាន់ខ្ពស់នៃគណៈរដ្ឋមន្ត្រី

*បន្ថែមពីលើអភ័យឯកសិទ្ធិសម្រាប់កិច្ចផ្លូវការ(អភ័យឯកសិទ្ធិមុខងារ) ប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសដែលបំពេញបេសកកម្មផ្លូវការនៅបរទេសទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ទាំងទាក់ទិនទៅនឹងទីតាំងដែលពួកគេបំពេញប្រតិបត្តិការផ្លូវការ ឬរស់នៅ និងទាំងទាក់ទិនទៅនឹងកិច្ចឯកជនរបស់ពួកគេ។*

*មានភាពខុសគ្នាមួយចំនួននៅក្នុងអក្សរសិល្ប៍គតិយុត្ត ដោយត្រូវដឹងថា តើបុព្វសិទ្ធិដែលលើកឡើងខាងលើ និងអភ័យឯកសិទ្ធិដែលផ្តល់ឱ្យភ្នាក់ងារការទូតអាចត្រូវពន្យារបន្តទាំងមូលនៅក្នុងប្រភេទបុគ្គលទាំងនេះឬទេ។ ទស្សនៈល្អបំផុតគឺថា ការពង្រីកបន្តនេះត្រូវបានទទួលយកដោយច្បាប់អន្តរជាតិ។ យុទ្ធសាស្ត្រក៏បញ្ជាក់អះអាងលើសំណើនេះដែរ។ យុត្តាធិការជាតិបានបង្កើតសេចក្តីសន្និដ្ឋានដោយឈរនៅលើគោលការណ៍មួយដែលស្របទៅនឹងការសន្និដ្ឋានដែលអនុវត្តចំពោះអ្នកការទូតដែលក្នុងនោះមាន* ne impediatur officium *(ភាពចាំបាច់ត្រូវការពារមន្ត្រីជាន់ខ្ពស់បរទេសពីការជ្រៀតជ្រែកក្នុងមុខងារផ្លូវការរបស់ពួកគេ)។*

*នៅទីនេះ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិគឺអាចទាក់ទងទៅនឹងទ្រព្យសម្បត្តិ ឬជាបាតិបុគ្គល និងមានគោលដៅផ្តល់ជម្រកដល់ភ្នាក់ងាររដ្ឋបរទេសប្រឆាំងនឹងរាល់ការជ្រៀតជ្រែកដែលធ្វើឡើងពីសំណាក់រដ្ឋម្ចាស់ផ្ទះនៅក្នុងជីវិតឯកជនរបស់ភ្នាក់ងារនោះដែលនេះនឹងបង្កគ្រោះថ្នាក់ដល់សកម្មភាពរបស់មន្ត្រីនោះ ក្នុងឋានៈជាមន្ត្រីបរទេស។*

*ប៉ុន្តែ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិត្រូវផ្តល់ជូនមន្ត្រីជាន់ខ្ពស់តែមួយចំនួនដែលបំពេញបេសកកម្មផ្លូវការតែប៉ុណ្ណោះ។ ហាក់ដូចជានៅពេលដែលពួកគេបំពេញទស្សនកិច្ចឯកជន និងធ្វើដំណើរដោយសម្ងាត់មិនឱ្យគេស្គាល់អត្តសញ្ញាណ រដ្ឋម្ចាស់ផ្ទះត្រូវផ្តល់ការការពារពិសេសដល់ពួកគេ។*

*យុត្តាធិការជាតិ ព្រមទាំងតុលាការយុត្តិធម៌អន្តរជាតិ(នៅក្នុងដីកាឃាត់ខ្លួន)បានសង្កត់ធ្ងន់ទៅលើគំនិតដែលថាអភ័យឯកសិទ្ធិដែលសំខាន់បំផុតគឺអភ័យឯកសិទ្ធិផ្តន្ទាទោសដោយតុលាការ*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បរទេសមួយ សម្រាប់បទល្មើសនៃនីតិរួម ឬក៏ឧក្រិដ្ឋកម្មអន្តរជាតិ។ ទស្សនៈនេះដែលមានតាំងពីជំនាន់រឿងក្តីល្បីល្បាញ ដូចជា The Schooner Exchange c McFaddon, de 1812 (à 137), ត្រូវបានបញ្ជាក់ច្រើនលើកដោយយុត្តិសាស្ត្រ។ យុត្តិកម្មនៃការលើកលែងយុត្តាធិការព្រហ្មទណ្ឌរបស់តុលាការបរទេសគឺមានទ្វេ ៖

ដំបូង ដូចដែលតុលាការអាមេរិកមួយបានលើកឡើងនៅក្នុងរឿងក្តីរវាង Gladys M. Lafontant និង Jean-Bertrand Aristide «អភ័យឯកសិទ្ធិរបស់ប្រមុខរដ្ឋដូចជាអភ័យឯកសិទ្ធិអធិបតេយ្យបរទេសមានមូលដ្ឋាននៅលើគំនិតដែលថា រដ្ឋ និងអ្នកដឹកនាំគឺព្រមព្រៀងចំពោះការអនុវត្តអភ័យឯកសិទ្ធិ»។

ទីពីរ គំនិតដែលថា រដ្ឋទាំងអស់ស្មើគ្នាជាមួយនឹងផលវិបាកដែលថា គ្មានរដ្ឋណាមួយអាច «អនុវត្តអំណាចតុលាការលើរដ្ឋមួយទៀតបាន»(រឿងក្តីខាងលើ)។ ប្រហែលជាសម្រាប់ប្រមុខរដ្ឋគឺមានហេតុផលដែលថា ការនាំប្រមុខរដ្ឋទៅសវនាការនៅក្នុងតុលាការបរទេសមួយនឹងនាំឱ្យមានការរំខានដល់ជីវិតនយោបាយរបស់រដ្ឋ និងប៉ះពាល់ដល់កិត្តិនាមអន្តរជាតិរបស់រដ្ឋ។

ចំណែកឯរដ្ឋមន្ត្រីការបរទេសវិញ អភ័យឯកសិទ្ធិរបស់ពួកគេត្រូវបានអះអាងបញ្ជាក់នៅក្នុងកិច្ចការជាតិ។ ជាឧទាហរណ៍ រដ្ឋមន្ត្រីការបរទេសសាំងម៉ារ៉ាំងលែងអាចទទួលបាននូវអភ័យឯកសិទ្ធិយុត្តាធិការសម្រាប់កិច្ចដែលបានបំពេញជាលក្ខណៈឯកជន បន្ទាប់ពីបានចាកចេញពីអាណត្តិនិងសាលដីកាតុលាការយុត្តិធម៌អន្តរជាតិស្តីពីអំណាចនៅក្នុងដីកាឃាត់ខ្លួន(កថាខណ្ឌ៥៣-៦១)។

## ៥- រយៈពេលនៃបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

អភ័យឯកសិទ្ធិមុខងារមិនចប់ជាមួយនឹងការចប់នៃមុខងារដែលបានប្រគល់ជូនភ្នាក់ងាររដ្ឋទេ ហើយនេះក៏ជាអ្វីដែលត្រូវបានអះអាងបញ្ជាក់ដោយយុត្តាធិការដែរ។

ប៉ុន្តែ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិបាតិបុគ្គលចប់ជាមួយនឹងការបញ្ចប់បេសកកម្ម។

នៅឆ្នាំ១៩២៥ តុលាការមួយនៅក្រុងប៉ារីសបានកំណត់និយមន័យអំពីការផ្តល់ហេតុផលនៅពីក្រោយនិយ័តកម្មអន្តរជាតិនេះ នៅក្នុងរឿងក្តី Laperdrix et Penquer v Kouzoubojf et Belin ដូចតទៅនេះ ៖ «គោលការណ៍អភ័យឯកសិទ្ធិការទូតត្រូវបានបង្កើតឡើង សម្រាប់ជាផលប្រយោជន៍របស់រដ្ឋាភិបាល មិនមែនជាផលប្រយោជន៍សម្រាប់អ្នកការទូតទេ ហើយអភ័យឯក-សិទ្ធិមិនអាចអនុវត្តឱ្យហួសពីបេសកកម្ម[ការទូត]ដែរ...។ យោបល់ផ្ទុយពីនេះនឹងបង្កើតអាជ្ញាយុកាលមួយប្រភេទ និងភាពមិនទទួលខុសត្រូវគ្មានដែនកំណត់ ជាប្រយោជន៍ដល់ភ្នាក់ងារការទូត។

ដូច្នេះ ជាឧទាហរណ៍ ប្រសិនបើឯកអគ្គរដ្ឋទូតម្នាក់ប្រព្រឹត្តឧក្រិដ្ឋកម្មធម្មតា ដូចជាធ្វើឃាតករិយាខ្លួននៅក្នុងរដ្ឋម្ចាស់ផ្ទះដែលជារដ្ឋដែលឯកអគ្គរដ្ឋទូតនោះត្រូវចាត់តាំងឱ្យបំពេញបេសក-

*កម្ម គាត់នឹងត្រូវរួចផុតពីយុត្តាធិការព្រហ្មទណ្ឌ ប៉ុន្តែប្រសិនបើគាត់ត្រលប់មកប្រទេសនេះវិញ បន្ទាប់ពីបានបោះបង់តំណែងការទូតរបស់គាត់ គាត់អាចត្រូវគេឃាត់ខ្លួន និងបញ្ជូនទៅកាត់ក្តីនៅតុលាការបាន។*

*ប៉ុន្តែ ការចប់អភ័យឯកសិទ្ធិមិនកើតឡើងដំណាលគ្នានឹងការបញ្ចប់មុខងាររបស់អ្នកការទូតម្នាក់នៅក្នុងរដ្ឋម្ចាស់ផ្ទះទេ។ ដូចដែលរដ្ឋមន្ត្រីការបរទេសអាមេរិកបានប្រកាសនៅឆ្នាំ១៩០៨ នៅក្នុងកំណត់ទូតមួយជូនចំពោះស្ថានទូតប្រេស៊ីលប្រចាំនៅសហរដ្ឋអាមេរិក «អភ័យឯកសិទ្ធិការទូតដែលជាប់ជាមួយនឹងបុគ្គលនៃភ្នាក់ងារការទូតមានវិសាលភាពនៅក្នុងរយៈពេលសមស្របមួយបន្ទាប់ពីចប់មុខងារការទូត ដើម្បីឱ្យពួកគេអាចបំពេញបទប្បញ្ញត្តិផ្សេងៗដើម្បីចាកចេញពីប្រទេសបាន។ សំណើនេះត្រូវអះអាងបញ្ជាក់ដោយយុត្តិសាស្ត្រ(jurisprudence) និងត្រូវបានចងក្រងជាក្រមនៅមាត្រា៣៩.២នៃអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតដែលនៅក្នុងនោះបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ(ចប់នៅពេលដែល[អ្នកការទូត]ចាកចេញពីប្រទេស ឬនៅពេលផុតរយៈពេលសមស្របសម្រាប់ការចាកចេញ ប៉ុន្តែអភ័យឯកសិទ្ធិនៅតែបន្តមាន ទាំងនៅក្នុងករណីជម្លោះប្រដាប់អាវុធក៏ដោយ»។ លើសពីនេះទៅទៀត ភ្នាក់ងារការទូតទទួលបានអភ័យឯកសិទ្ធិនៅលើទឹកដីរបស់រដ្ឋទីបី នៅពេលដែលភ្នាក់ងារនេះធ្វើដំណើរត្រលប់ទៅប្រទេសដើមវិញ(សូមមើលមាត្រា៤០.១នៃអនុសញ្ញាទីក្រុងវីយែន)។*

## ១០- អភ័យឯកសិទ្ធិ និងឧក្រិដ្ឋកម្មអន្តរជាតិ

*អភ័យឯកសិទ្ធិបាតិបុគ្គលការពារភ្នាក់ងាររដ្ឋទាំងអស់ដែលត្រូវទទួលការផ្តន្ទាទោសសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ ចំណែកភ្នាក់ងាររដ្ឋគឺនៅតែរក្សាមុខងារដដែល។ តុលាការអេស្ប៉ាញ បារាំង និងបែលហ្ស៊ិកបានប្រកាសយ៉ាងច្បាស់ពីសញ្ញាណនេះដែលមានដូចជាហ្វីដែល កាស្ត្រូ(ហេតុផលគតិយុត្ត១-២) កាដាហ្វី(២១៨-១៩) និងស្យារ៉ុន(en 3)។*

*ប៉ុន្តែ នៅពេលដែលពួកគេចាកចេញពីមុខងារ ភ្នាក់ងាររដ្ឋដែលមានពោលនៅខាងលើបាត់បង់អភ័យឯកសិទ្ធិបាតិបុគ្គល។ ជាផលវិបាក ពួកគេអាចត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មអន្តរ-ជាតិដែលពួកគេបានប្រព្រឹត្តនៅក្នុងអាណត្តិ ឬមុនអាណត្តិរបស់ពួកគេ។ សំណើនេះត្រូវបានគាំទ្រដោយយុត្តិសាស្ត្រ(ជាឧទាហរណ៍ សូមមើលករណី Pinochet, Bouterse, Hissène Habré) និងការប្រកាសរបស់រដ្ឋ។*

*ប៉ុន្តែករណីខ្លះហាក់ដូចជានិយាយផ្ទុយពីនិន្នាការយុត្តិសាស្ត្រ។ នៅក្នុងសេចក្តីសម្រេចយ៉ាងហោចណាស់ចំនួនពីរស្តីពីអតីតប្រមុខរដ្ឋ តុលាការអាមេរិកប្រកាន់ជំហរថា ពួកគេមានសមត្ថកិច្ចទៅលើអតីតប្រមុខរដ្ឋទាំងនោះ ព្រោះរដ្ឋរបស់ប្រមុខរដ្ឋទាំងនោះបានលះបង់ចោលអភ័យឯក-*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិទ្ធិ ៖ សូមមើលនៅក្នុងកិច្ចពិភាក្សាធំរបស់អង្គចៅក្រម( ស្តីពីអតីតប្រធានាធិបតីហ្វីលីពីន ម៉ាកូស ដែលតាមច្បាប់រដ្ឋប្បវេណីជាអ្នកទទួលខុសត្រូវដោយមិនបានគោរពរបាយការណ៍ subpoenas របស់អង្គចៅក្រមកាត់សេចក្តី) និងរឿងក្តី Paul c Avril ( ស្តីពីអតីតមេដឹកនាំយោធាប្រទេសហៃទី ដែលគេផ្តន្ទាទោសដោយត្រូវចោទប្រកាន់ថាបានរំលោភសិទ្ធិមនុស្ស)។

លើសពីនេះទៅទៀត យោងតាមតុលាការយុត្តិធម៌អន្តរជាតិនៅក្នុងដីកាឃាត់ខ្លួន សំណើខាងលើមានន័យតែសម្រាប់កិច្ចដែលត្រូវបំពេញដោយអតីតរដ្ឋមន្ត្រីការបរទេស( ហើយយើងអាចគិតថា អាចជាអតីតប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល) «នៅក្នុងកម្រិតឯកជន»( កថាខណ្ឌ៦១)។ ការចូលរួមរបស់តុលាការពិតជាអាចពិភាក្សាបាន ពីព្រោះមិនអាចនឹងទៅរួចទេដែលភ្នាក់ងារជាន់ខ្ពស់របស់រដ្ឋម្នាក់អាចប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ដូចជាឧក្រិដ្ឋកម្មសង្គ្រាម ទារុណកម្មឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ភេរវកម្ម ឬប្រល័យពូជសាសន៍ «ក្នុងកម្រិតឯកជននោះ»។ ផ្ទុយទៅវិញ នៅក្នុងការប្រតិបត្តិដែលមានការបញ្ជា ឬមានការធានាដល់ការប្រព្រឹត្តអំពើទាំងនេះ ភ្នាក់ងារជាន់ខ្ពស់របស់រដ្ឋម្នាក់បំពេញតួនាទីអនុវត្តមុខងារសាធារណៈរបស់ខ្លួន។ ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងជាឯកជន អាចអនុម័តជាបទល្មើសបាតិបុគ្គល ដូចជាសម្លាប់ភរិយាខ្លួនឯង( ឬស្វាមី) ការលួចនៅក្នុងហាងមួយ ឬការវាយអ្នកបម្រើម្នាក់-ល-។

ភ្នាក់ងាររបស់រដ្ឋដែលមិនទទួលបានអភ័យឯកសិទ្ធិបាតិបុគ្គល ដោយអនុលោមទៅតាមច្បាប់អន្តរជាតិទំនៀមទម្លាប់( ឧទាហរណ៍រដ្ឋមន្ត្រីការពារជាតិ នគរបាល ទោះជាពួកគេជាមន្ត្រីយោធា ឬមិនមែនក៏ដោយ-ល-) អាចត្រូវផ្តន្ទាទោសនៅគ្រប់ពេលវេលា ទោះបីកំពុងបំពេញមុខងារជានិច្ចក៏ដោយ។ សំណើនេះត្រូវបានគាំទ្រដោយយុត្តិសាស្ត្រ។

## ១១- ការកំណត់ព្រំដែនទៅលើប្រព្រឹត្តកម្មស្ថានភាពជនបរទេស និងបុគ្គល

អស់រយៈពេលដ៏យូរ វិធានទំនៀមទម្លាប់ និងបទប្បញ្ញត្តិនៃសន្ធិសញ្ញាស្តីពីប្រព្រឹត្តកម្មដែលត្រូវផ្តល់ឱ្យជនបរទេសបានដាក់ជាឧបសគ្គចម្បងមួយដល់អធិបតេយ្យរបស់រដ្ឋ។ ទោះបីជាជនបរទេសត្រូវបានដាក់ឱ្យស្ថិតនៅក្រោមអធិបតេយ្យទឹកដីរបស់រដ្ឋម្ចាស់ផ្ទះ និងត្រូវគោរពតាមច្បាប់ និងបទបញ្ជារបស់រដ្ឋនេះក្តី ជនបរទេសទាំងនេះក៏ទទួលបានសិទ្ធិមួយចំនួនដែលមានចែងដោយវិធានអន្តរជាតិដែលផ្តល់សិទ្ធិអន្តរជាតិរបស់រដ្ឋពួកគេ។ វិធានអន្តរជាតិមានគោលដៅការពារជីវិត បុគ្គល និងទ្រព្យសម្បត្តិរបស់ជនបរទេស។ តុលាការជាតិ និងអន្តរជាតិបានវិនិច្ឆ័យថា ជនបរទេសមិនអាចស្ថិតនៅក្រោមប្រព្រឹត្តកម្មដោយគ្មានហេតុផល និងជាពិសេសមិនអាចត្រូវបង្អត់ពីទ្រព្យសម្បត្តិរបស់ពួកគេដោយគ្មានការផ្តល់សំណងប៉ះប៉ូវប្រកបដោយសមធម៌ ហើយក៏មិនអាចដាក់ឱ្យស្ថិតនៅចំណុះមណ្ឌលយោធាបានដែរ-ល-។

# ជំពូក៤
# អង្គការអន្តរជាតិ

## ផ្នែកទី១
## ការបង្កើតអង្គការអន្តរជាតិ

អង្គការអន្តរជាតិ[៧៩]គឺជាប្រធានលំដាប់ទីពីរ ឬប្រធានក្លាយនៃច្បាប់អន្តរជាតិធៀបទៅនឹងប្រធានទី១(រដ្ឋ)។ រដ្ឋសម្រេចបង្កើតអង្គការអន្តរជាតិមួយដោយអនុម័តកិច្ចបង្កើតអង្គការមួយ។

កិច្ចបង្កើតអង្គការ[៨០]គឺជាសន្ធិសញ្ញាពហុភាគីដែលចុះហត្ថលេខាដោយរដ្ឋសមាជិក។ នៅក្នុងកិច្ចនេះ រដ្ឋបង្ហាញការឯកភាពរបស់ខ្លួនក្នុងការចូលរួមជាមួយអង្គការ និងឆន្ទៈបង្កើតបុគ្គលគតិយុត្តថ្មីមួយ។ កិច្ចបង្កើតអង្គការរៀបចំដំណើរប្រព្រឹត្តតាមការបង្កើតអង្គភាពនានា ធ្វើការកំណត់សមត្ថកិច្ច និងអំណាចរបស់ខ្លួន និងរៀបចំវិធានកំណត់ទំនាក់ទំនងរវាងសមាជិក និងអង្គភាពទាំងនោះ។ ប៉ុន្តែ រដ្ឋជាច្រើនខ្លាចរអានឹងទទួលយកថា អាចនឹងមានប្រភពច្បាប់អនុវត្តផ្សេងទៀតសម្រាប់អង្គការនៅខាងក្រៅប្រភពច្បាប់ដែលចែងដោយធម្មនុញ្ញបង្កើតអង្គការ។

អង្គការអន្តរជាតិមានសណ្ឋានខុសៗគ្នាខ្លាំង។ ក្នុងនោះ គេបែងចែកជា៖

- អង្គការដែលមានគោលដៅសកល សម្រាប់ទទួលរដ្ឋទាំងអស់ ប្រសិនបើរដ្ឋទាំងនោះបំពេញលក្ខខណ្ឌធ្វើជាសមាជិក(អង្គការសហប្រជាជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិ អង្គការពាណិជ្ជកម្មពិភពលោក)។
- អង្គការដែលមានគោលដៅតំបន់ បើកទូលាយដល់រដ្ឋក្នុងទ្វីប និងឧបទ្វីប(ក្រុមប្រឹក្សាអឺរ៉ុប សហភាពអឺរ៉ុប អាស៊ាន)។

យោងទៅតាមវិស័យសកម្មភាព យើងក៏អាចធ្វើការបែងចែកជា៖

- អង្គការអន្តរជាតិដែលមានសមត្ថកិច្ចទូទៅ ជាអាទិ៍អង្គការសហប្រជាជាតិ។

---

[៧៩] អង្គការអន្តរជាតិប្រាកដខ្លួនឡើងនាសតវត្សទី១៩ ក្នុងនាមជាគណៈកម្មការមជ្ឈិមប្រចាំ *Rhin* ដែលបង្កើតនាឆ្នាំ១៨១៥ ដើម្បីចាត់វិធានលើនាវាចរណ៍តាមទន្លេ។

[៨០] ធម្មនុញ្ញអង្គការសហប្រជាជាតិឆ្នាំ១៩៤៥ លក្ខន្តិកៈរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ(១៩៤៥) រដ្ឋធម្មនុញ្ញរបស់ OIT (១៩៤៦)

• អង្គការអន្តរជាតិដែលមានសមត្ថកិច្ចឯកទេស ដូចជាអង្គការអូតង់ អង្គការសុខភាពពិភព-លោក អង្គការពាណិជ្ជកម្មពិភពលោក...

យោងទៅតាមប្រភេទកម្មវត្ថុ គេបែងចែកដូចតទៅ ៖

• អង្គការសហប្រតិបត្តិការដែលអនុគ្រោះដល់សហប្រតិបត្តិការអន្តររដ្ឋាភិបាល

• អង្គការសមាហរណកម្ម ពោលគឺរដ្ឋទាំងអស់ផ្ទេរសមត្ថកិច្ចខ្លះជូនអង្គការណាដែលធ្វើការជំនួសខ្លួនក្នុងវិស័យទាំងនេះ។

## ១- សមាជិកភាពរបស់អង្គការអន្តរជាតិ

សមាជិកអង្គការអន្តរជាតិភាគច្រើនគឺជារដ្ឋ។ ប៉ុន្តែ អង្គការនោះបើកទូលាយផងដែរដល់អង្គភាពពុំមែនរដ្ឋ។ ឧទាហរណ៍ អង្គការពាណិជ្ជកម្មពិភពលោកទទួលសហគមន៍អឺរ៉ុប និងតៃវ៉ាន់។ អង្គការមិនមែនរដ្ឋាភិបាល(ONG) និងអង្គការអន្តររដ្ឋាភិបាលគឺជាអ្នកអង្កេតការទៅលើអង្គការអន្តរជាតិមួយចំនួន។

សមាជិកដើមពុំនៅចំណុះលក្ខខណ្ឌណាមួយឡើយ។ ប៉ុន្តែ សមាជិកចូលរួមត្រូវបំពេញលក្ខខណ្ឌខ្លះ ដូចជាការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាបង្កើតអង្គការ។ ការទទួលបានសមាជិកភាពប្រព្រឹត្តទៅតាមនីតិវិធីចូលជាសមាជិក។ ឧទាហណ៍ ដើម្បីក្លាយជាសមាជិកអង្គការសហ-ប្រជាជាតិ រដ្ឋនោះត្រូវជារដ្ឋមានសន្តិភាព ព្រមទទួលកាតព្វកិច្ចចែងក្នុងធម្មនុញ្ញ មានសមត្ថភាព និងប្តេជ្ញាបំពេញកាតព្វកិច្ចទាំងនោះ(មាត្រា៤ កថាខណ្ឌ១នៃធម្មនុញ្ញ)។

ការបាត់បង់សមាជិកភាពអាចកើតឡើងតាមការដកខ្លួន ឬការបណ្តេញចេញ។ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិបានចែងពីការបណ្តេញចេញដែលសម្រេចដោយមហាសន្និបាតផ្អែកទៅតាមអនុសាសន៍របស់ក្រុមប្រឹក្សាសន្តិសុខ។ ប៉ុន្តែ អង្គការសហប្រជាជាតិចូលចិត្តប្រើប្រាស់វិធីលើកទឹកចិត្ត ឬព្យួរសិទ្ធិជាង(មាត្រា៥ និង១៩នៃធម្មនុញ្ញ)។

## ២- សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក

រដ្ឋសមាជិកទទួលសិទ្ធិ និងកាតព្វកិច្ចមួយចំនួន។

### ២.១- សិទ្ធិ

រដ្ឋសមាជិកមានសិទ្ធិមានអាសនៈនៅក្នុងអង្គភាព និងមានសិទ្ធិបោះឆ្នោត។ យើងឃើញមានអង្គភាពពេញអង្គ និងអង្គភាពមានកំហិត។

• **អង្គភាពពេញអង្គ** ៖ រដ្ឋទាំងអស់ត្រូវបានតំណាងក្នុងអង្គភាពពេញអង្គ។ មហាសន្និបាត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រមូលផ្តុំតំណាងរដ្ឋាភិបាលរបស់សមាជិកទាំងអស់។ មហាសន្និបាតអង្គការសហប្រជាជាតិ ឬ សន្និសីទថ្នាក់ក្រសួងរបស់អង្គការពាណិជ្ជកម្មពិភពលោកទទួលបន្ទុកផ្តល់ការជំរុញ និងតម្រង់ទិសចម្បងនៃនយោបាយរបស់អង្គការ។

• **អង្គភាពមានកំហិត** ៖ អង្គភាពនេះមានសមាជិកមួយចំនួន ហើយធ្វើការប្រជុំនៅក្នុងអំឡុងពេលទៀងទាត់ និងមានអំណាចសម្រេច។ ឧទាហរណ៍ ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ឬក្រុមប្រឹក្សាភិបាលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។

រដ្ឋសមាជិកមានសិទ្ធិបោះឆ្នោត។ វិធានដែលថា រដ្ឋមួយគឺសំឡេងមួយគោរពបានល្អប្រសើរនូវសមភាពអធិបតេយ្យភាពរបស់រដ្ឋ។ ប៉ុន្តែ ប្រព័ន្ធសមភាពសំឡេងត្រូវបានប្រើប្រាស់នៅក្នុងអង្គការមួយចំនួន ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ។

ចំពោះការអនុម័តសេចក្តីសម្រេច បែបបទខាងក្រោមត្រូវបានយកមកប្រើប្រាស់ដូចជា ៖

- ឯកច្ឆន្ទភាពតម្រូវឱ្យមានការព្រមព្រៀងពីសមាជិកទាំងអស់ ប៉ុន្តែអាចបណ្តាលឱ្យមានភាពពាំងស្ទះ។
- សំឡេងភាគច្រើនអនុញ្ញាតឱ្យអង្គការធ្វើការសម្រេចចិត្ត។
- សំឡេងភាគច្រើនប្រកបដោយគុណវុឌ្ឍន៍ធានាដល់ភាពតំណាងនៅក្នុងការធ្វើសេចក្តីសម្រេច។
- កុងសង់ស៊ីសពុំតម្រូវឱ្យមានការបោះឆ្នោត ហើយគ្រប់គ្នាយល់ព្រម។

## ២.២- កាតព្វកិច្ច

រដ្ឋសមាជិកមានកាតព្វកិច្ចចូលរួមសម្រេចគោលដៅ គោរពគោលការណ៍ និងវិធាននានា ចូលរួមចំណែកដល់ថវិកាអង្គការ និងចាត់វិធានការធានាការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

## ៣- អង្គការអន្តរជាតិក្នុងនាមជាប្រធាននៃច្បាប់អន្តរជាតិ

អាស្រ័យដោយអង្គការអន្តរជាតិគឺជាប្រធានក្លាយនៃច្បាប់អន្តរជាតិ គឺរដ្ឋទាំងអស់ជាអ្នកផ្តល់បុគ្គលភាពគតិយុត្ត និងសមត្ថកិច្ចដល់អង្គការទាំងនោះ។

## ៣.១- បុគ្គលភាពគតិយុត្ត

អស់កាលដ៏យូរលង់ លទ្ធិបានចាត់ទុកថា មានតែរដ្ឋទាំងអស់ប៉ុណ្ណោះដែលអាចជាប្រធាននៃច្បាប់អន្តរជាតិ។ ក្រោយមក លទ្ធិបានផ្តាច់អធិបតេយ្យភាព និងបុគ្គលភាពគតិយុត្ត។ អាស្រ័យដោយអង្គការអន្តរជាតិមានបុគ្គលភាពគតិយុត្តអន្តរជាតិ អង្គការទាំងនោះជាកម្មសិទ្ធិករនៃសិទ្ធិ

*និងកាតព្វកិច្ចក្នុងសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ។ បុគ្គលភាពគតិយុត្តរបស់អង្គការសហប្រជាជាតិ អាចនឹងត្រូវរដ្ឋទាំងអស់ជំទាស់ ទាំងរដ្ឋសមាជិក ឬនិងរដ្ឋមិនមែនសមាជិក។[៨១] ប៉ុន្តែបុគ្គលភាព នេះមានជាបុគ្គលភាពមុខងារ ហើយកំហិតដោយគោលការណ៍ឯកទេស។[៨២]*

*អង្គការអន្តរជាតិក៏មានផងដែរនូវបុគ្គលភាពគតិយុត្តក្នុងលំដាប់គតិយុត្តរបស់រដ្ឋដែល ទទួលអង្គការនោះ។ បុគ្គលភាពគតិយុត្តផ្ទៃក្នុងអនុញ្ញាតដល់អង្គការអន្តរជាតិឱ្យធ្វើកិច្ចសន្យាទិញ និងលក់ចលនៈទ្រព្យ និងអចលនៈទ្រព្យ និងប្តឹងទៅតុលាការបាន។*

*អង្គការអន្តរជាតិបង្កើតច្បាប់ គឺច្បាប់ក្លាយតាមរយៈការអនុម័តនូវកិច្ច ដំណោះស្រាយ អនុ-សាសន៍ សេចក្តីសម្រេចដែលត្រូវស្រុបទៅតាមកិច្ចបង្កើតអង្គការ។*

## ៣.២- សមត្ថកិច្ច

*ខណៈពេលរដ្ឋមានសមត្ថកិច្ចទូទៅ អង្គការអន្តរជាតិមានត្រឹមតែសមត្ថកិច្ចដែលផ្តល់ដោយ កិច្ចបង្កើតអង្គការប៉ុណ្ណោះដោយអនុលោមទៅតាមគោលការណ៍ឯកទេស។*

*ប៉ុន្តែ យុត្តិសាស្ត្របានពង្រីកសមត្ថកិច្ចទាំងនេះតាមទ្រឹស្តីសមត្ថកិច្ចមិនចំពោះ។[៨៣] អាស្រ័យ ហេតុនេះ អង្គការអន្តរជាតិអនុវត្តសមត្ថកិច្ចរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព និងពុំបិតក្រោម ខ្ទឹមសារតឹងរឹងនៃកិច្ចបង្កើតអង្គការទេ។ ប៉ុន្តែ ទ្រឹស្តីសមត្ថកិច្ចមិនចំពោះត្រូវអនុវត្តក្នុងដែនកំណត់ នៃគោលការណ៍ឯកទេស។*

## សមត្ថកិច្ចរបស់អង្គការអន្តរជាតិ

*ប៉ុន្តែ រដ្ឋជាច្រើនខ្លាចរអានឹងទទួលស្គាល់ថា អាចនឹងមានប្រភពច្បាប់អនុវត្តផ្សេងទៀត សម្រាប់អង្គការ ក្រៅពីប្រភពច្បាប់ដែលចែងដោយធម្មនុញ្ញបង្កើតអង្គការ។*

*នីតិអន្តរជាតិទូទៅផ្សារភ្ជាប់ការទទួលបានសមត្ថភាព និងសមត្ថកិច្ចដែលបង្កើតឡើងជា មុន ទៅនឹងកម្មសិទ្ធិបុគ្គលភាពគតិយុត្តអន្តរជាតិ។ ការបែងចែកសមត្ថកិច្ចធ្វើឡើងដោយធៀប ទៅនឹងកម្មវត្ថុ និងគោលដៅរបស់អង្គការអន្តរជាតិ។*

---

*[៨១] តុលាការយុត្តិធម៌អន្តរជាតិ ក្នុងសំណុំរឿងសងសំណងដល់អង្គការសហប្រជាជាតិ។ សេចក្តីជូនដំណឹងចុះថ្ងៃទី១១ មេសា ១៩៤៩។*

*[៨២] អង្គការមានបុគ្គលភាពអន្តរជាតិមានព្រំដែន សម្រាប់សម្រេចកម្មវត្ថុ និងគោលបំណងដែលមានចែងក្នុងកិច្ចផ្សំរបស់ខ្លួន។*

*[៨៣] ក្នុងសេចក្តីជូនដំណឹងឆ្នាំ១៩៤៩ តុលាការយុត្តិធម៌អន្តរជាតិបញ្ជាក់ថា ៖ «យោងតាមនីតិអន្តរជាតិ អង្គការត្រូវបានចាត់ទុកថា មានអំណាចទាំងនេះ[ក្នុងការការពារភ្នាក់ងាររបស់ខ្លួន និងធ្វើការទាមទារលក្ខណៈអន្តរជាតិ] ដែលផ្តល់ជូនអង្គការក្នុងនាម ជាធាតុសំខាន់ក្នុងការអនុវត្តមុខងារទាំងនេះ ទោះបីអំណាចនេះពុំបង្ហាញច្បាស់ក្នុងធម្មនុញ្ញតាមវិបាកសំខាន់ក្តី» (កម្រង ឆ្នាំ១៩៤៩ ទំព័រ១៨២)។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤- សមត្ថកិច្ចប្រកាស និងសមត្ថកិច្ចមិនចំពោះ

*សមត្ថកិច្ចរបស់អង្គការអន្តរជាតិ មិនថាជាសមត្ថកិច្ចធម្មនិយាម រដ្ឋបាល ឬយុត្តាធិការទេ ត្រូវបានផ្តល់ច្បាស់ក្រឡែត ឬដោយមិនចំពោះដល់អង្គការ ដោយសន្ធិសញ្ញាដែលបង្កើតអង្គការនោះ។ ប៉ុន្តែ គោលការណ៍មួយចំនួនគ្រប់គ្រងសមត្ថកិច្ចរបស់អង្គការអន្តរជាតិ គឺ ៖*

- *គោលការណ៍ឯកទេស*
- *គោលការណ៍បន្ទាប់បន្សំ*
- *គោលការណ៍ផ្តល់សមត្ថកិច្ច*

### ៤.១- គោលការណ៍ឯកទេស

*គោលការណ៍នេះមានន័យថា អង្គការអន្តរជាតិគឺជាប្រធានក្លាយនៃនីតិអន្តរជាតិដែលបង្កើតឡើងដើម្បីសម្រេចកម្មវត្ថុដែលកំណត់ដោយឡែកដោយរដ្ឋសមាជិក និងថាគឺការសម្រេចកម្មវត្ថុទាំងនេះដែលកំណត់វិសាលភាពរបស់សមត្ថកិច្ចរបស់រដ្ឋទាំងនោះ( យោបល់ពិគ្រោះរបស់តុលាការយុត្តិធម៌អន្តរជាតិចុះថ្ងៃទី០៨ កក្កដា ១៩៩៦)។*

### ៤.២- គោលការណ៍ផ្តល់សមត្ថកិច្ចដល់អង្គការមូលដ្ឋាន( Subsidiarité )

*គោលការណ៍នេះមានន័យថា អង្គការអន្តរជាតិអន្តរាគមន៍តែនៅពេលកម្មវត្ថុនៃសកម្មភាពគ្រោងទុកពុំអាចសម្រេចបានគ្រប់គ្រាន់ពីសំណាក់រដ្ឋសមាជិក ហើយអាចនឹងសម្រេចបានល្អប្រសើរដោយអង្គការ អាស្រ័យដោយទំហំ ឬអានុភាពរបស់សកម្មភាពគ្រោង។ ( មាត្រា៥នៃសន្ធិសញ្ញាស្តីពីសហគមន៍អឺរ៉ុប)។ បើអង្គការអាចបំពេញការងារបានល្អជាង ត្រូវតែផ្តល់សមត្ថកិច្ចនេះដល់អង្គការដែលពាក់ព័ន្ធដោយផ្ទាល់នឹងសកម្មភាពនេះ។*

### ៤.៣- គោលការណ៍ផ្តល់សមត្ថកិច្ច

*ខុសពីរដ្ឋ អង្គការអន្តរជាតិពុំមានសមត្ថកិច្ចឥតព្រំដែនទេ ប៉ុន្តែមានសមត្ថកិច្ចសាមញ្ញតាមការផ្តល់ឱ្យ មានន័យថា គ្រប់សកម្មភាពអាច ហើយត្រូវពង្រីកដល់ផ្នែកមួយចំនួនដែលកំណត់ដោយរឹតត្បិតដោយសន្ធិសញ្ញាបង្កើតអង្គការនោះតែប៉ុណ្ណោះ។*

*ប៉ុន្តែ ប្រសិនបើសមត្ថកិច្ចកំណត់ជាក់ច្បាស់ទាំងនេះចាំបាច់ដល់អង្គការក្នុងការអនុវត្តអត្ថបទដែលត្រូវបានចងជាក្រម រាល់អង្គការអន្តរជាតិក៏អាចសម្រេចផងដែរនូវកម្មវត្ថុ និងគោលដៅរបស់សន្ធិសញ្ញា ករណីមានតុណ្ហីភាពរបស់សន្ធិសញ្ញា តាមរយៈសមត្ថកិច្ចមិនចំពោះ( មិនមែនលាយល័ក្ខអក្សរ)។*

## ៥- សមត្ថកិច្ចមិនចំពោះ

*ទ្រឹស្តីនេះបង្កើតឡើងជាលើកដំបូងដោយយុត្តិសាស្រ្តធម្មនុញ្ញរបស់តុលាការកំពូលសហរដ្ឋអាមេរិកនៅក្នុងសំណុំរឿងGIBBSONC/OGDEN។*

*ក្នុងរឿងនេះ ចៅក្រមធម្មនុញ្ញអាមេរិកទទួលស្គាល់ទៅលើអត្ថិភាពនៃសមត្ថកិច្ច និងធម្មនុញ្ញភាពទាំងនេះ ដោយបញ្ជាក់ថា ប្រសិនបើគ្រប់គោលដៅមានលក្ខណៈស្របច្បាប់ទោះក្នុងដែនធម្មនុញ្ញក្តី ពល់មធ្យោបាយដែលសមស្របសម្រាប់គោលដៅទាំងនោះដែលពុំមានការហាមប្រាមនិងដែលមានសមិតភាពជាមួយខ្លឹមសារ និងស្មារតីធម្មនុញ្ញ ត្រូវមានលក្ខណៈធម្មនុញ្ញ។*

***ប៉ុន្តែ តុលាការទទួលស្គាល់អត្ថិភាពនៃសមត្ថកិច្ចមិនចំពោះសម្រាប់អង្គការអន្តរជាតិ។***

*ធម្មនុញ្ញសហប្រជាជាតិពុំបានផ្តល់យ៉ាងច្បាស់នូវសិទ្ធិរាប់បញ្ចូលសំណើសំណងខូចខាតទៅលើជនរងគ្រោះ និងចារីឱ្យអង្គការទេ។ តុលាការយុត្តិធម៌អន្តរជាតិចោទជាសំណួរដើម្បីដឹងថា តើត្រូវបន្ថយបញ្ញត្តិរបស់ធម្មនុញ្ញដែលសហប្រជាជាតិមានអំណាចធានានូវការការពារមានព្រំដែនដល់ភ្នាក់ងាររបស់ខ្លួនឬទេ?*

*តុលាការបានឆ្លើយអះអាងថា យោងទៅតាមច្បាប់អន្តរជាតិ អង្គការអន្តរជាតិត្រូវបានចាត់ទុកថា មានអំណាចដែលពុំបានចែងច្បាស់ក្នុងធម្មនុញ្ញ។ ប៉ុន្តែមានភាពចាំបាច់ និងត្រូវផ្តល់ឱ្យអង្គការនូវសមត្ថកិច្ចដែលចាំបាច់ដល់ការអនុវត្តមុខងាររបស់ខ្លួន។ ប៉ុន្តែ សហភាពអឺរ៉ុបបានអនុវត្តទ្រឹស្តីសមត្ថកិច្ចមិនចំពោះនេះ។ យុត្តិសាស្រ្តបានអះអាងពីទ្រឹស្តីនេះនៅពេលដែលតុលាការចេញសេចក្តីសម្រេចនានា( មតិ១/៧៦ ២.៩២-ល-)។*

## ៦- សមត្ថកិច្ចជាក់លាក់

*អង្គការអន្តរជាតិបានចែងពីសមត្ថកិច្ចពិសេសចំនួនបីប្រភេទ ដូចជាសមត្ថកិច្ចធម្មនិយាមប្រតិបត្តិ និងត្រួតពិនិត្យ។*

## ៦.១- សមត្ថកិច្ចធម្មនិយាម

*សកម្មភាពធម្មនិយាមរបស់អង្គការអន្តរជាតិមានច្រើនណាស់ និងមានការប្រែប្រួល។ យើងឃើញមានកិច្ចដែលបញ្ចេញអានុភាពក្នុងលំដាប់គតិយុត្តរបស់អង្គការ និងកិច្ចដែលមានអានុភាពក្រៅអង្គការ ព្រោះថា កិច្ចនោះបង្កើតវិធានដែលប៉ះពាល់ដល់ប្រធានច្បាប់អន្តរជាតិផ្សេងៗ។*

*ចំពោះសមត្ថកិច្ចធម្មនិយាមក្នុង អង្គការអន្តរជាតិនឹងកំណត់ផងដែរពីសមត្ថកិច្ចសមាសភាព និងមុខងាររបស់អង្គភាព។*

### ៦.២- សមត្ថកិច្ចប្រតិបត្តិ

*សមត្ថកិច្ចនេះមានលក្ខណៈប្លែកពីគ្នា និងប្រែប្រួលពីអង្គការមួយទៅអង្គការមួយ ទៅតាមកម្មវត្ថុ និងគោលដៅរបស់អង្គការ។ សមត្ថកិច្ចទាំងនេះប្រមូលផ្តុំអំណាចភាគច្រើននៃសកម្មភាពរបស់អង្គការអន្តរជាតិ។*

### ៦.៣- សមត្ថកិច្ចត្រួតពិនិត្យ

*សមត្ថកិច្ចទាំងនេះអនុញ្ញាតឱ្យវាយតម្លៃទៅលើភាពចាំបាច់កើនឡើងដែលគ្របដណ្តប់លើការការពារសិទ្ធិមនុស្សអន្តរជាតិ។ សមត្ថកិច្ចត្រួតពិនិត្យទាំងនេះត្រូវបានពង្រឹងក្នុងអង្គការអន្តរជាតិដែលចែងពីប្រព័ន្ធត្រួតពិនិត្យដែលបញ្ចូលទៅក្នុងអង្គការ។*

*ករណីអង្គការអន្តរជាតិពុំចែងពីប្រព័ន្ធត្រួតពិនិត្យ នីតិវិធីនៃទំនាក់ទំនងតាមពេលវេលារវាងរដ្ឋសមាជិក និងអង្គការស្តីពីវិធីដែលរដ្ឋសមាជិករួចកាតព្វកិច្ចជាលក្ខណៈលក្ខន្តិកៈ ឬជាអនុសញ្ញានោះ មានភាពចាំបាច់គួរឱ្យកត់សម្គាល់។*

*សរុបមក យើងអាចនិយាយបានថា អង្គការអន្តរជាតិត្រូវបានចាត់ទុកជាប្រធានស្ទើរតែស្វយ័តពីសង្គមអន្តរជាតិដែលនេះជួយពង្រឹងវិធានច្បាប់សាធារណៈអន្តរជាតិជាសារវន្ត។*

# ផ្នែកទី២

# ច្បាប់អង្គការសហប្រជាជាតិ

## ១- គោលដៅ និងគោលការណ៍អង្គការសហប្រជាជាតិ

*កម្មវត្ថុចម្បងរបស់អង្គការសហប្រជាជាតិគឺធានាសន្តិភាព និងសន្តិសុខអន្តរជាតិ។ ការប្រជុំកំពូលពិភពលោកស្តីពីកំណែទម្រង់អង្គការសហប្រជាជាតិនាខែកញ្ញា ២០០៥ពុំបានចេញជាលទ្ធផលទេ។*

### ១.១- គោលដៅនៃអង្គការសហប្រជាជាតិ

***មាត្រា១របស់ធម្មនុញ្ញអង្គការសហប្រជាជាតិបានចែងពីគោលដៅចំនួន៤ ៖***

*• រក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ៖ អង្គការសហប្រជាជាតិចាត់វិធានការរួម ដើម្បីបង្ការ និងបញ្ចៀសរាល់ការគំរាមកំហែងដល់សន្តិភាព។ រាល់ជម្លោះត្រូវដោះស្រាយដោយសន្តិវិធី។ គោលដៅនេះត្រូវបំពេញដោយគោលការណ៍ហាមប្រើប្រាស់កម្លាំងទ័ព( មាត្រា២ កថាខណ្ឌទី៤)។*

• ការអភិវឌ្ឍមេត្រីភាពរវាងរដ្ឋទាំងអស់ ៖ គឺផ្អែកទៅលើគោលការណ៍សមភាពផ្លូវច្បាប់និងសិទ្ធិស្វ័យសម្រេចរបស់ប្រជាជន។

• សម្រេចឱ្យបាននូវសហប្រតិបត្តិការអន្តរជាតិដោយ«ដោះស្រាយបញ្ហាអន្តរជាតិផ្នែកសេដ្ឋកិច្ច សង្គម សតិបញ្ញា ឬមនុស្សធម៌» (មាត្រា១ កថាខណ្ឌទី៣) ដោយឆ្លងកាត់តាមការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត។

• «ជាមជ្ឈមណ្ឌលសម្រួលការប្រឹងប្រែងរបស់សហប្រជាជាតិទៅរកការសម្រេចគោលដៅរួម» (មាត្រា១ កថាខណ្ឌទី៤) ជាទីជួបជុំគ្នារបស់រដ្ឋទាំងអស់ក្នុងពិភពលោក។

## ១.២- គោលការណ៍នៃអង្គការសហប្រជាជាតិ

**មាត្រា២នៃធម្មនុញ្ញបានចែងពីគោលការណ៍ចំនួន៧ ៖**

១- គោលការណ៍សមភាពអធិបតេយ្យរបស់សមាជិកទាំងអស់(មាត្រា២ កថាខណ្ឌទី១) ជាសមភាពគតិយុត្តរបស់សមាជិកអង្គការសហប្រជាជាតិ។

២- គោលការណ៍សុចរិត។ រដ្ឋទាំងអស់ត្រូវបំពេញកាតព្វកិច្ចជាសមាជិកដោយសុចរិត (មាត្រា២ កថាខណ្ឌទី២)។

៣- គោលការណ៍ដោះស្រាយជម្លោះដោយសន្តិវិធី។ យោងតាមមាត្រា២ កថាខណ្ឌទី៣ សមាជិកទាំងអស់ដោះស្រាយជម្លោះដោយសន្តិវិធី ដើម្បីរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

៤- គោលការណ៍មិនប្រើកម្លាំងទ័ព។ រាល់សមាជិកធ្វើអនុប្បវាទមិនប្រើប្រាស់កម្លាំងបាយក្នុងទំនាក់ទំនងរបស់ខ្លួន(មាត្រា២ កថាខណ្ឌទី៤)។ ដូច្នេះ គោលការណ៍ទាំងពីរមានចំណងរវាងគ្នានិងគ្នា។

៥- រាល់សមាជិកផ្តល់ជំនួយដល់អង្គការទៅលើសកម្មភាពដែលអង្គការធ្វើ ជាអាទិ៍នៅពេលអង្គការធ្វើសកម្មភាពក្នុងក្របខ័ណ្ឌជំពូកទី៧របស់ធម្មនុញ្ញ។

៦- សមាជិកត្រូវធ្វើអនុប្បវាទផងដែរក្នុងការជួយរដ្ឋមួយដែលជាកម្មវត្ថុនៃសកម្មភាពទប់ស្កាត់ ឬបង្ខិតបង្ខំ(ធម្មនុញ្ញ មាត្រា២ កថាខណ្ឌទី៥)។

៧- គោលការណ៍ពុំជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋពីសំណាក់អង្គការសហប្រជាជាតិ។

## ២- រចនាសម្ព័ន្ធអង្គការសហប្រជាជាតិ

មាត្រា៧របស់ធម្មនុញ្ញចែងពីអង្គភាពចម្បងចំនួន៦ រួមមាន មហាសន្និបាត ក្រុមប្រឹក្សាសន្តិសុខ ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម ក្រុមប្រឹក្សាអាណាព្យាបាល តុលាការយុត្តិធម៌អន្តរជាតិ និងលេខាធិការដ្ឋាន។

*អង្គភាពចម្បងអាចបង្កើតអង្គភាពបន្ទាប់បន្សំដែលមានលក្ខណៈចាំបាច់(មាត្រា៧ កថាខណ្ឌទី២)។ ឧទាហរណ៍ មហាសន្និបាតបានបង្កើតគណៈកម្មការច្បាប់អន្តរជាតិ(CDI)នាឆ្នាំ១៩៤៧ ឬតុលាការរដ្ឋបាលសហប្រជាជាតិ(TANU)នាឆ្នាំ១៩៤៩ដែលមានសមត្ថកិច្ចទៅលើវិវាទមុខងារសាធារណៈរបស់អង្គការសហប្រជាជាតិ ឬក្រុមប្រឹក្សាសិទ្ធិមនុស្សនាឆ្នាំ២០០៦។*

## ៣- អង្គភាពអន្តររដ្ឋ

*សមាសភាពអង្គភាពទាំងនេះមានតំណាងរបស់រដ្ឋាភិបាល។*

### ៣.១- មហាសន្និបាត

*គឺជាអង្គភាពពេញអង្គរបស់អង្គការសហប្រជាជាតិ(ធម្មនុញ្ញ ពីមាត្រា៩ ដល់២២)។ រដ្ឋនីមួយៗត្រូវបានតំណាងនៅមហាសន្និបាត និងមានសំឡេងមួយ។ រាល់ការសម្រេចធំៗប្រព្រឹត្តទៅតាមសំឡេងពីរភាគបីរបស់សមាជិកមានវត្តមាន និងតាមការបោះឆ្នោត ហើយពាក់ព័ន្ធនឹងបញ្ហាផ្សេងៗទៀត ការបោះឆ្នោតប្រព្រឹត្តទៅតាមសំឡេងភាគច្រើនរបស់សមាជិកមានវត្តមាន និងតាមការបោះឆ្នោត។ មហាសន្និបាតពិនិត្យ និងឯកភាពលើថវិការបស់អង្គការ(មាត្រា១៧របស់ធម្មនុញ្ញ)។ មហាសន្និបាតបោះឆ្នោតជ្រើសរើសសមាជិកមិនអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខ។*

*មហាសន្និបាតសហការជាមួយក្រុមប្រឹក្សាសន្តិសុខក្នុងការចូលរួមបោះឆ្នោតជ្រើសរើសរដ្ឋសមាជិកថ្មី(ធម្មនុញ្ញ មាត្រា៤) រើសអគ្គលេខាធិការ និងចៅក្រមសម្រាប់តុលាការយុត្តិធម៌អន្តរជាតិ។*

*ជាគោលការណ៍ ដំណោះស្រាយរបស់មហាសន្និបាតពុំមានអានុភាពបង្ខិតបង្ខំទេ។ ដំណោះ-ស្រាយនោះមានលក្ខណៈជាសេចក្តីប្រកាសប៉ុណ្ណោះ ប៉ុន្តែចំណុចនេះពុំរាំង ពុំឱ្យមានឥទ្ធិពលលើវិវត្តន៍នៃច្បាប់អន្តរជាតិឡើយ។*

### ៣.២- ក្រុមប្រឹក្សាសន្តិសុខ

*គឺជាអង្គភាពកំហិតមួយដែលមានសមាជិក១៥រូប(ពីមាត្រា២៣ដល់៣២របស់ធម្មនុញ្ញ)។ ក្នុងនោះ សមាជិកប្រាំរូបជាសមាជិកអចិន្ត្រៃយ៍។ សមាជិក១០រូបទៀតត្រូវបោះឆ្នោតជ្រើសរើសដោយមហាសន្និបាតសម្រាប់រយៈពេល២ឆ្នាំ ទៅតាមសំឡេងពីរភាគបី ផ្អែកតាមភូមិសាស្ត្រ ហើយសមាជិកពាក់កណ្តាលត្រូវផ្លាស់ប្តូរវៀងរាល់ឆ្នាំ។*

*មាត្រា២៧ក្នុងធម្មនុញ្ញបានពណ៌នាពីបែបបទក្នុងការសម្រេចចិត្តដែលត្រូវផ្តល់សិទ្ធិវេតូដល់សមាជិកអចិន្ត្រៃយ៍ ដោយហេតុថា ក្នុងការអនុម័តការសម្រេច ត្រូវមានការព្រមព្រៀងជា*

ឯកច្ឆន្ទ(លើកលែងការសម្រេចពាក់ព័ន្ធបញ្ហានីតិវិធី)។

ជួនកាល ការទាមទារនេះឈានទៅរកភាព«កកស្ទះ»ដល់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាសន្តិសុខមានការទទួលខុសត្រូវសំខាន់ក្នុងការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ (មាត្រា២៤នៃធម្មនុញ្ញ)។ ចំណុចនេះពាក់ព័ន្ធពិសេសទៅនឹងការដោះស្រាយជម្លោះដោយសន្តិវិធីក្នុងក្របខ័ណ្ឌជំពូកទី៦ និងសកម្មភាពករណីមានការគំរាមកំហែងដល់សន្តិភាពក្នុងក្របខ័ណ្ឌជំពូកទី៧។

រាល់កិច្ចធ្វើឡើងដោយក្រុមប្រឹក្សាសន្តិសុខមានលក្ខណៈចាប់បង្ខំទៅលើសមាជិករបស់អង្គការ(មាត្រា២៥ក្នុងធម្មនុញ្ញ)។

## ៣.៣- ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម

គឺមានសមាជិក៥៤រូបដែលជ្រើសរើសដោយមហាសន្និបាតសម្រាប់រយៈពេល៣ឆ្នាំ(ពីមាត្រា៦១ដល់៧១ ក្នុងធម្មនុញ្ញ)។ ក្រុមប្រឹក្សាធ្វើរបាយការណ៍ និងការសិក្សាពីបញ្ហាអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ សុខភាពសាធារណៈ។ ក្រុមប្រឹក្សាផ្តល់អនុសាសន៍។

## ៤- អង្គភាពសមាហរណកម្ម

អង្គភាពទាំងនេះពុំមែនតំណាងរដ្ឋទេ។

## ៤.១- អគ្គលេខាធិការ

គឺជាមន្ត្រីជាន់ខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិ។ អគ្គលេខាធិការត្រូវបានតែងតាំងដោយមហាសន្និបាតទៅតាមអនុសាសន៍របស់ក្រុមប្រឹក្សាសន្តិសុខ។ (មាត្រា៩៧ ក្នុងធម្មនុញ្ញ)។ អាណត្តិរបស់អគ្គលេខាមានរយៈពេលប្រាំឆ្នាំ និងអាចបន្តទៀតបាន។ អគ្គលេខាធិការបង្ហាញរបាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់អង្គការជូនមហាសន្និបាត។ អគ្គលេខាធិការអាចឱ្យក្រុមប្រឹក្សាសន្តិសុខផ្តោតទៅលើរឿងណាដែលបង្កគ្រោះថ្នាក់ដល់សន្តិភាព និងសន្តិសុខអន្តរជាតិ (មាត្រា៩៩ ក្នុងធម្មនុញ្ញ)។

អគ្គលេខាធិការគឺជាក្បាលម៉ាស៊ីនគ្រប់គ្រងរដ្ឋបាលរបស់អង្គការសហប្រជាជាតិ។ អគ្គលេខាតែងតាំងបុគ្គលិកលេខាធិការដ្ឋាន។ អគ្គលេខាគឺជាអ្នកតម្កល់ទុកសន្ធិសញ្ញាអន្តរជាតិជាច្រើន។

## ៤.២- តុលាការយុត្តិធម៌អន្តរជាតិ(CIJ)

គឺជាអង្គភាពយុត្តិធម៌របស់អង្គការសហប្រជាជាតិ។ លក្ខន្តិកៈរបស់អង្គភាពត្រូវបញ្ចូលជាឧបសម្ព័ន្ធនៃធម្មនុញ្ញសហប្រជាជាតិ និងជាផ្នែកពេញលេញមួយនៃធម្មនុញ្ញ។ តុលាការមាន

មន្ទីរក្រឡាបញ្ជីជំនួយមួយ។ តុលាការមានចៅក្រមជ្រើសតាំង១៥រូប សម្រាប់រយៈពេល៩ឆ្នាំ និង អាចជ្រើសតាំងជាថ្មីដោយមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខដោយមិនប្រកាន់សញ្ជាតិ។ តុលាការយុត្តិធម៌អន្តរជាតិគឺជាអង្គភាពយុត្តិធម៌ដែលមានសមត្ថកិច្ចវិវាទ និងសមត្ថកិច្ចពិគ្រោះ។

# ជំពូក៥
# ច្បាប់សន្ធិសញ្ញា

## ផ្នែកទី១
## ការចុះសន្ធិសញ្ញាអន្តរជាតិ

*សន្ធិសញ្ញាអន្តរជាតិទ្វេភាគី(រវាងរដ្ឋពីរ) ឬពហុភាគី(ដែលមានរដ្ឋច្រើនជាគូភាគី) គឺជាប្រភពសំខាន់មួយរបស់នីតិអន្តរជាតិ។*

### ១- សន្ធិសញ្ញាជាប្រភពនីតិអន្តរជាតិ

*អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាដែលចុះហត្ថលេខាកាលពីថ្ងៃទី២៣ ឧសភា ១៩៦៩ បានចងក្រងជាក្រមនូវនីតិទំនៀមទម្លាប់ពាក់ព័ន្ធនឹងសន្ធិសញ្ញា។ អនុសញ្ញាទីក្រុងវីយែនបានចូលជាធរមាននៅថ្ងៃទី២៧ មករា ១៩៨០ បន្ទាប់ពីឧបករណ៍ផ្តល់សច្ចាប័នទី៣៥ត្រូវបានដាក់តម្កល់(អនុសញ្ញាទីក្រុងវីយែន មាត្រា៨៤)។ ការចូលជាធរមានយឺតយ៉ាវនេះឆ្លុះបញ្ចាំងពីការជំទាស់របស់រដ្ឋមួយចំនួនទៅនឹងបទប្បញ្ញត្តិច្បាប់ថ្មីដែលមានចែងក្នុងអនុសញ្ញា។ ប្រទេសបារាំងពុំមែនជាភាគីអនុសញ្ញានេះទេ ព្រោះថាខ្លួនស្ទាក់ស្ទើរទៅលើបញ្ញត្តិពាក់ព័ន្ធនឹង jus cogens។ ប៉ុន្តែ ប្រទេសបារាំងមានចំណងភ្ជាប់ទៅនឹងវិធានទំនៀមទម្លាប់ដែលប្រទេសបារាំងបានព្រមទទួល និងដែលត្រូវបានចងក្រងជាក្រមក្នុងអនុសញ្ញា ព្រោះថាវិធានទំនៀមទម្លាប់ ទោះត្រូវចងក្រងជាក្រមក្តី ក៏នៅមានវត្តមានជាទំនៀមទម្លាប់ដដែល។*

*អនុសញ្ញាទីក្រុងវីយែនមានតម្លៃបំពេញជំនួស។ អនុសញ្ញានេះត្រូវអនុវត្តករណីមានតុណ្ហីភាពរបស់សន្ធិសញ្ញា។ អត្ថបទនេះត្រូវបានបំពេញដោយអនុសញ្ញាទីក្រុងវីយែនចុះថ្ងៃទី២១ មីនា ១៩៨៦ ស្តីពីច្បាប់សន្ធិសញ្ញារវាងរដ្ឋ និងអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិ។*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**និយមន័យនៃសន្ធិសញ្ញា(អនុសញ្ញាទីក្រុងវីយែន មាត្រា២ កថាខណ្ឌទី១a)**

*សន្ធិសញ្ញាគឺជាកិច្ចព្រមព្រៀងដែលចុះជាលាយល័ក្ខអក្សរ។ អនុសញ្ញាទីក្រុងវីយែនពុំមែនពុំរាប់បញ្ចូលថា សន្ធិសញ្ញាអាចមានទម្រង់ផ្ទាល់មាត់ទេ(កិច្ចព្រមព្រៀងផ្ទាល់មាត់យោងតាមអនុសញ្ញាទីក្រុងវីយែន មាត្រា៣)។*

*ពុំមានភាពខុសគ្នារវាងសន្ធិសញ្ញាទេ យោងតាមឈ្មោះរបស់សន្ធិសញ្ញា។ វាក្យស័ព្ទមានភាពប្រែប្រួលដូចជា សន្ធិសញ្ញា កិច្ចព្រមព្រៀង ពិធីសារ ធម្មនុញ្ញ កតិកាសញ្ញា លក្ខន្តិកៈ ការឆ្លើយឆ្លងលិខិត ឬកំណត់ទូត...។*

*សន្ធិសញ្ញាមួយមានទិដ្ឋភាពផ្សេងៗគ្នា។ គឺជាអត្ថបទតែមួយដែលនៅខាងក្រោមនោះ គ្រប់ភាគីបានចុះហត្ថលេខា។ ប៉ុន្តែ អត្ថបទនោះក៏អាចផ្សំពីឯកសារច្រើនផងដែរ។ គឺជាការឆ្លើយឆ្លងលិខិត(លិខិតឆ្លើយឆ្លងរវាងមនុស្សដែលមានអំណាចតំណាងឱ្យរដ្ឋរបស់ខ្លួន) ឬជាការឆ្លើយឆ្លងកំណត់ទូត។ ក្នុងករណីនេះ គឺជាសន្ធិសញ្ញាតែមួយ ទោះឯកសារមានច្រើនក្តី។ សន្ធិសញ្ញាគឺជាការបង្ហាញឆន្ទៈស្របគ្នា ដើម្បីសម្រេចគោលដៅ ឬកម្មវត្ថុរួមមួយ។*

## ២- ដំណាក់កាលនៃការចុះសន្ធិសញ្ញា

### ២.១- ការអនុម័តសន្ធិសញ្ញា

*ដំណាក់កាលដំបូងចាប់ផ្តើមដោយការចរចារវាងរដ្ឋដែលមានតំណាងដោយប្រេសិតពេញសមត្ថភាព ពោលគឺបុគ្គលដែលមាន«អំណាចពេញទី»ដែលមានសម្បទានិកធ្វើការអនុម័តទៅលើអត្ថបទសម្រាប់ជាប្រយោជន៍រដ្ឋ។*

*ការអនុម័តទៅលើអត្ថបទបន្ទាប់ពីការចរចាធ្វើឡើងទៅតាមកិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់អ្នកតំណាង។ ការអនុម័តអាចប្រព្រឹត្តទៅនាអំឡុងពេលមានសន្និសីទអន្តរជាតិស្តីពីការអនុម័តនេះ ឬក្នុងអង្គការអន្តរជាតិ។*

*ក្នុងដំណាក់កាលនេះ រដ្ឋដែលចូលរួមធ្វើការចរចាពុំមានកាតព្វកិច្ចអ្វីមួយឡើយ។ ជាទូទៅអត្ថបទដែលត្រូវបានអនុម័តមានច្រើនមាត្រា និងជួនកាលផ្តើមដោយបុព្វកថានៅខាងមុខ និងបញ្ចប់ដោយឧបសម្ព័ន្ធនៅខាងចុង។ ក្នុងចំណោមមាត្រាទាំងអស់ គេធ្វើការបែងចែកជាបទប្បញ្ញត្តិខ្លឹមសារដែលពាក់ព័ន្ធនឹងខ្លឹមសារនៃសន្ធិសញ្ញាផ្ទាល់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងជីវិតនៃសន្ធិសញ្ញា (បែបបទចូលជាធរមាន ការចូលជាសមាជិករបស់គូភាគីថ្មី លទ្ធភាពបញ្ចេញនូវឧបម្រុងទុក...) អវសានប្បញ្ញត្តិ។*

*ដំណាក់កាលចរចាត្រូវបញ្ចប់ដោយយថាភូតកម្មអត្ថបទ។ រដ្ឋទទួលស្គាល់អត្ថបទដែលអនុម័តថាជាលទ្ធផលនៃការចរចា។ យថាភូតកម្មអត្ថបទនោះស្តែងឡើងតាមការចុះហត្ថលេខាខ្លី*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឬការចុះហត្ថលេខា។ ដូច្នេះ រដ្ឋមានកាតព្វកិច្ចតែមួយគត់ គឺកាតព្វកិច្ចដែលកើតចេញពីការអនុវត្តឡើងវិញនូវគោលការណ៍ដោយសុចរិតទៅលើច្បាប់អន្តរជាតិ ពុំត្រូវបង្កជាបញ្ហាចោទជាថ្មីទៅលើគោលដៅ និងកម្មវត្ថុនៃសន្ធិសញ្ញា មុនសន្ធិសញ្ញានេះចូលជាធរមានទេ( អនុសញ្ញាទីក្រុងវីយែន មាត្រា១៨)។ កាលបរិច្ឆេទសន្ធិសញ្ញាគឺជាកាលបរិច្ឆេទចុះហត្ថលេខា។

## ២.២- ការសន្យារបស់រដ្ឋ

នេះគឺជាការបង្ហាញពីការឯកភាពរបស់រដ្ឋថានឹងត្រូវចងដោយសន្ធិសញ្ញា។ ការសន្យានេះត្រូវបង្ហាញជាផ្លូវការ ហើយទម្រង់នៃការបង្ហាញមានបញ្ជាក់នៅក្នុងអវសានប្បញ្ញត្តិរបស់សន្ធិសញ្ញា។

ដូច្នេះ រដ្ឋក្លាយទៅជារដ្ឋភាគីកិច្ចសន្យា( នៅពេលសន្ធិសញ្ញាពុំទាន់ចូលជាធរមានជាអន្តរ-ជាតិ) ឬក្លាយជារដ្ឋភាគី( នៅពេលសន្ធិសញ្ញាចូលជាធរមានជាអន្តរជាតិ)។

ការសន្យាស្តែងឡើងទៅតាមនីតិវិធីពីរប្រភេទគឺ ៖

- ***នីតិវិធីខ្លី*** ៖ ការសន្យាស្តែងឡើងតាមការចុះហត្ថលេខាមួយគត់។ ដំណាក់កាលយថាភូតកម្ម និងការសន្យាមានការភ័ន្តច្រឡំគ្នា។ គេហៅថាជាកិច្ចព្រមព្រៀងតាមទម្រង់សាមញ្ញ។ អវសានប្បញ្ញត្តិចែងពីនីតិវិធីនេះដែលពាក់ព័ន្ធនឹងប្រភេទសន្ធិសញ្ញានានា។
- ***នីតិវិធីវែង*** ៖ ការសន្យារបស់រដ្ឋកើតចេញពីទម្រង់បែបបទពិសេសមួយ។ ការចុះហត្ថ-លេខាមានតម្លៃស្មើនឹងយថាភូតកម្មអត្ថបទប៉ុណ្ណោះ ព្រោះថារដ្ឋត្រូវបង្ហាញបន្ថែមអំពីឆន្ទៈផ្សារភ្ជាប់ទៅនឹងសន្ធិសញ្ញា។ ដូច្នេះ សច្ចាប័នទៅលើសន្ធិសញ្ញាគឺផ្តល់ដោយប្រមុខរដ្ឋ។

នាចុងក្រោយ រដ្ឋដែលបានចូលរួមចរចាទាំងអស់ តែងតាំងអ្នកទទួលតម្កល់ឯកសារមួយរូបដែលអាចជារដ្ឋមួយ ឬច្រើន ជាអង្គការអន្តរជាតិ ឬមន្ត្រីជាន់ខ្ពស់របស់អង្គការអន្តរជាតិ( អគ្គលេខាធិការអង្គការសហប្រជាជាតិ)។

សន្ធិសញ្ញាអាចត្រៀមលក្ខខណ្ឌមួយចំនួនសម្រាប់ការចូលជាធរមានអន្តរជាតិរបស់វា។ ក្នុងនោះ អាចជាចំនួនផ្តល់សច្ចាប័នអប្បបរមា ដូចជាអនុសញ្ញាទីក្រុងវីយែនជាដើម( សូមមើលអត្ថបទខាងលើ)។

# ផ្នែកទី២
# សិទ្ធិបម្រុងសម្រាប់សន្ធិសញ្ញាពហុភាគី

សិទ្ធិបម្រុងអនុញ្ញាតដល់រដ្ឋជាភាគីសន្ធិសញ្ញាពហុភាគីក្នុងការកែប្រែខ្លឹមសារការសន្យារបស់ខ្លួនដោយពុំកែប្រែសន្ធិសញ្ញា(សម្រាប់តែសន្ធិសញ្ញាពហុភាគីប៉ុណ្ណោះ)។

## ១- និយមន័យនៃសិទ្ធិបម្រុង(Réserves)

សិទ្ធិបម្រុងគឺជាសេចក្តីប្រកាសឯកតោភាគីរបស់រដ្ឋមួយ។ សិទ្ធិបម្រុងចេញពីរដ្ឋតែមួយគត់ ពោលគឺជាកិច្ចឯកតោភាគីរបស់រដ្ឋ។[៩៤] មិនថាមានអត្ថបទតែង ឬឈ្មោះអ្វីទេ ប្រសិនបើកិច្ចនោះបង្ហាញចរិតលក្ខណៈជាសិទ្ធិបម្រុង កិច្ចនោះត្រូវចាត់ទុកថាជាកិច្ចជាឯកតោភាគីរបស់រដ្ឋ ទោះចារីកំណត់ថាជាសេចក្តីប្រកាសក្តី។ រដ្ឋបង្ហាញពីសិទ្ធិបម្រុង នៅពេលរដ្ឋនោះធ្វើការសន្យា។ ដូច្នេះរដ្ឋនោះបង្ហាញសិទ្ធិបម្រុងនៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ព្រមទទួលឬយល់ព្រម ឬចូលជាសមាជិកសន្ធិសញ្ញា។ សិទ្ធិបម្រុងមានគោលដៅកែសម្រួលការសន្យារបស់រដ្ឋ ដូច្នេះសិទ្ធិបម្រុងនោះត្រូវបញ្ចេញនៅពេលធ្វើការសន្យា។

សិទ្ធិបម្រុងមានគោលដៅដកចេញ ឬកែប្រែនូវឥទ្ធិពលគតិយុត្តនៃបញ្ញត្តិខ្លះរបស់សន្ធិសញ្ញាសម្រាប់ការអនុវត្តទៅលើរដ្ឋនោះ។ អាស្រ័យដោយមុខងារនេះ វត្តមានបញ្ញត្តិណាក៏ដោយ លែងជាឧបសគ្គរាំងដល់ការចូលរួមរបស់រដ្ឋមួយចំនួនហើយ។

សន្ធិសញ្ញាខ្លះហាមប្រាមមិនឱ្យមានសិទ្ធិបម្រុងទេ។ រដ្ឋទាំងអស់ត្រូវព្រមទទួលខ្លឹមសារសន្ធិសញ្ញាទាំងមូល។ អនុសញ្ញាខ្លះកំហិតទៅលើលទ្ធភាពធ្វើសិទ្ធិបម្រុងដោយអនុញ្ញាតឱ្យមានសិទ្ធិបម្រុងនោះតែនៅក្នុងបទប្បញ្ញត្តិខ្លះប៉ុណ្ណោះ និងដោយហាមពុំឱ្យមានសិទ្ធិបម្រុងសម្រាប់ការវិនិច្ឆ័យជាសារវន្តផ្សេងទៀត។

លើសពីនេះ អនុសញ្ញាទីក្រុងវីយែន ត្រង់មាត្រា១៩ ចែងថា រដ្ឋមួយអាចធ្វើសិទ្ធិបម្រុងបាន ប្រសិនបើ៖

១- សិទ្ធិបម្រុងនោះពុំត្រូវបានសន្ធិសញ្ញាហាមឃាត់

២- សន្ធិសញ្ញាចែងថា មានតែសិទ្ធិបម្រុងដែលកំណត់ជាក់លាក់ប៉ុណ្ណោះ[...]ដែលអាចធ្វើបាន[...]។

---

[៩៤] មាត្រា២ កថាខណ្ឌ១ ចំណុចឃ ក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីសិទ្ធិសន្ធិសញ្ញាបានផ្តល់និយមន័យពីសិទ្ធិបម្រុង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២- ឥទ្ធិពលរបស់សិទ្ធិបម្រុង

*ឥទ្ធិពលរបស់សិទ្ធិបម្រុងពុំអាស្រ័យទៅលើការឯកភាពរបស់ភាគីសន្ធិសញ្ញាឯទៀតទេ។ ការឯកភាពនេះត្រូវបានសន្មតថាបានផ្តល់ នៅពេលព្រមទទួលខអនុញ្ញាត(អនុសញ្ញាទីក្រុងវីយែន មាត្រា២០ កថាខណ្ឌទី១)។ ក្នុងន័យទូទៅ នៅពេលសន្ធិសញ្ញាអនុញ្ញាតឱ្យមានសិទ្ធិបម្រុង រដ្ឋជាភាគីទាំងអស់«មានសិទ្ធិប្រតិកម្មទៅនឹងសិទ្ធិបម្រុងដែលអនុលោមទៅតាមបញ្ញត្តិរបស់សិទ្ធិបម្រុងនោះ ហើយថែមទាំងបដិសេធសិទ្ធិបម្រុងនោះចោល»។[៩៥]*

*ប៉ុន្តែ គឺក្នុងករណីតុណ្ហីភាពសន្ធិសញ្ញាទើបបញ្ហាទៅលើការទទួលយកសិទ្ធិបម្រុងបានវិវត្តយ៉ាងខ្លាំងក្លា។ នេះគឺជាសម្មតិកម្មដែលតាមរយៈនោះ សន្ធិសញ្ញាពុំមានផ្ទុកបទប្បញ្ញត្តិណាមួយដែលពាក់ព័ន្ធនឹងសិទ្ធិបម្រុង។*

*លទ្ធិបុរាណមានបំណងថា ដើម្បីឱ្យសិទ្ធិបម្រុងអាចទទួលយកបាន សិទ្ធិបម្រុងនោះត្រូវទទួលយកជាឯកច្ឆន្ទពីរដ្ឋភាគីសន្ធិសញ្ញាទាំងអស់។ ពីពេលនោះមក អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាទទួលស្គាល់ថា ក្នុងករណីតុណ្ហីភាពរបស់សន្ធិសញ្ញា សិទ្ធិបម្រុងមួយអាចធ្វើទៅរួច ប្រសិនបើសិទ្ធិបម្រុងនោះមិនមាន«វិសមិតភាពទៅនឹងកម្មវត្ថុ និងគោលដៅរបស់សន្ធិសញ្ញា» (មាត្រា១៩ វាក្យខណ្ឌគ)។*

## ការទទួលយក និងការជំទាស់ទៅនឹងសិទ្ធិបម្រុង

*អនុសញ្ញាទីក្រុងវីយែនបញ្ជាក់ពីរបប និងវិធាននៃភាពជំទាស់បានទៅនឹងសិទ្ធិបម្រុងទៅតាមប្រតិកម្មរបស់ដៃគូរដ្ឋដែលបានបង្ហាញពីសិទ្ធិបម្រុង ពោលគឺរដ្ឋដែលធ្វើសិទ្ធិបម្រុង(មាត្រា ២០ a២៣)។ រវាងរដ្ឋដែលធ្វើសិទ្ធិបម្រុង និងរដ្ឋព្រមទទួលសិទ្ធិបម្រុង សន្ធិសញ្ញានឹងអនុវត្តដោយគិតទៅដល់ខ្លឹមសាររបស់សិទ្ធិបម្រុង។ លើសពីនេះ រដ្ឋអាចធ្វើការជំទាស់ពីរប្រភេទទៅនឹងសិទ្ធិបម្រុងមួយ។*

• ***ការជំទាស់សាមញ្ញ*** *ពោលគឺសន្ធិសញ្ញាចូលជាធរមានរវាងរដ្ឋពីរ ប៉ុន្តែបទប្បញ្ញត្តិ និងសិទ្ធិបម្រុងដែលពាក់ព័ន្ធនឹងការជំទាស់នោះពុំអនុវត្តរវាងភាគីទាំងពីរនេះទេ។ ការជំទាស់សាមញ្ញមានន័យថា រដ្ឋជំទាស់ប្រានសិទ្ធិបម្រុងចោល ប៉ុន្តែព្រមទទួលថា សន្ធិសញ្ញាត្រូវបានអនុវត្តនៅក្នុងបទប្បញ្ញត្តិផ្សេងទៀតរបស់សន្ធិសញ្ញា រវាងរដ្ឋជំទាស់ និងរដ្ឋដែលស្នើសុំសិទ្ធិបម្រុង។*

• ***ការជំទាស់ខ្លាំងក្លា****ត្រូវបានធ្វើឡើងដោយរដ្ឋមួយដែលវាយតម្លៃថា សិទ្ធិបម្រុងផ្ទុយទៅនឹងកម្មវត្ថុ និងគោលដៅរបស់សន្ធិសញ្ញា ហើយរារាំងសន្ធិសញ្ញាមិនឱ្យចូលជាធរមានរវាងរដ្ឋនេះ និងចារីនៃសិទ្ធិបម្រុង។ នេះត្រូវសន្មតថា ចារីនៃការជំទាស់បានបង្ហាញជាក់ច្បាស់ពីចេតនានេះ។*

---

[៩៥] *សាលក្រមមជ្ឈត្តការចុះថ្ងៃទី៣០ មិថុនា ១៩៧៧ សំណុំរឿងការកំណត់ព្រំដែនខ្ពង់រាបបាតសមុទ្រក្នុងសមុទ្រអ៊ីរ៉ង់ France c. Royaume-Uni, RSA XVIII, p. 175.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ក្នុងការអនុវត្តគោលការណ៍បដិការ សិទ្ធិបម្រុង និងការជំទាស់ក៏អាចត្រូវជំទាស់បានផង ដែរពីចារីផ្ទាល់។ ដូច្នេះ រដ្ឋដែលសិទ្ធិបម្រុងមកបញ្ចៀសបទប្បញ្ញត្តិមួយរបស់សន្ធិសញ្ញា ពុំអាច ទាមទារឱ្យសិទ្ធិបម្រុងត្រូវអនុវត្តដោយភាគីផ្សេងទៀតទេ។ ប៉ុន្តែ ភាគីចុងក្រោយនេះត្រូវប្រកាន់ អនុវត្តសិទ្ធិបម្រុងសម្រាប់ភាគីមួយដែលពុំបានធ្វើសិទ្ធិបម្រុង និងដែលអនុវត្តសិទ្ធិបម្រុងខ្លួនឯង។*

# ផ្នែកទី៣

## សុពលភាពនៃការសន្យាតាមអនុសញ្ញា

*នីតិមុនអនុសញ្ញាទីក្រុងវីយែនបានចោទជាបញ្ហាត្រង់សុពលភាពនៃការសន្យាតាមអនុសញ្ញា ដែលមានលក្ខណៈស្មាក់ស្មើរ និងកំណត់មិនបានត្រឹមត្រូវ។ ជាក់ស្តែង នៅក្នុងផ្នែកទី៥ ទាំងអស់ អះអាងអំពីភាពចាំបាច់នៃតថភាពនៃការឯកភាព អនុសញ្ញាបានបញ្ញត្តិថ្មីដោយទទួលស្គាល់ឱ្យ មានអសុពលភាពនៃសន្ធិសញ្ញាដែលផ្ទុយពីជម្មនិយាមដែលមានលក្ខណៈបញ្ញោ។*

### ១- មូលហេតុនៃអសុពលភាព

### ១.១- វិការនៃការឯកភាព(មាត្រាពី៤៦ដល់៥២ក្នុងអនុសញ្ញាទីក្រុងវីយែន)

• ***ការរំលោភនីតិផ្ទៃក្នុងរបស់រដ្ឋពាក់ព័ន្ធនឹងសមត្ថកិច្ចធ្វើសន្ធិសញ្ញា។*** *វិការនេះពុំអាចលើក មកសំអាងបានទេ «លើកលែងតែការរំលោភនេះស្តែងឡើងជាក់ច្បាស់ ហើយពាក់ព័ន្ធវិធាន[...] ជាសារវន្តមួយ»(មាត្រា៤៦ កថាខណ្ឌទី១)។ ការរំលោភមានភាពជាក់ស្តែង នៅពេលការរំលោភ «ប្រាកដឡើងជាលក្ខណៈជំទាស់ពីរដ្ឋទាំងអស់ដែលជំទាស់ ដោយអនុលោមទៅតាមការអនុវត្ត តាមទម្លាប់ និងសុចរិត»(មាត្រាទី៤៦ កថាខណ្ឌទី២)។*

• ***ករណីដែលអ្នកតំណាងរំលោភអំណាចរបស់ខ្លួន។*** *វិការនេះពុំអាចលើកយកមកសំអាង បានទេ «ប្រសិនបើការរឹតត្បិតពុំត្រូវបានជូនជាដំណឹងដល់រដ្ឋផ្សេងៗដែលចូលរួមចរចា មុននឹង បង្ហាញពីការឯកភាព»(មាត្រា៤៧)។ ទោះមូលហេតុអ្វីក៏ដោយ ការអនុវត្តក្នុងផ្នែកនេះសឹងតែពុំ ធ្លាប់មាន។*

• ***ការភ័ន្តច្រឡំ៖*** *ការភ័ន្តច្រឡំគឺសំដៅទៅលើព្រឹត្តិការណ៍ ឬស្ថានភាពមួយដែលរដ្ឋសន្មត ថា មាននៅពេលចុះសន្ធិសញ្ញា និងដែលជាមូលដ្ឋានសំខាន់នៃការឯកភាពរបស់រដ្ឋនោះ។ និយាយ ម៉្យាងទៀតគឺ ប្រសិនបើរដ្ឋដឹងជាមុនថា ស្ថានភាព ឬព្រឹត្តិការណ៍នោះមានខុសគ្នា រដ្ឋនោះប្រហែល ជាពុំចូលរួមសន្យាឡើយ។ ការភ័ន្តច្រឡំប្រភេទនេះឧស្សាហ៍កើតមានក្នុងករណីសន្ធិសញ្ញាដែនដី*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅពេលផែនទី និងសម្រង់បានលេខាមិនច្បាស់លាស់ និងខ្វះភាពជាក់លាក់។ ដូច្នេះ រដ្ឋអាចលើកពីការភ័ន្តច្រឡំថាធ្វើឱ្យប៉ះពាល់ខូចខាតដល់ការឯកភាពថានឹងផ្សារភ្ជាប់ទៅនឹងសន្ធិសញ្ញា។ ប៉ុន្តែរដ្ឋពុំអាចធ្វើដូច្នេះបានទេ ប្រសិនបើរដ្ឋនេះផ្ទាល់មានចំណែកក្នុងការភ័ន្តច្រឡំ ឬប្រសិនកាលៈទេសៈទាំងអស់គឺដូចដែលរដ្ឋនោះទទួលបានការជូនដំណឹងពីការភ័ន្តច្រឡំដែលអាចកើតមាន (មាត្រា៤៨ កថាខណ្ឌទី២)។

• **ការបន្លំ ៖** ក្នុងករណីនេះ រដ្ឋត្រូវដឹកនាំឱ្យធ្វើសន្ធិសញ្ញា ក្រោមមធ្យោបាយបន្លំពីរដ្ឋផ្សេងទៀតដែលបានចូលរួមចរចា(មាត្រា៤៩)។ ការបន្លំគឺជាការភ័ន្តច្រឡំដែលបង្កឡើងដោយចេតនា។ របបនៃការបន្លំនេះមានលក្ខណៈដូចគ្នានឹងរបបនៃការភ័ន្តច្រឡំដែរ។ ជនរងគ្រោះពីការភ័ន្តច្រឡំអាចលើកសំអាងពីការបន្លំបានថាធ្វើវិការនៃការឯកភាពរបស់ខ្លួន។ ប៉ុន្តែ ចារីបន្លំបានប្រព្រឹត្តទង្វើខុសច្បាប់ និងត្រូវទទួលខុសត្រូវជាអន្តរជាតិតាមការសន្យា។

• **អំពើពុករលួយរបស់តំណាងរដ្ឋ ៖** អំពើពុករលួយនេះកើតពីសកម្មភាពផ្ទាល់ ឬប្រយោលរបស់រដ្ឋមួយដែលបានចូលរួមចរចាទៅលើតំណាងរដ្ឋមួយទៀត។ ប្រសិនបើការឯកភាពរបស់រដ្ឋត្រូវទទួលបានតាមមធ្យោបាយពុករលួយនេះ រដ្ឋនោះអាចលើកសំអាងពីការឯកភាពនោះដូចជាធ្វើវិការនៃការឯកភាពរបស់ខ្លួន (មាត្រា៥០)។ ប៉ុន្តែ ភាគីម្ខាងពុំអាចលើកសំអាងពីមូលហេតុមោឃៈភាពណាមួយបានទេ ប្រសិនបើបានដឹងរួចហើយពីអង្គហេតុ។ ភាគីនោះបានព្រមយ៉ាងជាក់ច្បាស់ ឬដោយមូលហេតុនៃការប្រព្រឹត្តរបស់ខ្លួនថា ចាត់ទុកថាសន្ធិសញ្ញា ឬការឯកភាពរបស់ខ្លួនមានសុពលភាព(មាត្រា៤៥)។

• **ភាពបង្ខិតបង្ខំ ៖** ការបង្ខិតបង្ខំអាចធ្វើទៅលើតំណាងរដ្ឋ ពោលគឺជាទង្វើ ឬការគំរាមកំហែងទៅលើតំណាងរដ្ឋ ដើម្បីទទួលបានការឯកភាពពីរដ្ឋ។ ការគាបសង្កត់បង្កឱ្យមានការមិនឯកភាពពីដំបូង(*ab initio*) ហើយកិច្ចព្រមព្រៀងពុំមានឥទ្ធិពលគតិយុត្តអ្វីទាំងអស់(មាត្រាទី៥១ សូមមើលខាងក្រោម)។ ការបង្ខិតបង្ខំអាចធ្វើមកលើរដ្ឋខ្លួនឯងផ្ទាល់។ នេះសំដៅលើការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង។

## ១.២- គោលដៅមិនស្របច្បាប់ និងកម្មវត្ថុនៃសន្ធិសញ្ញា

មូលហេតុនៃអសុពលភាពនៅទីនេះមានលក្ខណៈសត្យានុម័ត ពោលគឺជាការជំទាស់ទៅនឹងធម្មនិយាមខ្ពស់ជាងមួយ រីឯពាក់ព័ន្ធនឹងវិការនៃការឯកភាពវិញ មូលហេតុមានទំនាក់ទំនងនឹងការសម្តែងនូវការឯកភាព។

មាត្រាទី៥៣នៃអនុសញ្ញាទីក្រុងវីយែនចែងថា ត្រូវចាត់ទុកជាមោឃៈនូវរាល់សន្ធិសញ្ញាទាំងឡាយណាដែលនៅពេលធ្វើ ផ្ទុយជាមួយបញ្ញត្តិចាប់បង្ខំនៃច្បាប់អន្តរជាតិទូទៅ(*jus cogens*)។

*អាស្រ័យដោយចរិតលក្ខណៈបញ្ហា វិធានពីមុននេះត្រូវគោរពដោយរដ្ឋទាំងអស់ នៅពេលធ្វើសន្ធិ-សញ្ញា។ ដូច្នេះ សន្ធិសញ្ញាមួយដែលតាមរយៈនោះ រដ្ឋរំលោភជម្មនិយាមបញ្ហាធ្លាប់មានស្រាប់មួយត្រូវមានមោឃៈភាព និងទទួលយកមិនបាន។*

## ២- ផលវិបាកនៃអសុពលភាព

***មោឃៈភាពមិនដាច់ខាត ៖*** *គឺជាមោឃៈភាពនៃការសន្យារបស់រដ្ឋដែលលើកឡើងមូលហេតុនៃអសុពលភាព។ មោឃៈភាពនេះមានអានុភាពតែទៅលើភាគីពាក់ព័ន្ធ ហើយមិនប៉ះពាល់ដល់សន្ធិសញ្ញាពហុភាគីទាំងមូលដែលនៅបន្តមានរវាងគូភាគីផ្សេងទៀត(ក្នុងករណីសន្ធិសញ្ញាទ្វេភាគី មោឃៈភាពនៃការសន្យារបស់ភាគីម្ខាងបណ្តាលឱ្យសន្ធិសញ្ញាទាំងមូលត្រូវបញ្ចប់)។*

***មោឃៈភាពទាំងស្រុង ៖*** *ក្នុងករណីនេះ វិការប៉ះពាល់ដល់សន្ធិសញ្ញាទាំងមូលដែលពុំនៅមានវត្តមានទៀតទេ។ សន្ធិសញ្ញាទាំងមូល និងទាំងសម្រាប់ភាគីទាំងអស់មានមោឃៈភាពពីដំបូង។ មោឃៈភាពទាំងស្រុងត្រូវបានតម្កល់ទុកក្នុងករណីមានការគាបសង្កត់ទៅលើរដ្ឋ និងមានការប្រឆាំងទៅលើបញ្ញត្តិចាប់បង្ខំ។ រដ្ឋជាភាគីអាចលើកមកសំអាងនូវមូលហេតុមោឃៈភាពទាំងនេះដែលមានគោលដៅការពារសណ្តាប់ធ្នាប់សាធារណៈរបស់សង្គមអន្តរជាតិ ពុំមែនការពាររដ្ឋមួយដោយឡែកដូចករណីវិការនៃការឯកភាពឡើយ។*

***មោឃៈភាពនៃបទប្បញ្ញត្តិខ្លះ ៖*** *នៅពេលដែលបទប្បញ្ញត្តិខ្លះអាចត្រូវផ្តាច់ចេញបានពីខ្លឹមសារនៅសេសសល់របស់សន្ធិសញ្ញា ត្រូវទទួលស្គាល់ថា មានតែមាត្រាដែលជាប់វិការទេដែលត្រូវមានមោឃៈភាព។ ចំណុចនេះពាក់ព័ន្ធតែករណីមោឃៈភាពមិនដាច់ខាតប៉ុណ្ណោះ។ នៅពេលមានមោឃៈភាពដាច់ខាត គឺពុំអាចនឹងធ្វើឱ្យនៅសល់តែសន្ធិសញ្ញាមួយផ្នែកបានឡើយ។*

# ផ្នែកទី៤

## អានុភាពនៃសន្ធិសញ្ញា

*នៅពេលចូលជាធរមានរួច សន្ធិសញ្ញាមួយនឹងមានអានុភាពទៅលើរដ្ឋភាគី។ ចំពោះបណ្តារដ្ឋទីបីវិញ គោលការណ៍នេះគឺជាគោលការណ៍អានុភាពមិនដាច់ខាត។ ទោះជាយ៉ាងនេះក្តី នៅពេលខ្លះសន្ធិសញ្ញាមួយក៏មានអានុភាពខ្លះទៅលើរដ្ឋទីបីដែរ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១- អានុភាពសន្ធិសញ្ញាទៅលើរដ្ឋភាគី

*មាត្រា២៦នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាបានចែងអំពីគោលការណ៍ ៖ «Pacta sunt servanda» ពោលគឺរាល់សន្ធិសញ្ញាចូលជាធរមានចងភាគីទាំងអស់ ហើយត្រូវអនុវត្តដោយសុចរិតដោយភាគីទាំងនោះ»។ ភាគីទាំងអស់ត្រូវគោរពបទប្បញ្ញត្តិក្នុងសន្ធិសញ្ញាដែលខ្លួនបានទទួលយក។ ការអនុវត្តដោយសុចរិតគឺពាក់ព័ន្ធនឹងលក្ខខណ្ឌដែលក្នុងនោះរដ្ឋរួចផុតពីកាតព្វកិច្ចរបស់ខ្លួន។*

## ២- អានុភាពសន្ធិសញ្ញាទៅលើរដ្ឋទីបី

*គោលការណ៍អានុភាពមិនដាច់ខាតនៃសន្ធិសញ្ញា ៖ «សន្ធិសញ្ញាពុំបង្កើតជាកាតព្វកិច្ច ឬសិទ្ធិណាមួយសម្រាប់រដ្ឋទីបីដោយពុំមានការឯកភាពរបស់រដ្ឋនោះទេ»(អនុសញ្ញាទីក្រុងវីយែន មាត្រា៣៤)។ ក្នុងការអនុវត្តគោលការណ៍អធិបតេយ្យភាពរបស់រដ្ឋ រដ្ឋមួយពុំអាចត្រូវបានគេដាក់កំហិតជាកាតព្វកិច្ច ឬសិទ្ធិដែលខ្លួនពុំបានស្នើសុំនោះទេ។*

*ប៉ុន្តែ គោលការណ៍អធិបតេយ្យភាពក៏អនុញ្ញាតឱ្យសន្ធិសញ្ញាទាំងអស់បង្កើតអានុភាពទៅលើរដ្ឋទីបីដែលបានឯកភាពដែរ។ បទប្បញ្ញត្តិមួយរបស់សន្ធិសញ្ញាបង្កើតជាកាតព្វកិច្ចសម្រាប់រដ្ឋមួយ ប្រសិនបើគ្រប់ភាគីសន្ធិសញ្ញានោះបានព្រមព្រៀមគ្នាបង្កើតកាតព្វកិច្ចនោះ និងប្រសិនបើរដ្ឋទីបីយល់ព្រមទទួលជាលាយល័ក្ខអក្សរដោយជាក់ច្បាស់(អនុសញ្ញាទីក្រុងវីយែន មាត្រា៣៥)។ ប្រសិនបើជាច្បាប់ដែលគូភាគីទាំងអស់ព្រមព្រៀងបង្កើត នោះការឯកភាពរបស់រដ្ឋទីបីក៏តម្រូវឱ្យមានផងដែរ ប៉ុន្តែផ្ទុយពីកាតព្វកិច្ច ការឯកភាពនេះអាចជាការឯកភាពដោយតុណ្ហីភាព។ «ការឯកភាពត្រូវបានសន្មតថាមាន ដរាបណាពុំមានការបង្ហាញផ្ទុយ លើកលែងតែសន្ធិសញ្ញាចែងផ្សេងពីនេះ»(អនុសញ្ញាទីក្រុងវីយែន មាត្រា៣៦)។*

*ករណីទាំងនេះពុំមែនជាការលើកលែងទៅលើគោលការណ៍អានុភាពមិនដាច់ខាតនៃសន្ធិសញ្ញាទេ។ រដ្ឋទីបី ទាំងខ្លួននៅជារដ្ឋទីបី បង្ហាញពីការឯកភាពរបស់ខ្លួនទៅលើសិទ្ធិ ឬកាតព្វកិច្ចក្នុងសន្ធិសញ្ញា។ នេះគឺជាយន្តការព្រមព្រៀងជាសាខា។ នេះគឺជាករណីនៃខរបស់ជាតិដែលទទួលបានការអនុគ្រោះបំផុត។*

*លើសពីនេះ វិធាននៃសន្ធិសញ្ញាមួយអាចក្លាយជាវិធានចាប់បង្ខំទៅលើរដ្ឋទីបី តាមការបំលែងខ្លួនជាវិធានទំនៀមទម្លាប់(អនុសញ្ញាទីក្រុងវីយែន មាត្រា៣៨)។ ក្នុងករណីនេះ នេះពុំមែនជាបទប្បញ្ញត្តិរបស់សន្ធិសញ្ញាទេដែលត្រូវដាក់កំហិតទៅលើរដ្ឋទីបី ប៉ុន្តែជាវិធានទំនៀមទម្លាប់ដែលបង្កើត ហើយដែលរដ្ឋទីបីបានទទួលយក។*

# ផ្នែកទី៥
# ជីវិតនៃសន្ធិសញ្ញា

## ១- សន្ធិសញ្ញាបន្តបន្ទាប់ និងការសើរើសន្ធិសញ្ញា

### ១.១- សន្ធិសញ្ញាបន្តបន្ទាប់(អនុសញ្ញាទីក្រុងវីយែន មាត្រា៣០)

*ការអនុវត្តសន្ធិសញ្ញាបន្តបន្ទាប់ដែលមានកម្មវត្ថុតែមួយដូចគ្នា អាចបង្កការលំបាក។ ការលំបាកទាំងនោះលេចឡើងក្នុងករណីវិសមិតភាពរវាងអត្ថបទនៃសន្ធិសញ្ញាទាំងពីរ។ ព្រោះបើសន្ធិសញ្ញាទាំងអស់បំពេញគ្នាទៅវិញទៅមក ហើយអាចអនុវត្តព្រមគ្នា នោះពុំមានការលំបាកទេ។ ប៉ុន្តែ អាចមានផលលំបាក ប្រសិនបើបញ្ញត្តិរបស់សន្ធិសញ្ញាទាំងពីរពុំអាចអនុវត្តបាន ហើយសន្ធិសញ្ញាទីមួយមិនត្រូវបាននិរាករណ៍នោះ។*

*វៀរលែងតែមាត្រា១០៣របស់ធម្មនុញ្ញសហប្រជាជាតិដែលចែងពីឧត្តមានុភាពនៃកាតព្វកិច្ចដែលកើតចេញពីធម្មនុញ្ញសហប្រជាជាតិទៅលើកាតព្វកិច្ចផ្សេងៗទៀត សម្រាប់សមាជិកអង្គការសហប្រជាជាតិ អនុសញ្ញាទីក្រុងវីយែនគ្រោងទុកនូវសម្មតិកម្មជាច្រើន។ សន្ធិសញ្ញាអាចចែងថា វានៅក្រោមចំណុះសន្ធិសញ្ញាចាស់ ឬសន្ធិសញ្ញាថ្មី។*

*កាលណាភាគីមួយចុះសន្ធិសញ្ញាពីរ «សន្ធិសញ្ញាដែលចុះមុនអាចអនុវត្តបានតែក្នុងពេលដែលបញ្ញត្តិរបស់វាមានសមិតភាពនឹងបទប្បញ្ញត្តិនៃសន្ធិសញ្ញាដែលចុះក្រោយប៉ុណ្ណោះ» (មាត្រា៣០ កថាខណ្ឌទី៣)។ ដូច្នេះ ក្នុងករណីវិសមិតភាព គេប្រកាន់យកបទប្បញ្ញត្តិថ្មីបំផុត ដោយអនុវត្តវិធានបច្ឆាកាលបដិប្បញ្ញត្តិទៅលើអាទិកាល(postérior derogate priori)។ ចំណុចនេះគឺមកបញ្ចប់ ឬកែប្រែសន្ធិសញ្ញាចាស់ យោងទៅតាមករណី។*

*កាលណាពុំមានអត្តសញ្ញាណរបស់ភាគីនៃសន្ធិសញ្ញាទាំងពីរ គប្បីបែងចែកស្ថានភាពជាពីរគឺ ៖*

- *នៅក្នុងទំនាក់ទំនងរវាងគូភាគីនៃសន្ធិសញ្ញាទាំងពីរ គេអនុវត្តបទប្បញ្ញត្តិថ្មីបំផុត។*
- *ប៉ុន្តែ នៅក្នុងទំនាក់ទំនងរវាងរដ្ឋមួយដែលជាភាគីនៃសន្ធិសញ្ញាទាំងពីរ និងរដ្ឋមួយដែលជាភាគីនៃសន្ធិសញ្ញាមួយក្នុងសន្ធិសញ្ញាទាំងពីរ គេអនុវត្តសន្ធិសញ្ញាដែលរួមគ្នារបស់ភាគីទាំងពីរ។ ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើមានវិសមិតភាពរវាងសន្ធិសញ្ញាទាំងពីរ ការដែលអនុវត្តសន្ធិសញ្ញាមួយ គឺជាការរំលោភសន្ធិសញ្ញាមួយទៀត។ ដូច្នេះ ការពុំគោរពរបស់រដ្ឋទៅលើកាតព្វកិច្ចអនុសញ្ញារបស់ខ្លួនត្រូវទទួលខុសត្រូវជាអន្តរជាតិទៅលើរដ្ឋជាភាគីសន្ធិសញ្ញាផ្សេងទៀតដោយសារពុំគោរពបញ្ញត្តិនោះ។ រដ្ឋផ្សេងទៀតបន្តអនុវត្តរវាងគ្នានឹងគ្នានូវសន្ធិសញ្ញាដែលខ្លួនជាគូភាគី។*

## ១.២- វិសោធនកម្មសន្ធិសញ្ញា(អនុសញ្ញាទីក្រុងវីយែន ពីមាត្រា៣៩ដល់៤១)

វិសោធនកម្មគឺជាការកែប្រែសន្ធិសញ្ញាពហុភាគីដែលគេអនុវត្តវិធានពាក់ព័ន្ធនឹងការធ្វើសន្ធិសញ្ញា។ សំណើធ្វើវិសោធនកម្មត្រូវចរចាដោយគូភាគី។ កិច្ចព្រមព្រៀងស្តីពីវិសោធនកម្មចងត្រឹមតែរដ្ឋទាំងឡាយណាដែលជាភាគីនៃកិច្ចព្រមព្រៀងនេះប៉ុណ្ណោះ។ ដូច្នេះ ចំពោះរដ្ឋដែលពុំមែនជាភាគីកិច្ចព្រមព្រៀងនេះ សន្ធិសញ្ញាត្រូវអនុវត្តតាមអត្ថបទចាស់ ហើយមានតែរដ្ឋព្រមព្រៀងលើការកែប្រែប៉ុណ្ណោះដែលអនុវត្តរវាងគ្នា និងគ្នានូវសន្ធិសញ្ញាដែលធ្វើវិសោធនកម្មរួច។

## ២- ការបកស្រាយសន្ធិសញ្ញា

ក្នុងច្បាប់អន្តរជាតិ រដ្ឋនីមួយៗមានសមត្ថកិច្ចបកស្រាយអត្ថន័យនៃសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន។ ប៉ុន្តែ ការបកស្រាយតាមការជ្រើសរើសរបស់ខ្លួនអាចយកមកពិភាក្សាបាន។ ចំណុចនេះមានន័យជាពិសេសចំពោះច្បាប់សន្ធិសញ្ញា ហើយនៅក្នុងអនុសញ្ញាទីក្រុងវីយែនមានមាត្រាចំនួនបីទាក់ទងនឹងការបកស្រាយដែលក្នុងនោះវាបង្ហាញពីវិធានទូទៅក្នុងការបកស្រាយ(ពីមាត្រា៣១ដល់៣៣)។ វិធានទូទៅគឺថា «សន្ធិសញ្ញាមួយត្រូវបកស្រាយដោយសុចរិតទៅតាមអត្ថន័យសាមញ្ញដែលត្រូវផ្តល់ឱ្យបទប្បញ្ញត្តិនៃសន្ធិសញ្ញានៅក្នុងបរិបទរបស់វា និងផ្អែកលើកម្មវត្ថុ និងគោលដៅរបស់សន្ធិសញ្ញា»(មាត្រា៣១ កថាខណ្ឌទី១។

សុចរិតត្រូវដឹកនាំការបកស្រាយអត្ថបទដែលជាបឋមត្រូវប្រើប្រាស់ន័យសាមញ្ញរបស់ពាក្យ។ ជាក់ស្តែង អត្ថបទសន្ធិសញ្ញាត្រូវសន្មតថា ឆ្លុះបញ្ចាំងពីអ្វីដែលគូភាគីចង់បាននៅពេលចុះកិច្ចព្រមព្រៀងរបស់ពួកគេ។ ន័យរបស់វាក្យសព្ទសន្ធិសញ្ញាត្រូវបកស្រាយក្នុងបរិបទរបស់វា។ អនុសញ្ញាទីក្រុងវីយែនបញ្ជាក់ថា ក្រៅពីអត្ថបទ បរិបទរួមមានបុព្វកថា និងឧបសម្ព័ន្ធ និងរាល់កិច្ចព្រមព្រៀង ឬលិខិតូបករណ៍ពាក់ព័ន្ធនឹងសន្ធិសញ្ញា។ អនុសញ្ញាបញ្ជាក់ផងដែរថា ត្រូវគិតគូរដល់ការអនុវត្តជាបច្ចាកាលនៅក្នុងការអនុវត្តសន្ធិសញ្ញា ពោលគឺការអនុវត្តបន្តបន្ទាប់របស់ភាគីសន្ធិសញ្ញា។ ដូច្នេះ គេចាត់ទុកថា របៀបដែលគូភាគីអនុវត្តសន្ធិសញ្ញាគឺជាសូចនាករដែលបង្ហាញពីរបៀបដែលភាគីយល់ពីកាតព្វកិច្ចរបស់ខ្លួន។ ចុងក្រោយ រាល់វិធានច្បាប់អន្តរជាតិសមហេតុផលទាំងអស់ដែលអាចអនុវត្តបានទៅលើទំនាក់ទំនងរបស់គូភាគីទាំងអស់នោះក៏ជាធាតុចាំបាច់មួយផងដែរក្នុងការបកស្រាយសន្ធិសញ្ញា។

នៅពេលការលំបាកក្នុងការបកស្រាយនៅបន្តមាន អនុសញ្ញានោះចែងថា ត្រូវស្វែងរកមធ្យោបាយបំពេញបន្ថែម ដូចជាការសិក្សាទៅលើការងារត្រៀម ឬការពិនិត្យទៅលើកាលៈទេសៈដែលសន្ធិសញ្ញាត្រូវបានធ្វើ(មាត្រា៣២)។

វិធីបកស្រាយដែលបញ្ជាក់តាមរបៀបនេះនឹងត្រូវយកទៅប្រើប្រាស់ដោយគូភាគីទាំងអស់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ដែលជាការបកស្រាយយថាភូត ឬដោយភាគីទីបី ដូចជាសាលក្រមជាដើមដែលជាការបកស្រាយពុំមែនយថាភូត។*

# ផ្នែកទី៦

## អវសានត្តនៃការសន្យាតាមអនុសញ្ញា

*ក្នុងផ្នែកទី៥នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាមានចែងពី«មោឃៈភាព ការផុតរលត់ និងការផ្អាកការអនុវត្តសន្ធិសញ្ញា»។ ប្រាកដណាស់ មោឃៈភាពគឺជាវិធីបញ្ចប់ការសន្យាតាមអនុសញ្ញា។*

### ១- មូលហេតុនៃអវសានត្តនៃការសន្យាតាមអនុសញ្ញា

*គូភាគីអនុសញ្ញាមួយអាចគ្រោងទុកពីបែបបទផុតរលត់របស់សន្ធិសញ្ញាផ្ទាល់ ឬឯកភាពគ្នាតាមក្រោយ(អនុសញ្ញាទីក្រុងវីយែន មាត្រា៥៤)។ អនុសញ្ញាទីក្រុងវីយែនបានលើកឡើងពីហេតុការណ៍ជាច្រើនដែលអាចបញ្ចប់ការសន្យាតាមអនុសញ្ញាមួយបាន។*

*• ការធ្វើសន្ធិសញ្ញា បច្ឆាគតអាចនាំឱ្យសន្ធិសញ្ញាបុរេគតផុតរលត់ ឬត្រូវផ្អាក នៅពេលចំណុចនោះកើតចេញពីសន្ធិសញ្ញា ឬនៅពេលគូភាគីទាំងអស់ឯកភាពបែបនេះ ឬប្រសិនបើមានភាពផ្ទុយរវាងអត្ថបទទាំងពីរ(អនុសញ្ញាទីក្រុងវីយែន មាត្រា៥៩)។*

*• ការលើកលែងការពុំអនុវត្ត(អនុសញ្ញាទីក្រុងវីយែន មាត្រា៦០)។ អវសានត្ត ឬការផ្អាកសន្ធិសញ្ញាមួយគឺជាផលវិបាកកើតចេញពីការរំលោភសន្ធិសញ្ញានោះដោយភាគីម្ខាង។ ដោយអនុវត្តគោលការណ៍បដិការ ភាគីផ្សេងទៀតត្រូវបានអនុញ្ញាតពុំឱ្យគោរពសន្ធិសញ្ញានេះដែរ ដោយបដិសេធមិនអនុវត្តសន្ធិសញ្ញានេះ។ ចំណុចនេះសន្មតថា មានការរំលោភធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាដែលអាចជាការច្រានចោលនៃសន្ធិសញ្ញា ឬការរំលោភបទប្បញ្ញត្តិសំខាន់ក្នុងការសម្រេចកម្មវត្ថុ ឬគោលដៅរបស់សន្ធិសញ្ញា(មាត្រា៦០ កថាខណ្ឌទី៣)។ លើសពីនេះ ការរំលោភដែលចោទឡើងនោះគឺជាការរំលោភធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាផ្ទាល់ ពុំមែនលើកាតព្វកិច្ចដទៃទេ(តុលាការយុត្តិធម៌អន្តរជាតិ សាលដីកាចុះថ្ងៃទី២៥ កញ្ញា ១៩៩៧ រឿងក្តីគម្រោង Gabcikovo-Nagymaros)។*

*• ការលេចឡើងនូវស្ថានភាពញាំងការអនុវត្តឱ្យមិនអាចទៅរួច(អនុសញ្ញាទីក្រុងវីយែន មាត្រា៦១)។ ការមិនអាចអនុវត្តបាននេះកើតចេញពីការបំបាត់ ឬបំផ្លាញជាស្ថាពរនូវកម្មវត្ថុ*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចាំបាច់បំផុតសម្រាប់ការអនុវត្តសន្ធិសញ្ញា។ ការមិនអាចអនុវត្តនេះអាចលើកឡើងបានលុះត្រាតែវាជាផលវិបាកកើតពីការរំលោភកាតព្វកិច្ចអន្តរជាតិមួយដោយរដ្ឋដែលលើកឡើង។

• ការប្តូរកាលៈទេសៈជាសារវន្ត Rebus sic stantibus (អនុសញ្ញាទីក្រុងវីយែន មាត្រា៦២)។ ក្នុងករណីនេះ ភាគីសន្ធិសញ្ញាមួយលើកឡើងពីការប្រែប្រួលទាំងស្រុងនូវស្ថានភាពដែលកើតពីការចរចា និងបដិសេធពុំបន្តអនុវត្តការសន្យារបស់ខ្លួន។ ខ Rebus sic stantibus អាចលើកយកមកសំអាងបានតែក្នុងលក្ខខណ្ឌខ្លះប៉ុណ្ណោះ ដើម្បីបញ្ចៀសចំណោទបញ្ហាលើការសន្យាដែលធ្វើឡើងតាមគោលការណ៍ Pacta sunt servanda។ តុលាការយុត្តិធម៌អន្តរជាតិបានរំឭកពីចរិតលក្ខណៈពិសេសរបស់ខនេះ ដើម្បីធានាដល់ស្ថិរភាពទំនាក់ទំនងអនុសញ្ញា។[៩៦]

ខនេះអាចត្រូវលើកឡើងក្នុងលក្ខខណ្ឌពីរគឺ ៖

• ទីមួយគឺ អត្ថិភាពកាលៈទេសៈត្រូវមានមូលដ្ឋានគ្រឹះនៃការឯកភាពរបស់គូភាគីដែលត្រូវចងដោយសន្ធិសញ្ញា ពោលគឺប្រសិនបើកាលៈទេសៈទាំងនោះមានលក្ខណៈខុសៗគ្នា គូភាគីនឹងពុំមានការសន្យាឡើយ។

• ទីពីរគឺជាលក្ខខណ្ឌត្រួត គឺការប្តូរបំប្លែងទាំងស្រុងនូវប្រភេទកាតព្វកិច្ចដែលរង់ចាំអនុវត្តទៅតាមសន្ធិសញ្ញា។ ការប្តូរនេះ«ធ្វើឱ្យកាតព្វកិច្ចទាំងនេះមានលក្ខណៈធ្ងន់ជាងមុន រហូតដល់ការអនុវត្តកាតព្វកិច្ចនោះខុសគ្នាខ្លាំងពីកាតព្វកិច្ចដែលគេបានចូលរួមពីដំបូង»។[៩៧] គឺគូភាគី ឬចៅក្រមដែលទទួលបណ្តឹង ជាអ្នកវាយតម្លៃថា តើមានលក្ខខណ្ឌគ្រប់ឬទេ។

លើសពីនេះ ការប្តូរកាលៈទេសៈជាសារវន្តពុំអាចលើកឡើងបាន ទាំងសម្រាប់បញ្ចប់សន្ធិសញ្ញាព្រំដែន និងទាំងពេលកើតមានការរំលោភការសន្យាអន្តរជាតិរបស់ភាគីដែលលើកឡើង (អនុសញ្ញាទីក្រុងវីយែន មាត្រា៦២ កថាខណ្ឌទី២)។

• ការផ្តាច់ទំនាក់ទំនងការទូត ឬកុងស៊ុល ជាគោលការណ៍ គឺពុំមានអានុភាពលើសន្ធិសញ្ញាទេ លើកលែងតែទំនាក់ទំនងនោះមានភាពចាំបាច់ដល់ការអនុវត្តសន្ធិសញ្ញា(អនុសញ្ញាទីក្រុងវីយែន មាត្រា៦៣)។

• ការលេចឡើងនូវបញ្ញត្តិចាប់បង្ខំថ្មីនៃច្បាប់អន្តរជាតិ(Jus Cogens) (អនុសញ្ញាទីក្រុងវីយែន មាត្រា៦៤)។ បញ្ញត្តិនេះលេចឡើងក្រោយការចូលជាធរមាននៃសន្ធិសញ្ញាដែលកម្មវត្ថុដើមស្របច្បាប់។ អាស្រ័យដោយភាពផ្ទុយទៅនឹងបញ្ញត្តិថ្មី សន្ធិសញ្ញាពុំស្របច្បាប់ត្រង់កម្មវត្ថុ ឬគោលដៅរបស់វា។ សន្ធិសញ្ញានឹងក្លាយជាមោឃៈ និងបញ្ចប់ក្នុងអនាគត។

[៩៦] *CIJ, arrêt du 25 septembre 1997, Affaire du projet Gabcikovo-Nagymaros, § 104.*

[៩៧] *CIJ, arrêt du 2 fevrier 1973, Compétence en matière de pêcheries, Rec. 1973, p. 65.*

## ២- បែបបទនៃអវសាន្តនៃការសន្យាតាមអនុសញ្ញា

• ការបដិសេធចោលគឺជាការទាមទារជាឯកតោភាគីរបស់ភាគីម្ខាងដែលមានបំណងបញ្ចប់ការសន្យារបស់ខ្លួន(ការដកខ្លួនចេញពីអង្គការមួយ)។ សន្ធិសញ្ញាអាចចែងពីករណីនេះ។ នៅពេលសន្ធិសញ្ញាមានភាពស្ងាត់ស្ងៀម ការបដិសេធចោលពុំអាចប្រព្រឹត្តទៅរួចឡើយ លើកលែងតែត្រូវបានឯកភាពថា ៖ «ភាគីមានចេតនាទទួលយកលទ្ធភាពនៃការបដិសេធចោល ឬការដកខ្លួនចេញ ឬនៅពេលដែលគេអាចបង្ហាញនូវសិទ្ធិនៃការបដិសេធចោល តាមរយៈប្រភេទនៃសន្ធិសញ្ញាបាន(អនុសញ្ញាទីក្រុងវីយែន មាត្រា៥៦)»។

• ការផុតរលត់សន្ធិសញ្ញាទាំងមូលនឹងកើតឡើងដោយសារមូលហេតុដដែលដែលគួបផ្សំបន្ថែមនឹងការលេចឡើងនូវធម្មនិយាមបញ្ញានៃច្បាប់អន្តរជាតិ។

• ការផ្អាកការអនុវត្តសន្ធិសញ្ញាអនុញ្ញាតឱ្យរង់ចាំលក្ខខណ្ឌអនុវត្តសន្ធិសញ្ញាត្រលប់មករកភាពប្រក្រតី។ នោះគឺជាវិធានការបណ្ដោះអាសន្នដែលពុំចោទជាបញ្ហាទៅលើសន្ធិសញ្ញាទេ ប៉ុន្តែទៅលើការអនុវត្តនៅក្នុងអំឡុងពេលជាក់លាក់ណាមួយ។

## ៣- សន្ធិសញ្ញា និងរដ្ឋទីបី

ការដឹងថា តើសន្ធិសញ្ញាមួយបង្កើតអានុភាពទៅលើរដ្ឋមិនមែនជាភាគីនោះនៅតែជាចំណោទមួយដែលត្រូវពិភាក្សាច្រើនដោយលទ្ធិ។ អនុលោមទៅតាមមាត្រា៣៨ តុលាការយុត្តិធម៌អន្តរជាតិអនុវត្តអនុសញ្ញាអន្តរជាតិទាំងឡាយណាដែលបង្កើតវិធានដែលទទួលស្គាល់ច្បាស់ក្រឡែតដោយរដ្ឋមានវិវាទ។ បទប្បញ្ញត្តិនេះសន្មតថា ពុំមានអនុសញ្ញាណាមួយដែលក្នុងនោះភាគីជាប់វិវាទពុំត្រូវបានចង ត្រូវយកមកពិចារណាដោយតុលាការឡើយ។[៨៨] បទប្បញ្ញត្តិនេះស្រប ទៅតាមឧបធារណ៍ដ៏ល្បីល្បាញរបស់ច្បាប់រ៉ូម៉ាំង *pacta sunt servenda* ដែលទទួលស្គាល់ដោយលំដាប់គតិយុត្តផ្ទៃក្នុង និងដែលឋិតក្នុងយោបល់ទូទៅនៃច្បាប់អន្តរជាតិ។

តាមតក្កវិជ្ជា យើងគប្បីត្រូវចាំទុកគោលការណ៍ដែលតាមរយៈនោះសន្ធិសញ្ញាត្រូវបង្កើតឡើងដោយផ្អែកលើការឯកភាព និងឆន្ទៈរួមរបស់ភាគីក្នុងការបង្កើតសិទ្ធិ និងកាតព្វកិច្ចរវាងភាគីជាប់កិច្ចសន្យាប៉ុណ្ណោះ ពោលគឺឆន្ទៈរួមក្នុងការបង្កើតឱ្យមានសិទ្ធិ និងកាតព្វកិច្ចមានអានុភាពគ្របដណ្ដប់កិច្ចព្រមព្រៀងអន្តរជាតិ។ (ដូច្នេះ ភស្តុតាងនៃការឯកភាពរបស់រដ្ឋទីបីចាំបាច់ណាស់ ព្រោះថាភស្តុតាងនោះដោះបន្ទុករដ្ឋទីបីពីកាតព្វកិច្ចអនុសញ្ញា។[៨៩]

[៨៨] B. MULAMBA MBUYI, *Introduction à l'étude des sources modernes du droit international public*, Bruxelles, Ed. Bruylant, 1999, p. 111.

[៨៩] B. MULAMBA MBUYI, *ibid.*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤- អានុភាពមិនដាច់ខាតនៃសន្ធិសញ្ញា

*ជាទូទៅ សន្ធិសញ្ញាចងតែគូភាគីជាប់កិច្ចសន្យាប៉ុណ្ណោះ។ សន្ធិសញ្ញាពុំបង្កើតសិទ្ធិ ឬកាតព្វកិច្ចសម្រាប់រដ្ឋទីបីទេ លុះត្រាណាតែរដ្ឋទីបីទាំងនេះឯកភាពដូច្នេះ។ ការពិតទៅ អានុភាពមិនដាច់ខាតនៃសន្ធិសញ្ញាកើតចេញពីអធិបតេយ្យភាពរបស់រដ្ឋ និងស្វយ័តភាពឆន្ទៈដែលលើកឡើងថាពុំមានរដ្ឋណាមួយអាចចងខ្លួនឯងបានទេ លុះត្រាតែតាមរយៈកិច្ចដែលចេញពីឆន្ទៈផ្ទាល់របស់ខ្លួន ដូចដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានគូសបញ្ជាក់ក្នុងរឿងក្ដីស្ដីពីរោងចក្រឆូហ្សូ( Usine de Chorzów) ចុះថ្ងៃទី១៥ ឧសភា ១៩២៦។*

*ការរស់រានរបស់សន្ធិសញ្ញាមួយអាស្រ័យលើឆន្ទៈពិតប្រាកដរបស់រដ្ឋមួយ ហើយការទាមទារឱ្យមានការឯកភាពក្នុងករណីនៃសន្ធិសញ្ញាមួយដែលចែងពីកាតព្វកិច្ចសម្រាប់រដ្ឋទីបី ត្រូវច្បាស់ក្រឡែត និងជាលាយលក្ខណ៍អក្សរ។*[៩០]

*បែបនេះ កាតព្វកិច្ចទាំងនេះកើតចេញពីការឯកភាពរបស់រដ្ឋទាំងនេះ លុះត្រាតែមានការឯកភាពផ្សេងពីនេះ។ ដូច្នេះ យោងតាមគោលការណ៍អានុភាពមិនដាច់ខាតនៃសន្ធិសញ្ញា ពុំមានរដ្ឋណាមួយអាចលើកយកកាតព្វកិច្ចនៃសន្ធិសញ្ញាមួយដែលខ្លួនពុំមែនជាភាគីមកសំអាងបានទេ។ ឧទាហរណ៍ ពាក់ព័ន្ធនឹងវិវាទជាមួយប្រទេសបារាំងស្ដីអំពីអធិបតេយ្យភាពលើកោះClipperton ប្រទេសម៉ិចស៊ិកូបានសាកល្បងជំទាស់ទាំងឥតបានផលទៅនឹងបារាំងនៅត្រង់បទប្បញ្ញត្តិមួយចំនួននៃកិច្ចទីក្រុងប៊ែឡាំង( Acte de Berlin) ឆ្នាំ១៩៨៥ដែលមានបារាំងជាភាគី តែពុំមែនមានម៉ិចស៊ីកូជាភាគីទេ។ មជ្ឈត្តករបានច្រានចោលការទាមទារនេះទាំងស្រុង និងដោយសាមញ្ញបំផុត។*[៩១]

*ក្នុងរឿងក្ដីមួយទៀតនោះ មជ្ឈត្តករក៏បានប្រកាសផងដែរថា រដ្ឋាភិបាលក្រិចដែលពុំមែនជាហត្ថលេខីសន្ធិសញ្ញាកុងស្តង់ទីណូប( Constantinople) ពុំមានមូលដ្ឋានគតិយុត្តធ្វើការទាមទារអ្វីមួយដោយផ្អែកលើសេចក្ដីបញ្ជាក់នៃសន្ធិសញ្ញាជាសត្យានុម័តបានទេ។ ប៉ុន្តែ វឌ្ឍនភាពនៃអង្គការអន្តរជាតិមានទំនោរបង្កើនសម្មតិកម្មដែលសម្រាប់លើកលែងដល់គោលការណ៍មិនដាច់ខាតនៃសន្ធិសញ្ញា ទោះជាកិច្ចព្រមព្រៀងអន្តររដ្ឋដែលកែប្រែដំណើរប្រព្រឹត្តទៅរបស់អង្គការអន្តរជាតិ ហើយដែលចូលជាធរមានភាគច្រើន ឬទោះជាកិច្ចព្រមព្រៀងធ្វើឡើងដោយអង្គការអន្តរជាតិ និងដាក់កំហិតទៅលើរដ្ឋសមាជិកក្ដី។*[៩២] *សន្ធិសញ្ញាអន្តររដ្ឋ និងសន្ធិសញ្ញាដែលមានអង្គការអន្តរជាតិជាសមាជិកខុសគ្នាត្រង់បែបបទបង្ហាញការឯកភាពផ្នែកច្បាប់ ឬកាតព្វកិច្ចរបស់សន្ធិសញ្ញាដែលរដ្ឋនោះ ឬអង្គការនោះពុំមែនជាភាគី និងខុសគ្នាត្រង់សច្ចធារណ៍នៃការឯកភាពពុំដាក់លាក់។*

---

[៩០] *ibid.*

[៩១] *P. DAILLER et A. PELLET, op. cit., p. 243.*

[៩២] *ibid.*

# ជំពូក៦
# អង្គការមិនមែនរដ្ឋាភិបាល បុគ្គលឯកជន និងនីតិបុគ្គល

## ផ្នែកទី១
## អង្គការមិនមែនរដ្ឋាភិបាល

អង្គការមិនមែនរដ្ឋាភិបាលគឺត្រូវបានមើលឃើញថា ជាក្រុមនៃបុគ្គល ឬសង្គមដែលត្រូវបានបង្កើតឡើងដោយស្ម័គ្រចិត្ត ហើយធ្វើសកម្មភាពដោយឯករាជ្យពីរដ្ឋាភិបាល ឈរលើមូលដ្ឋាននៃការមិនស្វែងរកប្រាក់ចំណេញ។

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនត្រូវបានបង្កើតឡើងក្រោមប្រព័ន្ធច្បាប់ជាតិតែមួយ ប៉ុន្តែសកម្មភាពរបស់វាមានលក្ខណៈអន្តរជាតិ ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ដែលត្រូវបានបង្កើតឡើងនៅក្រោមច្បាប់នៃប្រទេសស្វីស ហើយសមាជិករបស់គណៈកម្មាធិការនេះគឺសុទ្ធតែជាជនជាតិស្វីសទាំងអស់។ ប៉ុន្តែអង្គការសន្តិភាពបៃតងអន្តរជាតិដែលមានទីស្នាក់-ការនៅក្នុងប្រទេសហូល្លង់ មានការិយាល័យជាតិ និងតំបន់ចំនួន២៧ ក្នុងការធ្វើប្រតិបត្តិការក្នុងរដ្ឋចំនួន៤១ដែលមានអាជ្ញាប័ណ្ណក្នុងការប្រើប្រាស់ឈ្មោះ សន្តិភាពបៃតង។ IUCN/សហភាពអភិរក្សពិភពលោកដែលមានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលជាង៨០០ ព្រមទាំងមានរដ្ឋជាសមាជិកចំនួន៨០ និងទីភ្នាក់ងាររដ្ឋាភិបាលចំនួន១១០ផងដែរ។

វិទ្យាស្ថាននីតិអន្តរជាតិដែលត្រូវបានបង្កើតឡើងនៅប្រទេសបារាំងក្នុងឆ្នាំ១៨៧៣ មានសមាជិកចំនួន១២០រូបដែលត្រូវបានបោះឆ្នោតដោយវិទ្យាស្ថាន ផ្អែកទៅលើស្នាដៃរបស់ពួកគេក្នុងផ្នែកច្បាប់អន្តរជាតិ។ វិទ្យាស្ថាននេះអនុម័តនូវដំណោះស្រាយដែលកំណត់នូវអ្វីដែលវិទ្យា-ស្ថានត្រូវពិចារណាថាជាវិធាននៃច្បាប់អន្តរជាតិ។

សមាគមនីតិអន្តរជាតិគឺជាអង្គការអ្នកជំនាញមួយនៅក្នុងវិស័យនៃច្បាប់អន្តរជាតិដែល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងនោះរួមមានអង្គការសាកលមួយ និងសាខាជាច្រើនទៀតនៅក្នុងបណ្តារដ្ឋជាច្រើន។

អង្គការមិនមែនរដ្ឋាភិបាលចូលរួមកាន់តែច្រើនទៅៗនៅក្នុងការចរចាសន្ធិសញ្ញាពហុភាគីក្នុងនាមជាអ្នកសង្កេតការណ៍ដោយធ្វើការអធិប្បាយលើអត្ថបទសេចក្តីព្រាងសន្ធិសញ្ញា និងដោយព្យាយាមជះឥទ្ធិពលទៅលើទស្សនៈរបស់រដ្ឋជាច្រើន។ អង្គការមិនមែនរដ្ឋាភិបាលក៏បានចូលរួមយ៉ាងសកម្មផងដែរក្នុងសន្និសីទរបស់បណ្តារដ្ឋភាគីនៃរបបសន្ធិសញ្ញាពហុភាគីដែលសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើង។ អង្គការមិនមែនរដ្ឋាភិបាលក៏បានដាក់នូវមតិយោបល់សង្ខេបនានាដោយផ្ទាល់(ឬតាមរយៈរដ្ឋសមាជិក)ទៅកាន់តុលាការផ្សេងៗផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលក៏សកម្មនៅក្នុងការតាមដានទៅលើឥរិយាបថរបស់រដ្ឋ ដូចជាទៅលើបញ្ហានៃការអនុវត្តរបបសិទ្ធិមនុស្សដែលជាមធ្យោបាយកែតម្រូវឱ្យរដ្ឋគោរពការអនុវត្ត។ ការរិះគន់របស់អង្គការមិនមែនរដ្ឋាភិបាលបង្ហាញពីការខ្វះខាតនូវគណនេយ្យភាពជាទូទៅរបស់រដ្ឋទាំងអស់នោះ។ អង្គការមិនមែនរដ្ឋាភិបាលគឺមិនមែនប្រជាធិបតេយ្យទេ ក្នុងអត្ថន័យធម្មតានៃវាក្យស័ព្ទ។

## ១- រូបវន្តបុគ្គល និងក្រុម

កិច្ចការពារលើបុគ្គលបានរីកចម្រើនជាខ្លាំង ជាពិសេសជាមួយការកើនឡើងយ៉ាងគំហុកនៃច្បាប់ស្តីពីសិទ្ធិមនុស្ស និងមនុស្សធម៌អន្តរជាតិនាចុងស.វទី២០។ បច្ចុប្បន្ននេះ រូបវន្តបុគ្គលមិនអាចត្រូវកាត់ទោសពីបទឧក្រិដ្ឋសម្រាប់ការបំពានលើច្បាប់អន្តរជាតិ រួមទាំងនៅចំពោះមុខតុលា-ការអន្តរជាតិដែរ។ សន្ធិសញ្ញាសេដ្ឋកិច្ចផ្សេងៗជាច្រើន ដូចជាសន្ធិសញ្ញាស្តីពីពាណិជ្ជកម្ម និងវិនិយោគគឺត្រូវបានរចនាឡើងដើម្បីបង្កើតនូវសិទ្ធិ សម្រាប់បុគ្គលម្នាក់ៗ ឬក៏ក្រុមហ៊ុនសាជីវកម្មក្នុងការធ្វើបណ្តឹងលើបណ្តារដ្ឋនៅចំពោះមុខតុលាការជាតិ ឬអន្តរជាតិ សម្រាប់ទាមទារនូវសិទ្ធិត្រឹមត្រូវស្របច្បាប់របស់ខ្លួន។ ស្ថិតក្នុងស្ថានភាពកំណត់មួយ រូបវន្តបុគ្គលអាចប្តឹងរដ្ឋរបស់ខ្លួនដើម្បីទាមទារនូវសិទ្ធិត្រឹមត្រូវរបស់ខ្លួន ដូចជានៅចំពោះមុខតុលាការសិទ្ធិមនុស្សអឺរ៉ុបជាដើម។

សញ្ជាតិរបស់បុគ្គលម្នាក់ៗគឺជាទិដ្ឋភាពសំខាន់មួយពាក់ព័ន្ធនឹងសិទ្ធិ និងកិច្ចការពារដែលត្រូវបានផ្តល់ជូនពួកគេនៅក្រោមច្បាប់អន្តរជាតិ។ រដ្ឋនីមួយៗមានសិទ្ធិក្នុងការកំណត់ពីវិធីសាស្ត្រដែលបុគ្គលម្នាក់ត្រូវទទួលបាននូវសញ្ជាតិ។

ក្រុមបុគ្គលក៏អាចមានសិទ្ធិ និងកាតព្វកិច្ចខ្លះៗនៅក្រោមច្បាប់អន្តរជាតិ ឧទាហរណ៍ដូចជាក្រុមជនជាតិស៊ែប បូស្នៀ ឬឃើឌ(Kurdes)នៃប្រទេសអ៊ីរ៉ង់ អ៊ីរ៉ាក់ និងតួគី។ ពួកគេទាំងអស់នេះត្រូវបានគេសំដៅទៅលើក្រុមជនជាតិភាគតិច។ សិទ្ធិរបស់ជនជាតិដើមកាន់តែត្រូវបានគេទទួលស្គាល់ជាបន្តបន្ទាប់ក្នុងសន្ធិសញ្ញាអន្តរជាតិ(អនុសញ្ញាស្តីពីជីវៈចម្រុះ)។ ការចូលរួមរបស់ពួកគេក្នុងប្រព័ន្ធច្បាប់អន្តរជាតិ និងសិទ្ធិដែលត្រូវបានព្រមព្រៀងផ្តល់ជូនពួកគេ គឺត្រូវបានប្រគល់ជូន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងត្រួតពិនិត្យរដ្ឋនានា ឬអង្គការអន្តរជាតិ។

**២- នីតិបុគ្គល**

ក្នុងខណៈពេលដែលក្រុមហ៊ុនសាជីវកម្មគឺត្រូវបានចាត់ទុកថា មានសញ្ជាតិរបស់រដ្ឋដែលនៅក្នុងរដ្ឋនោះក្រុមហ៊ុននេះធ្វើសាជីវកម្ម សកម្មភាពរបស់ក្រុមហ៊ុនពហុជាតិ(MNCs)អាចមានវិសាលភាពជាសាកល។ មានមធ្យោបាយផ្សេងៗជាច្រើនដែលក្រុមហ៊ុនពហុជាតិអាចពាក់ព័ន្ធក្នុងការបង្កើតការបកស្រាយ និងការអនុលោមតាមច្បាប់អន្តរជាតិ។ នៅក្នុងស្ថានភាពខ្លះ ក្រុមហ៊ុនពហុជាតិចូលរួមដោយផ្ទាល់នៅក្នុងការបង្កើតកិច្ចព្រមព្រៀងអន្តរជាតិ ដូចជាតួនាទីតំណាងនិយោជកក្នុងភាពតំណាងត្រីភាគីនៅក្នុងអង្គការពលកម្មពិភពលោកជាដើម។ ក្រុមហ៊ុនពហុជាតិបានអភិវឌ្ឍ ឬទទួលយកបទដ្ឋានគតិយុត្តអន្តរជាតិក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងបណ្តារដ្ឋនានាដែលពួកគេធ្វើពាណិជ្ជកម្មជាមួយ។ ពួកគេបានធ្វើអន្តរជាតិកម្មកិច្ចសន្យាវិនិយោគរបស់ពួកគេជាមួយបណ្តារដ្ឋនានាទាំងនោះ។ ក្រុមហ៊ុនពហុជាតិគឺជាតួអង្គសំខាន់ផងដែរក្នុងវិស័យនៃច្បាប់អន្តរជាតិឯកជន ពីព្រោះសកម្មភាពរបស់ពួកគេពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច។ ក្រុមហ៊ុនពហុជាតិក៏ជាប្រភព( និងគោលដៅ)នៃកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍទម្រង់ខ្លះៗនៃវិធានបទដ្ឋានស្របច្បាប់ដែលមិនចងជាកាតព្វកិច្ច( ច្បាប់ទន់)ដែលជារឿយៗកើតចេញមកពីច្បាប់អន្តរជាតិពាក់ព័ន្ធនឹងការងារ សិទ្ធិមនុស្ស និងបរិស្ថាន។

# ជំពូក៧
# នីតិអាស៊ាន

## ផ្នែកទី១
## សេចក្ដីផ្ដើមទូទៅ

អាស៊ានត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៧ ប៉ុន្តែការប៉ុនប៉ងក្នុងការបង្កើតគឺត្រូវបានធ្វើឡើងតាំងពីមុននេះទៅទៀត។ អាស៊ីអាគ្នេយ៍គឺជាពាក្យដែលមានប្រភពដើមមកពីពាក្យរបស់អង់គ្លូ-សាក់សុងដែលត្រូវបានប្រើប្រាស់ថ្មីៗក្នុងឆ្នាំ១៩៤៣ដោយមេបញ្ជាការយោធាមួយរូបក្នុងអំឡុងសង្គ្រាមប៉ាស៊ីហ្វិក។ អាស៊ានមិនប្រមូលផ្ដុំប្រទេសទាំងអស់ទេ។ ការពិត ពាក្យនេះគឺជាពាក្យចាស់មួយ និងមានរួចមកហើយនៅក្នុងភូមិសាស្ត្រពិភពលោក តាមរយៈអ្នកភូមិសាស្ត្រជាតិបារាំងម្នាក់ដែលទទួលឥទ្ធិពលមកពីអ្នកភូមិសាស្ត្រជាតិអូទ្រីស ក្នុងឆ្នាំ១៩០៩។ ពាក្យអាស៊ីអាគ្នេយ៍លេចឡើង និងបង្កើតឡើងដោយអ្នកភូមិសាស្ត្រជាតិអូទ្រីស និងត្រូវបានយកមកប្រើប្រាស់ឡើងវិញដោយភូមិសាស្ត្រពិភពលោក។

អាស៊ីអាគ្នេយ៍ត្រូវបានចាត់ទុកថា ជាទីប្រសព្វមួយនៃអារ្យធម៌ឥណ្ឌា និងចិនក្នុងតំបន់ឥណ្ឌូ-ចិន។ ប្រទេសបារាំងបានផ្ដល់វាក្យស័ព្ទនេះ គឺកូសាំងស៊ីន ហើយជាបន្តបន្ទាប់ចក្រភពបារាំងបានធ្វើការពង្រីកខ្លួន ដើម្បីក្ដោបក្ដាប់យកឥណ្ឌូចិនបារាំងតាមភូមិសាស្ត្រ និងវប្បធម៌។

អាស៊ានគឺជាបណ្ដុំចាក់ស្រេះនៃសាសនា នយោបាយ រាជានិយម របបយោធា របបប្រជាធិបតេយ្យ និងរបបប្រធានាធិបតី។ អាស៊ានមានភាពសម្បូរបែបនៅក្នុងទិដ្ឋភាពជាតិពន្ធុវិទ្យា និងសម្បូរហូរហៀរនូវព្រៃត្រូពិច តែក៏បានបាត់បង់យ៉ាងឆាប់រហ័សដែរ។

ជាទីប្រសព្វរវាងមហាសមុទ្រពីរ ៖ មហាសមុទ្រប៉ាស៊ីភិច និងឥណ្ឌា។ ដែសមុទ្រឥណ្ឌូនេស៊ីជាកន្លែងដឹកជញ្ជូនប្រេងកាត ពោលគឺតំបន់ភូមិសាស្ត្រនយោបាយ(*géopolitique*)។

ជាតំបន់ដែលបានទទួលរងនូវអាណានិគមគ្រប់យ៉ាង ៖ ការមកដល់របស់អ្នកជំនួញនៃតំបន់អារ៉ាប៊ីដែលបានសាយភាយសាសនាអ៊ីស្លាម។ មានពួកអាណានិគមបារាំង អេស្ប៉ាញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព័ទ្ធយប្អាល់ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក ជប៉ុន-ល-។ រដ្ឋតែមួយដែលគេចផុតពីអាណានិគម គឺសៀម(Siam)។

## គឺជាតំបន់ដ៏សំខាន់មួយ

អាស៊ានមានប្រជាជនជាង៦០០លាននាក់ ច្រើនជាងសហគមន៍អឺរ៉ុប(៥០០លាន)។ នេះគឺជាទីផ្សារមួយដ៏ធំ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និងប្រទេសចិនបង្កើតបានជាទីផ្សារដែលមានប្រជាជន២ពាន់លាននាក់ ខណៈដែលពិភពលោកមានប្រជាជនប្រមាណ៧ពាន់លាននាក់។ អាស៊ានបូក៦បង្កើតបានជាទីផ្សារដ៏ធំមហិមាមួយ។

ការប៉ុនប៉ងលើកដំបូងៗក្នុងការរួបរួមបង្កើតទីផ្សារនេះចេញមកពីការផ្តួចផ្តើមដោយសហគមន៍អឺរ៉ុប ឬដោយមហាអំណាចលោកខាងលិច ៖ (១) ក្នុងឆ្នាំ១៩៤៦ មានការបង្កើតគម្រោងលើកទីមួយនៅក្នុងតំបន់ពាក់ព័ន្ធនឹងទន្លេមេគង្គ គឺការបង្កើតគណៈកម្មការទន្លេមេគង្គមួយ សម្រាប់ការលើកតម្កើងទន្លេមួយនេះ។ (២) ក្នុងឆ្នាំនោះផងដែរ មានការបង្កើតគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍ប្រចាំនៅអង្គការសហប្រជាជាតិ។ (៣) ក្រោមគំនិតផ្តួចផ្តើមរបស់ចក្រភពអង់គ្លេស គឺការបង្កើតផែនការកូឡុំបូ(Colombo) ចុះឆ្នាំ១៩៥០ ដែលបានរួមបញ្ចូលចក្រភពអង់គ្លេស និងបណ្តាប្រទេសដែលជាសមាជិកនៃអង្គការខុមម៉ិនវៀល(Commonwealth)។ អង្គការខុមម៉ិនវៀលប្រមូលផ្តុំនូវអតីតរដ្ឋរបស់ប្រទេសអង់គ្លេសទាំងអស់(៥៥រដ្ឋ) ហើយដែលមានម្ចាស់ស្រ្តីអេលីហ្សាបែតទី២ជាប្រមុខ។

ប្រព័ន្ធផែនការកូឡុំបូនេះដែលមានគោលដៅរក្សាការពារផលប្រយោជន៍របស់ចក្រភពអង់គ្លេស ពុំមានដំណើរការប្រកបដោយប្រសិទ្ធភាពទេ។

ក្នុងទិដ្ឋភាពយោធាវិញ គេបានប៉ុនប៉ងបង្កើតអង្គការសេអាតូ(SEATO)(ដូចជាOTAN)ក្នុងទសវត្សឆ្នាំ៥០ដោយមូលហេតុសំខាន់គឺថា មានការគំរាមកំហែងរបស់កុម្មុយនីស(ឆ្នាំ១៩៤៩ ពួកកុម្មុយនីសបានទទួលជ័យជម្នះប្រទេសចិន) មានសង្គ្រាមឥណ្ឌូចិន និងដើម្បីការពារបណ្តារដ្ឋដែលស្និទ្ធនឹងលោកខាងលិច ប្រឆាំងទៅនឹងការគំរាមកំហែងរបស់ពួកកុម្មុយនីស ហើយអង្គការនេះបានឈប់ដំណើរការក្នុងឆ្នាំ១៩៧៧។

នៅចំពោះមុខការបរាជ័យនៃគំនិតផ្តួចផ្តើមទាំងនេះ មានគំនិតផ្តួចផ្តើមដទៃទៀតក្នុងអំឡុងឆ្នាំ១៩៦០ ពោលគឺការប៉ុនប៉ងបង្កើតអង្គការASAដែលរួមមាន២ប្រទេស ៖ ម៉ាឡេស៊ី និងហ្វីលីពីន (ប្រទេសទាំងពីរបានចុះសន្ធិសញ្ញា ប៉ុន្តែមិនត្រូវបានអនុវត្តទេ)។ មានកិច្ចផ្តួចផ្តើមដទៃទៀតត្រូវបានធ្វើឡើង គឺកិច្ចផ្តួចផ្តើម Maphilindo ដែលជាការរួបរួមគ្នារវាងប្រទេសបី តែត្រូវបានបរាជ័យនៅពេលសង្គ្រាមបានផ្ទុះឡើងរវាងប្រទេសឥណ្ឌូនេស៊ី និងប្រទេសម៉ាឡេស៊ី។ ការបង្កើតប្រទេស

ម៉ាឡេស៊ី ក្នុងឆ្នាំ១៩៦៣(ក្រោយឯករាជ្យឆ្នាំ១៩៥៧) ៖ ការភ្ជាប់រដ្ឋសាបា និងសារ៉ាវ៉ាក់ដែលស្ថិតនៅលើកោះប័រនេអូទៅក្នុងទឹកដីម៉ាឡេស៊ី។ ប្រទេសឥណ្ឌូនេស៊ីមិនបានយល់ព្រមទៅនឹងការភ្ជាប់រដ្ឋពីរនេះជាមួយប្រទេសម៉ាឡេស៊ីទេ។

ក្នុងឆ្នាំ១៩៦៧ មានការប៉ុនប៉ងថ្មីមួយទៀតក្នុងការបង្កើតសមាគមមួយដែលផ្តល់កំណើតឱ្យអាស៊ាន(ASEAN)។ រដ្ឋចំនួន៥បានអនុម័តអត្ថបទបង្កើតសមាគមនេះ គឺសេចក្តីប្រកាសទីក្រុងបាងកកចុះហត្ថលេខាដោយរដ្ឋស្ថាបនិកទាំង៥ មាន ៖ ឥណ្ឌូនេស៊ី ហ្វីលីពីន ម៉ាឡេស៊ី សិង្ហបុរី និងថៃឡង់ដ៍។ គោលដៅទីមួយ គឺប្រយុទ្ធប្រឆាំងនឹងរបបកុម្មុយនីស។ សង្គ្រាមវៀតណាមកំពុងក្តៅគគុកក្រោមការដឹកនាំរបស់សហរដ្ឋអាមេរិក។ ប្រទេសទាំងប្រាំនេះពុំមានទំនាក់ទំនងការទូតជាមួយនឹងប្រទេសកុម្មុយនីសឡើយ។

សមាគមនេះមិនមែនជាអង្គការអន្តរជាតិទេ តែជាសមាគមប្រជាជាតិមួយ។ សមាគមនេះបានក្លាយជាអង្គការអន្តរជាតិមួយក្នុងឆ្នាំ២០០៧ ជាមួយនឹងធម្មនុញ្ញមួយ។ វាមានគោលដៅតែមួយគត់ គឺប្រយុទ្ធប្រឆាំងនឹងចលនាកុម្មុយនីសលើពិភពលោក តាមរយៈការការពារយោធា។ ឧបសគ្គនានាទាក់ទងទៅនឹងរចនាសម្ព័ន្ធរបស់សមាគម ៖

- **ទំហំខុសគ្នា ៖** ប្រទេសឥណ្ឌូនេស៊ី និងប្រទេសសិង្ហបុរី។
- **រចនាសម្ព័ន្ធនយោបាយ ៖** ទិដ្ឋភាពជាតិពន្ធុ និងសាសនា ៖ រដ្ឋកាន់ព្រះពុទ្ធសាសនា និងអ៊ីស្លាម។
- **ឧបសគ្គសេដ្ឋកិច្ច ៖** សេដ្ឋកិច្ចមានការប្រកួតប្រជែងគ្នា និងមិនបំពេញបន្ថែមឱ្យគ្នាឡើយ ៖ ពួកគេនាំចេញផលិតផលដូចគ្នានៅលើទីផ្សារ។
- **ឧបសគ្គទេសកាលនានា ៖** (១) ប្រតិកម្មមិនច្បាស់លាស់ទៅលើបញ្ហាសង្គ្រាមនៅវៀត-ណាមដូចជាមានអព្យាក្រឹតខ្លាំងដូចជាប្រទេសឥណ្ឌូនេស៊ី(ចលនាមិនចូលបក្សសម្ព័ន្ធ) និន្នាការប្រឆាំងកុម្មុយនីស ដូចជាប្រទេសថៃឡង់ដ៍។(២) បញ្ហាព្រំដែន និងទឹកដីរវាងប្រទេសទាំងនេះ ៖ រវាងប្រទេសប្រ៊ុយណេ និងប្រទេសម៉ាឡេស៊ី(នៅកោះប័រនេអូ មានដែនដីពីរចំណែក ហើយនឹងនៅកណ្តាលទឹកដីនេះ មានប្រទេសប្រ៊ុយណេដែលទាមទារយកតំបន់នោះ ក្រោយពេលដែលកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខាក្នុងរយៈពេលប៉ុន្មានថ្ងៃ)។

សេចក្តីប្រកាសទីក្រុងបាងកក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ សម្រាប់បង្កើតអាស៊ាន។

## គោលដៅរបស់អាស៊ាន (១៥) ៖

- ថែរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់។
- អភិវឌ្ឍកិច្ចសហប្រតិបត្តិការក្នុងតំបន់ ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វប្បធម៌។

• បង្កើតទីផ្សាររួមតែមួយគត់មួយ។

• ប្រយុទ្ធប្រឆាំងភាពក្រីក្រ កាត់បន្ថយភាពក្រីក្រ និងគម្លាតនៃការអភិវឌ្ឍក្នុងសមាគម។

• លើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។

• លើកតម្កើងសុខមាលភាពប្រជាជន។

ដើម្បីឈានទៅដល់គោលដៅទាំងអស់នេះ ត្រូវគោរពគោលការណ៍មួយចំនួនដែលដឹកនាំអាស៊ាន ដូចជា ៖

• គោរពឯករាជ្យភាព អធិបតេយ្យភាព បូរណភាពដែនដី និងអត្តសញ្ញាណជាតិរបស់រដ្ឋសមាជិក។

• ការទទួលខុសត្រូវរួមរបស់រដ្ឋសមាជិកក្នុងការថែរក្សាសន្តិភាព និងសន្តិសុខតំបន់។

• គោលការណ៍មិនប្រើប្រាស់កម្លាំងក្នុងការដោះស្រាយជម្លោះផ្សេងៗ និងផ្តល់អាទិភាពដល់ការដោះស្រាយដោយសន្តិវិធី។

• គោលការណ៍មិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋសមាជិក។

• គោរពគ្រប់វប្បធម៌ ភាសា និងសាសនារបស់ប្រជាជនអាស៊ាន។

**សមាគមនេះបានពង្រីកជាបន្តបន្ទាប់ ៖** ឆ្នាំ១៩៦៧(៥ប្រទេស) ឆ្នាំ១៩៨៤(៦ប្រទេស) ប្រទេសប្រ៊ុយណេបានទទួលឯករាជ្យ ឆ្នាំ១៩៩៥(សមាជិកទី៧ គឺប្រទេសវៀតណាម) ឆ្នាំ១៩៩៧ (ប្រទេសឡាវ និងភូមា) និងឆ្នាំ១៩៩៩(ប្រទេសកម្ពុជា)។ សមាគមក៏បានគ្រោងទុកថានឹងមានរដ្ឋសមាជិកទី១១ក្នុងឆ្នាំ២០១២ គឺទីម័រខាងកើតដែលនឹងទទួលបានឯករាជ្យក្នុងឆ្នាំ២០០២។

**តំបន់ភាវូបនីយកម្ម ៖** ទាក់ទងនឹងការប្រមូលផ្តុំ ឬមជ្ឈការលំហូរសេដ្ឋកិច្ចរវាងប្រជាជាតិដែលមានទីតាំងភូមិសាស្ត្រជិតគ្នា។

**តំបន់និយម ៖** ទាក់ទងនឹងតំបន់និយមនេះ វាក្យស័ព្ទនេះគឺសំដៅតែមួយគត់ដល់ស្ថាប័នភាវូបនីយកម្មនៃទំនាក់ទំនងអន្តររដ្ឋរវាងប្រជាជាតិនានាដែលមានទីតាំងភូមិសាស្ត្រជិតខាងគ្នា (ទិដ្ឋភាពនយោបាយ)។

**សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ៖** ការរួមបញ្ចូលគ្នារវាងតំបន់ភាវូបនីយកម្ម និងតំបន់និយម។

នៅពេលអាស៊ានត្រូវបានបង្កើតក្នុងឆ្នាំ១៩៦៧ នៅលើជាតួរួមដ៏តិចតួចមួយ និងបានចាប់-ផ្តើមជាមួយនឹងអ្វីៗដែលធម្មតាបំផុត ពោលគឺមានក្របខ័ណ្ឌស្ថាប័នដ៏ធូរស្រាល។ ធម្មនុញ្ញឆ្នាំ២០០៧ មានគោលដៅប្រែក្លាយអាស៊ានទៅជាសហគមន៍មួយក្នុងឆ្នាំ២០១៥។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី២
## ប្រវត្តិនៃការអភិវឌ្ឍស្ថាប័នអាស៊ាន

*គេត្រូវស្វែងរកសមតារវាងការការពារអធិបតេយ្យភាពជាតិ និងអាជ្ញាធរតំបន់។*

1- *ខណៈពេលដែលអាស៊ានត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៧ អាស៊ានមិនមែនជាអង្គការថ្នាក់លើរដ្ឋទេ។ តែផ្ទុយទៅវិញ គឺដើម្បីបង្ករភាពងាយស្រួលក្នុងការធ្វើកិច្ចសន្ទនារវាងអំណាចនីតិប្រតិបត្តិរបស់រដ្ឋជាសមាជិកនីមួយៗ ៖ រវាងប្រធានាធិបតីហ្វីលីពីន នាយករដ្ឋមន្ត្រីម៉ាឡេស៊ី សិង្ហបុរី ថៃឡង់ និងប្រធានាធិបតីឥណ្ឌូនេស៊ី។*

2- *សមាគមនេះមិនមែនជាវេទិកាប្រជាពលរដ្ឋនោះទេ(សង្គមស៊ីវិល) វេទិកានេះទុកសម្រាប់តែមេដឹកនាំនយោបាយប៉ុណ្ណោះ។*

3- *សម្រាប់អាស៊ាន យុទ្ធសាស្ត្របានដើរមុខស្ថាប័ន។ គោលដៅគឺមានលក្ខណៈសាមញ្ញ។ ក្របខ័ណ្ឌស្ថាប័នក៏ដូច្នេះដែរ។*

### ១- អង្គភាពនយោបាយ
### ១.១- កិច្ចប្រជុំកំពូលអាស៊ាន

*កិច្ចប្រជុំកំពូលគឺជាអង្គភាពពិគ្រោះពិភាក្សារបស់អាស៊ាន។ នេះជាអង្គភាពរបស់ប្រមុខរដ្ឋ។ មុនឆ្នាំ១៩៩២ ប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលនានាមិនធ្វើការប្រជុំគ្នាទៀងទាត់ទេ។ រដ្ឋមន្ត្រីការបរទេសជាអ្នកចូលរួមកិច្ចប្រជុំកំពូល។ ចាប់ពីឆ្នាំ១៩៩២មក ប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលចាប់ផ្តើមមានទម្លាប់ជួបប្រជុំគ្នាក្នុងកិច្ចប្រជុំកំពូល។ នៅក្រោយកិច្ចប្រជុំកំពូលនេះ សេចក្តីថ្លែងការណ៍រួមមួយត្រូវបានផ្សព្វផ្សាយ ៖ ក្នុងនោះរួមបញ្ចូលអ្នកចូលរួម បញ្ហាដែលត្រូវបានពិភាក្សា និងសេចក្តីសម្រេចដែលត្រូវបានធ្វើឡើង។ នៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនីមួយៗ មានគ្រប់បញ្ហាទាំងអស់ដែលមានវេតយិទភាព។ ចាប់ពីឆ្នាំ១៩៩២មក ប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលជួបប្រជុំគ្នាជាលក្ខណៈផ្លូវការនៅរៀងរាល់៣ឆ្នាំម្តង នៅក្នុងកិច្ចប្រជុំកំពូល។ ពេលនោះពុំទាន់មានគំនិតខិតជិតគ្នានៅឡើយ។ ក្នុងឆ្នាំ១៩៩២ គឺមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន(AFTA)។ កិច្ចប្រជុំកំពូលលើកទីមួយត្រូវបានប្រព្រឹត្តទៅនៅសិង្ហបុរី នៅខែមករា ឆ្នាំ១៩៩២។ ការប្រជុំរដ្ឋមន្ត្រីអាស៊ាន(AMM)មិនរលប់បាត់ទេ តែត្រូវបានដាក់ទៅជាផែននយោបាយលំដាប់ទីពីរ និងមិនមែនជាអង្គភាពធ្វើសេចក្តីសម្រេចទៀតទេ។ អង្គភាពធ្វើសេចក្តីសម្រេចគឺកិច្ចប្រជុំកំពូល។ គ្រប់កិច្ចប្រជុំកំពូលអាស៊ានទាំងអស់បង្កើតបានជាដំណាក់កាលថ្មីមួយនៃជីវិត*

*របស់សមាគម ៖ ឆ្នាំ១៩៩២ AFTA។ល។ លើកទីបួនក្នុងឆ្នាំ១៩៩២ លើកទីប្រាំ កិច្ចប្រជុំកំពូលឆ្នាំ ១៩៩៥បានសម្រេចថា កិច្ចប្រជុំកំពូលនឹងត្រូវបានប្រព្រឹត្តឡើងជារៀងរាល់ឆ្នាំ។ ចាប់ពីឆ្នាំ២០០៩ មក ត្រូវមានកិច្ចប្រជុំកំពូល២ដងក្នុងមួយឆ្នាំ។*

## ១.២- អង្គភាពពាក់កណ្ដាលនយោបាយ

### ១.២.១- ជំនួបរដ្ឋមន្ត្រីការបរទេស(AMM)

*AMMត្រូវប្រព្រឹត្តទៅជារៀងរាល់ឆ្នាំ ក្នុងប្រព័ន្ធចាស់ ហើយនឹងមានគោលដៅកំណត់ទិសដៅទូទៅមួយដែលអនុវត្តដោយសមាគមក្នុងផ្នែកកិច្ចសហប្រតិបត្តិការ ការអភិវឌ្ឍសុខសន្តិភាព និងសន្តិសុខក្នុងតំបន់ ក្នុងផ្នែកបរិស្ថាន កសិកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ នេះជាអង្គភាពដែលទទួលបន្ទុកលើឯកសារដែលមានវេតយិទភាព។ សេចក្ដីសម្រេចត្រូវបានធ្វើឡើងតាមរយៈការព្រមព្រៀងគ្នា ហើយកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខា ដោយរដ្ឋមន្ត្រីការបរទេសទាំងអស់។ បន្ទាប់មក មានសេចក្ដីប្រកាសរួមមួយ។*

### ១.២.២- អង្គភាពពាក់កណ្ដាលនយោបាយទីពីរ ៖ ជំនួបរដ្ឋមន្ត្រីសេដ្ឋកិច្ច(AEM)

*ជំនួបរដ្ឋមន្ត្រីសេដ្ឋកិច្ច(AEM)នេះចាប់ផ្ដើមក្នុងឆ្នាំ១៩៧៦ តាមរយៈសេចក្ដីប្រកាស Concorde I។ រដ្ឋមន្ត្រីទាំងនេះកំណត់នយោបាយសេដ្ឋកិច្ច និងបានប៉ុនប៉ងផ្ដល់អនុសាសន៍នានាដើម្បីធ្វើសុខដុមនីយកម្មគោលនយោបាយក្នុងតំបន់។ កិច្ចប្រជុំនេះប្រព្រឹត្តទៅរៀងរាល់ឆ្នាំ និងរៀបចំឡើងដោយមន្ត្រីជាន់ខ្ពស់ និងប្រតិបត្តិតាមដោយកិច្ចប្រជុំរដ្ឋមន្ត្រីមានសមត្ថកិច្ចនានាក្នុងវិស័យថាមពល។ ពេលបច្ចុប្បន្ននេះ មានកិច្ចប្រជុំអាស៊ានបូក១ អាស៊ានបូក៣។ សព្វថ្ងៃនេះកិច្ចការងាររបស់AEM គឺមានលក្ខណៈសម្បូរបែបកាន់តែខ្លាំង។*

## ២- អង្គភាពសម្របសម្រួល

### ២.១- គណៈកម្មាធិការអចិន្ត្រៃយ៍អាស៊ាន

*មាត្រា៣៦បានបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍មួយដែលស្ថិតក្រោមការគ្រប់គ្រងដឹកនាំរបស់រដ្ឋមន្ត្រីការបរទេសនៃប្រទេសម្ចាស់ផ្ទះ។ គណៈកម្មាធិការអចិន្ត្រៃយ៍រួមមានឯកអគ្គរដ្ឋទូតនៃបណ្ដារដ្ឋសមាជិកនីមួយៗក្នុងប្រទេសម្ចាស់ផ្ទះ។ តួនាទីរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នេះគឺជានាទូវការគ្រប់គ្រងការងារចរន្តប្រចាំថ្ងៃ។ ក្នុងការអនុវត្ត គណៈកម្មាធិការអចិន្ត្រៃយ៍នេះបំពេញការងារដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងប្រធានអាស៊ាន។ គណៈកម្មាធិការនេះដើរតួនាទីជាចំណងរវាងប្រទេសជាសមាជិក និងរដ្ឋមន្ត្រីការបរទេស។ គណៈកម្មាធិការនេះជួប*

ប្រជុំជាញឹកញាប់ប្រហែលជា៤ទៅ៥ដងក្នុងមួយឆ្នាំ។

## ២.២- លេខាធិការដ្ឋានជាតិ

អង្គទីពីរនេះបង្កើតឡើងតាំងពីឆ្នាំ១៩៦៧ គឺលេខាធិការដ្ឋានជាតិ(មាត្រា៣dនៃសេចក្តីប្រកាសទីក្រុងបាងកក)។ លេខាធិការដ្ឋានជាតិនេះមានមុខងារប្រតិបត្តិពលសេចក្តីសម្រេចដែលធ្វើឡើងដោយសមាគមនៅថ្នាក់ជាតិ និងទទួលបន្ទុកតាមដានសេចក្តីសម្រេច។ អង្គភាពនេះមានមុខងារផ្ទៀងផ្ទាត់ថា តើសេចក្តីសម្រេចត្រូវបានដាក់ចេញអនុវត្តនៅថ្នាក់ជាតិឬទេ។ លេខាធិការដ្ឋាននេះមានទីស្នាក់ការនៅក្នុងក្រសួងការបរទេសនីមួយៗ។ គេបានសម្គាល់ឃើញយ៉ាងឆាប់រហ័សថា អង្គភាពទាំងនេះនៅមិនទាន់គ្រប់គ្រាន់ទេ។

## ៣- អង្គភាពមិនបានព្រាងទុក

## ៣.១- លេខាធិការដ្ឋានអាស៊ាន

អគ្គលេខាធិការដ្ឋានត្រូវបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំកំពូលនៅទីក្រុងបាលីក្នុងឆ្នាំ១៩៧៦។ លេខាធិការដ្ឋាននេះរួមមានអគ្គលេខាធិការមួយរូប ប្រធានការិយាល័យ៣រូប មន្ត្រី៣រូប និងអគ្គលេខាធិការរងមួយរូប(ឥឡូវនេះ ឡើងដល់បីរូប ហើយអគ្គលេខាធិការដ្ឋានក៏មាននាយកដ្ឋាន និងមន្ត្រីច្រើនដែរ)។ អគ្គលេខាធិការនេះត្រូវបានតែងតាំងសម្រាប់អាណត្តិពីរឆ្នាំ។ រដ្ឋមន្ត្រីការបរទេសជាអ្នកតែងតាំងអគ្គលេខាធិការតាមប្រព័ន្ធតួនាទីវិលជុំ និងផ្លាស់ប្តូរវេននៃប្រទេសជាសមាជិក។ តួនាទីរបស់អគ្គលេខាធិការដ្ឋានគឺរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ តាមដានសេចក្តីសម្រេចដែលបានដាក់ចេញនានា ផ្តល់ការបកស្រាយលើសេចក្តីណែនាំ ឬសេចក្តីសម្រេចនានាដែលបានអនុម័តដោយអង្គភាពធ្វើសេចក្តីសម្រេចនានា និងដើរតួជាអ្នកសម្របសម្រួលរវាងបណ្តារដ្ឋជាសមាជិក។ អគ្គលេខាធិការដ្ឋានមានអំណាចរដ្ឋបាល និងហិរញ្ញវត្ថុ។

## ៣.២- គណៈកម្មាធិការ និងអនុគណៈកម្មាធិការពិសេស

ក្នុងឆ្នាំដំបូងៗ នៅពេលមានបេសកកម្មថ្មី គឺមានការបង្កើតអង្គភាពថ្មី។ យើងសង្កេតឃើញភាពរាត់រាយនៃអង្គភាពនានា។ ក្នុងឆ្នាំ១៩៨៥ យើងឃើញមានគណៈកម្មការជាង២៥ គណៈកម្មាធិការជាង៧០ ក្រុមជំនាញការច្រើនជាង១០ក្រុម។ ដោយសារតែគ្មានការសម្របសម្រួល គេបានចាត់ទុកថា សៀកផ្លាស់ទី។ ជានិច្ចកាល នៅក្នុងគណៈកម្មាធិការទាំងនោះ តែងតែមានក្រុមការងារគ្រប់គ្រងគម្រោងនានាដែលត្រូវបានកំណត់នៅកម្រិតមូលដ្ឋាន។ ក្រុមការងារទាំងនេះគ្រប់គ្រងគម្រោងទៅតាមវិស័យជាក់លាក់ ៖ ដូចជាដើម្បីប្រតិបត្តិគម្រោង ZOPFAN (តំបន់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្មានអាវុធនុយក្លេអ៊ែរនៅអាស៊ីអាគ្នេយ៍) គណៈកម្មាធិការដើម្បីប្រតិបត្តិ AFTA គឺទទួលបន្ទុកទាក់ទងជាមួយនឹងសហគមន៍អឺរ៉ុប។ នេះគឺជាបណ្ដុំស្មុគស្មាញមួយដែលមុខងារមិនសូវមានប្រសិទ្ធភាពប៉ុន្មានទេ។ ចាប់ពីឆ្នាំ២០០៣មក សមាគមនេះបានធ្វើការកែទម្រង់ ដើម្បីជៀសវាងការលំបាកទាំងអស់នេះ។ លើទិដ្ឋភាពស្ថាប័ន រចនាសម្ព័ន្ធសមាគមមានលក្ខណៈស្រាលៗ។ តែលើទិដ្ឋភាពគ្រប់គ្រងគម្រោងវិញ វាបានក្លាយជាការងារធ្ងន់។

# ផ្នែកទី៣

## យន្តការដោះស្រាយអធិករណ៍របស់អាស៊ាន

គោលដៅចម្បងរបស់អាស៊ាន ចាប់តាំងពីការបង្កើតមក គឺការថែរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់។ ប៉ុន្តែ យន្តការដំណោះស្រាយអធិករណ៍មិនមានចែងក្នុងសេចក្ដីប្រកាសទីក្រុងបាងកកដែលជាធម្មនុញ្ញបង្កើតអាស៊ានទេ ដោយមានមូលហេតុពីរ។ ទីមួយ គោលដៅរបស់អាស៊ានគឺការប្រយុទ្ធប្រឆាំងនឹងលទ្ធិកុម្មុយនីស។ ដោយផ្អែកលើជាតួរួមតូចបំផុតមួយ រដ្ឋជាសមាជិកបានរួបរួមគ្នាក្រោមការដឹកនាំរបស់សហរដ្ឋអាមេរិកដើម្បីទប់ទល់នឹងការវាតទីរបស់លទ្ធិកុម្មុយនីសប្រទេសចិន និងវៀតណាម។ ដូច្នេះ ស្ថាបនិកអាស៊ានបានផ្ដល់អាទិភាពទៅលើកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការ ជាជាងបង្កើតអង្គការថ្នាក់លើរដ្ឋ ដើម្បីការពារអធិបតេយ្យភាពជាតិនៃបណ្ដារដ្ឋសមាជិក។ បន្ថែមពីលើនេះទៀត សញ្ញាណតំបន់និយមមិនត្រូវប្រឆាំងទៅនឹងផលប្រយោជន៍ជាតិនីមួយៗទេ។ ដោយសារមូលហេតុនេះហើយដែលក្របខ័ណ្ឌស្ថាប័នអាស៊ាននៅតែស្ថិតក្នុងសភាពស្រាលៗបំផុត ប្រៀបធៀបទៅនឹងកម្មវត្ថុដែលខ្លួនស្វែងរក។ ទីពីរ វិធីដោះស្រាយអធិករណ៍ឆ្លុះបញ្ចាំងពីវប្បធម៌ប្រពៃណីរបស់បណ្ដារដ្ឋសមាជិក។ សេចក្ដីសម្រេចធ្វើឡើងតាមការព្រមព្រៀងគ្នា ដើម្បីជៀសវាងដំណោះស្រាយគំហុក និងអនុញ្ញាតឱ្យមានដំណោះស្រាយដែលអាចទទួលយកបាន សម្រាប់គ្រប់រដ្ឋទាំងអស់គ្នា។ ប្រសិនបើមានអធិករណ៍ត្រូវតែដោះស្រាយដោយការស្រុះស្រួលគ្នា។ ការព្រមព្រៀងគ្នាគឺជាវប្បធម៌ប្រពៃណីដែលមានយូរយារណាស់មកហើយ នៅក្នុងបណ្ដាប្រទេសស្ថាបនិកអាស៊ានភាគច្រើន ជាពិសេសនៅក្នុងពិភពម៉ាឡាយូនៃប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងហ្វីលីពីន។ វាអនុញ្ញាតឱ្យគូភាគីរកឃើញដំណោះស្រាយមួយដែលទទួលយកបានទាំងសងខាង ដោយមិនធ្វើឱ្យបាក់មុខដល់ប្រទេសជាដៃគូទេ។

ទោះជាយ៉ាងនេះក្ដី ប្រទេសអាស៊ានត្រូវតែអភិវឌ្ឍវិធីសាស្ត្រនយោបាយ ឬអាចរហូតដល់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គតិយុត្ត សម្រាប់ដោះស្រាយអធិករណ៍ជាបណ្តើរៗ ទន្ទឹមនឹងការអភិវឌ្ឍក្របខ័ណ្ឌស្ថាប័នសមាគមៗ សេចក្តីប្រកាសស្តីពីតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត (ZOPFAN) ដែលត្រូវបានអនុម័តក្នុងឆ្នាំ១៩៧១ បានចែងជាលើកទីមួយពីភាពចាំបាច់ក្នុងការបង្កើតឱ្យមានយន្តការដោះស្រាយអធិករណ៍ ៖

«រដ្ឋទាំងអស់ការពារគោលការណ៍អធិបតេយ្យភាព ការគោរពបូរណភាពដែនដី លះបង់ចោលនូវការប្រើប្រាស់កម្លាំង ឬការគំរាមកំហែងក្នុងការប្រើប្រាស់កម្លាំង ការដោះស្រាយអធិករណ៍ដោយសន្តិវិធី សិទ្ធិស្វ័យសម្រេចរបស់ប្រជាជន ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ»។[៩៣]

ម្យ៉ាងទៀត អាស៊ីអាគ្នេយ៍បានស្គាល់នូវបដិវត្តន៍មួយក្នុងឆ្នាំ១៩៧៥ ជាមួយនឹងការឡើងគ្រប់គ្រងអំណាចរបស់ពួកកុម្មុយនីសនៅប្រទេសកម្ពុជា ឡាវ និងវៀតណាមៗ ជាការឆ្លើយតបទៅនឹងព្រឹត្តិការណ៍ទាំងនេះ ប្រទេសសមាជិកអាស៊ានបានជួបប្រជុំគ្នានៅបាលី ក្នុងឆ្នាំ១៩៧៦ ដើម្បីពិនិត្យពិចារណាលើបញ្ហាថ្មីនេះៗ ពួកគេបានអនុម័តសេចក្តីប្រកាសConcord I និងសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ(TAC)ៗ មាត្រា៣នៃ TAC បញ្ជាក់ថា គូភាគីកិច្ចសន្យាសន្យា «... អភិវឌ្ឍន៍ភាពជាអ្នកជិតខាងល្អ និងសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋដែលជាកិច្ចសហប្រតិបត្តិការពហុទម្រង់ សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ រដ្ឋបាល»ៗ សេចក្តីប្រកាស Concord I នៃអាស៊ានដាក់កំហិតឱ្យរដ្ឋសមាជិក«ធ្វើការប្រើប្រាស់ជាដាច់ខាតនូវមធ្យោបាយសន្តិវិធីក្នុងការដោះស្រាយអធិករណ៍ក្នុងតំបន់»ៗ

គេរិះគន់អាស៊ានចំពោះកង្វះខាតនៃការតាមដានសេចក្តីសម្រេចដែលបានអនុម័តរួចហើយៗ ក្នុងការអនុវត្តកិច្ចព្រមព្រៀងទាំងអស់នេះ អាចលេចឡើងនូវអធិករណ៍នានាៗ ដូច្នេះត្រូវគ្រោងទុកនូវយន្តការដោះស្រាយអធិករណ៍ៗ ធម្មនុញ្ញឆ្នាំ២០០៧ ក្នុងមាត្រា៨ចែងពីគោលការណ៍ទូទៅ និងយន្តការដោះស្រាយជម្លោះ និងតាមដានសេចក្តីសម្រេចដែលត្រូវអនុវត្តៗ

## ១- គោលការណ៍ទូទៅនៃការដោះស្រាយអធិករណ៍

អាស៊ានបានដាក់ចេញនូវយន្តការចំនួន៣ ដើម្បីដោះស្រាយអធិករណ៍ ៖ (១) ធម្មនុញ្ញអាស៊ាន និងពិធីសារចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០របស់ធម្មនុញ្ញពាក់ព័ន្ធនឹងយន្តការដំណោះស្រាយអធិករណ៍ (២) សន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ(TAC) ឆ្នាំ១៩៧៦ និង (៣) ពិធីសារឆ្នាំ២០០៤ ពាក់ព័ន្ធនឹងការយន្តការដោះស្រាយអធិករណ៍ដែលត្រូវបានពង្រឹងក្នុងវិស័យសេដ្ឋកិច្ចៗ

ធម្មនុញ្ញអាស៊ានបានលើកយកមកវិញនូវយន្តការដែលមានរួចហើយនៃវិធីដោះស្រាយ

[៩៣] សេចក្តីប្រកាសស្តីពីតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត. PP3.


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នយោបាយ និងវិធីដោះស្រាយតាមតុលាការ គឺមជ្ឈត្តការ។ មាត្រា២២នៃធម្មនុញ្ញបញ្ជាក់ថា ៖

«រដ្ឋសមាជិកទាំងអស់ត្រូវតែដោះស្រាយគ្រប់អធិករណ៍របស់ខ្លួនដោយសន្តិវិធី តាមរយៈកិច្ចសន្ទនា ការប្រឹក្សាយោបល់ និងការចរចាគ្នា»។[៩៤]

វិធីសាស្ត្រដែលមានចែងនៅមាត្រា២៣នៃធម្មនុញ្ញ មាន៣គឺការផ្សះផ្សារ ការសម្រុះសម្រួល និងសន្ធានកម្ម។ ពិធីសារឆ្នាំ២០១០បន្ថែមផងដែរនូវវិធីសាស្ត្រសាមញ្ញគឺការប្រឹក្សាយោបល់។ វិធីសាស្ត្រដោះស្រាយទាំង៤នេះគឺជាវិធីដោះស្រាយជម្លោះបែបនយោបាយ។ ធម្មនុញ្ញក៏ចែងផងដែរអំពីវិធីដោះស្រាយតាមយុត្តាធិការ គឺមជ្ឈត្តការ។

ប៉ុន្តែ ពុំមានអង្គភាពយុត្តាធិការណាមួយដែលមានសម្បទានិកដោះស្រាយអធិករណ៍នោះទេ។ មាត្រា២៤ចែងថា ៖

«គូភាគីវិវាទអាចដាក់ពាក្យបណ្តឹងទៅកាន់ប្រធានអាស៊ាន ឬអគ្គលេខាធិការអាស៊ានដែលមានសមត្ថកិច្ចតាមតួនាទី ឬមុខតំណែងក្នុងការផ្សះផ្សារ សម្រុះសម្រួល ឬសន្ធានកម្ម»។

មានបែបបទ៤យ៉ាងនៃការដោះស្រាយជម្លោះ ៖

## ១.១- ជម្លោះពាក់ព័ន្ធនឹងលិខិតូបករណ៍យថាប្រភេទ

ធម្មនុញ្ញធ្វើការបែងចែងផ្អែកទៅតាមវិស័យដែលពាក់ព័ន្ធដោយជម្លោះ។ សម្រាប់អធិករណ៍ទាក់ទងនឹងលិខិតូបករណ៍យថាប្រភេទរបស់អាស៊ាន ដំណោះស្រាយត្រូវតែធ្វើឡើងដោយអនុលោមទៅតាមយន្តការ និងនីតិវិធីនានាបង្កើតឡើងដោយលិខិតូបករណ៍ទាំងនេះ។[៩៥]

## ១.២- ជម្លោះពាក់ព័ន្ធនឹងលិខិតូបករណ៍សេដ្ឋកិច្ច

សម្រាប់ជម្លោះទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តនូវលិខិតូបករណ៍សេដ្ឋកិច្ចនានានៃអាស៊ាន ដំណោះស្រាយត្រូវតែធ្វើឡើងទៅតាមពិធីសារឆ្នាំ២០០៤ស្តីពីការពង្រឹងយន្តការត្រូវពង្រឹងនៃការដោះស្រាយអធិករណ៍។

## ១.៣- ជម្លោះមិនពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តធម្មនុញ្ញ

ជម្លោះមិនទាក់ទងនឹងការបកស្រាយ និងការអនុវត្តធម្មនុញ្ញត្រូវតែដោះស្រាយ ដោយអនុលោមទៅតាមសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ(TAC) និងវិធាននីតិវិធីរបស់វា។[៩៦]

---

[៩៤] ធម្មនុញ្ញសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ មាត្រា២២។

[៩៥] ធម្មនុញ្ញអាស៊ាន មាត្រា២៤។

[៩៦] *ibid.*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ១.៤- ជម្លោះពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តធម្មនុញ្ញ

*សម្រាប់ដំណោះស្រាយជម្លោះពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តធម្មនុញ្ញ ឬលិខិតូបករណ៍គតិយុត្តដទៃៗទៀតរបស់អាស៊ាន ធម្មនុញ្ញបានចែងពីវិធីដោះស្រាយបែបគតិយុត្ត គឺមជ្ឈត្តការ។*[៩៧]

## ១.៥- របបបដិប្បញ្ញត្តិ

*បន្ថែមពីលើនេះទៀត រដ្ឋសមាជិកក៏អាចប្រើប្រាស់វិធីដោះស្រាយដោយសន្តិវិធីដែលមានចែងក្នុងមាត្រា៣៣(១)នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ឬក្នុងលិខិតូបករណ៍គតិយុត្តផ្សេងៗទៀតដែលមានរដ្ឋសមាជិកពាក់ព័ន្ធដោយជម្លោះ ជាគូភាគី។*[៩៨]

## ២- ធម្មនុញ្ញអាស៊ាន

*ពិធីសារនៃធម្មនុញ្ញអាស៊ានទាក់ទងនឹងយន្តការដោះស្រាយជម្លោះនានាត្រូវបានអនុម័តដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំកំពូលអាស៊ានដែលបានប្រព្រឹត្តឡើងនៅទៅទីក្រុងហាណូយ។*

*គំរូនានាចែងក្នុងពិធីសារឆ្នាំ២០១០មានការប្រឹក្សាយោបល់ ការជួយសម្រុះសម្រួល សន្ទានកម្ម ការផ្សះផ្សារ និងមជ្ឈត្តការ។*

## ២.១- ការប្រឹក្សាយោបល់

*មាត្រា៥នៃពិធីសារឆ្នាំ២០១០បញ្ជាក់ថា វិធីដោះស្រាយទីមួយគឺការប្រឹក្សាយោបល់។ នេះគឺជាវិធីសាស្ត្រសាមញ្ញបំផុតដែលចែងពីទំនាក់ទំនងដោយផ្ទាល់ ឬប្រយោលរវាងគូភាគីនៃជម្លោះ ហើយនៅពេលប្រឹក្សាយោបល់នេះ គូភាគីត្រូវគោរពគោលការណ៍ច្បាប់ចំនួន២ ៖ ភាពសុចរិត និងការគោរពសំដីដែលបាននិយាយ។ ពាក្យបណ្ដឹង និងចម្លើយត្រូវតែធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃគត់(រយៈពេលពិតប្រាកដ délai franc)។ ក្នុងករណីដែលមានការព្រមព្រៀង ការប្រឹក្សាយោបល់នឹងចាប់ផ្ដើម ប្រសិនបើគេទទួលយកក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីថ្ងៃដាក់ពាក្យបណ្ដឹងដើម្បីសុំការប្រឹក្សាយោបល់។ ការបញ្ចប់នៃការប្រឹក្សាយោបល់គឺ៩០ថ្ងៃ(ចាប់ពីថ្ងៃដាក់បណ្ដឹងរហូតដល់ចុងបញ្ចប់នៃការប្រឹក្សាគឺ៩០ថ្ងៃ)។*

---

[៩៧] *ibid.* មាត្រា២៥

[៩៨] *ibid.* មាត្រា២៨

## ២.២- ការជួយសម្រុះសម្រួល ( Les bons offices )

វិធីសាស្ត្រទីមួយនៃមាត្រា៦នៃពិធីសារគឺការជួយសម្រុះសម្រួល។ ភាគីទីបីនឹងស្នើកិច្ចអន្តរាគមន៍របស់ខ្លួនទៅកាន់គូភាគី។ ក្នុងពេលបេសកកម្មជួយសម្រុះសម្រួល ភាគីទីបីមិនបង្ហាញពីដំហរណាមួយឡើយ គឺធ្វើនីតិវិធីទៅវិញទៅមករវាងរដ្ឋទាំងពីរ។ តួនាទីរបស់ភាគីទីបី គឺអ្នកនាំការណ៍ និងមិនស្នើនូវដំណោះស្រាយណាមួយឡើយ។

## ២.៣- សន្ទានកម្ម

វិធីសាស្ត្រទីពីរគឺសន្ទានកម្ម។ ពាក់ព័ន្ធសន្ទានកម្មនេះ ជាការចាប់ផ្ដើម ភាគីទីបីនឹងស្នើកិច្ចអន្តរាគមន៍របស់ខ្លួន។ សន្ទានកម្មខុសពីការជួយសម្រុះសម្រួល ភាគីអន្តរាគមន៍ធ្វើសេចក្ដីស្នើមួយ។ ក្នុងជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសថៃឡង់ដ៍ ប្រធានាធិបតីឥណ្ឌូនេស៊ីចាប់ផ្ដើមការជួយសម្រុះសម្រួល ស្នើជាដំណោះស្រាយ ប៉ុន្តែមិនចាប់បង្ខំឱ្យទទួលយកទេ។ មានន័យថាមិនត្រឹមតែភាគីទីបីស្នើធ្វើអន្តរាគមន៍ទេ តែក៏ស្នើជាដំណោះស្រាយផងដែរ។

## ២.៤- ការផ្សះផ្សារ

គំរូទីបី គឺការផ្សះផ្សារ។ ការផ្សះផ្សារគឺជាបង្កើតគណៈកម្មការចម្រុះមួយដែលមានសមាជិក ២ ឬ៣ ក្រោមអធិបតីភាពរបស់បុគ្គលទីបី។ គណៈកម្មាការផ្សះផ្សារចម្រុះនេះនឹងលើកសំណើជាដំណោះស្រាយមួយដែលអាចទទួលយកបានដោយគូភាគី។ គូភាគីមានសិទ្ធិសេរីភាពក្នុងការទទួលយក ឬមិនទទួលយកនូវដំណោះស្រាយនេះ។ វិធីដោះស្រាយនយោបាយពុំមានចរិតលក្ខណៈចាប់បង្ខំទេ។

## ២.៥- មជ្ឈត្តការ

វិធីសាស្ត្រទីបួន គឺមជ្ឈត្តការ។ មាត្រា២៩នៃធម្មនុញ្ញបញ្ជាក់ថា ក្នុងករណីដែលគ្មានបទប្បញ្ញត្តិពិសេសណាមួយចែង គ្រប់នីតិវិធីដំណោះស្រាយអធិករណ៍អាចត្រូវបានប្រើប្រាស់ក្នុងនោះរួមបញ្ចូលទាំងមជ្ឈត្តការផងដែរ។ មជ្ឈត្តការមានចែងក្នុងមាត្រា៨នៃពិធីសារឆ្នាំ២០១០។

មាត្រា៨នៃពិធីសារគឺជាវិធានយុត្តាធិការ ហើយមានចរិតលក្ខណៈចាប់បង្ខំ។ គូភាគីចរចាលើការសម្របសម្រួលនៃមជ្ឈត្តការ( ជាអត្ថបទមួយដែលក្នុងនោះ គូភាគីកំណត់ពីលក្ខខណ្ឌនៃដំណើរការមជ្ឈត្តការ) បញ្ជាក់ពីដំណើរការមជ្ឈត្តការ( អាជ្ញាកណ្ដាលមួយរូប ឬអង្គសហសេរិក-តា)។ អាស៊ានបានជ្រើសរើសអង្គសហសេរិកតាដែលមានអាជ្ញាកណ្ដាលចំនួន៣រូប។ គូភាគីត្រូវតែទទួលយកនូវសេចក្ដីសម្រេច( សេចក្ដីសម្រេចអាជ្ញាកណ្ដាលដែលមានចរិតលក្ខណៈចាប់បង្ខំ)។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*វិធីសាស្ត្រមួយទៀតនៃដំណោះស្រាយយុត្តាធិការ គឺតុលាការ។*

## ៣- សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ

*សម្រាប់អធិករណ៍មិនពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តលិខិតូបករណ៍អាស៊ាន រួមទាំងជម្លោះព្រំដែន ផ្អែកទៅលើមាត្រា២៤ កថាខណ្ឌទី២នៃធម្មនុញ្ញ ជម្លោះទាំងនេះត្រូវតែដោះស្រាយដោយសន្តិវិធី ប៉ុន្តែអនុលោមទៅតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញា TAC ឆ្នាំ១៩៧៦។*

*ជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសថៃឡង់ដ៍ត្រូវតែធ្វើឡើងក្នុងក្របខ័ណ្ឌនៃ TAC ៖ សន្ធិសញ្ញា បើនិយាយឱ្យចំ គឺសេចក្តីប្រកាស Concorde I ដែលត្រូវអនុម័តនៅទីក្រុងបាលី ឆ្នាំ ១៩៧៦។ សង្គ្រាមឥណ្ឌូចិនលើកទីពីរបានបញ្ចប់។ ដើម្បីអនុញ្ញាតធ្វើការបញ្ចូលបណ្តារដ្ឋដទៃដែលជាអតីតរដ្ឋកុម្មុយនីស គេបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ (TAC)។ សម្រាប់រដ្ឋសមាជិកថ្មីៗ មានភារកិច្ចគោរពនូវអ្វីដែលមានរួចហើយ គឺសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ។*

### ៣.១- គោលការណ៍ទូទៅ

*យោងទៅតាមគោលដៅដែលគេស្វែងរក គោលការណ៍រួមមាន ៖ (១) ការគោរពអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និងអត្តសញ្ញាណជាតិទៅវិញទៅមក។ (២) សិទ្ធិរបស់រដ្ឋនីមួយៗក្នុងការដឹកនាំអត្ថិភាពនៃរដ្ឋ ដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅ(រដ្ឋទីបីក្រៅពីសមាគម)។ (៣) ការមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ។ (៤) ការសន្យារបស់រដ្ឋហត្ថលេខីក្នុងការដោះស្រាយអធិករណ៍តាមរយៈមធ្យោបាយសន្តិវិធី។ (៥) ការលះបង់ចោលនូវការប្រើប្រាស់កម្លាំង និងការគំរាមកំហែងប្រើប្រាស់កម្លាំង។ (៦) សហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋជាសមាជិក។ យន្តការដោះស្រាយជម្លោះរួមមាន ៖*

#### ៣.១.១- គោលការណ៍ទូទៅ

*គូភាគីជម្លោះត្រូវមានឆន្ទៈពិតប្រាកដ(ភាពសុចរិត)ក្នុងការបង្ការការពារ និងឈានទៅដល់ការដោះស្រាយដោយសន្តិវិធី។ ភាគីជម្លោះទាំងពីរត្រូវដោះស្រាយអធិករណ៍របស់ពួកគេដោយការចរចាទ្វេភាគី។*

#### ៣.១.២- ការអនុវត្តប្រព័ន្ធដោះស្រាយជម្លោះ

*ចំណុចទីមួយ ភាគីជម្លោះទាំងពីរត្រូវទទួលយល់ព្រមថា នឹងអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញា។*

ចំណុចទីពីរ គ្មានបទប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញាដែលត្រូវច្រានចោលវិធីដោះស្រាយជម្លោះដោយសន្តិវិធីដែលមានចែងក្នុងមាត្រា៣១-១នៃធម្មនុញ្ញអង្គការសហប្រជាជាតិនោះទេ។

ភាគីជម្លោះអាចធ្វើការសម្រេចដោយសេរីក្នុងការជ្រើសរើសវិធីដោះស្រាយដោយសន្តិវិធី ហើយគូភាគីអាចជាសមាជិកនៃក្រុមប្រឹក្សាជាន់ខ្ពស់ដែលក្នុងនោះរួមមានតំណាងមួយរូបមានឋានៈរដ្ឋមន្ត្រី សម្រាប់រដ្ឋជាសមាជិកសន្ធិសញ្ញា។ វិសោធនកម្មសន្ធិសញ្ញា TAC ដែលអនុម័តក្នុងឆ្នាំ១៩៨៧ បានអនុញ្ញាតឱ្យគូភាគីនៃជម្លោះក្រៅពីសមាជិកអាស៊ាន មានអាសនៈក្នុងក្រុមប្រឹក្សាផងដែរ នៅពេលពួកគេមានការពាក់ព័ន្ធនឹងដំណោះស្រាយ។ តួនាទីក្រុមប្រឹក្សាជាន់ខ្ពស់នេះមានដែនកំណត់ ពីព្រោះថាកាលណាគូភាគីមិនអាចស្វែងរកឃើញនូវជំហរមួយបាន ក្រុមប្រឹក្សាជាន់ខ្ពស់នេះត្រូវធ្វើអនុសាសន៍ឱ្យជ្រើសរើសយកមធ្យោបាយដោះស្រាយសមស្របមួយទៅកាន់គូភាគីនៃជម្លោះ(សន្ទានកម្ម ការផ្សះផ្សារ-ល-)។ គេត្រូវរង់ចាំរហូតដល់ឆ្នាំ២០០១ទើបវិធាននីតិវិធីត្រូវបានអនុម័ត។

## ៣.២- ក្រុមប្រឹក្សាជាន់ខ្ពស់

### ៣.២.១- ការរៀបចំរបស់ក្រុមប្រឹក្សាជាន់ខ្ពស់

ក្រុមប្រឹក្សាជាន់ខ្ពស់នេះ រួមមានតំណាងនៃគូភាគីកិច្ចសន្យាជម្លោះដែលមានថ្នាក់ក្នុងជួររដ្ឋមន្ត្រី។ ការចាត់តាំងសមាជិកម្នាក់ ឬគ្រប់ការផ្លាស់ប្តូរអ្នកតំណាងត្រូវតែជូនដំណឹងទៅកាន់គូភាគីនៃជម្លោះទាំងអស់។ ក្រុមប្រឹក្សានេះស្ថិតក្រោមអធិបតីភាពនៃតំណាងរដ្ឋណាដែលកំពុងបំពេញមុខងារជាប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍អាស៊ាន។ ក្នុងឆ្នាំ២០១១ ប្រធានគឺជាតំណាងជនជាតិឥណ្ឌូនេស៊ី។ ក្រុមប្រឹក្សាជាន់ខ្ពស់នេះនឹងត្រូវស្ថិតក្រោមអធិបតីភាពរបស់រដ្ឋជាសមាជិកដទៃទៀត ប្រសិនបើមូលហេតុនៃជម្លោះលើកឡើងដោយរដ្ឋសមាជិកធ្វើឡើងប្រឆាំងនឹងរដ្ឋដែលជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍អាស៊ាន។ សមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាន់ខ្ពស់គ្របដណ្តប់លើផ្នែកផ្សេងៗទៀតដូចដែលមានចែងក្នុងមាត្រា១៤នៃសន្ធិសញ្ញា។

### ៣.២.២- ដំណើរប្រព្រឹត្តទៅនៃនីតិវិធីនានា

#### ៣.២.២.១- ដំណាក់កាលដំបូង

***ដំណើរការចាប់ផ្តើមគឺ ៖*** មានតែគូភាគីជម្លោះផ្ទាល់ប៉ុណ្ណោះដែលអាចលើកពីនីតិវិធីបាន។ ប៉ុន្តែ គំនិតផ្តួចផ្តើមនេះត្រូវតែគោរពនូវលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌខ្លឹមសារ(ឬអត្ថរស)។

• ***លក្ខខណ្ឌទម្រង់ ៖*** (១)ជាការផ្តួចផ្តើមដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងតាមរយៈផ្លូវទូតទៅកាន់ប្រធាននៃក្រុមប្រឹក្សា ហើយការផ្តួចផ្តើមនេះត្រូវបញ្ជូនទៅគ្រប់គូភាគីជម្លោះ។ ការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជូនដំណឹងជាលាយលក្ខណ៍អក្សរនេះត្រូវបញ្ជាក់ពីស្ថានភាពនៃជម្លោះ គូភាគី និងត្រូវតែជាកម្មវត្ថុនៃការទាមទារ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរនេះក៏បញ្ជាក់ពីមូលដ្ឋានគតិយុត្តដែលក្រុមប្រឹក្សាជាន់ខ្ពស់ត្រូវដំណើរការ។ (២) ក្នុងរយៈពេល១៤ថ្ងៃ មុនការបញ្ជូនសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ភាគីដើមបណ្តឹងត្រូវជូនដំណឹង ភាគីជម្លោះម្ខាងទៀតជាលាយលក្ខណ៍អក្សរ។

**• លក្ខខណ្ឌខ្លឹមសារ ឬអត្ថរស ៖** (១) កាលណាសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូន ប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ស្នើសុំការអះអាងបញ្ជាក់ជាលាយលក្ខណ៍អក្សរពីគ្រប់ភាគីទាំងអស់នៃអធិករណ៍ស្តីពីការយល់ព្រមទៅលើការប្រើប្រាស់នីតិវិធីដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាជាន់ខ្ពស់។ នៅក្នុងលិខិតអះអាងបញ្ជាក់ជាលាយលក្ខណ៍អក្សរនេះ គូភាគីអាចបញ្ចូលសារណាដែលបញ្ជាក់លម្អិតពីធម្មជាតិនៃជម្លោះ បញ្ហាដែលបានចោទឡើង និងសេចក្តីបញ្ជាក់ផ្សេងៗទៀត។ ប្រសិនបើលិខិតអះអាងបញ្ជាក់នេះមិនត្រូវបានធ្វើឡើងទេ ក្រុមប្រឹក្សាជាន់ខ្ពស់បញ្ឈប់នីតិវិធីនេះភ្លាម។

## ៣.២.២.២- កិច្ចប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់

ប្រធានក្រុមប្រឹក្សាជាន់ខ្ពស់មានរយៈពេល៦សប្តាហ៍ដើម្បីកោះប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់នេះ។ ការកោះអញ្ជើញនេះត្រូវជូនដំណឹងទៅគូភាគីទាំងអស់យ៉ាងហោចណាស់៣សប្តាហ៍មុនថ្ងៃប្រជុំ។ លិខិតកោះអញ្ជើញនេះត្រូវភ្ជាប់សំណៅនៃសេចក្តីជូនដំណឹងដើម និងលិខិតអះអាងជាលាយលក្ខណ៍អក្សរ។ នៅពេលក្រុមប្រឹក្សាជាន់ខ្ពស់ជួបប្រជុំគ្នា គឺតំណាងជាអ្នកមានអាសនៈ (យើងអាចត្រូវតំណាងដោយអាណត្តិគាហកមួយរូប)។ គូភាគីនៅក្រៅអាស៊ីអាគ្នេយ៍(ASE)អាចចូលរួមក្នុងកិច្ចប្រជុំនេះបានក្នុងនាមជាអ្នកសង្កេតការណ៍។

សេចក្តីសម្រេចនៃក្រុមប្រឹក្សាជាន់ខ្ពស់ធ្វើឡើងតាមរយៈការព្រមព្រៀងគ្នា។ ប៉ុន្តែ មុននឹងធ្វើការវិនិច្ឆ័យតាមការព្រមព្រៀងគ្នា ម្យ៉ាង ក្រុមប្រឹក្សាជាន់ខ្ពស់អាចសម្រេចនឹងប្រកាសពីភាពត្រឹមត្រូវទៅតាមសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ(TAC) ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន និងម្យ៉ាងទៀត ទៅលើលក្ខខណ្ឌនៃសកម្មភាពខ្លួនក្នុងសម្មតិកម្មនៃការធ្វើសេចក្តីសម្រេចវិនិច្ឆ័យមួយ។

មាត្រា២៧នៃធម្មនុញ្ញបញ្ជាក់ថា កាលណាដំណោះស្រាយមួយត្រូវបានរកឃើញ លេខាធិការដ្ឋានអាស៊ានមានភារៈទទួលបន្ទុកតាមដានការអនុវត្តនូវអនុសាសន៍ ឬសេចក្តីសម្រេចដែលបានធ្វើឡើង។ ហើយដើម្បីធ្វើសកម្មភាពនេះ លេខាធិការដ្ឋាននឹងសរសេរ និងបញ្ជូននូវរបាយការណ៍ទៅកិច្ចប្រជុំកំពូលអាស៊ាន។ ក្នុងសម្មតិកម្មដែលភាគីម្ខាងនៃរដ្ឋភាគីជម្លោះ ឬគ្រប់រដ្ឋដែល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប៉ះពាល់ដោយការមិនប្រតិបត្តិនូវវិធានការដែលបានធ្វើឡើង រដ្ឋភាគីម្ខាងទៀតអាចធ្វើការប្តឹងពីបញ្ហានេះទៅកិច្ចប្រជុំកំពូលអាស៊ានបាន ដើម្បីឱ្យកិច្ចប្រជុំកំពូលចេញសេចក្តីសម្រេចមួយ។ ក្នុងករណីនេះ កិច្ចប្រជុំកំពូលអាចគ្រោងនឹងដាក់ទណ្ឌកម្មនានាបាន។

ថ្វីបើអាស៊ានអនុម័តធម្មនុញ្ញ តែមិនមានសំណុំវិធានមួយដែលចង់ជាក្រមល្អឥតខ្ចោះទេ។ អាស៊ានមានបទដ្ឋានតិចតួចណាស់ក្នុងវិស័យមួយចំនួន នីតិជាតិមានភាពខុសគ្នាច្រើន។ ដើម្បីជាផលប្រយោជន៍ក្នុងការការពារអធិបតេយ្យភាពជាតិ គេមិនត្រូវការច្បាប់ថ្នាក់លើរដ្ឋទេ។ ហេតុដូច្នេះ មានការទប់ទល់មួយពីរដ្ឋ។

## ៤- យន្តការដោះស្រាយក្នុងផ្នែកសេដ្ឋកិច្ច

អាស៊ានទទួលឥទ្ធិពលពីស្ថាប័នអន្តរជាតិនានា។ រដ្ឋសមាជិកទាំងអស់បានចុះហត្ថលេខាក្នុងឆ្នាំ១៩៩៦នូវពិធីសារទីមួយពាក់ព័ន្ធនឹងដំណោះស្រាយអធិករណ៍នានា។ ពិធីសារនេះបំពេញបន្ថែមទៅលើពិធីសារដែលបង្កើតឡើងដោយក្របខ័ណ្ឌកិច្ចព្រមព្រៀងស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចចុះហត្ថលេខានៅប្រទេសសិង្ហបុរី ឆ្នាំ១៩៩២។ ពិធីសារទីពីរត្រូវបានចុះហត្ថលេខា ក្នុងឆ្នាំ២០០៤ និងចូលជាធរមានក្នុងឆ្នាំ២០០៥។ ពិធីសារឆ្នាំ២០០៤នេះ ត្រង់មាត្រា១ចែងថា វិធាន និងនីតិវិធីនានាអាចអនុវត្តមិនត្រឹមតែទៅលើគ្រប់យន្តការនៃដោះស្រាយជម្លោះនានាដែលចេញមកពីក្របខ័ណ្ឌកិច្ចព្រមព្រៀងឆ្នាំ១៩៩២ប៉ុណ្ណោះទេ តែក៏អាចអនុវត្តផងដែរទៅលើគ្រប់កិច្ចព្រមព្រៀងនានាដែលមានជាធរមាន និងដែលនឹងមាននៅពេលអនាគត និងដែលនឹងអនុម័តដោយអាស៊ានក្នុងវិស័យសេដ្ឋកិច្ច។ ពិធីសារឆ្នាំ២០០៤នេះពុំមានភាពដាច់ខាតទេ។ គ្មានអ្វីហាមឃាត់គូភាគីមិនឱ្យជ្រើសរើសវិធីដោះស្រាយ ឬយុត្តាធិការដទៃនោះទេ។ ក្នុងសម្មតិកម្មដែលនីតិវិធីដោះស្រាយនេះត្រូវបានជ្រើសរើស អង្គភាព SEOM (កិច្ចប្រជុំមន្ត្រីសេដ្ឋកិច្ចជាន់ខ្ពស់) ពោលគឺកិច្ចប្រជុំ SEOM នឹងធ្វើអន្តរាគមន៍។

## ៤.១- ការប្រឹក្សាយោបល់

យន្តការនេះមានប្រភពពីពិធីសារឆ្នាំ២០០៤ និងប៉ុនប៉ងលើកកម្ពស់ដំណោះស្រាយមួយដែលអាចទទួលយកបានដោយគូភាគីនៃជម្លោះ។ អនុលោមតាមមាត្រា៣នៃពិធីសារនេះ រដ្ឋសមាជិកត្រូវតែផ្តោតជាសំខាន់ទៅលើការប្រឹក្សាយោបល់នានាដែលអនុញ្ញាតឱ្យគូភាគីអាចស្វែងរកដំណោះស្រាយចំពោះជម្លោះរវាងគូភាគី(ដំណោះស្រាយជាមិត្តភាព)។ លក្ខខណ្ឌនានាត្រូវបានទាមទារ ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៤.១.១- លក្ខខណ្ឌខ្លឹមសារ ឬអត្ថរស

*រដ្ឋសមាជិកនៃពិធីសារអាចស្នើសុំទៅកាន់រដ្ឋដទៃទៀតឱ្យធ្វើការប្រឹក្សាយោបល់។ ការប្រឹក្សាយោបល់នេះអាចត្រូវធ្វើឡើងក្នុងសម្មតិកម្មចំនួនពីរ ៖ (១) កាលណារដ្ឋមួយសង្កេតឃើញថាអត្ថប្រយោជន៍ដែលរដ្ឋនោះទទួលបានដោយផ្ទាល់ ឬដោយប្រយោលដែលចែងដោយពិធីសារនោះ។ (២) កាលណារដ្ឋដែលស្នើសុំការប្រឹក្សាយោបល់នេះ សម្គាល់ឃើញថា រដ្ឋម្ខាងទៀតមិនបំពេញនូវកាតព្វកិច្ចនានារបស់ខ្លួន។*

### ៤.១.២- លក្ខខណ្ឌទម្រង់

*ការស្នើសុំប្រឹក្សាយោបល់ត្រូវបង្ហាញទៅកាន់ SEOM ជាលាយលក្ខណ៍អក្សរដោយចង្អុលបង្ហាញវិធានការណ៍នានាដែលត្រូវបានជំទាស់ និងដោយបញ្ជាក់ថា តើទៅលើមូលដ្ឋានគតិយុត្តណាខ្លះដែលការស្នើសុំនេះត្រូវបានធ្វើឡើង។ ការប្រឹក្សាយោបល់នឹងត្រូវបញ្ជូន និងមានផលប៉ះពាល់ទៅលើរដ្ឋមួយទៀត ហើយរដ្ឋមួយនេះត្រូវតែពិចារណាលើការស្នើសុំនេះ និងត្រូវឆ្លើយតបនឹងសំណើនេះនៅក្នុងរយៈពេល១០ថ្ងៃ។ រដ្ឋមួយនេះត្រូវចូលមកប្រឹក្សាយោបល់ក្នុងរយៈពេល៣០ថ្ងៃ ក្នុងគោលដៅដើម្បីស្វែងរកដំណោះស្រាយដ៏ពេញចិត្តមួយរវាងរដ្ឋភាគីទាំងពីរ។ ក្នុងករណីបន្ទាន់( ផលិតផលដែលអាចរលួយ) នីតិវិធីនឹងត្រូវបានពន្លឿន។*

## ៤.២- ឆ្ពោះទៅកាន់ដំណោះស្រាយយុត្តាធិការ

*យោងតាមមាត្រា៥នៃពិធីសារ កាលណារដ្ឋមួយដែលជាកម្មវត្ថុផ្ទាល់នៃការប្រឹក្សាយោបល់មិនធ្វើការឆ្លើយតបក្នុងរយៈពេល១០ថ្ងៃ ឬមិនបានចូលរួមក្នុងការប្រឹក្សាយោបល់នេះក្នុងរយៈពេល៣០ថ្ងៃ ឬមិនបានផ្តល់លទ្ធផលក្នុងរយៈពេល៦០ថ្ងៃ រឿងក្តីនេះនឹងត្រូវបញ្ជូនទៅកាន់ SEOM ប្រសិនបើភាគីដើមបណ្តឹងប្រាថ្នាធ្វើបែបនេះ។ ក្នុងសម្មតិកម្មនេះ ក្រុមការងារពិសេសមួយនឹងត្រូវបានបង្កើតឡើង(គឺ SEOM ជាអ្នកបង្កើត)។ ប៉ុន្តែគ្មានអ្វីហាមឃាត់មិនឱ្យគូភាគីជម្លោះបន្តការស្វែងរកដំណោះស្រាយជាមិត្តភាពទេ។ ក្នុងសម្មតិកម្មដែលការប៉ុនប៉ងនេះមិនដំណើរការនីតិវិធីនេះនឹងបន្តទៅទៀត។*

### ៤.២.១- ដំណើរការប្រព្រឹត្តទៅរបស់ក្រុមការងារពិសេស

*ក្រុមការងារពិសេស រួមមានសមាជិក៣រូប ឬ៥រូប ប្រសិនបើគូភាគីពេញចិត្តចង់បានសមាជិក៥រូប។ ការស្នើសុំដំឡើងសមាជិកចំនួន៥រូប ត្រូវតែធ្វើឡើងក្នុងរយៈពេល១០ថ្ងៃពីថ្ងៃបង្កើត។*

កាលណាក្រុមការងារពិសេសនេះត្រូវបានបង្កើត សមាជិកទាំងអស់ ជាគោលការណ៍មានឯកពជ្យភាព និងមិនទទួលការណែនាំណាមួយពីរដ្ឋាភិបាលឡើយ។ ដើម្បីអាចក្លាយខ្លួនជាសមាជិកក្រុមការងារពិសេសនេះ សមាជិកម្នាក់ៗត្រូវមានលក្ខណៈសម្បត្តិ និងបទពិសោធន៍វិជ្ជាជីវៈក្នុងវិស័យរដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ធ្លាប់បានបង្រៀននីតិពាណិជ្ជកម្មអន្តរជាតិ និងជាទីប្រឹក្សា។

អគ្គលេខាធិការដ្ឋានក៏មានលទ្ធភាពជ្រើសរើសសមាជិកនៃក្រុមការងារពិសេសដែរ។ ក្នុងសម្មតិកម្មដែលក្រុមការងារពិសេសមិនត្រូវបានបង្កើតក្នុងរយៈពេល២០ថ្ងៃនោះទេ អគ្គលេខាធិការដ្ឋានអាស៊ាន មានរយៈពេល១០ថ្ងៃក្នុងការតែងតាំងសមាជិកក្រុមការងារនេះដែលខ្លួនវាយតម្លៃឃើញថា មានសមត្ថភាពដោយប្រឹក្សាយោបល់ជាមួយនឹង SEOM។ នៅពេលក្រុមការងារពិសេសនេះត្រូវបានបង្កើត ក្រុមការងារនេះនឹងពិនិត្យលើអង្គហេតុនានា និងភាពត្រឹមត្រូវរបស់វាជាមួយនឹងកិច្ចព្រមព្រៀងដែលបានកំណត់ ស្នើនូវដំណោះស្រាយនានានៅក្នុងរបាយការណ៍មួយដែលនឹងត្រូវបញ្ជូនទៅកាន់ SEOM។ ក្នុងនីតិវិធីនៃការតាក់តែងរបាយការណ៍ ក្រុមការងារពិសេសអាចស្តាប់យោបល់អ្នកជំនាញនានាបាន។ ពេលក្រុមការងារពិសេសនេះតាក់តែងរបាយការណ៍រួចហើយ ហើយមុននឹងដាក់របាយការណ៍នេះជូន SEOM ក្រុមការងារពិសេសត្រូវផ្តល់លទ្ធភាពទៅឱ្យគូភាគីវិវាទធ្វើការសង្កេត និងស្នើសុំពិនិត្យសារជាថ្មី។ របាយការណ៍ក្រុមការងារពិសេសនឹងត្រូវអនុម័តដោយស្ងៀមស្ងាត់ ក្នុងករណីដែលSEOMមិនធ្វើការប្រជុំក្នុងរយៈពេលនេះ។ ការស្ងៀមស្ងាត់មានន័យថា ទទួលយកអនុសាសន៍នានាដែលមាននៅក្នុងរបាយការណ៍។ ហើយប្រសិនបើភាគីណាមួយមិនពេញចិត្តនឹងដំណោះស្រាយនេះ គេនៅតែមានលទ្ធភាពក្នុងការប្តឹងឧទ្ធរណ៍។

## ៤.២.២- ការរៀបចំ ការប្រព្រឹត្តទៅ និងការអនុម័តរបាយការណ៍នៃអង្គភាពបណ្តឹងឧទ្ធរណ៍

ខុសពីក្រុមការងារពិសេស អង្គភាពបណ្តឹងឧទ្ធរណ៍ គឺជាអង្គភាពអចិន្ត្រៃយ៍ដែលរួមមានសមាជិកចំនួន៧រូបដែលក្នុងនោះ ៣រូបត្រូវមានគុណវុឌ្ឍិវិជ្ជាជីវៈទាក់ទងផ្ទាល់ទៅនឹងរឿងក្តីដែលអង្គភាពបណ្តឹងឧទ្ធរណ៍នឹងត្រូវពិនិត្យវិនិច្ឆ័យ។ អាណត្តិគឺ៤ឆ្នាំ និងបន្តបានតែម្តងទេ។ អង្គភាពបណ្តឹងឧទ្ធរណ៍ត្រូវបានចាត់តាំងដោយកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ច(AEM)។ ក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន សមាជិកអង្គភាពបណ្តឹងឧទ្ធរណ៍ត្រូវឯករាជ្យពីសមាជិករដ្ឋាភិបាល ហើយមិនត្រូវមានជម្លោះផលប្រយោជន៍ ទោះដោយចំពោះ ឬមិនចំពោះក៏ដោយ។

មានតែគូភាគីជម្លោះផ្ទាល់តែប៉ុណ្ណោះដែលអាចប្តឹងទៅកាន់អង្គភាពបណ្តឹងឧទ្ធរណ៍បាន។ កាលណាបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើង នីតិវិធីនៅចំពោះមុខអង្គភាពឧទ្ធរណ៍នេះមិនត្រូវហួស

*រយៈពេលសរុបចំនួន៦០ថ្ងៃទេ។ អង្គភាពឧទ្ធរណ៍ក៏មានលទ្ធភាពក្នុងការស្នើសុំរយៈពេលបន្ថែម ៣០ថ្ងៃទៀតផងដែរ តែនៅក្នុងគ្រប់ករណីទាំងអស់ រយៈពេលនៃនីតិវិធីមិនត្រូវលើសពីរយៈពេល ៩០ថ្ងៃឡើយ។ អង្គភាពឧទ្ធរណ៍នេះវិនិច្ឆ័យតែលើជម្លោះនានាដែលទាក់ទិននឹងបញ្ហាច្បាប់ដែល បានលើកឡើងនៅក្នុងរបាយការណ៍របស់ក្រុមការងារពិសេសប៉ុណ្ណោះ។ អង្គភាពឧទ្ធរណ៍អាច ធ្វើមោឃភាព អះអាងបញ្ជាក់ ឬកែប្រែអនុសាសន៍នានារបស់ក្រុមការងារពិសេសបាន។ ការ ពិភាក្សាក្នុងអង្គភាពឧទ្ធរណ៍ គឺជាការសម្ងាត់។ មតិយោបល់របស់សមាជិកក៏សម្ងាត់ដែរ។ គូភាគី ជម្លោះមិនមានវត្តមានក្នុងការតាក់តែងរបាយការណ៍របស់អង្គភាពនេះទេ។ របាយការណ៍របស់ អង្គភាពឧទ្ធរណ៍នឹងត្រូវបញ្ជូន និងអនុម័តដោយ SEOM ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃ ជូនដំណឹង។ ការអនុម័តនឹងធ្វើឡើងជាឱឡារិក។ ការអនុម័តនឹងធ្វើឡើងដោយស្ងៀមស្ងាត់ ប្រសិន បើ SEOM មិនធ្វើការប្រជុំគ្នា ហើយភាពស្ងៀមស្ងាត់របស់ SEOM មានន័យថា របាយការណ៍ ត្រូវបានអនុម័ត។*

## ៤.២.៣- ការប្រតិបត្តិនូវអនុសាសន៍ និងសេចក្តីសម្រេចនានា

*កាលណាក្រុមការងារពិសេស និងអង្គភាពឧទ្ធរណ៍សន្និដ្ឋានថា វិធានការណ៍មួយបាន បំពានទៅលើការព្រមព្រៀងដែលមានចែងក្នុងពិធីសារឆ្នាំ២០០៤ អង្គភាពទាំងពីរនេះនឹងផ្តល់ ជាអនុសាសន៍ទៅកាន់រដ្ឋពាក់ព័ន្ធឱ្យចេញវិធានការណ៍ចាំបាច់នានា ដើម្បីប្រែក្លាយកំហុសឆ្គង ដែលមានឱ្យអនុលោមទៅតាមកិច្ចព្រមព្រៀងក្នុងពិធីសារ។ ដើម្បីពិនិត្យមើលការអនុវត្តសេចក្តី សម្រេចនោះ មានការតាមដានមួយ។*

## ៤.២.៣.១- ការតាមដានការប្រតិបត្តិ

*ដើម្បីធានាប្រសិទ្ធភាពនៃដំណោះស្រាយដែលតម្រូវដោយអង្គភាពឧទ្ធរណ៍ គូភាគីដែល បំពានកិច្ចព្រមព្រៀង ត្រូវតែគោរពអនុសាសន៍ដែលគេផ្តល់ឱ្យ។ ភាគីបំពានមានរយៈពេល៦០ ថ្ងៃក្នុងការប្រតិបត្តិតាមអនុសាសន៍។ នេះគឺជារយៈពេលធម្មតា។ ភាគីម្ខាងអាចព្រមព្រៀងផ្តល់ ជូនភាគីម្ខាងទៀតនូវរយៈពេលសមហេតុផលមួយដែលកើតឡើងចេញមកពីការចរចារវាងភាគី ទាំងពីរ។ កាលណារយៈពេលសមស្របមួយត្រូវបានផ្តល់ជូនដោយភាគីម្ខាង គឺក្នុងកាលៈទេសៈ ពិសេសទាំងអស់នេះហើយ(ករណីដោយឡែក)ដែលបង្កើតឱ្យមានភាពសាំញ៉ាំក្នុងការប្រតិបត្តិ អនុសាសន៍នានា ដើម្បីធានាការគោរពអនុសាសន៍ដែលបានអនុម័តដោយក្រុមការងារពិសេស ឬដោយអង្គភាពឧទ្ធរណ៍ ភាគីដែលពាក់ព័ន្ធ ត្រូវផ្តល់នូវរបាយការណ៍ជាលាយលក្ខណ៍អក្សរ មួយស្តីពីការរីកចម្រើននៃការប្រតិបត្តិទៅកាន់ SEOM។*

## ៤.២.៣.២- វិធានការណ៍ទណ្ឌកម្ម

ទណ្ឌកម្មចំនួនពីរមានចែងក្នុងពិធីសារឆ្នាំ២០០៤ ៖ សំណងប៉ះប៉ូវ និងការព្យួរសម្បទាន និងកាតព្វកិច្ច។

វិធានការណ៍ទាំងពីរនេះជាវិធានការបណ្ដោះអាសន្ន និងមានសុពលភាពក្នុងករណីដែលសេចក្ដីសម្រេច ឬអនុសាសន៍មិនត្រូវបានប្រតិបត្តិដោយគូភាគីពាក់ព័ន្ធក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពីការអនុម័ត ឬក្រោយពីការផុតរយៈពេលកំណត់នៃរយៈពេលសមស្របមួយដែលបានព្រមព្រៀងផ្ដល់ឱ្យ។

វិធានការទីមួយ ៖ សំណងប៉ះប៉ូវ។ សំណងប៉ះប៉ូវគឺជាវិធានការស្ម័គ្រចិត្តមួយ។ ក្នុងករណីព្រមទទួលយកសំណងនេះ ត្រូវតែស្របទៅតាមកិច្ចព្រមព្រៀងដែលមានចែង។ ប្រសិនបើគ្មានការព្រមព្រៀងគ្នាលើសំណងនេះទេ គឺត្រូវប្រើការព្យួរសម្បទាន និងកាតព្វកិច្ច។

ភាគីដើមបណ្ដឹងនឹងធ្វើការស្នើសុំទៅកាន់ SEOM នូវវិធានការព្យួរនេះ។ ដើម្បីអាចដាក់ចេញវិធានការនេះបាន ត្រូវមានលក្ខខណ្ឌ៣យ៉ាង ៖ (១) រដ្ឋជាប់បំណុលមិនអាចប្រតិបត្តិនូវសេចក្ដីសម្រេចដែលប្រកាសឡើងដោយក្រុមការងារពិសេស ឬអង្គភាពឧទ្ធរណ៍ក្នុងរយៈពេលសមស្រប៦០ថ្ងៃបាន។ (២) រដ្ឋកូនបំណុលនេះមិនបានស្នើទៅកាន់រដ្ឋម្ចាស់បំណុលនូវការចរចាមួយ ដើម្បីស្វែងរកសំណងហិរញ្ញវត្ថុគួរទទួលយកបានមួយ។ (៣) ប្រសិនបើមានការចរចាបានធ្វើឡើង តែគ្មានសំណងគួរពេញចិត្តណាមួយ ត្រូវបានធ្វើឡើងក្នុងរយៈពេល២០ថ្ងៃ បន្ទាប់ពីរយៈពេលនៃការផុតរលត់រយៈពេល៦០ថ្ងៃ ឬរយៈពេលសមស្រប។ ការព្យួរសម្បទាន និងកាតព្វកិច្ចគឺជាវិធានការទប់វិញមួយប៉ុណ្ណោះ។

ជាទូទៅ រដ្ឋដែលបង់សំណង នឹងស្វែងរកការព្យួរ ឬកាតព្វកិច្ចនៅក្នុងវិស័យសកម្មភាពដូចគ្នានោះ។ ប្រសិនបើសម្រាប់មូលហេតុមួយចំនួន SEOM មិនបានធ្វើការព្យួរនៅក្នុងវិស័យសកម្មភាពនោះទេ SEOM អាចសម្រេចប្រើប្រាស់វិធានការផ្ទាញ់តបនៅក្នុងវិស័យសកម្មភាពផ្សេងទៀត។ វិធានការផ្ទាញ់តបត្រូវតែមានលក្ខណៈសមាមាត្រគ្នា។

## ៤.២.៣.៣- បណ្ដឹងទៅកាន់មជ្ឈត្តការ

អធិករណ៍ត្រូវតែដោះស្រាយតាមរយៈនីតិវិធីអាជ្ញាកណ្ដាលដែលនឹងដឹកនាំដោយក្រុមការងារពិសេស ឬដោយអាជ្ញាកណ្ដាលមួយរូបដែលតែងតាំងដោយអគ្គលេខាធិការអាស៊ាន។ មជ្ឈត្តការនេះត្រូវតែបញ្ចប់ជាដាច់ខាតក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីរយៈពេលផុតកំណត់នៃរយៈពេល៦០ថ្ងៃដំបូង ឬបន្ទាប់ពីផុតកំណត់រយៈពេលសមស្របមួយ។ ដោយសារតែនេះជាមជ្ឈត្តការ សេចក្ដីសម្រេចដែលបានធ្វើឡើងដោយអាជ្ញាកណ្ដាល គឺជាសេចក្ដីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# នីតិស្ថាប័នអាស៊ាន

ក្នុងកិច្ចប្រជុំកំពូលនៅទីក្រុងវៀងចន្ទ ឆ្នាំ២០០៤ គំនិតផ្តួចផ្តើមឱ្យអាស៊ាននូវធម្មនុញ្ញមួយ បានលេចឡើង។ ក្នុងកិច្ចប្រជុំកំពូលឆ្នាំ២០០៥ នៅប្រទេសម៉ាឡេស៊ី សេចក្តីសម្រេចបង្កើតធម្ម-នុញ្ញត្រូវបានអនុម័ត។

ផែនទីបង្ហាញផ្លូវ ៖

- ធម្មនុញ្ញ ត្រូវប្រើជាក្របខ័ណ្ឌស្ថាប័ន និងគតិយុត្តតែមួយគត់ ក្នុងការប្រែក្លាយអាស៊ាន ទៅជាសហគមន៍មួយ។
- អង្គការនេះត្រូវតែមានបុគ្គលភាពគតិយុត្តអន្តរជាតិ។
- ធានានូវនិរន្តរភាពនៃសមាគម និងចងក្រងជាក្រមនូវគ្រប់បទដ្ឋានទាំងអស់។

ធម្មនុញ្ញត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលលើកទី១៣នៅប្រទេសសិង្ហបុរី ក្នុងឆ្នាំ២០០៧ ហើយបានចូលជាធរមាននៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨ និងត្រូវបានផ្តល់សច្ចាប័នដោយគ្រប់ បណ្តារដ្ឋសមាជិកទាំងអស់(ការតម្កល់ឧបករណ៍ផ្តល់សច្ចាប័ន)។ ធម្មនុញ្ញនេះរួមមាន៥៥មាត្រា ១៣ជំពូក និង៤ឧបសម្ព័ន្ធ។

កម្មវត្ថុជាយុទ្ធសាស្ត្រនៃធម្មនុញ្ញ គឺមានចំនួន៣ ៖ (១) ធ្វើឱ្យមានទម្រង់ផ្លូវការនៃអាស៊ាន ក្នុងនាមជាអង្គការអន្តររដ្ឋាភិបាល និងបុគ្គលភាពគតិយុត្ត (២) ពង្រឹងស្ថាប័នអាស៊ាន (៣) បង្កើតយន្តការនៃភាពអនុលោម និងដំណោះស្រាយអធិករណ៍នានា។

# ផ្នែកទី៤

## ស្ថាប័នរបស់អាស៊ាន

រចនាសម្ព័ន្ធសមាគមលែងសមស្រប និងលែងឆ្លើយតបទៅនឹងបរិបទតំបន់ទៀតហើយ។ ក្នុងក្របខ័ណ្ឌស្ថាប័ន នៅតែរក្សារូបរាងជាសាជីជ្រុង ហើយនៅតែមានអង្គភាពគតិយុត្ត និងអង្គភាព សម្របសម្រួលជានិច្ច។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១- ស្ថាប័ននយោបាយ

### ១.១- កិច្ចប្រជុំកំពូលអាស៊ាន

*កិច្ចប្រជុំកំពូលអាស៊ានគឺជាអង្គភាពកំពូលផ្នែកតម្រង់ទិសនយោបាយនៃអនាគតសហគមន៍អាស៊ាន។*

### ១.១.១- សមាសភាពនៃកិច្ចប្រជុំកំពូល

*កិច្ចប្រជុំកំពូលរួមមានប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលរបស់រដ្ឋសមាជិក។ កិច្ចប្រជុំកំពូលនេះធ្វើឡើង២ដងក្នុងមួយឆ្នាំ ក្រោមអធិបតីភាពរបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាលនៃប្រទេសដែលកំពុងកាន់កាប់តំណែងជាប្រធានអាស៊ាន។ ក្នុងករណីចាំបាច់ កិច្ចប្រជុំកំពូលនេះអាចរៀបចំជាពិសេស តាមការកោះហៅរបស់ប្រធានអាស៊ាន។ ទីកន្លែងនៃកិច្ចប្រជុំវិសាមញ្ញនេះនឹងត្រូវបានកំណត់ដោយបណ្តារដ្ឋសមាជិក។*

### ១.១.២- សមត្ថកិច្ចរបស់កិច្ចប្រជុំកំពូល

#### ១.១.២.១- ការចាត់តាំង និងការតែងតាំង

*ប្រមុខរដ្ឋ និងរដ្ឋាភិបាលទាំងអស់ចាត់តាំងរដ្ឋមន្ត្រីមានសមត្ថកិច្ចនៃក្រុមប្រឹក្សាសហគមន៍នីមួយៗដែលនឹងមានសមត្ថកិច្ច សម្រាប់ក្រុមប្រឹក្សាពាក់ព័ន្ធនីមួយៗ ដើម្បីចូលរួមក្នុងជំនួបអន្តរក្រសួងស្តីពីបញ្ហាពហុវិស័យពាក់ព័ន្ធនឹងសហគមន៍ទាំងបី។ គឺប្រមុខរដ្ឋ និងរដ្ឋាភិបាលផងដែរដែលអនុញ្ញាតឱ្យបង្កើត ឬរំលាយអង្គភាពក្រសួង ឬស្ថាប័នដទៃទៀតរបស់អាស៊ាន។ គឺកិច្ចប្រជុំកំពូលអាស៊ាននេះដែរដែលចាត់តាំងអគ្គលេខាធិការអាស៊ាន ដោយគោរពអនុសាសន៍ធ្វើឡើងដោយរដ្ឋមន្ត្រីការបរទេស។*

#### ១.១.២.២- សមត្ថកិច្ចក្នុងផ្នែកធ្វើសេចក្តីសម្រេច

*ប្រមុខរដ្ឋនឹងពិភាក្សាពីនយោបាយទូទៅរបស់សហគមន៍ ហើយនឹងកំណត់ពីទិសដៅនយោបាយ ហើយកិច្ចប្រជុំកំពូលដោះស្រាយទៅលើគ្រប់បញ្ហាដែលជូនលើកឡើងដោយក្រុមប្រឹក្សាសម្របសម្រួល ជូនដោយក្រុមប្រឹក្សាសហគមន៍អាស៊ាន ហើយជូនដោយអង្គភាពរដ្ឋមន្ត្រីអាស៊ាន។ កិច្ចប្រជុំកំពូលត្រូវឆ្លើយតបទៅនឹងស្ថានភាពអាសន្ន ពេលសេចក្តីសម្រេចនេះទាមទារនូវសេចក្តីសម្រេចសមស្របត្រឹមត្រូវមួយ។*

### ១.១.២.៣- អធិបតីភាពអាស៊ាន

មុខងារអធិបតីដំណើរការទៅតាមវិធីផ្លាស់ប្តូរវេនគ្នាមួយឆ្នាំម្តង ទៅតាមលំដាប់អក្សរភាសាអង់គ្លេសនៃឈ្មោះរបស់រដ្ឋជាសមាជិក។ រដ្ឋដែលកាន់កាប់តំណែងប្រធាន ទទួលបន្ទុកបេសកកម្មមួយសំណុំ ៖ ដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលជាឧបសម្ព័ន្ធ ដូចជាអាស៊ានបូក១ អាស៊ានបូក៣ និងកិច្ចប្រជុំកំពូលអាស៊ីខាងកើត។ ប្រធានអាស៊ានដឹកនាំក្រុមប្រឹក្សាសម្របសម្រួល និងក្រុមប្រឹក្សាសហគមន៍ផងដែរ។ ប្រធានអាស៊ានដឹកនាំអង្គភាពរដ្ឋមន្ត្រី និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់នានាផងដែរ។ ប្រធានអាស៊ានក៏ដឹកនាំអង្គភាពថ្មីមួយទៀត គឺគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍។

មានបេសកកម្មមួយទៀតផងដែរ ៖ គឺទទួលបន្ទុកលើកតម្កើងផលប្រយោជន៍នានារបស់អាស៊ាន។ នេះគឺជាតួនាទីក្នុងនាមជាតំណាងនៅខាងក្រៅប្រចាំអង្គការអន្តរជាតិ និងដៃគូខាងក្រៅដទៃៗទៀត។

## ១.២- ក្រុមប្រឹក្សាសហគមន៍

មានក្រុមប្រឹក្សាចំនួន៣ ៖ នយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គមវប្បធម៌។

### ១.២.១- សមាសភាព និងស្ថាប័នកម្មក្រុមប្រឹក្សា

រដ្ឋជាសមាជិកនីមួយៗចាត់តាំងតំណាងប្រចាំក្រុមប្រឹក្សានីមួយៗ។ ក្រុមប្រឹក្សាទាំងបីមានអង្គភាពរដ្ឋមន្ត្រីម្នាក់មួយ។ អង្គភាពរដ្ឋមន្ត្រីតាមជំនាញត្រូវប្រតិបត្តិនូវកិច្ចព្រមព្រៀង និងសេចក្តីសម្រេចទាំងឡាយដែលត្រូវបានអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ាន។ អង្គភាពរដ្ឋមន្ត្រីនេះមានភារៈកិច្ចជួយពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យជាក់លាក់ ហើយដើម្បីបំពេញសកម្មភាពនេះបាន អង្គភាពត្រូវដាក់នូវរបាយការណ៍ និងអនុសាសន៍នានាទៅកាន់ក្រុមប្រឹក្សាសហគមន៍របស់ខ្លួន។ នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួន អង្គភាពនេះអាចទទួលបានជំនួយពីក្រុមមន្ត្រីជាន់ខ្ពស់ ឬអង្គភាពជំនួយបន្ទាប់បន្សំដទៃៗទៀត។

ក្រុមប្រឹក្សាសហគមន៍ជួបប្រជុំគ្នាយ៉ាងហោចណាស់២ដងក្នុងមួយឆ្នាំ ហើយប្រធានក្រុមប្រឹក្សាជារដ្ឋមន្ត្រីនៃរដ្ឋដែលជាប្រធានអាស៊ាន។

### ១.២.២- តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ

#### ១.២.២.១- ក្រុមប្រឹក្សាសហគមន៍នយោបាយ និងសន្តិសុខអាស៊ាន ៖

មាន៦អង្គភាព ៖ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស(AMM) វេទិកាតំបន់អាស៊ាន(ARF) កិច្ច

ប្រជុំរដ្ឋមន្ត្រីការពារជាតិ(ADMM) រដ្ឋមន្ត្រីយុត្តិធម៌ បទឧក្រិដ្ឋអន្តរជាតិ ហើយនិងគណៈកម្មការទទួលបន្ទុកឃ្លាំមើលការប្រតិបត្តិ ZOPFAN (តំបន់គ្មានអាវុធនុយក្លេអ៊ែរ ឆ្នាំ១៩៩៥)។

### ១.២.២.២- ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន ៖

រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន(AEM) ក្រុមប្រឹក្សាAFTA(តំបន់ពាណិជ្ជកម្មសេរីអាស៊ាន) ថាមពល វិស័យស្បៀងអាហារ កសិកម្ម និងរុក្ខាប្រមាញ់ ហិរញ្ញវត្ថុ វិនិយោគ ធនធានរ៉ែ ការដឹកជញ្ជូន ទូរគមនាគមន៍និងបច្ចេកវិទ្យាថ្មីៗ ទេសចរណ៍ ហើយនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

### ១.២.២.៣- ក្រុមប្រឹក្សាសហគមន៍សង្គមវប្បធម៌អាស៊ាន ៖

វិស័យវប្បធម៌ និងសិល្បៈ ការអប់រំ គ្រប់គ្រងគ្រោះមហន្តរាយ បរិស្ថាន សុខភាព ព័ត៌មាន ការងារ ការអភិវឌ្ឍជនបទ និងភាពក្រីក្រ ការការពារសង្គម និងការអភិវឌ្ឍ ស្ត្រីភេទ យុវវ័យ និងធនធានឆ្លងព្រំដែន។

ក្រុមប្រឹក្សាមួយបំពេញបេសកកម្មគោលចំនួន៣ គឺ ៖ (១) ការអនុវត្តសេចក្ដីសម្រេចដែលធ្វើឡើងដោយកិច្ចប្រជុំកំពូលអាស៊ាន (២) ការសម្របសម្រួលការងាររបស់អង្គភាពផ្សេងៗដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន និងបញ្ហាពហុវិស័យ (៣) តាក់តែងរបាយការណ៍ ឬអនុសាសន៍ សម្រាប់ផ្ដល់ជូនប្រមុខរដ្ឋ(នៅកិច្ចប្រជុំកំពូលអាស៊ាន)។

ក្រុមប្រឹក្សាទាំងនេះគឺជាទីកន្លែងបំផុសគ្រប់កម្រិតទាំងអស់នៅក្នុងកិច្ចសហប្រតិបត្តិការទៅវិញទៅមកយ៉ាងជិតស្និទ្ធ។ គេអាចធ្វើការកត់សម្គាល់ឃើញពីអវត្តមានអង្គភាពត្រួតពិនិត្យស្វយ័តមួយដែលជាលក្ខខណ្ឌនៃប្រសិទ្ធភាពនយោបាយរបស់សហគមន៍។ យើងក៏អាចកត់សម្គាល់ឃើញពីការវិវត្តដ៏គួរឱ្យចាប់អារម្មណ៍មួយ បើប្រៀបធៀបទៅនឹងប្រព័ន្ធចាស់។

## ២- ស្ថាប័នសម្របសម្រួល

ស្ថាប័នសម្របសម្រួលទាំងនេះជាកម្មវត្ថុនៃធម្មនុញ្ញឆ្នាំ២០០៧ ៖ អង្គភាពសម្របសម្រួលរួម និងអង្គភាពសម្របសម្រួលថ្នាក់ជាតិ។

### ២.១- អង្គភាពសម្របសម្រួលរួម

មានអង្គភាពសម្របសម្រួលសហគមន៍ចំនួន២ ៖ ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន និងលេខាធិការដ្ឋាន។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.១.១- ក្រុមប្រឹក្សាសម្របសម្រួល

ក្រុមប្រឹក្សាសម្របសម្រួលរួមមានរដ្ឋមន្ត្រីការបរទេសរបស់រដ្ឋជាសមាជិកនានាដោយមានជំនួយក្នុងការបំពេញការងាររបស់ខ្លួនពីក្រុមមន្ត្រីជាន់ខ្ពស់ ហើយជួបប្រជុំគ្នាចំនួន២ដងក្នុងមួយឆ្នាំនៅចុះកិច្ចប្រជុំ AFMM។ ក្រុមប្រឹក្សាសម្របសម្រួលនេះទទួលតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍អាស៊ាន។ តួនាទី និងបេសកកម្មមាន ៖

• រៀបចំកិច្ចប្រជុំកំពូលអាស៊ាន និងធ្វើឱ្យមានភាពងាយស្រួលក្នុងការអនុវត្តកិច្ចព្រមព្រៀង និងសេចក្តីសម្រេចនានាដែលបានអនុម័តក្នុងកិច្ចប្រជុំកំពូល។

• ប្រតិបត្តិកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា។

• សម្របសម្រួលសកម្មភាពរបស់ក្រុមប្រឹក្សាសហគមន៍ទាំងបី ៖ ធ្វើឱ្យមានភាពស៊ីចង្វាក់គ្នាបង្កើនប្រសិទ្ធភាព និងកិច្ចសហប្រតិបត្តិការរវាងសហគមន៍ទាំងបី។ ក្រុមប្រឹក្សាទាំងនេះទទួលយកគ្រប់ការណែនាំប្រឹក្សានានា និងធ្វើជារបាយការណ៍ទៅកាន់ប្រមុខរដ្ឋ និងរដ្ឋាភិបាលទាំងអស់ ៖ របាយការណ៍មួយស្តីពីសកម្មភាពសហគមន៍ ប៉ុន្តែក្នុងនោះក៏មានរបាយការណ៍ស្តីពីអគ្គលេខាធិការដ្ឋានទូទៅផងដែរ។

• ទទួលបន្ទុកបង្ហាញបេក្ខភាពនៃរដ្ឋជាសមាជិក ៖ តើអ្វីទៅជាលក្ខខណ្ឌ សម្រាប់រដ្ឋជាសមាជិក ៖ (មាត្រា៦នៃធម្មនុញ្ញ) មាន៤លក្ខខណ្ឌ ៖ (១) ត្រូវមានទីតាំងភូមិសាស្ត្រនៅក្នុងតំបន់អាស៊ីអាគ្នេយ៍(អាស៊ីបូព៌ា ៖ អាស៊ីខាងកើត និងអាស៊ីភាគឥសានគឺប្រទេសចិន និងតៃវ៉ាន់)។ (២) ការទទួលស្គាល់ដោយគ្រប់រដ្ឋជាសមាជិកទាំងអស់(ទាំងផ្នែកការទូត និងការទទួលយកបេក្ខភាពនេះដោយរដ្ឋជាសមាជិកទាំងអស់)។ (៣) ការទទួលយកនូវកាតព្វកិច្ចនានាដែលមានចែងក្នុងធម្មនុញ្ញ នៅពេលចូលជាសមាជិករបស់រដ្ឋបេក្ខជន។ (៤) សមត្ថភាពក្នុងការធ្វើសមាហរណកម្មរបស់រដ្ឋនោះទៅក្នុងអាស៊ាន។

## ២.១.២- លេខាធិការដ្ឋានអាស៊ាន

លេខាធិការដ្ឋានរួមមានអគ្គលេខាធិការមួយរូប(កាន់តំណែងសម្រាប់រយៈពេល៥ឆ្នាំ ពីខែមករា ឆ្នាំ២០០៨ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ គឺលោក សូរិន ពិតសូវ៉ាន់ (Surin Pitsowan) ហើយពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៧ គឺលោក ឡេ ឡឿង មិញ (Le Luong Minh)។ អគ្គលេខាធិការដ្ឋានរួមមានអគ្គលេខាធិការរងចំនួន៤រូបដែលស្នើឡើងដោយអគ្គលេខាធិការ និងក្រុមប្រឹក្សាសម្របសម្រួលដែលឯកភាពលើការតែងតាំងចុងក្រោយ។ គេក៏ឃើញមានបុគ្គលិក និងមន្ត្រីដែលបំពេញការងារក្នុងលេខាធិការដ្ឋានផងដែរ។ អគ្គលេខាធិការដ្ឋានគឺមិនទាន់រឹងមាំ ៖ (១) កង្វះខាតថវិកា។ (២) ការប្រុងប្រយ័ត្នរបស់រដ្ឋសមាជិកចំពោះអាជ្ញាធរតំបន់មួយដែលរំលោភទៅលើ

*អធិបតេយ្យភាពជាតិ។*

*អគ្គលេខាធិការត្រូវបានតែងតាំងឡើងដោយកិច្ចប្រជុំកំពូល ហើយអាណត្តិមិនអាចបន្តបានទេ និងត្រូវជ្រើសរើសក្នុងចំណោមពលរដ្ឋរបស់រដ្ឋជាសមាជិកណាមួយ ម្តងមួយៗតាមលំដាប់អក្ខរក្រម។*

*តួនាទីអគ្គលេខាធិការ ៖*

*• លើផែនផ្ទៃក្នុង ៖ អគ្គលេខាធិការទទួលបន្ទុកតាមដានការអនុវត្តកិច្ចព្រមព្រៀង និងសេចក្តីសម្រេចរបស់អាស៊ាន និងចូលរួមនៅក្នុងគ្រប់កិច្ចប្រជុំសំខាន់ៗរបស់អាស៊ាននានា(កិច្ចប្រជុំកំពូល ប្រជុំក្រុមប្រឹក្សា) ជួយរៀបចំកិច្ចប្រជុំ និងតាមដានការអនុវត្តកិច្ចព្រមព្រៀង។*

*• លើផែនផ្ទៃក្រៅ ៖ តំណាងអាស៊ានប្រចាំនៅអង្គការ ឬប្រទេសជាដៃគូខាងក្រៅនានាក្នុងក្របខ័ណ្ឌអាណត្តិការងារមួយដែលកំណត់ដោយកិច្ចប្រជុំកំពូល។*

*អគ្គលេខាធិការ និងបុគ្គលិករបស់អាស៊ានទាំងអស់ទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដូចដែលមានចែងក្នុងមាត្រា១៨នៃធម្មនុញ្ញ។*

## ២.១.៣- អង្គភាពសម្របសម្រួលថ្នាក់ជាតិ

*ក្នុងអង្គភាពទាំងពីរនេះ អង្គភាពមួយមានរួចមកហើយ ហើយមួយទៀតទើបតែបង្កើតថ្មី។*

### ២.១.៣.១- តំណាងអចិន្ត្រៃយ៍(មាត្រា១២C)

*រដ្ឋជាសមាជិកនីមួយៗចាត់តាំងតំណាងអចិន្ត្រៃយ៍ម្នាក់ក្នុងអាស៊ាន ឋានៈជាឯកអគ្គរដ្ឋទូត។ តំណាងអចិន្ត្រៃយ៍ទាំងអស់បង្កើតបានជាអង្គភាពសហសេវិកតាមួយ គឺគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ ទីស្នាក់ការរបស់គណៈកម្មាធិការនេះគឺស្ថិតនៅទីក្រុងហ្សាកាតា(រដ្ឋនានាក្រៅពីសមាជិកអាស៊ាននឹងចាត់តាំងឯកអគ្គរដ្ឋទូតរបស់ខ្លួនប្រចាំនៅអាស៊ាន)។ តួនាទីរបស់គណៈកម្មាធិការនេះមានពីរ ៖ (១) លើផែនផ្ទៃក្នុង គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ផ្តល់ជំនួយ និងការគាំទ្រសម្រាប់ការងាររបស់ក្រុមប្រឹក្សាសហគមន៍ ជានាតួនាទីសម្របសម្រួលរបស់លេខាធិការដ្ឋានជាតិ និងអង្គភាពរដ្ឋមន្ត្រី ជានាការទំនាក់ទំនងជាមួយនឹងអគ្គលេខាធិការ សម្រាប់គ្រប់មុខងារដែលជាសមត្ថកិច្ចរបស់អង្គភាពទាំងពីរ។(២) លើផែនផ្ទៃក្រៅ គណៈកម្មាធិការជួយសម្រួលកិច្ចសហប្រតិបត្តិការរបស់អាស៊ានជាមួយនឹងដៃគូខាងក្រៅ។*

### ២.១.៣.២- លេខាធិការដ្ឋានជាតិ(មាត្រា១៣)

*នៅក្នុងរដ្ឋសមាជិកនីមួយៗ មានលេខាធិការដ្ឋានជាតិអាស៊ានមួយដែលមានភារៈកិច្ចត្រៀម*

រៀបចំកិច្ចប្រជុំ និងសម្របសម្រួលការអនុវត្តសេចក្តីសម្រេចរបស់អាស៊ាននៅក្នុងថ្នាក់ជាតិ។ នេះគឺជាតួនាទីសម្របសម្រួលជូនដំណឹងដល់អគ្គលេខាធិការ និងជូនដំណឹងពីសេចក្តីសម្រេចរបស់អាស៊ាននៅក្នុងរដ្ឋជាសមាជិក។

តួនាទីលេខាធិការដ្ឋានជាតិគឺធ្វើឱ្យមានការចាប់អារម្មណ៍ និងជួយជំរុញអត្តសញ្ញាណតំបន់នៅក្នុងប្រទេសជាសមាជិកទាំងអស់។

# ផ្នែកទី៥

# ក្របខ័ណ្ឌគតិយុត្តដែលកែលម្អមួយចំនួន

ការកែលម្អធម្មនុញ្ញក្នុងផ្នែកគតិយុត្តពុំបង្ហាញជាក់ច្បាស់ដូចការកែលម្អស្ថាប័នទេ។ ការកែលម្អនេះមានដូចតទៅ ៖

អង្គភាពទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិមនុស្ស។ អង្គភាពនេះពោលគឺគណៈកម្មការសិទ្ធិមនុស្សអាស៊ានត្រូវបានបង្កើតឡើងដោយមានសមាជិក១០រូប។ រដ្ឋសមាជិកទាំងអស់ចាត់តាំងដោយខ្លួនឯងនូវតំណាង។ តំណាងត្រូវរាយការណ៍ពីសកម្មភាពរបស់ខ្លួនជូនរដ្ឋាភិបាល (ឯករាជ្យភាពពុំអាចជានាបាន មានតែប្រទេសឥណ្ឌូនេស៊ី និងថៃប៉ុណ្ណោះដែលបានចាត់តាំងតំណាងពីសង្គមស៊ីវិល រីឯប្រទេសផ្សេងចាត់តាំងមន្ត្រីជាន់ខ្ពស់)។ គណៈកម្មការមានគោលដៅលើកស្ទួយ និងការពារសិទ្ធិមនុស្ស។ គណកម្មការពុំអាចដាក់ទណ្ឌកម្មណាមួយទៅលើរដ្ឋសមាជិក(ពុំមែនសិទ្ធិដាក់ទណ្ឌកម្មទេ) ពុំមានអំណាចអង្កេតទៅលើការរំលោភបំពានដោយហេតុណាមួយឡើយ។ ពុំមានយន្តការណាមួយដែលអនុញ្ញាតដល់បុគ្គលឱ្យប្តឹងទៅគណៈកម្មការទេ (ពុំអាចប្តឹងពីការសន្មតថា មានការរំលោភបំពានសិទ្ធិមនុស្ស)។

## ១- ដំណើរការធ្វើសេចក្តីសម្រេចក្នុងអាស៊ាន

ពីដើមរៀងមក គ្រប់ស្ថាបនិកពុំចង់បានអាជ្ញាលើសថ្នាក់ជាតិទេ។ ទស្សនាទានតំបន់និយមពុំត្រូវប្រឆាំងនឹងផលប្រយោជន៍ជាតិឡើយ។ ដូច្នេះ ការសម្រេចចិត្តប្រព្រឹត្តទៅតាមរយៈកុងសង់ស៊ីស ដើម្បីរក្សាមាគ៌ាអាស៊ាន(ASEAN way)។

នាពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ បញ្ហាបានចោទឡើងត្រង់ថា តើការធ្វើសេចក្តីសម្រេចតាមរយៈកុងសង់ស៊ីសមានប្រសិទ្ធភាពឬទេ។ ធម្មនុញ្ញឆ្នាំ២០០៧នៅរក្សាការប្រើកុងសង់ស៊ីសជាវិធីធ្វើសេចក្តីសម្រេចគោលដដែល។ ប៉ុន្តែ ដោយហេតុ ធម្មនុញ្ញបានចែងពីការអនុម័តវិធីធ្វើ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេចក្តីសម្រេចមួយផ្សេងក្នុងករណីបរាជ័យ។

## ១.១- សារតារនៃកុងសង់ស៊ីសក្នុងអាស៊ាន

កុងសង់ស៊ីសគឺជាប្រពៃណីវប្បធម៌ដ៏រស់រវើកមួយក្នុងរដ្ឋសមាជិក ពិសេសក្នុងពិភពម៉ាឡេ (ប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន)។ ក្នុងប្រពៃណីនេះ ការសម្រេចពុំឆ្លងកាត់ការបោះឆ្នោតទេ ប៉ុន្តែតាមកុងសង់ស៊ីស ដើម្បីបញ្ចៀសដំណោះស្រាយខ្វែងគ្នា និងជួយផ្តល់ដំណោះស្រាយដែលអាចទទួលយកបាន។

ចាប់ពីឆ្នាំ១៩៨៧មក មានវិតិក្រមទៅលើកុងសង់ស៊ីសនេះ គឺកុងសង់ស៊ីស៥-១។ ប្រសិនបើរដ្ឋមួយពុំអាចទទួលយកបាន នោះគេអាចទទួលយកការសម្រេចមួយ លើកលែងរដ្ឋមួយ គឺនៅពេលប្រទេសសិង្ហបុរីពុំចង់អនុម័តនយោបាយឧស្សាហកម្មអាស៊ាន។

## ១.២- វិធីធ្វើសេចក្តីសម្រេច

ការពិគ្រោះយោបល់ និងកុងសង់ស៊ីសនៅតែជាវិធីសម្រេចគោល។ ធម្មនុញ្ញពុំបញ្ជាក់ថានឹងឈានដល់ការបោះឆ្នោតនោះទេ។ កុងសង់ស៊ីសគឺសម្រាប់បញ្ហារសើបខ្លាំង ៖ ការទទួលរដ្ឋសមាជិកមួយថ្មីត្រូវឆ្លងកាត់ការសម្រេចជាឯកច្ឆន្ទ។ ការផ្អាកជាបណ្តោះអាសន្ន និងយថាហេតុនូវអភ័យឯកសិទ្ធិរបស់រដ្ឋសមាជិកគឺអាស្រ័យលើការសម្រេចជាឯកច្ឆន្ទ។ សម្រាប់បញ្ហានយោបាយក្រៅប្រទេស បញ្ហាសន្តិសុខ កុងសង់ស៊ីសនៅតែជាវិធីក្នុងការសម្រេច។

ចំពោះវិស័យពុំសូវរសើបវិញ យើងឃើញមានប្រើរូបមន្ត អាស៊ាន-Xដែលអនុវត្តក្នុងផ្នែកសហប្រតិបត្តិការ។ ជាជាងរារាំងមិនអនុម័តគម្រោងនេះ ការប្រើប្រាស់រូបមន្តនេះអាចឱ្យបរទេសដែលគាំទ្រគម្រោង ចុះកិច្ចព្រមព្រៀងយកទៅអនុវត្តបាន។ ផ្ទុយមកវិញ គេអាចប្រើប្រព័ន្ធ២+X ផ្សេង។ មាត្រា២០ត្រង់កថាខណ្ឌទី១ក្នុងធម្មនុញ្ញអាស៊ានឆ្នាំ២០០៧បានចែងថា រាល់សេចក្តីសម្រេចរបស់អាស៊ានត្រូវឈរលើមូលដ្ឋាននៃការប្រឹក្សាយោបល់ និងកុងសង់ស៊ីស។ នៅក្នុងករណីដែលមិនមានកុងសង់ស៊ីស គឺកិច្ចប្រជុំកំពូលអាស៊ានជាអ្នកសម្រេចអំពីរបៀបនៃការធ្វើសេចក្តីសម្រេចជាក់លាក់មួយ(មាត្រា២០-២នៃធម្មនុញ្ញ)។ ចំណុចនេះអនុញ្ញាតដល់រដ្ឋនានាឱ្យធ្វើការសម្រេចដោយផ្អែកលើការកំណត់រួមដ៏តូចនេះ។ ប៉ុន្តែ ការប្រឹក្សាយោបល់ និងកុងសង់ស៊ីសមិនធ្វើឱ្យប៉ះពាល់ដល់វិធីសាស្ត្រធ្វើសេចក្តីសម្រេចនានាដូចដែលមានកំណត់ក្នុងលិខិតូបករណ៍គតិយុត្តពាក់ព័ន្ធរបស់អាស៊ានទេ។ ការប្រឹក្សាយោបល់ និងកុងសង់ស៊ីសពុំមានលក្ខណៈផ្តាច់មុខទេ(មាត្រា២០-៣)។ ដើម្បីបង្ហាញពីយថាភាពនេះ ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗត្រូវបញ្ញត្តនូវវិធាននៃនីតិវិធីរបស់ខ្លួន(មាត្រា២១-១) ហើយចំពោះការបង្ហាញពីការធ្វើសេចក្តីសម្រេចក្នុងសេដ្ឋកិច្ចរូបមន្តសម្រាប់

*ការចូលរួមដែលមានភាពបត់បែនបាន(អាស៊ាន-X)អាចអនុវត្តបាន ប្រសិនបើមានកុងសង់ស៊ីសក្នុងការអនុវត្ត(មាត្រា២១-២)។*

**ច្បាប់សត្យានុម័តអាស៊ាន**

*អាស៊ានវិវត្តយឺត ប៉ុន្តែ ឆ្ពោះទៅរកការបង្កើតប្រព័ន្ធធម្មនិយាមយ៉ាងប្រាកដប្រជា។ នេះពុំមែនជានីតិសហគមន៍ទេ។ គឺជាប្រព័ន្ធកិច្ចព្រមព្រៀងអន្តររដ្ឋ។ អាស៊ានគឺជាអង្គការអន្តររដ្ឋាភិបាលមួយ។ ពុំមានវិធាន ឬគោលការណ៍ណែនាំរបស់អាស៊ានទេ។ ពុំមានតុលាការទេ ប៉ុន្តែអាស៊ានផ្អែកលើសុច្ឆន្ទៈរបស់រដ្ឋសមាជិក។*

*សេចក្តីថ្លែងការណ៍នៃកិច្ចស្រុះស្រួល២ ចុះថ្ងៃទី០៧ តុលា ២០០៣ បានបញ្ជាក់អះអាងជាផ្លូវការនូវការបំលែងអាស៊ានទៅជាសហគមន៍មួយដែលផ្អែកលើសសរទ្រូង៣ រាប់បញ្ចូលទាំងសហគមន៍សេដ្ឋកិច្ចដែរ។*

*ផែនការលម្អិតសហគមន៍សេដ្ឋកិច្ច (ASEAN Economic Community Blueprint) ត្រូវបានអនុម័តនៅប្រទេសសិង្ហបុរីនាឆ្នាំ២០០៧ ដើម្បីអនុវត្តផែនការនេះសម្រាប់ឆ្នាំ២០១៥។ សមាហរណកម្មសេដ្ឋកិច្ចនេះមានធាតុសំខាន់៤គឺ ៖*

- *ទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ*
- *សេដ្ឋកិច្ចប្រកួតប្រជែង*
- *ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌*
- *សមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក*

# ផ្នែកទី៦

## សេរីភាវូបនីយកម្មដោយជម្រើស និងវិវឌ្ឍបន្តិចម្តងៗ

*សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មរវាងរដ្ឋសមាជិកអាស៊ានបានធ្វើឡើងជាលំដាប់ក្នុងវិស័យដែលបានជ្រើសរើសដូចជា ទំនិញ សេវាកម្ម និងហិរញ្ញវត្ថុផងដែរ ទាំងវិនិយោគ និងមូលធន។ បណ្តូរពាណិជ្ជកម្មរវាងរដ្ឋអាស៊ានទាំងអស់មិនប្រែប្រួលរយៈពេល២៥ឆ្នាំមកហើយ គឺពី២០%ទៅ២៥%។ គឺជាសេដ្ឋកិច្ចដែលបានជ្រើសរើសគំរូឆ្ពោះទៅរកការនាំចេញ ជាសេដ្ឋកិច្ចដែលមួយផ្នែកធំមានការប្រកួតប្រជែងខ្លាំង និងពុំមែនបំពេញបន្ថែមគ្នាទេ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១- សេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញ

*សេរីភាវូបនីយកម្មទៅលើចរាចរណ៍ទំនិញកើតចេញពីលទ្ធផលនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច(១៩៩២) និងកិច្ចព្រមព្រៀងស្តីពីអត្រាពន្ធគយរួមអនុគ្រោះ(CEPT) សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន(AFTA-១៩៩២)ដែលអនុម័តនៅប្រទេសសិង្ហបុរី ដើម្បីអនុញ្ញាតដល់ការបង្កើតតំបន់ពាណិជ្ជកម្មសេរីក្នុងអាស៊ាន AFTA។*

## ១.១- មូលដ្ឋានគតិយុត្តនៃពាណិជ្ជកម្មសេរីនៃទំនិញ

*កិច្ចព្រមព្រៀងសិង្ហបុរី(១៩៩២)បានគ្រោងនឹងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ានក្នុងរយៈពេល១៥ឆ្នាំ។ នាឆ្នាំ១៩៩៥ រយៈពេលនេះត្រូវបានបង្រួញមកនៅ១០ឆ្នាំ។ យន្តការដែលប្រើប្រាស់គឺអត្រាពន្ធគយរួមអនុគ្រោះ។ រដ្ឋសមាជិកប្តេជ្ញាបន្ថយ និងបំបាត់របាំងមិនមែនតម្លៃនានាដែលបង្កការរាំងស្ទះដល់ការនាំចូល និងនាំចេញទំនិញរវាងរដ្ឋសមាជិក។ CEPT បានចែងពីប្រតិទិនកាត់បន្ថយជាលំដាប់។ អាត្រាបន្ថយកាលពីមុនមានចំនួន២០%។ ការកាត់បន្ថយប្រព្រឹត្តទៅតាមបញ្ជីទំនិញដែលរដ្ឋនីមួយៗបានចុះហត្ថលេខា។ កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ានបានចែងពីបញ្ជីទំនិញចំនួន៤គឺ ៖*

*១. បញ្ជីរួមបញ្ចូល(Inclusive list-IL) រួមមានបណ្តុំផលិតផលដែលឋិតក្រោមអត្រាពន្ធគយរួមអនុគ្រោះ។ បញ្ជីរួមបញ្ចូលរួមមានគ្រប់ផលិតផលដែលនៅក្រៅបញ្ជីរសើប និងក្រៅបញ្ជីលើកលែងទូទៅ។*

*២. បញ្ជីពុំរាប់បញ្ចូលបណ្តោះអាសន្ន(Temporarily Exclusive List-TEL)៖ បញ្ជីនេះមានក្រាំងបញ្ជីផលិតផលដែលនឹងឈានចូលក្នុងបញ្ជីរួមបញ្ចូល ក្រោយរយៈកាលកែតម្រូវរួច។*

*៣. បញ្ជីរសើប(Sensitive List-SL)ពាក់ព័ន្ធនឹងកសិផលដើមដែលគ្រប់ប្រទេសសមាជិកចាត់ទុកថា មានលក្ខណៈរសើប។*

*៤. បញ្ជីលើកលែងទូទៅ(General Exception List-GEL) ក្នុងនោះ ផលិតផលទាំងអស់ឋិតនៅក្រៅកិច្ចព្រមព្រៀងជាស្ថាពរ ព្រោះអាចប៉ះពាល់សុខភាពសាធារណៈ សន្តិសុខជាតិ និងកេរមត៌កវប្បធម៌របស់ប្រទេសនីមួយៗ។*

*របាំងតម្លៃទាំងនេះត្រូវបានលុបចេញក្នុងរយៈពេល៥ឆ្នាំ។*

## ១.២- ទស្សនៈវិស័យបច្ចុប្បន្ន

*កិច្ចព្រមព្រៀងថ្មីស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន(Asean Trade in Goods Agreement-ATIGA)ត្រូវបានចុះហត្ថលេខានៅប្រទេសថៃឡង់ដ៍នាឆ្នាំ២០០៩ ហើយចូលជាធរមាននាខែ*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឧសភា ឆ្នាំ២០១០។ កិច្ចព្រមព្រៀងថ្មីស្តីពីពាណិជ្ជកម្មទំនិញអាស៊ានបានជំនួសកិច្ចព្រមព្រៀង និង ការស្រុះស្រួលមុនៗទាំងអស់ រួមទាំងកិច្ចព្រមព្រៀងស្តីពី CEPT ( នីតិវិជ្ជមាន)។ កិច្ចព្រមព្រៀង ថ្មីនេះផ្តោតទៅលើគោលការណ៍ពាណិជ្ជកម្មទូទៅ ចំណាត់ថ្នាក់ទំនិញ សេរីភាវូបនីយកម្មតម្លៃ ការ លុបបំបាត់អនិមិត្តភាពពាណិជ្ជកម្ម វិធានការក្រៅតម្លៃ នីតិវិធីគយ វិធានអនុលោមបច្ចេកទេស និយ័តកម្ម វិធានភូតគាមអនាម័យSPS នីតិវិធីពិសេស និងដាក់លាក់ក្នុងករណីដោះស្រាយអធិករណ៍។

កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មទំនិញនេះក៏បង្កើតផងដែរនូវគណៈកម្មការប្រឹក្សា រួមទទួលបន្ទុកសម្រួលកិច្ចការពាណិជ្ជកម្មដែលទទួលខុសត្រូវលើការអនុវត្តកិច្ចព្រមព្រៀងនេះ។

## ១.២.១- ការកាត់បន្ថយ និងការលុបបំបាត់តម្លៃ

- ការកាត់បន្ថយទៅលើផលិតផលក្នុងបញ្ជី១ ៖ រាប់បញ្ចូលពី០%ដល់៥% ត្រូវបានទទួល តាំងពីឆ្នាំ២០០៣សម្រាប់អាស៊ាន៦។ សម្រាប់ប្រទេសវៀតណាមវិញ គឺតាំងពីឆ្នាំ២០០៦។ សម្រាប់ ប្រទេសឡាវ និងមីយ៉ាន់ម៉ា គឺតាំងពីឆ្នាំ២០០៩ ឯប្រទេសកម្ពុជាឆ្នាំ២០១០។

- ការលុបបំបាត់ពន្ធនាំចូលចំនួន៦០%ទៅលើផលិតផលក្នុងបញ្ជីរួមបញ្ចូល គឺដូចគ្នា។

- ការលុបចោលពន្ធគយនាថ្ងៃទី០១ មករា ២០១០ ស្តីពីផលិតផលក្នុងបញ្ជីរួមបញ្ចូល គឺ តម្រង់ឆ្ពោះទៅរកអាស៊ាន៦ប៉ុណ្ណោះ( ៩៩,៦៥%នៃច្បាប់គយ និង៨៧,២%នៃពាណិជ្ជកម្មក្នុង អាស៊ាន)។ ចំពោះបួនទៀត គេរក្សាការបន្ថយត្រឹម០,៥%។ ប្រសិនបើគេបញ្ចូលរដ្ឋបួនទៀត គឺ៩៨%។

- គេអាចធ្វើការសន្និដ្ឋានបានថា កម្មវត្ថុលុបចោលតម្លៃគយទទួលបានជោគជ័យ។

## ១.២.២- ការលុបបំបាត់របាំងមិនមែនពន្ធ

ទន្ទឹមនឹងសមិទ្ធផលលុបរបាំងចោល បច្ចុប្បន្ន អាស៊ាននឹងផ្តោតទៅលើការសន្យាលុបរបាំង មិនមែនពន្ធ និងវិធានការណ៍សម្រួលដល់ពាណិជ្ជកម្មទំនិញ។ បញ្ជីនៃរបាំងមិនមែនពន្ធត្រូវ បានបោះពុម្ពផ្សាយក្នុងវ៉ិបសាយអាស៊ាន ដើម្បីជានាតម្លាភាព។

## ១.២.៣- វិធានការដែលមាននិន្នាការសម្រួលដល់ពាណិជ្ជកម្មទំនិញ

ក្នុងនោះមានបញ្ជរតែមួយអាស៊ាន ការធ្វើឱ្យនីតិវិធីមានលក្ខណៈសាមញ្ញពាក់ព័ន្ធនឹងម៉ាក អាស៊ាន ស្តង់ដារ អនុលោមភាព ផែនការសកម្មភាពក្នុងការសម្រួលពាណិជ្ជកម្មអាស៊ានត្រូវបាន អនុម័តហើយ។

អាស៊ាន-៦បានផ្តើមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិរបស់អាស៊ាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.៣- សេរីភាវូបនីយកម្មទៅលើពាណិជ្ជកម្មសេវាកម្ម

*ពាណិជ្ជកម្មសេវាកម្មមានចំណែកច្រើនធៀបទៅនឹងផលិតផលសរុបក្នុងស្រុករបស់រដ្ឋសមាជិកអាស៊ាន។ ជាមធ្យម វិស័យសេវាកម្មជួយប្រមាណជាពាក់កណ្ដាល( ៥០%)ដល់ផលិតកម្មសេដ្ឋកិច្ច ស្មើនឹងទឹកប្រាក់១៥៧ពាន់លានដុល្លារ នាឆ្នាំ២០០៧។ សេរីភាវូបនីយកម្មទៅលើវិស័យសេវាកម្មត្រូវបានគ្រោងដោយកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីសេវាកម្ម( AFAS-១៩៩៥)។*

### ១.៣.១- មូលដ្ឋានគតិយុត្តនៃសេរីភាវូបនីយកម្ម

*រដ្ឋទាំងអស់ប្ដេជ្ញាលុបបំបាត់ជាទ្រង់ទ្រាយធំនូវវិធានការរើសអើងទាំងអស់ ព្រមទាំងព្រំដែនកំហិតទៅលើទីផ្សារសេវាកម្ម និងប្ដេជ្ញាពុំបញ្ចូលវិធានការថ្មីឡើយ។ គោលការណ៍ចរចាទាំងពីរវាងសមាជិកគឺជាគោលការណ៍ដែលគេស្គាល់ច្រើន នោះគឺប្រព្រឹត្តកម្មពុំរើសអើង រាប់បញ្ចូលទាំងប្រព្រឹត្តកម្មជាតិ និងឋានៈជាតិទទួលបានការអនុគ្រោះខ្លាំង( MFN)។ រាល់ការចរចាប្រព្រឹត្តទៅតាមជុំៗ រៀងរាល់ជុំនីមួយៗ រដ្ឋទាំងអស់សន្យាបន្ថែមវិស័យរណបថ្មីៗ។*

### ១.៣.២- ទស្សនៈវិស័យបច្ចុប្បន្ន

*ចាប់ពីឆ្នាំ១៩៩៦មក ប្រទេសអាស៊ានទាំងអស់បានសម្រេចបាននូវការអនុវត្ត«កញ្ចប់»នៃការសន្យាទី៧ដែលចែងដោយកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីសេវាកម្ម តាមរយៈវដ្ដនៃការចរចាចំនួន៥។ «កញ្ចប់»សន្យាទី៨ត្រូវបានចុះហត្ថលេខានៅអំឡុងពេលកិច្ចប្រជុំកំពូលនាឆ្នាំ២០១០នៅទីក្រុងហាណូយ។ កម្មវត្ថុចុងក្រោយគឺការលុបបំបាត់រាល់ការរឹតត្បិតទៅលើពាណិជ្ជកម្មទាំងអស់ចាប់ពីឆ្នាំ២០១៥ លើកលែងវិស័យអាទិភាព៤ដែលលឿនជាងគេ គឺការដឹកជញ្ជូនតាមផ្លូវអាកាស ពាណិជ្ជកម្មអេឡិចត្រូនិក ការព្យាបាលជំងឺ និងទេសចរណ៍។ សម្រាប់ករណីសេវាកម្មហិរញ្ញវត្ថុពិសេស សេរីភាវូបនីយកម្មប្រព្រឹត្តទៅតាមសុច្ឆន្ទៈរបស់រដ្ឋសមាជិក ដើម្បីសម្រួលដល់ស្ថិរភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ច។*

*សេរីភាវូបនីយកម្មទៅលើសេវាកម្មហិរញ្ញវត្ថុនេះអាចត្រូវបានសម្រេចធ្វើទៅតាមរូបមន្តអាស៊ាន-X ដើម្បីគោរពទៅតាមកម្មវត្ថុនយោបាយជាតិ។*

#### ១.៣.២.១- បញ្ជីនៃការសន្យា

*ចាប់ពីឆ្នាំ២០០៨-២០០៩ រដ្ឋទាំងអស់បានចូលរួមបង្កើនបញ្ជីដែលធ្វើសេរីភាវូបនីយកម្ម។ សម្រាប់ឆ្នាំ២០១០-២០១១ ត្រូវមានវិស័យបន្ថែមពី១០ទៅ២០វិស័យ។*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.៣.២.២- ការលុបបំបាត់ការរឹតត្បិត

*ចាប់ពីឆ្នាំ២០០៨-២០០៩មក រដ្ឋទាំងអស់បានលុបបំបាត់ការរឹតត្បិតទាំងអស់ចោល សម្រាប់វិធី១ និងវិធី២នៃពាណិជ្ជកម្មសេវាកម្ម។ វិធី១ គឺការផ្គត់ផ្គង់ឆ្លងដែន និងវិធី២គឺការប្រើប្រាស់នៅបរទេសដោយបុគ្គលនៃប្រទេសមួយទៀត។*

### ១.៣.២.៣- លទ្ធភាពចូលទីផ្សារ

*រដ្ឋទាំងអស់សន្យាលុបរបាំងចូលទីផ្សារសម្រាប់វិធី៣ ពោលគឺវត្តមានពាណិជ្ជកម្ម សំដៅបង្កើតសាខាតាមរយៈសហគ្រាសបរទេសសម្រាប់ផ្គត់ផ្គង់សេវាកម្មក្នុងប្រទេសមួយទៀត។*

## ១.៤- សេរីភាវូបនីយកម្មទៅលើចរាចរកម្មករឯកទេស

*ជាក់ស្ដែង វិស័យនេះជាផ្នែកនៃសេរីភាវូបនីយកម្មនៃពាណិជ្ជកម្មសេវាកម្មដែលជាវត្តមានរូបវ័ន្តបុគ្គលបរទេសក្នុងប្រទេសមួយសម្រាប់ការផ្សព្វផ្សាយ ឬសម្រេចសេវាកម្ម។ គេគួរជ្រើសរើសវិធី៤កំណត់ដោយកិច្ចព្រមព្រៀងទូទៅស្ដីពីពាណិជ្ជកម្មសេវាកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោកដែលបញ្ជូនរូបវ័ន្តបុគ្គលបរទេសរបស់ខ្លួនដែលចាកចេញពីប្រទេសរបស់គេដើម្បីផ្ដល់សេវាកម្មជូនប្រទេសផ្សេងៗ។ សេរីភាវូបនីយកម្មទៅលើកម្មករឯកទេសក្នុងអាស៊ានត្រូវឆ្លងកាត់ការជ្រើសរើស និងមានកម្រិតនៅឡើយនាពេលបច្ចុប្បន្ន។*

*សកម្មភាពចម្បងលើផែនការជាក់ស្ដែងគឺសម្រួលដល់ការចេញទិដ្ឋាការ ព្រមទាំងប័ណ្ណសម្គាល់ការងារ ប័ណ្ណអនុញ្ញាត សម្រាប់តែអ្នកអាជីព ជាអាទិ៍ដល់កម្មករឯកទេស។ សេរីភាវូបនីយកម្មនេះក៏ពាក់ព័ន្ធនឹងសាកលវិទ្យាល័យ ហើយទេសន្តរប្រវេសន៍របស់និស្សិតទទួលបានការជំរុញផងដែរ។ វិស័យសកម្មភាពឯកសិទ្ធិគឺពាណិជ្ជកម្មឆ្លងដែន និងសកម្មភាពពាក់ព័ន្ធវិនិយោគ។*

*កិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមកជាច្រើនត្រូវបានចុះហត្ថលេខាក្នុងអាស៊ានស្ដីពីសេវាកម្មគណនេយ្យ ការព្យាបាលជំងឺ ដូចជាទន្តបណ្ឌិត សេវាវិស្វកម្ម ស្ថាបត្យករ និងអ្នកវាស់វែងដីធ្លី(surveyor)។ សកម្មភាពរបស់សហគមន៍អាស៊ាននាពេលអនាគតគឺបំពេញបញ្ជីវិជ្ជាជីវៈក្នុងវិស័យពាក់ព័ន្ធពីមួយឆ្នាំទៅមួយឆ្នាំ ពោលគឺរៀងរាល់ឆ្នាំ គេចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមកសម្រាប់វិស័យថ្មីៗ។*

## ២- សេរីភាវូបនីយកម្មហិរញ្ញវត្ថុ

*រដ្ឋអាស៊ានទាំងអស់ត្រូវការមូលនិធិហិរញ្ញវត្ថុក្នុង និងលំហូរពីខាងក្រៅ។ វិស័យពីរមានសេរីភាវូបនីយកម្មទៅលើវិនិយោគ និងមូលធន។*

## ២.១- សេរីភាវូបនីយកម្មទៅលើវិនិយោគ

*វិស័យវិនិយោគត្រូវបានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌតំបន់វិនិយោគអាស៊ាន(AIA) ចុះនៅឆ្នាំ១៩៩៨ និងក្នុងកិច្ចព្រមព្រៀងលើកស្ទួយ និងការពារវិនិយោគរបស់អាស៊ានដែលចុះហត្ថលេខានៅឆ្នាំ១៩៨៧។ កិច្ចព្រមព្រៀងឆ្នាំ១៩៩៨នេះបានឆ្លងកាត់វិសោធនកម្មពីពិធីសារឆ្នាំ២០០១ និងវិវត្តន៍ចុងក្រោយនៃវិស័យវិនិយោគ។ កិច្ចព្រមព្រៀងពេញលេញថ្មីនៃអាស៊ានស្តីពីវិនិយោគ(ASEAN Comprehensive Investment Agreement-ACIA) ត្រូវបានចុះហត្ថលេខានាឆ្នាំ២០០៩ ក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី១៤នៅប្រទេសថៃ។*

## ២.១.១- មូលដ្ឋានគ្រឹះគតិយុត្តនៃសេរីភាវូបនីយកម្មវិនិយោគ

*ក្នុងមាត្រា៣នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌឆ្នាំ១៩៩៨ គ្រប់រដ្ឋទាំងអស់សន្យាទាក់ទាញលំហូរវិនិយោគទាំងក្នុង និងក្រៅតំបន់ចូលមកក្នុងតំបន់អាស៊ាន។ ទីតាំងអាស៊ានផ្នែកវិនិយោគនេះអាស្រ័យផលប្រព្រឹត្តកម្មជាតិបានយ៉ាងច្រើន ពិសេសផ្នែកវិនិយោគិននៅអាស៊ីអាគ្នេយ៍ នាឆ្នាំ២០១០ និងប្រព្រឹត្តកម្មជាតិពាក់ព័ន្ធនឹងវិនិយោគិននាឆ្នាំ២០២០ក្នុងវិស័យឧស្សាហកម្ម។ វិនិយោគផ្ទាល់ពីបរទេសកើនដល់៥០ពាន់លានដុល្លារ។*

## ២.១.២- ទស្សនៈវិស័យបច្ចុប្បន្ន

*វិធានការពីរត្រូវបានជ្រើសយកគឺ (១) វិធានការសេរីភាវូបនីយកម្ម (២) វិធានការលើកស្ទួយ និងការពារ។*

*១) វិធានការសេរីភាវូបនីយកម្ម គឺសេរីភាវូបនីយកម្មជាលំដាប់ដែលត្រូវឈានទៅសម្រេចឱ្យបាននូវប្រព័ន្ធបើកចំហទាំងស្រុងមួយ ពោលគឺប្រព្រឹត្តកម្មពុំរើសអើង អាចផ្អែកទៅលើប្រព្រឹត្តកម្មជាតិ ឬទៅលើឋានៈប្រជាជាតិទទួលបានការអនុគ្រោះខ្លាំង(MFN) ទាំងសម្រាប់វិនិយោគិនក្នុងតំបន់ និងវិនិយោគិនក្រៅតំបន់។*

*២) វិធានការលើកស្ទួយ និងការពារ។*

*ក. ពាក់ព័ន្ធវិធានការលើកស្ទួយ គឺរដ្ឋអាស៊ានទាំងអស់ប្តេជ្ញាចាត់វិធានការរាំង ឬឧបសគ្គរារាំងដល់វិនិយោគ។ ក្នុងនោះ រដ្ឋអាស៊ានប្តេជ្ញាជានាបញ្ជូន ឬទាញមូលធន ប្រាក់ចំណេញភាគលាភចូលក្នុងស្រុក។*

*ខ. ពាក់ព័ន្ធវិធានការការពារ គឺរដ្ឋអាស៊ានទាំងអស់ប្តេជ្ញាធ្វើឱ្យនីតិវិធី បទដ្ឋានទាំងអស់សម្រាប់វិនិយោគិនកាន់តែមានតម្លាភាព និងសង្គតភាព។*

*ទិនានុលេខន៍អនុវត្តរបស់សហគមន៍សេដ្ឋកិច្ចគឺថា ប្រតិទិនដែលអនុម័តមាន ៖*

### ២.១.២.១- សេរីភាវូបនីយកម្ម

*ខ្លឹមសារសេរីភាវូបនីយកម្មមានលក្ខណៈសាមញ្ញ នោះគឺការកាត់បន្ថយ និងលុបបំបាត់ការរឹតត្បិត និងរបាំងដល់វិនិយោគិនទាំងអស់។ សេរីភាវូបនីយកម្មនេះប្រតិបត្តិការជាបីថ្នាក់ គឺបីដំណាក់កាល។*

***ដំណាក់កាលទី១ ៖*** *បានចាប់ផ្តើមនាឆ្នាំ២០០៨ និងសឹងតែបញ្ចប់នាឆ្នាំ២០១០សម្រាប់អាស៊ាន-៨( លើកលែងប្រទេសឡាវ និងមីយ៉ាន់ម៉ា)។*

***ដំណាក់កាលទី២ ៖*** *បានចាប់ផ្តើមនាឆ្នាំ២០១១ និងបញ្ចប់ឆ្នាំ២០១២សម្រាប់អាស៊ាន-៨ និងសម្រាប់ប្រទេសឡាវ និងមីយ៉ាន់ម៉ានាឆ្នាំ២០១៣។*

***ដំណាក់កាលចុងក្រោយ ៖*** *ចាប់ផ្តើមនាឆ្នាំ២០១២-២០១៣ និងបញ្ចប់នាឆ្នាំ២០១៤ សម្រាប់អាស៊ាន-៨ និងបញ្ចប់សម្រាប់ឆ្នាំ២០១៥សម្រាប់ប្រទេសផ្សេងទៀត។*

### ២.១.២.២- ការសម្រួលដែលផ្តល់ឱ្យដោយអាស៊ាន

*ការបង្កើតរបបបើកចំហក្នុងវិស័យវិនិយោគ និងដោយសេរីត្រូវសម្រេចនាឆ្នាំ២០១៥។ ប៉ុន្តែនាឆ្នាំ២០១៥នេះដែរ ការអនុម័តវិធានការសុខដុមរមណីយកម្មក្នុងការធ្វើសេរីភាវូបនីយកម្មនូវភាពងាយស្រួលសម្រាប់សកម្មភាពវិនិយោគ។*

## ២.២- សមាហរណកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុ

### ២.២.១- ផែនទីបង្ហាញផ្លូវសម្រាប់សមាហរណកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុអាស៊ាន

*សមាហរណកម្មហិរញ្ញវត្ថុត្រូវបានដឹកនាំដោយផែនទីបង្ហាញផ្លូវសម្រាប់សមាហរណកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុអាស៊ាន។ ផែនទីនេះមានគោល៣គឺការអភិវឌ្ឍទីផ្សារមូលធន សេរីភាវូបនីយកម្មទៅលើសេវាកម្មហិរញ្ញវត្ថុ និងសេរីភាវូបនីយកម្មគណនីមូលធន។*

### ការអភិវឌ្ឍទីផ្សារមូលធន

*វិស័យទីផ្សារមូលធនពាក់ព័ន្ធនឹងទិដ្ឋភាពពីរគឺការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណ និងសមាហរណកម្មទីផ្សារមូលធន( ទីផ្សារភាគហ៊ុន)។ ពាក់ព័ន្ធនឹងទីផ្សារសញ្ញាបណ្ណ គេផ្តល់ភាពចាំបាច់ទៅលើយន្តការជានា ប្រព័ន្ធបង់ប្រាក់ ព្រមទាំងសំណាង និងការអភិវឌ្ឍទីភ្នាក់ងារទទួលបន្ទុកកំណត់ត្រាក្នុងស្រុក។ កម្មវត្ថុគឺធ្វើសមាហរណកម្មទីផ្សារសញ្ញាបណ្ណជាតិទៅជាទីផ្សារតំបន់។ ពាក់ព័ន្ធនឹងផ្សារមូលធន ត្រូវធ្វើការបែងចែកជាពីរដំណាក់កាលគឺ(១) ដំណាក់ទីមួយគឺសំដៅដល់ការកែទីផ្សារមានស្រាប់ទាំងអស់ឱ្យបានប្រសើរ និងការបង្កើតទីផ្សារថ្មីក្នុងរដ្ឋពុំទាន់មាន និង(២)*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ដំណាក់កាលទីពីរ គឺសមាហរណកម្មទីផ្សារមូលធន។*

## សេរីភាវូបនីយកម្មនៃសេវាកម្មហិរញ្ញវត្ថុ

*សេវាកម្មហិរញ្ញវត្ថុក្នុងប្រទេសអាស៊ានទាំងអស់ត្រូវបានធ្វើសេរីភាវូបនីយកម្មក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម(AFAS) ឆ្នាំ១៩៩៥។ រដ្ឋសមាជិកបានឯកភាពធ្វើការប្ដេជ្ញានឹងផ្ដល់ការសន្យាមួយ យ៉ាងហោចណាស់ក្នុងអនុវិស័យរួមមួយ នៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចចរចា។ ការប្ដេជ្ញានេះត្រូវហួសពីការប្ដេជ្ញាក្នុងGATS សម្រាប់រដ្ឋសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ហើយមានលក្ខណៈអនុគ្រោះជាងរបបបច្ចុប្បន្នសម្រាប់ប្រទេសនៅក្រៅអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់។ រដ្ឋសមាជិកទាំងអស់មានសិទ្ធិកំណត់គ្រប់ដំណាក់កាលសេរីភាវូបនីយកម្មទៅលើអនុវិស័យ និងបំបាត់រាល់ភាពរឹតត្បិតទាំងឡាយណាទៅនឹងវិធីផ្ដល់សេវាកម្មទាំងបួន ដោយអនុលោមទៅតាមបញ្ញត្តិនៃGATSស្ដីពីលទ្ធភាពចូលទីផ្សារ ប្រព្រឹត្តកម្មជាតិ និងគោលការណ៍ស្ដីពីប្រទេសជាតិដែលទទួលបានការអនុគ្រោះបំផុត(MFN)។ ដំណាក់កាលចរចាទីផ្សារស្ដីពីសេវាកម្មហិរញ្ញវត្ថុបានប្រព្រឹត្តទៅតាមនីតិវិធីបញ្ជីវិជ្ជមាន ហើយត្រូវបានធ្វើនៅឆ្នាំ២០១០។*

## សេរីភាវូបនីយកម្មនៃគណនីមូលធន

*ដំណើរការសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានបានចែងពីសេរីភាវូបនីយកម្មតាមលំដាប់ទៅលើគណនីមូលធនក្នុងបំណងគាំទ្រកំណើនសេដ្ឋកិច្ច និងជានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សហគមន៍អាស៊ានមានកម្មវត្ថុបង្កើតចរាចរណ៍មូលធនសេរីនាឆ្នាំ២០១៥ដែលជួយឱ្យប្រសិទ្ធភាពសេដ្ឋកិច្ច និងសុខមាលភាពតំបន់មានភាពប្រសើរឡើង។ ប៉ុន្តែ សេរីភាវូបនីយកម្មទៅលើទីផ្សារហិរញ្ញវត្ថុអាចនឹងផ្ដល់នូវប្រសិទ្ធភាពសេដ្ឋកិច្ច ប្រសិនបើការត្រួតពិនិត្យហ្មត់ចត់មានលក្ខណៈល្អ អភិបាលកិច្ចល្អទៅលើសហគ្រាសមានភាពខ្លាំង សិទ្ធិឥណទាយីត្រូវបានគោរពត្រឹមត្រូវ ស្តង់ដារគណនេយ្យ និងសវនកម្មមានតម្លាភាព ហើយនីតិវិធីធនាគារ និងនីតិវិធីអសា-ធនភាពត្រូវអនុវត្តបានត្រឹមត្រូវ។ ក្នុងគោលបំណងនេះ គេហទំព័រស្ដីពីរបបគណនីមូលធនបានចាប់ផ្ដើមបង្ហោះនាខែមេសា ឆ្នាំ២០០៦ អំឡុងពេលជំនួបទី១០រវាងរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ដើម្បីអនុញ្ញាតដល់គ្រប់ប្រទេសជាសមាជិកធ្វើការកំណត់របបមួយដែលសមស្របសម្រាប់ខ្លួន និងចាត់វិធានការធ្វើកំណែទម្រង់ស្ថាប័នហិរញ្ញវត្ថុ និងអាជ្ញាធរនិយតករ។*

*ពាក់ព័ន្ធនឹងការកៀរគរមូលធន រដ្ឋអាស៊ានទាំងអស់បានប្ដេជ្ញាធ្វើសេរីភាវូបនីយកម្មគ្រប់ចលនាសកម្មភាពទាំងអស់។ គោលការណ៍ចំនួន៣ត្រូវតែគោរពតាមគឺ(១) ការគោរពទិនានុ-*

លេខន៍ដែលរដ្ឋសមាជិកអាស៊ានទាំងអស់បានគ្រោង សមត្ថភាពស្រូបទាញសេដ្ឋកិច្ចរបស់ខ្លួន (២) ការអនុញ្ញាតទៅលើវិធានការសង្គ្រោះសមស្រប ករណីអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីកាត់បន្ថយហានិភ័យជាប្រព័ន្ធពាក់ព័ន្ធនឹងដំណើរការសេរីភាវូបនីយកម្ម និង(៣) ការធានាផលវិបាកសេដ្ឋកិច្ចសមធម៌សម្រាប់រដ្ឋសមាជិកនីមួយៗ។

ជាឧទាហរណ៍នៃសកម្មភាពជាក់ស្តែង យើងឃើញមានលទ្ធភាពបន្ថយ និងថែមទាំងលុបបំបាត់ភាពរឹតត្បិតនានា ដើម្បីសម្រួលការបង់ប្រាក់ និងប្រតិបត្តិការសេដ្ឋកិច្ចរបស់គណនីចរន្ត។ យោងទៅតាមទិនានុលេខន៍នៃផែនការរបស់សហគមន៍សេដ្ឋកិច្ច សេរីភាវូបនីយកម្មបានចាប់ផ្តើមក្រោយឆ្នាំ២០១៥ប៉ុណ្ណោះ ដោយរង់ចាំឱ្យសកម្មភាពចូលរួមទាំងអស់នោះមានភាពសុខដុមរមណីយកម្មក្នុងប្រព័ន្ធ និងរង់ចាំឱ្យមានការចែករំលែកព័ត៌មានរវាងរដ្ឋសមាជិកដើម្បីអនុវត្តទីផ្សារហិរញ្ញវត្ថុ និងទីផ្សារមូលធនរួមសិន ដើម្បីឱ្យអាស៊ានទាក់ទាញខ្លាំងដល់វិនិយោគិនបរទេស។

## ២.២.២- សហប្រតិបត្តិការហិរញ្ញវត្ថុរបស់អាស៊ាន

សហប្រតិបត្តិការហិរញ្ញវត្ថុរបស់អាស៊ានមានគោល៤គឺ ការពិនិត្យមើលលើម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ សហប្រតិបត្តិការគយ និងសហប្រតិបត្តិការផ្នែកពន្ធដារ។

### ការពិនិត្យមើលលើម៉ាក្រូសេដ្ឋកិច្ច

រដ្ឋសមាជិកទាំងអស់ឯកភាពគ្នាក្នុងការពង្រឹងការពិនិត្យមើលលើម៉ាក្រូសេដ្ឋកិច្ចតំបន់ដើម្បីគ្រប់គ្រងហានិភ័យ និងភាពទន់ខ្សោយឱ្យបានល្អ។ ដើម្បីសម្រេចគោលដៅនេះ ការិយាល័យត្រួតពិនិត្យម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយទើបនឹងត្រូវបានបង្កើតឡើង។

### ហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ

ប្រទេសអាស៊ានទាំងអស់ និងធនាគារអភិវឌ្ឍអាស៊ី(ADB)បានបង្កើតមូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ានមួយក្នុងទឹកប្រាក់៥០០លានដុល្លារ។ មូលនិធិនេះត្រូវមានស្នាក់ការនៅប្រទេសម៉ាឡេស៊ី ដើម្បីទ្រទ្រង់គម្រោងទាំងឡាយណាដែលមានបំណងពង្រឹងទំនាក់ទំនង និងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ។

### សហប្រតិបត្តិការគយ

សហប្រតិបត្តិការនេះផ្តោតទៅលើបញ្ចរតែមួយរបស់អាស៊ានលើប្រព័ន្ធឆ្លងកាត់គយអាស៊ាន

និងលើមធ្យោបាយសម្រួលដល់ការគ្រប់ពាណិជ្ជកម្មទាំងអស់។

**សហប្រតិបត្តិផ្នែកសារពើពន្ធ**

វេទិកាអាស៊ានស្តីពីសារពើពន្ធបានត្រូវបង្កើតឡើង ដើម្បីលើកស្ទួយសមាហរណកម្មតំបន់។ វេទិកានេះបានគ្រោងសកម្មភាពដំបូងទៅលើពន្ធកាត់ទុក និងការយកពន្ធទ្វេ។

# ផ្នែកទី៧

## សហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ និងក្រៅតំបន់

ចំពោះវិស័យសមាហរណកម្មតំបន់ សហប្រតិបត្តិការសេដ្ឋកិច្ចរបស់អាស៊ាន ដំបូងគឺជាសហប្រតិបត្តិការក្នុងតំបន់ ប៉ុន្តែនេះក៏ជាសហប្រតិបត្តិការក្រៅតំបន់ផងដែរ ក្នុងនោះមានដៃគូតំបន់ដូចជាប្រទេសចិន ជប៉ុន កូរ៉េ និងដៃគូផ្សេងទៀត។

**១- សហប្រតិបត្តិការក្នុងតំបន់**

សហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់មានផែនការច្បាស់លាស់ នៅត្រង់គោលទី២ និងទី៣ នៃផែនការសហគមន៍សេដ្ឋកិច្ច។ ក្នុងនោះ មានអ័ក្សពីរគឺ (១) តម្រង់ទិសតំបន់ឆ្ពោះទៅរកសេដ្ឋកិច្ចប្រកួតប្រជែងខ្លាំង និង(២) តម្រង់ទិសតំបន់ឆ្ពោះទៅរកសេដ្ឋកិច្ចសមធម៌ខ្លាំង។

**១.១- តម្រង់ទិសតំបន់ឆ្ពោះទៅរកសេដ្ឋកិច្ចប្រកួតប្រជែងខ្លាំង**

គោលទី២នេះបំពេញនយោបាយទីផ្សាររួម។ គោលទី២នេះជាដំបូងបញ្ចូលនូវនយោបាយការពារឯកបុគ្គល ក្នុងនាមជាអ្នកប្រើប្រាស់ផលិតផល ឬក្នុងនាមជាម្ចាស់កម្មសិទ្ធិបញ្ញាស្របច្បាប់។ បន្ទាប់មក គោលនេះបញ្ចូលនយោបាយមួយក្នុងការប្រកួតប្រជែងលើវិស័យដោយឡែកមួយចំនួន។

**១.១.១- នយោបាយការពារ**

**១.១.១.១- ការការពារអ្នកប្រើប្រាស់**

លើកលែងប្រទេសសិង្ហបុរីចេញ នៅក្នុងអាស៊ាន អ្នកប្រើប្រាស់ទាំងអស់ពុំទាន់ទទួលបានការការពារនៅឡើយទេ។ ដើម្បីបង្កើតសេដ្ឋកិច្ចសេរី ពុំត្រូវធ្វេសប្រហែសលើការការពារអ្នកប្រើ-

ប្រាស់ឡើយ។ ការការពារអ្នកប្រើប្រាស់ត្រូវបញ្ចូលក្នុងសមាហរណកម្មសេដ្ឋកិច្ច។ រដ្ឋអាស៊ានទាំងអស់ត្រូវធ្វើសកម្មភាពពីរជាក់លាក់គឺ (១) បង្កើតគណៈកម្មការសម្របសម្រួលអាស៊ានទទួលបន្ទុកការពារអ្នកប្រើប្រាស់ (២) បង្កើតប្រព័ន្ធភ្នាក់ងារការពារអ្នកប្រើប្រាស់ (ក)ដើម្បីសម្រួលពាណិជ្ជកម្ម និងការចែករំលែកព័ត៌មានក្នុងវិស័យការពារអ្នកប្រើប្រាស់ (ខ)បង្កើតមន្ត្រីថ្នាក់ជាតិក្នុងវិស័យការពារអ្នកប្រើប្រាស់។ ចាប់ពីឆ្នាំ២០១៥ ការការពារទទួលបានការធានា។

## ១.១.១.២- កម្មសិទ្ធិបញ្ញា

សញ្ញាណកម្មសិទ្ធិបញ្ញានៅមានគេស្គាល់តិចតួចនៅឡើយក្នុងសង្គមប្រពៃណីអាស៊ានជាអាទិ៍នៅគ្រប់តំបន់ និងខេត្តជុំវិញ។ កម្មសិទ្ធិបញ្ញាជាញឹកញាប់ត្រូវបានគេបញ្ចូលក្នុងនីតិកម្មអន្តរជាតិ ដោយផ្អែកលើគតិវិនិច្ឆ័យរបស់ប្រទេសអភិវឌ្ឍ។ ពាក់ព័ន្ធកម្មសិទ្ធិបញ្ញា នយោបាយល្អអាចជាមធ្យោបាយលើកទឹកចិត្តក្នុងការស្វែងរក ច្នៃប្រឌិត បង្កើត និងពាណិជ្ជកម្មលើការបង្កើតឬការស្វែងរកនេះ។ ក្នុងន័យម្យ៉ាងទៀត ក្នុងការអភិវឌ្ឍទៅលើផែនការជាតិ នយោបាយស្វែងរកគឺជាអត្ថប្រយោជន៍ឥតប្រកែកបានសម្រាប់សេដ្ឋកិច្ចរបស់ប្រទេសមួយ។ ក្នុងទស្សនៈវិស័យនេះការការពារកម្មសិទ្ធិបញ្ញាត្រូវលើកស្ទួយកេរមត៌កប្រពៃណីរបស់រដ្ឋក្នុងតំបន់ និងធ្វើទំនើបកម្មកេរមត៌កនេះ ដើម្បីស្វែងរកលំនាំឥទ្ធិពលថ្មីមួយ។ ពាក់ព័ន្ធនឹងបញ្ហាចោទទៅលើសិទ្ធិនេះ នយោបាយការពារពុំត្រូវបង្អាក់ដល់ការចែករំលែក ឬផ្ទេរបច្ចេកវិទ្យារវាងរដ្ឋសមាជិកទេ។ ដើម្បីគោលដៅនេះ សកម្មភាពរបស់រដ្ឋអាស៊ានត្រូវមាន (១) ការទទួលពិធីសារម៉ាឌ្រីតឆ្នាំ១៩៨៩(សម្រាប់កត់ត្រាម៉ាកអន្តរជាតិនានា។ អង្គភាពទទួលបន្ទុកពិធីសារនេះ គឺការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(OMPI)ដែលមានទីស្នាក់ការនៅទីក្រុងហ្សឺណែវ) (២) ការការពារប្រព័ន្ធសហប្រតិបត្តិការស្តីពីចំណេះដឹងប្រពៃណី និងធនធានសេនេទិច។ យោងតាមទិន្នន័យលេខនៃផែនការសហគមន៍សេដ្ឋកិច្ច កម្មវត្ថុចម្បងខ្លះសម្រេចបាននៅឆ្នាំ២០១៥ ក្នុងនោះមាន (១) ការគ្រប់គ្រងរួមទៅលើប្រព័ន្ធសិទ្ធិអ្នកនិពន្ធ (២) ការបង្កើតទិន្នន័យចំណេះដឹងប្រពៃណី (៣) ការអនុវត្តពិធីសារម៉ាឌ្រីត។

## ១.១.១.៣- នយោបាយប្រកួតប្រជែង

នយោបាយនេះមានបំណងលើកស្ទួយការប្រកួតប្រជែងដោយស្មោះត្រង់ដោយផ្អែកលើស្ថាប័ន និងធម្មនិយាមទាំងអស់ដែលរដ្ឋសមាជិកអនុវត្ត។ ជាដំបូងនៅថ្នាក់ជាតិ អាស៊ានមានសកម្មភាពជំរុញការបញ្ចូលវិធានប្រកួតប្រជែងស្មោះត្រង់ទៅក្នុងច្បាប់ជាតិ។ ប៉ុន្តែ នៅថ្នាក់តំបន់គឺបង្កើតប្រព័ន្ធអាជ្ញាធរ ឬភ្នាក់ងារជាតិទទួលបន្ទុកដឹកនាំនយោបាយប្រកួតប្រជែង។ អាស៊ានក៏

ត្រូវបង្កើតនៅថ្នាក់ជាតិផងដែរនូវមគ្គុទេសក៍អនុវត្តទៅលើការប្រកួតប្រជែង។ មគ្គុទេសក៍នេះត្រូវគិតគូរទៅដល់ការអនុវត្តជាតិ និងអន្តរជាតិផងដែរក្នុងវិស័យប្រកួតប្រជែង។ ផែនការសហគមន៍សេដ្ឋកិច្ចបានគ្រោងធ្វើសេចក្តីព្រាងផែនការតំបន់ចាប់ពីឆ្នាំ២០១១មក។

## ១.១.២- គោលនយោបាយពាក់ព័ន្ធនឹងវិស័យតាមផ្នែក

### ១.១.២.១- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

អាស៊ានបានកំណត់ហេដ្ឋារចនាសម្ព័ន្ធតាមបែបពង្រីក។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្របដណ្តប់ពុំត្រឹមតែទៅលើបញ្ហាដឹកជញ្ជូនទេ ថែមទាំងគ្របដណ្តប់លើបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាទំនាក់ទំនង ថាមពល និងអាជីវកម្មរ៉ែផងដែរ។

វិស័យដែលទំនងជាមានអាទិភាពជាងគេគឺវិស័យដឹកជញ្ជូន ពីព្រោះការសាងសង់លំហសេដ្ឋកិច្ចដែលធ្វើសមាហរណកម្មពុំអាចប្រព្រឹត្តទៅដោយពុំមានការកែលម្អ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកដឹកជញ្ជូនបានទេ។ សេរីភាវូបនីយកម្មនឹងរាំងស្ទះ ប្រសិនបើការអភិវឌ្ឍវិស័យដឹកជញ្ជូនពុំគ្រប់គ្រាន់។ តាមលក្ខណៈធម្មជាតិ ភូមិសាស្ត្ររូបវន្តអាស៊ានបង្កើតជាឧបសគ្គដល់ការបំលាស់ទីផ្ទៃក្នុង។ នៅថ្នាក់ជាតិ ឧបសគ្គគឺចោទទៅលើរដ្ឋដែលមានលក្ខណៈជាកោះដូចជាប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី។ ប្រទេសឥណ្ឌូនេស៊ីមានកោះ និងកូនកោះចំនួន១៧ ០០០ ឯហ្វីលីពីនវិញមានកោះ និងកូនកោះចំនួន៧ ២០០។

ក្រៅពីឧបសគ្គភូមិសាស្ត្ររូបវន្តនេះ អាស៊ានត្រូវផ្តល់ជូនរដ្ឋសមាជិកនូវបណ្តាញផ្លូវថ្នល់សម្រាប់ការដឹកជញ្ជូនទំនិញតាមផ្លូវគោក និងបង្កើតទីផ្សារតែមួយសម្រាប់ការដឹកជញ្ជូនតាមផ្លូវទឹក និងអាកាស។ សេរីភាវូបនីយកម្មការដឹកជញ្ជូនតាមផ្លូវអាកាសបិតក្រោមការដឹកនាំពីនយោ-បាយអាស៊ានបើកចំហដែលបើកចរាចរណ៍ផ្លូវអាកាសឥតដែនកំណត់ដល់ទីក្រុងទាំងអស់ក្នុងតំបន់។

ផែនការសហគមន៍សេដ្ឋកិច្ចបានព្រាងការអនុម័តបទដ្ឋានធម្មនិយាមសម្រាប់ការដឹកជញ្ជូនក្រៅសកម្មភាពសេដ្ឋកិច្ច។ ទោះបីជាមានវឌ្ឍនភាពក្តី(កិច្ចប្រជុំនៅទីក្រុងហាណូយ ឆ្នាំ២០១០) ក៏គម្រោងសាងសង់ផ្លូវក្នុងអាស៊ាននៅមានតិចតួចនៅឡើយ។ ថ្នាក់ដឹកនាំអាស៊ានទាំងអស់សុទ្ធតែយល់ថា ទាំងនេះជាចំណុចសំខាន់។

### ១.១.២.២- ពាណិជ្ជកម្មអេឡិចត្រូនិក

ពាណិជ្ជកម្មអេឡិចត្រូនិកពុំទាន់ជាចំណោទសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់នៅឡើយទេ។ ពាណិជ្ជកម្មអេឡិចត្រូនិកត្រូវនៅរង់ចាំយូរអង្វែងទៀត។ ចំពោះមុខ សកម្មភាពអាស៊ានផ្នែក


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាណិជ្ជកម្មអេឡិចត្រូនិកផ្ដោតទៅលើទិដ្ឋភាពគតិយុត្ត ជាអាទិ៍ទី១ ត្រូវជំរុញរដ្ឋសមាជិកឱ្យបង្កើតគ្រប់នីតិកម្មជាតិ។ ទីពីរ ត្រូវអនុម័តរាល់នីតិកម្មស្ដីពីការទទួលស្គាល់ហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិកទៅវិញទៅមក( នៅប្រទេសបារាំង ក្រុមរដ្ឋប្បវេណីបានចែងថា ហត្ថលេខាអេឡិចត្រូនិកមានតម្លៃស្មើគ្នានឹងហត្ថលេខាដោយដៃ)។ ទី៣ ត្រូវធ្វើសុខដុមរមណីយកម្មលើនីតិវិធីកិច្ចសន្យា និងលើការដោះស្រាយអធិករណ៍ពាក់ព័ន្ធនឹងពាណិជ្ជកម្មអេឡិចត្រូនិក។ ផែនការសហគមន៍សេដ្ឋកិច្ច បានគ្រោងនីតិកម្មធ្វើសុខដុមរមណីយកម្មរវាងរដ្ឋអាស៊ានទាំងអស់នាពេលឆាប់ៗខាងមុខ។

សហប្រតិបត្តិការផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង(ITC)បានគ្រោងបង្កើតគេហបថល្បឿនលឿន ការបញ្ជាក់ជំនាញការផ្នែកIT ការធ្វើសុខដុមរមណីយកម្មលើធម្មនិយាមផ្នែកIT លើសុវត្ថិភាពអ៊ិនធឺណិត(Cyber) សេវាកម្មសកល និងសេវាកម្មអេឡិចត្រូនិក។

## ១.២ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌

នេះជានយោបាយក្នុងគោលទីបីដែលមានបំណងឆ្ពោះទៅរកសេដ្ឋកិច្ចប្រកបដោយសមធម៌រវាងរដ្ឋសមាជិកអាស៊ាន។ នយោបាយនេះមានសកម្មភាពចម្បងពីរគឺ (១)ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និង(២) កិច្ចផ្ដួចផ្ដើមអាស៊ានដើម្បីបំពេញលើភាពខុសគ្នានៃការអភិវឌ្ឍរវាងរដ្ឋ និងរដ្ឋ។

### ១.២.១- ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម

សេដ្ឋកិច្ចអាស៊ានផ្សំជាចម្បងពីសហគ្រាសធុនតូច និងមធ្យម និងពីវិស័យក្រៅផ្លូវការ។ សេរីភាវូបនីយកម្មលើសេដ្ឋកិច្ចត្រូវមានកោសិកាសេដ្ឋកិច្ចរបស់សហគ្រាសធុនតូច និងមធ្យមដែលមានអង្គការចាត់តាំង និងរចនាសម្ព័ន្ធត្រឹមត្រូវ។ ករណីមានហានិភ័យក្នុងផ្នែកបង្កើតរចនាសម្ព័ន្ធកម្ម ផលវិបាកសេដ្ឋកិច្ចនឹងពុំត្រូវបានចែកចាយដោយសមធម៌ទេ។ នេះគឺជាការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។ សហគ្រាសធុនតូច និងមធ្យមមានលក្ខណៈចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចអាស៊ាន។ ដើម្បីទ្រទ្រង់សហគ្រាសធុនតូច និងមធ្យមទាំងអស់ កាលពីថ្ងៃទី០៣ កញ្ញា ២០០៤ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចបានអនុម័តផែនការសកម្មភាពសម្រាប់អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមសម្រាប់ឆ្នាំ២០០៤-២០១៤ ក្នុងគោលបំណងអភិវឌ្ឍ និងគាំទ្រដល់ការបង្កើតសហគ្រាសធុនតូច និងមធ្យមដើម្បីបង្កើនល្បឿនការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមទាំងអស់ និងឱ្យសហគ្រាសធុនតូច និងមធ្យមជួយជាវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ កម្មវិធី និងសកម្មភាពរបស់ផែនការផ្ដោតជាចម្បងទៅលើ (១) ការអភិវឌ្ឍធនធានមនុស្ស (២) ការពង្រឹង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សមត្ថភាពផ្នែកទីផ្សារ (៣) លទ្ធភាពងាយទទួលបានហិរញ្ញប្បទាន និង(៤) បង្កភាពសាមញ្ញដល់បរិដ្ឋានគតិយុត្តដើម្បីឱ្យសហគ្រាសធុនតូច និងមធ្យមទាំងអស់អាចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។ ពោល នោះគឺជាគម្រោងពីរយៈពេលខ្លីទៅរយៈពេលវែង។

## ១.២.២- កិច្ចផ្តួចផ្តើមរបស់អាស៊ានសម្រាប់សមាហរណកម្មរដ្ឋសមាជិកដែលអភិវឌ្ឍតិចតួចជាងគេ

ឧបសគ្គទាំងអស់ទៅលើសមាហរណកម្មគឺភាពខុសគ្នាត្រង់ការអភិវឌ្ឍសេដ្ឋកិច្ច ពោលគឺគម្លាត។ អាស៊ានបានសាកល្បងអនុវត្តកិច្ចផ្តួចផ្តើមកាត់បន្ថយគម្លាតអភិវឌ្ឍទាំងនេះ។ នាខែវិច្ឆិកា ២០០២ អំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាន រដ្ឋសមាជិកទាំងអស់បានអនុម័ត (១) កិច្ចផ្តួចផ្តើមសម្រាប់សមាហរណកម្មចូលក្នុងអាស៊ាន(IAI) និង(២) ផែនការសកម្មភាពទីពីរ។ មួយឆ្នាំក្រោយគឺនៅថ្ងៃទី២៣ កក្កដា ២០០៣ គេបានអនុម័តសេចក្តីប្រកាសសកម្មភាពក្រុងហាណូយស្តីពីការកាត់បន្ថយគម្លាតសម្រាប់សមាហរណកម្មកាន់តែជិតស្និទ្ធក្នុងអាស៊ាន (៣) ផែនការសកម្មភាពត្រូវបានអនុម័តនៅទីក្រុងភ្នំពេញ ក្នុងខែវិច្ឆិកា ២០០២ អំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី៦(៩០គម្រោង)។ វិស័យអាទិភាពទាំង៤ក្នុងផែនការសកម្មភាព២០០២ដែលពាក់ព័ន្ធនឹងរដ្ឋដែលអភិវឌ្ឍតិចតួចជាងគេទាំង៤(CLMV)មាន (១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ(ការដឹកជញ្ជូន និងថាមពល) (២) ការអភិវឌ្ឍធនធានមនុស្ស (៣) បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង និង(៤) ការលើកស្ទួយសមាហរណកម្មសេដ្ឋកិច្ចតំបន់។

ចាប់តាំងពីពេលអនុវត្តផែនការមក គម្រោងចំនួន៩០ត្រូវបានអនុវត្ត ក្នុងនោះគម្រោង២ភាគ៣ទទួលបានហិរញ្ញប្បទាន ហើយគម្រោងប្រមាណជា១ភាគ៤ត្រូវបានបំពេញចប់។ ពាក់ព័ន្ធនឹងហិរញ្ញប្បទានវិញ នេះគឺជាបញ្ហាចម្បង។ ហិរញ្ញប្បទានមានប្រភពមកពីកន្លែងផ្សេងៗគ្នាដូចជាហិរញ្ញប្បទានអាស៊ាន-៦ដែលជាមូលនិធិអភិវឌ្ឍអាស៊ានទ្រទ្រង់ដោយរដ្ឋសមាជិកទាំង៦(៤លានដុល្លារ)។ ចំពោះប្រភពខាងក្រៅវិញ មានចំនួន២លានដុល្លារដែលបានមកពី (១) គ្រប់ដៃគូអាស៊ាន+៣ មានប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង និង(២) គម្រោងទ្រទ្រង់ដោយកម្មវិធីអភិវឌ្ឍសហប្រជាជាតិ(PNUD)។ ក្នុងចំណោមគម្រោងគោលទាំងអស់ក្នុងក្របខ័ណ្ឌសមាហរណកម្ម មានគម្រោងមួយគឺគម្រោងផ្លូវអេយស្ម័យយានរវាងសិង្ហបុរី និងគុនមីង(Kunming) (អនុវត្តនាឆ្នាំ២០០០)។ នេះគឺជាគម្រោងចាស់។ រដ្ឋអភិវឌ្ឍខ្លាំងទាំងអស់ត្រូវលុបបំបាត់គម្លាតអភិវឌ្ឍសេដ្ឋកិច្ច។

## ២- សហប្រតិបត្តិការក្រៅតំបន់

សហប្រតិបត្តិការក្រៅតំបន់ប្រព្រឹត្តទៅតាមលក្ខណៈពីរ គឺលក្ខណៈទ្វេភាគី និងពហុភាគី។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.១- ក្របខ័ណ្ឌទ្វេភាគី

*ក្នុងក្របខ័ណ្ឌទ្វេភាគី ក្របខ័ណ្ឌនេះគឺសំដៅកិច្ចព្រមព្រៀងទ្វេភាគីទាំងអស់របស់អាស៊ាន ដូចជាកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង ព្រមទាំងអាស៊ាន+៦ គឺឥណ្ឌា និងនូវ៉ែលហ្សេឡង់ផងដែរ។*

## ២.១.១- ទំនាក់ទំនងអាស៊ាន-ចិន

*កិច្ចសន្ទនារវាងអាស៊ាន-ចិនជួបវិបត្តិអស់រយៈពេលយ៉ាងយូរដោយសារវិវាទរវាងរដ្ឋអាស៊ានខ្លះ និងប្រទេសចិន។ រវាងប្រទេសចិន និងឥណ្ឌូនេស៊ី គឺពុំមានទំនាក់ទំនងការទូតទេ។ ប្រទេសចិនធ្លាប់គាំទ្រការប្រយុទ្ធរបស់វៀតណាមជាមួយសហរដ្ឋអាមេរិក ហើយប្រទេសចិនធ្លាប់គាំទ្រការបះបោរកុម្មុយនីស្តសម្រាប់ប្រទេសហ្វីលីពីន ម៉ាឡេស៊ី និងថៃនាទសវត្សរ៍ឆ្នាំ៥០ ធ្លាប់គាំទ្រការប្រឆាំងស៊ូហាតូ( ដែលជាបក្សកុម្មុយនីស្ត មានសមាជិក៥លានរូប ហើយចន្លោះឆ្នាំ១៩៦៥ និង១៩៦៦ សមាជិក២លានរូបបានបាត់បង់ជីវិត)។ ចុងបញ្ចប់នៃសង្គ្រាមឥណ្ឌូចិន និងការចុះចូលរបស់អតីតរដ្ឋកុម្មុយនីស្តបានសម្រួលដល់កិច្ចសន្ទនារវាងអាស៊ាន និងប្រទេសចិន។ កិច្ចសន្ទនានេះបានចាប់ផ្ដើមវិវត្តនៅឆ្នាំ១៩៩១។ វិវាទផ្សេងៗទៀតនៅកើតមាន ដូចជានៅសមុទ្រចិនខាងត្បូង។ នាកិច្ចប្រជុំកំពូលនៅកោះបាលីឆ្នាំ២០០៣ សេចក្ដីប្រកាសរួមស្ដីពីការអភិវឌ្ឍភាពជាដៃគូរួមសម្រាប់សន្តិភាព និងវិបុលភាពត្រូវបានអនុម័តឱ្យប្រើប្រាស់។ នាឆ្នាំ២០០៤ ផែនការសកម្មភាពមួយត្រូវបានអនុម័តឡើងដើម្បីប្រែក្លាយសេចក្ដីប្រកាសរួមនេះឱ្យមានប្រសិទ្ធភាព និងអនុវត្តសម្រាប់ឆ្នាំ២០០៥-២០១០។ ផែនការទីមួយបានសម្រេចឈានដល់ការអនុវត្តតំបន់ពាណិជ្ជកម្មសេរី។ ផែនការសកម្មភាពទីពីរត្រូវបានអនុម័តនៅអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាននៅទីក្រុងហាណូយ និងអនុវត្តក្នុងអំឡុងឆ្នាំ២០១១-២០១៥។ ក្នុងក្របខ័ណ្ឌផែនការសកម្មភាពទាំងនេះ សហប្រតិបត្តិការអាស៊ាន-ចិនត្រូវអនុវត្តនៅក្នុងវិស័យអាទិភាពចំនួន១១គឺ (១) កសិកម្ម (២) ព័ត៌មាន ព្រមទាំងទំនាក់ទំនង (៣) បច្ចេកវិទ្យា (៤) ការអភិវឌ្ឍធនធានមនុស្ស (៥) ការអភិវឌ្ឍអាងទន្លេមេគង្គ (៦) វិនិយោគ (៧) ថាមពល (៨) ការដឹកជញ្ជូន (៩) វប្បធម៌ (១០) សុខភាពសាធារណៈ និង(១១) ទេសចរណ៍ និងបរិស្ថាន។*

*ទំនាក់ទំនងពាណិជ្ជកម្មរវាងអាស៊ាន និងចិនត្រូវបានអភិវឌ្ឍយ៉ាងឆាប់រហ័សនាអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ នាឆ្នាំ២០០៣ គ្រប់ពាណិជ្ជកម្មទាំងអស់មានទឹកប្រាក់ជិតស្មើនឹង៦០ពាន់លានដុល្លារ និងប្រមាណជា២០០ពាន់លានដុល្លារនៅឆ្នាំ២០០៩។ ពាណិជ្ជកម្មទាំងនេះមានចំនួន១១,៦%នៃពាណិជ្ជកម្មរួមសរុបរបស់អាស៊ាន។ សហប្រតិបត្តិការសេដ្ឋកិច្ចនេះបានចេញជារូបរាងអាស្រ័យដោយការអនុម័ត និងចូលជាធរមាននៃតំបន់ពាណិជ្ជកម្មសេរីរវាងប្រទេសក្នុង*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាស៊ានមួយចំនួន និងចិន។ កិច្ចព្រមព្រៀងនេះបង្កើតជាតំបន់សេរីACFTA។ ក្នុងខ្លឹមសារនៃកិច្ចព្រមព្រៀងនេះដែលចូលជាធរមាននាថ្ងៃទី០១ មករា ២០១០ គឺសំដៅលើប្រទេសចិន និងអាស៊ាន-៦ (ច្បាប់គយកាលពីមុនគិត៥%)។ ចាប់ពីពន្ធគយចូលជាធរមានមក ឥណ្ឌូនេស៊ីបានដកខ្លួនថយដោយស្នើសុំអនុគ្រោះរយៈពេល២ឆ្នាំ(រហូតដល់ឆ្នាំ២០១២)។ ប្រទេសថៃបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមុនពេល កសិផលទាំងអស់ត្រូវវិនាសហិនហោចដោយសារខ្លឹមបារាំងចូលលុកលុយ។ ចំពោះរដ្ឋអភិវឌ្ឍយឺតខ្លាំងទាំង៤វិញ គឺស្នើសុំនៅឆ្នាំ២០១៥។ កិច្ចព្រមព្រៀងនេះលុបបំបាត់ពន្ធគយរវាងរដ្ឋហត្ថលេខីទៅលើទំនិញប្រមាណជា៧ ០០០ក្រុម និងសេវាកម្មដែលគ្របដណ្ដប់បណ្ដូរពាណិជ្ជកម្មប្រមាណជា៩០%។គោលបំណងពាណិជ្ជកម្មនេះគឺឈានទៅសម្រេចបាន៥០០ពាន់លានដុល្លារជារៀងរាល់ឆ្នាំ និង២០០ពាន់លានដុល្លារក្នុងរយៈពេល៤ឆ្នាំ(២០១៥)។

បំណងប្រាថ្នាដ៏មុតមាំរបស់ប្រទេសចិនមានបីគឺ (១) ឆ្លៀតឱកាសដែលពន្ធគយត្រូវលុបបំបាត់ ដើម្បីបង្កើនការនាំចូលវត្ថុធាតុដើម ដូចជាកៅស៊ូជាដើម-ល-។ (២) បង្កើនការនាំចេញទំនិញឧស្សាហកម្មក្នុងតំបន់អាស៊ានដើម្បីបង្វែរប់មួយផ្នែកទៅលើការធ្លាក់ចុះនៃការនាំចេញទៅកាន់សហរដ្ឋអាមេរិក និងទ្វីបអឺរ៉ុប (៣) ព្យាយាមជំទាស់អនុត្តរភាពលុយដុល្លារនៅអាស៊ីអាគ្នេយ៍។ ក្នុងន័យម្យ៉ាងទៀត ដោយបង្កើតតំបន់ពាណិជ្ជកម្មសេរីនេះ ប្រទេសចិនសង្ឃឹមធ្វើឱ្យប្រាក់យ័នរបស់ខ្លួនក្លាយជារូបិយវត្ថុបង្អែក។ គ្រប់កិច្ចព្រមព្រៀងជាមួយវៀតណាម និងឡាវធ្វើឡើងជាប្រាក់យ័ន។ ប្រទេសចិនព្យាយាមប្រើអំណាចទន់ភ្លន់ដើម្បីអាចប្រើប្រាស់ល្បែងសរសេរគណនេយ្យដើម្បីជំនួសដុល្លារ។ ប្រទេសចិនបារម្ភក្រែងអាស៊ានក្លាយជាឈ្នាន់(*stepping stone*) អាមេរិកនៅអាស៊ី។ នេះគឺជាចំណោទបញ្ហាសំខាន់មួយ។

## ២.១.២- ទំនាក់ទំនងអាស៊ាន-ជប៉ុន

ជប៉ុនជាដៃគូចំណាស់ជាងគេ។ គ្រប់ទំនាក់ទំនងបានចាប់ផ្ដើមជាលក្ខណៈផ្លូវការនាឆ្នាំ១៩៧៧ក្នុងក្របខ័ណ្ឌវេទិកាអាស៊ាន-ជប៉ុន។ ចាប់ពីឆ្នាំនោះមក គ្រប់ទំនាក់ទំនងត្រូវបានពង្រីក ហើយនៅខែធ្នូ ២០០៣ គេបានអនុម័តផែនការសកម្មភាពអាស៊ាន-ជប៉ុន និងសេចក្ដីប្រកាសរួមស្ដីពីដៃគូយុទ្ធសាស្ត្រស៊ីជម្រៅរវាងអាស៊ាន និងជប៉ុន នៅគូឡាឡាំពួរនៅឆ្នាំ២០០៥។ នាសម័យប្រជុំកំពូលលើកទី៧ ប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី១៣ ដៃគូទាំងពីរបានសម្រេចអនុវត្តដំណើរការពិនិត្យទៅលើផែនការសកម្មភាពឡើងវិញ ហើយសេចក្ដីប្រកាសរួមត្រូវបានគ្រោងធ្វើដើម្បីបញ្ចប់នាកិច្ចប្រជុំកំពូលលើកទី១៤នៅប្រទេសឥណ្ឌូនេស៊ី។

ប្រទេសជប៉ុនគឺជាដៃគូសំខាន់មួយរបស់អាស៊ាន។ ពាណិជ្ជកម្មរវាងអាស៊ាន និងជប៉ុនមានទឹកប្រាក់ជិត២១៥ពាន់លានដុល្លារកាលពីឆ្នាំ២០០៨។ នៅឆ្នាំ២០០៩ តួលេខនេះធ្លាក់ចុះមកត្រឹម

១៦១ពាន់លានដុល្លារ។ ពាណិជ្ជកម្មរវាងអាស៊ាន និងជប៉ុនស្មើនឹង១០,៩%នៃពាណិជ្ជកម្មសរុបរបស់អាស៊ាន។ អ្វីដែលស្ដែងច្បាស់គឺការចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាស៊ាន-ជប៉ុនស្ដីពីការបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាន និងជប៉ុននាឆ្នាំ២០០៨។ តំបន់ពាណិជ្ជកម្មសេរីនេះបានចូលជាធរមាននៅខែធ្នូ ឆ្នាំ២០០៨។ កិច្ចព្រមព្រៀងនេះគ្របដណ្ដប់វិស័យផ្សេងៗគ្នាគឺ ពាណិជ្ជកម្មទំនិញ សេវាកម្ម វិស័យវិនិយោគ និងសហប្រតិបត្តិការសេដ្ឋកិច្ច។ នាអំឡុងពេលកិច្ចប្រជុំកំពូលលើកទី១៣ ភាគីទាំងពីរបានបន្តសម្រេចការអភិវឌ្ឍប្រកបដោយចីរភាព ដោយបញ្ចូលវិស័យថាមពលទៅក្នុងក្របខ័ណ្ឌទំនាក់ទំនងទាំងនេះ។

## ២.១.៣- ទំនាក់ទំនងអាស៊ាន-កូរ៉េខាងត្បូង

ទំនាក់ទំនងទាំងនេះបានចាប់ផ្ដើមនៅឆ្នាំ១៩៨៩ ហើយប្រទេសកូរ៉េបានទទួលឋានៈជាដៃគូសន្ទនាកាលពីខែកក្កដា នាកិច្ចប្រជុំកំពូលនៅទីក្រុងគូឡាឡាំពួរ។ មានសេចក្ដីប្រកាសរួមអាស៊ាន-សាធារដ្ឋកូរ៉េ និងការអនុម័តផែនការសកម្មភាព។ ទំនាក់ទំនងទាំងនេះត្រូវបានអភិវឌ្ឍនាឆ្នាំ២០០៩ នាពេលកិច្ចប្រជុំកំពូលអាស៊ាន-សាធារណៈរដ្ឋកូរ៉េ ហើយកិច្ចផ្ដួចផ្ដើមដើម្បីធ្វើឱ្យស៊ីជម្រៅនូវទំនាក់ទំនងទាំងនេះត្រូវបានអនុម័តអំឡុងពេលកិច្ចប្រជុំនេះ។ កិច្ចប្រជុំអាស៊ាន-សាធារណៈរដ្ឋកូរ៉េលើកទី១៣បានធ្វើឱ្យស៊ីជម្រៅនូវទំនាក់ទំនងទាំងនេះ ដោយធ្វើឱ្យកូរ៉េខាងត្បូងក្លាយជាដៃគូយុទ្ធសាស្ត្ររវាងដៃគូទាំងពីរ។ ដៃគូទាំងពីរបានសម្រេចធ្វើសេចក្ដីប្រកាសរួមថ្មីមួយសម្រាប់អំឡុងពេលឆ្នាំ២០១១-២០១៥។

ពាណិជ្ជកម្មរវាងអាស៊ាន និងសាធារណៈរដ្ឋកូរ៉េបានកើនដល់៧៨ពាន់លានដុល្លារនាឆ្នាំ២០០៨ និងធ្លាក់ចុះបន្តិចមកត្រឹម៧៥ពាន់លានដុល្លារនាឆ្នាំ២០០៩។ នាឆ្នាំ២០០៥ កិច្ចព្រមព្រៀងស្ដីពីការបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េត្រូវបានអនុម័ត ដោយគ្រោងអំពីប្រតិទិនមួយចាប់ពីឆ្នាំ២០១០ទៅជាមួយនឹងភាពបត់បែនមួយចំនួន រហូតដល់ឆ្នាំ២០១២សម្រាប់អាស៊ាន-៦ ឆ្នាំ២០១៦សម្រាប់វៀតណាម និងឆ្នាំ២០១៨សម្រាប់ប្រទេសនៅសេសសល់។ ក្នុងកិច្ចព្រមព្រៀងនេះ យើងឃើញមានយន្តការដោះស្រាយអធិករណ៍នានាដែរ។

## ២.១.៤- ទំនាក់ទំនងអាស៊ាន-ឥណ្ឌា

ភាពជាដៃគូនេះបានចាប់ផ្ដើមនាឆ្នាំ១៩៩២ រីឯភាពជាដៃគូក្នុងកិច្ចសន្ទនាគឺនៅខែធ្នូ ឆ្នាំ១៩៩៥។ នៅឆ្នាំ២០០២ គេបានសម្រេចរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាប្រចាំឆ្នាំ។ រៀងរាល់ឆ្នាំ មានកិច្ចប្រជុំកំពូលជាឧបសម្ព័ន្ធនានា។

ពាក់ព័ន្ធនឹងទំនាក់ទំនងសេដ្ឋកិច្ច ទំហំពាណិជ្ជកម្មអាស៊ាន-ឥណ្ឌាមានចំនួន៤០ពាន់លាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដុល្លារ នាឆ្នាំ២០០៨ ហើយទំនាក់ទំនងពាណិជ្ជកម្មក៏បង្កើនសន្ទុះដែរ។ សហប្រតិបត្តិការនេះស្តែងឡើងតាមរយៈការចុះហត្ថលេខាកាលពីឆ្នាំ២០០៩រវាងអាស៊ាន-ឥណ្ឌា ក្រោយកិច្ចចរចាដ៏ក្តៅគគុករយៈពេល៦ឆ្នាំស្តីពីការបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាន និងឥណ្ឌា។ តំបន់ពាណិជ្ជកម្មសេរីនេះប្រមូលផ្តុំទំនិញចំនួន៤ ០០០ក្រុម។ គោលបំណងនៃកិច្ចចរចាគឺអនុវត្តកិច្ចសហប្រតិបត្តិការ។ កិច្ចព្រមព្រៀងនេះបានចូលជាធរមាននៅថ្ងៃទី០១ មករា ២០១០។ យោងតាមប្រតិទិននោះ គឺពុំបានផ្តល់ជាផ្លែផ្កាទាំងនេះទេ។ ប្រទេសឥណ្ឌាបានក្លាយជាដៃគូចម្បង រួមនឹងចក្ខុវិស័យភូមិសាស្ត្រនយោបាយសំខាន់។ ប្រទេសឥណ្ឌាមានប្រជាជនមួយពាន់ពីររយលាននាក់។ ប្រទេសឥណ្ឌាពុំចង់ឱ្យគូប្រជែងជាប់របងរបស់ខ្លួនគឺប្រទេសចិនដើរតួនាទីចម្បងទេ។ ប្រទេសឥណ្ឌាគឺជាមហាអំណាចដែលកំពុងផុសឡើង។

## ២.១.៥- ទំនាក់ទំនងអាស៊ាន-អូស្ត្រាលី-នូវែលហ្សេឡង់

គឺរដ្ឋចំនួន៦ដែលបង្កើតអាស៊ាន+៦ក្នុងក្របខ័ណ្ឌនៃអនាគតសហគមន៍អាស៊ានខាងកើត (អាស៊ាន+៦)។ ការណ៍និយមចង់ឱ្យគេចាប់ផ្តើមពីអាស៊ាន+៣ នាឆ្នាំ១៩៧៤សម្រាប់ប្រទេសអូស្ត្រាលី និងនាឆ្នាំ១៩៧៧សម្រាប់នូវែលហ្សេឡង់។ អាស៊ានបានធ្វើកិច្ចប្រជុំកំពូលដំបូងនៅឆ្នាំ២០១០។ ក្នុងវិស័យសេដ្ឋកិច្ច អាស៊ានគឺជាដៃគូសំខាន់មួយសម្រាប់ប្រទេសអូស្ត្រាលី។ សម្រាប់ឆ្នាំ២០០៩ បណ្តូរពាណិជ្ជកម្មទាំងអស់រវាងអូស្ត្រាលី និងអាស៊ានមានចំនួន៤៤ពាន់លានដុល្លារ។

ភាពជាដៃគូអាស៊ាន-អូស្ត្រាលី និងនូវែលហ្សេឡង់បានចាប់ផ្តើមនៅឆ្នាំ២០០៤ ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី និងនូវែលហ្សេឡង់កាលពីថ្ងៃទី០៤ កុម្ភៈ ២០០៩។ កិច្ចព្រមព្រៀងនេះគ្របដណ្តប់លើច្រើនវិស័យច្រើនជាងចិន និងជប៉ុន មានដូចជា ទំនាក់ទំនងពាណិជ្ជ-កម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម ហិរញ្ញវត្ថុ និងទំនាក់ទំនង ការវិនិយោគ ពាណិជ្ជកម្មអេឡិចត្រូនិកចរាចរមនុស្ស កម្មសិទ្ធិបញ្ញា សហប្រតិបត្តិការ។ កិច្ចព្រមព្រៀងនេះបានចូលជាធរមាននៅថ្ងៃទី០១ មករា ២០១០ ហើយអនុវត្តនៅក្នុងរដ្ឋអាស៊ានទាំងអស់ និងក្នុងប្រទេសកម្ពុជា ឡាវ និងឥណ្ឌូនេស៊ីតាមក្រោយ។

## ២.២- ក្របខ័ណ្ឌពហុភាគី

## ២.២.១- សហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន+៣

សហប្រតិបត្តិការអាស៊ាន+៣បានចាប់ផ្តើមនៅឆ្នាំ២០០៧ ហើយពង្រីកទៅលើផ្នែកអាហារសុវត្ថិភាពថាមពល សហប្រតិបត្តិការហិរញ្ញវត្ថុ ភាពងាយស្រួលផ្នែកពាណិជ្ជកម្ម ការគ្រប់គ្រងគ្រោះធម្មជាតិ ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ ការប្រយុទ្ធប្រឆាំងភាពក្រីក្រតាមជនបទ ការ

*ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការងារ ការប្រយុទ្ធប្រឆាំងជំងឺ បរិស្ថាន ការប្រយុទ្ធប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន។*

*នៅឆ្នាំ២០១០ មានយន្តការ៦៤សម្រាប់សហប្រតិបត្តិការអាស៊ាន+៣ដែលមានការប្រជុំកំពូល ការប្រជុំថ្នាក់រដ្ឋមន្ត្រី សហប្រតិបត្តិការកម្រិតស្ថាប័ន។ ចំពោះផែនការសេដ្ឋកិច្ច កិច្ចផ្តួចផ្តើមគោលមួយមានឈ្មោះល្បីថា ជាកិច្ចផ្តួចផ្តើមក្រុងឈៀងម៉ៃ នាឆ្នាំ២០០០។ កិច្ចផ្តួចផ្តើមនេះត្រូវបានសម្រេចយកក្រោយកើតវិបត្តិហិរញ្ញវត្ថុកាលពីឆ្នាំ១៩៩៧ដែលបានធ្វើឱ្យរង្គោះរង្គើយ៉ាងខ្លាំងដល់ប្រទេសក្នុងតំបន់ទាំងអស់។ ប្រទេសទាំងនេះបានដាក់ចេញនូវប្រព័ន្ធពាណិជ្ជកម្មរូបិយវត្ថុជាតិរវាងធនាគារកណ្តាលរបស់ប្រទេសទាំងនោះ ពេលណាប្រទេសណាមួយជួបវិបត្តិហិរញ្ញវត្ថុ។ ប្រព័ន្ធដំបូងខ្វះភាពទន់ភ្លន់ ដោយហេតុថា ប្រព័ន្ធនេះដាក់កំហិតរដ្ឋាភិបាលដែលជួបវិបត្តិឱ្យចរចាជាមួយប្រទេសហត្ថលេខីនីមួយៗ។ នាឆ្នាំ២០០៦ គេបានកែប្រែកតិកាសញ្ញានេះ ពោលគឺថារដ្ឋាភិបាលមួយអាចនឹងត្រូវការនូវមូលធនជាប្រាក់សុទ្ធដើម្បីទទួលបានក្នុងគណនីយោងមួយ និងក្នុងរយៈពេលក្រោមមួយសប្តាហ៍នូវសិទ្ធិទទួលគណនីរូបិយប័ណ្ណក្នុងតំបន់ដែលទទួលការផ្គត់ផ្គង់ពីធនាគារកណ្តាលជាហត្ថលេខី ដើម្បីទទួលបានជំនួយហិរញ្ញវត្ថុមួយដែលគណនាទៅតាមវិភាគទានផ្ទាល់របស់រដ្ឋនោះ។ មូលនិធិនេះស្មើនឹង១២០ពាន់លានដុល្លារសម្រាប់រំលស់ហានិភ័យនៃវិបត្តិមួយ។ វិភាគទានទាំងអស់រួមមាន ១ភាគ៣ដែលផ្តល់ដោយប្រទេសចិន ២០%ដោយអាស៊ាន ១ភាគ៣ដោយជប៉ុន និង១៦%សម្រាប់កូរ៉េខាងត្បូង។*

*ដំណាក់កាលទី៣ត្រូវបានសម្រេចនាឆ្នាំ២០១០ និងត្រូវបានអនុម័តនាខែមីនា ២០១០។ នោះគឺកិច្ចព្រមព្រៀងនៃពហុភាគីកម្មនៃមូលនិធិSWAP។ នេះគឺជាដំណាក់កាលបន្ថែមក្នុងការបង្កើតសហប្រតិបត្តិការហិរញ្ញវត្ថុ និងរូបិយវត្ថុក្នុងតំបន់។ បណ្តូរពាណិជ្ជកម្មរវាងអាស៊ាន និងប្រទេសទាំង៣មានទឹកប្រាក់ជិត៤១៤ពាន់លានដុល្លារកាលពីឆ្នាំ២០០៩ ល្បឿងចុះបន្តិចធៀបនឹងឆ្នាំ២០០៨ ដែលមានទឹកប្រាក់ស្មើនឹង៤៩០ពាន់លានដុល្លារ។ សម្រាប់ឆ្នាំ២០១០ ពាណិជ្ជកម្មទាំងអស់បានកើនឡើងវិញ។ អាស៊ាន+៣គឺជាក្របខ័ណ្ឌបង្អែក (១) កិច្ចផ្តួចផ្តើមពីស្ថាប័នទាំងអស់ ពោលគឺតំបន់ភាវូបនីយកម្ម (២) លំហូរនៃបណ្តូរសេដ្ឋកិច្ចមានសារៈសំខាន់ជាងគេ ពោលគឺតំបន់និយម។*

### ២.២.២- ទំនាក់ទំនងអាស៊ាន+៦

*ការពិចារណាទៅលើការបង្កើតផ្ទៃក្នុងនូវតំបន់ពាណិជ្ជកម្មសេរីរបស់អាស៊ាន+៦ត្រូវបានចាប់ផ្តើមនៅឆ្នាំ២០០៩។ កិច្ចប្រជុំអាស៊ីបូព៌ាដំបូងបានចាប់ផ្តើមធ្វើនៅឆ្នាំ២០០៥ ប៉ុន្តែមានប្រទេសរុស្ស៊ីផងដែរ ដើម្បីអាចធ្វើសមាហរណកម្មអាស៊ីបូព៌ាបាន (១) ដៃគូសន្ទនា (២) សមាជិកTAC ឬប្តេជ្ញាចូលជាសមាជិក (៣) បេក្ខប្រទេសត្រូវអភិវឌ្ឍទំនាក់ទំនងគោលជាមួយអាស៊ាន។ ជាការ*

ផាយក្នុងការចាប់ផ្តើមពីអាស៊ាន+៣ ព្រោះថាស្ថាប័នទាំងអស់មានស្រាប់ហើយ។ ប៉ុន្តែ អាស៊ាន+៦ ផ្សេងទៀត។ គេនិយាយអំពីគំនិត។ នៅក្នុងកិច្ចសហប្រតិបត្តិការនេះ អាស៊ានត្រូវជានាទូវតួនាទីចម្បងរបស់ខ្លួន ដោយដាក់អាស៊ានឱ្យនៅចំស្នូលកណ្តាល( ASEAN Centrality )។

# ទស្សនៈវិស័យនៃសហប្រតិបត្តិការ នយោបាយ-សន្តិសុខ និងសង្គម-វប្បធម៌

## ផ្នែកទី៨

## កិច្ចសហប្រតិបត្តិការផ្នែកនយោបាយសន្តិសុខ

ទិដ្ឋានយោបាយ និងសន្តិសុខ គឺជាក្តីកង្វល់ចម្បងរបស់សមាគម ពីព្រោះថាគោលដៅមួយក្នុងចំណោមគោលដៅជាច្រើន គឺការនាំមកនូវសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ក្នុងឆ្នាំ១៩៦៧ គឺជាសម័យទ្វេប៉ូលដែលមានការប្រកួតប្រជែងគ្នារវាងសហរដ្ឋអាមេរិក និងប្រទេសរុស្ស៊ីនៅពាសពេញពិភពលោក។ សមាគមនេះត្រូវបានបង្កើតឡើង ដើម្បីជៀសវាងការឆ្លងរាលដាលរបបកុម្មុយនីសក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅទីបញ្ចប់នៃការប្រឈមមុខដាក់គ្នារវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត រវាងប្លុកទាំងពីរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បណ្តារដ្ឋស្ថាបនិក និងរដ្ឋកុម្មុយនីសបានផ្តួចផ្តើមនយោបាយកិច្ចសហប្រតិបត្តិការនេះឡើងនៅក្នុងកិច្ចប្រជុំកំពូលនៅប្រទេសសិង្ហបុរី នៅក្នុងឆ្នាំ១៩៩២។ កិច្ចប្រជុំកំពូលនៅក្នុងប្រទេសសិង្ហបុរីនេះបានបំផុសឡើងវិញពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងមជ្ឈត្តការតំបន់ និងអភិវឌ្ឍវេទិកាតំបន់អាស៊ានដែលអនុញ្ញាតឱ្យថែរក្សាបាននូវសន្តិភាព និងស្ថិរភាព។ ការវាយប្រហារថ្ងៃទី១១ ខែកញ្ញាបានញ៉ាំងឱ្យអាមេរិកចូលប្រលូកសារជាថ្មីនៅតំបន់អាស៊ីអាគ្នេយ៍ជាមួយនឹងគោលដៅយ៉ាងច្បាស់លាស់តាំងពីដំបូង គឺដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ប្រយុទ្ធប្រឆាំងនឹងក្រុមឧទ្ទាមអាប៊ូសាយ៉ាស( Abou Sayyaf )( មេដឹកនាំដោយដាវ-porteur de sabre )នៅភាគខាងត្បូងប្រទេសហ្វីលីពីន។

អាស៊ីបានក្លាយទៅជាអាទិភាពមួយក្នុងចំណោមអាទិភាពជាច្រើននៃនយោបាយការទូតអឺរ៉ុប។ មូលហេតុមួយគឺដើម្បីប្រយុទ្ធប្រឆាំងទៅនឹងឥទ្ធិពលចិននៅក្នុងតំបន់មួយនេះ។ អាស៊ានបានក្លាយទៅជាដៃគូអាទិភាពមួយដោយមិនអាចប្រកែកបាន គឺជាដៃគូដែលមិនអាចធ្វើឱ្យបាត់បង់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*និងជាដៃគូឯកសិទ្ធិរវាងអាស៊ាន និងសហរដ្ឋអាមេរិក។ សិង្ហបុរីគឺជាឫសកែវនៃវត្តមានអាមេរិកនៅតំបន់អាស៊ីអាគ្នេយ៍។ ហ្វីលីពីនបានផ្ដល់ឱ្យនូវមូលដ្ឋានយោធាផងដែរ។*

*ការវាយប្រហារភេរវកម្មទាំងនោះបានធ្វើឱ្យមានវត្តមានអាមេរិកសាជាថ្មីនៅក្នុងតំបន់។ អាស៊ានបានអភិវឌ្ឍសសរស្ដម្ភមួយនៅក្នុងក្របខ័ណ្ឌនៃសសរស្ដម្ភខ្លួនដែលបង្ហាញពីចរិតលក្ខណៈជាសារវន្តចំនួន៣ ៖ (១) សហគមន៍នេះបង្កើតឡើងដោយផ្អែកទៅលើបទដ្ឋាននានា និងតម្លៃរួមគ្នា។ (២) សហគមន៍នេះគឺមានមូលដ្ឋានផ្អែកទៅលើភាតរភាពក្នុងតំបន់ ស្ថិរភាព សន្តិភាពជានាបានសន្តិសុខទាំងមូល និងរួមគ្នា។ (៣) សហគមន៍ដែលបែរទៅរកពិភពខាងក្រៅ ហើយប្រសិនបើអាចគឺការចូលរួមទៅក្នុងពិភពអន្តរអនិស្សរភាព។ ការតម្រង់ទិសពាក់ព័ន្ធនឹងសហគមន៍នយោបាយសន្តិសុខនេះត្រូវបានអភិវឌ្ឍនៅក្នុងឯកសារគោលចំនួន៣ ៖ (១) ឯកសារទីក្រុងវៀងច័ន្ទដែលគ្របដណ្ដប់អំឡុងឆ្នាំ២០០៤-២០១០ (២) ផែនការសកម្មភាពសន្តិសុខសហគមន៍អាស៊ានដែលត្រូវបានអនុម័តនៅទីក្រុងវៀងច័ន្ទ ឆ្នាំ២០០៤ និង(៣) ឯកសារទី៣ គឺផែនការសហគមន៍នយោបាយ និងសន្តិសុខអាស៊ាន អនុម័តឆ្នាំ២០០៩ដែលបានបញ្ជាក់អះអាងសារជាថ្មីពីមូលដ្ឋានត្រឹមត្រូវឬការរក្សាឱ្យនៅដដែលនូវគោលការណ៍និងយន្តការនានាដែលមានស្រាប់ និងដែលកំណត់ផងដែរនូវផែនការសកម្មភាពថ្មី។*

## ១- ការបញ្ជាក់អះអាងសារជាថ្មីពីគោលការណ៍ និងយន្តការដែលមានស្រាប់

*មានទិដ្ឋភាព២ ៖*

### ១.១- យន្តការគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋសមាជិក

### ១.១.១- តំបន់សន្តិភាព សេរីភាព និងអព្យាក្រឹតភាព(*ZOPFAN*)

*សេចក្ដីប្រកាសស្ដីពីតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹតភាព(ZOPFAN) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧១ គឺខ្វីណាស់ ៖ វាមានគំនិតជាសារវន្តពីរគឺ ៖ (១) រដ្ឋទាំងអស់ការពារគោល-ការណ៍អធិបតេយ្យភាព គោរពបូរណភាពដែនដី លះបង់ចោលនូវការប្រើប្រាស់កម្លាំង ឬការគំរាមកំហែងការប្រើប្រាស់កម្លាំង ដោះស្រាយអធិករណ៍នានាដោយសន្តិវិធី សិទ្ធិស្វ័យសម្រេចរបស់ប្រជាជន ការមិនចូលជ្រៀតជ្រែកទៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃទៀត។ រដ្ឋហត្ថលេខីនៃសេចក្ដីប្រកាសនេះបានទទួលរងឥទ្ធិពលពីចរន្តអព្យាក្រឹតដែលបានស្រោចស្រពពាសពេញតំបន់ទាំងមូលក្នុងទសវត្សរ៍ឆ្នាំ១៩៥០ សន្និសីទទីក្រុងបានដុង ប្រធានាធិបតីឥណ្ឌូនេស៊ីSukarno, Nehru, Nasser និងព្រះអង្គម្ចាស់នរោត្តម សីហនុ។ ការបូកបញ្ចូលគ្នានូវគំនិតទាំងពីរនេះដែលរដ្ឋហត្ថលេខីមានចេតនាចង់ធ្វើឱ្យអាស៊ីអាគ្នេយ៍ក្លាយជាតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត។*

## ១.១.២- សន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការចុះថ្ងៃទី២៤ កុម្ភៈ ១៩៦៧

*ក្នុងឆ្នាំ១៩៧៥ ឧបទ្វីបឥណ្ឌូចិនទាំងមូលត្រូវស្ថិតក្រោមការគ្រប់គ្រងត្រួតត្រាដោយកុម្មុយនីស ៖ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបលន់នល់ត្រូវបានផ្ដួលរំលំដោយខ្មែរក្រហម។ ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ កងពលវៀតណាមខាងជើងបានចូលទៅក្នុងទីក្រុងសៃហ្គន ហើយនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៥ ក្រុមប៉ាថេតឡាវបានផ្ដួលរំលំរបបរាជានិយមដែលកំពុងគ្រប់គ្រងប្រទេសឡាវ ហើយរបបសាធារណៈរដ្ឋប្រជាមានិតឡាវត្រូវបានប្រកាសឡើង។ ប្រទេសទាំង៣ដែលបង្កើតបានជាតំបន់ឥណ្ឌូចិនដោយបារាំង បានធ្លាក់ចូលទៅក្នុងកុម្មុយនីស។*

*ប្រទេសអាស៊ានទាំង៥បានរៀបចំជំនួបមួយ ដើម្បីគិតគូរពិចារណាពីបញ្ហាថ្មីមួយនេះ ហើយអត្ថបទចំនួន៣ត្រូវបានអនុម័ត ក្នុងចំណោមអត្ថបទទាំង៣នេះ មានសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ(TAC)។ មាត្រា៣នៃសន្ធិសញ្ញាTACចែងថា គូភាគីកិច្ចសន្យា សន្យានឹងធ្វើការអភិវឌ្ឍ និងពង្រឹងចំណងជាប្រពៃណី វប្បធម៌ ប្រវត្តិសាស្ត្រដែលចងភ្ជាប់រវាងគ្នានឹងគ្នា។ ពួកគេសន្យាផងដែរថា នឹងធ្វើការអភិវឌ្ឍភាពជាអ្នកជិតខាងល្អ និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋទាំងអស់នូវកិច្ចសហប្រតិបត្តិការពហុទម្រង់ សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ និងរដ្ឋបាល។*

## ១.១.៣- តំបន់គ្មានអាវុធនុយក្លេអ៊ែរអាស៊ីអាគ្នេយ៍

*តំបន់គ្មានអាវុធនុយក្លេអ៊ែរអាស៊ីអាគ្នេយ៍នេះ(SEANWFZ) គឺជាការសំដែងឥទ្ធៈយ៉ាងច្បាស់លាស់នៃតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត(ZOPFAN)ដែលត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ ដែលបង្កើតតំបន់គ្មានអាវុធនុយក្លេអ៊ែរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ សន្ធិសញ្ញានេះហាមឃាត់ដល់រដ្ឋសមាជិក ទោះនៅក្នុង ឬក្រៅតំបន់ដែលបានពោលនេះក្ដី មិនឱ្យអភិវឌ្ឍ អភិរក្ស ដឹកជញ្ជូន សាកល្បង ឬប្រើប្រាស់អាវុធនុយក្លេអ៊ែរដោយខ្លួនឯង ឬដោយរដ្ឋទីបីដែលចូលមកនោះទេ(មាត្រា៣-១ និង៣-២នៃសន្ធិសញ្ញានេះ។ ជាសន្ធិសញ្ញាដែលគេស្គាល់ថា ជាសន្ធិសញ្ញាទីក្រុងបាងកក)។*

*ទិដ្ឋភាពទី២នៃសន្ធិសញ្ញា ៖ សន្ធិសញ្ញាចែងថា រដ្ឋហត្ថលេខីមិនត្រូវចាក់ចោលនៅលើដែនដី(ដែនដីគោក ដែនសមុទ្រ និងបរិយាកាស) ឬអនុញ្ញាតឱ្យមានចាក់ចោលនូវសម្ភារ ឬកាកសំណល់វិទ្យុសកម្មទេ។*

*សន្ធិសញ្ញានេះបានចែងករណីលើកលែងមួយចំនួន ៖ អនុញ្ញាតឱ្យរដ្ឋប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់ធ្វើការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ក្នុងគោលដៅយថាប្រភេទនានា (មាត្រា៤-១)។ សន្ធិសញ្ញាទីក្រុងបាងកកនេះលើកទឹកចិត្តឱ្យរដ្ឋហត្ថលេខីប្រើប្រាស់វាជាជំនួយក្នុងការអភិវឌ្ឍ និងដោយវឌ្ឍនធម៌នៃការមិនធ្វើឱ្យមានការរីកសាយភាយដោយជាទូទៅ គឺធ្វើការផ្សព្វផ្សាយ*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទៅកាន់រដ្ឋទាំងអស់នោះនូវសន្ធិសញ្ញាមិនរីកសាយភាយអាវុធនុយក្លេអ៊ែរឆ្នាំ១៩៦៨។ មាត្រា៨ ចែងពីការបង្កើតគណៈកម្មការមួយ សម្រាប់តំបន់គ្មានអាវុធនុយក្លេអ៊ែរនៅតំបន់អាស៊ីអាគ្នេយ៍។ សមាជិករបស់គណៈកម្មការនេះ គឺរដ្ឋមន្ត្រីការបរទេសនៃរដ្ឋហត្ថលេខីទាំងអស់។

## ១.២- យន្តការអន្តរតំបន់ក្នុងផ្នែកសន្តិសុខ

គឺជាយន្តការដែលមាននិន្នាការបង្ការជម្លោះនានា តាមរយៈការអភិវឌ្ឍនូវបរិយាកាសជឿទុកចិត្តគ្នារវាងរដ្ឋ។ អាស៊ានព្យាយាមស្វែងរកនូវការលើកកម្ពស់សន្តិភាព និងស្ថិរភាព ដោយមិនត្រឹមតែចំពោះរដ្ឋជាសមាជិកប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅក្នុងតំបន់ និងនៅក្នុងពិភពលោក។ ចាប់តាំងពីទសវត្សរ៍ទី៩០មក យន្តការចំនួន៣ត្រូវបានរចនាឡើងគឺ វេទិកាតំបន់អាស៊ាន(l'ARF) ត្រូយកាអាស៊ាន(ASEAN Troïka) និងសេចក្តីប្រកាសពីក្រមប្រតិបត្តិនៅតំបន់សមុទ្រចិនខាងត្បូង។

### ១.២.១- វេទិកាតំបន់អាស៊ាន(ARF)

វេទិកាតំបន់អាស៊ាន(ARF)ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ ហើយចាប់ផ្តើមបំពេញសកម្មភាពក្នុងឆ្នាំ១៩៩៤។ វេទិកានេះរួមមានសមាជិកចំនួន២៧ នាពេលបច្ចុប្បន្ននេះ ៖ គឺរដ្ឋទាំង១០ដែលជាសមាជិកអាស៊ាន រដ្ឋចំនួន១០ដែលជាដៃគូសន្ទនា និងរដ្ឋចំនួន៧ផ្សេងទៀតដែលបានចូលមកបំពេញបញ្ជីសមាជិកនេះ។ វេទិកានេះបំពេញតួនាទីពីរ ៖ (១) កិច្ចសន្ទនាភ្លាមៗ និងកិច្ចពិភាក្សាទ្វេភាគី និងពហុភាគី។ (២) ដើម្បីធ្វើការពិភាក្សាពាក់ព័ន្ធនឹងបញ្ហាផ្នែកសន្តិសុខ (បញ្ហាចោរសមុទ្រ គ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ) និងបញ្ហាផ្នែកនយោបាយនៅក្នុងតំបន់។ វេទិកានេះជួបប្រជុំគ្នាក្នុងពេលជាមួយការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន សន្និសីទរដ្ឋមន្ត្រីដែលវេទិកាប្រព្រឹត្តទៅ។ ដើម្បីអាចក្លាយខ្លួនទៅជាសមាជិកនៃវេទិកានេះ គេត្រូវបំពេញលក្ខខណ្ឌចំនួន២ ៖ (១) យល់ព្រមទទួលយកនូវគោលដៅ និងគោលការណ៍នានានៃកិច្ចបង្កើតវេទិកាARF។ (២) រដ្ឋនោះត្រូវមានឥទ្ធិពលទៅលើសន្តិភាព និងសន្តិសុខនៅក្នុងទីតាំងភូមិសាស្ត្រ (អាស៊ីឦសាន អាស៊ីអាគ្នេយ៍ និងអូសេអានី)ដែលគ្របដណ្តប់ដោយកិច្ចនេះ។ ប្រសិនបើរដ្ឋនេះដើរតួនាទីមួយ រដ្ឋនេះអាចក្លាយជាសមាជិកនៃវេទិកាតំបន់នេះ។ នេះជាកិច្ចប្រជុំលើកទី១៧។ នៅវេទិកាឆ្នាំ២០១០ មានប្រធានបទដូចតទៅ ៖ (១) ការរំឭកឡើងវិញពីមូលដ្ឋានត្រឹមត្រូវនៃភាពចាំបាច់អនុវត្តក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង ដោយរង់ចាំដំណោះស្រាយស្ថាពរ។ (២) តួនាទីរបស់អាស៊ានក្នុងការរក្សាសន្តិភាព និងស្ថិរភាព ដោយការរក្សាសន្ធិសញ្ញា TAC សន្ធិសញ្ញាដែលបង្កើតតំបន់គ្មានអាវុធនុយក្លេអ៊ែរនៅតំបន់អាស៊ីអាគ្នេយ៍ និងក្រមប្រតិបត្តិ។ (៣) សេចក្តីប្រកាសដែលបានបង្កើតឡើងពាក់ព័ន្ធនឹងបញ្ហានៅកូរ៉េ។ សមាជិកនៃវេទិកាបានរំឭកទៅ

កាន់ភាគីពាក់ព័ន្ធនានាដូចជា កូរ៉េ និងរដ្ឋនានាដែលបានចូលរួមកិច្ចសន្ទនា៦ភាគីឱ្យបន្តកិច្ចចរចា និងជៀសវាងការប្រើប្រាស់កម្លាំង(កងកម្លាំងទាហានជើងទឹកកូរ៉េខាងត្បូងត្រូវបានរងការវាយប្រហារពីគ្រាប់បែកមុជទឹក) ចាប់តាំងពីឆ្នាំ១៩៥៣ គឺមានតែយុទ្ធសន្តិភាពទេ ហើយមិនមែនជាសន្ធិសញ្ញាសន្តិភាពទេ។

វេទិកានេះស្ថិតក្រោមអធិបតីភាពរបស់រដ្ឋដែលកំពុងកាន់មុខតំណែងជាប្រធានអាស៊ាន។ ប្រធានដឹកនាំវេទិកាជាប្រធានអាស៊ានក្នុងអាណត្តិ និងអនុប្រធានដែលនឹងក្លាយខ្លួនជាប្រធានអាស៊ាននាពេលអនាគត។ ដំណើរការវេទិកានេះត្រូវបានរៀបចំឡើងជាបីដំណាក់កាល ៖ (១) ការចាត់វិធានការក្នុងគោលបំណងលើកកម្ពស់បរិយាកាសជឿទុកចិត្តគ្នា។ (២) ចេតនាក្នុងការអភិវឌ្ឍយន្តការបង្ការផ្នែកការទូត(ការសាកល្បងដាក់ចេញប្រតិបត្តិយន្តការបង្ការអធិករណ៍)។ (៣) ការដាក់ចេញការប្រើប្រាស់យន្តការដំណោះស្រាយជម្លោះ។

ដំណាក់កាលទី១ គឺជាដំណាក់កាលជាសារវន្ត ពីព្រោះថាជាដំណាក់កាលដែលដាក់ឱ្យអនុវត្តគោលការណ៍ដែលចេញមកពីអាស៊ានដើម្បីបង្ការជម្លោះនានារវាងរដ្ឋសមាជិក។ ប្រសិនបើមិនដំណើរទេ វេទិកានឹងផ្តល់អភ័យឯកសិទ្ធិទៅលើវិធីសាស្ត្រអាស៊ានតាមរយៈការប្រឹក្សា និងការព្រមព្រៀងឯកភាព(ជាមុន)។ ហើយក្នុងសម្មតិកម្មដែលការព្រមព្រៀងឯកភាពមិនអាចធ្វើឡើងបាន វេទិកានឹងចាត់វិធានការណ៍សកម្មភាព។ វេទិកានេះមិនត្រឹមតែបញ្ចូលតែរដ្ឋក្នុងតំបន់អាស៊ីអាគ្នេយ៍ប៉ុណ្ណោះទេ តែក៏មានរួមបញ្ចូលប្រទេសមហាអំណាចពិភពលោកផងដែរ។

### ១.២.២- ត្រូយកាអាស៊ាន(ASEAN Troïka)

ត្រូយកាអាស៊ានត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៩ដោយផ្អែកទៅលើគំនិតរបស់នាយករដ្ឋមន្ត្រីថៃឡង់ដ៍ដើម្បីបង្កើតអង្គភាពគ្រប់គ្រងថ្នាក់រដ្ឋមន្ត្រីដែលមានសមត្ថកិច្ចលើប្រធានបទទាំងឡាយណាដែលប៉ះពាល់ដល់សន្តិភាព និងស្ថិរភាពតំបន់។ គំនិតនេះត្រូវបានអនុម័តនៅខែវិច្ឆិកា ឆ្នាំ១៩៩៩។ Troïka នេះរួមមានសមាសភាពរដ្ឋមន្ត្រីការបរទេសរបស់បណ្តាប្រទេសជាសមាជិកអាស៊ាន និងក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រីការបរទេសដែលជាប្រធានក្រុមប្រឹក្សាសម្របសម្រួល។ ជាធម្មតាអង្គភាពនេះមានសមាសភាព៣រូប(រដ្ឋមន្ត្រីការបរទេសនៃប្រធានអាស៊ានអតីតកាល បច្ចុប្បន្ន និងទៅអនាគត)។ Troïka គ្មានអំណាចចេញសេចក្តីសម្រេចណាមួយឡើយ។ វាគ្រាន់តែដើរតួនាទីជាអង្គភាពជំនួយមួយប៉ុណ្ណោះ។ កាលណាសំណួរមួយលេចឡើង ហើយអាចនឹងមានផលវិបាករំខានដល់សន្តិភាព និងស្ថិរភាពក្នុងតំបន់ Troïka នេះអាចសម្រេចពិនិត្យលើសំណុំឯកសារនេះ ចាប់ផ្តើមធ្វើសកម្មភាព ហើយដើម្បីធ្វើបាន រដ្ឋមន្ត្រីការបរទេស៣រូបត្រូវបានចាត់តាំងឱ្យសិក្សាលើសំណុំឯកសារ និងផ្តល់អនុសាសន៍ និងសេចក្តីណែនាំនានាឱ្យក្រុមប្រឹក្សាសម្រប

សម្រួល។ Troïka នេះបំពេញអាណត្តិជាក់លាក់មួយដែលនឹងផ្តល់ដោយរដ្ឋមន្ត្រីការបរទេសអាស៊ានទាំងអស់។

### ១.២.៣- សេចក្តីប្រកាសស្តីពីក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង

សំណួរមួយក្នុងចំណោមសំណួរជាច្រើនដែលមានភាពចម្រូងចម្រាស់ និងការលំបាកបំផុតសម្រាប់អាស៊ាន គឺកំពុងតែប្រឈមឡើង។ ប្រទេសចិនទាមទារ៩០%នៃតំបន់សមុទ្រចិនខាងត្បូងតាមច្បាប់ឆ្នាំ១៩៩២។ តំបន់នេះមានកោះចំនួន៣០០ និងកោះតូចៗ ព្រមទាំងប្រជុំកោះចំនួន២ទៀត គឺប្រជុំកោះស្ប៉ាតលី(Spratly) និងប៉ារាសែល(Paracel)។ គឺជាការទាមទារត្រួតគ្នារវាងប្រទេសចិន និងវៀតណាម។ ប្រជុំកោះស្ប៉ាតលីត្រូវទាមទារដោយប្រទេសចិន តៃវ៉ាន់ វៀតណាម ម៉ាឡេស៊ី និងហ្វីលីពីន។ ប្រទេសប្រ៊ុយណេមិនបានទាមទារកោះណាមួយទេ តែទាមទារយកតំបន់ដែលនៅជុំវិញ។ ប្រទេសដែលទាមទារពាក់កណ្តាលមាន ម៉ាឡេស៊ី និងហ្វីលីពីន។ ប្រទេសចិនទាមទារដោយមានមូលដ្ឋានទៅលើអនុសញ្ញាម៉ុងតេហ្គូបៃ(Montego Bay) ឆ្នាំ១៩៨២(ប្រទេសហ្សាម៉ាអ៊ិច)ស្តីពីនីតិសមុទ្រ និងចូលជាធរមានក្នុងឆ្នាំ១៩៩៤។ ក្នុងខ្លឹមសារនៃអនុសញ្ញានេះដែនដីសមុទ្រ(១២ម៉ាយសមុទ្រស្មើនឹង១៨៥២ម៉ែត្រ រដ្ឋមានសិទ្ធិដាច់មុខនៅលើអាកាស លើផ្ទៃទឹក ក្នុងទឹក និងក្រោមដី) តំបន់សេដ្ឋកិច្ចផ្តាច់មុខ(ZEE-២០០ម៉ាយសមុទ្រ រដ្ឋមានសិទ្ធិផ្តាច់មុខក្នុងផ្នែករុករក និងធ្វើអាជីវកម្មធនធាននេសាទ និងរ៉ែ)។ ក្នុងអនុសញ្ញាMontego Bay កោះមួយអាចមានតំបន់សេដ្ឋកិច្ចផ្តាច់មុខ(ZEE) ចម្ងាយ២០០ម៉ាយសមុទ្រ។ ច្បាប់ប្រទេសចិនចែងថាសមុទ្រចិនគឺជាដែនដីជនប្រទេសចិន ឯប្រជុំកោះParacelស្ថិតនៅចំណុះឱ្យខេត្តហៃណាន។ រដ្ឋទាំងអស់បានចាប់ផ្តើមធ្វើសកម្មភាព(គ្រប់គ្រងដោយកម្លាំងយោធាលើកោះ និងថ្មប៉ប្រះទឹកនានា)។ សម្រាប់ប្រជុំកោះParacel ដែនអធិបតេយ្យភាពគឺប្រទេសបារាំងបានភ្ជាប់ប្រជុំកោះParacelទៅឱ្យវៀតណាម។ ក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ប្រជុំកោះប៉ារ៉ាសែលត្រូវបានភ្ជាប់ទៅឱ្យវៀតណាមខាងត្បូង។ក្នុងឆ្នាំ១៩៧៤ វៀតណាមទាំងពីរកំពុងតែមានសង្គ្រាមរវាងគ្នា ប្រទេសចិនបានគ្រប់គ្រងដោយសន្តិវិធីទៅលើគ្រប់ប្រជុំកោះParacel។ សម្រាប់ប្រជុំកោះSpratlyវិញ ប្រទេសនីមួយៗព្យាយាមចាប់យកការគ្រប់គ្រង។ ក្នុងពេលរង់ចាំនេះ គ្រប់គ្នាបានគ្រប់គ្រងកោះ និងកូនកោះនានា។ ប្រទេសវៀតណាម ហ្វីលីពីន និងម៉ាឡេស៊ី មិនយល់ស្របឱ្យប្រទេសចិនអនុវត្តអធិបតេយ្យខ្លួនឡើយ។ សម្រាប់ប្រទេសចិន អធិបតេយ្យភាពមិនអាចចរចាដោយយោងទៅលើកងទ័ពជើងទឹករបស់ចិនក្នុងសតវត្សរ៍ទី១២។

ក្នុងទសវត្សរ៍ឆ្នាំ៩០ ចម្បាំងជើងទឹកពិតប្រាកដមួយបានកើតឡើងរវាងអ្នកនេសាទចិន និងវៀតណាម។ ក្នុងទសវត្សរ៍ឆ្នាំ៨០ មានការបញ្ជាក់អះអាងសារជាថ្មី ហើយក្នុងរវាងឆ្នាំ១៩៩៥ មាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជម្លោះរវាងជនជាតិហ្វីលីពីន និងជនជាតិចិន។ កងទ័ពចិនត្រូវបានពង្រឹង ហើយឆន្ទៈនៃការបញ្ចេញអំណាចរបស់ចិនមិនត្រឹមតែក្នុងតំបន់ប៉ុណ្ណោះទេ។ ផ្អែកលើមូលដ្ឋាននៃវេទិកាតំបន់អាស៊ាន(ARF) ឆ្នាំ២០០២ សេចក្តីប្រកាសស្តីពីក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ ត្រូវបានអនុម័តដោយគូភាគីជម្លោះនៅទីក្រុងភ្នំពេញ។ ក្នុងសេចក្តីប្រកាសនេះ ប្រទេសចិនបានស្នើឱ្យមានកិច្ចពិភាក្សាស្តីពីការគ្រប់គ្រងរួមគ្នា។ មានផលប្រយោជន៍ចំនួន២ ៖ (១) តំបន់ដែលសម្បូរទៅដោយធនធាននេសាទ និងធនធានប្រេង និងឧស្ម័ន(ប្រទេសវៀតណាមយល់ព្រមផ្តល់សម្បទានទៅឱ្យក្រុមហ៊ុនអាមេរិក)។ (២) សមុទ្រចិនគឺជាផ្លូវយុទ្ធសាស្ត្រមួយ(៨០%នៃប្រេងចិន។ ៨៥%នៃប្រេងជប៉ុនឆ្លងកាត់តាមសមុទ្រចិន គឺដែលសមុទ្រម៉ាឡាកា Malacca)។ ជាតុទីមួយនៃសេចក្តីប្រកាសនេះ គឺថាគូភាគីហត្ថលេខីសន្យា និងឯកភាពទទួលយកគោលការណ៍នានានៃធម្មនុញ្ញអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ និងសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ (TAC)។ គឺជាគោលការណ៍ដែលបានកំណត់នៅក្នុងអត្ថបទ។ ចំណុចទីពីរ ក្រមនេះពុំមានអានុភាពចាប់បង្ខំទេ វាគ្រាន់តែជាសេចក្តីប្រកាសសំដែងពីឆន្ទៈល្អប៉ុណ្ណោះ។ ប៉ុន្តែ ជាសេចក្តីប្រកាសដែលព្យាយាមផ្តល់អភ័យឯកសិទ្ធិចំពោះគោលការណ៍នៃការមិនប្រឈមមុខដាក់គ្នា និងគោលការណ៍ការទូតបង្ការ។ ចំណុចទីបី គូភាគីហត្ថលេខីសន្យាមិនធ្វើការគ្រប់គ្រងលើកោះដទៃៗទៀត និងកោះតូចៗបន្ថែមទៀត និងមិនធ្វើការបញ្ចូលការកែប្រែណាមួយទៅកាន់កោះតូចៗដែលបានគ្រប់គ្រងរួចហើយ(Status quo) និងមិនឱ្យមានការរៀបចំណាមួយឡើយ។ វិធានការណ៍ច្បាស់លាស់ទីពីរ គូភាគីទាំងអស់រក្សាទុកសេរីភាពនាវាចរណ៍ និងគោលការណ៍ហោះហើរដោយសេរី។ ក្នុងករណីដែលមានអធិករណ៍ ភាគីទាំងអស់សន្យាមិនប្រើប្រាស់កម្លាំង និងធ្វើការដោះស្រាយជម្លោះដោយសន្តិវិធីតាមរយៈការចរចាគ្នា។

ស្ថានភាពបច្ចុប្បន្ន មានការប្រឈមមុខដាក់គ្នារវាងក្រុមអ្នកនេសាទ។ ក្នុងឆ្នាំ២០១០ មានការប្រឈមមុខដាក់គ្នារវាងអ្នកនេសាទវៀតណាម និងទាហានចិន។ ហើយជាតុថ្មីមួយទៀតគឺប្រទេសហ្វីលីពីនក្នុងឆ្នាំ២០០៩ បានអនុម័តក្រឹត្យប្រធានាធិបតី គឺក្រឹត្យស្តីពីខ្សែបន្ទាត់មូលដ្ឋានប្រជុំកោះ(Archipelagic Baseline Act) ប្រទេសហ្វីលីពីនបានក្លាយជារដ្ឋប្រជុំកោះ។ ប្រទេសហ្វីលីពីនបានបញ្ជាក់អះអាងសារជាថ្មីពីដែនអធិបតេយ្យភាពរបស់ហ្វីលីពីនលើកោះមួយចំនួន និងកោះតូចៗផ្សេងៗទៀត។ ក្នុងឆ្នាំ២០១០ លោកAquinoបានសំដែងពីឆន្ទៈរបស់ខ្លួនដោយធ្វើការបំពានទៅលើសេចក្តីប្រកាសឆ្នាំ២០០២ ស្តីពីការរៀបចំដែនដី និងពង្រឹងការការពារនៅលើកោះចំនួន១០ និងកោះតូចៗផ្សេងៗទៀតនៅប្រជុំកោះSpratlyដែលគ្រប់គ្រងដោយប្រទេសហ្វីលីពីន។ ក្នុងកិច្ចប្រជុំលើកទី១៧របស់វេទិកាតំបន់អាស៊ាន(ARF) សមាជិកនៃវេទិកាបានជំរុញឱ្យគ្រប់ភាគីទាំងអស់នៃជម្លោះធ្វើការដោះស្រាយដោយសន្តិវិធីឱ្យគោរពខ្លឹមសារនៃសេចក្តីប្រកាស


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឆ្នាំ២០០២ ស្តីពីធនធ្ទះល្អ កិច្ចប្រជុំកំពូលទីក្រុងហាណូយ នាខែតុលា ឆ្នាំ២០១០ និងបានបង្ហាញពីឆន្ទៈដើម្បីឈានទៅឱ្យមានការចរចានានា និងធ្វើឱ្យល្បែងមួយនេះវិលទៅរកការស្ងៀមស្ងាត់វិញ។ រដ្ឋមន្ត្រីការបរទេសអាមេរិកបានធ្វើសេចក្តីប្រកាសផ្លូវការមួយដែលថាសហរដ្ឋអាមេរិកមានចំណាប់អារម្មណ៍លើផ្នែកសមុទ្រ។ សហរដ្ឋអាមេរិកគឺជាមហាអំណាចប៉ាស៊ីហ្វិចវ័យចំណាស់មួយដែលបានមានវត្តមាននៅប្រទេសហ្វីលីពីន និងសេរីភាពផ្នែកនាវាចរណ៍សមុទ្រ។ គឺជាចក្កុវិស័យភពផែនដី និងពិភពលោក។ ជាពិភពពហុប៉ូល ប៉ុន្តែត្រូវដឹកនាំដោយមហាអំណាចអាមេរិក ជាមួយនឹងឥទ្ធិពលអាមេរិក។ គេបានត្រលប់តួនាទីនេះវិញ ប្រទេសចិននិយាយថា បងធំប្រចាំតំបន់មួយនេះ គឺខ្ញុំ។ ក្នុងស្ថានភាពបច្ចុប្បន្ននេះ គេកំពុងតែស្វែងរកកិច្ចព្រមព្រៀងមួយស្តីពីការដឹកនាំល្អ។ ប្រសិនបើថ្ងៃណាមួយ កិច្ចព្រមព្រៀងអាចធ្វើឡើងបាន គេនឹងឈានទៅរកការគ្រប់គ្រងប្រចាំតំបន់ ដូច្នេះ គេត្រូវរង់ចាំ ដើម្បីអាចឃើញថាយ៉ាងណាខ្លះ(រង់ចាំ និងមើល)។ នេះគឺជាគ្រាប់មីនមួយប្រភេទសម្រាប់អាស៊ានខ្លួនឯងផងដែរ។ រដ្ឋសមាជិកអាស៊ានទាំងអស់គាំទ្រជំហរនានារបស់ប្រទេសវៀតណាម និងហ្វីលីពីន។ អាស៊ានតែងតែអភិវឌ្ឍដំណោះស្រាយបែបបង្ការ។ គឺទិដ្ឋភាពផ្នែកបង្ការដែលគេផ្តល់អភ័យឯកសិទ្ធិ។ អាស៊ានបានបញ្ចូលនូវកិច្ចផ្តួចផ្តើមថ្មីសម្រាប់អភិវឌ្ឍបរិយាកាសឱ្យកាន់តែមានលក្ខណៈប្រជាធិបតេយ្យ។

## ២- ការកែលម្អនៅពេលអនាគត

យើងអាចរំពឹកឡើងវិញថា អាស៊ានមានគោលដៅចុងក្រោយនឹងបំលែងខ្លួនជាសហគមន៍ដែលមានមូលដ្ឋានផ្អែកលើបទដ្ឋាននានា និងតម្លៃរួមគ្នា ដែលនេះជាមធ្យោបាយតែមួយក្នុងការបង្ការការពារអធិបតេយ្យភាពរបស់ខ្លួន។ ក្នុងចំណោមបទដ្ឋាន និងតម្លៃរួមគ្នាទាំងនោះ យើងឃើញមានការអភិវឌ្ឍ តែក៏មានផងដែរនូវសិទ្ធិមនុស្ស ហើយនឹងសក្តានុពលក្នុងការឈានឆ្ពោះទៅរកពាក្យប្រជាធិបតេយ្យ។ មានការជជែកតវ៉ាគ្នានៅក្នុងតំបន់ចំពោះបញ្ហាសិទ្ធិមនុស្ស គេបានព្យាយាមដាក់ប្រឈមតម្លៃជាសកលទៅនឹងតម្លៃអាស៊ី។ អតីតមេដឹកនាំអាស៊ានពីររូប គឺលោកលីក្វាន់យូ(Lee Kuan Yew)និងលោកមហាធារ(Mahathir) នៅក្នុងទសវត្សរ៍ឆ្នាំ៨០ និងដើមទសវត្សរ៍ឆ្នាំ៩០ បានស្នើឡើងពីតម្លៃនៅអាស៊ី ដោយធ្វើការប្រឆាំងទៅនឹងតម្លៃលោកខាងលិចដែលជាគ្រឹះនៅក្នុងសេចក្តីប្រកាសទីក្រុងបាងកក ឆ្នាំ១៩៩៣។ ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ក្រោមការឧបត្ថម្ភគាំទ្ររបស់អង្គការសហប្រជាជាតិ គឺការធ្វើសន្និសីទនានា។ សម្រាប់អាស៊ីវិញ សន្និសីទតំបន់ត្រូវបានប្រព្រឹត្តឡើងនៅទីក្រុងបាងកក។ នៅក្នុងសេចក្តីប្រកាសទីក្រុងបាងកក គេបានរកឃើញគំនិតរបស់លោកលី និងលោកមហាធារ។ ឥទ្ធិពលមកពីក្រៅមិនអាចដំណើរការបានទេ។ ហេតុដូច្នេះ សិទ្ធិមនុស្ស គឺប្រៀបដូចជាអាវុធមនោគមវិជ្ជារបស់លោកខាងលិចដែលបានដាក់ទៅលើ

បួនប្រទេស។ តម្លៃលោកខាងលិចផ្តល់អភ័យឯកសិទ្ធិទៅឱ្យឯកត្តជន។ នៅក្នុងតម្លៃអាស៊ីនេះវិញ វាគ្រាន់តែជាយានបថលំដាប់ទីបីប៉ុណ្ណោះ ព្រោះគ្រួសារដើរតួនាទីសំខាន់ជាងបុគ្គល ហើយសង្គមមានតួនាទីសំខាន់ជាងគ្រួសារ។ ឯកត្តនិយមនេះហើយដែលជាចំណុចឧបសគ្គគោល (ឧបសគ្គ)។ កុំធ្វើឱ្យពិបាក សូមបំពេញការងារដោយការអត់ធន់។ គឺជាការថ្លៃថ្នូរកថាមនោគមន៍វិជ្ជាប្រឆាំងទៅនឹងលោកខាងលិច។ ច្បាប់ស្តីពីសន្តិសុខផ្ទៃក្នុងអនុញ្ញាតឱ្យមានការឃុំឃាំងបណ្តោះអាសន្នសម្រាប់រយៈពេល២ឆ្នាំ ដោយមិនចាំបាច់មានការវិនិច្ឆ័យ។ ប្រព័ន្ធសេដ្ឋកិច្ចគឺសេដ្ឋកិច្ចទីផ្សារ។ សេដ្ឋកិច្ចចិនបានប្រែក្លាយជាសេដ្ឋកិច្ចទីផ្សារសេរី។ សេចក្តីប្រកាសទីក្រុងវីយែន (ជាទូទៅ) ឆ្នាំ២០០៣ គឺជាអត្ថបទចុងក្រោយ ប៉ុន្តែគេមិនបានដកស្រង់នូវគំនិតនានានៃសេចក្តីប្រកាសទីក្រុងបាងកកទេ។ ពាក្យថាប្រជាធិបតេយ្យ និងសិទ្ធិមនុស្សពុំមានអត្ថន័យដូចពីមុនទេ។

ផ្នែកទី១នៃផែនការសហគមន៍នយោបាយ និងសន្តិសុខចែងពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកប្រជាធិបតេយ្យ អភិបាលកិច្ចល្អ ការចូលរួមនៅក្នុងសង្គមស៊ីវិល ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការពង្រឹងវិធាននៃនីតិ ការពង្រឹងប្រព័ន្ធតតិយុត្តនិងយុត្តាធិការ និងការពង្រឹងការការពារសិទ្ធិមនុស្ស។ គេបានមើលឃើញធម្មនុញ្ញអាស៊ានត្រង់មាត្រា១៤ចែងពីកិច្ចបង្ការ និងការពារសិទ្ធិមនុស្ស។ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ប្រទេសទាំងអស់ប្រើប្រាស់ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ មានរដ្ឋដែលដើរមុនទៅមុខមួយជំហាន។ ពាក់ព័ន្ធនឹងការចូលរួមរបស់សង្គមស៊ីវិល មានដំណើរការដ៏វែងឆ្ងាយមួយដែលត្រូវឆ្លងកាត់។ សង្គមស៊ីវិលបានលេចឡើង។ ទោះបីជាក្នុងសង្គមដែលមានការរីកចម្រើន ដូចជាប្រទេសសិង្ហបុរីក្តី សង្គមស៊ីវិលមិនបានចូលរួមនៅក្នុងការតាក់តែងនយោបាយសាធារណៈនោះទេ។ គេបានរិះគន់អាស៊ានពាក់ព័ន្ធនឹងការកាត់ផ្តាច់ប្រជាពលរដ្ឋ។ នេះជាឱកាសរបស់អាស៊ានក្នុងការសាកល្បងខិតទៅជិតប្រជាពលរដ្ឋវិញ។ ក្របខ័ណ្ឌស្ថាប័នផ្តល់អំណាចទៅឱ្យមេដឹកនាំនានា។ ដំណើរផ្លូវគឺនៅវែងឆ្ងាយខ្លាំងដែរ ដើម្បីធ្វើឱ្យអារម្មណ៍កាត់ផ្តាច់នេះផុតរលត់ទៅ។

# ផ្នែកទី៩
## នយោបាយកិច្ចសហប្រតិបត្តិការសង្គមវប្បធម៌

នៅក្នុងផ្នែកនេះ អាស៊ានបានដើរហួសក្របខ័ណ្ឌការទូតបុរាណ ដើម្បីឈានទៅដល់កម្រិតក្រសួង។ មានអង្គភាពក្រសួងតាមវិស័យដែលធ្វើអន្តរាគមន៍នៅក្នុងវិស័យសង្គម និងវប្បធម៌។ នៅក្នុងវិស័យទាំងនេះ សមត្ថកិច្ចនៅតែថ្នាក់តំបន់ដដែល។ តួនាទីអាស៊ាននៅតិចតួចនៅឡើយ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប៉ុន្តែតាំងពីជាង១០ឆ្នាំមកនេះ កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យមួយចំនួនបានកំពុងអភិវឌ្ឍឡើង។

បញ្ហាទីមួយដែលបានចោទឡើង គឺសកម្មភាពរួមគ្នាមួយ គឺពិពិធភាពនៃស្ថានភាពជាតិ។ គេបានមើលឃើញពីភាពផ្សេងៗគ្នានៃកម្រិតអភិវឌ្ឍ។ សិង្ហបុរីបានឈានទៅដល់កម្រិតអភិវឌ្ឍន៍មួយផ្នែកអប់រំ សុខភាព និងការងារដែលអាស៊ានមិនអាចផ្តល់ឱ្យបាន។ ឧបសគ្គទីពីរ(អន្ទាក់គ្រោះថ្នាក់) គឺបញ្ហាហិរញ្ញវត្ថុ។ បណ្តារដ្ឋសមាជិកទាំងអស់មិនមានធនធានហិរញ្ញវត្ថុចាំបាច់សម្រាប់ផ្តល់ទុនទៅឱ្យគ្រោងការវប្បធម៌ ហើយក៏គ្មានមនុស្សដែលមានសមត្ថភាពបំពេញការងារទាំងនេះផងដែរ។ រដ្ឋទាំងអស់រក្សាទុកលទ្ធភាពនៃការគ្រប់គ្រងយ៉ាងធំ។ ផ្នែកសង្គមវិញ ក្នុងអត្ថន័យបែបទូលាយ អាស៊ានអភិវឌ្ឍសភាពការណ៍នយោបាយដោយការដាក់ចេញនូវការពង្រឹងកិច្ចសហប្រតិបត្តិការគោលមួយ តាមរយៈការប្រព្រឹត្តទៅជាទៀងទាត់នូវកិច្ចប្រជុំនានានៅកម្រិតរដ្ឋមន្ត្រី។ ក្រុមប្រឹក្សាសង្គមវប្បធម៌សហគមន៍ទទួលទីតាំងអង្គភាពក្រសួងជំនាញ។ ប្រភពចម្បងនៃនយោបាយសង្គមអាស៊ាន ពោលគឺផ្លែផ្កានៃកិច្ចប្រជុំរដ្ឋមន្ត្រីត្រូវបានអនុម័តដោយអង្គភាពក្រសួងទាំងនេះ។ មិនសូវជាមានវិធានដែលដាក់កំហិតនោះទេ។ គេនៅតែស្ថិតក្នុងក្របខ័ណ្ឌកាតព្វកិច្ចតាមសីលធម៌នៅឡើយ។ ផែនការសហគមន៍សង្គមវប្បធម៌អាស៊ាន ឆ្នាំ២០០៩-២០១៥ បានដាក់ចេញនូវគោលគំនិតនៃកិច្ចសហប្រតិបត្តិការដែលវិវត្តមួយ។ ហើយអ្វីដែលសំខាន់ គឺអាស៊ានបានដាក់បញ្ចូលនូវគោលគំនិតនៃដំណើរការនិរន្តរមិនមែនជាសកម្មភាពដាក់លាក់ សម្រាប់រយៈពេលកំណត់ណាមួយឡើយ។ ការកសាងសហគមន៍នេះគឺជាអភិក្រមអចិន្ត្រៃយ៍មួយ។ ការតម្រង់ទិសជាយុទ្ធសាស្ត្រនៃផែនការនេះមានពីរ ៖ (១) ឆន្ទៈតម្រង់ទិសសហគមន៍ឆ្ពោះទៅកាន់ប្រជាជន។ (២) ឯកភាពនៅក្នុងពិពិធភាព(បាវចនាអាស៊ាន និងម៉ាឡេស៊ី)។ ក្នុងរបៀបកាន់តែដាក់ច្បាស់ទៅទៀត ផែនការនេះប្រជុំនូវសកម្មភាពជា៤ផ្នែក ៖

- ផ្នែកទី១ ៖ ការអភិវឌ្ឍមនុស្ស និងសុខមាលភាពសង្គម
- ផ្នែកទី២ ៖ បរិស្ថាន
- ផ្នែកទី៣ ៖ ការលើកកម្ពស់អត្តសញ្ញាណអាស៊ាន
- ផ្នែទី៤ ៖ ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងរដ្ឋសមាជិក។

ដើម្បីឈានទៅដល់ទស្សនាទានសហគមន៍នេះ កិច្ចសហប្រតិបត្តិការពីរប្រភេទ ត្រូវបានដាក់ចេញ ៖ កិច្ចសហប្រតិបត្តិការផ្នែកសង្គម និងកិច្ចសហប្រតិបត្តិការផ្នែកបរិស្ថាន។

## ១- កិច្ចសហប្រតិបត្តិការផ្នែកសង្គម

កិច្ចសហប្រតិបត្តិការផ្នែកនេះ ពាក់ព័ន្ធនឹង២ប្រភេទ ៖ តាមវិស័យ និងឆ្លងព្រំដែន។

## ១.១- កិច្ចសហប្រតិបត្តិការតាមវិស័យ

*ទន្ទឹមគ្នានេះ អាស៊ានបានសាកល្បងអភិវឌ្ឍនូវវេទិការួមផ្នែកប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ លើកកម្ពស់ការអប់រំ ការងារសមរម្យ និងសុខភាព ហើយចុងក្រោយ ការពារស្ត្រីនិងកុមារ។*

### ១.១.១- ការលុបបំបាត់ភាពក្រីក្រ

*ការលុបបំបាត់ភាពក្រីក្របានក្លាយទៅជាកង្វល់ចម្បងរបស់រដ្ឋសមាជិក។ រំឭកឡើងវិញបន្តិច ៖ ធ្វើដូចម្តេចអាចវាស់វែងការអភិវឌ្ឍមនុស្សនៅក្នុងប្រទេសមួយបាន។ សូចនាករដែលត្រូវបានប្រើប្រាស់គឺផលិតផលក្នុងស្រុកសរុប(GDP)។ GDP នេះបានផ្តល់នូវការចង្អុលបង្ហាញទៅលើភាពសម្បូរបែបរបស់រដ្ឋមួយ ប៉ុន្តែត្រឹមតែផ្នែកៗទេ។ ក្នុងឆ្នាំ១៩៩០ អង្គភាពមួយក្នុងប្រព័ន្ធអង្គការសហប្រជាជាតិUNDPបានបង្កើតសន្ទស្សន៍មួយនៃការអភិវឌ្ឍមនុស្សដែលអនុញ្ញាតឱ្យមើលឃើញនូវទស្សនៈវិស័យពេញលេញមួយចំពោះកម្រិតអភិវឌ្ឍន៍របស់ប្រទេសជាតិមួយ។ សន្ទស្សន៍នេះប្រើប្រាស់សូចនាករជាច្រើន ហើយនៅឆ្នាំ២០១០ គេបានកែប្រែសូចនាករមួយចំនួន ឧទាហរណ៍ដូចជា សូចនាករដែលគិតគូរពីអត្រាអនក្ខរកម្ម នៅឆ្នាំ២០១០ និងរយៈពេលមធ្យមនៃអប់រំនៅសាលា។ ចំណុចទីពីរ គឺលែងជា GDP ទៀតហើយ គឺចំណូលជាតិសរុប។ កាលណាគេយកGDP គឺជាធនធានជាតិដែលត្រូវបានផលិត។ ចំណូលជាតិសរុបមិនត្រឹមតែជាចំណូលសរុបទេ ក៏ប៉ុន្តែក៏រាប់បញ្ចូលជំនួយ និងការផ្ទេរមូលនិធិផងដែរ(ការផ្ទេរប្រាក់)។ ក្នុងឆ្នាំ២០១០ សម្រាប់ប្រទេសទីម័រខាងកើត បានកើនឡើងលំដាប់ ពីព្រោះគេបានរាប់បញ្ចូលចំណូលជាតិសរុប និងជំនួយ។*

*សន្ទស្សន៍ទីមួយ ៖ ការសង្ឃឹមរស់ ចាប់តាំងពីកំណើត។*

- *រយៈពេលជាមធ្យមនៃការរៀនសូត្រ។*
- *ចំណូលជាតិសរុបក្នុងប្រជាជនម្នាក់(ឆ្នាំ២០០៨ សម្រាប់របាយការណ៍ឆ្នាំ២០១០)ពី១ (កម្រិតខ្ពស់ខ្លាំង)*

*នៅក្នុងរបាយការណ៍ឆ្នាំ២០១០(ខួបលើកទី២០ ឆ្នាំ១៩៨០-២០១០) រដ្ឋចំនួន១៦៩ត្រូវបានរៀបចំជាចំណាត់ថ្នាក់ ៖ (ទី១) ន័រវេស(សន្ទស្សន៍០,៩៣៨) អូស្ត្រាលី សហរដ្ឋអាមេរិក អៀឡង់ បារាំង (ទី១៤) សិង្ហបុរី(ទី២៧ គឺ០,៨៤៦) ប្រ៊ុយណេ(ទី៣៧ គឺ០,៨០៥) សន្ទស្សន៍ខ្ពស់ ម៉ាឡេស៊ី (ទី៥៧ គឺ០,៧៤៤)។ សន្ទស្សន៍មធ្យមមានថៃឡង់ដ៍(ទី៩២ គឺ០,៦៥៤) ហ្វីលីពីន(ទី៩៦ គឺ០,៦៣៨) ឥណ្ឌូនេស៊ី(ទី១០៨ គឺ០,៦០០) វៀតណាម(ទី១១៣ គឺ០,៥៧២) ឡាវ(ទី១២២ គឺ០,៤៩៧) កម្ពុជា(ទី១២៤ គឺ០,៤៩៤)។ សន្ទស្សន៍ការអភិវឌ្ឍមនុស្សខ្សោយ គឺមីយ៉ាន់ម៉ា(ទី១៣២ គឺ០,៤៥១) ទីម័រ(ទី១២០ គឺ០,៥០២)។ ក្នុងកម្រិតនៃសន្ទស្សន៍ អាស៊ានមានការរីកចម្រើន។*

*អំពីការលុបបំបាត់ភាពក្រីក្រ សូចនាករគឺសមាមាត្ររវាងប្រជាជនទីក្រុង និងប្រជាជនជនបទ។ នៅក្នុងបណ្តាប្រទេសអាស៊ាន ប្រជាជាននៅប្រទេសសិង្ហបុរីគឺ១០០%ជាប្រជាជនទីក្រុង គឺផ្ទុយជាមួយនឹងចំនួន៦៥%នៅប្រទេសភូមាដែលជាប្រជាជននៅជនបទ។ ភាពក្រីក្រគឺភាពក្រីក្រនៅជនបទ។ ទាក់ទងនឹងភាពក្រីក្រនៅទីក្រុងវិញ គឺតំបន់អនាធិបតេយ្យដោយអ្នកជនបទបានចាកចេញពីជនបទ ដើម្បីមករស់នៅក្នុងមជ្ឈដ្ឋានទីក្រុង។ គឺជាកិច្ចប្រជុំរដ្ឋមន្ត្រីអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ(AMRDPE) កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ និងក្រុមជំនាញនានា។ នៅក្នុងផ្នែកនេះ អាស៊ានបានអភិវឌ្ឍផែនការសកម្មភាពដែលត្រូវបានបង្កើតឡើងសម្រាប់រយៈពេល២០០៤-២០១០។ ផែនការសកម្មភាពនេះចែងពីដែនសកម្មភាពជាអាទិភាពនានាដូចជា ៖ (១) ការប្រយុទ្ធប្រឆាំងនឹងឥទ្ធិពលអវិជ្ជមាននៃសកលភាវូបនីយកម្ម និងសេរីភាវូបនីយកម្មសេដ្ឋកិច្ច។ (២) កាត់បន្ថយគម្លាតនៃការអភិវឌ្ឍក្នុងផ្នែកគាំពារសង្គម (៣) កាត់បន្ថយការបែកខ្ញែកនៃសេដ្ឋកិច្ចសង្គមដែលមានស្រាប់ ពិសេសបង្កើនកម្រិតជីវភាពរស់នៅរបស់ក្រុមងាយរងគ្រោះ ជាពិសេសស្ត្រី និងសហគមន៍ក្នុងស្រុក។ អាទិភាពមួយទៀត គឺឱកាសទទួលបានការងារធ្វើ។*

*គំនិតផ្តួចផ្តើមផ្សេងៗត្រូវបានអនុម័តក្នុងឆ្នាំ២០០៩ ៖ (១) គំនិតផ្តួចផ្តើមទាំងនេះ គឺចលនាយុវជនស្ម័គ្រចិត្តជនបទអាស៊ានដែលអនុញ្ញាតឱ្យមានការចាត់បញ្ជូនក្រុមយុវជនស្ម័គ្រចិត្តទៅកាន់មជ្ឈដ្ឋានជនបទ ដើម្បីពង្រឹងសមត្ថភាព។ (២) កម្មវិធីផ្លាស់ប្តូរមេភូមិ( គាំទ្រដោយអាស៊ានបូក៣) ដើម្បីពាំនាំយកបទពិសោធន៍បច្ចេកទេសកសិកម្មជាដើម-ល-។*

*តួនាទីចម្បងត្រូវធ្វើដោយអាស៊ានបូក៣។ រដ្ឋសមាជិកនីមួយៗបន្តកម្មវិធីរបស់ខ្លួន។ កិច្ចប្រជុំរដ្ឋមន្ត្រីនេះអនុញ្ញាតឱ្យមានការកំណត់ពីគំនិតផ្តួចផ្តើមនានា។*

## ១.១.២- ការអប់រំ

*ផ្នែកទីពីរ គឺការលើកកម្ពស់ការអប់រំ។ ការអប់រំគឺកម្លាំងរុញច្រានគោលមិនអាចប្រកែកបានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមវប្បធម៌របស់បណ្តាប្រទេសអាស៊ានផងដែរ។ គុណភាពអប់រំសំខាន់ខ្លាំងណាស់ ប៉ុន្តែត្រូវមានឱកាសទទួលបានការអប់រំ។ ការទទួលបានឱកាសអប់រំ គឺមិនមានភាពស្មើគ្នាទេ។ គុណភាពនៃការបង្រៀនអាស្រ័យទៅលើហេដ្ឋារចនាសម្ព័ន្ធនានា។ ក្នុងលទ្ធភាពដែលអាចធ្វើបាន គេត្រូវផ្តល់នូវប្រាក់បៀវត្សរ៍សមស្រប។ មានលក្ខន្តិកៈសង្គមរបស់គ្រូបង្រៀនផងដែរ។*

*ពាក់ព័ន្ធនឹងការអប់រំ ពុំមាននយោបាយអប់រំពិតប្រាកដណាមួយទេ ប៉ុន្តែអាចជាគំនិតផ្តួចផ្តើមណាមួយ។ កិច្ចប្រជុំរដ្ឋមន្ត្រីអប់រំអាស៊ាន(ASED)បានលើកឡើងនៅកិច្ចប្រជុំកំពូលលើកទី១១ នាខែធ្នូ ឆ្នាំ២០០៥ នូវគំនិតផ្តួចផ្តើមថ្មីៗពាក់ព័ន្ធនឹងវិស័យអប់រំ ៖ (១) ការលើកកម្ពស់អត្ត-*

សញ្ញាណអាស៊ានក្នុងចំណោមប្រជាពលរដ្ឋអាស៊ាន (២) ការពង្រឹងធនធានមនុស្សពាក់ព័ន្ធនឹងវិស័យអប់រំ និង (៣) ការពង្រឹងបណ្ដាញផ្លាស់ប្ដូរនៅតាមសាកលវិទ្យាល័យនៃប្រទេសអាស៊ាន។ កម្មវិធីផ្លាស់ប្ដូរដែលអនុញ្ញាតឱ្យនិស្សិតបន្តការសិក្សាជំនាញរបស់ខ្លួននៅក្នុងសាកលវិទ្យាល័យណាមួយដែលភ្ជាប់ជាមួយនឹងកម្មវិធីផ្លាស់ប្ដូរនេះ។ (៤) ការស្វែងរកការអភិវឌ្ឍអត្តសញ្ញាណអាស៊ាននេះមានគោលដៅផ្សព្វផ្សាយក្នុងចំណោមក្រុមយុវវ័យ។ វិស័យនៃកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា អាស៊ានបានបង្កើតនូវគណៈកម្មាធិការអាស៊ាន សម្រាប់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលត្រូវបង្កើតឡើងនៅឆ្នាំ១៩៧៨ ហើយបានធ្វើសកម្មភាពឡើងវិញក្នុងឆ្នាំ២០០៩។ ផែនការសកម្មភាពផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសនេះត្រូវបានអនុម័ត សម្រាប់រយៈពេល ២០០៧-២០១១ ឯផ្នែកសកម្មភាពជាអាទិភាពមួយចំនួនត្រូវបានអនុម័តដែរ ៖ បច្ចេកវិទ្យាខាងជីវសាស្ត្រ វិទ្យាសាស្ត្រចំណីអាហារ ឧតុនិយមវិទ្យា បច្ចេកវិទ្យាអគ្គិសនី និងការស្រាវជ្រាវផ្នែកថាមពល។ ដើម្បីជួយអភិវឌ្ឍផ្នែកទាំងអស់នេះ មូលនិធិអាស៊ាន ដើម្បីវិទ្យាសាស្ត្រត្រូវបានបង្កើតឡើង ដោយសារទទួលបានវិភាគទានពីបណ្ដារដ្ឋសមាជិក(២លានដុល្លារ) ដើម្បីជួយអភិវឌ្ឍវិស័យនេះដែលនេះជាប្រភពនៃសារៈសំខាន់នៃការបង្កើតរូបមន្តអាស៊ានបូក៣។ ពាក់ព័ន្ធនឹងវិស័យអប់រំនេះ កិច្ចប្រជុំអាស៊ានបូក៣លើកទីមួយត្រូវបានប្រព្រឹត្តនាខែវិច្ឆិកា ឆ្នាំ២០១០។

### ១.១.៣- ការការពារពលករ ស្ត្រី និងកុមារ

ពាក់ព័ន្ធនឹងការការពារពលករ អាស៊ានបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គការពលកម្មពិភពលោក(ICO) ក្នុងឆ្នាំ២០០៧។ កិច្ចព្រមព្រៀងនេះចែងពីកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានអាស៊ាន និងការិយាល័យនៃអង្គការ ICO។ កិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរនេះផ្ដោតទៅលើការផ្លាស់ប្ដូរព័ត៌មាន ករណីសិក្សា ការអនុវត្តកម្មវិធីពាក់ព័ន្ធនឹងសន្តិសុខ និងសុខភាពពលករ( មាត្រា១នៃកិច្ចព្រមព្រៀង)។ ជាតុដទៃៗទៀតនៃកិច្ចព្រមព្រៀងនេះគឺអង្គការទាំងពីរបានចែងឱ្យមានកិច្ចប្រជុំទៀងទាត់នានាដែលអនុញ្ញាតឱ្យមានការផ្លាស់ប្ដូរព័ត៌មាន និងជួបជុំគ្នា ដើម្បីអាស៊ាន។ អគ្គលេខាធិការធ្វើប្រតិភូកម្មសមត្ថកិច្ចរបស់ខ្លួនទៅឱ្យនរណាម្នាក់ក្នុងចំណោមលេខាធិការរងអាស៊ានទាំងបួន។ អគ្គលេខាធិការរងដែលមានសមត្ថកិច្ចសម្រាប់ការងារមួយនេះនឹងចូលរួមក្នុងកិច្ចប្រជុំនោះ។ កិច្ចប្រជុំអាស៊ានបូក៣ លើកទីមួយបានធ្វើឡើងជាមួយនឹងសិក្ខាសាលាតំបន់ចំនួន៤ស្ដីពីលាភការពលករផលិតភាព និងទំនាក់-ទំនងឧស្សាហកម្ម។ ពាក់ព័ន្ធនឹងចំណុចចុងក្រោយនេះ កម្មវិធីការងារអាស៊ានមួយត្រូវបានអនុម័តសម្រាប់ឆ្នាំ២០០៥-២០១០។ គោលដៅនៃកម្មវិធីការងារនេះគឺការពង្រឹងសមត្ថភាពរដ្ឋា-ភិបាល និយោជក និងកម្មករ ក្នុងការសម្រេចកិច្ចអាទិភាពនានា ៖ ការបណ្ដុះបណ្ដាលមន្ត្រី


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពាជការ និយោជក សហជីព ការអភិវឌ្ឍអង្គភាពសម្របសម្រួល។

ផ្នែកការពារពលករវិញ អាស៊ានបានអនុម័តផែនទីបង្ហាញផ្លូវ(Roadmap) សម្រាប់ឆ្នាំ២០០៩-២០១៥។ ផែនទីបង្ហាញផ្លូវនេះបានដឹកនាំឱ្យមានការអនុម័តនូវកម្មវិធីការងារ សម្រាប់ឆ្នាំ២០១០-២០១៥។ ទស្សនៈវិជ្ជាគឺការរៀបចំអាស៊ានទៅកាន់ការផ្លាស់ប្តូរ នាំមកដោយសកលភាវូបនីយកម្ម។

ពាក់ព័ន្ធនឹងស្ត្រី សេចក្តីប្រកាសមួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ត្រូវបានអនុម័ត។ សេចក្តីប្រកាសនេះផ្តោតទៅលើដែនសកម្មភាពចំនួន៤គឺ ៖ (១) ការផ្តល់សេវាកម្មនានា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ជនរងគ្រោះ ដោយសារអំពើហិង្សាក្នុងគ្រួសារ។ (២) ការចាត់វិធានការសមស្របប្រឆាំងទៅនឹងជនបង្កអំពើហិង្សា។ (៣) ការសិក្សាទៅលើធម្មជាតិ និងមូលហេតុនៃអំពើហិង្សាចំពោះស្ត្រី។ (៤) ការធ្វើឱ្យប្រសើរឡើងនូវឥរិយាបថ និងអាកប្បកិរិយាសង្គម។ ផែនការការងារត្រូវបានអនុម័តសម្រាប់អំឡុងពេលឆ្នាំ២០០៦-២០១០ ក្នុងគោលដៅលើកកម្ពស់នូវភាពស្មើគ្នារវាងស្ត្រី និងបុរស។ ជ្រុងមួយទៀតដែលត្រូវវាយលុក គឺនយោបាយអាស៊ានសម្រាប់ការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ពាក់ព័ន្ធនឹងស្ត្រី និងកុមារ។

## ១.២- កិច្ចសហប្រតិបត្តិការឆ្លងដែន

កិច្ចសហប្រតិបត្តិការឆ្លងដែន ផ្តោតទៅលើបញ្ហាជាអាទិភាពមួយចំនួន ៖ អន្តោប្រវេសន៍ ប៉ុន្តែក៏ផ្តោតផងដែរទៅលើបញ្ហាស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរគ្រឿងញៀន ឧក្រិដ្ឋកម្ម និងអំពើភេរវកម្ម។

### ១.២.១- កិច្ចសហប្រតិបត្តិការផ្នែកអន្តោប្រវេសន៍

កិច្ចសហប្រតិបត្តិការផ្នែកអន្តោប្រវេសន៍បានក្លាយជាភាពចាំបាច់នៅក្នុងទស្សនៈវិស័យនៃការកាត់បន្ថយភាពក្រីក្រ ហើយអាស៊ានបានអនុម័តផែនការសកម្មភាពផ្នែកកិច្ចសហប្រតិបត្តិការក្នុងវិស័យអន្តោប្រវេសន៍ដែរ។ កិច្ចសហប្រតិបត្តិការនេះមានគោលដៅបង្កើត និងពង្រឹងបណ្តាញមួយដែលអនុញ្ញាតឱ្យមានការធ្វើចរាចរណ៍បានកាន់តែប្រសើររបស់បុគ្គល ជាពិសេសសេរីភាពក្នុងការចរាចរកម្លាំងពលកម្មជំនាញនៅក្នុងក្របខ័ណ្ឌនៃសេរីភាវូបនីកម្មសេដ្ឋកិច្ច។ កម្មវិធីសកម្មភាពនេះផ្តោតជាសំខាន់ទៅលើការផ្លាស់ប្តូរព័ត៌មាន សិក្ខាសាលាបណ្តុះបណ្តាល ហើយក៏ផ្តោតទៅលើការជំរុញឱ្យរដ្ឋជាសមាជិកធ្វើការពង្រឹងលិខិតបទដ្ឋានគតិយុត្តជាតិរបស់ខ្លួនផងដែរ។ នៅឆ្នាំ២០០៦ កិច្ចព្រមព្រៀងក្របខ័ណ្ឌមួយត្រូវបានអនុម័តនៅទីក្រុងកូឡាឡាំពួរ។ កិច្ចព្រមព្រៀង



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នេះអនុញ្ញាតឱ្យមានការលើកលែងទិដ្ឋាការ សម្រាប់ពលរដ្ឋអាស៊ានដែលមានបំណងស្នាក់នៅលើដែនដីនៃរដ្ឋជាសមាជិកណាមួយតិចជាងរយៈពេល២សប្តាហ៍។

## ១.២.២- ការប្រយុទ្ធប្រឆាំងនឹងការជួញដូរគ្រឿងញៀន និងអំពើភេរវកម្ម

### ១.២.២.១- ការប្រយុទ្ធប្រឆាំងនឹងការជួញដូរគ្រឿងញៀន

ក្នុងផ្នែកប្រយុទ្ធប្រឆាំងនឹងការជួញដូរគ្រឿងញៀន អាស៊ីអាគ្នេយ៍ត្រូវបានចាត់ទុកថា ជាទីតាំងសំខាន់បំផុតនៃការផលិត ឆ្លងកាត់ និងប្រើប្រាស់គ្រឿងញៀន។ ជាតំបន់មួយដែលមានតំបន់ត្រីកោណមាស។ នេះក៏ជារបៀបមួយសម្រាប់ធ្វើការផ្គត់ផ្គង់ហិរញ្ញវត្ថុទៅឱ្យក្រុមឧទ្ទាមផងដែរ។ ការផលិតគ្រឿងញៀននាំឱ្យមានការជួញដូរដែលនាំឱ្យមានឧក្រិដ្ឋកម្ម ហើយជាបន្ទាប់បន្សំ បង្កើតបានជាបញ្ហាសង្គម។ នៅអាស៊ីអាគ្នេយ៍ ការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀននាំមកនូវការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនានាដែរ។ ក្នុងនាមអាស៊ាន ការប្រយុទ្ធប្រឆាំងគ្រឿងញៀន គឺជាសកម្មភាពចាស់មួយដែលត្រូវផ្តួចផ្តើមដោយសេចក្តីប្រកាសទីក្រុងម៉ានីលក្នុងឆ្នាំ១៩៧៦ដែលចែងពីការគ្រប់គ្រង ហើយនៅអនាគត គឺការលុបបំបាត់ចម្ការដាំដុះដើមអាភៀន និងប្រព្រឹត្តកម្មរុក្ខជាតិទាំងនេះ។ ផែនការសកម្មភាពអាស៊ានត្រូវបានអនុម័ត។ ផែនការសកម្មភាពនេះផ្តល់អាទិភាពឱ្យមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋជាសមាជិក តាមរយៈការបង្កើតកម្មវិធីដែលមានគោលដៅផ្តោតទៅលើការអប់រំបង្ការ ការស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយសារគ្រឿងញៀន។ កិច្ចសហប្រតិបត្តិការនេះមានគោលដៅត្រូវធ្វើឡើងក្នុងរយៈពេលវែង។ សេចក្តីប្រកាសរួមមួយត្រូវបានធ្វើឡើងក្នុងឆ្នាំ១៩៩៨ដែលកំណត់ថា រហូតដល់ឆ្នាំ២០២០ អាស៊ានគឺគ្មានគ្រឿងញៀន។ នៅឆ្នាំ២០០០ គេបានស្តីបន្ទោសទៅលើប្រតិទិនសម្រាប់ឆ្នាំ២០១៥(ក្តីប្រាថ្នាដែលមិនអាចសម្រេចបាន)។ នេះជាសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអាស៊ានបូក៣។ គ្មានការលើកលែងទេ។

សេចក្តីប្រកាសចំនួនពីរ ក្នុងឆ្នាំ១៩៧៦ និង១៩៩០ ចែងពីវិធានការណ៍សហប្រតិបត្តិការក្នុងតំបន់ ប៉ុន្តែក៏មានកិច្ចសហប្រតិបត្តិការជាមួយនឹងការិយាល័យជំនាញអង្គការសហប្រជាជាតិក្នុងកាប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនដែរ។ កម្មវិធីសហប្រតិបត្តិការដទៃទៀតត្រូវបានធ្វើឡើងរវាងអាស៊ាន និងប្រទេសចិនដែលបាននាំឱ្យមានសកម្មភាពរួមគ្នានានា។

### ១.២.២.២- ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន

ទាក់ទងនឹងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន សេចក្តីប្រកាសចំនួនពីរត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៧ និង១៩៩៨ ដើម្បីប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋឆ្លងដែនទាំងនោះ។ នៅក្នុងសេចក្តី

ប្រកាសទីមួយ ឆ្នាំ១៩៩៧ រដ្ឋអាស៊ានទាំងអស់បានសន្យាចាត់វិធានការណ៍ ដើម្បីជានាការសម្រប សម្រួលល្អប្រសើរមួយនៅក្នុងការប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋឆ្លងដែន។ ដើម្បីធ្វើសកម្មភាពទាំងនេះបាន អង្គភាពចំនួន៣ត្រូវបានបង្កើតឡើង ៖ (១) កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ផ្នែកគ្រឿងញៀន (២) កិច្ចប្រជុំប្រមុខនគរបាលជាតិនីមួយៗ(ASEANPOL)ក្នុងនាមរដ្ឋជាសមាជិកអាស៊ាន (៣) ការបង្កើតមជ្ឈមណ្ឌលអាស៊ាន សម្រាប់ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។ សេចក្តីប្រកាសទីពីរ ឆ្នាំ១៩៩៨ បានអះអាងជាថ្មីពីឆន្ទៈរបស់ប្រទេសអាស៊ានក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ប៉ុន្តែក៏ធ្វើកិច្ចសហការផងដែរជាមួយនឹងបណ្តាយន្តការអន្តរជាតិដែលមានរួចស្រាប់នានាពាក់ព័ន្ធនឹងដែនសកម្មភាពដូចជាឧក្រិដ្ឋកម្មសេដ្ឋកិច្ចឆ្លងដែនជាដើម។ បទឧក្រិដ្ឋដែលមានការចាត់តាំងឆ្លងដែន(Le crime organisé transnational-le COT)ជាមួយនឹងផលរបរក្នុងឆ្នាំ ២០០៩ គឺមានទឹកប្រាក់ដល់២០០០លានដុល្លារ។

### ១.២.២.៣- ការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម

អំពីភេរវកម្ម ការលំបាកទីមួយ គឺនិយមន័យរបស់វា។ មហាសន្និបាតអង្គការសហប្រជាជាតិឱ្យនិយមន័យថាជា ៖ «ចេតនាក្នុងការធ្វើឱ្យមានរបួស និងបង្កការស្លាប់ដល់ជនស៊ីវិល»។ ឧទាហរណ៍ដូចជាក្រុមឧទ្ទាម Abou Sayyaf(ប្រភពហិរញ្ញវត្ថុបានមកពីការចាប់ជំរិត) រណសិរ្សរំដោះជាតិអ៊ីស្លាមម្សូរ(le Front moro de libération islamique)។ នៅអាស៊ីអាគ្នេយ៍ ក្រុមភេរវកម្មគឺក្រុម Jemaah Islamiyah នៅប្រទេសឥណ្ឌូនេស៊ី។ ជំរុំហ្វឹកហ្វឺនមានទីតាំងនៅប្រទេសហ្វីលីពីន។ Jemaah Islamiyah មិនបានត្រូវកម្ចាត់ចោលទេ ហើយបានធ្វើការវាយប្រហារនៅបាលីក្នុងឆ្នាំ ២០០២ និង២០០៥ នៅទីក្រុងហ្សាកាតា ឆ្នាំ២០០៩។ មធ្យោបាយទីមួយក្នុងការប្រយុទ្ធប្រឆាំងគឺ ៖ (១) ច្បាប់ (២) ការប្រើប្រាស់ក្រុមស៊ើបការណ៍(ការជ្រៀតខ្លួនចូលទៅក្នុងនៃចលនា) (៣) ការប្រយុទ្ធប្រឆាំងនឹងហិរញ្ញប្បទាន (៤) ការប្រើប្រាស់កម្លាំង(អាចជាកម្លាំងនគរបាល ឬកងទ័ព)។ សកម្មភាពរបស់អាស៊ានក្នុងវិស័យភេរវកម្មត្រូវបានកំណត់នៅក្នុងសេចក្តីប្រកាសរួមឆ្នាំ២០០១ ៖ ពោលគឺកិច្ចសហប្រតិបត្តិការក្នុងផ្នែកប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មដែលឆ្លងកាត់តាមរយៈកិច្ចសហប្រតិបត្តិការគតិយុត្ត និងសុខដុមនីយកម្មនៃច្បាប់ និងមធ្យោបាយក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម។ នីតិជាតិទាំងអស់គឺមានប្រសិទ្ធភាពច្រើនជាងអាស៊ានដែលដើរតួនាទីសម្រប-សម្រួល។ អាជ្ញាធរព័ត៌មានច្បាប់អាស៊ាន(ASEAN Legal Information Authority-ALIA) ទទួលបន្ទុកក្នុងការផ្លាស់ប្តូរព័ត៌មានចាំបាច់នានា។ ទម្រង់មួយទៀតនៃភេរវកម្មគឺសកម្មភាពចោរសមុទ្រ។ គឺសកម្មភាពរបស់រដ្ឋជាសមាជិកនានា និងជាពិសេសកិច្ចព្រមព្រៀងធ្វើឡើងរវាងរដ្ឋនៅតាមមាត់សមុទ្រចំនួន៣នៃដែសមុទ្រមាឡាកា គឺម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងសិង្ហបុរីដែលបានដាក់

ការល្បាតនៅតាមសមុទ្រ។ ប្រទេសនីមួយៗ បានកំណត់តំបន់ពិសេសមួយៗ នៅឆ្នាំ២០០៥ ប្រទេសថៃឡង់ដ៍បានចូលរួមជាមួយរដ្ឋទាំងអស់នោះ ក្នុងការល្បាតតាមអាកាស។ ចាប់តាំងពីឆ្នាំ២០០៥មក សកម្មភាពប្រព្រឹត្តឡើងដោយចោរសមុទ្របានធ្លាក់ចុះយ៉ាងខ្លាំង។ នៅក្នុងឆ្នាំ២០១០ មានសកម្មភាពធ្វើឡើងដោយចោរសមុទ្រតិចជាង៣០ ដោយសារតែមានសកម្មភាពសម្របសម្រួលរវាងគ្នានឹងគ្នានេះ។

## ២. កិច្ចសហប្រតិបត្តិការផ្នែកបរិស្ថាន

បរិស្ថានគឺជាវិស័យដែលមានការអភិវឌ្ឍច្រើន សម្រាប់អាស៊ាន។ អាស៊ីអាគ្នេយ៍មានផ្ទៃក្រឡា៤០០លានគីឡូម៉ែត្រការ៉េ។ ព្រៃឈើតំណាងឱ្យចំនួនពាក់កណ្តាល។ ដើមកោងកាង និងថ្មប៉ប្រះទឹកតំណាងឱ្យចំនួន៣០%នៃដើមកោងកាង និងថ្មប៉ប្រះទឹកនៅជុំវិញពិភពលោក។ បញ្ហាមួយទៀតទាក់ទិននឹងព្រៃឈើ គឺការកាប់ព្រៃឈើដែលជាបញ្ហាចម្បង។ ព្រៃឈើនៅតំបន់អាស៊ីអាគ្នេយ៍គឺជាព្រៃឈើបឋមដែលមានតាំងពីរាប់ពាន់ឆ្នាំមកហើយ និងដែលបានស្រូបយកឧស្ម័នកាបូនិចជាច្រើន។ ព្រៃឈើទាំងនោះមានតែនៅតំបន់អាហ្វ្រិកកណ្តាល និងតំបន់អាម៉ាសូនប៉ុណ្ណោះ។ ដើម្បីធ្វើការដាំដុះប្រេងដូង គេបានកាប់ដើមឈើ។

ប្រទេសសិង្ហបុរីបានលុបបំបាត់ព្រៃឈើជាង៩០% និងពូជសត្វព្រៃជាច្រើនដែលទាំងអស់នេះគឺក្តីបារម្ភក្នុងការការពារបរិស្ថាន។ អាស៊ានបានចូលរួមនៅក្នុងចរន្តនៃការការពារបរិស្ថាននេះ។

### ២.១- ការការពារបរិស្ថាន

ការការពារបរិស្ថានត្រូវស្វែងរកលំនឹងរវាងការការពារបរិស្ថាន និងការអភិវឌ្ឍ។ ក្នុងផ្នែកនេះ អាស៊ានពុំមានប្រពៃណីទេ ប៉ុន្តែអាស៊ានដើរតួនាទីជាអ្នកបង្រួបបង្រួមឯកភាពនយោបាយជាតិទាំងអស់។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ អាស៊ានបានអនុម័តសេចក្តីប្រកាសពីរ និងដំណោះស្រាយមួយដោយបញ្ជាក់អះអាងសារជាថ្មីពីការទទួលយកគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីធ្វើឱ្យលេចចេញជារូបរាងនូវឆន្ទៈល្អនេះ អាស៊ានបានអនុម័តកម្មវិធីបរិស្ថានដែលបានដឹកនាំធ្វើជាពីរលើក។ អាស៊ានបានអភិវឌ្ឍគោលការណ៍តម្រង់ទិសស្តីពីការគ្រប់គ្រងបរិស្ថានល្អ ឬស្តីពីការអភិរក្ស និងការការពារធម្មជាតិ និងបរិស្ថានសមុទ្រ។ សេចក្តីប្រកាសឆ្នាំ១៩៨៧បានពាំនាំជំនួយខ្វះៗទៀត និងបានអះអាងពីគោលការណ៍សុខុមាលភាពរួម។ ការអនុវត្តជាក់ស្តែងនៃដំណោះស្រាយនេះគឺសេចក្តីប្រកាសរបស់បណ្តារដ្ឋក្នុងឆ្នាំ២០០៣ស្តីពីឧទ្យាន និងដែនបម្រុងធម្មជាតិ។ ពាក់ព័ន្ធនឹងផ្នែកបរិស្ថាន នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើកទី១១(AMME)ដែលបានប្រព្រឹត្តទៅនៅប្រទេសសិង្ហបុរី នាខែតុលា ឆ្នាំ២០០៩ អាស៊ានបានរំឭកឡើងថា ការការពារ

បរិស្ថានគឺជាលក្ខខណ្ឌចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ចរយៈពេលវែង និងសម្រាប់ការអភិវឌ្ឍសង្គមរបស់ប្រជាជន។ ចក្ខុវិស័យឆ្នាំ២០២០ គឺសេចក្ដីប្រាថ្នាឱ្យមានបរិស្ថានល្អឥតខ្ចោះមួយ។ ផែនការសកម្មភាពទីក្រុងវៀងច័ន្ទត្រូវបានអនុម័ត សម្រាប់រយៈពេល២០០៤-២០១០។ ការប្រជុំរដ្ឋមន្ត្រីនេះបានរំឭកឡើងវិញពីគោលដៅដែលបានកំណត់ក្នុងឆ្នាំ២០០២ ៖ (១) ការការពារប្រឆាំងនឹងការឆេះព្រៃ និងការបំពុលឆ្លងដែន (២) ការការពារបរិស្ថានសមុទ្រ (៣) ការគ្រប់គ្រងធនធានព្រៃឈើ (៤) ការគ្រប់គ្រងលំហដែលត្រូវការពារ និងឧទ្យានជម្មជាតិ (៥) ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាដែលគោរពបរិស្ថាន និង (៦) ការអភិវឌ្ឍវប្បធម៌បរិស្ថានក្នុងចំណោមប្រជាពលរដ្ឋ។

ចាប់តាំងពីឆ្នាំ១៩៩៧មក មានមជ្ឈមណ្ឌលតំបន់អាស៊ានមួយ សម្រាប់អភិរក្សជីវចម្រុះ។ មជ្ឈមណ្ឌលនេះមានទីតាំងនៅទីក្រុងហ្សាកាតា។ បញ្ហាដ៏ធំមួយនៃការកាប់ព្រៃឈើគឺការបំពុលនៅតាមបណ្ដោយព្រំដែន។ អាស៊ានបានចុះហត្ថលេខាក្នុងឆ្នាំ២០០២នូវកិច្ចព្រមព្រៀងមួយដែលបានចែងពីការព្យាករណ៍ទុកមុន និងការបង្ការការពារបញ្ហានេះ។ ប្រទេសចំនួន៥ដែលទទួលរងផលប៉ះពាល់ជាងគេ(គឺប្រ៊ុយណេ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃឡង់ដ៍ និងសិង្ហបុរី) បានសម្រេចបង្កើតមជ្ឈមណ្ឌលសម្របសម្រួល ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យពីការវិវឌ្ឍទៅនៃបាតុភូតនេះ។ នៅក្នុងកិច្ចប្រជុំក្រុមការងារជំនាញ និងមន្ត្រីជាន់ខ្ពស់លើកទី១១ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ ពួកគេបានបញ្ជាក់អះអាងសារជាថ្មីពីការប្រយុទ្ធប្រឆាំងនឹងការបំពុលឆ្លងដែន។ នេះគឺជាការបង្ហាញពីមនសិការដែលបានអភិវឌ្ឍយ៉ាងឆាប់រហ័ស។ នេះក៏ជាផលវិបាកផ្នែកសុខាភិបាលផងដែរ។ កិច្ចប្រជុំមួយបានប្រព្រឹត្តទៅ ដើម្បីប្រយុទ្ធប្រឆាំងនឹងការបំពុលឆ្លងដែននៅក្នុងតំបន់ទន្លេមេគង្គ។

## ២.២- ការគ្រប់គ្រងគ្រោះមហន្តរាយ

ការគ្រប់គ្រងគ្រោះមហន្តរាយនៅឆ្នាំ២០០៣បាននាំទៅដល់ការបង្កើតកម្មវិធីមួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងគ្រោះមហន្តរាយ(២០០៤-២០១០)។ គោលដៅគឺដើម្បីពង្រឹងក្របខ័ណ្ឌជាតិ និងសមត្ថភាពអន្តរាគមន៍របស់រដ្ឋជាសមាជិក ការបែងចែកព័ត៌មាន ការសហការរវាងរដ្ឋជាសមាជិក និងវេទយិតកម្មសាធារណជន ចំពោះបាតុភូតនេះ។ កម្មវិធីនេះមានសកម្មភាពគោលចំនួន២ប្រភេទ ៖ (១) បញ្ហាគឺការសហការឆ្លងព្រំដែន (២) ការគាំទ្រថ្នាក់តំបន់ចំពោះសកម្មភាពជាតិ។ ហិរញ្ញប្បទាននៃកម្មវិធីនេះគឺត្រូវបានធានាទាំងស្រុងដោយដៃគូខាងក្រៅ។

ការវាយប្រហារដោយរលកយក្សស៊ូណាមិ នាខែធ្នូ ឆ្នាំ២០០៤ បានបង្ហាញឱ្យឃើញពីភាពទន់ខ្សោយនៃក្របខ័ណ្ឌអន្តរាគមន៍របស់អាស៊ាន។ ដើម្បីដោះស្រាយនូវភាពទន់ខ្សោយនេះ កិច្ច

ព្រមព្រៀងស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការអន្តរាគមន៍បន្ទាន់ ត្រូវបានចុះហត្ថលេខា នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៥ នៅទីក្រុងវៀងច័ន្ទ ៖ គោលការណ៍ចំនួនពីរ ដឹកនាំយន្តការអន្តរាគមន៍នេះ ៖ (១) ក្នុងករណីមានកិច្ចអន្តរាគមន៍បន្ទាន់ រដ្ឋជាសមាជិកទាំងអស់ត្រូវគោរពដែនអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់រដ្ឋរងគ្រោះ ហើយដើម្បីធ្វើប្រតិបត្តិការនេះបាន រដ្ឋរងគ្រោះត្រូវផ្តើមសកម្មភាពមុន ហើយរដ្ឋជាសមាជិកដទៃទៀតអាចនឹងធ្វើអន្តរាគមន៍បាន លុះត្រាតែមានការស្នើសុំពីរដ្ឋរងគ្រោះ(មាត្រា៣-១នៃកិច្ចព្រមព្រៀង) (២) គោលការណ៍ទីពីរ ៖ រដ្ឋមានកាតព្វកិច្ចចាត់វិធានការបង្ការ ធ្វើអត្តសញ្ញាណកម្ម វាយតម្លៃ និងឃ្លាំមើលពីសក្តានុពលនៃហានិភ័យរបស់គ្រោះមហន្តរាយនៅលើទឹកដីរៀងៗខ្លួន(មាត្រា៣-២នៃកិច្ចព្រមព្រៀង)។ អង្គភាពដែលមានសមត្ថកិច្ចរបស់អាស៊ាន គឺកិច្ចប្រជុំរដ្ឋមន្ត្រីស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (*AMMDM*)។

# ជំពូក៨

# នីតិអង្គការពាណិជ្ជកម្មពិភពលោក

**នីតិស្ថាប័ននៃអង្គការពាណិជ្ជកម្មពិភពលោក**

*អង្គការនេះចាប់បដិសន្ធិឡើងតាមកិច្ចព្រមព្រៀងម៉ារ៉ាកិច(Marrakech) ចុះថ្ងៃទី១៥ មេសា ១៩៩៤ បន្ទាប់ពីវគ្គនៃកិច្ចប្រជុំនៅអ៊ុយរុយហ្គេ(Cycle de Uruguay)។ ជាមួយអង្គការពាណិជ្ជកម្មពិភពលោក វិធានសាវ័ន្តដែលគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ ដើម្បីបង្កើតប្រព័ន្ធពាណិជ្ជកម្មពហុភាគីត្រូវបានបង្កើតឡើង។*

*អង្គការបង្កើតឱ្យមាន (១) ប្រព័ន្ធដែលមានស្រាប់គឺកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) (២) នវភាព និង (៣) វិធានការផ្សេងៗទៀតផងដែរ។*

*អង្គការនេះពុំមានកម្មវត្ថុគ្រប់គ្រងពិភពលោកទេ។ អង្គការនេះចូលរួមក្នុងអភិបាលកិច្ចពិភពលោក និងមានវិសាលភាពលើសពីដែនវង្វង់សេដ្ឋកិច្ច និងពាណិជ្ជកម្មទៅទៀត។ អង្គការដើរតួនាទីចម្បងនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ អង្គការនេះមានគោលដៅទៅលើបញ្ហាសេដ្ឋកិច្ច និងពាណិជ្ជកម្ម។*

# ផ្នែកទី១

# រចនាសម្ព័ន្ធគតិយុត្ត និងស្ថាប័នអង្គការពាណិជ្ជកម្មពិភពលោក

**១- រំឭកសាវតា ៖ កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម**

*កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មគ្រាន់តែជាសន្ធិសញ្ញាមួយ ហើយពុំធ្លាប់ជាអង្គការអន្តរជាតិឡើយ។ ប៉ុន្តែ កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មត្រូវបានធ្វើស្ថាប័នកម្មបន្តិចម្ដងៗ។ រដ្ឋទាំងអស់ឯកភាពបង្កើតវិធានពាណិជ្ជកម្មពហុភាគីដែលបានទទួលទម្រង់ជាកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម។*

*កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មត្រូវបានចុះហត្ថលេខានាឆ្នាំ១៩៤៧*


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដោយរដ្ឋហត្ថលេខីចំនួន២៣ដែលជាគូភាគីកិច្ចសន្យា។ ប៉ុន្តែ ចំនួនរដ្ឋហត្ថលេខីបានឈានដល់ ១២៣នាឆ្នាំ១៩៩៤។

សមាជិករបស់អង្គការមានចំនួន១៦៤រដ្ឋ(ប្រទេសកម្ពុជាចូលជាសមាជិកនាឆ្នាំ២០០៤)។ រដ្ឋចុងក្រោយ គឺអាហ្វហ្គានីស្ថានកាលពីឆ្នាំ២០១៦។

ដែនអនុវត្តរបស់កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម ៖ កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មផ្ដោតទៅលើពាណិជ្ជកម្មទំនិញប៉ុណ្ណោះ។

ដែនអនុវត្តរបស់អង្គការពាណិជ្ជកម្មពិភពលោក ៖ ទំនិញ សេវាកម្ម ច្បាប់កម្មសិទ្ធិបញ្ញា។

## ១.១- អង្គភាពមុនៗរបស់កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម

ក្រោយវិបត្តិឆ្នាំ១៩២៩ គំនិតដឹកនាំល្អផ្នែកពាណិជ្ជកម្មអន្តរជាតិបានប្រាកដឡើង។ ការអនុវត្តប្រព័ន្ធពាណិជ្ជកម្មសេរីលំដាប់ពិភពលោកត្រូវរង់ចាំរហូតដល់ក្រោយសង្គ្រាមលោកលើកទី២។ ប្រព័ន្ធនេះត្រូវបានដាក់អនុវត្ត មានដូចជា (១) អង្គការពាណិជ្ជកម្មអន្តរជាតិសម្រាប់ពាណិជ្ជកម្ម (OIC) (២) អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (FMI) និង (៣) ធនាគារពិភពលោកសម្រាប់បញ្ហាហិរញ្ញវត្ថុ។ អង្គការពាណិជ្ជកម្មអន្តរជាតិពុំដែលកកើតជារូបរាងឡើយ និងត្រូវបានជំនួសដោយកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ។

## ១.២- និរន្តភាពរបស់កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយនិងពាណិជ្ជកម្ម និងការអភិវឌ្ឍរបស់វា

ដើមកំណើតកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មមានលក្ខណៈបណ្ដោះអាសន្ន ៖ វាមានផលវិបាកចំនួនពីរ គឺ (១) គេពុំបានគ្រោងជាមុននូវរចនាសម្ព័ន្ធស្ថាប័នពិតប្រាកដទេ (២) វិធានដ៏ទន់ភ្លន់បត់បែនបានរបស់កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម។ គំនិតនេះគឺបង្កើតនូវប្រព័ន្ធពហុភាគី ប៉ុន្តែពុំមែនបន្ទាចរដ្ឋទាំងអស់ឡើយ ដោយធានាឱ្យបាននូវអធិបតេយ្យភាព។ វិធានអន្តរកាល ពោលគឺរដ្ឋទាំងអស់អាចរក្សាវិធានពាណិជ្ជកម្មដែលមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មបាន។ វិធានបុរេគតអាចមានវិសមិតភាព ប៉ុន្តែវិធានបច្ឆាគតត្រូវមានសមិតភាពដើម្បីលើកទឹកចិត្តដល់រដ្ឋទាំងអស់ឱ្យផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម។

ដូចគ្នាទៅនឹងអង្គការពាណិជ្ជកម្មពិភពលោកដែរ កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មគឺជាវេទិកាចរចាអចិន្ត្រៃយ៍។ ជារៀងរាល់ថ្ងៃ រដ្ឋទាំងអស់ចរចាជាសារវន្តលើរឿងពីរប្រភេទគឺ (១) វិធានទូទៅសម្រាប់គ្រប់គ្រងទៅលើបណ្ដូរពាណិជ្ជកម្ម(ទិដ្ឋភាពអរូបីបំផុត)

(២) ការចរចាទៅលើពន្ធគយ(ឧបសគ្គដល់ពាណិជ្ជកម្ម) របាំងពុំមែនពន្ធ(រូបីខ្លាំង) បទដ្ឋានបច្ចេកទេស និងអនាម័យ។

ការចរចាទាំងអស់អាចប្រើពេលយូរ ដូចជាទៅលើការបើកទីផ្សារ និងវិធានរួម។ រាល់ខួបទាំងអស់ត្រូវបន្តវេនគ្នា ដើម្បីបង្កើតវិធានរួម និងរបាំងពន្ធ និងពុំមែនពន្ធសម្រាប់ការបើកទីផ្សារ។

អត្ថប្រយោជន៍នៃប្រព័ន្ធសកលគឺវិធានគ្រប់គ្រងប្រព័ន្ធសកល ឯគុណវិបត្តិវិញគឺប្រើរយៈពេលយូរ។ ការចរចាទាំងអស់ត្រូវមានប្រទេសពី២០ទៅ៣០ ដើម្បីឈានដល់ការព្រមព្រៀងមួយទៅលើបណ្តុំបញ្ហា។

ខួបដំបូងរបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មផ្តោតសុទ្ធសាធទៅលើវិស័យពន្ធគយ និងទៅលើផលិតផលកម្មន្តសាល។ ចាប់ពីឆ្នាំ១៩៥៥មក វិស័យកសិកម្មត្រូវបានដកចេញពីកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មដោយសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប។ ការភ័យខ្លាចគឺការខ្វះខាត។ រដ្ឋទាំងអស់ត្រូវជានាសុវត្ថិភាពស្បៀងក្រោយសង្គ្រាម។ ប្រទេសកំពុងអភិវឌ្ឍចាប់អារម្មណ៍ទៅលើកសិកម្ម។ ខួបចរចានៅដូហា(Cycle de Doha)បានធ្វើឱ្យរាំងស្ទះដានិច្ចដល់បញ្ហាកសិកម្ម។ វឌ្ឍនកិច្ចពិបាកនឹងទទួលបានណាស់។

ខួបទី១គឺខួបហ្សឺណែវដែលប្រព្រឹត្តទៅពីខែមេសាដល់ខែតុលា ១៩៤៧ និងបន្តដោយខួបអាន់ស៊ី(Cycle de Annecy)នាឆ្នាំ១៩៤៩ ខួបតគេ(Torquay)នៅឆ្នាំ១៩៥១ និង១៩៥២(រដ្ឋកាន់តែច្រើនរអាពុំហ៊ានទៅកាន់តែឆ្ងាយ)។

ខួបឌីឡុង(Cycle Dillon)នាឆ្នាំ១៩៦១ដល់ឆ្នាំ១៩៦២មានសារៈសំខាន់ ព្រោះថាមានការប្តូរវិធីចរចា។ មុនខួបឌីឡុង ពហុភាគីនិយមប្រព្រឹត្តទៅតាមឋានៈប្រជាជាតិទទួលការអនុគ្រោះខ្លាំងបំផុត។ លទ្ធផលនៃការចរចាពហុភាគី(ការបញ្ចុះពន្ធគយជាថ្នូរនឹងការបញ្ចុះពន្ធគយរបស់រដ្ឋមួយទៀត)ត្រូវបានលាតសន្ធឹងរហូតដល់រដ្ឋឯទៀតៗតាមរយៈឋានៈប្រជាជាតិទទួលការអនុគ្រោះខ្លាំងបំផុត។ វិធីនេះជាវិធីដែលគោរពអធិបតេយ្យភាពជាងគេ ប៉ុន្តែមានរយៈពេលយូរ។ គេធ្វើការចរចាលើផលិតផលម្តងមួយៗ។

ចាប់ពីខួបឌីឡុងទៅ វិធីខ្សែបណ្តោយត្រូវបានបញ្ចូល នោះគឺការបញ្ចុះភាគរយទៅលើពន្ធគយ(ការបញ្ចុះជាបន្តបន្ទាប់ចំនួន៥%ទៅលើពន្ធគយ)។

• វិធីខ្សែបណ្តោយពុំអនុវត្តទៅលើផលិតផលទាំងអស់ទេ ដូចជាទៅលើផលិតផលរសើប (ស្រូវ) ដើម្បីការពារអធិបតេយ្យភាពរបស់រដ្ឋ។

• គុណវិបត្តិមួយទៀត វិធីខ្សែបណ្តោយពុំបានដោះស្រាយបញ្ហាតម្លៃខ្ពស់ខ្លាំងទេ(៣០០% ទៅលើស្ករសម្រាប់ប្រេស៊ីល)។ រដ្ឋទាំងអស់នឹងយកពន្ធខ្លាំងទៅលើការនាំចូល។ វិធីខ្សែបណ្តោយពុំអាចបញ្ចុះពន្ធគយខ្ពស់ខ្លាំងឡើយ(បញ្ចុះ៥%ក្នុង៣០០% ស្មើនឹង២៩៥%ដូចពុំមានការបញ្ចុះ

អ៊ីចិន)។

មុននឹងក្លាយជាសមាជិកកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម រដ្ឋទាំងអស់នឹងបង្កើនពន្ធគយ។ រដ្ឋសមាជិកថ្មីរបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មបានបង្កើនពន្ធគយ ហើយខួបដំបូងៗពុំបានផ្តល់សេរីភាវូបនីយកម្មទេ។

ផ្ទុយមកវិញ មុននឹងចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក រដ្ឋទាំងអស់ត្រូវបញ្ចុះពន្ធគយដើម្បីឱ្យមានលំនឹងដូចគ្នានឹងរដ្ឋដែលបានធ្វើសេរីភាវូបនីយកម្មអស់រយៈពេល៣០ទៅ៤០ឆ្នាំ។ ប្រសិនបើរដ្ឋបដិសេធ គេនឹងច្រានការអនុវត្តនោះចោល។

ខួបឃែននីឌី(Cycle Kennedy)១៩៦៣-១៩៦៧ នឹងសម្រេចចេញជាការអភិវឌ្ឍចម្បងដូចជាបរិបទសេដ្ឋកិច្ចអនុគ្រោះ ការអភិវឌ្ឍផ្នែកពន្ធគយ និងមិនមែនពន្ធគយដើមដំបូងនៃការប្រកួតប្រជែងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប ការកើនអំណាចរបស់សហគមន៍អឺរ៉ុប និងការប្តូរនយោបាយសេដ្ឋកិច្ចរបស់អាមេរិក(ចក្ខុវិស័យដណ្តើមទីផ្សារបរទេស) ការបញ្ចុះតម្លៃចំនួន៣៥%ទៅលើផលិតផលកម្មន្តសាល និងរបាំងមិនមែនពន្ធ។ ប្រទេសកំពុងអភិវឌ្ឍទាំងអស់នឹងទទួលផល និងនៅចំណុះវិន័យធូរជាងរដ្ឋដទៃៗទៀត។ ចាប់ពីមានកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មមក ការរឹតត្បិតផ្នែកបរិមាណត្រូវបានហាមប្រាមដែលមកដល់ត្រឹមនោះបង្កជាឧបសគ្គដល់ពាណិជ្ជកម្មទាំងអស់។

ក្នុងផ្នែកទី៤របស់កិច្ចព្រមព្រៀងទូទៅស្តីពីតម្លៃពន្ធគយ និងពាណិជ្ជកម្ម សន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងអភិវឌ្ឍន៍គឺជាបន្ទុកមួយដ៏ធ្ងន់ទៅលើកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម។ នាសម័យនោះ រដ្ឋកំពុងអភិវឌ្ឍទាំងអស់ការពារនយោបាយដូចគ្នា។ គ្រប់ប្រទេសកំពុងអភិវឌ្ឍមានរណសិរ្សរួបរួមសម្រាប់ប្រទេសអភិវឌ្ឍ ព្រោះថា ប្រទេសទាំងនោះមានលក្ខណៈដូចគ្នា។

ខួបតូក្យូ(Cycle de Tokyo) ពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៩ ផ្តោតទៅលើពន្ធគយ និងមិនមែនពន្ធគយ ប៉ុន្តែនៅក្នុងបរិបទដើរថយក្រោយ និងគាំពារនិយមទេ។ ការផុសឡើងរបស់ប្រទេសជប៉ុនក្នុងវិស័យពាណិជ្ជកម្មបានធ្វើឱ្យការចរចាលំបាក។ កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មបានចាប់ផ្តើមរាប់គិតភាគីជាប់កិច្ចសន្យាទាំងអស់ដែលមានប្រភពពីប្រទេសកំពុងអភិវឌ្ឍ។ ជាលទ្ធផល គេឃើញមាន ៖

(១) ការបញ្ចុះពន្ធគយចំនួន៣៤%ជាលើកដំបូង។ តម្លៃខ្ពស់ខ្លាំងមួយចំនួនបានចាប់ផ្តើមចុះ។

(២) ខួបតូក្យូបានអនុម័តក្រមទាំងអស់ដែលនឹងកំហិតវិន័យទៅលើឧបត្ថម្ភធន និងការប្រឆាំងនឹងការទម្លាក់ថ្លៃ(anti-dumping) តាមការជ្រើសរើស និងបន្ទំ។ រដ្ឋតិចណាស់ព្រមចូល


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាសមាជិកក្រុមទាំងនេះ។

(៣) ការអភិវឌ្ឍថ្មីរបស់ប្រទេសកំពុងអភិវឌ្ឍទៅលើប្រព្រឹត្តកម្មអនុគ្រោះ តាមរយៈជំនួយបច្ចេកទេសដែលផ្តល់ជូនប្រទេសកំពុងអភិវឌ្ឍ។

នាចុងបញ្ចប់នៃវគ្គ ប្រព័ន្ធពហុភាគីចាកចេញពីវគ្គទន់ខ្សោយ នោះគឺកំណត់ប្រព័ន្ធពហុភាគីតាមរយៈក្រុមទាំងនេះ។ វិធានទាំងអស់ត្រូវបានអនុវត្តទៅលើប្រទេសមួយចំនួន។ ប៉ុន្តែ ការបញ្ចុះពន្ធគយខ្ពស់ខ្លាំងគឺជាលទ្ធផលសំខាន់មួយ។ រដ្ឋទាំងអស់នឹងបង្កើតរបាំងមិនមែនពន្ធ ដើម្បីការពារទីផ្សាររបស់ខ្លួន។

មានវិស័យមួយដែលមានប្រភពពីកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម នោះគឺវាយនភណ្ឌទាំងអស់នឹងចាកចេញពីកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ(AMF)ដែលជាការឯកភាពមួយដែលក្នុងនោះប្រទេសកំពុងអភិវឌ្ឍយល់ព្រមកំហិតការនាំចេញវាយនភណ្ឌទៅកាន់ប្រទេសអភិវឌ្ឍ ហើយមានរយៈពេល៤ឆ្នាំ ប៉ុន្តែបន្តរហូតដល់ទីបញ្ចប់របស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម។ នេះគឺធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធពហុភាគីនិយម។

ឈានចេញពីគំនិតបង្ហាញសារជាថ្មីនូវវគ្គអ៊ុយរុយហ្គេថ្មី(១៩៨៦-១៩៩៤) យើងឃើញមានប្រទេសចំនួន១១៤។ វិស័យកសិកម្ម និងវិស័យថ្មីៗ ដូចជាកម្មសិទ្ធិបញ្ញា សេវាកម្ម ក៏ជាបានអូសបន្លាយការចរចា។ ដំណើរគាំងត្រង់ផ្នែកដោយឡែកណាមួយពាំងដល់ការចរចាទាំងមូល។ ទោះយ៉ាងនេះក្តី គេបានឈានដល់ការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។

## ១.៣- ការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក

រយៈពេលជិត៩០ឆ្នាំ អង្គការពាណិជ្ជកម្មពិភពលោកផ្តល់ជាសញ្ញាស្ថាប័ននៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលជាប្រព័ន្ធមួយដែល(១)មានប្រសិទ្ធភាព (២) មានលក្ខណៈគតិយុត្តខ្លាំង គួបផ្សំនឹងវិធានចាប់បង្ខំជាងមុន និង(៣) ជាយន្តការដោះស្រាយអធិករណ៍មានប្រសិទ្ធភាព។

## ១.៣.១- និរន្តរភាព និងភាពខុសគ្នារវាងកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម និងអង្គការពាណិជ្ជកម្មពិភពលោក

### ១.៣.១.១- អង្គការពាណិជ្ជកម្មពិភពលោកគឺជាអង្គការអន្តរជាតិពិតប្រាកដ

អង្គការពាណិជ្ជកម្មពិភពលោកមានបេសកកម្មធំៗបីគឺ (១) ធ្វើឱ្យរដ្ឋទាំងអស់អនុវត្តគ្រប់កិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក (២) ពិនិត្យជាប្រចាំទៅលើនយោបាយពាណិជ្ជកម្មរបស់រដ្ឋសមាជិក(បង្កើតបញ្ជីសារពើភ័ណ្ឌនយោបាយ) (៣) ដោះស្រាយអធិករណ៍រវាងរដ្ឋសមាជិក។ ប្រសិនបើពុំមានទណ្ឌកម្ម ប្រព័ន្ធនេះពុំដើរទេ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មមានចំនួនបីគឺ (១) កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មនាឆ្នាំ១៩៤៧(អត្ថបទអនុវត្តសម្រាប់ពាណិជ្ជកម្មទំនិញ) (២) កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មនាឆ្នាំ១៩៩៤(អត្ថបទដែលចែងពីវិធានពាណិជ្ជកម្មទំនិញក្នុងអង្គការពាណិជ្ជកម្មពិភពលោក) (៣) ប្រព័ន្ធនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មនាឆ្នាំ១៩៤៧(ប្រព័ន្ធពហុភាគី)។

កម្មវត្ថុកំពូលរបស់អង្គការពាណិជ្ជកម្មពិភពលោក គឺ (១) កែលម្អ និងលើកតម្កើងកម្រិតជីវភាព (២) ការអភិវឌ្ឍរបស់រដ្ឋជាសមាជិក។ ពាណិជ្ជកម្មសេរីគឺជាមធ្យោបាយអភិវឌ្ឍ។

អង្គការនេះនៅជាអង្គការតូចមួយនៅឡើយដែលមានមន្ត្រីបម្រើការពី៨០០ទៅ១០០០រូប។ អង្គការនេះប្រើសេដ្ឋកិច្ចវិទូប្រមាណជា២០០នាក់ និងអ្នកច្បាប់ប្រមាណ២០០នាក់។

អង្គការពាណិជ្ជកម្មពិភពលោកគឺជាអង្គការអន្តរជាតិពិតប្រាកដនៅក្នុងច្បាប់ពាណិជ្ជកម្មអន្តរជាតិ ព្រោះមាន (១) បុគ្គលភាពគតិយុត្ត (២) បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិការទូត (៣) កិច្ចព្រមព្រៀងអាសនៈ និងភាពឯករាជ្យពីសមាជិក (៤) ថវិកាផ្ទាល់ខ្លួនដែលផ្តល់ដោយរដ្ឋសមាជិក។

លក្ខណៈពិសេសរបស់អង្គការពាណិជ្ជកម្មពិភពលោកមួយទៀតគឺរក្សាទំនាក់ទំនងដែលពេលខ្លះមានលក្ខណៈស្និទ្ធជាមួយនឹងអង្គការអន្តរជាតិមួយចំនួន ពិសេសជាមួយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក(កិច្ចព្រមព្រៀងឆ្នាំ១៩៩៦-១៩៩៧(អង្គការសុខភាពពិភពលោក អង្គការយូណេស្កូ))។ ការញែករវាងការសម្របសម្រួល(ដើមដំបូងគឺដើម្បីបញ្ចៀសវិវាទ និងភាពមិនស៊ីចង្វាក់គ្នាក្នុងសកម្មភាពដែលកំពុងធ្វើ ការបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់) និងកិច្ចសហប្រតិបត្តិការនាពេលបច្ចុប្បន្ន(ចំណងត្រូវបានរឹត ការបន្តអនុវត្តនយោបាយរួមគ្នាដឹកនាំសកម្មភាពរួមក្នុងក្របខ័ណ្ឌកម្មវិធី)។ ពីរបីឆ្នាំមកនេះ អង្គការបានអភិវឌ្ឍទៅមុខនូវជំនួយសម្រាប់ពាណិជ្ជកម្ម(APC)ដែលជាកិច្ចសហប្រតិបត្តិការរួមជាមួយមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ និងធនាគារពិភពលោកដើម្បីផ្តល់ជំនួយដល់រដ្ឋសមាជិកមួយចំនួន ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់ពាណិជ្ជកម្ម(ការសាងសង់ផ្លូវថ្នល់អាកាសយានដ្ឋាន)។

អង្គការពាណិជ្ជកម្មពិភពលោកមានកម្រិតស្ថាប័នអប្បបរមានិយម ប៉ុន្តែមានលក្ខណៈអភិវឌ្ឍខ្លាំងពាក់ព័ន្ធនឹងធម្មនិយាមសំខាន់ៗ។

កិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក - ធម្មនុញ្ញបង្កើតអង្គការ និងបណ្តុំនៃឧបសម្ព័ន្ធបច្ចេកទេស និងវិធានដែលចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋសមាជិក។

ការកាត់ផ្តាច់រវាងកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម និងអង្គការពាណិជ្ជកម្មពិភពលោក។

### ១.៣.១.២- មត៌ករបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម និងអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម

*កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មបានរលត់បាត់នៅថ្ងៃទី៣១ ធ្នូ ១៩៩៤ ដោយសាររដ្ឋសមាជិកចូលជាសមាជិកក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ ប៉ុន្តែ កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៤៧នៅរស់រានទន្ទឹមនឹងអង្គការពាណិជ្ជកម្មពិភពលោក។ គំនិតរបស់អ្នកចរចាគឺជានានិរន្តរភាពរវាងកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម និងអង្គការពាណិជ្ជកម្មពិភពលោក។ មាត្រា២៦នៃកិច្ចព្រមព្រៀងដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោកចែងថា សមាជិកអង្គការពាណិជ្ជកម្មពិភពលោកត្រូវដឹកនាំដោយអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម។ វិធីធ្វើសេចក្តីសម្រេចជាកុងសង់ស៊ីសរបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មនឹងយកមកប្រើឡើងវិញក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក។*

*ភាពខុសគ្នារវាងកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម និងអង្គការពាណិជ្ជកម្មពិភពលោកពាក់ព័ន្ធនឹងការដោះស្រាយអធិករណ៍។ អង្គការពាណិជ្ជកម្មពិភពលោកមានភាពបែបបទនិយមគតិយុត្តកាន់តែច្រើន និងវិន័យកាន់តែច្រើន។*

### ១.៣.២- រចនាសម្ព័ន្ធគតិយុត្តរបស់អង្គការពាណិជ្ជកម្មពិភពលោក

*កិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកមាន ៖ ធម្មនុញ្ញបង្កើតអង្គការពាណិជ្ជកម្មពិភពលោក(ឯកសារខ្ចីល្មម មាន១៦មាត្រា) និងឧបសម្ព័ន្ធបច្ចេកទេស៤ដែលបង្កើតកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក(វិធានសំខាន់ៗនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីដូចជាសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក)។ បញ្ជីសម្បទានតម្លៃជាតិ និងការសន្យារបស់រដ្ឋ។ ឧបសម្ព័ន្ធទាំង៤គឺជាអាយុជីវិតរបស់អង្គការពាណិជ្ជកម្មពិភពលោក។*

*ឧបសម្ព័ន្ធទី១គឺកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី។ រដ្ឋដែលត្រូវក្លាយជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកត្រូវនៅក្នុងចំណុះវិធានទាំងនេះ។ អង្គការពាណិជ្ជកម្មពិភពលោកត្រូវដឹកនាំដោយគោលការណ៍ឯកភាពតែមួយ។ ឧបសម្ព័ន្ធទី១មាន៣ផ្នែក។*

*ផ្នែកទី១កគឺសម្រាប់ពាណិជ្ជកម្មទំនិញ ដូចជា (១) កិច្ចព្រមព្រៀងទូទៅរបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ (២) កិច្ចព្រមព្រៀងពិសេស មានកិច្ចព្រមព្រៀងប្រឆាំងនឹងដាំភីង កិច្ចព្រមព្រៀងឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ(SMC) កិច្ចព្រមព្រៀងស្តីពីការការពារ(លើកលែងវិធានរបស់ប្រព័ន្ធចេញ) កិច្ចព្រមព្រៀងស្តីពីឧបសគ្គបច្ចេកទេសចំពោះពាណិជ្ជកម្ម(OCT) កិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ(SPS)។ គេក៏មានកិច្ចព្រមព្រៀង*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កសិកម្មមួយផងដែរ(១៩៩៥)។

វិធានបុរាណនៃទីតិពាណិជ្ជកម្មអន្តរជាតិគឺកិច្ចព្រមព្រៀងពិសេសមានអានុភាពទៅលើកិច្ចព្រមព្រៀងទូទៅ។ យោងតាមអង្គភាព បណ្តឹងឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក ពុំមានវិវាទរវាងកិច្ចព្រមព្រៀងទេ គឺមានតែការអនុវត្តរួម។

សំណុំរឿងឆ្នាំ១៩៩៧ គឺជាសំណុំរឿងផ្ទៃដូងរបស់សីស៊ែល(Seychelles)។ ក្នុងនោះ មានការអនុវត្តរួមរវាងកិច្ចព្រមព្រៀងរបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤(កិច្ចព្រមព្រៀងទូទៅ) និងកិច្ចព្រមព្រៀងពិសេសសម្រាប់ករណីនេះ។

ក្នុងសំណុំរឿងស្តីពីអ័រម៉ូន ក៏មានការអនុវត្តរួមរវាងកិច្ចព្រមព្រៀងរបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្មឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ។ កិច្ចព្រមព្រៀងពិសេសបំពេញបន្ថែមលើកិច្ចព្រមព្រៀងទូទៅ។

ផ្នែកទី២របស់ឧបសម្ព័ន្ធ១ ចំណុច១ខផ្តោតទៅលើវិស័យថ្មី នោះគឺកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម(AGCS ឬGATS)។

ផ្នែកទី៣ ចំណុច១គផ្តោតទៅលើកម្មសិទ្ធិបញ្ញា នោះគឺកិច្ចព្រមព្រៀងស្តីពីការការពារច្បាប់កម្មសិទ្ធិបញ្ញាដែលទាក់ទិននឹងពាណិជ្ជកម្ម(ADPIC ឬTRIPS) សលាកប័ត្រអាជ្ញាប័ណ្ណ-ល-។

ឧបសម្ព័ន្ធ២ សំដៅលើអនុស្សរណៈនៃកិច្ចព្រមព្រៀងស្តីពីការដោះស្រាយអធិករណ៍។ អនុស្សរណៈនេះនឹងយកមកអនុវត្តទៅលើកិច្ចព្រមព្រៀងដែលអង្គការពាណិជ្ជកម្មពិភពលោកបានគ្រោង។

ឧបសម្ព័ន្ធ៣ សំដៅលើយន្តការពិនិត្យនយោបាយពាណិជ្ជកម្ម(MEPC) ៖(១) កម្មវត្ថុគឺតម្លាភាពនយោបាយពាណិជ្ជកម្មរបស់រដ្ឋសមាជិក និង (២) យន្តការបង្ការដែលជួយស្វែងរកការលំបាករបស់សមាជិកក្នុងការអនុវត្តកិច្ចព្រមព្រៀងមួយ។

ឧបសម្ព័ន្ធ៤ សំដៅលើកិច្ចព្រមព្រៀងពហុភាគី។ នេះគឺជាកិច្ចព្រមព្រៀងតាមការជ្រើសរើសមានដូចជាកិច្ចព្រមព្រៀងលើលទ្ធកម្មសាធារណៈ(AMP;៤០) និងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មអាកាសយានស៊ីវិល(សមាជិក៣២រដ្ឋ)។

## ១.៤- រចនាសម្ព័ន្ធស្ថាប័នរបស់អង្គការពាណិជ្ជកម្មពិភពលោក

កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មពុំមែនជាអង្គការអន្តរជាតិទេ។ នៅក្នុងកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម គេឃើញមានអង្គភាពអចិន្ត្រៃយ៍មួយចំនួនដូចជា សន្និសីទពេញអង្គដែលប្រើឈ្មោះជាភាគីជាប់កិច្ចសន្យា ក្រុមប្រឹក្សាតំណាង(អង្គភាពពេញអង្គ)ដែលទទួលបន្ទុកជានាដំណើរប្រព្រឹត្តទៅរបស់អង្គការ លេខាធិការដ្ឋាន និងអគ្គនាយក


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ម្នាក់។

អង្គការពាណិជ្ជកម្មពិភពលោកបានប្រើប្រាស់ឡើងវិញនូវរចនាសម្ព័ន្ធដែលគេឃើញមានក្នុងកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម នោះគឺរចនាសម្ព័ន្ធស្ថាប័ន ដូចជា (១) សន្និសីទថ្នាក់រដ្ឋមន្ត្រី (២) អគ្គក្រុមប្រឹក្សាអមដោយក្រុមប្រឹក្សាតាមវិស័យ ព្រមទាំងអង្គភាពដោះស្រាយអធិករណ៍ និងអង្គភាពពិនិត្យនយោបាយពាណិជ្ជកម្ម (៣) លេខាធិការដ្ឋានមួយ និងអគ្គនាយកម្នាក់។

## ១.៤.១- សន្និសីទថ្នាក់រដ្ឋមន្ត្រី

សន្និសីទថ្នាក់រដ្ឋមន្ត្រីឋិតនៅលំដាប់កំពូលរបស់អង្គការ ក្រោមការចូលរួមពីតំណាងរបស់រដ្ឋសមាជិកទាំងអស់(១៥៣)។ សន្និសីទនេះពុំមែនជាអង្គភាពអចិន្ត្រៃយ៍ទេ ហើយធ្វើការជួបប្រជុំគ្នារៀងរាល់ពីរឆ្នាំម្ដង។ សន្និសីទនេះមានតួនាទី (១) ផ្ដល់កម្លាំងជំរុញថាមភាពដល់អង្គការដោយញ៉ាំងឱ្យមានការដ្ឋានថ្មីៗ (២) ធ្វើសុពលកម្មលើលទ្ធផលចរចា នៅក្នុងសន្និសីទចំនួន៧លើកជាដើម។

សន្និសីទទី១ប្រព្រឹត្តទៅនៅប្រទេសសិង្ហបុរីនាឆ្នាំ១៩៩៦។ សន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី២ប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវឆ្នាំ១៩៩៨ ដើម្បីប្រារព្ធខួបកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មលើកទី៥០។ សន្និសីទទី៣ប្រព្រឹត្តទៅនៅសៀថល(Seattle) នាឆ្នាំ១៩៩៩(រួមទាំងចលនាដ៏ខ្លាំងក្លារបស់សង្គមស៊ីវិល)។ រាល់ការប្រឹងប្រែងទាំងអស់ត្រូវបានលើកទៅធ្វើនៅក្នុងសន្និសីទលើកទី៤នៅដូហា ឆ្នាំ២០០១ ក្នុងបរិបទបរាជ័យពេញទី និងការវាយប្រហារភេរវកម្មថ្ងៃទី១១ កញ្ញា។ បរិបទនេះបានជំរុញទឹកចិត្តអ្នកចរចា ហើយបញ្ហា និងសម្បទានជាច្រើនបានដើរទៅមុខ។

សន្និសីទទី៥ប្រព្រឹត្តទៅនៅកង់គុន(Cancun) នាឆ្នាំ២០០៣។ កង្វល់របស់ប្រទេសកំពុងអភិវឌ្ឍគឺការធ្វើឱ្យច្បាប់កម្មសិទ្ធិបញ្ញាមានលក្ខណៈទន់ភ្លន់។ សន្និសីទទី៦នៅទីក្រុងហុងកុងនាឆ្នាំ២០០៥ ត្រូវបានប្រើសម្រាប់តម្រង់ខួបដូហាឱ្យនៅផ្លូវត្រង់ឡើងវិញ ផ្ដល់កម្លាំងជំរុញថ្មីសម្រាប់បិទខួបចរចាទីក្រុងដូហា។ ការអនុម័តអត្ថបទនេះគឺអនុគ្រោះដល់រដ្ឋសមាជិកដែលជាអ្នកផលិតកប្បាស(ប្រទេសនៅអាហ្វ្រិក ដូចជាបេណាំង និងឆាត)។

សន្និសីទទី៧ប្រព្រឹត្តទៅនៅឆ្នាំ២០០៩នាទីក្រុងហ្សឺណែវ។ ចំណុចជាច្រើនត្រូវបានលើកមកពិភាក្សាដើម្បីផ្ដល់ភាពស្វាហាប់ឡើងវិញដល់ខួបចរចាទីក្រុងដូហា ហើយក៏មានការអភិវឌ្ឍបន្ទាប់បន្សំនានា ដូចជាជំនួយសម្រាប់ពាណិជ្ជកម្ម(APC) ដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍ។ សព្វថ្ងៃ ខួបចរចាទីក្រុងដូហានៅស្រពេចស្រពិលនៅឡើយ។ ប្រទេសអភិវឌ្ឍមានបំណងចង់បាន

ជម្មនិយាមស្តីពីបរិស្ថាន និងជម្មនិយាមសង្គម ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍមានអវិភាពទៅនឹងបញ្ហាថ្មីៗ។

មុខងាររបស់អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានអនុវត្តដោយសន្និសីទថ្នាក់រដ្ឋមន្ត្រីដែលមានអំណាចសម្រេចកំពូល។

តាមវិធានទូទៅ ការធ្វើសេចក្តីសម្រេចផ្អែកលើកុងសង់ស៊ីស លើកលែងមានបញ្ញត្តិពិសេសដូចជាការបោះឆ្នោតដែលធ្វើឡើងករណីពុំមានកុងសង់ស៊ីស(ពីសំឡេង២ភាគ៣ក្នុងកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ទៅសំឡេងភាគច្រើន៣ភាគ៤ដាច់ខាត ក្នុងករណីអង្គការពាណិជ្ជកម្មពិភពលោក(ក្នុងករណីបកស្រាយអត្ថបទ)។ មានតែសន្និសីទថ្នាក់រដ្ឋមន្ត្រីប៉ុណ្ណោះដែលមានអំណាចបកស្រាយជាយថាភូត។ គេបញ្ចៀសពុំឱ្យរដ្ឋខ្លួនឯងផ្ទាល់ជាអ្នកបកស្រាយកាតព្វកិច្ចរបស់ខ្លួន។ មានតែសន្និសីទថ្នាក់រដ្ឋមន្ត្រីទេដែលអាចធ្វើបដិបញ្ញត្តិបាន(គេពុំចង់ឱ្យរដ្ឋទាំងអស់រួចពីកាតព្វកិច្ចរបស់ខ្លួននោះទេ)។

## ១.៤.២- ក្រុមប្រឹក្សាអង្គភាពដោះស្រាយអធិករណ៍ និងអង្គភាពពិនិត្យនយោបាយពាណិជ្ជកម្ម

ចំណុចរួមមួយគឺថា អង្គភាពទាំងនេះមានលក្ខណៈពេញអង្គ(គ្រប់តំណាងរបស់អង្គការពាណិជ្ជកម្មទាំងអស់ចូលរួម)។ ក្រុមប្រឹក្សាមាន៤ក្នុងនោះមាន ៖

ក្រុមប្រឹក្សាធំជាងគេគឺអគ្គក្រុមប្រឹក្សាដែល (១) មានសមត្ថកិច្ចទូទៅទៅលើការត្រួតពិនិត្យ (គឺក្រោមសន្និសីទថ្នាក់រដ្ឋមន្ត្រីតែម្តង) (២) ជានាទិវន្តរភាពនៃដំណើរប្រព្រឹត្តទៅរបស់អង្គការដោយធ្វើការប្រជុំប្រចាំខែ និងធ្វើឡើងដោយសន្និសីទថ្នាក់រដ្ឋមន្ត្រី និង (៣) ជានាទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត។

ក្រុមប្រឹក្សាបីទៀតជាក្រុមប្រឹក្សាតាមវិស័យដែលឆ្លើយតបទៅនឹងកិច្ចព្រមព្រៀងពហុភាគីធំៗដូចជាក្រុមប្រឹក្សាពាណិជ្ជកម្មទំនិញ ក្រុមប្រឹក្សាពាណិជ្ជកម្មសេវាកម្ម និងក្រុមប្រឹក្សាទិដ្ឋភាពច្បាប់កម្មសិទ្ធិបញ្ញាដែលទាក់ទិននឹងពាណិជ្ជកម្ម(ADPIC)។

រាល់បដិបញ្ញត្តិត្រូវឆ្លងកាត់ការប្រឹក្សាពីសន្និសីទថ្នាក់រដ្ឋមន្ត្រី និងក្រុមប្រឹក្សាតាមវិស័យផងដែរ។ ក្រុមប្រឹក្សាទាំងនេះផ្សំបានជាបរិមណ្ឌលសម្រាប់កិច្ចចរចាក្នុងវិស័យផ្សេងៗ។

អង្គភាពដោះស្រាយអធិករណ៍(ORD) និងអង្គភាពពិនិត្យនយោបាយពាណិជ្ជកម្ម(OEPC)។

## ១.៤.៣- ប្រភេទអង្គភាពទី៣ គឺជាលេខាធិការដ្ឋាន និងអគ្គនាយក

លេខាធិការដ្ឋានដើរតួនាទីជំរុញដើម្បីធ្វើឱ្យអង្គការស្វាហាប់ឡើងវិញ នៅពេលអង្គការត្រូវជាប់គាំង។ ទាំងនេះគឺជាកិច្ចការរដ្ឋបាល ប៉ុន្តែការងារជំរុញនេះមានសារៈសំខាន់ខ្លាំង នៅពេល



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការចរចាមានការលំបាក។ អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប។

## ១.៤.៤- អង្គភាពបន្ទាប់បន្សំ

អង្គភាពបន្ទាប់បន្សំគឺជាគណៈកម្មាធិការផ្សេងៗដូចជា គណៈកម្មាធិការពាណិជ្ជកម្ម និងការអភិវឌ្ឍគណៈកម្មាធិការពាណិជ្ជកម្មនិងបរិស្ថាន និងគណៈកម្មាធិការកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់។ គណៈកម្មាធិការចរចាពាណិជ្ជកម្មត្រូវបានបង្កើតឡើង បន្ទាប់ពីមានសេចក្ដីប្រកាសទីក្រុងដូហា ដើម្បីសម្រួលដល់ការចរចា។

## ១.៥- ទស្សនាទានថ្មីនៃរបបអនុសញ្ញា

ធម្មនុញ្ញរបស់អង្គការពាណិជ្ជកម្មពិភពលោកជាសក្ខីភាពបញ្ជាក់ពីទស្សនាទានថ្មីទៅលើរបបអនុសញ្ញាថ្មីដែលផ្ដោតទៅលើអ័ក្សគោលចំនួន២ និងយន្តការពីរ។ អ័ក្សទាំងពីរមាន (១) គោលការណ៍កិច្ចព្រមព្រៀងទោល (២) យន្តការដឹកនាំដែលមានដូចជាការបកស្រាយ ការធ្វើបដិបញ្ញត្តិ និងការសើរើ។ យន្តការទាំងពីរគឺជាយន្តការដោះស្រាយអធិករណ៍ និងអង្គភាពពិនិត្យនយោបាយពាណិជ្ជកម្ម។

## ១.៥.១- គោលការណ៍កិច្ចព្រមព្រៀងទោល

គោលការណ៍កិច្ចព្រមព្រៀងតែមួយដើរតួជំនួយឱ្យធម្មនុញ្ញបង្កើតអង្គការ និងឧបសម្ព័ន្ធដំបូងទាំង៣។ រដ្ឋដែលក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកសន្យាចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងទាំងពីរ។ កិច្ចព្រមព្រៀងទោលមានកម្មវត្ថុបញ្ចៀសរាល់ការកម្ទាយរបស់ខួបចរចាទីក្រុងតូក្យូ( ក្រម)។ រដ្ឋសមាជិកទាំងអស់ត្រូវចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងដែលបានគ្រោង(ធម្មនុញ្ញ និងឧបសម្ព័ន្ធទាំង៣)។ នេះគឺជាកត្តាសង្គតភាព និងសន្តិសុខគតិយុត្ត ព្រោះរដ្ឋសមាជិកត្រូវនៅចំណុះកាតព្វកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក។ កិច្ចព្រមព្រៀងទាំងឡាយដែលពុំឋិតក្រោមចំណុះគោលការណ៍កិច្ចព្រមព្រៀងទោល គឺកិច្ចព្រមព្រៀងតាមការជ្រើសរើស ឬពហុភាគីដែលទាក់ទងទៅនឹងលទ្ធកម្មសាធារណៈ និងពាណិជ្ជកម្មអាកាសយានស៊ីវិល។

ដើម្បីធានាប្រសិទ្ធភាពគោលការណ៍កិច្ចព្រមព្រៀងទោល គេប្រើសិទ្ធិបម្រុង។ រដ្ឋទាំងអស់ពុំអាចធ្វើសិទ្ធិបម្រុងទៅលើកិច្ចព្រមព្រៀងដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក និងទៅលើក្របខ័ណ្ឌកម្មតឹងរឹងសម្រាប់កិច្ចព្រមព្រៀងពហុភាគីទេ។

ប៉ុន្តែ រដ្ឋមួយអាចធ្វើសិទ្ធិបម្រុងទៅលើរដ្ឋមួយទៀតបាន។ សិទ្ធបម្រុងអាចធ្វើទៅបានរវាងរដ្ឋសមាជិកពីរ។ ប៉ុន្តែ សិទ្ធិបម្រុងអាចប្រព្រឹត្តទៅបានសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី

រវាងរដ្ឋនេះ និងរដ្ឋមួយទៀត។ ការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោកពុំអនុញ្ញាតឱ្យរដ្ឋ ហត្ថលេខីនៃកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មបង្ហាញពីសិទ្ធិបម្រុងទេ។ មានតែសមាជិកថ្មីទេដែលអាចបង្ហាញសិទ្ធិបម្រុងបាន ក្នុងនោះមានប្រទេសជាសមាជិកថ្មីប្រមាណ៣០។

តើនរណាទទួលអត្ថប្រយោជន៍ពីគោលការណ៍កិច្ចព្រមព្រៀងទោល? ក្នុងការបកស្រាយ គឺចៅក្រមជាអ្នកយកចិត្តទុកដាក់ជានាការអនុវត្តរួម គឺធ្វើឱ្យកិច្ចព្រមព្រៀងបិតក្នុងកម្រិតតែមួយ។ ពិសេស ក្នុងករណីមានអធិករណ៍ ចេតនារបស់អ្នកចរចាត្រូវមានចែងក្នុងកម្មវត្ថុ និងគោលបំណងរបស់កិច្ចព្រមព្រៀងមួយទៀត។ គ្រប់កិច្ចព្រមព្រៀងទាំងនេះមានបំណងដូចគ្នា។ កម្មវត្ថុ និងបំណងមាននៅក្នុងលិខិតូបករណ៍ ពោលគឺកិច្ចព្រមព្រៀងគោលជួយសម្រួលដល់ការងាររបស់ចៅក្រម។

## ១.៥.២- យន្តការដឹកនាំ

យន្តការដឹកនាំពាក់ព័ន្ធនឹងការបកស្រាយ ការធ្វើបដិបញ្ញត្តិ និងការសើរើ។

## ការបកស្រាយ

ការបកស្រាយជាយថាភូតគឺត្រៀមសម្រាប់សន្និសីទថ្នាក់រដ្ឋមន្ត្រី។ កាលណាពុំមានសន្និសីទទេ គឺអគ្គក្រុមប្រឹក្សាជាអ្នកទទួលបន្ទុក។ ការបកស្រាយជាឯកតោភាគីត្រូវបានដកចេញដោយច្បាស់ក្រឡែត។

សំណើសុំបកស្រាយត្រូវឆ្លងយោបល់ក្រុមប្រឹក្សាតាមវិស័យ។ បន្ទាប់មក ការបកស្រាយនេះត្រូវឆ្លងយោបល់សន្និសីទរដ្ឋមន្ត្រីដើម្បីសម្រេច។

ការបោះឆ្នោតគឺធ្វើឡើងតាមសំឡេងភាគច្រើន៣ភាគ៤នៃសមាជិកក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រី ឬរបស់អគ្គក្រុមប្រឹក្សា(ការបកស្រាយយថាភូត)។ ចំណុចនេះពុំរាប់បញ្ចូលនូវការបកស្រាយដើម្បីបន្ថយព្រំដែននៃនីតិវិធីធ្វើវិសោធនកម្មដើម្បីសើរើកិច្ចព្រមព្រៀងឡើយ។ ការសើរើនេះមានក្របខ័ណ្ឌយ៉ាងតឹងរឹង។ គេពុំចង់ឱ្យការបកស្រាយឈានទៅដល់ការធ្វើវិសោធនកម្ម និងបង្វែងចេញពីនីតិវិធីទេ។ ក្នុងការអនុវត្ត ពុំមានការបកស្រាយយថាភូតណាមួយត្រូវបានអនុម័តដោយអង្គការពាណិជ្ជកម្មពិភពលោកទេ។

## ការធ្វើបដិបញ្ញត្តិ

ភាពខុសគ្នាធំមួយរវាងកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយនិងពាណិជ្ជកម្ម និងអង្គការពាណិជ្ជកម្មពិភពលោក ៖ អន្តរបញ្ញត្តិត្រូវបានហាមប្រាមយ៉ាងតឹងរឹងនៅក្នុងអង្គការពាណិជ្ជកម្ម

ពិភពលោកពោលគឺលែងមានច្បាប់បុរេគតដែលមានវិសមិតភាពនឹងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកទៀតហើយ។ ករណីមានបដិបញ្ញត្តិ រដ្ឋមួយទៀតនឹងវាយប្រហាររដ្ឋពាក់ព័ន្ធនៅចំពោះមុខអង្គការពាណិជ្ជកម្មពិភពលោក។ ដូច្នេះ នឹងមានអាវុធហត្ថចំនួន១៥៣រូបដែលអាចបង្កជាចំណោទទៅលើរដ្ឋដែលពុំគោរពច្បាប់។

រដ្ឋមួយអាចស្នើសុំបដិបញ្ញត្តិបាន។ សំណើនេះត្រូវទទួលការយល់ព្រមពីសំឡេងចំនួន៣ភាគ៤ពីសមាជិក។ បដិបញ្ញត្តិទាំងនេះត្រូវបានផ្តល់ជូនសម្រាប់រយៈពេលដ៏ខ្លីមួយ។

## ការសើរើ ឬវិសោធនកម្ម

រាល់វិសោធនកម្មត្រូវបានចែងក្នុងមាត្រា១០ក្នុងធម្មនុញ្ញដែលរៀបរាប់អំពីគ្រប់នីតិវិធីវិសោធនកម្ម។ នីតិវិធីសើរើតាមសំឡេងភាគច្រើន ដោយសំឡេង២ភាគ៣ មានលក្ខណៈចាប់បង្ខំតិចជាង។ វិសោធនកម្មនេះពាក់ព័ន្ធតែបញ្ញត្តិមួយប៉ុណ្ណោះ។ វិសោធនកម្មពុំអនុវត្តទៅលើរដ្ឋទាំងអស់ដែលជំទាស់ទេ។ ចំណុចនេះជួយកាត់បន្ថយអានុភាព និងការប្រើប្រាស់វិសោធនកម្ម។ គ្រប់រដ្ឋសមាជិក និងក្រុមប្រឹក្សាតាមវិស័យអាចស្នើសុំវិសោធនកម្មបាន។

មាត្រា និងកិច្ចព្រមព្រៀងមួយចំនួនអាចត្រូវកែប្រែបានទាល់តែមានសំឡេងជាឯកច្ឆន្ទប៉ុណ្ណោះ គឺមាត្រា៩ចែងពីការធ្វើសេចក្តីសម្រេច។

## ១.៦- ការចូលរួមរបស់រដ្ឋក្នុងស្ថាប័ននានា

ក្នុងករណីនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម មានស្ថានភាពស្ថាប័ន៤របស់រដ្ឋសមាជិកគឺ (១) រដ្ឋជាភាគីកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (២) លក្ខន្តិកៈចូលជាសមាជិកបណ្តោះអាសន្ន គឺរដ្ឋមួយកំពុងស្ថិតនៅក្នុងពេលអន្តរកាល ពោលគឺសមាជិកមានភាពងាយស្រួលក្នុងការឈានទៅប្រើប្រាស់វិធានពហុភាគី (៣) អ្នកសង្កេតការណ៍ (៤) ការអនុវត្តតាមព្រឹត្តិហេតុ ពោលគឺអង្គភាពមួយចំនួនទោះពុំមែនជាសមាជិកក្តី អាចគោរពតាមវិន័យពាណិជ្ជកម្ម និងទទួលផលពីការអនុវត្តតាមព្រឹត្តិហេតុរបស់ភាគីជាប់កិច្ចសន្យា គឺសហគមន៍អឺរ៉ុប។

ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក គេឃើញមានលក្ខន្តិកៈគតិយុត្ត២គឺ (១) សមាជិក (ក) សមាជិកដើម(ឆ្នាំ១៩៩៥) និង(ខ) សមាជិកកំពុងចូលជាសមាជិក(ក្រោយឆ្នាំ១៩៩៥) សហភាពអឺរ៉ុបគឺជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (២) អ្នកសង្កេតការណ៍។

### ១.៦.១- សមាជិកដើម

មានលក្ខខណ្ឌពីរគឺ (១) រដ្ឋត្រូវតែជាភាគីជាប់កិច្ចសន្យារបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម(សហគមន៍អឺរ៉ុប ទោះពុំមែនជាភាគីជាប់កិច្ចសន្យាក្តី ក៏ជាសមាជិកដើមដែរ) (២) រដ្ឋត្រូវចូលជាសមាជិកក្នុងបណ្តុំកិច្ចព្រមព្រៀងដែលបានគ្រោងទុក។ រដ្ឋនីមួយៗត្រូវបង្ហាញបញ្ជីសម្បទានជាតិមួយ។ ប្រទេសអភិវឌ្ឍតិចតួចធ្វើការសន្យាតែក្នុងកម្រិតលទ្ធភាពដែលខ្លួនអាចផ្តល់ឱ្យបានតែប៉ុណ្ណោះ។ ប្រទេសអភិវឌ្ឍបានផ្តល់ភាពទន់ភ្លន់ងាយបត់បែនបាន។ ប្រទេសអភិវឌ្ឍតិចតួច និងប្រទេសកំពុងអភិវឌ្ឍពុំមានសមត្ថភាពស្ថាប័ន និងរដ្ឋបាលដើម្បីដំណើរការកិច្ចព្រមព្រៀងទេ។

### ១.៦.២- ការចូលជាសមាជិក

ការចូលជាសមាជិកត្រូវបើកសម្រាប់គ្រប់រដ្ឋ និងដែនដីពន្ធគយស្វយ័តទាំងអស់(ហុងកុងគឺជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក)។ អង្គការពាណិជ្ជកម្មពិភពលោកជាផ្នែកមួយនៃសន្និសញ្ញាបិទពាក់កណ្តាល។ រដ្ឋចង់ក្លាយជាសមាជិកត្រូវធ្វើការចរចាជាមួយរដ្ឋសមាជិក។ រដ្ឋនោះត្រូវស្នើពីសម្បទានតម្លៃ និងមិនមែនតម្លៃ ហើយទទួលផលពីលក្ខខណ្ឌសម្រាប់រដ្ឋជាសមាជិក។ ដើម្បីក្លាយជាសមាជិក ត្រូវធ្វើសេរីភាវូបនីយកម្ម ប្រសិនបើបំពេញគ្រប់លក្ខខណ្ឌ។ ក្រោយចរចារួច បេក្ខភាពត្រូវដាក់ជូនសន្និសីទថ្នាក់រដ្ឋមន្ត្រីដើម្បីអនុម័ត។

## ១.៧- លក្ខន្តិកៈនៃអ្នកសង្កេតការណ៍

ដើម្បីសង្កេតមើលដំណើរប្រព្រឹត្តទៅ និងជៀបជាមួយសេចក្តីសម្រេចនានាដែលបានធ្វើរួច មានជំហរឯកសិទ្ធិមួយ ប៉ុន្តែពុំមានលទ្ធភាពណាមួយក្នុងការជះឥទ្ធិពលដល់សិទ្ធិបោះឆ្នោតទេ។ ឧទាហរណ៍ ដូចជាសន្តនិកេតន៍(le Saint-Siège)ជាដើម។

## ១.៨- ការបាត់បង់សមាជិកភាព

ក្នុងករណីនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ពុំមាននីតិវិធីដកខ្លួន និងបណ្តេញចេញណាមួយត្រូវបានគ្រោងឡើយ។ មានតែការព្យួរប៉ុណ្ណោះ។

ក្នុងករណីនៃអង្គការពាណិជ្ជកម្មពិភពលោក ខដកខ្លួនមួយត្រូវបានគ្រោងទុក រដ្ឋមួយអាចសម្រេចដកខ្លួនចេញបាន(មាត្រា១៥ក្នុងធម្មនុញ្ញ) ដោយជូនដំណឹង៦ខែមុន។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី២

## យន្តការដោះស្រាយអធិករណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក

ឧបសម្ព័ន្ធ២នៃកិច្ចព្រមព្រៀងម៉ារ៉ាកិច(Marrakech)ឆ្នាំ១៩៩៤(កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មនាឆ្នាំ១៩៩៤)ចែងពីយន្តការដែលជំនួសក្រុមពិភាក្សាប្រពៃណី(ត្រូវបានរក្សាទុកក្រោមឈ្មោះ«ក្រុមពិសេស»)។

អង្គភាពដោះស្រាយអធិករណ៍(ORD) គឺជាអង្គភាពថ្មី ទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀង (បង្កើតក្រុមការងារពិសេស និងអង្គភាពទទួលបន្ទុកផ្នែកបណ្ដឹង មើលការខុសត្រូវពីលើការអនុវត្តសេចក្ដីសម្រេច និងអនុសាសន៍)។

ក្នុងដំណាក់កាលដំបូង សមាជិកមួយរូបអាចស្នើសុំការពិគ្រោះយោបល់ដែលសមាជិកពាក់ព័ន្ធមួយ ឬច្រើនពុំអាចដកខ្លួនចេញបាន។ ប្រសិនបើការពិគ្រោះយោបល់ពុំចេញជាលទ្ធផលក្នុងរយៈពេល៦០ថ្ងៃ(២០ថ្ងៃករណីបន្ទាន់) ភាគីបណ្ដឹងអាចស្នើសុំឱ្យបង្កើត«ក្រុមពិសេស»បាន។

សវនាការទី១ ក្រុមការងារពិសេសដែលមានសមាសភាព៣រូបដែលមាន«គុណវុឌ្ឍិខ្ពស់» និងឯករាជ្យ និង«ស្នើឡើង»ដោយលេខាធិការអង្គភាពដោះស្រាយអធិករណ៍ ឬចាត់តាំងដោយអគ្គនាយក ប្រសិនបើគ្មានសំណើខាងលើ។ ក្រុមនេះអាចប្រមូលមតិពីក្រុមជំនាញការផ្នែកប្រឹក្សាយោបល់ ហើយត្រូវ«ប្រឹក្សាយោបល់»គ្រប់ភាគីទាំងអស់ដើម្បីទទួលបានចម្លើយពេញចិត្តទៅវិញទៅមក។ នេះគឺជា«ការប្រឹក្សាយោបល់ផ្ទាល់»ដែលត្រូវនាំទៅរក«ដំណោះស្រាយដែលទទួលយកបានទៅវិញទៅមក» និងមានសមិតភាពជាមួយនឹងវិធាននៃកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម។ ក្នុងករណីផ្ទុយពីនេះ ក្រុមការងារពិសេសបង្ហាញ«លទ្ធផលសង្កេត និងអនុសាសន៍របស់ខ្លួន»។ របាយការណ៍ត្រូវអនុម័តដោយអង្គភាពដោះស្រាយអធិករណ៍ លើកលែងតែភាគីមួយសម្រេចប្ដឹងទៅអង្គភាពបណ្ដឹងឧទ្ធរណ៍អចិន្ត្រៃយ៍។

សវនាការទី២ អង្គភាពបណ្ដឹងអចិន្ត្រៃយ៍របស់អង្គការពាណិជ្ជកម្មពិភពលោកមានសមាសភាព៧រូបដែលចាត់តាំងដោយអង្គភាពដោះស្រាយអធិករណ៍សម្រាប់រយៈពេល៤ឆ្នាំ។ របាយការណ៍របស់អង្គភាពបណ្ដឹងនឹងត្រូវអនុម័តដោយអង្គភាពដោះស្រាយអធិករណ៍ និងត្រូវទទួលយកដោយឥតលក្ខខណ្ឌពីគូភាគីអធិករណ៍ទាំងអស់ លើកលែងតែអង្គភាពដោះស្រាយអធិករណ៍សម្រេចតាមកុងសង់ស៊ីសថា មិនអនុម័តរបាយការណ៍របស់អង្គភាពបណ្ដឹង។ អង្គភាពបណ្ដឹងប្រកាសដោយខ្លួនឯងតាមលក្ខណៈច្បាប់ និងសម្រេច ហើយបញ្ជាក់ថា ខុស ឬត្រូវទៅលើក្រុមពិសេស។ នីតិវិធីទាំងនេះត្រូវធ្វើដោយសម្ងាត់។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លទ្ធផលធម្មតារបស់អង្គភាពគឺការដកយ៉ាងឆាប់នូវវិធានការដែលជាចំណោទបញ្ហា។ ការប៉ះប៉ូវ ឬការព្យួរសម្បទានពាណិជ្ជកម្មត្រូវតែធ្វើអន្តរាគមន៍តែក្នុងនាមជាជំនួយដោយគ្មានជម្រើសពិសេស( ជាអ្វីដែលគេប្រើប្រាស់ ពេលគ្មានអ្វីប្រសើរជាងនេះ)។

រដ្ឋត្រូវអនុលោមខ្លួនទៅតាមក្រុមពិសេស ឬអង្គភាពបណ្ដឹង។ ប្រសិនបើរដ្ឋនោះពុំកែប្រែ ឬដកខ្លួនទេ រដ្ឋផ្សេងនឹងចាត់វិធានការណ៍។ ប្រតិវិធានការនេះពុំមែនជាទណ្ឌកម្មទេ។ វិធានការទាំងនេះមានគោលដៅបង្កើតលំនឹងរវាងសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកឡើងវិញ។

ដំណោះស្រាយមានលក្ខណៈចាប់បង្ខំសម្រាប់គូភាគីទាំងអស់។ ទោះយ៉ាងនេះក្ដី ភាគីទាំងអស់អាចពឹងរកជំនួយពីមជ្ឈត្តករផ្ទុវការ។ ពីប្រព័ន្ធបញ្ចុះបញ្ចូលដោយទន្លឹករណ៍ គេឈានទៅរកយន្តការផ្សះផ្សារលក្ខណៈចាប់បង្ខំ។

អង្គភាពដោះស្រាយអធិករណ៍មានថវិកាផ្ទាល់ខ្លួនដើម្បីធានាឯករាជ្យភាព។ លេខាធិការដ្ឋានរងការរិះគន់ទៅលើអំណាចដែលខ្លួនកាន់។ សមាជិកលេខាធិការដ្ឋានទាំងអស់ស្គាល់ច្បាស់ពីអង្គការពាណិជ្ជកម្មពិភពលោក ដូច្នេះសុទ្ធសឹងជាបុគ្គលិកដែលមានការចងចាំ និងចំណេះដឹងដែលអាចមានឥទ្ធិពលផ្ទាល់ទៅលើរឿងគ្រប់យ៉ាង។

ប្រទេសចិនបានរំលោភមាត្រានេះ។ ប្រសិនបើប្រទេសចិនត្រូវផ្ដន្ទាទោស នឹងមានការខាតបង់។ រដ្ឋអាចដាក់កំហិតបាន។

ទាក់ទងនឹងសាច់មកពីអាមេរិកក្នុងករណីមានអ័រម៉ូន។ អង្គការពាណិជ្ជកម្មពិភពលោកសហគមន៍អឺរ៉ុប-កាណាដា។ សហគមន៍អឺរ៉ុបត្រូវបានផ្ដន្ទាទោស ហើយត្រូវអនុញ្ញាតឱ្យសាច់មានអ័រម៉ូនចូល។ សហគមន៍អឺរ៉ុប និងកាណាបានចាត់ប្រតិវិធានការ ដោយតម្លើងថ្លៃពន្ធគយលើថ្ងើមខ្ទាញ់ និងហ្វូម៉ាស។ មតិរិះគន់នោះគឺថា សម្រាប់អាមេរិក ប្រតិបត្តិករ និងអ្នកនាំសាច់គោចេញ ហើយសម្រាប់សហគមន៍អឺរ៉ុប អ្នកផលិតថ្ងើម និងហ្វូម៉ាសដែលពុំពាក់ព័ន្ធនឹងសាច់គោ។ ប៉ុន្តែយន្តការនេះមានបំណងឱ្យកិច្ចព្រមព្រៀងទូទៅ និងពិសេសទាំងអស់ត្រូវបានគេគោរព។

# ច្បាប់សត្យានុម័តរបស់ អង្គការពាណិជ្ជកម្មពិភពលោក

## ផ្នែកទី៣

## ការពង្រឹងវិន័យ

### ១- ការពង្រឹងវិន័យផ្ទាល់ខ្លួន

*ការពង្រឹងវិន័យផ្ទាល់ខ្លួនធ្វើឡើងតាមរយៈយន្តការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម(MEPC) ដើម្បីជានាតម្លាភាពនៃប្រព័ន្ធ។ រដ្ឋនីមួយៗត្រូវជូនដំណឹងដល់រដ្ឋដទៃទៀត ហើយរដ្ឋដទៃទៀតទាំងនោះនឹងពិនិត្យមើលបញ្ជីសារពើភណ្ឌដែលធ្វើឡើងដោយរដ្ឋផ្សេងទៀត។*

*នៅឆ្នាំ១៩៨៩ យន្តការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មត្រូវបានបង្កើតឡើង ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម(GATT)។ យន្តការនេះអនុវត្តចំពោះទំនិញ សេវាកម្ម និងសិទ្ធិលើកម្មសិទ្ធិបញ្ញា។ គោលបំណង ៖ បង្ការឱ្យមានតម្លាភាពដែលអាចបញ្ចៀសបាននូវអតុល្យភាពខ្លាំងពេកនៅក្នុងគោលនយោបាយ និងទម្លាប់អនុវត្តន៍ក្នុងពាណិជ្ជកម្ម។ អ្នកទទួលប្រយោជន៍ទីមួយគឺរដ្ឋខ្លួនឯងផ្ទាល់។ យន្តការនេះមិនអាចនាំឱ្យចាប់ផ្ដើមយន្តការដោះស្រាយជម្លោះបានឡើយ។ យន្តការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម និងយន្តការដោះស្រាយជម្លោះត្រូវបានចែកដាច់ពីគ្នា។ យន្តការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម គឺជាយន្តការដែលធ្វើបច្ចុប្បន្នកម្មច្បាប់ដែលមិនត្រឹមត្រូវតាមបទដ្ឋាន។ ប្រសិនបើមានទំនាក់ទំនងគ្នា រដ្ឋមួយបោះពុម្ពផ្សាយច្បាប់របស់ខ្លួន ហើយរដ្ឋមួយទៀតអាចកំណត់ចំណុចខ្វះចន្លោះនៃច្បាប់នោះដើម្បីតតាំងក្នុងក្របខ័ណ្ឌនៃយន្តការដោះស្រាយជម្លោះ។*

*យោងតាមការចូលរួមរបស់ប្រទេសក្នុងពាណិជ្ជកម្មពិភពលោក យើងសង្កេតឃើញមានបីក្រុម ៖ (i) ប្រទេសធំៗចំនួន៤ដែលធ្វើការត្រួតពិនិត្យរៀងរាល់២ឆ្នាំម្ដង ៖ ចិន សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងជប៉ុន (ii) ប្រទេស១៦ទៀតធ្វើការត្រួតពិនិត្យរៀងរាល់៤ឆ្នាំម្ដង និង (៣) សម្រាប់ប្រទេសផ្សេងទៀត រៀងរាល់៦ឆ្នាំម្ដង។ ប្រទេសអភិវឌ្ឍតិចតួចអាចទទួលបានរយៈពេលកំណត់យូរ។*

*នៅឆ្នាំ២០០៩ យន្តការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មជាង៣០០ត្រូវបានធ្វើឡើងនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ រដ្ឋចំនួន១៣៦ជាកម្មវត្ថុនៃយន្តការត្រួតពិនិត្យគោល*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នយោបាយពាណិជ្ជកម្ម។ យន្តការនេះមានភាពសមស្របសម្រាប់សមាជិកដែលមានបំណងចង់ធ្វើកំណែទម្រង់។ យន្តការនេះគឺដើម្បីស្នើឱ្យជួយអនុលោមតាមអង្គការពាណិជ្ជកម្មពិភពលោកដោយសុច្ឆន្ទៈ។ ប្រសិនបើក្នុងចំណោមរដ្ឋទាំង១៦ គេរកឃើញភាពមិនអនុលោម ការត្រួតពិនិត្យនឹងធ្វើឡើងកាន់តែញឹកញាប់ គឺពី៤ឆ្នាំម្តងមកត្រឹម២-៣ឆ្នាំម្តង។

## ២- ការពង្រឹងវិន័យរួម

អង្គការពាណិជ្ជកម្មពិភពលោក គឺត្រូវដោះស្រាយបញ្ហាមួយចំនួននៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម(GATT)ដោយប្រើការលើកលែង និងបដិប្បញ្ញត្តិ។ ដើម្បីធ្វើការពង្រឹងនេះ អ្វីជាច្រើនត្រូវបានបង្កើតឡើង។

១- យើងរកឃើញគោលការណ៍នៃកិច្ចព្រមព្រៀងតែមួយដែលមានគោលបំណងធ្វើយ៉ាងណាឱ្យទាំងអស់គ្នាគោរពតាមកាតព្វកិច្ច។ ដែនអនុវត្តត្រូវបានពង្រីកពីទំនិញរហូតដល់សេវាកម្ម និងសិទ្ធិលើកម្មសិទ្ធិបញ្ញា។

២- មធ្យោបាយមួយទៀត គឺជានាឱ្យមានតម្លាភាព ជាការបង្ការ ប៉ុន្តែក៏ដើម្បីអនុវត្តការឃ្លាំមើលរួមគ្នាផងដែរ។ សមាជិកនីមួយៗមានកាតព្វកិច្ចជូនដំណឹង។ បន្ទាប់មក ការជូនដំណឹងទាំងនេះនឹងនាំឱ្យមានការត្រួតពិនិត្យដោយស្ថាប័នជំនាញមួយ ៖ គណៈកម្មាធិការចូលទៅកាន់ទីផ្សារ។ ការធ្វើដូច្នេះអនុញ្ញាតឱ្យរដ្ឋដទៃទៀតធ្វើការជូនដំណឹងអំពីការសង្កេតឃើញរបស់ខ្លួននូវការលាក់លៀមអំពីវិធានការដែលត្រូវបានជូនដំណឹង។ រដ្ឋម្ចាស់វិធានការនឹងផ្តល់ការពន្យល់។ យើងត្រូវរកឱ្យឃើញតុល្យភាពរវាងគោលជំហររបស់រដ្ឋនីមួយៗ។ នីតិវិធីនៃការជូនដំណឹងនេះគឺជាប្រភពនៃបញ្ហា។ បណ្តារដ្ឋតូចៗនឹងមានការលំបាកក្នុងការអនុវត្តតាមវិធានការដែលបានជូនដំណឹង។

៣- គោលការណ៍នៃការផ្សព្វផ្សាយដោយមិនមានការរឹតត្បិត

ឯកសារទាំងអស់ត្រូវផ្សព្វផ្សាយដោយមិនមានការរឹតត្បិត លើកលែងតែឯកសារសម្ងាត់ប៉ុណ្ណោះ។

៤- ក្នុងវិស័យកសិកម្ម អង្គការពាណិជ្ជកម្មពិភពលោកផ្តល់ការអនុគ្រោះដល់ការគាំទ្រផ្ទៃក្នុង(មានតម្លាភាពខ្ពស់)ជាជាងការឧបត្ថម្ភកធនដល់ការនាំចេញ(ហាមឃាត់)។ អង្គការពាណិជ្ជកម្មពិភពលោក ផ្តល់ការអនុគ្រោះដល់ពន្ធគយជាជាងរបាំងមិនមែនពន្ធគយ។ យើងងាយស្រួលកំណត់ពន្ធគយ ហើយដូច្នេះ វាមានភាពងាយស្រួលក្នុងការលុបចោលពន្ធគយ។

# ផ្នែកទី៤
# គោលការណ៍គ្រឹះ និងដំណើរការនៃកិច្ចព្រមព្រៀងផ្សេងៗ របស់អង្គការពាណិជ្ជកម្មពិភពលោក

*គោលការណ៍ស្នូលគឺគោលការណ៍មិនរើសអើង។ ប្រព្រឹត្តកម្មជាតិ(TN) និងខចែងនៃឋានៈប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុត(MFN) មានគោលដៅធានាឱ្យបាននូវការមិនរើសអើង។*

## ១- ទំនិញ

### ១.១- ខចែងនៃឋានៈប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុត

*ខចែងនៃឋានៈប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុត-NPF (ប្រការ១នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤) ជាផ្នែកដ៏សំខាន់នៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលជាការអនុវត្តដោយឥតលក្ខខណ្ឌ ក្នុងករណីនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម។ កាលណារដ្ឋមួយព្រមព្រៀងផ្តល់ការអនុគ្រោះដល់រដ្ឋមួយទៀត ខចែងនេះនឹងផ្តល់ប្រយោជន៍ដល់រដ្ឋដទៃផ្សេងទៀតដោយឥតលក្ខខណ្ឌ។ ប្រព័ន្ធនេះផ្អែកលើគោលការណ៍បដិការ។*

*ការកាត់បន្ថយពន្ធគយ(ប្រការ II) ៖ ការបន្ថយពន្ធគយគិតជាភាគរយ។ កម្រិតពន្ធគយមិនដូចគ្នាទេ។ អ្វីដែលសំខាន់គឺមធ្យមភាគនៃការបន្ថយពន្ធ ហើយរដ្ឋត្រូវជ្រើសរើសថាតើវិស័យណាត្រូវស្ថិតក្រោមអថេរនៃកម្រិតពន្ធគយ។ ការចរចាមានរយៈពេលវែង ពីព្រោះគេត្រូវប្រៀបធៀបថា តើរដ្ឋមួយផ្តល់ការបន្ថយដែលសមមូលដែរឬទេ។ ការបន្ថយ៣៥% ៖ ការបន្ថយ៥០% សម្រាប់វិស័យមួយ និង៥% សម្រាប់វិស័យមួយទៀត។*

*ក្នុងករណីនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម គោលការណ៍សំខាន់គឺខចែងនៃឋានៈប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុត(របាំងពន្ធគយ)។ ក្នុងករណីនៃអង្គការពាណិជ្ជកម្មពិភពលោក ប្រព្រឹត្តកម្មជាតិត្រូវបានប្រើ(របាំងមិនមែនពន្ធគយមានសារៈសំខាន់)។ ត្រូវស្នើឱ្យមានប្រព្រឹត្តកម្មចំពោះផលិតផលបរទេសដូចផលិតផលជាតិដែរ។*

### ១.២- ខចែងស្តីពីប្រព្រឹត្តកម្មជាតិ

*ខចែងស្តីពីប្រព្រឹត្តកម្មជាតិ TN - (ប្រការ III នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម)៖ ពន្ធ និងច្បាប់ជាតិទាក់ទងនឹងការធ្វើពាណិជ្ជកម្មមិនត្រូវវាយប្រហារលើផលិតផល*

នាំចូលដោយការរើសអើងធៀបនឹងផលិតផលជាតិឡើយ។ មាត្រា III-២ មានគោលដៅប្រយុទ្ធប្រឆាំងនឹងការអនុគ្រោះលើផលិតផលជាតិ។ មាត្រា III-៣ ទាក់ទងនឹងការយកពន្ធ និងមាត្រា III-៤ ទាក់ទងនឹងច្បាប់ពាណិជ្ជកម្មក្នុងប្រទេស(ការបិទប្រកាសលើទូកញ្ចក់)។ ផលិតផលត្រូវតែដូចគ្នា និងស្រដៀងគ្នា ទើបគោលការណ៍ត្រូវបានអនុវត្ត។ បញ្ហានៃភាពស្រដៀងគ្នានេះគឺជាប្រភពនៃវិវាទដ៏សំខាន់ក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក។

រឿងក្តីដំបូងៗ ៖ សហរដ្ឋអាមេរិក(ចុងចម្លើយ) - ប្រេងសាំង(ដើមបណ្តឹង ប្រទេសវេណេស៊ុយអេឡា) ទាក់ទងនឹងភាពស្រដៀងគ្នារបស់អង្គការពាណិជ្ជកម្មពិភពលោក។ រឿងក្តីទីពីរ ៖ ជប៉ុន - ភេសជ្ជៈមានជាតិអាល់កុល ឆ្នាំ១៩៩៦ ៖ ទាក់ទងនឹងភាពស្រដៀងគ្នា។

ការទាមទារការមិនរើសអើង ៖ មាត្រា III-២ ៖ (ទីមួយ) ទាក់ទងនឹងផលិតផលស្រដៀងគ្នា (ដូចគ្នា) (ទីពីរ) ផលិតផលប្រកួតប្រជែង ឬអាចជំនួសគ្នាបាន។

ប្រសិនបើផលិតផលស្រដៀងគ្នា «ផលិតផលដូចគ្នា ប្រព្រឹត្តកម្មដូចគ្នា» (គេមិនត្រូវមានប្រព្រឹត្តកម្មខុសគ្នាឡើយ)។ ផលិតផលត្រូវបានធ្វើចំណាត់ថ្នាក់ ៖ សម្បទានតម្លៃថ្នាក់ជាតិ (មាត្រា II) កំណត់ឱ្យសមាជិកនូវបញ្ជីតម្លៃ ដើម្បីផ្ទៀងផ្ទាត់ថា តើផលិតផលត្រូវបានចាត់ទុកជាស្រដៀងគ្នាឬទេ។ សូម្បីតែការលើសបន្តិចបន្តួចក៏ដោយ ក៏ចាត់ទុកជាខុសគ្នាខ្លាំងដែរ។

ប្រសិនបើផលិតផលមិនស្រដៀងគ្នាទេ យើងឆ្លងទៅដំណាក់កាលទី២ ៖ ប្រសិនបើផលិតផលមានលក្ខណៈប្រកួតប្រជែង ប្រកួតប្រជែងដោយផ្ទាល់ ឬអាចជំនួសគ្នាបាន ៖ លក្ខណៈវិនិច្ឆ័យ៤ ៖ (i) ចំណាត់ថ្នាក់តម្លៃនៃផលិតផល (ii) លក្ខណៈរូបវន្តនៃផលិតផល (iii) ការប្រើប្រាស់ចុងក្រោយ (iv) លក្ខណវិនិច្ឆ័យទីផ្សារ។ យើងនឹងផ្ទៀងផ្ទាត់ភាពបត់បែននៃភាពអាចជំនួសគ្នាបាន។ គ្មានភាពខុសគ្នានៃការកំណត់ពន្ធដែលលើសពីកម្រិតអប្បបរមាទេ(មិនអាចប្រហែសបាន មានភាពខុសគ្នានៃការកំណត់ពន្ធ ប៉ុន្តែភាពខុសគ្នានេះត្រូវតែមានលក្ខណៈសមរម្យ)។

មាត្រា III - ២ ត្រូវបានអនុវត្ត ៖ ការរើសអើងតាមច្បាប់ ឬតាមភាពជាក់ស្តែង។ មិនសុទ្ធតែមានចេតនារើសអើងឡើយ។ យើងអាចមានរដ្ឋមួយដែលនឹងអនុម័តច្បាប់ដែលនឹងមានការរើសអើង(ការរើសអើងនេះនឹងត្រូវទទួលទោស)។

អានុភាពជាក់ស្តែងនៃវិធានការ ៖ ក្នុងរឿងក្តីជប៉ុន - ភេសជ្ជៈមានជាតិអាល់កុល ៖ យើងដាក់ចំណោទទៅលើច្បាប់របស់ប្រទេសជប៉ុន ៖ ការកំណត់ពន្ធខុសគ្នាទាក់ទងនឹងផលិតផល Soshu(ប្រទេសជប៉ុន) និងផលិតផល Gin, Whisky ឬ Vodka។ នេះគឺជាផលិតផលប្រកួតប្រជែង និងអាចជំនួសគ្នាបាន។

ប្រទេសបារាំងអនុវត្តការកំណត់ពន្ធ២ប្រភេទទៅតាមទំហំស៊ីឡាំងនៃយានយន្ត ៖ ផលិតផលត្រូវបានពិចារណា ៖ ពន្ធទាំងនោះទាក់ទងនឹងផលិតផលអាមេរិក និងបរទេស។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ប្រទេសកូរ៉េ គឺស្រា soju (២០០) និងស្រា Chile។ គេយកពន្ធខុសៗគ្នាទៅតាមកម្រិតអាល់កុល។*

*ប្រសិនបើភាពខុសគ្នាមានទំហំតូច គេអាចនិយាយបានថា គឺជាប្រព្រឹត្តកម្មជាតិ។*

*ប្រទេសកូរ៉េ - សាច់គោ ៖ អតិថិជនមានចំនួនច្រើន។*

*ខចែងនៃឋានៈប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុត(មាត្រា I) សំដៅឱ្យមានប្រព្រឹត្តកម្មដូចគ្នារវាងផលិតផលនាំចូល ផ្ទុយទៅវិញ ប្រព្រឹត្តកម្មជាតិ(មាត្រា III) សំដៅមិនឱ្យមានការរើសអើងរវាងផលិតផលនាំចូល និងផលិតផលជាតិ។*

## ១.៣- ការសន្យារបស់រដ្ឋ

*បញ្ជីសម្បទានជាតិ ៖ ផ្នែកសំខាន់នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤។ លក្ខន្តិកៈគតិយុត្ត ៖ បញ្ជីគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀង និងមានតម្លៃដូចកិច្ចព្រមព្រៀងដែរ។ ពន្ធគយកំពុងពង្រឹង។ ពន្ធនេះត្រូវបានបង្កកក្នុងរយៈពេល៣ឆ្នាំ និងបន្តឡើងវិញដោយស្វ័យប្រវត្តិ។ ផុតរយៈពេល៣ឆ្នាំនេះ រដ្ឋមួយអាចសម្រេចចិត្តកែប្រែ ប៉ុន្តែប្រសិនបើរដ្ឋនោះមិនកែប្រែទេ គឺទុកនៅដដែល។ គោលដៅនៃការពង្រឹងនេះ គឺដើម្បីជៀសវាងការដំណើរការពន្ធគយឡើងវិញ(ការដំឡើងពន្ធគយ)។ ផុតរយៈពេល៣ឆ្នាំ រដ្ឋមួយអាចដំឡើងពន្ធគយបានប៉ុន្តែត្រូវមានការចរចាជាមួយដៃគូពាណិជ្ជកម្ម។ រដ្ឋទាំងឡាយដែលរងគ្រោះ(មានការប៉ះពាល់) នឹងទាមទារការប៉ះប៉ូវ។*

*សមាជិកមានលទ្ធភាពដំឡើងពន្ធគយរៀងរាល់៣ឆ្នាំម្តងជាថ្នូរនឹងការប៉ះប៉ូវ ដើម្បីជានានូវតុល្យភាពរវាងសិទ្ធិ និងកាតព្វកិច្ច ៖ (១) រដ្ឋអាចបន្ថយពន្ធគយនៅក្នុងវិស័យផ្សេង ២) ឬពង្រឹងពន្ធគយដែលមិនធ្លាប់ពង្រឹងនៅឡើយ។ បើមិនដូច្នេះទេ រដ្ឋដទៃអាចលុបចោលសម្បទានដែលសមមូលគ្នា។ រដ្ឋមួយមិនអាចបំពាក់អាវុធដោយគ្មានថ្នូរបានឡើយ។ នៅពេលគេបន្ថយពន្ធគយឱ្យរដ្ឋមួយ ខចែងនៃប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុតនឹងត្រូវអនុវត្ត ហើយរដ្ឋនោះត្រូវផ្តល់ប្រព្រឹត្តកម្មដូចគ្នាដល់រដ្ឋដទៃដែលមានតម្លៃថ្លៃ។*

*យ៉ាងណាមិញ រដ្ឋទាំងឡាយអាចប្រើប្រាស់ការដំណើរការពន្ធគយឡើងវិញ ដោយប្រើវិធានការការពារខ្លួន ក្នុងលក្ខខណ្ឌតឹងរ៉ឹង និងក្នុងកាលៈទេសៈពិសេស។*

## ២- ពាណិជ្ជកម្មលើសេវាកម្ម

*គោលដៅពីរទាក់ទងនឹងកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម(AGCS) ៖ ភាពទន់ភ្លន់ និងភាពស្មុគស្មាញ។*

ភាពខុសគ្នារវាងកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម គឺកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្មជាកិច្ចព្រម-ព្រៀងគោលគំរូ ៖ គោលការណ៍ និងវិធាន។ កិច្ចព្រមព្រៀងមានភាពស្រពិចស្រពិលដែលធ្វើឱ្យមានការពិបាកយ៉ាងខ្លាំង។ ផលិតផលអាចកំណត់បានយ៉ាងពិបាក និងមានភាពស្មុគស្មាញ ៖ គឺបញ្ហាតម្លៃ និងសីលធម៌ដែលត្រូវបានបញ្ជូនទៅកាន់ការពិភាក្សានយោបាយ។ បញ្ហាសេវាកម្មនេះនឹងដាក់ចំណោទទៅលើសេវាកម្មសាធារណៈដែលមានភាពងាយរងគ្រោះខ្លាំង និងពិបាកធ្វើសេរីភាវូបនីយកម្ម។ យើងមានសមាសភាព៣នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម ៖

សមាសភាពទីមួយ ៖ វិធានដែលអនុវត្តចំពោះសមាជិកក្នុងវិស័យសេវាកម្ម។

សមាសភាពទីពីរ ៖ ឧបសម្ព័ន្ធចំនួន៨ដែលនឹងដោះស្រាយបញ្ហាលើកលែងពន្ធ ហើយឧបសម្ព័ន្ធដទៃទៀតនឹងអនុវត្តចំពោះវិស័យពិសេស គឺវិស័យហិរញ្ញវត្ថុដែលទទួលបានប្រព្រឹត្តកម្មពិសេស។

សមាសភាពទីបី ៖ បញ្ជីនៃការសន្យារបស់សមាជិក។ បញ្ជីទាំងនេះនឹងអនុញ្ញាតឱ្យវាស់វែងកាតព្វកិច្ចដែលដាក់បន្ទុកលើសមាជិកនីមួយៗ។ នេះគឺជាតក្កវិជ្ជានៃការពង្រឹង។ ប្រសិនបើសមាជិកណាមួយធ្វើការសន្យា សមាជិកនោះមិនអាចបកក្រោយវិញបានឡើយ។

## ២.១- វិសាលភាព និងដែនអនុវត្តនៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម

### ២.១.១- ដែនអនុវត្ត

កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្មមិនកំណត់និយមន័យនៃពាក្យសេវាកម្មទេ។ កិច្ចព្រមព្រៀងនេះអនុវត្តចំពោះសេវាកម្មទាំងអស់នៅក្នុងគ្រប់វិស័យ លើកលែងតែសេវាកម្មដែលត្រូវបានផ្តល់ជូននៅក្នុងការអនុវត្តអំណាចរដ្ឋាភិបាល។

សេវាកម្មដែលត្រូវបានផ្តល់នៅក្នុងការអនុវត្តអំណាចរដ្ឋាភិបាលទាំងនេះ គឺជាសេវាកម្មដែលមិនត្រូវបានផ្តល់ ដោយផ្អែកលើមូលដ្ឋានពាណិជ្ជកម្ម ឬដោយប្រកួតប្រជែងជាមួយអ្នកផ្តល់សេវាកម្មមួយ ឬច្រើន។ លើកលែងតែអំណាចស្តេច ៖ នគរបាល កងទ័ព ការកំណត់ពន្ធ និងការទូត។ សេវាកម្មសាធារណៈផ្សេងទៀតចេញមិនផុតពីកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្មឡើយ។ រដ្ឋទាំងអស់មិនមានទស្សនវិស័យដូចគ្នាអំពីសេវាកម្មសាធារណៈនោះទេ។ យើងចង់ផ្តល់វិសាលភាពអតិបរមាដល់កិច្ចព្រមព្រៀង។

មាត្រា១ចែងអំពីវិធានការទាំងអស់របស់រដ្ឋដែលប៉ះពាល់ដល់ពាណិជ្ជកម្មលើសេវាកម្មនៅគ្រប់កម្រិតនៃផ្នែករដ្ឋបាលដូចជា ៖ ថ្នាក់កណ្តាល តំបន់ និងមូលដ្ឋាន។ នៅប្រទេសបារាំង មាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឃុំមួយចំនួនដែលមិនស្ថិតនៅក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម។

ពាណិជ្ជកម្មអន្តរជាតិលើសេវាកម្ម ៖ របៀបផ្តល់សេវាកម្មអន្តរជាតិចំនួនបួន ៖

របៀបទី១ ៖ ការផ្តល់សេវាឆ្លងព្រំដែន ៖ សេវាកម្មមួយត្រូវបានផ្តល់ពីដែនដីរបស់រដ្ឋសមាជិកមួយទៅក្នុងដែនដីរបស់រដ្ឋសមាជិកមួយទៀត។ មានតែសេវាកម្មប៉ុណ្ណោះដែលឆ្លងព្រំដែន ពោលគឺគ្មានការបទ្វាស់ទីរបស់បុគ្គលណាមួយឡើយ ៖ សេវាកម្មប្រឹក្សា សេវាកម្មគណនេយ្យ។

របៀបទី២ ៖ ការប្រើប្រាស់នៅបរទេស ៖ អ្នកប្រើប្រាស់សេវាកម្មធ្វើដំណើរទៅកាន់ដែនដីរបស់រដ្ឋមួយទៀតដើម្បីទទួលបានការផ្តល់សេវា ៖ វិស័យទេសចរណ៍។

របៀបទី៣ ៖ វត្តមានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ៖ វត្តមានពាក់ព័ន្ធនឹងពាណិជ្ជកម្មរបស់អ្នកផ្គត់ផ្គង់សេវាកម្មណាម្នាក់នៅលើដែនដីនៃរដ្ឋសមាជិកមួយទៀត ដើម្បីធ្វើការវិនិយោគបង្កើតសាខាទីភ្នាក់ងារ។

របៀបទី៤ ៖ វត្តមានរបស់រូបវន្តបុគ្គល ៖ មានការអនុញ្ញាតឱ្យពលរដ្ឋបរទេសធ្វើការផ្តល់សេវាកម្មនៅក្នុងរដ្ឋមួយទៀត។

របៀបទី៣ និងទី៤ បង្ហាញឱ្យឃើញថា សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មទាមទារសេរីភាវូបនីយកម្មនយោបាយសាធារណៈ និងច្បាប់ផ្ទៃក្នុង។ គឺច្បាប់សាធារណៈដែលចោទជាឧបសគ្គដល់សេរីភាវូបនីយកម្មសេវាកម្ម។

## ២.១.២- ដំណើរការនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងផ្អែកលើបទប្បញ្ញត្តិ២ប្រភេទ។ ដំបូងគឺកាតព្វកិច្ច និងវិន័យទូទៅដែលអនុវត្តចំពោះសមាជិកទាំងអស់ បន្ទាប់មកគឺវិធានពិសេសដែលអាចសម្រេចបានតាមជម្រើសរបស់រដ្ឋ។ កិច្ចព្រមព្រៀងដំណើរការដោយផ្អែកលើតក្កវិជ្ជានៃការសន្យាជាវិជ្ជមានក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម ៖ វិស័យមួយនឹងបើកចំហឱ្យមានការប្រកួតប្រជែងបានតែក្នុងករណីដែលរដ្ឋមិនបានយល់ព្រមយ៉ាងច្បាស់លាស់ប៉ុណ្ណោះ។ រដ្ឋទាំងអស់ការពារសេវាកម្មតាមរយៈច្បាប់ដែលនឹងហាមប្រាម ឬដាក់កំហិតការទទួលសេវាកម្ម។

## ២.១.២.១- គោលការណ៍នៃបញ្ជីសន្យាជាវិជ្ជមាន

វិស័យ ឬអនុវិស័យសេវាកម្មបើកចំហឱ្យមានការប្រកួតប្រជែងតែក្នុងករណីដែលរដ្ឋបានចុះវិស័យ ឬអនុវិស័យនោះនៅក្នុងការសន្យាផ្នែកសេវាកម្ម និងបានយល់ព្រមយ៉ាងច្បាស់លាស់សម្រាប់របៀបផ្តល់សេវាកម្មនីមួយៗប៉ុណ្ណោះ។ ដើម្បីអាចបើកទីផ្សារសេវាកម្មបាន គេត្រួតពិនិត្យបញ្ជីសន្យា។ សហគមន៍អឺរ៉ុបចង់ផ្តល់ការត្រួតពិនិត្យបរិស្ថាន ប៉ុន្តែការធ្វើចំណាត់ថ្នាក់នេះមិន

អាចប្រើប្រាស់បានដោយងាយស្រួលទេ។ បច្ចុប្បន្ន រដ្ឋសមាជិកទាំងអស់មិនមែនសុទ្ធតែបានដាក់បញ្ជីនោះទេ មានតែសហភាពអឺរ៉ុបប៉ុណ្ណោះដែលបានធ្វើសេរីភាវូបនីយកម្មតាំងពីយូរណាស់មកហើយ។ លទ្ធភាពចូលទៅកាន់ទីផ្សារ និងប្រព្រឹត្តកម្មជាតិ គឺជាគោលការណ៍ដែលកើតចេញពីបញ្ជីរបស់រដ្ឋសមាជិក។ លុះត្រាតែបញ្ជីទាំងនោះមិនត្រូវបានដាក់ លុះត្រាតែគោលការណ៍ទាំងនេះមិនអាចយកមកអនុវត្តបានឡើយ។

លទ្ធភាពចូលទៅកាន់ទីផ្សារ ៖ រដ្ឋសមាជិកត្រូវបញ្ជាក់ថា តើខ្លួនចង់ផ្តល់លទ្ធភាពចូលទៅកាន់ទីផ្សារមួយណា។ មានតែការរឹតត្បិតដែលបានបញ្ជាក់ប៉ុណ្ណោះដែលអាចត្រូវបានរក្សាទុក។ ការរឹតត្បិតទាំងនេះអាចទាក់ទងនឹងអ្នកផ្តល់សេវា ដាក់កំហិតតម្លៃសរុបនៃប្រតិបត្តិការ ចំនួនប្រតិបត្តិការ ចំនួនរូបវន្តបុគ្គល ទម្រង់ពាណិជ្ជកម្មក្នុងរបៀបទី៣ ឬកម្រិតនៃការចូលទុន។

ប្រព្រឹត្តកម្មជាតិ ៖ រដ្ឋត្រូវធ្វើប្រព្រឹត្តកម្មដូចៗគ្នាចំពោះអ្នកផ្តល់សេវាជាតិ និងបរទេស។ ប្រព្រឹត្តកម្មត្រូវដូចគ្នា និងមិនត្រូវមានការរើសអើងឡើយ។ ប៉ុន្តែ អាចមានភាពខុសគ្នាផ្នែកទម្រង់រវាងអ្នកផ្តល់សេវាបរទេស និងជាតិ។ ប៉ុន្តែភាពខុសគ្នាផ្នែកទម្រង់នៅក្នុងប្រព្រឹត្តកម្មទាំងនេះមិនត្រូវផ្តល់ភាពអនុគ្រោះជាងដល់អ្នកផ្តល់សេវាជាតិឡើយ។ ប្រព្រឹត្តកម្មជាតិ ៖ អ្នកផ្តល់សេវាបរទេស និងជាតិមិនស្ថិតនៅក្នុងលក្ខខណ្ឌដូចគ្នាទេ។ ដូច្នេះប្រសិនបើអ្នកធ្វើប្រព្រឹត្តកម្មដូចគ្នានោះវាជាការរើសអើងហើយ។ មានតែការរើសអើងដែលនៅសល់ប៉ុណ្ណោះដែលអាចធ្វើទៅបាន គឺការរើសអើងដែលបានចុះនៅក្នុងបញ្ជី។ រដ្ឋមួយអាចរក្សាភាពផ្តាច់មុខក្នុងវិស័យមួយ ឬច្រើនបាន។ រដ្ឋមួយអាចបើកឱ្យមានការប្រកួតប្រជែងបាន ប៉ុន្តែដោយរក្សាទុកទីផ្សារសម្រាប់អ្នកផ្តល់សេវាជាតិ គឺបណ្តាសហគ្រាសរដ្ឋនានា។ ត្រូវធ្វើបញ្ជីសេរីភាវូបនីយកម្មដោយប្រុងប្រយ័ត្ន។ ការសន្យាទាំងនោះមិនបានបង្ខំឱ្យមុជកាន់តែជ្រៅទៅក្នុងសេរីភាវូបនីយកម្មទេ ប៉ុន្តែការសន្យាទាំងនោះមិនត្រូវដើរបកក្រោយវិញឡើយ។ យើងអាចពិនិត្យសើរើការសន្យាឡើងវិញរៀងរាល់៣ឆ្នាំម្តង ប៉ុន្តែគោលការណ៍ប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុតអាចមានផលវិបាកយ៉ាងធ្ងន់ធ្ងរក្នុងករណីមានការប៉ះប៉ូវ។ គឺមានតែគោលការណ៍ការពារខ្លួនប៉ុណ្ណោះដែលអាចត្រូវបានប្រើប្រាស់។ យើងកំពុងស្ថិតក្នុងរយៈពេលមិនច្បាស់លាស់ខ្លាំងនៅឡើយ ហើយវានៅតែមានការស្រពិចស្រពិលខ្លាំង។

## ២.១.២.២- កាតព្វកិច្ចឥតលក្ខខណ្ឌ

កាតព្វកិច្ចឥតលក្ខខណ្ឌ ៖ រដ្ឋទោះបីជាមិនបានធ្វើការសន្យាក៏ដោយ ក៏ត្រូវគោរពតាមកាតព្វកិច្ចដែរ។ កាតព្វកិច្ចទាំងនោះគឺជាកាតព្វកិច្ចឥតលក្ខខណ្ឌ ៖

- ប្រព្រឹត្តកម្មរបស់ប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុត ៖ ប្រសិនបើរដ្ឋមួយយល់ព្រម

ធ្វើសេរីភាវូបនីយកម្មដល់រដ្ឋមួយទៀត រដ្ឋនោះត្រូវលាតសន្ធឹងកាតព្វកិច្ចដែលបានធ្វើសម្បទាននោះទៅដល់រដ្ឋផ្សេងទៀត។ លទ្ធភាពធ្វើបដិប្បញ្ញត្តិលើខចែងនៃឋានៈប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុតធ្វើឡើងក្នុងក្របខ័ណ្ឌការលើកលែង។ លក្ខខណ្ឌចម្បង ៖ នៅពេលចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ឬក្នុងពេលដែលអង្គការពាណិជ្ជកម្មពិភពលោកចូលជាធរមាន។ រដ្ឋជាច្រើន ដូចជា សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប បានបង្កើតអញ្ញត្រកម្មក្នុងក្របខ័ណ្ឌសេវាកម្ម(វិស័យមួយថ្មី)។ ដែនកំណត់ទីមួយ ការលើកលែងទាំងនេះត្រូវមានទម្រង់ផ្តល់គ្រោះថ្នាក់តិចតួចបំផុតតាមដែលអាចធ្វើទៅបានចំពោះបណ្តូរសេវាកម្ម។ រដ្ឋទាំងអស់ត្រូវជៀសវាងប្រើប្រាស់ប្រព័ន្ធកូតា។ សហភាពអឺរ៉ុបបានបង្កើតអញ្ញត្រកម្មមួយដែលទាក់ទងនឹងវិស័យភាពយន្ត ដើម្បីជានាទូវពិពិធកម្មវប្បធម៌ ៖ ការទប់ទល់នឹងខ្សែភាពយន្តអាមេរិក។ គេប្រើកូតា។ ជាញឹកញាប់ សហរដ្ឋអាមេរិកបានចុះកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីបើកទីផ្សារទៅរកខ្សែភាពយន្តអាមេរិក។ គ្មានខ្សែភាពយន្តអូស្ត្រាលីទេ។ គឺជាគ្រោះថ្នាក់។ ដែនកំណត់ទីពីរ រយៈពេលនៃការលើកលែង ៖ ប្រសិនបើការលើកលែងមានរយៈពេលវែងជាង៥ឆ្នាំ ការលើកលែងត្រូវទទួលការត្រួតពិនិត្យ ហើយមិនត្រូវមានរយៈពេលលើសពី១០ឆ្នាំទេ។

- តម្លាភាព ៖ រដ្ឋត្រូវ ៖ (i) ចេញផ្សាយបទបញ្ញាទាំងអស់ដែលទាក់ទងនឹងពាណិជ្ជកម្មសេវាកម្ម (ii) បង្កើតការិយាល័យជាតិទំនាក់ទំនងដែលនឹងបម្រើដល់រដ្ឋផង និងអ្នកផ្តល់សេវាបរទេសផង។ បណ្តាប្រទេសកំពុងអភិវឌ្ឍមិនមានសមត្ថភាពផ្នែករដ្ឋបាល និងបន្ទុកហិរញ្ញវត្ថុទេ។ រដ្ឋអាចបដិសេធការចេញផ្សាយបទបញ្ញាមួយចំនួនដោយហេតុផលរក្សាការសម្ងាត់ពាណិជ្ជកម្ម។ អត្ថបទទាំងនោះត្រូវធ្វើការបកស្រាយ។
- កាតព្វកិច្ចឥតលក្ខខណ្ឌដទៃទៀត ៖ ធៀបនឹងខ្លឹមសារនៃបទបញ្ញា រដ្ឋទាំងអស់អាចកំណត់កម្រិតគុណភាព កម្រិតតម្លៃដែលខ្លួនចង់បន្តគោលដៅនយោបាយសាធារណៈផ្សេងទៀត។ ដែនកំណត់ពីរនឹងត្រូវគ្រប់គ្រងលើសេរីភាពទាំងនេះ ៖ (១) ការគ្រប់គ្រងបទបញ្ញាទាំងនេះដោយសមហេតុផល មិនលម្អៀង និងអព្យាក្រឹត្យ (២) បង្កើតលទ្ធភាពធ្វើឧបាស្រ័យប្រកបដោយប្រសិទ្ធភាព(ចៅក្រម) សម្រាប់អ្នកផ្តល់សេវា(យន្តការរបស់អង្គការពាណិជ្ជកម្មពិភពលោក គឺជាយន្តការអន្តររដ្ឋ។ អ្នកផ្តល់សេវាប្តឹងទៅរដ្ឋ រដ្ឋត្រូវត្រួតពិនិត្យថា តើខ្លួនចង់ទទួលយល់ស្រប នឹងបណ្តឹងដែរឬទេ)។ ក្នុងករណីជាច្រើន វិវាទត្រូវដោះស្រាយក្នុងប្រទេស។
- ប្រភេទកាតព្វកិច្ចផ្សេងទៀត ៖ ការទទួលស្គាល់ទៅវិញទៅមកទាក់ទងនឹងគុណវុឌ្ឍិនិយាមបច្ចេកទេស និងអាជ្ញាប័ណ្ណ។ ប្រទេសជឿនលឿនមិនត្រូវបដិសេធផ្តល់លទ្ធភាពចូលទៅកាន់ទីផ្សាររបស់ខ្លួនដោយផ្អែកលើនិយាមបច្ចេកទេសរបស់ប្រទេសកំពុងអភិវឌ្ឍឡើយ។

# ផ្នែកទី៥

## ការពង្រឹងច្បាប់ស្ដីពីពាណិជ្ជកម្មទំនិញ ពីកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៤៧ ទៅកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤

*សារៈសំខាន់នៃពាណិជ្ជកម្មផ្ដោតលើពាណិជ្ជកម្មទំនិញ(៩.០០០ពាន់លានដុល្លារក្នុងមួយឆ្នាំ)។*

### ១- ទិដ្ឋភាពទូទៅ

*កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីស្ដីពីពាណិជ្ជកម្មទំនិញ គឺជាផ្នែកលម្អិតជាងគេបំផុតនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក។ យើងមានកិច្ចព្រមព្រៀងធំៗចំនួនពីរប្រភេទ ៖ (i) កិច្ចព្រមព្រៀងទូទៅ(កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤) និង (ii) កិច្ចព្រមព្រៀងពិសេស។*

*កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤មិនធ្វើឱ្យគ្រឡាប់ចាក់ដល់កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៤៧ទេ ប៉ុន្តែមានការកែប្រែធំៗមួយចំនួនៗដែនអនុវត្ត ៖ បរិមាណផលិតផលកាន់តែច្រើន វិស័យកសិកម្ម និងវាយនភណ្ឌ។ មិនមានវិស័យដែលរួចផុតពីប្រព័ន្ធពហុភាគីឡើយ។*

*កិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ មានភាពស្មុគស្មាញ ៖ ក្នុងផ្នែកអត្ថបទនៃកិច្ចព្រមព្រៀងនេះ(កិច្ចព្រមព្រៀងទូទៅ) គេឃើញមានកិច្ចព្រមព្រៀងផ្សេងៗ(អនុស្សរណៈ)ដែលបញ្ជាក់អំពីចំណុចមួយចំនួន ៖ មាត្រា២៤ដែលទាក់ទងនឹងសមាហរណកម្មក្នុងតំបន់ អនុស្សរណៈចូលជាសមាជិក និងកិច្ចព្រមព្រៀងពិសេស(កិច្ចព្រមព្រៀងចំនួន១២)។ ការចាត់ថ្នាក់ជាពីរប្រភេទ ៖ កិច្ចព្រមព្រៀងទាក់ទងនឹងគោលការណ៍ និងកិច្ចព្រមព្រៀងទាក់-ទងនឹងផលិតផល។ កិច្ចព្រមព្រៀងមួយចំនួនជាកិច្ចព្រមព្រៀងថ្មី(៧)។ កិច្ចព្រមព្រៀងផ្សេងទៀតមានរួចហើយនៅក្នុងក្រមដែលបានចរចាជាថ្មីនៅក្រោយវគ្គចរចាក្រុងតូក្យូ(៥) ៖ ការប្រឆាំងនឹងការលក់បង្ខូចថ្លៃ របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ការវាយតម្លៃពន្ធគយ នីតិវិធីផ្ដល់អាជ្ញាប័ណ្ណនាំចូល(PLI) និងឧបត្ថម្ភកធន និងវិធានការប៉ះប៉ូវ(SMC)។ កិច្ចព្រមព្រៀងដែលប្រើប្រាស់ច្រើន(៤) ៖ ការប្រឆាំងនឹងការលក់បង្ខូចថ្លៃ កិច្ចព្រមព្រៀងស្ដីពីការអនុវត្តវិធានការអនាម័យ*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងកូតតាមអនាម័យ(SPS) កិច្ចព្រមព្រៀងស្តីពីកសិកម្ម និងកិច្ចព្រមព្រៀងស្តីពីការការពារសុវត្ថិភាព។ មានកិច្ចព្រមព្រៀងតិចតួចដែលពាក់ព័ន្ធនឹងពន្ធគយ និងវិធាននៃប្រភពដើម។

កិច្ចព្រមព្រៀង ៖ កិច្ចព្រមព្រៀងស្តីពីកសិកម្ម កិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យ និងកូតតាមអនាម័យ កិច្ចព្រមព្រៀងប្រឆាំងនឹងការលក់បន្ថូចថ្លៃ កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម(OTC) កិច្ចព្រមព្រៀងស្តីពីពន្ធគយ កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យទំនិញមុនពេលផ្ទុក(IAE) កិច្ចព្រមព្រៀងស្តីពីវិធាននៃប្រភពដើម កិច្ចព្រមព្រៀងស្តីពីនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភកធន និងវិធានការប៉ះប៉ូវ កិច្ចព្រមព្រៀងស្តីពីការការពារសុវត្ថិភាព កិច្ចព្រមព្រៀងស្តីពីវិធានការវិនិយោគទាក់ទិននឹងពាណិជ្ជកម្ម(MIC) និងកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ និងសម្លៀកបំពាក់(ATV)។ ដោយសារកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ និងសម្លៀកបំពាក់បានបញ្ចប់នៅឆ្នាំ២០០៥ យើងមានកិច្ចព្រមព្រៀងចំនួន១១។

## ២- ការពង្រីកពាណិជ្ជកម្មទំនិញ

ការពង្រីកទាំងនេះអាស្រ័យលើចំណុចពីរយ៉ាង ៖ ការបើកទីផ្សារផលិតផលឧស្សាហកម្ម និងការបញ្ចូលកសិកម្មទៅក្នុងពាណិជ្ជកម្មពហុភាគី។

## ២.១- ការបើកទីផ្សារផលិតផលឧស្សាហកម្ម

ការបើកទីផ្សារផលិតផលឧស្សាហកម្មកើតឡើងដោយសារការធ្លាក់ចុះជាលំដាប់នៃពន្ធគយ។ នៅដើមវគ្គចរចាក្រុងអ៊ុយរុយហ្គាយ គោលដៅគឺត្រូវពង្រីងវិស័យថ្មីៗជាច្រើន និងកាត់បន្ថយឧបសគ្គតម្លៃយ៉ាងតិចមួយភាគបី(១/៣)។ គេបន្ថយពី៤០%(អត្រាជាមធ្យមនៃពន្ធគយ) នៅដើមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម មកត្រឹម៥% នៅដើមវគ្គចរចាក្រុងអ៊ុយរុយហ្គាយ មកត្រឹម៣,៥% ក្រោយវគ្គចរចា។ នៅក្នុងវិស័យមួយចំនួន ពន្ធមានចំនួន០%។ នៅក្នុងសហភាពអឺរ៉ុប ការនាំចូលផ្នែកឧស្សាហកម្ម ៥០%ត្រូវបង់ពន្ធគយ០%។ គឺប្រទេសកំពុងអភិវឌ្ឍដែលត្រូវខិតខំប្រឹងប្រែងបន្ថយពន្ធគយ។

កិច្ចព្រមព្រៀងតែមួយគត់ដែលត្រូវបានគ្រោងនឹងលុបចោលនៅក្នុងរយៈពេល១០ឆ្នាំ គឺវាយនភណ្ឌដែលជាវិស័យដ៏ងាយរងគ្រោះ និងតែងតែមានភាពតានតឹងរវាងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៧៤ តាមរយៈទីភ្នាក់ងាររូបិយវត្ថុបារាំង វិស័យវាយនភណ្ឌបានចាកចេញពីពាណិជ្ជកម្មពហុភាគី ៖ សម្រាប់ប្រទេសជឿនលឿន គឺត្រូវធានានូវដំណើររលូននៃទីផ្សារ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍវិញ គឺត្រូវរឹតត្បិតការនាំចេញក្នុងវិស័យដែលខ្លួនទទួលបានការអនុគ្រោះប្រហាក់ប្រហែល។ តម្លៃផលិតកម្មមានតម្លៃទាបខ្លាំង។ នេះគឺ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាបញ្ហានៃការលក់ក្នុងតម្លៃថោកដើម្បីសង្គម។ វាយនភណ្ឌមានចំនួន៧%នៃពាណិជ្ជកម្មទំនិញ។ តាមការព្យាករណ៍របស់ទីភ្នាក់ងាររូបិយវត្ថុបារាំង ៖ (១) ប្រទេសអភិវឌ្ឍផ្តល់កូតាផលិតផលដែលត្រូវបានចរចាឡើងវិញ (២) យន្តការការពារខ្លួនក្នុងករណីធ្វើឱ្យចលាចលទីផ្សារ( លំហូរផលិតផល ឬក្នុងករណីតម្លៃទាបខ្លាំង)។ ៨០%នៃបណ្តូរទំនិញវាយនភណ្ឌត្រូវបានគ្រប់គ្រងដោយទីភ្នាក់ងាររូបិយវត្ថុបារាំង។ គឺជាកិច្ចព្រមព្រៀងមួយដើម្បីការពារផលិតផលជាតិ។ ចំពោះប្រទេសកំពុងអភិវឌ្ឍ សម្ព័ន្ធមិត្តរបស់ពួកគេបានបែកបាក់គ្នា ដោយសារប្រទេសមួយចំនួនដូចជា ឥណ្ឌា និងប៉ាគីស្ថាននៅពីលើប្រទេសដទៃ ហើយប្រទេសដទៃត្រូវទប់ស្កាត់ផលិតផលរបស់ឥណ្ឌា និងប៉ាគីស្ថាន ដើម្បីការពារទីផ្សាររបស់ខ្លួន។ ចំពោះប្រទេសកំពុងអភិវឌ្ឍ មានចែងលក្ខខណ្ឌវិវត្តន៍គឺកូតានឹងដំឡើង៥-៦%ជារៀងរាល់ឆ្នាំ។

ដោយសារអង្គការពាណិជ្ជកម្មពិភពលោក វាយនភណ្ឌនឹងធ្វើសមាហរណកម្មបន្តិចម្តងៗតាមរយៈកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ និងសម្លៀកបំពាក់(ATV-១៩៩៥)ក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ កិច្ចព្រមព្រៀងពឹងផ្អែកលើការដំឡើងតាមដំណាក់កាល គឺបើកចំហទីផ្សាររបស់ប្រទេសអភិវឌ្ឍ។ កិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ និងសម្លៀកបំពាក់អនុវត្តចំពោះសមាជិកទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក ៖ (i) យន្តការការពារខ្លួនក្នុងករណីផលិតករជាតិនៃប្រទេសអភិវឌ្ឍទទួលរងមហន្តរាយធ្ងន់ធ្ងរ ប៉ុន្តែផ្តោតគោលដៅទៅលើអ្នកនាំចេញជាក់លាក់។ ការរឹតត្បិតអាចផ្តោតទៅលើរដ្ឋតែមួយ។ លក្ខខណ្ឌតឹងរ៉ឹងចំពោះការចាប់ផ្តើមកិច្ចព្រមព្រៀង ៖ កំណើនយ៉ាងគំហុកនៃការនាំចូល។ រដ្ឋត្រូវបញ្ជាក់តាមផ្លូវច្បាប់អំពីការចាប់ផ្តើមវិធានការការពារខ្លួន។ នៅឆ្នាំ២០០៥ បណ្តាប្រទេសនៃសហគមន៍អឺរ៉ុបបានចុះកិច្ចព្រមព្រៀងទ្វេភាគីស្វ័យកំណត់ជាមួយប្រទេសចិនរហូតដល់ឆ្នាំ២០០៩។

អំបោះសំឡី ៖ ប្រទេសអាហ្វ្រិកមួយចំនួនបានចាប់ផ្តើមយន្តការអំបោះសំឡី ដើម្បីដណ្តើមទីផ្សាររបស់ប្រទេសអភិវឌ្ឍឱ្យបានច្រើន ប៉ុន្តែមិនបានសម្រេចឡើយ។ អ្វីៗត្រូវបានពាំងស្ទះដូចវិស័យដទៃទៀតនៅក្នុងវគ្គចរចាទីក្រុងដូហា។

## ២.២- ការបញ្ចូលវិស័យកសិកម្ម

កសិកម្មត្រូវបានកាត់ចេញក្នុងទសវត្សរ៍ទី៥០ដោយសហរដ្ឋអាមេរិក។ រដ្ឋទាំងអស់បានឯកភាពបញ្ចូលវិស័យកសិកម្ម ប៉ុន្តែហេតុផលគឺមិនដូចគ្នានោះទេ។ សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក និងក្រុម CAIRNS បណ្តាប្រទេសដែលមិនត្រូវការឧបត្ថម្ភកជនខាងក្នុង(អូស្ត្រាលី នូវែលហ្សេឡង់ និងឥណ្ឌា)។ ក្រុមបណ្តារដ្ឋ CAIRNS ចង់ធ្វើសេរីភាវូបនីយកម្មដើម្បីផលប្រយោជន៍របស់ខ្លួន។ បណ្តាប្រទេសនាំចូលក្រៅពីផលិតផលកសិកម្មដែលត្រូវការនាំចូល មាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អត្ថប្រយោជន៍ក្នុងការធ្វើសេរីភាវូបនីយកម្ម។ បញ្ហាកសិកម្មគឺជាបញ្ហាដ៏សេរីបំផុត។ សហភាពអឺរ៉ុបមិនអាចទ្រទ្រង់ថ្លៃឧបត្ថម្ភកធនបានទេ។ វិស័យកសិកម្មដែលពន្យឺតយ៉ាងខ្លាំងដល់វគ្គចរចាក្រុងអ៊ុយរុយហ្គាយ(រហូតដល់ឆ្នាំ១៩៩៤)។ ប្រទេសបារាំងជាប្រទេសដែលត្រូវបានការពារខ្លាំងជាងគេបំផុតក្នុងវិស័យកសិកម្ម ហើយប្រទេសបារាំងបានពន្យឺតដល់វគ្គចរចា។

វិស័យកសិកម្មមានការទាក់ទងនឹងកិច្ចព្រមព្រៀង២ ៖ កិច្ចព្រមព្រៀងស្តីពីកសិកម្ម និងកិច្ចព្រមព្រៀងស្តីពីអនាម័យ និងភូតគាមអនាម័យ(SPS)។

## ២.២.១- កិច្ចព្រមព្រៀងស្តីពីកសិកម្ម

យើងនឹងឃើញជាតុផ្សំធំៗ៣ ៖ (i) វិធាន និងគោលការណ៍ដែលទាក់ទងនឹងពាណិជ្ជកម្មផលិតផល (ii) បញ្ជីសន្យា និងសម្បទានទាក់ទងនឹងលទ្ធភាពចូលទៅកាន់ទីផ្សារ (iii) សេចក្តីសម្រេចថ្នាក់ក្រសួងទាក់ទងនឹងបណ្តាប្រទេសអភិវឌ្ឍតិចតួច និងប្រទេសកំពុងអភិវឌ្ឍដែលនាំចូលក្រៅពីផលិតផលចំណីអាហារ។

ដែនអនុវត្តន៍ ៖ ទាក់ទងនឹងវិធានការទាំងអស់ដែលប៉ះពាល់ដល់ពាណិជ្ជកម្មផលិតផលកសិកម្ម។ មានវិធានការ៣ប្រភេទដែលអាចមានផលប៉ះពាល់អវិជ្ជមាន ៖ (i) ឧបត្ថម្ភកធនដល់ការនាំចេញ (ii) ការគាំទ្រផ្ទៃក្នុង(ផ្តល់ប្រាក់ដល់ផលិតករ គឺសហរដ្ឋអាមេរិក) (iii) វិធានការនៅតាមព្រំដែនដែលគ្រប់គ្រងការនាំចូល។ សម្រាប់វិធានការនីមួយៗ រដ្ឋទាំងអស់នឹងធ្វើការសន្យាដែលនឹងត្រូវចុះក្នុងបញ្ជី។ កិច្ចព្រមព្រៀងចែងអំពីវិន័យពាក់ព័ន្ធនឹងការចូលទៅកាន់ទីផ្សារ ការគាំទ្រផ្ទៃក្នុង និងឧបត្ថម្ភកធនដល់ការនាំចេញ។ មានប្រព័ន្ធសម្គាល់ និងដាក់កូដផលិតផលយ៉ាងស៊ីចង្វាក់។ យើងអាចឃើញ (i) ផលិតផលធ្វើពីអង្ករ ស្រូវសាឡី ពោត ទឹកដោះគោ និងសត្វរស់ (ii) ផលិតផលក្លាយ ដូចជាម្សៅ នំប៉័ង ប៊ីរ ហ្វ្រូម៉ាស និង (iii) ផលិតផលកែច្នៃ ដូចជា សាច់ក្រកសូកូឡា គេសជ្ជៈមានជាតិអាល់កុល ដូចជាស្រា ថ្នាំជក់ ផលិតផលកសិកម្ម ប៉ុន្តែមិនមែនចំណីអាហារ ដូចជាអំបោះសំឡី សូត្រ អំបោះឡែន កៅស៊ូ។ ត្រី និងផលិតផលធ្វើពីត្រីមិនចាត់ទុកថាជាផលិតផលកសិកម្មទេ។ វិធានការដែលដាក់កំហិតលទ្ធភាពចូលទៅកាន់ទីផ្សារ ៖ កូតា របាំងពន្ធគយ។

ដំណាក់កាលទីមួយ ៖ ការកែច្នៃ ៖ ការផ្លាស់ប្តូរគឺត្រូវលុបចោល ការរឹតត្បិតផ្នែកបរិមាណនិងត្រូវកែប្រែវាឱ្យទៅជារបាំងពន្ធគយ(ត្រូវបានអនុញ្ញាត)។ សមាជិកបានគិតគូរធ្វើការកំណត់ពន្ធគយ និងបំប្លែងរបាំងមិនមែនពន្ធគយទៅជាពន្ធគយ(មានតម្លាភាពខ្ពស់)។

ដំណាក់កាលទីពីរ ៖ ចាប់ផ្តើមការកាត់បន្ថយពន្ធគយ។ ពន្ធគយត្រូវកាត់បន្ថយ៣៦% សម្រាប់ប្រទេសអភិវឌ្ឍក្នុងរយៈពេល៦ឆ្នាំក្រោយ និង២៤%ជាមធ្យមក្នុងរយៈពេល១០ឆ្នាំក្រោយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់ប្រទេសកំពុងអភិវឌ្ឍ។ ពុំមានការសន្យាកាត់បន្ថយណាមួយសម្រាប់បណ្តាប្រទេសអភិវឌ្ឍតិចតួចទេ។ ដោយសារតែវាជាមធ្យមភាគ ភាគរយនេះអាចប្រែប្រួល ប៉ុន្តែរដ្ឋត្រូវបានតម្រូវឱ្យបន្ថយយ៉ាងតិច១៥%នៃថ្លៃពន្ធគយដល់ផលិតផលងាយខូចខាត។ បច្ចុប្បន្ន សេរីភាវូបនីយកម្មនៅមានកម្រិតខ្លាំង។ ឧទាហរណ៍ សហភាពអឺរ៉ុបមិនផ្តល់ការបន្ថយសម្រាប់លទ្ធភាពចូលទៅកាន់ទីផ្សារទេ។

ការគាំទ្រផ្ទៃក្នុង (i) ការគាំទ្រដែលមិនមាន ឬមានឥទ្ធិពលតិចតួចទៅលើពាណិជ្ជកម្ម (ប្រភេទពណ៌បៃតង) ការគាំទ្រសម្រាប់ការទិញផលិតផលកសិកម្មត្រូវបានអនុញ្ញាត (ii) ការគាំទ្រដែលមានអតុល្យភាពទៅលើពាណិជ្ជកម្ម គឺការទិញដែលធ្វើឡើងដោយអំណាចសាធារណៈក្នុងតម្លៃកំណត់មួយ(ប្រភេទពណ៌ទឹកក្រូច)។ ការគាំទ្រទាំងនោះនឹងត្រូវពិនិត្យមើលថាតើវិធាននេះត្រូវគ្នាជាមួយវិធានពាណិជ្ជកម្មពហុភាគីដែរឬអត់។ ការគាំទ្ររបស់ប្រទេសកំពុងអភិវឌ្ឍដល់កសិកររបស់ខ្លួនមិនមែនជាឧបសគ្គទេ ពីព្រោះការគាំទ្រទាំងនេះអនុគ្រោះដល់ការអភិវឌ្ឍ។

ឧបត្ថម្ភកធនដល់ការនាំចេញ ៖ សមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកមានកាតព្វកិច្ចត្រូវបន្ថយឧបត្ថម្ភកធនដល់ការនាំចេញ ៖ ៣៦% រយៈពេល៦ឆ្នាំ សម្រាប់ប្រទេសអភិវឌ្ឍ ២៤% រយៈពេល១០ឆ្នាំ សម្រាប់ប្រទេសកំពុងអភិវឌ្ឍ។ ផលិតផលកសិកម្មដែលជាកម្មវត្ថុនៃជំនួយស្បៀងអាហារសម្រាប់ប្រទេសដែលមានតម្រូវការ មិនត្រូវបានរាប់បញ្ចូលឡើយ។

យន្តការការពារខ្លួន ៖ រដ្ឋមួយអាចដំឡើងពន្ធគយបាន ប្រសិនបើមានការបន្ថយថ្លៃនាំចូល ឬការបង្កើនផលិតផលនាំចូលលើសពីកម្រិតកំណត់។ លក្ខខណ្ឌ ៖ (i) ដាក់កំហិតទំហំនៃការដំឡើងដល់កម្រិតណាមួយ យើងមិនអាចដំឡើងពន្ធគយលើសពី១/៣នៃពន្ធគយធម្មតាបានទេ (ii) មិនត្រូវលើសពីមួយឆ្នាំទេ។ យើងមិនចាំបាច់បង្ហាញភ័ស្តុតាងនៃមហន្តរាយឡើយ(ត្រូវបានរិះគន់)។

## ២.២.២- កិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ(SPS)

ជាវិធានការដើម្បីធានាកុំឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈរបស់មនុស្សដែលបណ្តាលមកពីផលិតផលចំណីអាហារ និងដើម្បីធានាសុខភាពសត្វ និងការអភិរក្សរុក្ខជាតិ។ វិធានការអនាម័យ និងភូតគាមអនាម័យត្រួតពិនិត្យលើបណ្តូរទំនិញ។ ចំពោះគុណវិបត្តិវិញ លទ្ធផលខុសពីការរំពឹងទុកនៃវិធានការប្រភេទនេះគឺការការពារទីផ្សារជាតិ។ វាជាតក្កវិជ្ជារបស់អង្គការពាណិជ្ជកម្មពិភពលោកដែលធ្វើឱ្យមានសុខដុមកម្មរវាងវិធានការរបស់បណ្តារដ្ឋជាសមាជិកដែលជាបទដ្ឋានអន្តរជាតិយោងដើម្បីអនុវត្តសុខដុមកម្មនេះ។ អង្គការស្បៀងអាហារពិភពលោក និងអង្គការសុខភាពពិភពលោកមានគណៈកម្មការរួមមួយគឺ CODEX ALIMENTARIUS ដើម្បី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្កើតបទដ្ឋានអន្តរជាតិ។ រដ្ឋទាំងអស់មានសេរីភាពក្នុងការបង្កើតវិធានការតឹងរ៉ឹងជាង ប៉ុន្តែមានលក្ខខណ្ឌដែលត្រូវគោរពតាម ៖ ការបញ្ជាក់អះអាងតាមបែបវិទ្យាសាស្ត្រ ដើម្បីអះអាងពីភាពចាំបាច់នៃវិធានការតឹងរ៉ឹងជាង ឧទាហរណ៍ ភាពមានគ្រោះថ្នាក់នៃផលិតផល។

កាតព្វកិច្ចតម្លាភាពខ្ពស់ ៖ សមាជិកទាំងឡាយត្រូវចេញផ្សាយវិធានការទាក់ទងនឹងអនាម័យ និងភូតគាមអនាម័យដែលអនុវត្តដោយមានការរើសអើង ៖ ប្រព្រឹត្តកម្មជាតិ និងឋានៈប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុត។ ប្រទេសអភិវឌ្ឍជំរុញការអនុវត្ត ចំណែកប្រទេសកំពុងអភិវឌ្ឍអាចទទួលបានរយៈពេលអនុគ្រោះមួយ។ ប្រទេសអភិវឌ្ឍតិចតួចរហូតដល់ឆ្នាំ២០០០។ ការពន្យាររយៈពេលអនុគ្រោះអាចត្រូវផ្ដល់ជូន ដើម្បីពន្យារពេលការអនុវត្តកិច្ចព្រមព្រៀង។

វិធានការប្រុងប្រយ័ត្ន ៖ ហានិភ័យ និងការខូចខាតមិនត្រូវបានគេដឹងឡើយ អាចជាហានិភ័យ ឬអាចមិនមែនជាហានិភ័យ។ គោលការណ៍នេះត្រូវគ្នាជាមួយនឹងពាណិជ្ជកម្មពហុភាគី ប៉ុន្តែក្នុងលក្ខខណ្ឌមួយចំនួន។ រដ្ឋមួយអាចផ្អែកលើគោលការណ៍បម្រុងប្រយ័ត្ន ៖ រដ្ឋត្រូវបញ្ជាក់ឱ្យឃើញពីភាពមិនច្បាស់លាស់ដែលពិបាកនឹងសំអាង ក្នុងករណីគ្មានភស្តុតាងតាមបែបវិទ្យាសាស្ត្រ។ យើងនិយាយអំពីវិធានការបម្រុងប្រយ័ត្ន ៖ បញ្ហាអ័រម៉ូន រដ្ឋទាំងអស់មិនអាចសំអាងអំពីគោលការណ៍បម្រុងប្រយ័ត្នទូទៅដែលទទួលស្គាល់ក្នុងច្បាប់អន្តរជាតិបានឡើយ។ ប៉ុន្តែនៅក្នុងមាត្រាV-៧នៃកិច្ចព្រមព្រៀងស្ដីពីការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ ប្រសិនបើមានហានិភ័យ យើងអាចចាត់វិធានការបម្រុងប្រយ័ត្នបាន។ បញ្ហាសត្វគោអ័រម៉ូននេះ រដ្ឋអាចផ្អែកលើមតិបែបវិទ្យាសាស្ត្រភាគតិច។ ថ្ងៃណាមួយ មតិភាគតិចអាចក្លាយជាភាគច្រើន។ សហរដ្ឋអាមេរិក និងអាហ្សង់ទីនមានក្រុមហ៊ុន OGM ធំៗ។ សហភាពអឺរ៉ុបមិនមានការអភិវឌ្ឍក្នុងវិស័យ OGM នេះទេ។

ក្នុងកិច្ចព្រមព្រៀងស្ដីពីការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ គឺចៅក្រមដែលជាអ្នកដើរតួនាទីចម្បង។ ក្នុងរឿងក្ដីជាតិអាម្ទង់ អ្នកជំនាញខាងវិទ្យាសាស្ត្រទាំងនេះដែលធ្វើការនៅតាមបណ្ដាសហគ្រាសឯកជន ឬមន្ទីរពិសោធន៍ធំៗដែលទាក់ទងនឹងការលក់សារជាតុអាម្ទង់ ឬ OGM។ យើងចោទជាបញ្ហាទាក់ទងនឹងឯករាជ្យភាពរបស់ចៅក្រម។

## ២.២.៣- ការគ្រប់គ្រង និងការកាត់បន្ថយការលើកលែង ( Exceptions )

ការលើកលែងអនុញ្ញាតឱ្យប្រទេសជាសមាជិកអាចរួចផុតពីកាតព្វកិច្ចទាំងនេះ។ ការលើកលែងចោទជាបញ្ហា។ ការលើកលែងទាំងនោះនឹងផ្ទុយពីតក្កវិជ្ជានៃប្រព័ន្ធ ប៉ុន្តែវាជាសន្ទះសុវត្ថិភាពរបស់ប្រព័ន្ធ ដើម្បីរក្សាអធិបតេយ្យភាព។

### ២.២.៣.១- ការលើកលែងដោយមូលហេតុសមាហរណកម្មសេដ្ឋកិច្ច

*ការចូលរួមក្នុងសមាហរណកម្មតំបន់ ជានាបានទូវរបបអនុគ្រោះមួយធៀបនឹងរដ្ឋដទៃដែលមិនមែនជាសមាជិក។ ក្រឡេកមួយភ្លែត ការលើកលែងមិនត្រូវគ្នាជាមួយនឹងប្រព័ន្ធពាណិជ្ជកម្មពហុភាគីទេ។ ប៉ុន្តែ ត្រូវរៀបចំយន្តការសម្រុះសម្រួលផ្លូវច្បាប់មួយ។ កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មបានធ្វើឱ្យការគ្រប់គ្រងសមាហរណកម្មតំបន់ទទួលបរាជ័យ។ យើងបានចូលរួមធ្វើឱ្យមានការកើនឡើង។ ដោយសារអង្គការពាណិជ្ជកម្មពិភពលោក ធន្ទះផ្លាស់ប្តូរទាក់ទងនឹងសមាហរណកម្មតំបន់បានលេចឡើង។ កិច្ចព្រមព្រៀងទាំងនេះបំផ្លាញដល់ពហុភាគីនិយម។*

*បញ្ហាទីមួយនៃកិច្ចព្រមព្រៀងអនុគ្រោះ ៖ (i) បរិមាណ ៖ របបផ្សេងពីគេ (ii) គុណភាព។ ជាស្នូលរឹងដ៏រួបរួម និងគៀកកិតគ្នា ធៀបទៅនឹងស្នូលផ្សេងទៀតដែលបែកខ្ញែកគ្នា។*

*ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់នៃសមាហរណកម្មតំបន់ទៅលើបណ្តូរពាណិជ្ជកម្មនៅតែមានកម្រិត ព្រោះអត្ថប្រយោជន៍ពន្ធគយរបស់សមាជិកនៃកិច្ចព្រមព្រៀងអនុគ្រោះលែងជាឧបសគ្គដល់ពាណិជ្ជកម្មអន្តរជាតិទៀតហើយ។ សមាជិកនៃសមាហរណកម្មមិនមានអត្ថប្រយោជន៍ទាក់ទងនឹងរបាំងមិនមែនពន្ធគយឡើយ។ ប៉ុន្តែ របាំងមិនមែនពន្ធគយទាំងនេះគឺជាឧបសគ្គចម្បង។*

*សមាហរណកម្មតំបន់ហាក់ដូចជាបំពេញបន្ថែមដល់ប្រព័ន្ធពហុភាគី។ អង្គការពាណិជ្ជកម្មពិភពលោកអនុវត្តនយោបាយអនុគ្រោះឆ្ពោះទៅរកតំបន់និយមបើកចំហ។ ក៏ប៉ុន្តែ អង្គការពាណិជ្ជកម្មពិភពលោកត្រូវមានការប្រុងប្រយ័ត្នចំពោះសមាហរណកម្មតំបន់។ គឺកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ដែលចែងអំពីសមាហរណកម្មតំបន់( មាត្រា២៤) ដែលនឹងអនុញ្ញាតឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ ប្រសិនបើកិច្ចព្រមព្រៀងទាំងនោះគោរពលក្ខខណ្ឌគតិច្បាប់ ៖ (i) រដ្ឋមិនត្រូវបង្កើនរបាំងពន្ធគយដោយធៀបទៅនឹងរដ្ឋដែលមិនបានចូលរួមឡើយ (ii) របាំងពន្ធគយក្នុងប្រទេសត្រូវលុបចោលដោយសារសារៈសំខាន់នៃបណ្តូរទំនិញ និងក្នុងរយៈពេលសមស្រប។ កិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ត្រូវបង្កលក្ខណៈអនុគ្រោះដល់ការអភិវឌ្ឍស្មារតីបណ្តូរសេរី។ លក្ខខណ្ឌទម្រង់ ៖ កិច្ចព្រមព្រៀងទាំងនេះនឹងត្រូវជូនដំណឹង និងត្រូវឆ្លងកាត់នីតិវិធីត្រួតពិនិត្យ។ សមាហរណកម្មតំបន់ត្រូវឆ្លងកាត់ការត្រួតពិនិត្យតាំងពីដើមទី និងការត្រួតពិនិត្យពាក់កណ្តាលទី។ បណ្តារដ្ឋដែលរងការខូចខាតដោយសារសមាហរណកម្មទាំងនេះ( រងការប៉ះពាល់) អាចចាប់ផ្តើមការត្រួតពិនិត្យនេះបាន។*

*ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម បញ្ហាចម្រូងចម្រាសគឺសហគមន៍អឺរ៉ុបដែលជាភាគីនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ប៉ុន្តែបញ្ហាមិនដែលត្រូវបានដោះស្រាយយ៉ាងពិតប្រាកដឡើយ។ ភាពត្រូវគ្នានៃកិច្ចព្រមព្រៀងក្រុងរ៉ូម និង*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កិច្ចព្រមព្រៀងទូទៅមិនដែលត្រូវបានត្រួតពិនិត្យម្តងណាឡើយ។ ក្នុងការអនុវត្តជាក់ស្តែង ចំពោះសមាហរណកម្មតំបន់ នៅក្នុងប្រទេស គឺការបន្ថយពន្ធគយរវាងសមាជិក និងនៅក្រៅប្រទេស គឺការអនុវត្តគោលការណ៍មិនរើសអើង។ ក្នុងការអនុវត្តជាក់ស្តែង សន្និសញ្ញាក្រុងរ៉ូមគោរពលក្ខ-ខណ្ឌនៃមាត្រា២៤។ កិច្ចព្រមព្រៀងដែលបានចុះរវាងសហគមន៍អឺរ៉ុប និងរដ្ឋដទៃទៀត និងក្រុមរដ្ឋ ឧទាហរណ៍ កិច្ចព្រមព្រៀងអាហ្វ្រិក ការ៉ាអ៊ីប ប៉ាស៊ីហ្វិក(ACP)។

ចំនួនសរុបនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីដែលត្រូវបានជូនដំណឹងដល់អង្គការពាណិជ្ជកម្មពិភពលោក ៖ ៤១៨ក្នុងឆ្នាំ២០០៨។ ជាង៨០%ជាតំបន់ពាណិជ្ជកម្មសេរីដ៏សំខាន់ ហើយតិចជាង២០%ជាតំបន់គិតពន្ធគយ។ កិច្ចព្រមព្រៀងដទៃទៀតមានដំណើរការ ប៉ុន្តែមិនបានជូនដំណឹងទេ។ សូម្បីតែក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម មាត្រា២៤បានបង្ហាញពីដែនកំណត់របស់ខ្លួនយ៉ាងឆាប់រហ័ស។ មានការអនុម័តអនុស្សរណៈនៃការព្រមព្រៀងស្តីពីការបកស្រាយមាត្រានេះ ចំណុចមួយចំនួន ជាពិសេសរយៈពេលដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរី និងតំបន់ពន្ធគយ។ រយៈពេលសមស្របគឺក្នុងអំឡុងពេល១០ឆ្នាំខាងមុខ លើកលែងតែមានអំណះអំណាងលម្អិតក្នុងករណីលើសពីរយៈពេលនេះត្រូវបញ្ជាក់មូលហេតុ។ ផ្ទុយទៅវិញ អនុស្សរណៈនេះមិនផ្តល់ចម្លើយច្បាស់លាស់ទៅលើសារៈសំខាន់នៃពាណិជ្ជកម្មទំនិញទេ ទើបទុកទ្វារចំហដល់រដ្ឋនីមួយៗដើម្បីវាយតម្លៃដោយសេរី។ ផ្ទុយទៅវិញ អង្គជំនុំជម្រះឧទ្ធរណ៍ ក្នុងរឿងក្តី ឆ្នាំ១៩៩៩ តួគី-វាយនភណ្ឌ បានថ្លែងថា សារៈសំខាន់នៃពាណិជ្ជកម្មទំនិញមិនដូចគ្នានឹងពាណិជ្ជកម្មទំនិញទាំងមូលទេ ប៉ុន្តែ សំខាន់ខ្លាំងជាងផ្នែកមួយចំនួននៃពាណិជ្ជកម្មទំនិញ។ យើងបានបង្រួមគម្លាតបន្តិច។

## ២.២.៣.២- វិធានការការពារ

យន្តការការពារខ្លួន(មាត្រា១៩នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤) ៖ មានភាពចាំបាច់មិនអាចខ្វះបាននៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដោយហេតុថា យន្តការនេះគឺជាមតិប្រឆាំងនៃវិន័យរួមដែលបង្កើតឡើងដោយអង្គការពាណិជ្ជកម្មពិភពលោក។ វិធានការការពារខ្លួនគឺជាសន្ទះសុវត្ថិភាពរបស់ប្រព័ន្ធ(ភាពទន់ភ្លន់) ដើម្បីការពារប្រឆាំងនឹងការនាំចូលដែលបង្កមហន្តរាយដល់ផលិតករជាតិ។ មាត្រា១៩ចែងអំពីលក្ខខណ្ឌចំនួន៣៖ (i) ត្រូវមានការវិវត្តឥតគ្រោងទុកនៃកាលៈទេសៈ បន្ទាប់មក មានលក្ខខណ្ឌរុះរើទីផ្សារដែលកើតឡើងដោយសារបញ្ហា២យ៉ាង ៖ (ក) ការនាំចូលផលិតផលក្នុងតម្លៃទាបជាងតម្លៃក្នុងទីផ្សារជាតិមែនទែន(ការលក់បង្ខូចថ្លៃ) (ខ) បរិមាណនាំចូលមានទំហំធំ(មាត្រា២៤ ៖ ការបង្កើនការនាំចូលដោយគំហុក) (ii) បង្កមហន្តរាយ ឬគំរាមកំហែងបង្កមហន្តរាយដល់ផលិតករជាតិចំពោះផលិត

ផលស្រដៀងគ្នា ឬប្រកួតប្រជែង (iii) ទំនាក់ទំនងរវាងធាតុទាំង២ ៖ ទំនាក់ទំនងហេតុ និង បច្ច័យរវាងធាតុទាំង២ ប៉ុន្តែពិបាកនឹងបង្ហាញក័ស្តុតាង។ ប្រសិនបើលក្ខខណ្ឌទាំងនេះត្រូវបាន ប្រមូលផ្តុំ ភាគីនៃកិច្ចព្រមព្រៀងអាចដំឡើងពន្ធគយ ឬដាក់ការរឹតត្បិតផ្នែកបរិមាណបាន។

លក្ខខណ្ឌនៃការអនុវត្ត ៖ (i) វិធានការការពារខ្លួនត្រូវមានលក្ខណៈបណ្តោះអាសន្ន (ii) មិនត្រូវមានការរើសអើង និងត្រូវអនុវត្តចំពោះភាគីផ្សេងទៀតនៃកិច្ចព្រមព្រៀង និង (iii) ការ ផ្តល់សំណងដល់ប្រទេសដែលបានរងការខូចខាត។

យន្តការនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយភាគីនៃកិច្ចព្រមព្រៀង ពីព្រោះ លក្ខខណ្ឌនៃការចាប់ផ្តើមទុកលទ្ធភាពយ៉ាងទូលំទូលាយដល់រដ្ឋដើម្បីវាយតម្លៃ។ ការវិវត្តឥត គ្រោងទុកនៃកាលៈទេសៈទុកទ្វារចំហ។ ចុងបញ្ចប់ យន្តការនេះក៏មិនបង្អាក់ប្រព័ន្ធពាណិជ្ជកម្ម ពហុភាគីដែរ។ គឺគោលការណ៍មិនរើសអើងដែលទប់ស្កាត់ការរំលោភបំពានលើវិធានការការពារ ខ្លួន។ សមាជិកទាំងឡាយចង់ផ្តោតទៅលើអ្នកផ្គត់ផ្គង់ណាមួយ ប៉ុន្តែយន្តការនេះមិនអនុញ្ញាត ឡើយ គឺត្រូវអនុវត្តចំពោះទាំងអស់គ្នា។ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋទាំងអស់បានបោះបង់ វិធានការការពារខ្លួន ហើយចាប់យកវិធានការតំបន់ប្រផេះ ពោលគឺកិច្ចព្រមព្រៀងស្ម័យដាក់ កំហិតរវាងរដ្ឋ និងរដ្ឋ។ រដ្ឋទាំងអស់ក៏បានងាកមករកវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃផង ដែរ។ នេះគឺជាការនាំមកនូវច្បាប់ប្រឆាំងនឹងការលក់បង្ខូចថ្លៃដែលនឹងនាំតម្លៃផលិតផលទៅរក កម្រិតតម្លៃនៃផលិតផលជាតិ។

ក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក យន្តការការពារខ្លួនត្រូវបានបង្កើតឡើង វិញយ៉ាងងាយស្រួល បើប្រៀបធៀបនឹងអ្វីដែលធ្លាប់មានក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅស្តី ពីពន្ធគយ និងពាណិជ្ជកម្ម។ ជាពិសេស ការប្រើប្រាស់យន្តការនេះត្រូវបានត្រួតពិនិត្យដោយ លក្ខខណ្ឌតឹងរ៉ឹងជាងមុន។ ដោយឡែក យើងបានរៀបចំការអង្កេតនៅក្នុងប្រទេស(ថ្លៃនាំចូល ធៀបនឹងថ្លៃផលិតផលជាតិ ប្រកបដោយតម្លាភាព)។ បន្ទាប់មក ការពង្រឹងដែលទាក់ទងនឹងការ វាយតម្លៃមហន្តរាយ និងឧបទ្ទវហេតុនៃការនាំចូល។

បន្ថែមពីលើមាត្រា១៩នៃកិច្ចព្រមព្រៀងពហុភាគី មានកិច្ចព្រមព្រៀងស្តីពីការការពារ សុវត្ថិភាព(កិច្ចព្រមព្រៀងពិសេស)ដែលចូលមកបញ្ជាក់អំពីយន្តការការពារខ្លួន។ យើងមាន លក្ខណៈមិនរើសអើង ប៉ុន្តែក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក មានការលើកលែងមួយ គឺភាពអាចជ្រើសរើសបាន។ វិធានការការពារខ្លួនអាចមានលក្ខណៈអាចជ្រើសរើសបាន និង អនុវត្តចំពោះអ្នកនាំចូលមួយ ឬច្រើនមកពីប្រទេសមួយ ឬច្រើន ដោយរដ្ឋមានកាតព្វកិច្ចត្រូវ បង្ហាញឱ្យឃើញនូវទំនួលខុសត្រូវរបស់អ្នកនាំចូលទាំងនោះ។

មានដែនកំណត់មួយ ៖ វិធានការការពារខ្លួនគឺត្រូវដំឡើងពន្ធគយ។ យើងមិនអាចហាម

ឃាត់ទាំងស្រុងនូវការចូលទៅកាន់ដែនដីរបស់រដ្ឋណាមួយបានឡើយ។ ចំពោះវិធានការដែលអាចជ្រើសរើសបាន មានដែនកំណត់រយៈពេល៤ឆ្នាំដែលអាចបន្តបានម្តង។ ប្រសិនបើវិធានការមានរយៈពេលលើសពីមួយឆ្នាំ វិធានការនោះត្រូវធ្វើសេរីភាវូបនីយកម្មក្នុងអំឡុងពេលអនុវត្ត។ ចំពោះវិធានការការពារខ្លួនផ្សេងទៀតដែលមិនអាចជ្រើសរើសបាន វិធានការទាំងនោះមិនមានដែនកំណត់ពេលវេលាទេ។ ប៉ុន្តែ ដោយសាររដ្ឋត្រូវបន្ថយឆ្នាំ បន្ទាប់ នៅពេលដល់ពេលបញ្ចប់វាលែងមានទៀតហើយ។ បណ្តាប្រទេសកំពុងអភិវឌ្ឍអាចរួចផុតពីវិធានការការពារខ្លួនចាប់ពីពេលដែលចំណែករបស់រដ្ឋទាំងនោះនៅក្នុងការនាំចូលផលិតផលពាក់ព័ន្ធមានទំហំតិចជាង៣%។ វិធានការការពារខ្លួនត្រូវជូនដំណឹងដល់គណៈកម្មាធិការការពារខ្លួន។

## ២.២.៣.៣- បដិប្បញ្ញត្តិ

បដិប្បញ្ញត្តិអនុញ្ញាតឱ្យរដ្ឋរួចផុតពីកាតព្វកិច្ចទាំងនេះ ៖ ២ប្រភេទ គឺបដិប្បញ្ញត្តិនៃឧបនិស្ស័យទូទៅ និងបដិប្បញ្ញត្តិជាក់លាក់ សម្រាប់ស្ថានភាពដែលបានកំណត់។

(ក) បដិប្បញ្ញត្តិទូទៅ ៖

ប្រទេសអភិវឌ្ឍត្រូវផ្តល់ដល់ប្រទេសកំពុងអភិវឌ្ឍនូវប្រព្រឹត្តកម្មពិសេស និងខុសពីគេ។

(ខ) បដិប្បញ្ញត្តិជាក់លាក់មាន៣ ៖

(i)ផលិតកសិកម្មលើសតម្រូវការ គឺបដិប្បញ្ញត្តិលើមាត្រា១១នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ និងការហាមឃាត់ការរឹតត្បិតផ្នែកបរិមាណ លើកលែងតែករណីផលិតកម្មកសិកម្មលើសតម្រូវការ(ធ្វើស្តុកកម្មទីផ្សារ)។ លក្ខខណ្ឌតឹងរ៉ឹងសម្រាប់ការប្រើប្រាស់ ៖ រដ្ឋមិនអាចបង្កើតការហាមឃាត់ទាំងស្រុងមិនឱ្យនាំចូល គឺប្រកាសផ្សាយវិធានការរដ្ឋាភិបាលដែលធ្វើបដិប្បញ្ញត្តិលើមាត្រា១១ និង

(ii) អតុល្យភាពនៃជញ្ជីងទូទាត់ ៖ រដ្ឋមួយអាចអនុវត្តការរឹតត្បិតលើផ្នែកបរិមាណដែលនឹងអាចធ្វើឱ្យមានតុល្យភាពឡើងវិញនូវជញ្ជីងទូទាត់ និងដើម្បីអាចឱ្យអនុវត្តគោលនយោបាយកែតម្រូវរចនាសម្ព័ន្ធ។ លក្ខខណ្ឌ ៖ បង្ហាញភស្តុតាងអំពីការកាត់បន្ថយការរឹតត្បិតអន្តរជាតិដ៏ខ្លាំង។ ការប្រើប្រាស់បដិប្បញ្ញត្តិត្រូវមានដែនកំណត់ពេលវេលា។ ចាប់ពីពេលដែលជញ្ជីងទូទាត់ត្រូវបានធ្វើឱ្យមានតុល្យភាពឡើងវិញ រដ្ឋត្រូវលុបចោលការរឹតត្បិត។ មូលនិធិរូបិយប័ណ្ណអន្តរជាតិត្រូវធ្វើការវាយតម្លៃមួយអំពីការកាត់បន្ថយការរឹតត្បិត។

(iii) កាលៈទេសៈពិសេស ៖ មាត្រា២៥-៥នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤អនុញ្ញាតឱ្យរដ្ឋរួចផុតពីកាតព្វកិច្ចទាំងនេះមួយ ឬច្រើន។ បដិប្បញ្ញត្តិទាំងនេះត្រូវបានប្រើប្រាស់ដើម្បីអះអាងអំពីកិច្ចព្រមព្រៀងតំបន់ និងអនុគ្រោះ(កិច្ចព្រមព្រៀងទីក្រុងឡូម៉េ-

រដ្ឋ ACP) ដែលក្លាយជាកិច្ចព្រមព្រៀងទីក្រុងកូតូនូ (ប្រទេសបេណាំង)។

ដើម្បីទទួលបានបដិប្បញ្ញត្តិទាំងនេះ ត្រូវឱ្យសមាជិកសន្និសីទថ្នាក់ក្រសួង២/៣ផ្តល់ការអនុម័ត។

## ២.២.៣.៤- ការលើកលែងក្នុងន័យត្រង់

ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម យើងមានរបបការលើកលែងចំនួនបី ៖ ការលើកលែងទូទៅ២ លើមាត្រា២២ និង២១នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មនិងការលើកលែងជាក់លាក់មួយ (មាត្រា៤) ដែលចែងសម្រាប់ខ្សែភាពយន្ត។

ការលើកលែងទូទៅនៃមាត្រា២០ គឺការរឹតត្បិតដែលមានលក្ខណៈសាធារណៈ។ រដ្ឋទាំងអស់អាចចាត់វិធានការដែលផ្ទុយនឹងកាតព្វកិច្ចរបស់ខ្លួនបាន ប្រសិនបើកាតព្វកិច្ចទាំងនេះត្រូវស្ថិតនៅក្នុងទិសដៅមួយក្នុងចំណោមទិសដៅដូចមានចែងក្នុងមាត្រា២០ (ជាផងដប់គឺការការពារសីលធម៌សាធារណៈ សុខភាពសាធារណៈ សុខភាពសត្វ និងការអភិរក្សរុក្ខជាតិ ធនធានធម្មជាតិដែលចេះរីងស្ងួត វិធានការទាក់ទងនឹងសម្ភារផលិតនៅក្នុងពន្ធនាគារ ការថែរក្សារតនៈសម្បត្តិជាតិ (រូបសំណាក បេតិកភណ្ឌជាតិ) ឬការនាំចូល និងការនាំចេញមាស និងប្រាក់)។

ធនធានធម្មជាតិចេះរីងស្ងួត ៖ ស្ថាប័នឧទ្ធរណ៍កាត់សេចក្តីថា ខ្យល់គឺជាធនធានធម្មជាតិចេះរីងស្ងួត។ ក្នុងសំណុំរឿងសហរដ្ឋអាមេរិក-ប្រេងសាំង ការហាមឃាត់ការនាំចូលប្រេងសាំងដើម្បីការពារបរិស្ថាន។ ធនធានធម្មជាតិមិនកំណត់ត្រឹមសារធាតុខនិជ និងវត្ថុគ្មានជីវិតប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅផងទៅដល់វត្ថុដែលមានជីវិត កកើតឡើងវិញ និងអាចរីងស្ងួត។ បង្គារដែលលក់នៅសហរដ្ឋអាមេរិកត្រូវមានការបញ្ជាក់ថា បង្គារទាំងនោះត្រូវបាននេសាទដោយមានការការពារសត្វអណ្តើកសមុទ្រ។ ស្ថាប័នឧទ្ធរណ៍ទទួលស្គាល់ថា សត្វទាំងពីរប្រភេទនេះជាធនធានធម្មជាតិ ប៉ុន្តែបដិសេធសហរដ្ឋអាមេរិក ព្រោះវិធានការនេះមិនសំដៅទៅលើការការពារបរិស្ថានទេ ប៉ុន្តែទៅលើការរឹតត្បិតពាណិជ្ជកម្មទៅវិញទេ។

រឿងក្តីរវាងសហភាពអឺរ៉ុប និងប្រទេសចិន ៖ ចិនមានបំណងដាក់កំហិតការផ្សាយភាពយន្ត និងឧបករណ៍សំឡេងមួយចំនួន ដោយបារម្ភខ្លាចភាពយន្ត និងឧបករណ៍សំឡេងទាំងនោះធ្វើឱ្យប៉ះពាល់ដល់សីលធម៌សាធារណៈចិន។ ប្រាកដណាស់ ស្ថាប័នឧទ្ធរណ៍បានទទួលស្គាល់ថាភាពយន្តទាំងនោះអាចមានឥទ្ធិពលអវិជ្ជមានទៅលើសីលធម៌សាធារណៈនៅប្រទេសចិន។ ជាថ្មីម្តងទៀត គេបានចាត់ទុកថា វិធានការនេះមិនសំដៅទៅលើសីលធម៌សាធារណៈទេ វិធានការនេះមិនចាំបាច់ទេ មានវិធានការរឹតត្បិតតិចតួចផ្សេងទៀតដែលអាចធ្វើទៅបាន។ ចំពោះបញ្ហា

សីលធម៌សាធារណៈមានការលំបាកខ្លាំងណាស់។ នៅខាងក្រោយសីលធម៌សាធារណៈ វាអាចប៉ះពាល់ដល់សេរីភាពនៃការបញ្ចេញមតិ។

មាត្រា ២០៖ ទោះបីជាវិធានការនេះប៉ះពាល់ដល់គោលការណ៍នៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីក៏ពិតមែន ប៉ុន្តែវិធានការនេះហាក់ដូចជាមិនអាចខ្វះបានប្រៀបដូចជាសន្ទះសុវត្ថិភាពមួយអ៊ីចឹង។ រដ្ឋនីមួយៗមានអធិបតេយ្យភាព និងឯករាជ្យភាព។ ចំពោះបញ្ហានេះ រដ្ឋអាចបន្តគោលនយោបាយដែលខ្លួនយល់ថាចាំបាច់។ ដែនកំណត់តែមួយគត់គឺរដ្ឋត្រូវអនុវត្តដែនកំណត់របស់ខ្លួនតាមច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក គឺមានន័យថា គោរពវិធានរបស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ យើងអាចមានតម្លៃខុសៗគ្នា។ រដ្ឋមួយអាចហាមឃាត់ការនាំចូលស្រាក្នុងប្រទេសគោរពសាសនាអ៊ីស្លាម។

ការអនុវត្តមាត្រា២០ ៖ មាត្រានេះបង្កើតឱ្យមានការប៉ះពាល់ដល់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ ប្រវត្តិសាស្ត្របង្ហាញថា មិនដែលមានការប្រើប្រាស់មាត្រា២០ដោយបំពាន(លើសលុប)ម្តងណាឡើយ។ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម យើងមានរឿងក្តីចំនួន១៦ដែលត្រូវបានកាត់សេចក្តីទាក់ទងនឹងមាត្រា២០។

ឧទាហរណ៍ ប្រទេសថៃ រឿងបារី និងការកំណត់ពន្ធខុសគ្នា។ បារីពណ៌ត្នោត និងបារីពណ៌ស។ រឿងក្តីត្រីតុងក្រហម។ រដ្ឋទាំងឡាយដែលបង្កហេតុនឹងត្រូវផ្តន្ទាទោស ព្រោះមានវិធានការមិនសូវតឹងរ៉ឹងដែលអាចធ្វើឱ្យប៉ះពាល់ដល់គោលដៅដូចគ្នា។

របៀបដំណើរការមាត្រា២០ ៖ យើងនឹងសង្កេតឃើញធាតុចំនួន២។ លក្ខខណ្ឌទីមួយ ៖ (១) វិធានការមានការពាក់ព័ន្ធទៅនឹងការអភិរក្សធនធានធម្មជាតិ ឬ (២) វិធានការមានភាពចាំបាច់សម្រាប់ការការពារសុខភាពសាធារណៈ។ ចំពោះហេតុផលនីមួយៗនៃមាត្រា២០ ត្រូវមានទំនាក់ទំនងរវាងវិធានការ និងគោលដៅដែលកំណត់។ រដ្ឋត្រូវបង្ហាញថា វិធានការរបស់ខ្លួនមានការពាក់ព័ន្ធនឹងសុខភាពសាធារណៈ។ រឿងក្តីសារធាតុអាម្យង់បង្កហេតុឡើងដោយមាត្រា ២០b។ សហភាពអឺរ៉ុបហាមឃាត់ការនាំចូលសារធាតុអាម្យង់។ ក្នុងមាត្រា២០-b ក្នុងរឿងក្តីសារធាតុអាម្យង់ រដ្ឋមួយអាចល្មើសនឹងកាតព្វកិច្ចទាំងនេះ។ រឿងក្តីទី២ សហភាពអឺរ៉ុប-បង្គារ សហរដ្ឋអាមេរិកអាចចរចាជាមួយបណ្តារដ្ឋដែលប៉ះពាល់ និងអាចទទួលជោគជ័យ។ ប្រទេសប្រេស៊ីលដែលបានបង្កើតការហាមឃាត់ការនាំចូលសំបកកង់ជួសជុលឡើងវិញ។

មាត្រា២១ ៖ គឺការលើកលែងទាក់ទងនឹងសុវត្ថិភាព។ រដ្ឋមួយអាចចាត់វិធានការចាំបាច់សម្រាប់ការការពារផលប្រយោជន៍សំខាន់នៃសុវត្ថិភាពរបស់ខ្លួន ពេលដែលសុវត្ថិភាពនោះទាក់ទងនឹងពាណិជ្ជកម្មវត្ថុធាតុអាចផ្ទុះ(នុយក្លេអ៊ែរ) ការជួញដូរអាវុធ រំសេវ និងសម្ភារសង្គ្រាម និងអាចចាត់វិធានការចាំបាច់ពាក់ព័ន្ធនឹងការសន្យាទាំងនេះក្រោមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីការរក្សាសន្តិភាព។ ធម្មនុញ្ញចែងថា ធម្មនុញ្ញមានអានុភាពគ្របដណ្ដប់លើលិខិតូបករណ៍ផ្សេងទៀត។ មានហានិភ័យនៃការបំពាន។ ជាពិសេស យើងបានចូលរួមក្នុងការប្រើប្រាស់គោលនយោបាយទណ្ឌកម្មពាណិជ្ជកម្ម។ ក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក បញ្ហាដែលបានចោទឡើងទៅលើការប្រើប្រាស់ដោយសហរដ្ឋអាមេរិក មានច្បាប់២(១៩៩៦) ច្បាប់ HELMS-BURTON(ប្រទេសគុយបា) និង AMATO-KENNEY (ប្រទេសលីប៊ី និងអ៊ីរ៉ង់)។ ក្នុងករណីទាំងពីរនេះ សហរដ្ឋអាមេរិក បានគំរាមដាក់ទណ្ឌកម្មពាណិជ្ជកម្មលើប្រតិបត្តិករដែលបានធ្វើការវិនិយោគក្នុងប្រទេសលីប៊ី និងប្រទេសអ៊ីរ៉ង់ ឬធ្វើពាណិជ្ជកម្មជាមួយទ្រព្យជាតូបនីយកម្ម (ដែលត្រូវបានដកហូតដោយអំណាចទៅឱ្យឧស្សាហកម្មអាមេរិក)។ ទណ្ឌកម្មក្រៅដែនដីដែលប៉ះពាល់ដល់ក្រុមហ៊ុនទាំងអស់ សូម្បីតែក្រុមហ៊ុនបរទេស។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូក៩
# ច្បាប់ស្តីពីវិនិយោគទុនបរទេស

***អត្ថប្រយោជន៍នៃការវិនិយោគ*** ៖ *សម្រាប់ប្រទេសម្ចាស់ផ្ទះ គឺជាម៉ាស៊ីន គ្រឿងបរិក្ខារ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ បង្កើនចំណេះដឹងរបស់ប្រជាពលរដ្ឋ។ យើងវិនិយោគទៅលើការយល់ដឹង និងចំណេះដឹង។*

***គុណវិបត្តិ*** ៖ *ប្រទេសម្ចាស់ផ្ទះមើលឃើញការប្រកួតប្រជែងរវាងក្រុមហ៊ុនបរទេស និងក្នុងស្រុក។ បញ្ហានេះតម្រូវឱ្យមានការការពារផលប្រយោជន៍ជាតិ។ ត្រូវការពារឧស្សាហកម្មងាយរងគ្រោះ ៖ ការពារជាតិ ឧស្សាហកម្មគីមី-ល-។ ប៉ុន្តែសម្រាប់ប្រទេសម្ចាស់ផ្ទះ គឺត្រូវធ្វើឱ្យមាននិរន្តរភាពដល់ក្រុមហ៊ុនបរទេស និងផ្តល់ការធានាជូនពួកគេផងដែរ។*

## វិធានការវិនិយោគក្នុងពិភពលោក

*ការវិនិយោគផ្ទាល់ពីបរទេស (IDE) ៖ សរុប ៖ ១ ៨០០ពាន់លានដុល្លារ គឺ២២៨ពាន់លាននៅអាស៊ី និងអូសេអានី ១២៨ពាន់លាននៅអាមេរិកឡាទីន និងការ៉ាអ៊ីប ចំណែកសហរដ្ឋអាមេរិក និងប្រទេសអឺរ៉ុបទទួលបាន៧៩០ពាន់លានក្នុងប្រទេសនីមួយៗ។ ប្រទេសអភិវឌ្ឍទទួលបានការវិនិយោគផ្ទាល់ពីបរទេសច្រើនជាងប្រទេសកំពុងអភិវឌ្ឍ។*

## ទំនាក់ទំនងរវាងការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ច

*ប្រាក់សន្សំមានចំនួនតិចខ្លាំងណាស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ប្រទេសទាំងនោះបានអនុម័តយកគោលនយោបាយទាក់ទាញវិនិយោគ។ ប៉ុន្តែសព្វថ្ងៃ ប្រទេសកំពុងអភិវឌ្ឍបញ្ជូនប្រាក់ត្រលប់មកប្រទេសអភិវឌ្ឍវិញតាមរយៈមូលនិធិអធិបតេយ្យ។*

## ទំនាក់ទំនងរវាងការវិនិយោគ និងសិទ្ធិមនុស្ស

*យើងបានឃើញសន្ធិសញ្ញាទ្វេភាគីស្តីពីការជំរុញ និងការការពារការវិនិយោគ(TBI) តាមរយៈខចែងស្តីពីការការពារសិទ្ធិរបស់អ្នកធ្វើការ។*

# ផ្នែកទី១

## សេចក្តីផ្តើមនៃនីតិវិនិយោគ

### ១- ខ្លឹមសារនៃនីតិវិនិយោគ

### ១.១- និយមន័យនៃវិនិយោគទុនបរទេស

*មាននិយមន័យពីរ ៖ សេដ្ឋកិច្ច និងច្បាប់។*

### ១.១.១- និយមន័យនៃនីតិវិនិយោគតាមន័យសេដ្ឋកិច្ច

*មានការវិនិយោគពីរប្រភេទ ៖ ការវិនិយោគដោយផ្ទាល់ពីបរទេស និងការវិនិយោគផលបត្រ។*

### ការវិនិយោគទុនដោយផ្ទាល់ពីបរទេស

*ការវិនិយោគដោយផ្ទាល់ពីបរទេសជាប្រតិបត្តិការមួយដែលតាមរយៈប្រតិបត្តិការនេះ អ្នកវិនិយោគដែលតាំងទីនៅក្នុងប្រទេសមួយទិញភាគហ៊ុនក្នុងប្រទេសមួយទៀត(ប្រទេសម្ចាស់ផ្ទះ) ក្នុងគោលបំណងគ្រប់គ្រង(ធ្វើឱ្យស្ថិតស្ថិរ)។*

*សម្រាប់អ្នកច្បាប់ និយមន័យនេះបង្កើតបានជាប្រតិបត្តិការចំនួន៣ទម្រង់ ៖*

*១. ការបង្កើតក្រុមហ៊ុនថ្មី ឬការចូលរួមក្នុងដើមទុនរបស់ក្រុមហ៊ុនដែលមានស្រាប់នៅក្នុងប្រទេសម្ចាស់ផ្ទះ។*

*២. ការវិនិយោគឡើងវិញនៅនឹងកន្លែង(យើងរក្សាទុកភាគលាភដើម្បីវិនិយោគឡើងវិញក្នុងប្រទេសម្ចាស់ផ្ទះ)។*

*៣. កម្ចីដែលផ្តល់ដោយក្រុមហ៊ុនមេដែលស្ថិតនៅបរទេស(ភាគទុនជាទ្រព្យសកម្ម និងភាគទុនជាគណនីចរន្ត)។*

*សម្រាប់សេដ្ឋវិទូ កាលណាការវិនិយោគអនុញ្ញាតឱ្យជនបរទេសម្នាក់គ្រប់គ្រងភាគហ៊ុនលើសពី១០%របស់ក្រុមហ៊ុននៃប្រទេសម្ចាស់ផ្ទះ នោះគឺការវិនិយោគដោយផ្ទាល់ពីបរទេស។*

### ១.១.២- ការវិនិយោគជាភាគហ៊ុន

*ការវិនិយោគជាភាគហ៊ុន(IP)ទាក់ទងនឹងការចូលរួមភាគតិចទាបជាង១០%នៅក្នុងដើមទុននៃក្រុមហ៊ុនបរទេស។ គឺជាការដាក់ប្រាក់ដូចប្រាក់សន្សំដែរ។*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ភាពខុសគ្នារវាងការវិនិយោគទុនដោយផ្ទាល់ពីបរទេស និងការវិនិយោគជាភាគហ៊ុន គឺការគ្រប់គ្រង។*

**១.២- និយមន័យនៃនីតិវិនិយោគតាមន័យច្បាប់**

**១.២.១- វិធីសាស្ត្រទូទៅ**

*ចៅក្រមរបស់ធនាគារពិភពលោក( CIRDI) ផ្តល់លក្ខណវិនិច្ឆ័យចំនួន៤( សំយោគ) ៖*

*១. ភាគទុនជាភាគហ៊ុន សម្ភារ ឬសាច់ប្រាក់( ចលនាប្រាក់តាមព្រំដែន ការផ្ទេរប្រកាសនីយបត្រ ឬកម្មសិទ្ធិបញ្ញា)*

*២. ភាគទុនដែលត្រូវបានចុះបញ្ជីតាមរយៈពេល*

*៣. ហានិភ័យផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មសម្រាប់អ្នកវិនិយោគ*

*៤. ការអភិវឌ្ឍរបស់ប្រទេសម្ចាស់ផ្ទះ*

**១.២.២- វិធីសាស្ត្រដោយឡែក**

*អ្នកចរចាជ្រើសរើសការរៀបរាប់( ដូចនៅក្នុងសន្ធិសញ្ញា) ៖*

*១. ចលនទ្រព្យ អចលនទ្រព្យ និងសិទ្ធិកណ្ដិក អ៊ីប៉ូតែក ប្រាក់ជានា ផលុបភោគលើភាគហ៊ុនក្រុមហ៊ុនបរទេស( ក្រុមហ៊ុនចម្រុះ)*

*២. ភាគហ៊ុន ថ្លៃចេញផ្សាយ*

*៣. កាតព្វកិច្ចឥណទេយ្យ និងសិទ្ធិទទួលបានតាវកាលិកសេដ្ឋកិច្ច*

*៤. សិទ្ធិកម្មសិទ្ធិបញ្ញា*

*៥. សម្បទានដែលផ្តល់ដោយច្បាប់( ដល់ការស្វែងរុករក ការដាំដុះ ការធ្វើអាជីវកម្ម និងការបូមយកសម្បត្តិធម្មជាតិ)។*

*ចៅក្រមផ្តល់និយមន័យសំយោគ ប៉ុន្តែរដ្ឋពេញចិត្តនិយមន័យបែបរៀបរាប់ជាង។*

**២- ការកសាងនីតិវិនិយោគបរទេស(អន្តរជាតិ)**

**២.១- ដើមកំណើតជាប្រវត្តិសាស្ត្រនៃការវិនិយោគអន្តរជាតិ**

**២.១.១- លក្ខខណ្ឌនៃជនបរទេសនៅក្នុងប្រទេសម្ចាស់ផ្ទះ**

*ទីមួយ លក្ខខណ្ឌគតិយុត្តរបស់ជនបរទេស ៖ លទ្ធភាពរបស់ជនបរទេសក្នុងការទទួលបាននីតិរដ្ឋប្បវេណី*

*វិធានការពារទីមួយ ៖ វិធាន Calvo (អ្នកច្បាប់អាហ្សង់ទីននៅដើមសតវត្សរ៍ទី២០) ឬ*

*ខចែង Calvo ៖ ត្រូវជៀសវាងការការពារផ្នែកការទូត និងប្រើប្រាស់បែបបទតុលាការ សម្រាប់ការដោះស្រាយដោយសន្តិវិធីរវាងរដ្ឋដើម និងរដ្ឋម្ចាស់ផ្ទះ។*

*ទីពីរ ការការពារជនបរទេសជាអន្តរជាតិ។*

*វិធានទីពីរ ៖ វិធាន Drago (រដ្ឋមន្ត្រីការបរទេសអាហ្សង់ទីន)។ បំណុលដែលរដ្ឋជំពាក់មិនត្រូវបានប្រមូលដោយកម្លាំងទេ ពីព្រោះកម្លាំងធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យភាពរបស់រដ្ឋ។*

*វិធានទីបី ៖ រូបមន្តរបស់ Hull (រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក) ៖ ការវិនិយោគបរទេសមួយដែលត្រូវបានដកកម្មសិទ្ធិ (ជាតូបនីយកម្ម) ត្រូវអាចទទួលបានសំណងទាំងស្រុង ឆាប់រហ័ស និងត្រឹមត្រូវ។*

## ២.១.២- ការអនុវត្តការការពារតាមផ្លូវការទូត

*ទីមួយ ការការពារត្រូវបានធ្វើឡើងដោយអន្តរការីរបស់រដ្ឋដើម (ការការពារតាមផ្លូវការទូត)។ រដ្ឋធ្វើអន្តរាគមន៍ចំពោះមុខមជ្ឈត្តករអន្តរជាតិក្នុងនាមក្រុមហ៊ុនឯកជន (ណាប៉ូឡេអ៊ុងទី៣ ក្នុងករណីព្រែកជីកស៊ុយអេ ក្នុងនាមប្រទេសអេហ្ស៊ីប និងប្រទេសអង់គ្លេស)។*

*រឿងក្តី Barcelona traction ៖ នៅឆ្នាំ១៩៣៦ Franco បានធ្វើជាតូបនីយកម្មក្រុមហ៊ុនមួយនៅទីក្រុងបាសេឡូណាដែលផលិតក្បាលរថភ្លើង។ ប្រទេសបែលហ្ស៊ិកបានប្តឹងប្រទេសអេស្ប៉ាញទៅតុលាការយុត្តិធម៌អន្តរជាតិ។ សេចក្តីសម្រេចត្រូវបានចេញនៅឆ្នាំ១៩៧០។ គឺយូរខ្លាំងណាស់។ បន្ទាប់មក យើងប្តូរពីនីតិសាធារណៈ ទៅនីតិឯកជន (ឥទ្ធិពលផ្ទាល់)។*

## ២.១.៣- ឥទ្ធិពលផ្ទាល់លើការវិនិយោគបរទេស

*បុគ្គលឯកជនគ្រប់គ្នាអាចប្រើប្រាស់វិធាននៃនីតិវិនិយោគ ដោយផ្ទាល់នៅចំពោះមុខចៅក្រម។ អ្នកវិនិយោគផ្ទាល់តែម្តងអាចប្តឹងទៅតុលាការ នេះគឺជាឥទ្ធិពលផ្ទាល់។*

*ខចែងសម្របសម្រួល ៖ គឺចែងនៅក្នុងកិច្ចសន្យា ក្នុងករណីមានវិវាទកើតឡើង អំពីការប្រើមជ្ឈត្តការ។ CIRDI និងអនុសញ្ញាក្រុងវ៉ាស៊ីនតោនឆ្នាំ១៩៦៥។ CIRDI នៅតែជាការសម្ងាត់ដដែល។ បន្ទាប់មក យើងបង្កើតវិធានព្រមព្រៀងដោយឡែក ៖ កាលណារដ្ឋមួយយល់ព្រមពឹងពាក់សេវាកម្មរបស់ CIRDI នៅក្នុងច្បាប់ ឬសន្ធិសញ្ញា អ្នកវិនិយោគបរទេសទាំងអស់អាចប្តឹងទៅ CIRDI បានក្នុងករណីមានការលំបាកជាមួយរដ្ឋនោះ។*

## ២.១.៤- ប្រភពនៃនីតិវិនិយោគ

*មានប្រភពចំនួន២ ៖ ប្រភពទូទៅ (បទដ្ឋានសម្រាប់ប្រជាជនទាំងមូល) ឬប្រភពឯកត្ត*

បុគ្គល(កិច្ចសន្យា សេចក្តីសម្រេចរបស់តុលាការ)។

## ២.២- បទដ្ឋានទូទៅនៃនីតិវិនិយោគអន្តរជាតិ

បទដ្ឋាននេះមាន៣លំដាប់ ៖

- នីតិជាតិ
- បទដ្ឋាននៃអង្គការតំបន់ (ASEAN, UE, AFTA (ALENA) នឹងគ្រប់គ្រងលើបញ្ហាអន្តរជាតិនៃការវិនិយោគបរទេស
- បទដ្ឋានអន្តរជាតិ(ការបង្កើតដោយអង្គការអន្តរជាតិ)។

### ២.២.១- នីតិជាតិ

បទបញ្ញារបស់រដ្ឋផ្តល់នូវសុវត្ថិភាពគតិយុត្ត។ យើងមានច្បាប់ពីរប្រភេទ ៖

### ២.២.២- ច្បាប់ស្តីពីការវិនិយោគរបស់បណ្តារដ្ឋនាំចូលដើមទុន

ទីមួយ ៖ ក្រោយសង្គ្រាមលោកលើកទីពីរ ប្រទេសទាំងនេះបានបង្កើតច្បាប់ដើម្បីបង្កភាពងាយស្រួលដល់លំហូរចូលនៃដើមទុនដែលជាបទបញ្ញាដ៏សេរី និងបំផុសគំនិតដោយអតីតប្រទេសអាណានិគម។ ច្បាប់បារាំងឆ្នាំ១៩៥៦។

ទីពីរ ៖ ក្នុងទសវត្សរ៍ទី៨០ ប្រទេសកំពុងអភិវឌ្ឍមួយចំនួនបានសម្រេចចិត្តធ្វើការការពារខ្លួនដើម្បីកសាងសេដ្ឋកិច្ចជាតិដោយខ្លួនឯង ដោយសន្សឹមៗ ប៉ុន្តែដោយភាពច្បាស់លាស់។ ជាដំបូង ត្រូវធ្វើជាតូបនីយកម្មសេដ្ឋកិច្ច បន្ទាប់មកបើកចំហឱ្យមានដើមទុនបរទេស។ ជាសម័យការពារនិយម។ ប្រទេសកំពុងអភិវឌ្ឍបានបង្កើតបទបញ្ញាមួយដើម្បីត្រួតពិនិត្យវិនិយោគទុនបរទេស លើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹង។

ទីបី ៖ ប្រទេសកំពុងអភិវឌ្ឍបានការពារតាមផ្លូវច្បាប់ដល់វិស័យយុទ្ធសាស្ត្រ(អណ្តូងប្រេងកាត អណ្តូងរ៉ែ និងឧស្ម័ន)។ ជាញឹកញាប់ យើងឃើញមានក្រមស្តីពីអណ្តូងរ៉ែ ក្រមស្តីពីប្រេងកាត ឬក្រមស្តីពីឧស្ម័ន។

### ២.២.៣- ច្បាប់ជាតិរបស់បណ្តារដ្ឋនាំចេញដើមទុន

និទ្ទាការទីមួយ នៅក្នុងប្រទេសអភិវឌ្ឍ គឺបទបញ្ញាសេរីខ្លាំងដែលនឹងធានាឱ្យមានសុវត្ថិភាពគតិយុត្តជាអតិបរមា។ យើងមិនខ្លាចថា ប្រាក់សន្សំនេះត្រូវបានទិញយកវិញទេ។

និទ្ទាការទីពីរ គឺការការពារវិស័យយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងផលប្រយោជន៍ជាតិ ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថាមពល បច្ចេកវិទ្យាខ្ពស់ និងការបំពាក់អាវុធ។

នៅសហរដ្ឋអាមេរិក ច្បាប់«ក្រុម ៖ OMNIBUS TRADE and competitiveness, ១៩៨៨»៖ ប្រធានាធិបតីសហរដ្ឋអាមេរិកអាចហាមឃាត់ប្រតិបត្តិការទិញយក និង/ឬការរំលាយបញ្ចូលគ្នា និងលទ្ធកម្ម(M&A)នៃក្រុមហ៊ុនអាមេរិកដោយក្រុមហ៊ុនបរទេសបាន។

នៅប្រទេសអាល្លឺម៉ង់ ច្បាប់ AWG ឆ្នាំ១៩៦១ ស្តីពីពាណិជ្ជកម្មក្រៅប្រទេស ៖ ច្បាប់សេរីដែលការពារអ្នកវិនិយោគបរទេស ប៉ុន្តែរដ្ឋាភិបាលអាល្លឺម៉ង់អាចហាមឃាត់ការទិញយកបាន នៅពេលសុវត្ថិភាពយុទ្ធសាស្ត្រនៃប្រទេសចោទឡើង( ពេងចក្រនុយក្លេអ៊ែរ ៖ បច្ចេកវិទ្យា)។

នៅប្រទេសបារាំង ក្រុមរូបិយវត្ថុ និងហិរញ្ញវត្ថុ(CMF) (មាត្រាL(ច្បាប់)១៥១-១ និងមាត្រាបន្ទាប់ និង R (មានលក្ខណៈបទបញ្ជាសម្រាប់អនុវត្ត) ១៥១-១ និងមាត្រាបន្ទាប់)។ យើងមានប្រព័ន្ធពីរ ៖

- ប្រព័ន្ធប្រកាសតាមក្រោយ
- ការអនុញ្ញាតជាមុន

នៅប្រទេសអង់គ្លេស ច្បាប់ឧស្សាហកម្មព្រះរាជាណាចក្រអង់គ្លេសឆ្នាំ១៩៧៥ដែលមិនថែងអ្វីសោះ។ គេចាត់ទុកក្រុមហ៊ុនបរទេសដូចជាក្រុមហ៊ុនក្នុងស្រុកដែលមិនចាំបាច់ធ្វើប្រតិវេទឡើយ លើកលែងតែសហគ្រាសកម្មន្តសាល ដើម្បីការពារការងារ។ អាជ្ញាធរខ្លាចក្រុមហ៊ុនបរទេសចូលមកដើម្បីទទួលបានការច្នៃប្រឌិត បណ្តេញអ្នកធ្វើការ រួចចាកចេញទៅប្រទេសរបស់ពួកគេវិញ។

## ២.៣- ច្បាប់របស់អង្គការតំបន់

## ២.៣.១- សហភាពអឺរ៉ុប

### ២.៣.១.១- ការវិនិយោគអន្តរសហគមន៍

មាត្រា៤៣នៃសន្ធិសញ្ញាសហភាពអឺរ៉ុប ៖ សេរីភាពក្នុងការបង្កើត ៖ ពលរដ្ឋនៃសហភាពអឺរ៉ុបទាំងអស់អាចតាំងមូលដ្ឋានដើម្បីបង្កើតក្រុមហ៊ុនក្នុងប្រទេសសមាជិកទាំងអស់។ ប្រទេសសមាជិកគ្មានដែនកំណត់ទេ។

មាត្រា៥៦ ៖ សេរីភាពក្នុងការចរាចរដើមទុន ៖ ប្រាក់ ទំនិញ និងមធ្យោបាយផលិតកម្មធ្វើចរាចរដោយសេរីពីប្រទេសជាសមាជិកមួយទៅប្រទេសជាសមាជិកមួយទៀត។

ពេលយើងច្របាច់សេរីភាពទាំងពីរនេះបញ្ចូលគ្នា យើងឃើញថា គ្មានការរឹតត្បិតការវិនិយោគឡើយ។ សេរីភាពទាំងនេះត្រូវបានប្រើដោយចៅក្រមនៃតុលាការយុត្តិធម៌សហគមន៍អឺរ៉ុប (CJCE) ដែលដាក់ទណ្ឌកម្មលើរដ្ឋដែលរក្សាឧបសគ្គនៅក្នុងសហភាពអឺរ៉ុប។

*សាលដីការបស់ CJCE ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០២ ៖ សហគមន៍អឺរ៉ុប/ប្រទេសព័រទុយហ្កាល់ ៖ ប្រទេសព័រទុយហ្កាល់ហាមឃាត់អ្នកវិនិយោគក្នុងវិស័យមួយចំនួនសម្រាប់សមាជិករបស់សហភាពអឺរ៉ុប។*

*CJCE ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ ៖ សហគមន៍អឺរ៉ុប/ប្រទេសអ៊ីតាលី ៖ ប្រទេសអ៊ីតាលីអនុញ្ញាតឱ្យមានការចូលរួមក្នុងក្រុមហ៊ុន ប៉ុន្តែអ្នកវិនិយោគទាំងនេះមិនមានសិទ្ធិ( សិទ្ធិក្រុមហ៊ុន និងសិទ្ធិចូលហ៊ុន) ដូចអ្នកចូលហ៊ុនក្នុងស្រុកទេ។*

*CJCE ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០២ ៖ សហគមន៍អឺរ៉ុប/ប្រទេសបារាំង ៖ គេបានបង្កើតភាគហ៊ុនមាស( ភាគហ៊ុនមានបុព្វសិទ្ធិ)។ គឺជាភាគហ៊ុនដែលរដ្ឋបារាំងបានបញ្ចូលទៅក្នុងក្រុមហ៊ុនយុទ្ធសាស្ត្រមួយចំនួន ELF Aquitaine ( Total)។ ក្នុងករណីមានសង្គ្រាម រដ្ឋបារាំងមានអំណាចគ្រប់គ្រងលើ ENT។ ការរើសអើងចំពោះម្ចាស់ភាគហ៊ុនដទៃទៀត។*

*តុលាការយុត្តិធម៌សហគមន៍អឺរ៉ុប ថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៩ ៖ សាលដីកា CENTROS ៖ នៅប្រទេសអង់គ្លេស យើងអាចបង្កើតក្រុមហ៊ុនដោយគ្មានដើមទុន( ច្បាប់ទន់ភ្លន់ និងសេរីដើម្បីបង្កើតក្រុមហ៊ុន)។ លោក Centros ចង់បង្កើតក្រុមហ៊ុនមួយនៅប្រទេសដាណឺម៉ាក ប៉ុន្តែត្រូវការដើមទុនច្រើន។ ដើម្បីគេចពីច្បាប់ គាត់បានបង្កើតក្រុមហ៊ុនមួយនៅប្រទេសអង់គ្លេស ដោយមានបុគ្គលសម្ព័ន្ធមួយនៅប្រទេសដាណឺម៉ាក។ រដ្ឋាភិបាលដាណឺម៉ាកហាមឃាត់សាខានោះ។ តុលាការបង្គាប់ថា មិនត្រូវហាមឃាត់ការវិនិយោគទេ បើទោះបីជាអ្នកវិនិយោគចង់គេចពីច្បាប់ក៏ដោយ។ ទោះបីជាមានការបន្លំក៏ដោយ ត្រូវផ្តល់សេរីភាពដល់សហគ្រាសរបស់សហភាពអឺរ៉ុប។*

## ២.៣.១.២- ការវិនិយោគក្រៅសហគមន៍

*នៅពេលប្រទេសមិនមែនសមាជិកសហគមន៍ធ្វើការវិនិយោគនៅក្នុងប្រទេសសមាជិក អ្នកវិនិយោគទាំងនោះស្ថិតនៅក្រោម TBI។ ( TBI បារាំង/កម្ពុជា)។ មិនមែនសហភាពអឺរ៉ុបទេ គឺប្រទេសបារាំងដែលត្រូវយកចិត្តទុកដាក់ដល់ប្រទេសទីបី។ សន្ធិសញ្ញាក្រុងលីស្បូនឆ្នាំ២០០៧ចង់ឱ្យគណៈកម្មការជំនួសអាជ្ញាធររដ្ឋ ប៉ុន្តែគណៈកម្មការមិនមែនជាបុគ្គលគតិយុត្តទេ។*

## ២.៣.២- NAFTA ( ALENA )

*កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង( NAFTA) ដែលចុះហត្ថលេខាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩២ និងចូលជាធរមានថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៤ ប្រមូលផ្តុំសហរដ្ឋអាមេរិក កាណាដា និងម៉ិចសិក។*

*ក្នុងជំពូកទី១១នៃសន្ធិសញ្ញា យើងឃើញមានទិដ្ឋភាពចំនួន៦( ច្បាប់) ៖*

1) ជានានូវប្រព្រឹត្តកម្មជាតិដល់អ្នកវិនិយោគជាពលរដ្ឋនៃប្រទេស NAFTA ប្រសិនបើគាត់វិនិយោគក្នុងប្រទេសសមាជិកនៃ NAFTA។

2) អ្នកវិនិយោគនៃ NAFTA ទទួលបានប្រព្រឹត្តកម្មជាតិឋានៈទទួលបានភាពអនុគ្រោះបំផុត (MFN)។ អ្នកវិនិយោគនឹងទទួលបានប្រយោជន៍ពីរបបផ្តល់ភាពអនុគ្រោះខ្លាំងដែលប្រទេសសមាជិកមួយផ្តល់ឱ្យប្រទេសទីបី។

3) ការការពារ និងសុវត្ថិភាពពេញលេញ(ការធានាទាំងស្រុងផ្នែកច្បាប់) ៖ នៅក្នុង NAFTA យើងធានាតាមផ្នែកច្បាប់ដល់អ្នកវិនិយោគនៃប្រទេសសមាជិក។

4) ច្បាប់ស្តីពីមាតុភូមិនិវត្តនៃផលចំណេញ និងការផ្ទេរមូលនិធិទាក់ទងនឹងការវិនិយោគ ៖ (គ្មានពន្ធ គ្មានការត្រួតពិនិត្យ គ្មានឧបសគ្គ គ្មានកាតព្វកិច្ចវិនិយោគ ផលចំណេញឡើងវិញ)។

5) ស្តង់ដារអប្បបរមានៃការការពារក្នុងករណីដកហូតវិនិយោគទុនបរទេស ៖ ប្រសិនបើមានការធ្វើជាតូបនីយកម្ម មានលក្ខខណ្ឌសំណងមួយសម្រាប់ម្ចាស់ភាគហ៊ុនបរទេស។

6) វិវាទទាំងអស់រវាងអ្នកវិនិយោគ និងប្រទេសសមាជិក NAFTA ត្រូវដោះស្រាយដោយមជ្ឈត្តករអន្តរជាតិ។

### ២.៣.៣- MERCOSUR

កិច្ចព្រមព្រៀងឆ្នាំ១៩៩១។ ច្បាប់គឺស្ទើរតែដូចគ្នានឹងច្បាប់ NAFTA ដែរ។ លើសពីនេះទៀត សម្រាប់អ្នកវិនិយោគខាងក្នុង MERCOSUR សម្រាប់អ្នកវិនិយោគខាងក្រៅ MERCOSUR, MERCOSUR មានសមត្ថកិច្ចក្នុងកម្រិតមួយចំនួន។

### ២.៣.៤- COMESA

កិច្ចសន្យាលទ្ធកម្មរួមរបស់អាហ្វ្រិកខាងកើត និងខាងត្បូង ៖ ដែលចែងថា អ្នកវិនិយោគដែលជាសមាជិករបស់ COMESA នឹងទទួលបាន «ប្រព្រឹត្តកម្មត្រឹមត្រូវ និងសមធម៌»។ គេចែងអំពីសេរីភាពក្នុងការផ្ទេរមូលនិធិ(យើងអាចវិនិយោគ ប៉ុន្តែមិនមានការធានាថានឹងទទួលផលចំណេញទេ)។ មានការការពារតិចតួចបំផុតពីការរឹបអូស(យើងនឹងជូនដំណឹង ប៉ុន្តែគ្មានការធានាថានឹងផ្តល់សំណងទេ)។ អ្នកវិនិយោគអាចប្តឹងទៅមជ្ឈត្តករអន្តរជាតិ។

### ២.៣.៥- អាស៊ាន

អាស៊ានត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧។ ការវិនិយោគត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងគោលសម្រាប់វិស័យវិនិយោគអាស៊ាន(Framework Agreement

for ASEAN Investment Area (AIA)) ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៨៨។ យោងតាមកិច្ចព្រមព្រៀងនេះ៖

- អ្នកវិនិយោគបរទេសក្នុង ASEAN ត្រូវទទួលបាន «ប្រព្រឹត្តកម្មត្រឹមត្រូវ និងសមធម៌» ក៏ដូចជា «ប្រព្រឹត្តកម្មនៃប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត»។
- ប្រទេសជាសមាជិកអាស៊ានត្រូវបានអញ្ជើញឱ្យធ្វើការចរចាគ្នាជាលក្ខណៈទ្វេភាគីអំពីការផ្ដល់«ប្រព្រឹត្តកម្មជាតិ»។
- ក្នុងករណីរឹបអូស ការការពារអ្នកវិនិយោគត្រូវបានរៀបចំជាមុនដោយការសងជំងឺចិត្តចំពោះមហន្តរាយដែលបានទទួលរង។
- ក្នុងករណីគ្មានការស្រុះស្រួលគ្នារវាងអ្នកវិនិយោគ និងប្រទេសជាសមាជិកទេនោះ អាស៊ាននឹងទទួលបន្ទុកដោះស្រាយទំនាស់ដោយការស្រុះស្រួលគ្នា ហើយប្រសិនបើគ្មានការព្រមព្រៀងគ្នាទេ មជ្ឈត្តការត្រូវបានរៀបចំជាមុន អាចនៅ CIRDI ឬដោយមជ្ឈត្តការដែលគ្រប់គ្រងដោយនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ គឺគណៈកម្មការនៃអង្គការសហប្រជាជាតិទទួលបន្ទុកច្បាប់ពាណិជ្ជកម្មអន្តរជាតិ(CNUDCI)។

## ២.៤- នីតិអន្តរជាតិសាធារណៈ

សន្ធិសញ្ញា«ធម្មនុញ្ញស្ដីពីថាមពល» ឆ្នាំ១៩៩៤ ចែងអំពីរបបការពារ និងការលើកស្ទួយអ្នកវិនិយោគ ប៉ុន្តែនៅតែក្នុងវិស័យថាមពលប៉ុណ្ណោះ។ ដើមឡើយ សន្ធិសញ្ញានេះចង់ផ្ដល់សុវត្ថិភាពដល់អ្នកវិនិយោគមកពីអឺរ៉ុបខាងលិចដែលចង់ធ្វើការវិនិយោគនៅប្រទេសរុស្ស៊ី។ ចុងក្រោយប្រទេសជប៉ុន និងអូស្ត្រាលីបានចាប់អារម្មណ៍ជាមួយនឹងធម្មនុញ្ញនេះ។ ប្រទេសចំនួន៥០បានផ្ដល់សច្ចាប័ន។

អនុសញ្ញាក្រុងសេអ៊ូលឆ្នាំ១៩៨៥ ៖ ដែលបង្កើតទីភ្នាក់ងារធានាការវិនិយោគពហុជាតិដើម្បីរៀបចំយន្តការធានារ៉ាប់រងក្នុងប្រទេសកំពុងអភិវឌ្ឍ ក្នុងករណីមានការរឹបអូស សង្គ្រាម គេរវកម្ម វិច្ឆេទកម្ម និងភាពមិនប្ដូរបាននៃរូបិយប័ណ្ណក្នុងស្រុក។

## ៣- សន្ធិសញ្ញាទ្វេភាគីស្ដីពីការលើកស្ទួយ និងការការពារការវិនិយោគ(TBI)

ទីមួយ គឺសន្ធិសញ្ញាចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៥៩ រវាងប្រទេសអាល្លឺម៉ង់ និងប្រទសប៉ាគីស្ថាន។ សព្វថ្ងៃ យើងឃើញមានសន្ធិសញ្ញាបែបនេះជាង១៨០០នៅក្នុងពិភពលោក។

ជាពិសេស យើងឃើញមាន ៦ចែង៥ប្រភេទនៅក្នុងសន្ធិសញ្ញាទាំងនោះ៖

១. ដែនអនុវត្ត ៖ យើងរៀបរាប់វិសាលភាពនៃការវិនិយោគ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២. គោលការណ៍អនុវត្តក្នុងបញ្ហាទទួលអ្នកវិនិយោគ ៖ ត្រូវធ្វើសេចក្តីប្រកាស ឬត្រូវទទួលបានការអនុញ្ញាតមុននឹងធ្វើការវិនិយោគ។

៣. គោលការណ៍អនុវត្តក្នុងបញ្ហាប្រព្រឹត្តកម្មលើអ្នកវិនិយោគ ៖ ប្រព្រឹត្តកម្មជាតិ( ថៅក្រមក្នុងស្រុក) និងប្រជាជាតិដែលទទួលបានភាពអនុគ្រោះជាងគេបំផុត។

៤. ខចែងស្តីពីការរឹបអូស ៖ ការសង។

៥. ការដោះស្រាយវិវាទ ៖ ជូនកាលបញ្ជូនទៅកាន់យុត្តាធិការរបស់ធនាគារពិភពលោក។

## ៤- ច្បាប់ទន់( SOFT LAW )

គឺជាអត្ថបទសូចនាករមិនចាប់បង្ខំស្តីពីការលើកស្ទួយការវិនិយោគដែលបានធ្វើឡើងជាលក្ខណៈទ្វេភាគីរវាងរដ្ឋ និងរដ្ឋ។ សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិដែលបង្ហាញពីការតម្រង់ទិស និងអារម្មណ៍។ ឧទាហរណ៍ ៖

- សេចក្តីសម្រេច១៨០៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦២ ដែលអះអាងអំពីអធិបតេយ្យភាពរបស់រដ្ឋទៅលើធនធានធម្មជាតិ និងការការពារអ្នកវិនិយោគអន្តរជាតិ។
- សេចក្តីសម្រេច៣២៨១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៤ គឺជាធម្មនុញ្ញស្តីពីសិទ្ធិ និងកាតព្វកិច្ចផ្នែកសេដ្ឋកិច្ចរបស់រដ្ឋ ៖ ដើម្បីការពារសេដ្ឋកិច្ចជាតិ ត្រូវពង្រឹងសេដ្ឋកិច្ចមុននឹងបើកចំហដល់ការវិនិយោគបរទេស។
- ធនាគារពិភពលោកបានបង្កើតអត្ថបទចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩២ ស្តីពីគោលការណ៍ណែនាំស្តីពីការវិនិយោគនៅបរទេស ៖ ជាអត្ថបទដែលមានការលើកទឹកចិត្តពីគណៈកម្មាធិការអភិវឌ្ឍរបស់ធនាគារពិភពលោក ៖ «ប្រព្រឹត្តកម្មត្រឹមត្រូវ និងសមធម៌» មុននឹងឈានដល់គោល-ដៅរយៈពេលវែងនៃប្រព្រឹត្តកម្មជាតិ។

## ៥- បទដ្ឋាននីមួយៗនៃច្បាប់ស្តីពីការវិនិយោគអន្តរជាតិ

### ៥.១- សេចក្តីសម្រេច

សេចក្តីសម្រេចជាពាក្យប្រើសម្រាប់មជ្ឈត្តការដែលជារបៀបដោះស្រាយវិវាទជាលក្ខណៈឯកជន។

### គុណសម្បត្តិ ៖

- មជ្ឈត្តករគឺជាបុគ្គលមានជំនាញ និងជាអ្នកជំនាញក្នុងវិស័យមជ្ឈត្តការ។
- យុត្តិធម៌នេះមានលក្ខណៈស្រពិចស្រពិល សម្ងាត់ និងមិនត្រូវយកទៅផ្សព្វផ្សាយទេ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ភាពធាប់រហ័ស ៖ មជ្ឈត្តករចាត់ចែងសំណុំរឿងតែមួយ សម្រាប់ករណីជាក់លាក់ប្រតិទិនដែលត្រូវបានបង្កើតឡើង។

**គុណវិបត្តិធំបំផុត ៖**

- មានតម្លៃថ្លៃខ្លាំងណាស់។

ទាក់ទងនឹងសាលក្រមអន្តរជាតិ មជ្ឈត្តការគឺជាអ្នកមានយុត្តាធិការឯកជន។ យើងរៀបចំជាពីររបៀបខុសគ្នា ៖

- CIRDI (ធនាគារពិភពលោក) ៖
- នីតិវិធីគំរូធ្វើឱ្យមានស្តង់ដារ (CNUDCI) ៖

**ចរិតលក្ខណៈ ៖**

- គោលការណ៍ចំពោះមុខ ៖
- សេចក្តីសម្រេចគឺជាបទដ្ឋានដាច់ដោយឡែកដែលទាក់ទងតែនឹងភាគីជាក់លាក់ប៉ុណ្ណោះ។
- គុណវិបត្តិទីមួយ សេចក្តីសម្រេចទាំងនេះធ្វើឡើងដោយយុត្តាធិការច្រើន។
- គុណវិបត្តិទីពីរ សេចក្តីសម្រេចមិនត្រូវបានផ្សព្វផ្សាយទេ ដូច្នេះមិនមែនជាយុទ្ធសាស្ត្រទេ។ គ្មានសាលាឧទ្ធរណ៍ គ្មានតុលាការកំពូល។
- វិធាន Stare decisis ឬវិធានរឿងក្តីពីមុនៗ (ជាពាក្យឡាតាំងដែលមានន័យថា ទុកឱ្យសេចក្តីសម្រេចមានប្រសិទ្ធភាព។) អានថា ស្តា-រេ ឌី-សាយ-ស៊ីស។ ត្រូវយោងដល់រឿងក្តីមុនៗ។ គឺដើម្បីបញ្ជាក់សុវត្ថិភាពផ្នែកច្បាប់។

## ៥.២- កិច្ចសន្យាអន្តរជាតិ

កិច្ចសន្យារវាងអ្នកវិនិយោគ និងប្រទេសម្ចាស់ផ្ទះ ឬរវាងអ្នកវិនិយោគ និងក្រុមហ៊ុនឯកជនរបស់រដ្ឋម្ចាស់ផ្ទះ។ យើងបែងចែង ៖

### ៥.២.១- កិច្ចសន្យារដ្ឋ ៖ គឺជាកិច្ចសន្យារវាងអ្នកវិនិយោគ និងប្រទេសម្ចាស់ផ្ទះ

- ការអនុវត្តកិច្ចសន្យាមិនទាក់ទងនឹងអ្នកវិនិយោគឡើយ។ ឧទាហរណ៍ ការកសាងរបាំង ៖ បញ្ហាទាំងអស់ត្រូវបញ្ជូនទៅយុត្តាធិការក្នុងស្រុក។ ប្រសិនបើយុត្តាធិការក្នុងស្រុកមិនផ្តល់ប្រព្រឹត្តកម្មជាតិទេ យើងត្រូវប្តឹងទៅមជ្ឈត្តការ។

Treaty claims ៖ (បណ្តឹងប្រឆាំងសន្ធិសញ្ញា) នៅពេលគេធ្វើជាតូបនីយកម្មរបាំង គឺការ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លួចការវិនិយោគ ៖ គឺបូរណភាពនៃកិច្ចសន្យា និងការគោរពការវិនិយោគ ដូច្នេះបណ្ដឹងនេះស្ថិតក្រោមយុត្តាធិការអន្តរជាតិ។ ថៅក្រមកម្មសិទ្ធិ ៖ មជ្ឈត្តកអន្តរជាតិ( ឧទាហរណ៍ ក្នុងករណីជាតូបនីយកម្ម)។

Contract claims ៖ (បណ្ដឹងប្រឆាំងកិច្ចសន្យា) បញ្ហាអនុវត្តកិច្ចសន្យាត្រូវដោះស្រាយដោយយុត្តាធិការជាតិ ឬដោយមជ្ឈត្តកអន្តរជាតិ។ ប្រសិនបើវបាំងមានគុណវិបត្តិ និងមានច្រើនសន្ទឹកសន្ធាប់ចំពោះប្រជាជន គេត្រូវផ្ដល់សំណងដល់ពួកគេ( ការប្ដឹងទៅយុត្តាធិការជាតិ) ៖ នេះពុំមែនជាបញ្ហាវិនិយោគទេ។ ថៅក្រមកិច្ចសន្យា ៖ ( ជាតិ និងអន្តរជាតិ)។

**៥.២.២- កិច្ចសន្យាឯកជន ៖ រវាងប្រតិបត្តិករឯកជន និងអ្នកវិនិយោគឯកជននៃប្រទេសម្ចាស់ផ្ទះ ៖**

មានថៅក្រម ៖

- ថៅក្រមកិច្ចសន្យា និង
- ថៅក្រមកម្មសិទ្ធិ ដើម្បីការពារវិនិយោគ។

ច្បាប់ស្ដីពីវិនិយោគជាតិសម្រាប់ធានាការគោរពកម្មសិទ្ធិលើចលនទ្រព្យ និងអចលនទ្រព្យរបស់វិនិយោគិនបរទេស។

# ជំពូក១០
# ច្បាប់បារាំងស្តីពីវិនិយោគ

## ១- ច្បាប់ស្តីពីវិនិយោគបរទេស

*ការវិនិយោគបរទេសត្រូវគ្រប់គ្រងដោយក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ(CMF) (L 151-1 និងមាត្រាបន្តបន្ទាប់ និង R 151-1 និងមាត្រាបន្តបន្ទាប់)។*

*គោលការណ៍សេរីភាពវិនិយោគនៅបរទេស និងមកពីបរទេស ៖ កិច្ចព្រមព្រៀង Bretton Woods។*

## អញ្ញត្រកម្ម ៖ បទប្បញ្ញត្តិលម្អិតស្តីពីការវិនិយោគបរទេស

1. *សេចក្តីប្រកាសជាបច្ចាកាល*
2. *ការអនុញ្ញាតជាមុន*

## ច្បាប់អឺរ៉ុប

*គោលការណ៍ណែនាំលេខ 88/361/CEE របស់ក្រុមប្រឹក្សា ចុះថ្ងៃទី២៤ មិថុនា ១៩៨៨ សម្រាប់អនុវត្តមាត្រា៦៧នៃសន្ធិសញ្ញា។*

## ច្បាប់អឺរ៉ុប ៖

- *ច្បាប់សត្យានុម័ត ៖ ច្បាប់សន្ធិសញ្ញា*
- *ច្បាប់ក្លាយ ៖*
  - ➢ *បទបញ្ជា(អនុវត្តដោយផ្ទាល់ និងស្វ័យប្រវត្តិសម្រាប់ប្រជាពលរដ្ឋ ដូចជាសភាពិតប្រាកដមួយ)*
  - ➢ *គោលការណ៍ណែនាំ - មានពីរដំណាក់កាល ៖ រដ្ឋនីមួយៗបំប្លែងគោលការណ៍ណែនាំទៅជាច្បាប់ជាតិ តាមនីតិវិធីរៀងខ្លួន។ កាលណាហួសកាលបរិច្ឆេទកំណត់ គោល-ការណ៍ណែនាំមានឥទ្ធិពលផ្ទាល់(គោលការណ៍ដែលមានឥទ្ធិពលផ្ទាល់មានតម្លៃជាបទ*

បញ្ហា ហើយប្រជាពលរដ្ឋអាចប្រើគោលការណ៍ទាំងនេះបាន)។

- ចរាចរណ៍មូលធនដោយសេរី។
- ក្នុងករណីជួបការលំបាក រដ្ឋសមាជិកត្រូវតែអាចគ្រប់គ្រងមូលធនក្នុងរយៈពេលខ្លី(ការបង្ខាំងព្រំដែន ដូចជាក្នុងឆ្នាំ២០០៨ រដ្ឋបានការពារជាដើម)។
- រដ្ឋត្រូវលុបចោលការបង្ខាំងចលនាមូលធន។
- រដ្ឋអាចដាក់កំហិត ការត្រួតពិនិត្យដោយប្រុងប្រយ័ត្នទៅលើវិនិយោគហិរញ្ញវត្ថុ និងចែងវិធានការស្តីពីការប្រកាសចលនាមូលធន និងស្ថិតិ។
- សេរីភាវូបនីយកម្មទាំងមូលរវាងរដ្ឋសមាជិក និងប្រទេសទីបី គឺសេរីភាវូបនីយកម្មដែលមានកម្រិតដូចគ្នា( ប៉ុន្តែពុំមែនជាកាតព្វកិច្ចផ្តល់លទ្ធផលទេ)។

សាលដីកាតុលាការយុត្តិធម៌ពាណិជ្ជកម្មអឺរ៉ុប ចុះថ្ងៃទី២៣ កុម្ភៈ ឆ្នាំ១៩៩៥ នីតិវិធីព្រហ្មទណ្ឌប្រឆាំង Akdi Birdessa និង Vincte Mari Mellado និង សាលក្រម Barbero Maestre។ នៅប្រទេសអេស្ប៉ាញ ច្បាប់អេស្ប៉ាញមិនអនុលោមតាមគោលការណ៍ណែនាំទេ។ តាមច្បាប់អេស្ប៉ាញ ការនាំចេញរូបិយវត្ថុធនាគារត្រូវបានហាមឃាត់ និងត្រូវទទួលការពិន័យ។ តុលាការយុត្តិធម៌ពាណិជ្ជកម្មអឺរ៉ុបបានច្រានចោលច្បាប់របស់អេស្ប៉ាញ ហើយគោលការណ៍ណែនាំមានឥទ្ធិពលដោយផ្ទាល់ប្រឆាំងនឹងក្រុមអ្នកច្បាប់ជាតិ។

សាលដីកាតុលាការយុត្តិធម៌ពាណិជ្ជកម្មអឺរ៉ុប ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០០ ៖ ព្រះវិហារ Scientology ទល់នឹងប្រទេសបារាំង។ ព្រះវិហារ Scientology ចង់វិនិយោគក្នុងប្រទេសបារាំងដើម្បីបានអំណាចកាន់តែខ្លាំង។ ក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុមានភាពតឹងរ៉ឹង។ ប្រទេសបារាំងបានប្រើប្រព័ន្ធអនុញ្ញាតជាមុនរបស់ខ្លួន ដើម្បីហាមឃាត់ព្រះវិហារនេះមិនឱ្យវិនិយោគនៅប្រទេសបារាំង។ ព្រះវិហារ Scientology បានប្តឹងទៅតុលាការ។ តុលាការសម្រេចថា ប្រព័ន្ធរបស់បារាំងមិនគោរពតាមគោលការណ៍ណែនាំទេ ពីព្រោះវិស័យដែលបានរៀបរាប់មានលក្ខណៈទូលាយដើម្បីអាចឱ្យប្រទេសបារាំងរក្សាអំណាចផ្តាច់ការ និងឆន្ទានុសិទ្ធិបាន។ ក្រោយពីការផ្តន្ទាទោសនេះ ប្រទេសបារាំងបានលើកឡើងពីវិស័យដែលត្រូវមានការអនុញ្ញាតជាមុន។

## លក្ខណៈវិនិច្ឆ័យនៃវិនិយោគបរទេស

វិនិយោគិនបរទេសនៅប្រទេសបារាំងឋិតនៅក្រោមលក្ខណៈវិនិច្ឆ័យពីរ ៖ លក្ខណៈវិនិច្ឆ័យលំនៅដ្ឋាន និងលក្ខណៈវិនិច្ឆ័យសញ្ជាតិ។

សម្រាប់រូបវន្តបុគ្គល គេប្រើលក្ខណៈវិនិច្ឆ័យលំនៅដ្ឋាន ៖ ពោលគឺវិនិយោគិនបរទេសដែលមានលំនៅដ្ឋាននៅបរទេស ទោះជាសញ្ជាតិអ្វីក៏ដោយ( សូម្បីពលរដ្ឋបារាំងក៏ដោយ)។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់នីតិបុគ្គល គឺលក្ខណៈវិនិច្ឆ័យសញ្ជាតិ(ស្ថានភាព)។ គឺគ្រឹះស្ថានដែលស្ថិតនៅប្រទេសបារាំងដែលយើងចាត់ទុកថា ជាគ្រឹះស្ថានបារាំង(ការចុះបញ្ជី)។ គ្រឹះស្ថាននៅបរទេសត្រូវចាត់ទុកថាជាគ្រឹះស្ថានបរទេស។ ការចុះបញ្ជីផ្តល់បុគ្គលិកលក្ខណៈជានីតិបុគ្គល។

ក្រុមហ៊ុនក្រោមច្បាប់បារាំងដែលមានទីស្នាក់ការកណ្តាលនៅប្រទេសបារាំង គឺជាក្រុមហ៊ុនបារាំង។ ប៉ុន្តែក្រុមហ៊ុនបារាំងនេះអាចមានបុត្តសម្ព័ន្ធ(ក្រុមហ៊ុន១00%) ឬសាខា(មូលនិធិពាណិជ្ជកម្ម ប៉ុន្តែគ្មានក្រុមហ៊ុន)។ ប្រសិនបើក្រុមហ៊ុននេះស្ថិតនៅបរទេស យើងចាត់ទុកជាក្រុមហ៊ុនបរទេសតាមច្បាប់បារាំង។ កាលណា ក្រុមហ៊ុនបុត្តសម្ព័ន្ធនេះនាំប្រាក់ចូលមកប្រទេសបារាំង គេចាត់ទុកថា ប្រាក់នេះជាការវិនិយោគបរទេស។ ការបង្កើតក្រុមហ៊ុនមួយនៅប្រទេសបារាំងដោយមានស្នាក់ការកណ្តាលនៅសហរដ្ឋអាមេរិកគឺជាវិនិយោគិន។ គេមិនគិតពីសញ្ជាតិរបស់អ្នកវិនិយោគទេ គេគិតពីលំនៅដ្ឋាននៃទ្រព្យ។ និយាយដោយខ្លី លក្ខណៈវិនិច្ឆ័យសញ្ជាតិត្រូវឆ្លងកាត់ការចុះបញ្ជី។ ដោយផ្អែកលើការចុះបញ្ជី គេអាចខ្ចីឥណទានបាន(វិនិយោគិនមានសញ្ជាតិណាក៏ដោយ)។

## ២- ប្រព័ន្ធប្រតិវេទន៍

អ្នកវិនិយោគទាំងអស់ត្រូវធ្វើប្រតិវេទន៍រដ្ឋបាល នៅពេលណាដែលអ្នកវិនិយោគត្រូវបានចេញជារូបរាង(ច្បាប់ 152-5 ក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ)។ ទាក់ទងនឹងកាតព្វកិច្ចប្រតិវេទន៍ យើងត្រូវធ្វើការសិក្សាលើចំណុចពីរគឺ ដែនអនុវត្ត(ratione personae និង ratione materiae ៖ វិស័យ និងប្រតិបត្តិការ) និងទោសទណ្ឌ។

## ២.១- ដែនអនុវត្តន៍

តើបុគ្គលណាខ្លះពាក់ព័ន្ធ និងតើប្រតិបត្តិការណាខ្លះដែលជាគោលដៅ។ គឺ ratione personae (ទាក់ទងនឹងបុគ្គល) និង ratione materiae (លក្ខខណ្ឌទាក់ទងនឹងវិស័យ និងប្រតិបត្តិការ)។ ច្បាប់-151-1 (50/60/70)។

បុគ្គលពាក់ព័ន្ធនឹងប្រតិវេទន៍ ៖ ចំពោះរូបវន្តបុគ្គលគឺទាក់ទងនឹងនិវេសនជននៅបរទេស និងចំពោះនីតិបុគ្គល គឺសញ្ជាតិរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធ។

ប្រតិបត្តិការពាក់ព័ន្ធនឹងប្រតិវេទន៍ ៖

- ការបង្កើតសហគ្រាសថ្មីមួយ ដោយក្រុមហ៊ុនមួយក្រោមច្បាប់បរទេស ឬដោយរូបវន្តបុគ្គលម្នាក់ដែលមិនមែនជានិវេសនជន ៖ ជាលទ្ធកម្មទាំងស្រុង ឬដោយផ្នែកនៃសាខាសកម្មភាព(មូលនិធិពាណិជ្ជកម្ម)របស់សហគ្រាសក្រោមច្បាប់បារាំង ដោយក្រុមហ៊ុនក្រោមច្បាប់បរទេស។
- ប្រតិបត្តិការក្នុងមូលធនរបស់ក្រុមហ៊ុនក្រោមច្បាប់បារាំងមួយដែលមូលធន ឬសិទ្ធិ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បោះឆ្នោតត្រូវកាន់កាប់លើស៣៣,៣៣% ដោយសហគ្រាសក្រោមច្បាប់បរទេសមួយ ឬច្រើន ដោយរូបវន្តបុគ្គលមិនមែននិវេសនជនម្នាក់ ឬច្រើននាក់។

• ការផ្តល់កម្ចី ឬការធានា ឬការទិញប្រកាសនីយបត្រ ឬអាជ្ញាប័ណ្ណ ៖ លទ្ធកម្មកិច្ចសន្យាពាណិជ្ជកម្ម ឬការផ្តល់ជំនួយបច្ចេកទេសនាំឱ្យមានការទទួលបានការត្រួតត្រាជាក់ស្តែងលើសហគ្រាសក្រោមច្បាប់បារាំងមួយ ដោយក្រុមហ៊ុនក្រោមច្បាប់បរទេស ឬដោយរូបវន្តបុគ្គលមិនមែននិវេសនជនមួយ។ ជនបរទេសម្នាក់ដែលផ្តល់កម្ចីឱ្យក្រុមហ៊ុន គឺកាន់កាប់គណនីចរន្ត។ ពេលដែលកម្ចីមានទំហំធំដែលអាចអនុញ្ញាតឱ្យត្រួតត្រាសហគ្រាសបាន គេត្រូវតែធ្វើប្រតិវេទន៍។

## ការលើកលែង ៖

• ការបង្កើត ឬការពង្រីកសហគ្រាស(មូលនិធិពាណិជ្ជកម្ម) ក្រោមច្បាប់បារាំងមួយដែលមានស្រាប់ និងកាន់កាប់ដោយជនបរទេស(រូបវន្តបុគ្គល ឬនីតិបុគ្គល)។

• កំណើនការចូលរួមក្នុងសហគ្រាសក្រោមច្បាប់បារាំងមួយដែលកាន់កាប់លើសពី៥០% ដោយជនបរទេស។

• កាលណាគេដំឡើងដើមទុនរបស់ក្រុមហ៊ុនបារាំងមួយ ឬមានអ្នកចូលហ៊ុនបរទេសរួចហើយ ប្រាក់រង្វាន់សម្រាប់ការចេញផ្សាយ ពួកគេមានសិទ្ធិចុះបញ្ជីភាគហ៊ុន ដើម្បីកុំឱ្យផ្លាស់ប្តូរ។

## ការត្រួតត្រាក្រុមហ៊ុន ៖

*វិធានមូលដ្ឋាន ៖*

• ក្រុមហ៊ុនកាន់កាប់ចំណែកដើមទុនដែលផ្តល់សិទ្ធិបោះឆ្នោតភាគច្រើនដល់ខ្លួនដោយផ្ទាល់ ឬមិនផ្ទាល់។

• ក្រុមហ៊ុនកាន់កាប់តែម្នាក់ឯងនូវសំឡេងភាគច្រើននៃសិទ្ធិបោះឆ្នោតក្នុងក្រុមហ៊ុននេះ អនុលោមតាមកតិកាសញ្ញាម្ចាស់ភាគហ៊ុន ៖ អ្នកចូលហ៊ុនរៀបចំចាត់ចែងជាមួយគ្នា(កិច្ចសន្យាក្រៅលក្ខន្តិកៈ)។

• ដូច្នេះ តាមរយៈសិទ្ធិបោះឆ្នោតនេះ ក្រុមហ៊ុនជាអ្នកធ្វើសេចក្តីសម្រេចក្នុងមហាសន្និបាត។

• ក្រុមហ៊ុនជាអ្នកចូលហ៊ុនជាមួយ ឬមានម្ចាស់ភាគហ៊ុនរបស់ខ្លួន និងមានអំណាចតែងតាំង ឬដកហូតសំឡេងភាគច្រើនរបស់សមាជិកអង្គភាពរដ្ឋបាល គ្រប់គ្រង ឬត្រួតពិនិត្យ។

*វិធានភស្តុតាង(ងាយស្រួលបង្ហាញ) ៖*

• ការត្រួតត្រាត្រូវបានសន្មតថាមាន កាលណាក្រុមហ៊ុនមានសិទ្ធិមួយផ្នែកលើសពី៤០% ដោយផ្ទាល់ ឬដោយប្រយោល និងកាលណាគ្មានអ្នកចូលហ៊ុន ឬម្ចាស់ភាគហ៊ុនណាម្នាក់កាន់កាប់

ដោយផ្ទាល់។

• កាលណាក្រុមហ៊ុនជាអ្នកចូលហ៊ុនជាមួយ ឬមានម្ចាស់ភាគហ៊ុនរបស់ខ្លួន និងមានអំណាចតែងតាំង ឬដកហូតសំឡេងភាគច្រើនរបស់សមាជិកអង្គភាពរដ្ឋបាល គ្រប់គ្រង ឬត្រួតពិនិត្យ។

## ២.២- ខចែងអំពីរបបគតិយុត្ត ៖ ទោសទណ្ឌ

ប្រសិនបើគេមិនបានធ្វើប្រតិវេទន៍នៅក្រសួងហិរញ្ញវត្ថុ អ្នកវិនិយោគត្រូវទទួលការពិន័យដែលស្មើនឹងចំនួនទឹកប្រាក់អតិបរមានៃបទលហុកម្រិតទី៤ ៖ ៧៥0 អឺរ៉ូ( មាត្រាច្បាប់-165-2 ក្រមស្ដីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ) ( ទណ្ឌកម្មព្រហ្មទណ្ឌ)។

កាតព្វកិច្ចធ្វើប្រតិវេទន៍នេះមានបំណងពិនិត្យថា គេមិនស្ថិតក្នុងវិស័យយុទ្ធសាស្ត្រ ដើម្បីត្រួតពិនិត្យតាមក្រោយថា តើយើងត្រូវការទទួលការអនុញ្ញាតដែរឬទេ( ទណ្ឌកម្មមានកម្រិតធ្ងន់ជាង)។

## ២.៣- ប្រព័ន្ធអនុញ្ញាតជាមុន

ការអនុញ្ញាតជាមុនទាក់ទងនឹងវិស័យដែលគេវិនិច្ឆ័យថា ជាវិស័យយុទ្ធសាស្ត្រ។ ច្បាប់បារាំងចែងពីការអនុញ្ញាតដែលផ្តល់ដោយក្រសួងហិរញ្ញវត្ថុ ៖ ពោលគឺវិស័យដែលចូលរួមដល់អាជ្ញាធរសាធារណៈ ឬវិស័យដែលមានលក្ខណៈប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខសាធារណៈ ឬប្រយោជន៍ការពារជាតិ។ គេបាននិយាយថា ប្រព័ន្ធអនុញ្ញាតជាមុនជាប្រព័ន្ធជាតិនិយមសេដ្ឋកិច្ច ឬ«ប្រឆាំងនឹងការទិញយកក្រុមហ៊ុនបញ្ចូលគ្នា( anti-OPA )»។

ក្នុងប្រព័ន្ធនេះ គេធ្វើការបែងចែករវាងអ្នកវិនិយោគបរទេសដែលមកពីសហភាពអឺរ៉ុប ( មិនសូវតឹងរ៉ឹង ដោយអនុញ្ញាតឱ្យពលរដ្ឋអឺរ៉ុបទិញវិស័យមួយចំនួនបាន) និងទីពីរ គឺអ្នកវិនិយោគបរទេសក្រៅសហភាពអឺរ៉ុប។

## ៣- ដែនអនុវត្ត

មានដែនអនុវត្តពីរ។

( លក្ខណវិនិច្ឆ័យ ៖ បុគ្គល ( ratione personae) និងវិស័យ ៖ ប្រតិបត្តិការគតិយុត្ត( ratione materiae)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.១- សម្រាប់អ្នកវិនិយោគអឺរ៉ុប

*បុគ្គល( ratione personae )៖*

*- សម្រាប់រូបវន្តបុគ្គល ៖ ជានិវេសនជនក្នុងរដ្ឋមួយនៃសហភាពអឺរ៉ុប ក្រៅពីប្រទេសបារាំង។*

*- សម្រាប់នីតិបុគ្គល ៖ គេគិតពីទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន ឬកន្លែងបង្កើតសម្រាប់មូលនិធិពាណិជ្ជកម្ម។*

*វិស័យពាក់ព័ន្ធ( ratione materiae ) ៖*

*សម្រាប់អ្នកវិនិយោគរបស់សហភាពអឺរ៉ុប( ក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ - មាត្រា ច្បាប់ 153-5 ) ៖*

*- សកម្មភាពកាស៊ីណូ*

*- សន្តិសុខឯកជន*

*- ការចាប់សេចក្តីឆ្លើយឆ្លង និងការចាប់សេចក្តីសន្ទនាពីចម្ងាយ*

*- សន្តិសុខនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានការពារជាតិ ព្រមទាំងក្នុងវិស័យគីមីវិទ្យាមួយចំនួន ( ក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ - មាត្រា ច្បាប់ 153-4)*

*- សកម្មភាពមួយចំនួនទាក់ទងនឹងវិទ្យាសាស្ត្រសារសម្ងាត់*

*- ការការពារជាតិ និង*

*- ការស្រាវជ្រាវ និងពាណិជ្ជកម្មអាវុធនិងគ្រាប់រំសេវ។*

*ប្រសិនបើ និងក្នុងករណីដែលប្រតិបត្តិការមានការពាក់ព័ន្ធតែ ៖ សម្រាប់ប្រតិបត្តិការ( ដែលត្រួតគ្នា) ៖*

*- លទ្ធកម្មការត្រួតត្រាតាមន័យនៃមាត្រា233-3នៃក្រមពាណិជ្ជកម្មក្នុងសហគ្រាសមួយដែលមានទីស្នាក់ការកណ្តាលនៅប្រទេសបារាំង។*

*- លទ្ធកម្មផ្ទាល់ ឬប្រយោលនៃសាខាសកម្មភាពទាំងស្រុង និងដោយផ្នែករបស់សហគ្រាសដែលមានទីស្នាក់ការនៅប្រទេសបារាំង។*

*(មាត្រាL 233-3នៃក្រមពាណិជ្ជកម្ម)*

*ក- សម្រាប់ការអនុវត្តផ្នែក២ និង៤នៃជំពូកនេះ សហគ្រាសមួយត្រូវចាត់ទុកជាដូចជាត្រួតត្រាសហគ្រាសមួយទៀត ៖*

*១. កាលណាក្រុមហ៊ុនកាន់កាប់ដោយផ្ទាល់ ឬប្រយោលនូវចំណែកដើមទុនមួយផ្នែកដែលផ្តល់សិទ្ធិបោះឆ្នោតភាគច្រើនទៅឱ្យសហគ្រាសក្នុងមហាសន្និបាតរបស់សហគ្រាសនេះ។*

*២. កាលណាក្រុមហ៊ុនតែឯងមានសំឡេងបោះឆ្នោតភាគច្រើនក្នុងក្រុមហ៊ុននេះ អនុលោម*

ទៅតាមកិច្ចព្រមព្រៀងធ្វើឡើងរវាងអ្នកចូលហ៊ុន ឬម្ចាស់ភាគហ៊ុនដទៃទៀត និងដែលមិនប្រឆាំងទៅនឹងផលប្រយោជន៍របស់ក្រុមហ៊ុន។

៣. កាលណាក្រុមហ៊ុនកំណត់សេចក្តីសម្រេចក្នុងមហាសន្និបាតរបស់ខ្លួនតាមរយៈសិទ្ធិបោះឆ្នោតដែលខ្លួនមាន។

៤. កាលណាក្រុមហ៊ុនជាអ្នកចូលហ៊ុន ឬម្ចាស់ភាគហ៊ុន និងមានអំណាចតែងតាំង ឬដកហូតសមាជិកភាគច្រើនពីអង្គភាពរដ្ឋបាល ដឹកនាំ ឬត្រួតពិនិត្យក្រុមហ៊ុន។

ខ- ក្រុមហ៊ុនត្រូវបានសន្មតថា អនុវត្តការត្រួតត្រានេះ នៅពេលក្រុមហ៊ុនមានដោយផ្ទាល់ ឬប្រយោលនូវសិទ្ធិបោះឆ្នោតលើសពី៤0% និងនៅពេលគ្មានអ្នកចូលហ៊ុន ឬម្ចាស់ភាគហ៊ុនណាម្នាក់ផ្សេងទៀតកាន់កាប់ចំណែកភាគហ៊ុនលើសខ្លួន ដោយផ្ទាល់ ឬមិនផ្ទាល់។

គ- ចំពោះការអនុវត្តផ្នែកដដែលនៃជំពូកនេះ បុគ្គលពីរ ឬច្រើនរូបដែលប្រតិបត្តិការស្របគ្នាត្រូវចាត់ទុកថា ត្រួតត្រាក្រុមហ៊ុនមួយផ្សេងទៀតរួមគ្នា ពេលដែលបុគ្គលទាំងនោះកំណត់សេចក្តីសម្រេចដែលធ្វើឡើងក្នុងមហាសន្និបាត។

## ៣.២- ដែនអនុវត្តសម្រាប់អ្នកវិនិយោគមិនមែនអឺរ៉ុប(រដ្ឋដទៃក្រៅពីសហភាពអឺរ៉ុប)

បុគ្គល ៖

- ចំពោះរូបវន្តបុគ្គលដែលស្នាក់នៅក្នុងរដ្ឋមួយក្រៅសហភាពអឺរ៉ុប។
- ចំពោះនីតិបុគ្គលដែលមានទីស្នាក់ការនៅក្នុងរដ្ឋដទៃក្រៅសហភាពអឺរ៉ុប។

វិស័យពាក់ព័ន្ធ ៖ (ក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ មាត្រា ច្បាប់ 153-2)

- សកម្មភាពក្នុងវិស័យល្បែងស៊ីសង។
- សកម្មភាពសន្តិសុខឯកជន។
- សកម្មភាពស្រាវជ្រាវ អភិវឌ្ឍ ឬផលិតកម្មទាក់ទងនឹងមធ្យោបាយសម្រាប់ប្រឈមមុខនឹងការប្រើប្រាស់ខុសច្បាប់នូវភ្នាក់ងារបង្កជំងឺ ឬបំពុល ក្នុងក្របខ័ណ្ឌសកម្មភាពភេរវកម្ម និងបង្ការផលវិបាកផ្នែកសុខភាពក្នុងការប្រើប្រាស់នេះ។
- សកម្មភាពទាក់ទងនឹងសម្ភារដែលរចនាឡើងដើម្បីចាប់សេចក្តីឆ្លើយឆ្លង និងការចាប់យកការសន្ទនាពីចម្ងាយ។
- សកម្មភាពសេវាកម្មទាក់ទងនឹងការវាយតម្លៃ និងការបញ្ជាក់សុវត្ថិភាពដែលផ្តល់ដោយផលិតផល និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។
- សកម្មភាពផលិតទ្រព្យ និងការផ្តល់សេវាកម្មសន្តិសុខក្នុងវិស័យសន្តិសុខប្រព័ន្ធព័ត៌មានរបស់សហគ្រាសដែលពាក់ព័ន្ធនឹងកិច្ចសន្យាដែលត្រូវបានចុះជាមួយប្រតិបត្តិករសាធារណៈ ឬ

ឯកជនដែលញុំាងឱ្យមានការដំឡើងបរិក្ខារផ្សេងៗក្នុងវិស័យការពារជាតិ។

- សកម្មភាពទាក់ទងនឹងទ្រព្យ និងបច្ចេកវិទ្យាសម្រាប់បម្រើបម្រាស់ពីរយ៉ាងដូចបានរៀប-រាប់ក្នុងឧបសម្ព័ន្ធIVនៃបទបញ្ញា( ក្រុមប្រឹក្សាអឺរ៉ុប) លេខ n 1334/2000 របស់ក្រុមប្រឹក្សា ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០០ ដែលត្រូវបានកែប្រែ និងដែលបង្កើតរបបត្រួតពិនិត្យការនាំចូលទ្រព្យ និងបច្ចេកវិទ្យាដែលមានបម្រើបម្រាស់ពីររបស់សហគមន៍អឺរ៉ុប។

- សកម្មភាពវិទ្យាសាស្ត្រសារសម្ងាត់។

- សកម្មភាពស្រាវជ្រាវផលិតកម្ម ឬពាណិជ្ជកម្មអាវុធ រំសេវ ម្សៅ និងសាធាតុផ្ទុះ ក្នុងគោលដៅយោធា ឬសម្ភារសង្គ្រាម។

- សកម្មភាពអនុវត្តដោយសហគ្រាសដែលបានចុះកិច្ចសន្យាសិក្សា ឬផ្គត់ផ្គង់បរិក្ខារដល់ក្រសួងការពារជាតិ។

ប្រសិនបើ និងក្នុងករណីប្រតិបត្តិការពាក់ព័ន្ធតែ ៖

- លទ្ធកម្មការត្រួតត្រា តាមន័យនៃមាត្រា ២៣៣-៣នៃក្រមពាណិជ្ជកម្ម ក្នុងសហគ្រាសដែលមានទីស្នាក់ការនៅប្រទេសបារាំង។

- លទ្ធកម្មផ្ទាល់ ឬមិនផ្ទាល់នៃសាខាសកម្មភាពទាំងស្រុង និងដោយផ្នែករបស់សហគ្រាសដែលមានទីស្នាក់ការនៅប្រទេសបារាំង។

- ការឆ្លងផុតកម្រិត៣៣,៣៣%នៃការកាន់កាប់ដោយផ្ទាល់ ឬមិនផ្ទាល់លើមូលធន ឬសិទ្ធិបោះឆ្នោតរបស់សហគ្រាសមួយដែលមានទីស្នាក់ការនៅប្រទេសបារាំង។

### ៣.៣- ការលើកលែងទូទៅ

បើទោះបីជាមានលក្ខណៈវិនិច្ឆ័យនៃការអនុញ្ញាតគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏អ្នកវិនិយោគមិនស្ថិតក្រោមការអនុញ្ញាតទេ ប្រសិនបើការវិនិយោគនេះទាក់ទងនឹងការវិនិយោគដែលធ្វើឡើងរវាងសហគ្រាសនៃក្រុមហ៊ុនមេតែមួយដូចគ្នា( ច្បាប់-១៥៣-៦ ក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ)។ [ក្រុមក្រុមហ៊ុនដែលជាបណ្តុំនៃក្រុមហ៊ុនដែលត្រូវត្រួតត្រាតាមន័យនៃមាត្រា L-233-3 ដោយក្រុមហ៊ុនមេតែមួយ( បុគ្គលសម្ព័ន្ធដទៃទៀត)]។

## ៤- របបគតិយុត្ត ៖ ទោសទណ្ឌ

### ៤.១- ទម្រង់និយមនៃការអនុញ្ញាត

ការស្នើសុំលិខិតអនុញ្ញាតត្រូវដាក់ជូនរដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ចក្នុងលក្ខខណ្ឌដែលមានពន្យល់ក្នុងមាត្រា១៥៣-៧,៨,៩,១០នៃក្រមស្តីពីរូបិយវត្ថុនិងហិរញ្ញវត្ថុ។គឺរដ្ឋមន្ត្រីសេដ្ឋកិច្ច

ដែលវាយតម្លៃហានិភ័យរបស់អ្នកវិនិយោគ។ រដ្ឋមន្ត្រីនឹងគិតគូរពីកិត្តិនាម និងឥរិយាបថរបស់អ្នកវិនិយោគ។ កាលណាវាយតម្លៃរួចហើយ រដ្ឋមន្ត្រីអាចអនុញ្ញាត ឬបដិសេធអ្នកវិនិយោគ ឬចុងក្រោយអាចអនុញ្ញាតក្រោមលក្ខខណ្ឌ(ពេលរដ្ឋបារាំងត្រូវរក្សាផ្នែករសើបមួយ)។ សេចក្តីសម្រេចជាសមត្ថកិច្ចរបស់តុលាការរដ្ឋបាល។

ឧទាហរណ៍ ក្រុមប្រឹក្សារដ្ឋ រដ្ឋមន្ត្រីទល់នឹង Giancarlo X។

## ៤.២- ទោសទណ្ឌនៃការអនុញ្ញាត

ទោសទណ្ឌពីបទគ្មានការអនុញ្ញាតនឹងត្រូវបានអនុវត្ត កាលណាអ្នកវិនិយោគធ្វើការវិនិយោគក្នុងវិស័យណាដែលការវិនិយោគនេះត្រូវមានការអនុញ្ញាត។ អ្នកវិនិយោគច្រឡំនីតិវិធី ឬគឺជាវិស័យយុទ្ធសាស្ត្រ។ តើមានអ្វីកើតឡើង ពេលដែលអ្នកវិនិយោគធ្វើប្រតិវេទន៍តាមក្រោយ និងដោយគ្មានការអនុញ្ញាត ៖

១. អ្នកវិនិយោគមិនធ្វើអ្វីសោះ គ្មានដំណើរការផ្នែករដ្ឋបាលណាមួយ។

២. អ្នកវិនិយោគប្រកាសការវិនិយោគ បន្ទាប់ពីបានសម្រេចការវិនិយោគ(ប្រតិវេទន៍ជាបច្ឆាកាល)។

ប្រតិបត្តិការ(អ្នកវិនិយោគ)ត្រូវលុបចោលទាំងស្រុង។ ប្រតិបត្តិការគតិយុត្តរបស់អ្នកវិនិយោគ (L151-4 ក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ)។ លទ្ធកម្មត្រូវបានលុបចោល។ អ្នកទិញមូលនិធិពាណិជ្ជកម្មត្រូវសងមូលនិធិពាណិជ្ជកម្មវិញ ហើយអ្នកលក់ត្រូវប្រគល់ប្រាក់វិញ។ នេះការជាមោឃកម្មប្រតិសកម្ម។ គ្មានបុគ្គលណាម្នាក់អាចគេចវេសបានទេ។ ប្រសិនបើគេគេចវេសនោះ តាមមាត្រា6/1133នៃក្រមរដ្ឋប្បវេណី ប្រតិបត្តិការមិនត្រូវផ្ទុយនឹងច្បាប់ឡើយ។ នេះគឺប្រតិបត្តិការសណ្តាប់ធ្នាប់សាធារណៈ។ នេះគឺទោសរដ្ឋប្បវេណី។ ទោសប្រតិវេទន៍ជាទោសព្រហ្មទណ្ឌ(ជាមួយនឹងការផាកពិន័យ)។

## ៤.៣- របបវិនិយោគបារាំងនៅបរទេស

អ្នកវិនិយោគមកពីដែនដីបារាំង និងទៅកាន់បរទេសគឺស្ថិតក្រោមគោលការណ៍សេរីភាពទំនាក់ទំនងហិរញ្ញវត្ថុជាមួយបរទេស។ គោលការណ៍នេះអាចយកមកអនុវត្ត នៅពេលដែលអ្នកវិនិយោគជារូបវន្តបុគ្គលនិវេសនជននៅប្រទេសបារាំង ឬអនុវត្តចំពោះក្រុមហ៊ុនសញ្ជាតិបារាំង (មាត្រា151-1នៃក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ)។ គោលការណ៍នេះត្រូវចោទជាបញ្ហាយ៉ាងកម្រក្នុងករណីដាក់ទណ្ឌកម្មសេដ្ឋកិច្ច ចំពោះប្រទេសដែលកំណត់ដោយសហគមន៍អន្តរជាតិ ឧទាហរណ៍ដូចជា ៖

• ទណ្ឌកម្មសេដ្ឋកិច្ចប្រឆាំងប្រទេសស៊ីរី(ក្រឹត្យ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៩២ ក្រោយសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ)។ ក្នុងករណីមួយចំនួន ទណ្ឌកម្មសេដ្ឋកិច្ចរាំងដល់អ្នកវិនិយោគ(ពុំមែនគ្រប់ទម្រង់អ្នកវិនិយោគទាំងអស់ត្រូវបានហាមឃាត់ទេ គឺក្នុងវិស័យយុទ្ធសាស្ត្រតែប៉ុណ្ណោះ)។

• ទណ្ឌកម្មសេដ្ឋកិច្ចលើប្រទេសអ៊ីរ៉ង់ តាមបទបញ្ជារបស់សហភាពអឺរ៉ុប ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៧ ៖ ការកំណត់ និងហាមឃាត់វិនិយោគិនបារាំង និងពលរដ្ឋអឺរ៉ុបផ្សេងទៀតក្នុងវិស័យនុយក្លេអ៊ែរស៊ីវិល និងយោធា។

• ទណ្ឌកម្មសេដ្ឋកិច្ចលើប្រទេសភូមា តាមបទបញ្ជាច្បាប់ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ ៖ ហាមឃាត់អ្នកវិនិយោគបារាំង និងអឺរ៉ុបវិនិយោគនៅប្រទេសភូមាក្នុងវិស័យឈើ ការជីកយករ៉ែ និងត្បូង។

## ៤.៤- ការលើកលែង កាតព្វកិច្ចប្រតិវេទន៍

អ្នកវិនិយោគបារាំងដែលធ្វើវិនិយោគនៅបរទេសត្រូវប្រកាសអត្តិភាព និងទឹកប្រាក់នៃការវិនិយោគរបស់ខ្លួននៅធនាគារបារាំង(ដែលគណនាតុល្យការបង់ប្រាក់) ដើម្បីអាចឱ្យធ្វើការវាយតម្លៃគោលជំហរបរទេសរបស់ប្រទេសបារាំង។ នេះជាប្រតិវេទន៍ស្ថិតិ។ ប្រតិវេទន៍នេះគឺសម្រាប់លក្ខខណ្ឌបុគ្គល(ratione personae) និងលក្ខខណ្ឌ(ratione materiae)នៃប្រតិបត្តិការគតិយុត្ត ៖

1- បុគ្គលពាក់ព័ន្ធ(ratione personae) មាន៣ប្រភេទ ៖ និវេសនជន និងមិនមែននិវេសនជន (ពួកគេបើកប្រាក់នៅប្រទេសបារាំងជាមួយនឹងគណនីធនាគារនៅបារាំង) (R151-4 à R 151-4) និងអន្តរការីហិរញ្ញវត្ថុ(R152-1-I) (ពិសេសគឺធនាគារ)។ តក្កវិជ្ជាគឺត្រូវត្រួតត្រាចលនារបស់មូលធន។

2- លក្ខខណ្ឌពាក់ព័ន្ធ(ratione materiae) ៖ កាតព្វកិច្ចប្រតិវេទន៍ទាក់ទងនឹងប្រតិបត្តិការ ៤ ដូចតទៅ(R 151-1, 40) ៖

a. ប្រតិបត្តិការដែលតាមរយៈនោះ និវេសនជន និងអនិវេសនជនទទួលដើមទុនយ៉ាងតិច១0% ឬសិទ្ធិបោះឆ្នោតរបស់សហគ្រាសបរទេសមួយ។

b. ប្រតិបត្តិការដែលតាមរយៈនោះ អនិវេសនជន និងនិវេសនជនចូលរួមដើមទុននៅក្នុងសហគ្រាសបរទេសលើសពីកម្រិត១០%។

c. ប្រតិបត្តិការរវាងសហគ្រាសញាតិសម្ព័ន្ធ(កម្មសិទ្ធិរបស់ក្រុមតែមួយ) ៖ គឺជាកម្ចីរបស់សហគ្រាសមួយពីក្រុមតែមួយ។

d. អ្នកវិនិយោគអចលនទ្រព្យនៅបរទេស គឺមានន័យថា ការទិញអគារលើទឹកដីបរទេស។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ការខកខានមិនធ្វើប្រតិវេទន៍ត្រូវទទួលទោសដូចមានចែងក្នុងមាត្រា៤៩៩នៃក្រមពន្ធគយ (R 165-1 ក្រមស្តីពីរូបិយវត្ថុ និងហិរញ្ញវត្ថុ ៤៥៩នៃក្រមពន្ធគយ)។ ត្រូវពិន័យជាប្រាក់១000អឺរ៉ូ។ គ្មានការចោទជាបញ្ហាដល់អ្នកវិនិយោគនៅបរទេសទេ។*

## ៥- អានុភាពនៅប្រទេសបារាំងនៃច្បាប់បរទេសស្តីពីការវិនិយោគ

*(របៀបដែលច្បាប់បារាំងលើកឡើងពីច្បាប់បរទេសស្តីពីអ្នកវិនិយោគអន្តរជាតិ ៖ តើច្បាប់បរទេសអនុវត្តនៅប្រទេសបារាំងយ៉ាងដូចម្តេច)។*

*ក្នុងកិច្ចសន្យា គេអាចចាត់តាំងចៅក្រមកិច្ចសន្យាបារាំង ដើម្បីដោះស្រាយជម្លោះក្នុងការអនុវត្តកិច្ចសន្យាទិញអចលនទ្រព្យនៅប្រទេសវៀតណាមបាន។ ប្រសិនបើពលរដ្ឋបារាំងមិនបង់ប្រាក់ ចៅក្រមបារាំងនឹងអនុវត្តច្បាប់វៀតណាម មិនថាប្រតិបត្តិការនេះរំលោភ ឬមិនរំលោភលើច្បាប់វៀតណាម។ គេចាត់នៅក្នុងកិច្ចសន្យាថា ចៅក្រមបារាំងជាចៅក្រមមានសមត្ថកិច្ច។*

*សូម្បីតែនៅពេលដែលគេចាត់តាំងច្បាប់ក្នុងកិច្ចសន្យាក៏ដោយ គូភាគីនៃកិច្ចសន្យាមិនអាចគេចវេសច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈរបស់ប្រទេសដែលពាក់ព័ន្ធនឹងប្រតិបត្តិការបានឡើយ។ ទោះចែងអ្វីក្នុងកិច្ចសន្យាក៏ដោយ ច្បាប់ជាតិរបស់អ្នកវិនិយោគត្រូវយកមកអនុវត្ត។ ច្បាប់សណ្តាប់ធ្នាប់សាធារណៈ(ច្បាប់បញ្ញា) គឺចៅក្រមជាអ្នកវាយតម្លៃ។*

*សាលដីកាមួយរបស់សាលាឧទ្ធរណ៍ក្រុងប៉ារីស ចុះថ្ងៃទី១៥ ខែឧសភា ១៩៧៥។*

*ការពុះបំបែកកិច្ចសន្យា ៖ មួយផ្នែកយកច្បាប់កម្ពុជា មួយផ្នែកយកច្បាប់បារាំង និងមួយផ្នែកយកច្បាប់អង់គ្លេស។ គឺមានវេទិកាដើរផ្សារដើម្បីជ្រើសរើសចៅក្រម។*

# ជំពូក១១

# ច្បាប់វិនិយោគអន្តរជាតិ

(សិក្សានីតិអន្តរជាតិ ៖ ចៅក្រម មជ្ឈត្តករ រវាងវិស័យឯកជន និងរដ្ឋ)

ច្បាប់វិនិយោគអន្តរជាតិគឺជាច្បាប់នីតិវិធី។ នៅពេលមានវិនិយោគអន្តរជាតិ បញ្ហាដែលចោទឡើងគឺថា តើត្រូវយកច្បាប់ណាមកប្រើ។ ការប្រមាថមើលងាយចំពោះការវិនិយោគបរទេសកើតមានឡើង នៅក្នុងអស្សាមិករណ៍(expropriation) ឬនៅពេលដែលរដ្ឋមិនផ្តល់ប្រព្រឹត្តកម្មជាតិទៅជនបរទេស។

ហេតុផលក្នុងការទាមទារឱ្យមានមជ្ឈត្តករអន្តរជាតិ ហើយមិនមែនជាយុត្តាធិការជាតិមាន ៖

- យុត្តាធិការក្នុងស្រុករបស់ប្រទេសទទួលវិនិយោគមានភាពលម្អៀង(ត្រូវគេសង្ស័យថាមានភាពលម្អៀង និងមិនមានដំណើរការប្រកបដោយឧត្តមគតិឡើយ)។
- រដ្ឋទាំងអស់មានអភ័យឯកសិទ្ធិខាងយុត្តាធិការ(រដ្ឋមួយមិនអាចត្រូវបានផ្តន្ទាទោសដោយតុលាការផ្ទាល់របស់រដ្ឋនោះទេ)។

មានមជ្ឈត្តការអន្តរជាតិពីរប្រភេទ គឺ ៖

* គេអាចបង្កើតមជ្ឈត្តការចំពោះកិច្ច(ad hoc) (ដែលគោរពនីតិវិធីដែលត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ(CNUDCI) អង្គជំនុំជម្រះមជ្ឈត្តការនៃសភាពាណិជ្ជកម្មអន្តរជាតិ(CCI)នៅទីក្រុងប៉ារីស សភាពាណិជ្ជកម្មនៃទីក្រុង Stockholm សភាមជ្ឈត្តការនៅក្នុងប្រទេសចិន(China International Economic and Trade Commission (CIETAC)) និងតុលាការមជ្ឈត្តការអចិន្ត្រៃយ៍ដែលស្ថិតនៅទីក្រុងឡាអេ ប្រទេសហូឡង់។ មានការប្រើប្រាស់តិចតួចប៉ុណ្ណោះក្នុងពេលបច្ចុប្បន្ននេះ។

* មជ្ឈត្តការ CIRDI នៃអនុសញ្ញា Washington ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសចំនួន១៤០។ គេប្រើប្រាស់ CIRDI ច្រើនជាងគេបំផុត។ មានមូលហេតុជាច្រើន ៖

o វាជាប្រភេទតុលាការមួយដែលមានឯកទេសខ្ពស់ជាង និងមានសមត្ថកិច្ចជាងតុលាការដទៃទៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

o ប្រព័ន្ធមជ្ឈត្តការ CIRDI មានភាពគ្រប់គ្រាន់ខ្លួនឯង។ វាគឺជាប្រព័ន្ធស្វយ័តមួយ ព្រោះថា វាមានដំណើរការដោយមិនប្រើប្រាស់ប្រព័ន្ធជាតិឡើយ។ សេចក្តីសម្រេចរបស់មជ្ឈត្តការ CIRDI មានអានុភាពអនុវត្តដោយចាប់បង្ខំនៅក្នុងគ្រប់ប្រទេសទាំងអស់ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុង Washington។

o មជ្ឈត្តការ CIRDI មានតម្លាភាព និងបើកចំហសម្រាប់សាធារណជន។

## ១- វិធានស្តីពីសមត្ថកិច្ចពិសេសរបស់មជ្ឈត្តការ CIRDI

មាត្រា២៥នៃអនុសញ្ញាទីក្រុង Washington ចែងអំពីរឿងរ៉ាវចំនួនពីរប្រភេទ ៖ គូភាគីត្រូវតែឯកភាពគ្នា(អ្នកវិនិយោគ និងរដ្ឋម្ចាស់ផ្ទះ)ទៅលើមជ្ឈត្តការ។

## ១.១- ការព្រមព្រៀងទៅលើមជ្ឈត្តការ

មានការព្រមព្រៀងពីរប្រភេទ ៖

## ១.១.១- ការព្រមព្រៀងតាមកិច្ចសន្យា

គូភាគីនៃកិច្ចសន្យាព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យា ៖ អាចនៅមុនពេលដំណើរការរឿងក្តីនៅក្នុងកិច្ចសន្យា គេបញ្ចូលខព្រមព្រៀងផ្សះផ្សា ឬបន្ទាប់ពីកិច្ចសន្យា។ គូភាគីបានប្រគល់សិទ្ធិឱ្យមជ្ឈត្តការ CIRDI។ សិទ្ធិនេះគេហៅថាជាសិទ្ធិព្រមព្រៀងគ្នា។

## ១.១.២- ការព្រមព្រៀងបែកចេញពីគ្នា

កិច្ចព្រមព្រៀបែកចេញពីគ្នាកើតមានឡើង នៅពេលដែលគូភាគីមិនបានព្រមព្រៀងគ្នានៅក្នុងពេលតែមួយ។ រដ្ឋមួយព្រមទទួលយកមជ្ឈត្តការ CIRDI នៅក្នុងសន្ធិសញ្ញា TBI។ ចំណែកឯអ្នកវិនិយោគវិញ គេព្រមទទួលយកគោលការណ៍របស់មជ្ឈត្តការ CIRDI ដោយដាក់ពាក្យបណ្តឹងទៅកាន់មជ្ឈត្តការ CIRDI។

## ១.២- គូភាគីនៃមជ្ឈត្តការ

ក. រដ្ឋ ឬសមូហភាពក្នុងស្រុក នីតិបុគ្គលដែលមានអំណាចសាធារណៈ PPP ការរួចពន្ធ-ល-។

ខ. ចំពោះអ្នកវិនិយោគ ត្រូវតែធ្វើការបែងចែករវាងរូបវន្តបុគ្គល និងនីតិបុគ្គល។

ចំពោះរូបវន្តបុគ្គល អ្នកវិនិយោគត្រូវតែមានសញ្ជាតិនៃប្រទេសហត្ថលេខីនៃអនុសញ្ញាទីក្រុង Washington ក្រៅពីសញ្ជាតិរបស់រដ្ឋទទួលវិនិយោគ។ ចំពោះពលរដ្ឋនៃរដ្ឋដូចគ្នា ត្រូវតែ

ប្ដឹងទៅយុត្តាធិការជាតិ។

ចំពោះនីតិបុគ្គលវិញ មិនត្រូវមានចំណងដោយផ្ទាល់ជាមួយសញ្ជាតិនៃរដ្ឋទទួលវិនិយោគឡើយ។ នីតិបុគ្គលអាចមានកើតចេញពីច្បាប់បរទេស អាចមានទីស្នាក់ការនៅក្នុងរដ្ឋដែលជាសមាជិកនៃអនុសញ្ញា ក្រៅពីរដ្ឋទទួលវិនិយោគ ប៉ុន្តែអាចមានចំណងប្រយោលជាមួយប្រទេសទទួលវិនិយោគ។ គេមិនចាំបាច់មើលអ្វីដែលកើតឡើងនៅក្នុងសហគ្រាសទេ ប៉ុន្តែវាគ្រប់គ្រាន់ (ចំណងប្រយោល ម្ចាស់ភាគហ៊ុនរបស់រដ្ឋទទួលវិនិយោគអាចមាននៅក្នុងសហគ្រាស ប៉ុន្តែទីស្នាក់ការរបស់សហគ្រាសស្ថិតនៅក្នុងរដ្ឋមួយផ្សេងទៀត ហើយវាជាចំណងផ្ទាល់ នៅពេលដែលទីស្នាក់ការរបស់សហគ្រាសស្ថិតនៅក្នុងរដ្ឋដែលទទួលវិនិយោគ។)

## ១.៣- វិវាទដែលអាចប្ដឹងទៅមជ្ឈត្តការ CIRDI

វិវាទដែលដាក់ជូនត្រូវតែមានទំនាក់ទំនងជាមួយច្បាប់វិនិយោគ មានន័យថា ជម្លោះទាំងនោះពាក់ព័ន្ធនឹងវិនិយោគ ក៏ប៉ុន្តែមិនពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យានោះទេ។ លក្ខខណ្ឌទាំងឡាយដែលក្នុងនោះ CIRDI មានសមត្ថកិច្ច ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនិយមន័យនៃការវិនិយោគ (ភាគហ៊ុនជាមូលធន រយៈពេល ហានិភ័យសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងការអភិវឌ្ឍនៃប្រទេសម្ចាស់ផ្ទះ)។

## ២- នីតិវិធីរបស់មជ្ឈត្តការ CIRDI

### ២.១- ការដាក់ពាក្យបណ្ដឹង

ដំណាក់កាលដំបូង ៖ ការដាក់ពាក្យបណ្ដឹង។ ការផ្ដើមនីតិវិធីត្រូវបានធ្វើឡើងតាមរយៈពាក្យបណ្ដឹងរបស់អ្នកវិនិយោគ ឬរបស់រដ្ឋណាមួយដែលត្រូវតាក់តែងឡើងជាភាសាផ្លូវការណាមួយក្នុងចំណោមភាសារបារាំង ភាសាអង់គ្លេស និងភាសាអេស្ប៉ាញ។

ដំណាក់កាលទីពីរ ៖ ការសម្រិតសម្រាំង។ អគ្គលេខាធិការនៃស្ថានមជ្ឈត្តការ CIRDI សម្រិត-សម្រាំងរឿងក្ដី និងដកចេញនូវបណ្ដឹងដែលមិនមានទំនាក់ទំនងជាមួយមជ្ឈត្តការ CIRDI (ការរំលោភ)។

ដំណាក់កាលទីបី ៖ ការរៀបចំសមាសភាពរបស់តុលាការមជ្ឈត្តការ។ ជាញឹកញាប់ មានមជ្ឈត្តករចំនួនបីរូប ៖ មជ្ឈត្តករម្នាក់ត្រូវបានតែងតាំងដោយភាគីដែលបានដាក់ពាក្យបណ្ដឹង ម្នាក់ទៀតត្រូវបានតែងតាំងដោយភាគីចុងចម្លើយ ហើយបន្ទាប់មកមជ្ឈត្តករទាំងពីររូបត្រូវតែង-តាំងប្រធានមួយរូប។ ក្នុងករណីមិនមានការព្រមព្រៀងគ្នា ស្ថាប័នមជ្ឈត្តការ CIRDI ជាអ្នកតែង-តាំងប្រធាន។ មានក្រុមអ្នកជំនាញចូលរួមផងដែរ។

ដំណាក់កាលទីបួន ៖ សវនាការ។ សវនាការប្រព្រឹត្តទៅនៅទីក្រុងប៉ារីស។ សវនាការទាំងនេះប្រព្រឹត្តទៅតាមបែបប្រព័ន្ធច្បាប់ anglo-saxon។ ចៅក្រមសួរដេញដោលសាក្សីបន្ទាប់មកមេធាវីរបស់ដើមបណ្តឹងសាកសួរសាក្សី បន្ទាប់មកគឺការស្តាប់សេចក្តីថ្លែងរបស់សាក្សីភាគីចុងចម្លើយ-ល-។ (បើតាមច្បាប់បារាំងមិនមែនដូច្នេះនោះទេ)។ គឺមានទិន្នាការចង់ធ្វើសវនាការជាសាធារណៈ។ អង្គការក្រៅរដ្ឋាភិបាលនានាអាចធ្វើអន្តរាគមន៍ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីយោងតាមគោលការណ៍អ្នកជូនយោបល់តុលាការ។

## ២.២- នីតិវិធី

ចៅក្រមមានដែនកំណត់ ពេលគឺមានសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ។

## ២.៣- ច្បាប់អនុវត្តរបស់ស្ថាប័នមជ្ឈត្តការ CIRDI

សន្ធិសញ្ញា TBI កំណត់អំពីច្បាប់ដែលអាចអនុវត្តបាន។ ប្រសិនបើគ្មានបទប្បញ្ញត្តិនេះទេនោះគេត្រូវអនុវត្តច្បាប់ទំនៀមទម្លាប់ ៖ គេត្រូវវិភាគថា តើអ្នកវិនិយោគត្រូវបានធ្វើប្រព្រឹត្តកម្មត្រឹមត្រូវដោយប្រទេសទទួលវិនិយោគឬទេ។ ចៅក្រមនឹងពិនិត្យមើលថា តើច្បាប់ជាតិស្របទៅនឹងសន្ធិសញ្ញាដែររឺទេ។ នៅប្រទេស Burundi គឺច្បាប់ជាតិដែលគ្រប់គ្រងលើអាជ្ញាប័ណ្ណ។ មជ្ឈត្តករពិនិត្យ ហើយបន្ទាបមកវិនិច្ឆ័យថា តើអាជ្ញាប័ណ្ណត្រូវបានដកហូត ដោយអនុលោមទៅតាមកិច្ចសន្យានៅក្នុងសន្ធិសញ្ញា TBI ឬទេ។

## ២.៤- សេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យរបស់ស្ថាប័នមជ្ឈត្តការ CIRDI

ជាដំបូង សេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យរបស់ស្ថាប័នមជ្ឈត្តការ CIRDI អាចដាក់ឱ្យអនុវត្តបាននៅក្នុងប្រទេសជាសមាជិកនៃអនុសញ្ញាទីក្រុង Washington។

បន្ទាប់មកទៀត សេចក្តីសម្រេចនេះអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បាន ប៉ុន្តែវាមិនអាចធ្វើឡើងនៅចំពោះមុខតុលាការជាតិបានឡើយ ប៉ុន្តែនៅចំពោះមុខគណៈកម្មាធិការចំពោះកិច្ច (ad hoc) របស់ស្ថាប័នមជ្ឈត្តការ CIRDI (ការប្តឹងឧទ្ធរណ៍នេះត្រូវធ្វើឡើងជាផ្ទៃក្នុង)។ ការប្តឹងឧទ្ធរណ៍នេះមិនមែនជាបណ្តឹងឧទ្ធរណ៍ពិតប្រាកដនោះទេ។ ឧទាហរណ៍ តុលាការអាចជំនុំជម្រះសុំណុំរឿងម្តងទៀតបាន។

## មូលហេតុចំនួនប្រាំនៃការប្តឹងឧទ្ធរណ៍ ៖

១. មានវិការៈនៅក្នុងការបង្កើតតុលាការ។

២. ការរំលោភអំណាចច្បាស់ក្រឡែតរបស់តុលាការ( តុលាការមានការភ័ន្តច្រឡំយ៉ាងធ្ងន់ធ្ងរ មិនមានសមត្ថកិច្ច មានការរំលោភអំណាចដែលត្រូវបានចែងដោយច្បាប់ អនុវត្តច្បាប់មិនបានត្រឹមត្រូវទាល់តែសោះ)។

៣. អំពើពុករលួយរបស់សមាជិកណាមួយនៃតុលាការ។

៤. ការបំពានធ្ងន់ធ្ងរលើវិធានជាសារវន្តនៃនីតិវិធីមួយ( មិនគោរពគោលការណ៍តតាំងគ្នា-គូភាគីត្រូវតែផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវទឡ្ហីករណ៍ និងឆ្លើយតបលើទឡ្ហីករណ៍រៀងៗខ្លួន)។

៥. មិនមានមូលហេតុ( ក្នុងពេលដែលចៅក្រមមិនមានទឡ្ហីករណ៍គតិយុត្ត មិនបានផ្តល់អំណះអំណាង ធ្វើសេចក្តីសម្រេចដោយគ្មានទឡ្ហីករណ៍)។

ប្រសិនបើបណ្តឹងឧទ្ធរណ៍ត្រូវបានទទួល គេរៀបចំមជ្ឈត្តការថ្មីមួយទៀត។

# ជំពូក១២
# នីតិនៃវិវាទអន្តរជាតិ

នីតិនៃវិវាទអន្តរជាតិត្រូវចាត់ទុកថាជានីតិឯកជន។

នីតិនៃវិវាទអន្តរជាតិសាធារណៈ គឺជានីតិអន្តរជាតិសាធារណៈផ្លូវការ និងសម្ភារ។

នីតិសម្ភារ ៖ គោលការណ៍សុចរិតភាព(មេរៀននីតិអន្តរជាតិសាធារណៈ)។

វាគឺជាបាតុភូតយុត្តាធិការភាវូបនីយកម្ម។ ពេលមានចលនាមួយនៃយុត្តាធិការភាវូបនីយកម្ម ចៅក្រម និងតុលាការមានតួនាទីសំខាន់ខ្លាំងណាស់។

និយមន័យនៃយុត្តាធិការ ៖ គេឱ្យនិយមន័យយុត្តាធិការតាមរយៈមុខងាររបស់យុត្តាធិការ។ តុលាការមួយអាចមានមុខងារជាអ្នកពិគ្រោះយោបល់ ឬដោះស្រាយវិវាទ។

នៅក្នុងច្បាប់ផ្ទៃក្នុង តុលាការមួយមានមុខងារយុត្តាធិការ។ ក៏ប៉ុន្តែ នៅក្នុងមុខងារធ្វើច្បាប់ គេមានមុខងារយុត្តាធិការ។ អន្តរការីរបស់សាធារណៈរដ្ឋមានមុខងារយុត្តាធិការ។ មានការបង្កើតតុលាការពិសេសដូចជាតុលាការយោធា។ តុលាការក៏មានមុខងាររដ្ឋបាលនៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងផ្នែករដ្ឋបាលគតិយុត្តដែរ។

នៅក្នុងមុខងារយុត្តាធិការ ៖ *Léon Duguit* បានឱ្យនិយន័យអំពីមុខងារយុត្តាធិការបែបទូលាយគួរសម។ ការឱ្យនិយមន័យទៅលើមុខងារ គឺការឱ្យនិយមន័យទៅលើសកម្មភាព ពោលគឺត្រូវតែកំណត់ខ្លឹមសារ ៖ គឺជាកិច្ចយុត្តាធិការ។ គេអាចបង្វែរទៅរកកិច្ចយុត្តាធិការដែលផ្សំឡើងពីធាតុផ្សំចំនួនបីគឺ ៖ (*i*) បញ្ហាច្បាប់ដែលគេចោទសួរទៅចៅក្រម ឬដែលចៅក្រមចោទសួរដោយខ្លួនឯង(ជម្លោះ) (*ii*) ដំណោះស្រាយគតិយុត្ត(ការអនុវត្តច្បាប់) (*iii*) សេចក្តីសម្រេច - ផលវិបាកនៃដំណោះស្រាយ។

នៅក្នុងនីតិអន្តរជាតិ ៖ យុត្តាធិការគឺជាអង្គភាពមួយដែលមានមុខងារបញ្ចប់ជម្លោះ តាមរយៈសេចក្តីសម្រេចដែលមានលក្ខណៈចាប់បង្ខំដែលកើតចេញពីការអនុវត្តច្បាប់/នីតិ។

- *iuris dicto* សេចក្តីសម្រេចមានលក្ខណៈបង្ខំ
- វិវាទចាំបាច់ ជម្លោះ
- វិនិច្ឆ័យវិវាទមួយត្រូវអនុលោមទៅតាមមុខងាររបស់អង្គភាព ការអនុវត្តច្បាប់។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*មុខងារយុត្តាធិការអាចត្រូវបានអនុវត្តដោយតុលាការ អង្គភាពដោះស្រាយវិវាទ(ORD) របស់អង្គការពាណិជ្ជកម្មពិភពលោកដែលមានអាជ្ញាអង្គជំនុំ។*

*អ្នកសរសេរលិខិតយុត្តាធិការ ៖ អាចត្រូវហៅថាជាស្ថាប័ន ឬក្រុមប្រឹក្សាបាន។*

*គេត្រូវតែធ្វើការបែងចែកមុខងារយុត្តាធិការពីយុត្តាធិការវិវាទ។*

*វិវាទមួយមិនអាចសង្ខេបសេចក្តីរបស់ខ្លួនមកត្រឹមជាយុត្តាធិការបានទេ។ គេអាចមានរបៀបផ្ទាស់គ្នាក្នុងការដោះស្រាយវិវាទ ៖ ការចរចា ការផ្សះផ្សា ការជួយផ្សះផ្សា។*

*យុត្តាធិការ ៖ អង្គការពាណិជ្ជកម្មពិភពលោក(WTO ឬOMC) តុលាការអចិន្ត្រៃយ៍អន្តរជាតិ (CPI) តុលាការយុត្តិធម៌អន្តរជាតិ(CIJ ឬICJ) តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ(TIDM) តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស(CEDH) និងតុលាការយុត្តិធម៌សហគមន៍អឺរ៉ុប(CJCE)ជាស្ថាប័នថ្នាក់តំបន់ដែលមានយុត្តាធិការ។*

# ផ្នែកទី១

## កាតព្វកិច្ចនៃការដោះស្រាយជម្លោះដោយសន្តិវិធី

*កាតព្វកិច្ចនៃការដោះស្រាយជម្លោះដោយសន្តិវិធី ៖ វចនានុក្រម Salmon បានផ្តល់និយមន័យនៃពាក្យជម្លោះថា ៖ «ជាការតវ៉ារវាងប្រធានសិទ្ធិពីរដែលមានប្រភពចេញពីទំនាស់រវាងការទាមទារ ឬផលប្រយោជន៍ ហើយដែលអាចបង្កើតឱ្យមានជម្លោះប្រដាប់អាវុធរវាងគ្នា» (ទំព័រ៣៣៧)។ ជម្លោះ ៖ មានធាតុពីរ ៖ ការទាមទារដែលប្រឈមជាមួយការជំទាស់។*

*កាតព្វកិច្ចបានកើតឡើងនៅក្នុងស.វ.ទី២០នៅក្នុងច្បាប់សង្គ្រាមនៅក្នុងអនុសញ្ញាទីក្រុងឡាអេ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩០៧ ដើម្បីដោះស្រាយវិវាទអន្តរជាតិ(ដែលនៅជាចំណុះក្នុង soft lawនៅឡើយ)។ ចាប់ពីពេលនោះមក កាតព្វកិច្ចនេះត្រូវបានពង្រឹង ហើយទម្រង់របស់វាមានរចនាសម្ព័ន្ធត្រឹមត្រូវ ជាពិសេសនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ។*

*ជាមួយការបង្កើតសង្គមប្រជាជាតិ(SdN ១៩១៩)បន្ទាប់ពីសង្គ្រាមលោកលើកទីមួយ ការប្រើប្រាស់កម្លាំងមិនត្រូវបានហាមឃាត់ទេ ប៉ុន្តែត្រូវបានគ្រប់គ្រង។*

*កតិកាសញ្ញា Briand-Kellog ឆ្នាំ១៩២៨ ហាមប្រាមមិនឱ្យមានសង្គ្រាម(ដោយដាក់សង្គ្រាមនៅក្រៅច្បាប់)។ នេះគឺជាកាលបរិច្ឆេទសំខាន់នៅក្នុងនីតិអន្តរជាតិ។ គឺជាកាលបរិច្ឆេទដែលមានការហាមឃាត់មិនឱ្យមានសង្គ្រាមកើតឡើង។ សមាជិកនៃអង្គភាពនេះធ្វើអនុប្បវាទមិន*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រើប្រាស់សង្គ្រាម ព្រមទាំងការគំរាមកំហែងផងដែរ។ សន្ធិសញ្ញានេះត្រូវបានចុះហត្ថលេខានៅឆ្នាំ១៩២៨ នៅទីក្រុងប៉ារីស ហើយតាមរយៈនោះ ប្រទេសហត្ថលេខី«ផ្តន្ទាទោសចំពោះការប្រើ-ប្រាស់សង្គ្រាម ដើម្បីដោះស្រាយជម្លោះអន្តរជាតិ»។

ធម្មនុញ្ញអង្គការសហប្រជាជាតិចែងថា សមាជិកនានាត្រូវតែដោះស្រាយជម្លោះដោយសន្តិ-វិធី។ នេះជាច្បាប់ដែលត្រូវតែគោរព។ គឺជា«ការហាមឃាត់ការប្រើប្រាស់កម្លាំង ដើម្បីរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ»។

កាតព្វកិច្ចនេះត្រូវបានប្រកាសជាឱឡារិកដោយកថាខណ្ឌទី៣ មាត្រា២នៃធម្មនុញ្ញដែលតាមរយៈមាត្រានេះ «សមាជិកអង្គការនេះត្រូវដោះស្រាយជម្លោះអន្តរជាតិរបស់ពួកគេដោយមធ្យោបាយសន្តិវិធី ពោលគឺតាមគ្រប់មធ្យោបាយណាក៏ដោយដែលមិនបង្កគ្រោះថ្នាក់ដល់សន្តិ-ភាព និងសន្តិសុខអន្តរជាតិ ព្រមទាំងយុត្តិធម៌ផងដែរ»។

កថាខណ្ឌទី៤ មាត្រា២នៃធម្មនុញ្ញអង្គការសហប្រជាជាតិចែងក្នុងន័យនេះថា «នៅក្នុងទំនាក់ទំនងរបស់ពួកគេ សមាជិកទាំងអស់នៃអង្គការសហប្រជាជាតិមិនត្រូវប្រើប្រាស់ការគំរាមកំហែង ឬកម្លាំង ដើម្បីប្រឆាំងនឹងបូរណភាពដែនដី ឬឯករាជ្យភាពនយោបាយនៃរដ្ឋណាមួយ ឬតាមរបៀបណាមួយដែលផ្ទុយទៅនឹងគោលបំណងរបស់អង្គការសហប្រជាជាតិឡើយ»។

ធម្មនុញ្ញអង្គការសហប្រជាជាតិបានបង្កើតតុលាការយុត្តិធម៌អន្តរជាតិ(CIJ)ដែលជាស្ថាប័នសំខាន់ទី៥របស់អង្គការនេះ(ក្រុមប្រឹក្សាសន្តិសុខ អង្គមហាសន្និបាតក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម និងក្រុមប្រឹក្សាអាណាព្យាបាល)។ យុត្តិធម៌គឺជាអាទិភាពសម្រាប់អង្គការសហប្រជាជាតិ។ តុលាការយុត្តិធម៌នេះគ្រាន់តែជាអង្គភាពជំនួយសម្រាប់ថែរក្សាសន្តិភាព និងសន្តិសុខដើម្បីថែរក្សាសន្តិភាពតែប៉ុណ្ណោះ។

នៅក្នុងច្បាប់អន្តរជាតិ យុត្តិធម៌ត្រូវតែសំដែងឡើង។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(CETC)ក្លាយជាកម្មវត្ថុនៃការរិះគន់ ៖ «តុលាការនេះគ្មានយុត្តិធម៌ទេ ព្រោះថា ការជ្រើស-រើសមានលក្ខណៈងាយស្រួលហួសហេតុសម្រាប់ជនជាប់ចោទ»។ នៅក្នុងច្បាប់អន្តរជាតិ នៅពេលដែលគេវិនិច្ឆ័យពីយុត្តិធម៌ គឺដើម្បីថែរក្សាសន្តិភាព និងសន្តិសុខ។

តុលាការយុត្តិធម៌អន្តរជាតិ(CIJ)បានរំឭកថា សេចក្តីសម្រេចរបស់តុលាការនេះឈរលើការថែរក្សាសន្តិភាព។ នៅក្នុងសំណុំរឿងរដ្ឋ Kosovo តុលាការនេះបានរំឭកពីក្តីកង្វល់របស់ខ្លួនក្នុងការថែរក្សាសន្តិភាព តាមរយៈការដោះស្រាយជម្លោះដោយសន្តិវិធី(អធិបញ្ញាចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៩ កថាខណ្ឌ៣១-៣២)។

ការដោះស្រាយជម្លោះមិនចាំបាច់តាមលក្ខណៈគតិយុត្តនោះទេ នៅពេលដែលច្បាប់ដើរតួនាទីបន្ថែម ឬជំនួយ។ ក៏ប៉ុន្តែមហាសន្និបាតនៃអង្គការសហប្រជាជាតិបានតាក់តែងសេចក្តី

ថ្លែងការសំខាន់ៗចំនួនពីរទាក់ទងទៅនឹងការដោះស្រាយតាមយុត្តាធិការ ៖

- សេចក្តីប្រកាសស្តីពីគោលការណ៍នៃច្បាប់អន្តរជាតិដែលពាក់ព័ន្ធនឹងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ ស្របទៅនឹងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ( សេចក្តីសម្រេចលេខ២៦២៥(XXV) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧០)។

- សេចក្តីថ្លែងការណ៍ទីក្រុងម៉ានីលស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធី( សេចក្តីសម្រេចលេខ៣៧/១០ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៨២)។

កាតព្វកិច្ចនៃការដោះស្រាយជម្លោះ គឺជាការដោះស្រាយលើអាកប្បកិរិយា មិនមែនលទ្ធផលនោះទេ និងមិនតម្រូវឱ្យមានការដោះស្រាយជម្លោះជាក់លាក់នោះទេ។ និយាយម្យ៉ាងទៀត កាតព្វកិច្ចនេះមិនដាក់កំហិតដល់រដ្ឋនានាឱ្យត្រូវតែដោះស្រាយជម្លោះរបស់ពួកគេនោះឡើយ ប៉ុន្តែហាមឃាត់ពួកគេមិនឱ្យដោះស្រាយជម្លោះដោយប្រើមធ្យោបាយហិង្សា។ ដូច្នេះ មានចំណងរវាងការដោះស្រាយជម្លោះដោយសន្តិវិធី និងការហាមឃាត់មិនឱ្យប្រើប្រាស់កម្លាំង។

ក៏ប៉ុន្តែ នៅពេលមានជម្លោះរវាងរដ្ឋ និងរដ្ឋ ពួកគេត្រូវតែចរចាគ្នា និងធ្វើការចរចាដោយសុចរិត។

តុលាការយុត្តិធម៌អន្តរជាតិបានរំឭកនៅក្នុងសំណុំរឿងខ្ពង់រាបបាតសមុទ្រនៃសមុទ្រខាងជើង(Nord) (សាលដីកាចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៦៩)ថា «គូភាគីមានកាតព្វកិច្ចត្រូវប្រកាន់អាកប្បកិរិយាយ៉ាងណាដើម្បីឱ្យការចរចាមានន័យ ដែលនេះមិនអាចសម្រេចទៅបានទេ នៅពេលភាគីមួយនៅតែទទូចប្រកាន់គោលជំហរផ្ទាល់របស់ខ្លួន ដោយមិនគ្រោងទុកការកែប្រែណាមួយ»។ តុលាការចាត់ទុកថា នេះគឺជា«ការអនុវត្តជាពិសេសមួយនៃគោលការណ៍មួយដែលជាមូលដ្ឋានគ្រឹះនៃទំនាក់ទំនងអន្តរជាតិ»។ តុលាការត្រូវតែចាត់វិធានការដោយសុចរិត( គោលការណ៍សុចរិតភាព)។ ការអនុវត្តជាពិសេសនូវគោលការណ៍នៃសុចរិតភាព គឺជាមូលដ្ឋាននៃកាតព្វកិច្ចអន្តរជាតិ។

នៅក្នុងរបាយការណ៍របស់ខ្លួនឈ្មោះ Etat-Unis-Crevettes អង្គភាពបណ្តឹងឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោកក៏បានចាត់ទុកថា សុចរិតភាពគឺជាគោលការណ៍គតិយុត្តទូទៅ និងជាគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ។ សុចរិតភាពគឺជាវិធានទំនៀមទម្លាប់ដែលត្រូវបានបង្កើតយ៉ាងត្រឹមត្រូវ ទោះបីជាច្បាប់នេះជាកម្មវត្ថុនៃការរំឭកតាមអនុសញ្ញាក៏ដោយ។

ជាគោលការណ៍ រដ្ឋទាំងអស់មានកាតព្វកិច្ចប្រើប្រាស់រាល់វិធីដោះស្រាយជម្លោះដោយសន្តិវិធី។ រដ្ឋអាចសំអាងពីកង្វះខាតនៃកាតព្វកិច្ចដោយសុចរិតបាន។ គេអាចផ្អាកការចរចាបាន។ ប៉ុន្តែ ប្រឈមមុខនឹងកង្វះខាតនូវដំណោះស្រាយដោយសុចរិត គេអាចប្រើប្រាស់មធ្យោយហិង្សាដើម្បីដោះស្រាយជម្លោះ។

គ្មានកាតព្វកិច្ចក្នុងការចុះកិច្ចព្រៀមព្រៀងមួយឡើយ។ មានជម្លោះជាច្រើនដែលអូសបន្លាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*យូរ រួមទាំងជម្លោះរវាងរដ្ឋដែលរក្សានូវទំនាក់ទំនងមិត្តភាពឥតខ្ចោះទៀតផង។ ឧទាហរណ៍ ព្រំដែនរវាងសហរដ្ឋអាមេរិក និងប្រទេសម៉ិចស៊ិក។*

*ការលើកលែង ៖ នៅពេលដែលអវត្តមាននៃការដោះស្រាយជម្លោះដោយសន្តិវិធីក្លាយទៅជាការគំរាមកំហែងដល់សន្តិសុខ និងសន្តិភាពអន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិបានបង្កើតនូវបទប្បញ្ញត្តិមួយចំនួន សម្រាប់ការប្រើប្រាស់កម្លាំង។ ជំពូកទី៧នៃធម្មនុញ្ញអនុញ្ញាតឱ្យរដ្ឋនានាប្រើប្រាស់កម្លាំង អនុញ្ញាតដោយក្រុមប្រឹក្សាសន្តិសុខ។*

*មាត្រា៣៣នៃធម្មនុញ្ញអង្គការសហប្រជាជាតិដាក់កាតព្វកិច្ចដល់រដ្ឋនានាឱ្យស្វែងរកដំណោះស្រាយសន្តិវិធី។ ដើម្បីធ្វើដូច្នេះបាន រដ្ឋទាំងនោះត្រូវតែប្រើប្រាស់គ្រប់មធ្យោបាយក្នុងការដោះស្រាយ ដើម្បីជ្រើសរើសនៅក្នុងចំណោមមធ្យោបាយជាច្រើនដែលត្រូវបានរៀបរាប់មិនតាមលំដាប់ថ្នាក់ និងមិនទាន់អស់សេចក្តី។ ការដោះស្រាយបែបនេះពឹងផ្អែកទៅលើឆន្ទៈរបស់រដ្ឋដែលពាក់ព័ន្ធនឹងជម្លោះនោះ។ គឺការដោះស្រាយបែបនោះហើយដែលការប្រកួតប្រជែងរវាងមធ្យោបាយសន្តិវិធីនានាក្នុងការដោះស្រាយជម្លោះចូលមកធ្វើអន្តរាគមន៍។*

# ផ្នែកទី២
# ការប្រកួតប្រជែងនៃវិធីដោះស្រាយជម្លោះអន្តរជាតិ ដោយសន្តិវិធី

*គេមិនទាមទារឱ្យមានការដោះស្រាយតាមផ្លូវតុលាការនោះឡើយ។ ការដោះស្រាយដោយសន្តិវីធីគ្រប់គ្រាន់ហើយ។ កាតព្វកិច្ចក្នុងការដោះស្រាយជម្លោះមានកម្រិតអប្បបរមា។*

## ១- គោលការណ៍នៃការជ្រើសរើសដោយសេរី

*ច្បាប់អន្តរជាតិទូទៅពាក់ព័ន្ធនឹងទំនាក់ទំនងរវាងរដ្ឋ និងប្រធាននៃច្បាប់អន្តរជាតិ( ដូចជាអង្គការអន្តរជាតិជាដើម)។ វាក្តោបទៅលើច្បាប់ទំនៀមទម្លាប់ និងច្បាប់សន្ធិសញ្ញា។ ច្បាប់អន្តរជាតិទំនើបមិនផ្តោតតែទៅលើទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋនោះទេ ប៉ុន្តែក៏ផ្តោតទៅលើ ៖ លំហអង្គការអន្តរជាតិ សិទ្ធិ និងកាតព្វកិច្ចនៃបុគ្គលនានានៅក្នុងរដ្ឋផ្សេងៗ ជាឧទាហរណ៍មានទំនាក់-ទំនងជាមួយសិទ្ធិមនុស្ស ឬទោសទណ្ឌរបស់ច្បាប់អន្តរជាតិ។ បើរដ្ឋមួយមិនមែនជាសមាជិកនៃសន្ធិសញ្ញាមួយ ប៉ុន្តែប្រសិនបើទម្លាប់បានចែង រដ្ឋនោះត្រូវតែស្ថិតនៅក្រោមបែបបទនោះ។ គេ*


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អាចចែងនៅក្នុងសន្ធិសញ្ញាមួយ ហើយបន្ទាប់មកចែងនៅក្នុងទំនៀមទម្លាប់ថែមទៀត។

មានបែបបទជាច្រើនក្នុងការដោះស្រាយជម្លោះ។ បែបបទទាំងនោះមិនត្រូវបានប្រើប្រាស់ដាច់ដោយឡែកបាននោះទេ គឺគេប្រើប្រាស់របៀបដោះស្រាយជាច្រើន ពោលគឺគេមានសេរីភាពក្នុងការជ្រើសរើស។ រដ្ឋនានាអាចចរចាគ្នាដើម្បីស្វែងរកបែបបទនៃការដោះស្រាយណាមួយដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយដែលនៅក្នុងនោះ ពួកគេនឹងបង្កើតវិធីសាស្ត្រនៃការដោះស្រាយ។ គេអាចបង្កើតបេសកកម្មចម្រុះមួយដែលមានសមាសភាពមកពីគូភាគីស្មើគ្នា។ រដ្ឋនានាមានសេរីភាពក្នុងការជ្រើសរើស។

មាត្រា៣៣នៃធម្មនុញ្ញអង្គការសហប្រជាជាតិលើកឡើងនូវបញ្ជីដំណោះស្រាយមិនទាន់ពេញលេញមួយដែលរួមមានការចរចា ការស៊ើបអង្កេត សន្ទានកម្ម ការផ្សះផ្សា មជ្ឈត្តការ ការដោះស្រាយតាមផ្លូវតុលាការ។ គេបន្ថែមការនាំសម្រុះសម្រួលដែលមាត្រា៣៣មិនបានបញ្ជាក់ ប៉ុន្តែមានលេចឡើងនៅក្នុងសេចក្តីប្រកាសទីក្រុងម៉ានីលឆ្នាំ១៩៨២។

បែបបទនៃការដោះស្រាយជម្លោះតាមផ្លូវតុលាការមិនមែនមានអាទិភាពនោះឡើយ។ មាត្រា៣៦បង្ហាញថា «ជម្លោះផ្នែកគតិយុត្តត្រូវដាក់ជូនដោយគូភាគីទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ»។

ប៉ុន្តែ មានបទប្បញ្ញត្តិចម្រូងចម្រាស់មួយទៀតក្នុងមាត្រា៩៥នៃធម្មនុញ្ញដែលទទួលការរិះគន់យ៉ាងខ្លាំងដែលចែងថា ៖ «គ្មានបទប្បញ្ញត្តិណាមួយនៃធម្មនុញ្ញនេះហាមឃាត់មិនឱ្យសមាជិកអង្គការប្រគល់ការដោះស្រាយជម្លោះរបស់ពួកគេឱ្យទៅតុលាការផ្សេងៗ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងដែលមានស្រាប់ ឬដែលអាចនឹងត្រូវធ្វើនៅពេលអនាគតទេ»។ ដូច្នេះ គេអាចផ្តល់អាទិភាពទៅលើអនុសញ្ញា និងអង្គការតំបន់ ដើម្បីដោះស្រាយជម្លោះនានា។

សេរីភាពនៃការជ្រើសរើសមធ្យោបាយក្នុងការដោះស្រាយជម្លោះ មានចែងនៅក្នុងសេចក្តីប្រកាសទីក្រុងម៉ានីលស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធី - ជម្លោះអន្តរជាតិត្រូវតែដោះស្រាយដោយឈរលើសមភាពអធិបតេយ្យភាពរបស់រដ្ឋ និងស្របទៅតាមគោលការណ៍នៃការជ្រើសរើសមធ្យោបាយដោយសេរី»។ រដ្ឋទាំងអស់នៅតែមានអធិបតេយ្យភាព។

គោលការណ៍នៃការជ្រើសរើសដោយសេរីមានដែនកំណត់ នៅពេលដែលរដ្ឋប្រតិបត្តិ។ នេះជាវិធានជំនួសបន្ថែម។ រដ្ឋទាំងអស់នៅតែអាចព្រមព្រៀងគ្នាតាមរយៈកិច្ចព្រមព្រៀងពិសេសណាមួយក្នុងការប្រើប្រាស់មធ្យោបាយណាមួយ ដើម្បីដោះស្រាយជម្លោះជាក់លាក់នានា។

រដ្ឋសមាជិកនៃសហភាពអឺរ៉ុបមានកាតព្វកិច្ចដាក់ពាក្យបណ្តឹងទៅតុលាការយុត្តិធម៌សហគមន៍អឺរ៉ុប (CJCE) ដែលជានាមុខងារយុត្តាធិការ តាមមាត្រា ex-២១៩ នៃសន្ធិសញ្ញាទីក្រុងរ៉ូម។

នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក មានយន្តការដោះស្រាយជម្លោះផ្ទៃក្នុងដែលចាំបាច់។ មានការប្រឹក្សាក្រុមពិសេសមួយ និងអង្គភាពបណ្តឹងឧទ្ធរណ៍ដែលជាអង្គភាពអចិន្ត្រៃយ៍ដែលជានា


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

*យុត្តិសាស្ត្ររបស់អង្គការ WTO។*

*គោលការណ៍នៃការជ្រើសរើសដោយសេរីបានធ្វើឱ្យចំនួនយុត្តាធិការកើនឡើងច្រើន។ នេះគឺជាគោលការណ៍នៃច្បាប់អន្តរជាតិដែលជាឆន្ទៈនិយម។*

## ២- មធ្យោបាយតាមផ្លូវតុលាការ

*គេអាចមានអន្តរាគមន៍ពីសំណាក់តតិយជន។ ដំណោះស្រាយត្រូវសំអាងលើច្បាប់។ សេចក្តីសម្រេចមានការរឹតត្បិតគឺមានអាជ្ញាអង្គជំនុំ។*

*គេបែងចែកមធ្យោបាយដោះស្រាយជម្លោះជាពីរប្រភេទ ៖ មធ្យោបាយតាមផ្លូវនយោបាយ ឬតាមផ្លូវការទូតដែលឈានដល់ការដោះស្រាយជាក់លាក់ណាមួយ យោងទៅតាមមូលហេតុផ្សេងៗដែលមិនចាំបាច់ឱ្យមានការស្វែងរកនូវភាពស្របច្បាប់នោះឡើយ។ នៅក្នុងប្រភេទទីមួយ ៖ គេធ្វើចំណាត់ថ្នាក់នៅក្នុងប្រភេទនោះមានការចរចាការសម្រុះសម្រួលសន្ធានកម្ម(médiation) ការអង្កេត និងការផ្សះផ្សា។*

*ទីពីរគឺជាប្រភេទនៃមធ្យោបាយគតិយុត្តដែលឈានទៅដល់ដំណោះស្រាយមួយដោយឈរលើវិធានច្បាប់មួយ ឬច្រើន ៖ មជ្ឈត្តការ និងការដោះស្រាយតាមផ្លូវតុលាការ។ ឧទាហរណ៍មាត្រា៣៨នៃលក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិចែងថា វាជាសមត្ថកិច្ចរបស់តុលាការក្នុងការ «ដោះស្រាយជម្លោះដែលត្រូវបានប្តឹងមកតុលាការដោយអនុលោមទៅតាមច្បាប់អន្តរជាតិ»។ វិធីយុត្តាធិការទាំងនេះឈានដល់ដំណោះស្រាយចាប់បង្ខំមួយ។*

*យោងតាមចៅក្រមផ្ទៃក្នុង គេរិះគន់ច្បាប់អន្តរជាតិចំពោះសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ មិនមែនជាកាតព្វកិច្ចដូចច្បាប់ផ្ទៃក្នុងនោះទេ ព្រោះថា សេចក្តីសម្រេចទាំងនោះមិនបានដាក់ទណ្ឌកម្ម។ មានបញ្ហាប្រសិទ្ធភាពរបស់ច្បាប់។*

## ៣- មធ្យោបាយក្រៅផ្លូវតុលាការ

*មធ្យោបាយក្រៅផ្លូវតុលាការគឺជាមធ្យោបាយទន់ភ្លន់ដែលមិនឈរទៅលើច្បាប់។ រដ្ឋនានាផ្តោតជាចម្បងទៅលើកាលានុវត្តភាព សមធម៌ និងច្បាប់(ព្រំដែន)។ ទង្វើករណ៍ត្រូវបានប្រើប្រាស់ដោយរដ្ឋនៅក្នុងមធ្យោបាយក្រៅផ្លូវតុលាការ។ ដំណោះស្រាយការទូតត្រូវបានបង្ហាញតាមរយៈការស្វែងរកផលប្រយោជន៍របស់គូភាគី ពោលគឺដំណោះស្រាយតាមការព្រមព្រៀងគ្នា។*

*មធ្យោបាយដោះស្រាយជម្លោះក្រៅផ្លូវតុលាការត្រូវបែកចែកដាច់ពីគ្នា ទៅតាមអន្តរាគមន៍ ឬគ្មានការចូលរួមពីសំណាក់ជនទីបី។ ប៉ុន្តែគេធ្វើការបែងចែកកម្រិតនៃភាពពាក់ព័ន្ធរបស់ជនទីបីនៅក្នុងដំណើរការនៃការដោះស្រាយជម្លោះ។*

ការចរចា(négociation) ក្នុងន័យចង្អៀត គឺសំដៅដល់វិធីមួយដែលពាក់ព័ន្ធតែទៅលើគូភាគី។ ការចរចានេះមិនពាក់ព័ន្ធនឹងភាគីទីបី និងអាចជាមធ្យោបាយដែលមិនអាចសម្រេចជាលទ្ធផលបានឡើយ។ ការចរចាទ្វេភាគីមិនមែនជាវិធីសាស្ត្រទីមួយទេ ពីព្រោះថាការចរចាមានរយៈពេលយូរ។ ក៏ប៉ុន្តែការដោះស្រាយដែលត្រូវបានព្រមព្រៀងដោយផ្ទាល់ ដោយគូភាគីជម្លោះគឺជាដំណោះស្រាយដ៏ល្អបំផុត។

អន្តរាគមន៍របស់ភាគីទីបីភ្ជាប់នឹងគំនិតដែលថា ការដោះស្រាយទាមទារឱ្យមាននូវអន្តរាគមន៍ពីភាគីទីបី និងចាំបាច់ត្រូវការពាក្យបណ្ដឹងទៅតុលាការ។ បច្ចុប្បន្ននេះ អន្តរាគមន៍របស់ភាគីទីបីត្រូវប្រើញឹកញាប់យ៉ាងខ្លាំង។

ជាទូទៅ វិវាទគឺជាសញ្ញានៃច្បាប់ដែលដំណើរការមិនល្អ។ មិនត្រូវសប្បាយរីករាយជាមួយនឹងវិវាទអន្តរជាតិនោះឡើយ។ គឺមេធាវីទេដែលជាអ្នកទទួលបានផលប្រយោជន៍ មិនមែនវិធានច្បាប់នោះទេ។ ហេតុនេះហើយ នៅក្នុងច្បាប់អន្តរជាតិ មាននិន្នាការក្នុងការជំរុញឱ្យគូភាគីធ្វើការចរចាជាមុនសិន។

ដូច្នេះ យន្តការដោះស្រាយជម្លោះរបស់អង្គការពាណិជ្ជកម្មពិភពលោកនៅតែផ្ដល់អាទិភាពជាចម្បងទៅលើការស្វែងរកការចរចា ស្របពេលជាមួយនឹងការដោះស្រាយតាមផ្លូវតុលាការ។ ទោះបីជាក្នុងពេលដែលក្រុមពិសេសមួយត្រូវបានបង្កើតឡើងហើយក៏ដោយ ក៏គូភាគីអាចបន្តធ្វើការចរចាគ្នា ហើយអាចឈានទៅដល់ការដោះស្រាយជម្លោះដោយភាតរភាពជាយថាហេតុបានដែរ។

មធ្យោបាយដោះស្រាយជម្លោះក្រៅផ្លូវតុលាការដទៃទៀតត្រូវមានភាគីទីបីចូលរួម។

ការសម្រុះសម្រួល(les bons offices)គឺជាអន្តរាគមន៍របស់ភាគីទីបីដែលមានតួនាទីជួយគូភាគី និងដឹកនាំការចរចា។ ភាគីទីបីជាអ្នកបើកការចរចា និងកំណត់របៀបវារៈ។ ភាគីទីបីមិនស្នើដំណោះស្រាយទេ។ គូភាគីត្រូវតែជួបគ្នា និងពិភាក្សាគ្នា។ ឧទាហរណ៍ ៖ សន្និសីទសន្តិភាពនៅប្រទេសវៀតណាមដែលត្រូវបានប្រារព្ធឡើងពីឆ្នាំ១៩៦៩ដល់ឆ្នាំ១៩៧៣ នៅទីក្រុងប៉ារីស និងការចរចានៅប្រទេសស្វីសក្នុងអំឡុងពេលសង្គ្រាមអាល់សេដែលបានឈានដល់កិច្ចព្រមព្រៀង Evian ឆ្នាំ១៩៦២។

សន្ធានកម្ម(médiation) ៖ ភាគីទីបីអាចស្នើឡើងនូវដំណោះស្រាយមួយបាន។ សន្ធានកម្មល្អប្រសើរជាង។ សំណើទាំងនោះមានអព្យាក្រឹតភាពដែលគូភាគីអាចបន្ទន់ខ្លួនយល់ព្រម។ ឧទាហរណ៍ ៖ ការចរចានៅ Camp David ក្រោមការគាំទ្ររបស់លោកប្រធានាធិបតី Carter នៅឆ្នាំ១៩៧៨-១៩៧៩ រវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន។ ដំណើរការចរចាធ្វើឡើងដោយសម្ងាត់។ ភាគីទីបីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាត។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការផ្សះផ្សា(conciliation)ជាទម្រង់ផ្លូវការជាងគេដែលត្រូវបានរៀបចំនៅជុំវិញកិច្ចព្រៀងអន្តរជាតិមួយដែលកំណត់អង្គភាព បែបបទដំណើរការ និងនីតិវិធី។ នេះជាវិធីអន្តរាគមន៍មួយដែលឈានមុខខ្លាំងរបស់ភាគីទីបី។ ការផ្សះផ្សាអាចត្រូវបានគេចាត់ទុកថា ជាមជ្ឈត្តការគ្រាន់តែដំណោះស្រាយដែលស្នើឡើងមិនមែនជាកាតព្វកិច្ចទេ។ ចំពោះមជ្ឈត្តការ ដំណោះស្រាយគឺជាកាតព្វកិច្ច។ នៅក្នុងការផ្សះផ្សា ដំណោះស្រាយត្រូវបានស្នើឡើង ចំណែកនៅក្នុងមជ្ឈត្តការវិញដំណោះស្រាយត្រូវបានដាក់បង្ខំ។

គេអាចបញ្ចូលគោលការណ៍ចំពោះមុខ រឿងក្តីសមធម៌ រយៈពេលសមស្រប។ មាត្រា៦កថាខណ្ឌទី១នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សចែងពីបទប្បញ្ញត្តិសម្រាប់កំណត់ពីរឿងក្តីសមធម៌។ ការប្រើប្រាស់ការផ្សះផ្សាមិនច្រានចោលការចរចានៅពេលដំណើរការក្តី កាលានុវត្តភាព និងសមធម៌ទេ។ វាជាដំណោះស្រាយមានអានុភាព។ មុខងារយុត្តាធិការគឺជាមធ្យោបាយមួយដែលអាចឈានដល់ដំណោះស្រាយមានអានុភាព។

ការស៊ើបអង្កេត(enquête) ៖ ការស៊ើបអង្កេតត្រូវបានចែងនៅក្នុងសន្ធិសញ្ញាថា ជាវិធីមួយនៃការដោះស្រាយជម្លោះ ក៏ប៉ុន្តែវាមិនមែនជាវិធីមួយពិតប្រាកដនោះឡើយ ប៉ុន្តែវាជាឧបករណ៍មួយសម្រាប់ឱ្យគណៈកម្មការជំនុំជម្រះដឹកនាំការស៊ើបអង្កេត ដោយមិនទាន់ឈានដល់ការធ្វើសេចក្តីសន្និដ្ឋាន ឬការស្នើដំណោះស្រាយទេ។ ការស៊ើបអង្កេតត្រូវបានប្រើសម្រាប់បង្កើតនូវអង្គហេតុនានា ដោយហេតុថា អង្គហេតុទាំងនោះមិនត្រូវបានស្គាល់ច្បាស់ ឬមានការតវ៉ាប្រឆាំងហើយភាពមិនស្របគ្នាគឺទៅលើអង្គហេតុជាជាងនៅលើអង្គច្បាប់។ បែបបទនេះអាចសំខាន់ ព្រោះជម្លោះរវាងរដ្ឋ និងរដ្ឋជាញឹកញាប់កើតចេញមកពីការមិនយល់ស្របគ្នានៅលើអង្គហេតុជាងនៅលើអង្គច្បាប់។ ជាអាទិ៍គឺការស៊ើបអង្កេតលើការបំបាត់នុយក្លេអ៊ែរស៊ីវិលរបស់ប្រទេសអ៊ីរ៉ង់ ដើម្បីបកអាក្រាតអង្គហេតុដែលលើកឡើងដោយភាគីផ្សេងៗខុសគ្នា។

## ៤- មធ្យោបាយតាមផ្លូវយុត្តាធិការ

មធ្យោបាយតាមផ្លូវតុលាការមានពីរប្រភេទគឺ ៖ មជ្ឈត្តការ និងមធ្យោបាយតាមផ្លូវតុលាការ។ ចំណុចរួមគឺត្រូវជានាមុខងារយុត្តាធិការ ការបង្កើតមូលដ្ឋានច្បាប់ ដើម្បីឈានទៅរកដំណោះស្រាយមួយដែលឈរលើច្បាប់។

តុលាការក៏អាចដោះស្រាយជម្លោះដោយសមធម៌ ឬដោយគោលការណ៍ ex aequo et bono បានដែរ។ ក៏ប៉ុន្តែការដោះស្រាយនេះត្រូវតែមានការស្នើសុំយ៉ាងច្បាស់ក្រឡែតពីសំណាក់គូភាគីដែលនេះមិនដែលបានកើតឡើងទេសម្រាប់តុលាការយុត្តិធម៌អន្តរជាតិ។ តុលាការនៅតែអាចចេញសេចក្តីសម្រេចរបស់ខ្លួនដោយយោងទៅលើច្បាប់ និងកាតព្វកិច្ចសម្រាប់គូភាគី។

*មជ្ឈត្តការ និងមធ្យោបាយតាមផ្លូវតុលាការ មានភាពទីទៃពីគ្នាដោយលក្ខណៈមួយចំនួន ៖*

| មជ្ឈត្តការ | មធ្យោបាយតាមផ្លូវតុលាការ |
|---|---|
| *- សមាសភាពរបស់ស្ថាប័នមជ្ឈត្តការត្រូវបាន កំណត់ដោយគូភាគី។<br>- ច្បាប់ដែលអាចអនុវត្តបានចំពោះអង្គច្បាប់ នៃជម្លោះ និងនីតិវិធីដែលត្រូវយកមកអនុវត្ត អាចជ្រើសរើសដោយគូភាគី។* | *- តុលាការត្រូវបានកំណត់ជាមុន ហើយ សមាសភាពក៏ត្រូវបានបង្កើតជាមុនដែរ (លើកលែងការតែងតាំងចៅក្រមចំពោះកិច្ច នៅក្នុងតុលាការយុត្តិធម៌អន្តរជាតិ)។<br>- នីតិវិធីត្រូវបានកំណត់ដោយលក្ខន្តិកៈ និង បំពេញបន្ថែមដោយបទបញ្ជារបស់តុលាការ ហើយច្បាប់ដែលអនុវត្តត្រូវបានកំណត់ នៅក្នុងមាត្រា៣៨នៃលក្ខន្តិកៈនេះរួចស្រេច។* |

*ពាក់ព័ន្ធទៅនឹងមជ្ឈត្តការអន្តរជាតិ អនុសញ្ញាទីក្រុងឡាអេចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៨៩៩ បានកំណត់និយមន័យថា «វាមានគោលដៅដោះស្រាយវិវាទរវាងរដ្ឋ ដោយចៅក្រមដែលពួកគេ បានជ្រើសរើស និងដោយឈរលើមូលដ្ឋាននៃការគោរពច្បាប់»។*

*មជ្ឈត្តការគឺជាស្ថាប័នគតិយុត្តដែលមានវ័យជំក្មេងមួយ។ ជាទូទៅគេចាត់ទុកថា មជ្ឈត្តការ ទីមួយដែលឆ្លើយតបនឹងនិយមន័យនេះ គឺមជ្ឈត្តការដែលបានចេញសេចក្តីសម្រេចនៅឆ្នាំ១៨៧២ នៅក្នុងរឿងក្តីAlabama ដែលមានសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេសជាគូក្តី(សេចក្តីសម្រេច មជ្ឈត្តវិនិច្ឆ័យចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៨៧២)។*

*មជ្ឈត្តការបានអភិវឌ្ឍខ្លួនតាមច្រើនរបៀប។ តុលាការមជ្ឈត្តការអចិន្ត្រៃយ៍ដែលត្រូវបាន បង្កើតឡើងដោយអនុសញ្ញាទីក្រុងឡាអេ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៨៩៩ បានកំណត់កម្មវត្ថុ នៃមជ្ឈត្តការថាមានគោលដៅដោះស្រាយជម្លោះដោយចៅក្រមដែលត្រូវបានជ្រើសរើសដោយ គូភាគីដោយឈរទៅលើច្បាប់។ បន្ថែមពីលើអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៨៩៩ មានអត្ថបទសំខាន់ៗ ជាច្រើន ជាពិសេសគឺកិច្ចទូទៅនៃមជ្ឈត្តការចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩២៨ ដែលត្រូវបានអនុម័ត ដោយសន្និបាតរបស់សង្គមប្រជាជាតិ និងសើរើឡើងវិញនៅឆ្នាំ១៩៤៩ ដោយមហាសន្និបាត អង្គការសហប្រជាជាតិ។*

*សេចក្តីព្រាងនៃការចងក្រងជាក្រមនូវច្បាប់ស្តីពីមជ្ឈត្តការដែលត្រូវបានតាក់តែងឡើង នៅក្នុងគណៈកម្មការនីតិអន្តរជាតិ(CDI) បានសម្រេចត្រឹមតែជា«គំរូមួយនៃវិធានស្តីពីនីតិវិធី*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មជ្ឈត្តកម្ម»ប៉ុណ្ណោះ ហើយវឌ្ឍនភាពនៅពេលថ្មីៗបានកើតឡើងជាច្រើននៅក្នុងកម្រិតតំបន់(មានដូចជាអនុសញ្ញាទីក្រុង Strabourg ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៥៧ ស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធី អនុសញ្ញាទីក្រុង Stokholm ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩២ ដែលបង្កើតតុលាការផ្សះផ្សា និងមជ្ឈត្តការនៅក្នុងស្ថាប័នអង្គការដើម្បីសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប(OSCE)។ ការបង្កើតស្ថាប័នមជ្ឈត្តការត្រូវបានធ្វើឡើងមុនការបង្កើតតុលាការនេះ។

ជាចុងបញ្ចប់ មជ្ឈត្តការបានស្គាល់នូវការរាតទីយ៉ាងខ្លាំងក្លា នៅក្នុងវិស័យនៃការទំនាក់-ទំនងរវាងរដ្ឋ និងបុគ្គលឯកជនបរទេស(CIRDI តុលាការដោះស្រាយជម្លោះរវាងប្រទេសអ៊ីរ៉ង់ និងសហរដ្ឋអាមេរិកដែលយើងពិតជានឹងលើកយកមកនិយាយមុននឹងបញ្ចប់)។

## ៥- សុពលភាព និងការលំបាកនៅក្នុងការធ្វើចំណាត់ថ្នាក់

ការធ្វើចំណាត់ថ្នាក់មធ្យោបាយដោះស្រាយតាមផ្លូវយុត្តាធិការ និងក្រៅផ្លូវយុត្តាធិការមានការលំបាកដូចជាកង្វះភាពម៉ឺងម៉ាត់ មានប្រព័ន្ធកូនកាត់ និងមិនច្បាស់លាស់។ នៅក្នុងការអនុវត្តមានការបង្កើតដោយរដ្ឋនានាដែលអាចមានវិធីដោះស្រាយជម្លោះដែរ។ ការធ្វើចំណាត់ថ្នាក់មានលក្ខណៈសាមញ្ញបំផុត។

ក៏ប៉ុន្តែ ការប្រើប្រាស់ចំណាត់ថ្នាក់នេះជួបប្រទះនឹងការលំបាកជាច្រើន។

១) ទីមួយ ៖ កង្វះភាពម៉ឺងម៉ាត់នៅក្នុងការប្រើប្រាស់ពាក្យពេចន៍។ ការអនុវត្តនេះអាចនាំឱ្យកើតមានប្រព័ន្ធមិនច្បាស់លាស់ និងកូនកាត់។ ភាពមិនច្បាស់លាស់នេះប៉ះពាល់ជាពិសេសដល់សម្មតិកម្មនៃយន្តការនៃការផ្សះផ្សា។

ឧទាហរណ៍ ៖ ការវាយតម្លៃលើយន្តការដោះស្រាយជម្លោះ នៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រម-ព្រៀមទូទៅស្តីពីពាណិជ្ជកម្ម និងអត្រាតម្លៃ(GATT) និងបន្ទាប់មកក្នុងក្របខ័ណ្ឌអង្គការ WTO បង្កឱ្យមានការលំបាកជាច្រើន ពីព្រោះនីតិវិធីរបស់ GATT គ្រាន់តែនូវជំនាញការ និងអង្គភាពការទូត(ក្រុមប្រឹក្សាតំណាង)ដែលត្រូវបានបង្កើតឡើងដើម្បីជំទាស់ទៅនឹងគូភាគីបាន។ មិនមានគំរូសុទ្ធសាធណាមួយទេ។ ដូច្នេះ គេស្ថិតនៅក្នុងក្របខ័ណ្ឌនៃការផ្សះផ្សា។

ដំណើរការនៃនីតិវិធីស្ថិតនៅក្នុងលក្ខណៈផ្ទុយគ្នា និងត្រូវអាចចាត់ទុកថាជាការផ្សះផ្សា «ស្ទើរតែបែបយុត្តាធិការ»។ ចំពោះការហៅឈ្មោះវិញ អ្វីៗមានលក្ខណៈកាន់តែស្មុគស្មាញ។ ដំណោះស្រាយដែលត្រូវបានកំណត់តាមវិធីនេះ ជានិច្ចកាលត្រូវបានផ្តល់សច្ចាប័នដោយអង្គភាពការទូតមួយ(អង្គភាពដោះស្រាយជម្លោះ) តាមបច្ចេកទេសមួយដែលគេហៅថា ការព្រមព្រៀងអវិជ្ជមានដែលមានអានុភាពធ្វើឱ្យការអនុម័តនេះមានភាពស្វ័យប្រវត្ត(ប្រសិនបើគ្មានការជំទាស់ទំនាក់ទំនងនឹងត្រូវអនុម័ត)។

សេចក្ដីសម្រេចដែលមានលក្ខណៈជាកាតព្វកិច្ចត្រូវបានធ្វើឡើងសម្រាប់គូភាគី ហើយខ្លឹមសាររបស់វាឈរលើច្បាប់ និងកំណត់ដោយភាគីទីបីដែលគេស្គាល់ថា ពុំមានភាពលម្អៀងតាមរយៈនីតិវិធីមួយដែលបង្ហាញនូវរាល់ចរិតលក្ខណៈយុត្តាធិការ។ អ្វីដែលសេចក្ដីសម្រេចស្ដាពរត្រូវបានធ្វើឡើងដោយអង្គភាពការទូតមួយ អាចជាយថាហេតុធ្វើឱ្យគេនិយាយបានថា វាហាមឃាត់មិនឱ្យមានការវាយតម្លៃផ្នែកយុត្តាធិការទៅលើយន្តការដោះស្រាយជម្លោះនេះ។

២) ឧបសគ្គទីពីក្នុងការធ្វើចំណាត់ថ្នាក់គឺថា គូភាគីបានសន្យាជាមុនថា ពួកគេនឹងគោរពសេចក្ដីសម្រេចរបស់ភាគីទីបីថាជាកាតព្វកិច្ច។ រដ្ឋជាគូភាគីបានប្រើប្រាស់បច្ចេកទេសការទូត ប៉ុន្តែសេចក្ដីសម្រេចនេះគឺជាកាតព្វកិច្ច។ នៅក្នុងរឿងក្ដី Rainbow Warrior ដោយសារមិនអាចឈានដល់ការព្រមព្រៀងគ្នាតាមរយៈការចរចាដោយផ្ទាល់ ប្រទេសបារាំង និងប្រទេសណូវែលសេឡង់បានដាក់ពាក្យបណ្ដឹងទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយបានស្នើសុំអគ្គលេខាឱ្យស្នើនូវដំណោះស្រាយមួយដែលគូភាគីសន្យាជាមុនថានឹងគោរពប្រតិបត្តិតាម។ ការណ៍នេះស្រដៀងនឹងសន្ធានកម្មដែរ គ្រាន់តែថាគូភាគីសន្យាថានឹងគោរពតាមដំណោះស្រាយ។

ជាចុងក្រោយយន្តការដូចគ្នាមួយអាចត្រូវបានប្រើប្រាស់ជាបន្តបន្ទាប់ សម្រាប់មុខងារផ្សេងៗ ហើយដោយសារតែហេតុនេះហើយទើបមានការលំបាកក្នុងការធ្វើចំណាត់ថ្នាក់។ ការផ្សំគ្នានេះអាចកើតឡើងតាមរបៀបខុសៗគ្នា។

៣) ការលំបាកទីបី គឺលទ្ធភាពសម្រាប់រដ្ឋក្នុងការប្រើប្រាស់យន្តការខុសៗគ្នាបន្តបន្ទាប់គ្នា។ គេត្រូវតែកំណត់នូវការប្រើប្រាស់វិធីការទូតមួយ មុននឹងប្រើប្រាស់ការដោះស្រាយតាមផ្លូវតុលាការក្នុងករណី។

ឧទាហរណ៍ ៖ ការដាក់ពាក្យបណ្ដឹងទៅស្ថាប័នមជ្ឈត្តការ ឬតុលាការណាមួយត្រូវតែធ្វើឡើងក្រោយពេលពីមានការព្យាយាមធ្វើសន្ធានកម្ម ឬការផ្សះផ្សាជាមុនសិន(សូមមើលមាត្រា ២៦នៃអនុសញ្ញាទីក្រុង Stockholm ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩២ ស្ដីពីការផ្សះផ្សា និងមជ្ឈត្តការ)។ ការផ្សំគ្នាទាំងនេះក៏អាចមានលក្ខណៈស្មុគស្មាញដែរ ដូចមានបំភ្លឺនៅក្នុងមាត្រា៦៥ និង៦៦នៃអនុសញ្ញាទីក្រុង Vienne ស្ដីពីច្បាប់សន្ធិសញ្ញាដែលចែងពីរបបខុសៗគ្នាទៅតាមបទប្បញ្ញត្តិដែលមានការពាក់ព័ន្ធនៅក្នុងវិវាទដោយកំហិតជានិច្ចកាលឱ្យមានការចរចាជាមុនជានិច្ច។ ដូច្នេះសមត្ថកិច្ចរបស់តុលាការយុត្តិធម៌អន្តរជាតិត្រូវបានគ្រោងទុកតែនៅក្នុងពេលមានបញ្ហាលើវិធាន jus cogens (បញ្ញត្តិចាប់បង្ខំ)។

នេះបង្កើតឱ្យមាននូវការប្រកួតប្រជែងមួយគឺវេទិកាប្រកួតប្រជែង(Forum Shopping) ពោលគឺចំពោះរដ្ឋ គេអាចជ្រើសរើសយុត្តាធិការដើម្បីដោះស្រាយជម្លោះមួយ។ ការធ្វើដូច្នេះអាចឱ្យគេទទួលបាននូវដំណោះស្រាយមួយប្រកបដោយប្រសិទ្ធភាព។ នីតិអន្តរជាតិបង្ហាញថា នីតិផ្ដោត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាចម្បងទៅលើដំណោះស្រាយជម្លោះមួយដែលច្បាស់លាស់ បើប្រៀបធៀបទៅនឹងការសង្កត់ធ្ងន់ និងស៊ីចង្វាក់នៃវិធីគតិយុត្តិ និង/ឬនយោបាយ។ គោលបំណងចម្បងគឺត្រូវធ្វើការចរចាគ្នាដើម្បីស្វែងរកកិច្ចព្រមព្រៀងដោយភាតរភាព។ គូភាគីអាចផ្អាកនីតិវិធីមុននឹងឈានទៅដល់មជ្ឈត្តករ។

រឿងក្តី Lockerbie ៖ កាតព្វកិច្ចនៃការព្យាយាមដោះស្រាយជម្លោះតាមផ្លូវតុលាការ។ អនុសញ្ញាទីក្រុង Montréal ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧១ ស្តីពីការបង្ក្រាបអំពើខុសច្បាប់ដែលត្រូវបានធ្វើឡើងក្នុងគោលដៅប្រឆាំងនឹងសន្តិសុខអាកាសចរណ៍ស៊ីវិល បានចែងពីកាតព្វកិច្ចត្រូវធ្វើការចរចា និងបណ្តឹងសុំមជ្ឈត្តការមួយក្នុងរយៈពេលប្រាំមួយខែ ប្រសិនបើគូភាគីមិនអាចស្វែងរកដំណោះស្រាយបាន( មាត្រា១៤ កថាខណ្ឌទី១) មុននឹងប្រើប្រាស់លទ្ធភាពប្តឹងជាឯកតោភាគីទៅតុលាការយុត្តិធម៌អន្តរជាតិ។ ចុងចម្លើយបានជំទាស់ថា ប្រទេស Libye មិនបានគោរពរយៈពេលកំណត់ប្រាំមួយខែ មុនពេលដាក់ពាក្យបណ្តឹងទៅតុលាការអន្តរជាតិ។ ប្រទេស Libye បានឆ្លើយថា គូភាគីបដិបក្ខបានបង្ហាញដោយតុណ្ហីភាពនូវឆន្ទៈច្បាស់លាស់ថានឹងច្រានចោលសំណើសុំមជ្ឈត្តការដែលប្រទេស Libye បានស្នើទៅ។

គេសង្កេតឃើញហើយថា ការដាក់ដែនកំណត់រវាងប្រភេទទាំងនេះមិនអាចធ្វើទៅរួចនោះឡើយ ហើយវត្តមាននៃ«យុត្តាធិការមិនច្បាស់លាស់» គឺបង្កើតឱ្យមានភាពមិនច្បាស់លាស់ច្រើន ក៏ប៉ុន្តែទាំងនេះគឺជាតថភាពក្នុងពិភពលោក។

## សេចក្តីសន្និដ្ឋាន

ជាសេចក្តីសន្និដ្ឋាន សតវត្សរ៍ទី២០ គឺជាសតវត្សរ៍ថ្មីនៃការដោះស្រាយជម្លោះ។ ទោះបីជាមជ្ឈត្តការបានកើតមុនក្តី និងបានព្យាយាមចងក្រងជាក្រមនូវនីតិវិធីនានាក្តី ក៏មជ្ឈត្តការអន្តរជាតិនៅតែស្ថិតនៅក្រោយការដោះស្រាយតាមផ្លូវតុលាការដែរ។ អ្វីដែលជាកម្រិតមួយខ្ពស់គឺថាភាគីទីបីអព្យាក្រឹត្យមានអំណាចក្នុងការដោះស្រាយជម្លោះ។ សន្តិភាពអាចត្រូវបានទទួលតាមរយៈយុត្តិធម៌ប៉ុណ្ណោះ។ នេះគឺជាទស្សីករណ៍គន្លឹះក្នុងការបង្កើតតុលាការនានាដើម្បីជំនុំជម្រះក្តីលើប្រមុខរដ្ឋអំពីបទឧក្រិដ្ឋផ្សេងៗ។

នេះគឺជាយុត្តាធិការភាវូបនីយកម្មនៃនីតិអន្តជាតិ ៖ តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ ( TIDM) សាលាឧទ្ធរណ៍នៃអង្គការពាណិជ្ជកម្មពិភពលោក( ORD) ក្រុមអធិការកិច្ចរបស់ធនាគារពិភពលោក តុលាការរដ្ឋបាលរបស់អង្គការសហប្រជាជាតិ( TANU)។ល។ នីតិវិធីនានាកាន់តែច្បាស់លាស់ឡើង។

# ជំពូក១៣
# ចលនាទូទៅនៃយុត្តាធិការអាវូបនីយកម្ម នៅក្នុងនីតិអន្តរជាតិ

*នៅទីនេះ គោលបំណងគឺត្រូវផ្តល់នូវទិដ្ឋភាពទូទៅនៃមុខងារយុត្តាធិការ នៅក្នុងនីតិអន្តរជាតិទំនើប។ ដើម្បីធ្វើដូច្នេះបាន គេត្រូវពិនិត្យមើលតាមលំដាប់លំដោយនូវចរិតលក្ខណៈនៃយុត្តាធិការ ការូបនីយកម្ម(I) និងបន្ទាប់មកត្រូវផ្តោតទៅលើលក្ខណៈវិនិច្ឆ័យរួមនៃយុត្តាធិការអន្តរជាតិ(II)។*

# ផ្នែកទី១
## ចរិតលក្ខណៈរបស់យុត្តាធិការអាវូបនីយកម្មនៃនីតិអន្តរជាតិ

*ចៅក្រមគឺជារូបភាពថ្មីមួយនៅក្នុងនីតិអន្តរជាតិ ហើយរដ្ឋមិនមានជំនឿទៅលើចៅក្រមឡើយ។ គឺនៅក្នុងស.វ.ទី២០ដែលគេបានបង្កើតយុត្តាធិការអន្តរជាតិអចិន្ត្រៃយ៍ដំបូងៗដែលជាស្ថាប័នយុត្តិធម៌ដែលត្រូវបានបង្កើតឡើងជាស្ថាប័នដូចនៅក្នុងប្រព័ន្ធផ្ទៃក្នុងដែរ។*

*ការប៉ុនប៉ងដំបូងៗក្នុងការបង្កើតយុត្តាធិការអចិន្ត្រៃយ៍ត្រូវបានធ្វើឡើងក្នុងកម្រិតតំបន់(តុលាការយុត្តិធម៌អាមេរិកកណ្តាលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩០៧ ហើយមានដំណើរការរហូតដល់ឆ្នាំ១៩១៧) ឬតាមវិស័យ(តុលាការអន្តរជាតិដោះស្រាយជម្លោះដែលត្រូវបានគ្រោង-ទុកដោយអនុសញ្ញាXIIទីក្រុងឡាអេឆ្នាំ១៩០៧)។*

*ប្រវត្តិនៃយុត្តិធម៌អន្តរជាតិបានចាប់ផ្តើមជាសារវន្តជាមួយតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍(CPJI)ដែលត្រូវបានបង្កើតឡើងស្របពេលជាមួយសង្គមប្រជាជាតិ(SdN - មាត្រា១៤ នៃកតិកាសញ្ញា) ដោយតុលាការនេះមានឯកពាក្យទាំងស្រុង។ យុត្តិធម៌ដែលមានលក្ខណៈស្ថាប័ននឹងមានការរីកចម្រើន បន្ទាប់ពីសង្គ្រាមលោកលើកទី២រហូតដល់ថ្នាក់ដែលគេចាប់ផ្តើមនិយាយអំពីចលនាយុត្តាធិការអាវូបនីយកម្មនៃនីតិអន្តរជាតិ។ យុត្តិធម៌នេះសំដៅដល់ទាំងការកើនឡើងនូវចំនួន ឬតួនាទីនៃយុត្តាធិការ ទាំងការកែលម្អនៃនីតិវិធីដែលយុត្តាធិការទាំងនេះបំពេញមុខងារ*

របស់ខ្លួន។

CPIJ និងបន្ទាប់មកតុលាការយុត្តិធម៌អន្តរជាតិ CIJ ដំណើរការមួយសតវត្សរ៍មកហើយ ជាមួយនឹងការកើនឡើងនូវនីតិវិធី និងបែបបទច្បាស់ផ្សេងៗ។ សញ្ញាណយុត្តាធិការអន្តរជាតិមិនច្បាស់លាស់ប៉ុន្មានទេ។ គួរកត់សម្គាល់ផងដែរថា ដំណោះស្រាយក៏មិនសូវច្បាស់លាស់ណាស់ដែរស្របពេលនឹងការបង្កើនចំនួនយុត្តាធិការអន្តរជាតិនោះ។

ជាឧទាហរណ៍ យន្តការដោះស្រាយជម្លោះរបស់អង្គការពាណិជ្ជកម្មពិភពលោក រួមទាំងគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិផងដែរ។ ជាការពិតណាស់ ច្បាប់នីតិវិធីដែលត្រូវប្រើនៅក្នុងអង្គភាពទាំងនោះ - ហើយជាពិសេស វិធាននៃសវនាការប្រកបដោយសមធម៌ - មានទម្ងន់ដោយអនុគ្រោះដល់ការវាយតម្លៃជាអប្បបរមារបស់វាថា «ស្ថាប័នស្ទើរយុត្តាធិការ»។ អង្គការពាណិជ្ជកម្មពិភពលោក ជាស្ថាប័នយុត្តាធិការផង នយោបាយផង ព្រមទាំងជាស្ថាប័នស្ទើរតុលាការផង។ មានការសាយភាយនូវយុត្តាធិការអន្តរជាតិជាច្រើន។ ចំពោះបញ្ហាអាជ្ញាអស់ជំនុំ គេត្រូវធ្វើការប្រៀបធៀបជាមួយយុត្តាធិការផ្ទៃក្នុង។

និយាយអំពីពិពិធភាពនៃយុត្តាធិការអន្តរជាតិ មិនសំដៅត្រឹមតែពីភាពខុសគ្នារបស់វាទេ (ក) តែក៏បង្ហាញអំពីអវត្តមាននៃការឯកភាពគ្នា (ខ) នៃសំណុំដែលយុត្តាធិការទាំងនោះផ្តុំចូលគ្នាដែរ។

## ១- ភាពខុសគ្នានៃយុត្តាធិការអន្តរជាតិ

តុលាការឧក្រិដ្ឋកម្មអន្តរជាតិ គឺជាយុត្តាធិការលំដាប់ពិភពលោកមួយ និងមានសមត្ថកិច្ចចំពោះរឿងទូទៅ។ យុត្តាធិការអន្តរជាតិពិសេសត្រូវបានបង្កើតឡើងជាច្រើនរួមមាន ៖

- ការបង្កើតតុលាការអន្តរជាតិនៃនីតិសមុទ្រត្រូវបានភ្ជាប់ទៅនឹងការចូលជាធរមាននៃអនុសញ្ញាទីក្រុង Montego Bay ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២។
- យុត្តាធិការរដ្ឋបាលអន្តរជាតិបានបង្កើនចំនួននៅក្នុងអង្គការអន្តរជាតិជាច្រើន។
- យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិបានស្គាល់ការអភិវឌ្ឍសំខាន់ៗជាមួយនឹងការបង្កើតតុលាការចំពោះកិច្ចចំនួនពីរ ដោយក្រុមប្រឹក្សាសន្តិសុខគឺ ៖ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី (TPIY) (សេចក្តីសម្រេច៨២៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣) តុលាការឧក្រិដ្ឋកម្មសម្រាប់Rwanda (TPR) (សេចក្តីសម្រេចលេខ៩៥៥ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤)។ រដ្ឋនានាបានចរចាលើការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ(CPI)អចិន្ត្រៃយ៍មួយតាមរយៈអនុសញ្ញាមួយចុះហត្ថលេខានៅទីក្រុងរ៉ូម នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨។ ប្រទេសកម្ពុជាគឺជារដ្ឋទីមួយនៅអាស៊ីដែលបានធ្វើសច្ចាប័នលើលក្ខន្តិកៈនៃទីក្រុងរ៉ូម។

• គេក៏ឃើញមានតុលាការពិសេសថ្នាក់តំបន់មួយចំនួនក្នុងវិស័យសិទ្ធិមនុស្សតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស(CEDH) តុលាការអន្តរ-អាមេរិកាំងទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស)។ ចុងក្រោយគឺត្រូវបង្ហាញពីយុត្តាធិការអន្តរជាតិ«កូនកាត់»(ឧទាហរណ៍ ៖ តុលាការពិសេសសម្រាប់ Sierra Léone) ប៉ុន្តែត្រូវបង្ហាញផងដែរពីតុលាការដែលពាក់ព័ន្ធទៅនឹងការធ្វើសមាហរណកម្ម ដូចជាតុលាការយុត្តិធម៌សហគមន៍អឺរ៉ុប។

ប្រឈមទៅនឹងភាពចម្រុះគ្នានេះ មានលក្ខណៈវិនិច្ឆ័យជាច្រើនដែលអាចឱ្យលេចឡើងនូវភាពខុសគ្នានៃយុត្តាធិការអន្តរជាតិ។

## ១.១- បែបបទនៃការបង្កើត និងការរៀបចំ

យុត្តាធិការភាគច្រើនកើតចេញពីសន្ធិសញ្ញា។ រដ្ឋហត្ថលេខីនៃសន្ធិសញ្ញាទីក្រុងរ៉ូមគឺជាសមាជិកនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ តុលាការនេះមានលេខាធិការដ្ឋានមួយ។ នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ មានយន្តការមិនផ្ទាល់មួយ។ ជារឿយៗ វាគឺជាអំណាចនៃបង្កើតយុត្តាធិការអន្តរជាតិ ដើម្បីជាប្រយោជន៍ដល់អង្គការអន្តរជាតិណាមួយ ដោយមិនចាំបាច់ឆ្លងកាត់បែបបទដែលមានការព្រមព្រៀងនោះឡើយ។ ស្ថាប័នអន្តរជាតិនឹងបង្កើតមុខងារយុត្តាធិការដល់ស្ថាប័នមួយក្នុងចំណោមស្ថាប័នទាំងនោះ។ ដូច្នេះនៅឆ្នាំ១៩៤៩ អង្គមហាសន្និបាតអង្គការសហប្រជាជាតិបានសម្រេចបង្កើតតុលាការរដ្ឋបាលអន្តរជាតិ សម្រាប់អង្គការសហប្រជាជាតិមួយ។ តុលាការយុត្តិធម៌អន្តរជាតិបានចាត់ទុកថា អង្គការសហប្រជាជាតិមានអំណាចក្នុងការបង្កើតអ្វីមួយតាមរយៈសមត្ថកិច្ចមិនច្បាស់លាស់ ដោយផ្អែកទៅលើមាត្រាចំនួនពីរនៃធម្មនុញ្ញ ៖ ទីមួយគឺមាត្រា២២ដែលផ្តល់នីតិសម្បទាដល់មហាសន្និបាតក្នុងការបង្កើតស្ថាប័នទាំងឡាយណាដែលខ្លួនគិតថាចាំបាច់។ ទីពីរ មាត្រា១០១ផ្តល់ទៅឱ្យមហាសន្និបាតនូវអំណាចកំណត់បទដ្ឋាននានាដែលតាមរយៈនោះអគ្គលេខាធិការតែងតាំងបុគ្គលិក ហើយបុគ្គលិកទាំងនោះមិនអាចត្រូវបានតែងតាំងឡើងដោយគ្មានការការពារផ្នែកយុត្តាធិការនោះឡើយ(សំណុំរឿង Effets de jugements du TANU ដែលបានយល់ព្រមលើសំណង យោបល់ពិគ្រោះចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៥៤ ៖ Rec. ទំព័រ៤៧)។

ក្នុងពេលមានជម្លោះអន្តររដ្ឋ យុត្តាធិការភាគច្រើនតែងតែដោះស្រាយតាមរយៈអនុសញ្ញាមួយជានិច្ច។ រដ្ឋនៅតែមានសេរីភាពក្នុងការកំណត់វិធានដំណើរការ និងនីតិវិធីរបស់យុត្តាធិការដែលត្រូវបានបង្កើត។ រដ្ឋអាចមានភាពរារែក និងការសង្ស័យដែលស្តែងចេញឡើងតាមរយៈការកំណត់ដែនសមត្ថកិច្ច។ គេមិនចង់ឱ្យយុត្តាធិការទាំងនោះប៉ះពាល់ដល់អធិបតេយ្យភាពរបស់ពួកគេឡើយ។ គេអាចបង្ហាញថា រដ្ឋមានការសង្ស័យ ហើយយុត្តាធិការបានបង្កើតយុត្តិសាស្ត្រ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់ខ្លួនដែរ។

ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិមិនបានចែងច្បាស់ក្រឡែតអំពីអំណាចនៃការបង្កើត TANU ឬតុលាការព្រហ្មទណ្ឌឡើយ។ នេះជាទ្រឹស្តីនៃអំណាចមិនចំពោះ។ នេះគឺជាលក្ខណៈសម្គាល់មួយនៃអង្គការអន្តរជាតិ។ រដ្ឋមិនចង់កំណត់ព្រំដែននៃនីតិវិធីនៅក្នុងលក្ខន្តិកៈឡើយ ប៉ុន្តែនីតិវិធីទាំងនោះត្រូវបានបំពេញដោយបទបញ្ជាផ្ទៃក្នុង។ ស្វ័យគ្រប់គ្រងមានលក្ខណៈបុរាណ។ ពេលបង្កើតតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ និងយោងតាមទស្សនាទានដែលត្រូវបានរក្សាទុកសម្រាប់តុលាការយុត្តិធម៌អន្តរជាតិ ត្រូវបានសម្រេចថា មិនដោះស្រាយនៅក្នុងសេចក្តីលម្អិតនូវនីតិវិធីរបស់យុត្តាធិការនៅក្នុងលក្ខន្តិកៈរបស់វាទេ និងសម្រេចថា ផ្តល់ឱ្យយុត្តាធិការនោះនូវភារកិច្ចដោះស្រាយទៅតាមបទបញ្ជានីតិវិធីមួយ។ មានការកំណត់ដូចគ្នានេះដែរសម្រាប់តុលាការអន្តរជាតិនៃនីតិសមុទ្រ ឬស្ថាប័នបណ្តឹងឧទ្ធរណ៍នៃអង្គការពាណិជ្ជកម្មពិភពលោក។

បទពិសោធន៍របស់តុលាការព្រហ្មទណ្ឌចំពោះកិច្ចបានបង្ហាញថា យុត្តាធិការអាចទទួលបានដោយខ្លួនឯងនូវបុព្វសិទ្ធិដែលអ្នកបង្កើតមិនបានគ្រោងទុកជាចាំបាច់នោះទេ។ គេសង្កេតឃើញបាតុភូតដូចគ្នានេះចំពោះស្ថាប័នឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក។ អត្ថិភាពនៃបទបញ្ជានីតិវិធីអចិន្ត្រៃយ៍ និងដែលត្រូវបានបង្កើតជាមុន គឺជាចរិតលក្ខណៈមួយក្នុងចំណោមចរិតលក្ខណៈជាច្រើនដែលធ្វើឱ្យខុសគ្នារវាងការដោះស្រាយតាមផ្លូវតុលាការ និងការដោះស្រាយតាមបែបមជ្ឈត្តការ។

រដ្ឋកំណត់ព្រំដែននៃអំណាចស្វ័យសម្រេច។ នៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ រដ្ឋកំណត់ព្រំដែននៃនីតិវិធី។ នេះជាបទពិសោធន៍របស់តុលាការអន្តរជាតិ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(CETC) បានទទួលអំណាចដែលអនុញ្ញាតឱ្យជនរងគ្រោះធ្វើជាភាគីនៅក្នុងរឿងក្តី។ ក្រុមការងារអគ្គលេខាធិការUNរបស់លោក Kofi Annan បានធ្វើការចរចា និងបានចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ក្រុមចៅក្រមបានបង្កើតការិយាល័យមួយដើម្បីជួយដល់ជនរងគ្រោះ។ យុត្តាធិការមានលក្ខណៈសម្គាល់ពិសេស បើទោះបីជាយុត្តាធិការនោះមានទំហំដ៏តូច ឬដ៏ធំ( ពង្រីកសមត្ថកិច្ចរបស់ខ្លួន)។ ជានិច្ចកាល យុត្តាធិការតែងតែមាននីតិវិធី។

## ១.២- ចំណុចទីពីរ

អតីតភាពរបស់អង្គការ។ យុត្តាធិការដែលមានវ័យចំណាស់ជាងគេ គឺតុលាការយុត្តិធម៌អន្តរជាតិដែលបានជំនួសឱ្យតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍នៅឆ្នាំ១៩៤៦។ ក៏ប៉ុន្តែ យុត្តាធិការមួយចំនួនធំមានអាយុកាលក្មេងល្មម។ ទាំងនេះជាយុត្តាធិការនិងកាលបរិច្ឆេទនៃអត្ថបទច្បាប់បង្កើតអង្គការ និងកាលបរិច្ឆេទនៃការចាប់ផ្តើមសកម្មភាពពិតប្រាកដ (ប្រសិនបើមាន) ៖

តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ(១៩៨២, ១៩៩៧) តុលាការ WTO (១៩៩៤, ១៩៩៥) តុលាការឧក្រិដ្ឋកម្មអន្តរជាតិ(១៩៩៨, ២០០២) CJCE (១៩៥១, ១៩៥៤) CEDH (១៩៥០, ១៩៥៩) តុលាការអន្តរ-អាមេរិកាំងទទួលបន្ទុកសិទ្ធិមនុស្ស-CIADH (១៩៦៩, ១៩៧៩) តុលាការអាហ្វ្រិកទទួលបន្ទុកសិទ្ធមនុស្ស(១៩៩៨, ២០០៤) តុលាការយុត្តិធម៌ AELE (១៩៩២, ១៩៩៤) តុលាការយុត្តិធម៌នៃសហភាពអាហ្វ្រិក(២០០០) តុលាការយុត្តិធម៌ និងមជ្ឈត្តការ OHADA (១៩៩៣, ១៩៩៩)។

## ១.៣- យុត្តាធិការអចិន្ត្រៃយ៍មិនមានសមត្ថកិច្ចចំពោះវិវាទបច្ចាគតទេ

តុលាការឧក្រិដ្ឋកម្មអន្តរជាតិមានសមត្ថកិច្ចចាប់ពីក្រោយឆ្នាំ២០០២ប៉ុណ្ណោះ។ អាស្រ័យហេតុនេះហើយបានជាគេបង្កើតតុលាការចំពោះកិច្ច។

## ១.៤- យុត្តាធិការអន្តរជាតិមិនមានសមត្ថកិច្ចលំហទេ

យុត្តាធិការមួយចំនួនមានសមត្ថកិច្ចថ្នាក់តំបន់ដូចជា CJCE, CEDH តុលាការអន្តរ-អាមេរិកាំងទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស-ល-។ ចំណែកយុត្តាធិការផ្សេងទៀត មានគោលដៅពិភពលោកដូចជាតុលាការយុត្តិធម៌អន្តរជាតិ(CIJ), TIDM, តុលាការឧក្រិដ្ឋកម្មអន្តរជាតិ(CPI) ព្រមទាំងតុលាការរដ្ឋបាលនៃអង្គការពលកម្មអន្តរជាតិ និង ORDនៃWTO ផងដែរ។ គេត្រូវបែងចែកយុត្តាធិការនានាដែលមានដែនសមត្ថកិច្ចយ៉ាងតូចត្រឹមតែតំបន់ភូមិសាស្ត្រមួយដែលមានដូចជា TPIY, TPR អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា(CETC)។

## ១.៥- យុត្តាធិការអន្តរជាតិមិនមានសេចក្តីវិនិច្ឆ័យដូចគ្នានោះទេ

តុលាការយុត្តិធម៌អន្តរជាតិ ៖ វិនិច្ឆ័យដាច់មុខតែទៅលើរឿងក្តីរបស់រដ្ឋ។

TIDM និង ORDនៃWTO ៖ វិនិច្ឆ័យលើរដ្ឋ អង្គការអន្តរជាតិ និងបុគ្គលឯកជន។

CJCE ៖ ទទួលរដ្ឋ អង្គការអន្តរជាតិមួយ និងបុគ្គលឯកជន។

## ១.៦- យុត្តាធិការមិនមានដែនសមត្ថកិច្ចដូចគ្នានោះឡើយ គឺច្បាប់សត្យានុម័ត

មានតែតុលាការឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះដែលមានសមត្ថកិច្ចសកល។ យុត្តាធិការផ្សេងៗទៀតមានសមត្ថកិច្ចពិសេស។

- តុលាការឧក្រិដ្ឋកម្មអន្តរជាតិមានសមត្ថកិច្ចលើរឿងក្តីព្រហ្មទណ្ឌ ៖ ឧក្រិដ្ឋកម្មសង្គ្រាម ការរំលោភអនុសញ្ញាទីក្រុងហ្សឺណែវ។

- *ORD មានសមត្ថកិច្ចលើរឿងក្តីពាណិជ្ជកម្ម។*
- *CIRDI មានសមត្ថកិច្ចលើរឿងក្តីវិនិយោគ។*

*យុត្តាធិការមិនមានសេចក្តីវិនិច្ឆ័យដូចគ្នានោះឡើយ ៖ គេបែងចែកវាងវិវាទនៃសុពលភាព និងវិវាទនៃទំនួលខុសត្រូវ ឬរវាងវិវាទប្រភេទរដ្ឋប្បវេណី និងវិវាទដែលមានលក្ខណៈបង្រ្កាប។*

- *វិវាទនៃសុពលភាព( វិនិច្ឆ័យសេចក្តី បញ្ហាច្បាប់ សេចក្តីសម្រេច ៖ ដើម្បីវិនិច្ឆ័យលើបញ្ហាស្តីពីចំណុចច្បាប់មួយ)។*
- *វិវាទនៃទំនួលខុសត្រូវ( ដើម្បីកំណត់ថា តើរវាងគូភាគីទាំងពីរ មានការទទួលខុសត្រូវសំណងជួសជុលឱ្យភាគីម្ខាងទៀតឬទេ។ រឿងក្តីបែបនេះមានច្រើនចំពោះ CIRDI អង្គការពាណិជ្ជ-កម្មពិភពលោក)។ ជម្លោះភាគច្រើនជាជម្លោះក្នុងប្រភេទនេះ។*
- *វិវាទដែលលក្ខណៈបង្រ្កាប គឺតុលាការឧក្រិដ្ឋកម្មអន្តរជាតិជាអ្នកមានសមត្ថកិច្ច។*
- *វិវាទបន្ទាប់បន្សំផ្សេងៗទៀត មានវិវាទស្តីពីមុខងារសាធារណៈអន្តរជាតិ ពោលគឺ TANU និង TAOIT ដែលទទួលតែវិវាទរវាងអង្គការអន្តរជាតិ និងបុគ្គលិកអង្គការ ពាក់ព័ន្ធនឹងរឿងក្តីបញ្ឈប់ពីការងារ ប្រាក់បៀវត្សរ៍។*

*ក្រៅពីមានភាពខុសគ្នាច្រើនដែលបានសង្កេតឃើញ នៅមានអវត្តមាននៃឯកភាពនៃយុត្តា-ធិការទាំងនេះ។*

## ២- អវត្តមានឯកភាពនៃយុត្តាធិការអន្តរជាតិ

*គេអាចពិនិត្យលើទិដ្ឋភាពពីរ ៖ ទិដ្ឋភាពទូទៅ និងទិដ្ឋភាពជាអភិក្រម។*

### ២.១- នៅក្នុងទស្សនវិស័យទូទៅ

*មិនមានស្ថាប័នយុត្តិធម៌អន្តរជាតិទោលនោះទេ។ ការបង្កើតយុត្តាធិការអន្តរជាតិនីមួយៗផ្អែកទៅលើកិច្ចមួយៗ សន្ធិសញ្ញានីមួយៗស្វយ័ត បើប្រៀបធៀបជាមួយសន្ធិសញ្ញាផ្សេងទៀត។ រវាងយុត្តាធិការទាំងនេះ មិនមានទំនាក់ទំនងនៃភាពចំណុះគ្នាណាមួយឡើយ។ គ្មានយុត្តាធិការណាមួយមានកាតព្វកិច្ចត្រូវគោរព ឬប្រតិបត្តិតាមយុត្តិសាស្ត្ររបស់យុត្តាធិការមួយផ្សេងទៀតឡើយ។គ្មានយន្តការសម្របសម្រួលណាមួយទេ ប្រភេទដូចជាបញ្ហាព្យសនកម្ម( préjudiciable) ជាដើម។ នេះគឺជាអវត្តមាននៃសមាហរណកម្មសកលនៃច្បាប់អន្តរជាតិ។*

*គេអាចគិតពីអ្វីដែលមាននៅក្នុងសហភាពអឺរ៉ុប គឺរឿងក្តីដែលត្រូវជំនុំជម្រះមុនបណ្តឹងប្រធាន ក៏ប៉ុន្តែនៅក្នុងនីតិអន្តរជាតិ រឿងក្តីដែលត្រូវជម្រះមុនរឿងធំ( យុត្តាធិការត្រូវប្រឈមមុខនឹងបញ្ហាច្បាប់ដែលតុលាការមិនមានសមត្ថភាពក្នុងការវិនិច្ឆ័យ)។ នៅក្នុងនីតិផ្ទៃក្នុង ក៏មានរឿង*

ក្ដីដែលត្រូវជំនុំជម្រះមុនបណ្ដឹងប្រធានដែរ។ អស្សាមិករណ៍គឺជាបញ្ហាច្បាប់សាធារណៈ។ ក៏ប៉ុន្តែលំដាប់តុលាការជាអ្នកការពារ និងធានាចំពោះវិស័យឯកជន។ គេរង់ចាំថៅក្រមរដ្ឋបាល ដើម្បីបង្កើតទទ្បីករណ៍។ នៅប្រទេសកម្ពុជា នៅពេលមានការវិនិច្ឆ័យ គឺមានបញ្ហាស្ដីពីលំដាប់ធម្មនុញ្ញ។ ថៅក្រមពន្យារពេលវិនិច្ឆ័យសេចក្ដី ពីព្រោះថៅក្រមស្នើសុំទៅក្រុមប្រឹក្សាធម្មនុញ្ញ។ បន្ទាប់ពីបានទទួលចម្លើយ ថៅក្រមអាចទទួលរឿងក្ដីបាន។

នីតិអន្តរជាតិបែកសាខាទៅតាមវិស័យផ្សេងៗគ្នា។ ក៏ប៉ុន្តែ ត្រូវតែមានការសម្របសម្រួលរវាងយុត្តាធិការអន្តរជាតិ។ នៅក្នុងលំដាប់ផ្ទៃក្នុង គេមានសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល( នៅប្រទេសបារាំងគឺក្រុមប្រឹក្សារដ្ឋ)។ ជាទូទៅ ប្រព័ន្ធផ្ទៃក្នុងជានាទូវភាពប្រទាក់គ្នាល្អ។ នេះជាអ្វីដែលខ្វះខាតនៅក្នុងនីតិអន្តរជាតិ ព្រោះថាយុត្តាធិការអាស្រ័យលើកិច្ចបង្កើតអង្គការដែលធ្វើឱ្យយុត្តាធិការទាំងនោះស្វយ័ត។

នៅក្នុងលំដាប់អន្តរជាតិ មានហានិភ័យនៃការប្រកួតប្រជែង និងជម្លោះយុត្តាធិការ និង/ឬយុត្តិសាស្ត្រ។ គេអាចនិយាយបានថា នៅក្នុងនីតិអន្តរជាតិ គូភាគីក្ដីពិបាកនឹងទទួលបានថៅក្រម។ ដូច្នេះ មានជម្លោះដោយផ្ទាល់តិចតួចណាស់។ លើសពីនេះទៅទៀត ហានិភ័យនៃជម្លោះផ្នែកយុត្តាធិការផ្ទាល់គឺខ្សោយគួរសម។

ក៏ប៉ុន្តែហានិភ័យនៃជម្លោះប្រយោលមានច្រើន។ ហានិភ័យទាំងនេះកើតឡើងមកពីថៅក្រមពីរនាក់ទទួលពាក្យបណ្ដឹងទៅលើទិដ្ឋភាពខុសៗគ្នានៃរឿងក្ដីតែមួយ ឬមកពីបញ្ហាគតិយុត្ត( ការវាយតម្លៃគតិយុត្តនៃស្ថានភាពដូចគ្នាមួយ ការបកស្រាយបទដ្ឋានដូចគ្នា)។

ជាសំខាន់ ហានិភ័យនៃជម្លោះពាក់ព័ន្ធដល់អង្គច្បាប់។ ដូច្នេះគេបានសម្គាល់ឃើញថា តុលាការអឺរ៉ុបដូចជា CEDH និង CJCE ធ្លាប់បានបង្កើតយុត្តិសាស្ត្រដែលផ្ទុយគ្នានឹងច្បាប់អន្តរជាតិទូទៅ។ ឧទាហរណ៍ ពាក់ព័ន្ធនឹងវិធាននៃការបកស្រាយសន្ធិសញ្ញា + មានភាពមិនស្របគ្នាទាក់ទងនឹងសិទ្ធិមនុស្ស«សង្គ្រាមសិទ្ធិមនុស្ស»។

CEDH និង CJCE នៅលើសំណុំរឿងជាច្រើន គេបានផ្អែកសេចក្ដីសម្រេចតាមលក្ខណៈស្វយ័ត។ តុលាការទាំងពីរនេះបានអនុម័តវិធានសន្ទានកម្មខុសគ្នា។

ក្នុងការអនុវត្តគេត្រូវប្រយ័ត្ន។ អវត្តមាននៃយន្តការសម្របសម្រួលមិនរារាំងដល់យុត្តាធិការឱ្យយកចិត្តទុកដាក់ដល់ស្នាដៃរបស់យុត្តិការដទៃទៀតទេ។ ប៉ុន្តែគេអាចយកគំនិតតាមបាន។ យុត្តាធិការប្រើប្រាស់យុត្តិសាស្ត្ររបស់គ្នាទៅវិញទៅមក។ កម្ពីគឺមានពិតប្រាកដ។ កិត្តិនាម ឬអតីតភាពនៃស្ថាប័នមួយមានឥទ្ធិពលលើការបង្កើតនៃកម្ពីទាំងនេះ ពោលគឺវាមិនមែនត្រឹមតែជាការខ្ជាប់ខ្ជួនសារប៉ុណ្ណោះទេ គឺថែមទាំងអំណាច ឬនិត្យានុកូលភាពផងដែរ។

ដូច្នេះក្នុងពេលដែលតុលាការយុត្តិធម៌អន្តរជាតិត្រូវបានបើកឱកាសតិចតួចឱ្យលើកពី

យុត្តាធិការផ្សេងៗទៀត។ ស្ថាប័នបណ្តឹងឧទ្ធរណ៍របស់WTOលើកឡើងយ៉ាងច្រើនលើសលប់ពីតុលាការយុត្តិធម៌អន្តរជាតិ។ នេះគឺជាការយកចិត្តទុកដាក់ចំពោះតុលាការយុត្តិធម៌អន្តរជាតិ។ ដូច្នេះគោលការណ៍នៃការប្រុងប្រយ័ត្ន ក្នុងនាមជាគោលការណ៍ទូទៅនៃនីតិ ឬវិធានទំនៀមទម្លាប់ត្រូវបានលើកឡើង នៅមុខស្ថាប័នឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក(សហគមន៍អឺរ៉ុប - វិធានការដែលពាក់ព័ន្ធនឹងសាច់ និងផលិតផលសាច់(អ័រម៉ូន)។ នេះឆ្លុះបញ្ចាំងពីការច្រានចោល «ភាពនៅដាច់ឆ្ងាយគ្លីនិក»នៃច្បាប់អង្គការពាណិជ្ជកម្មពិភពលោក បើប្រៀបធៀបទៅនឹងច្បាប់អន្តរជាតិនៅសេសសល់។ ទំនាក់ទំនងដំបូងបានអនុញ្ញាតឱ្យស្ថាប័នឧទ្ធរណ៍តម្កល់ជាការផ្តល់ហេតុផលគតិយុត្ត។

ជាញឹកញាប់ TIDM យោងទៅលើយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ។ តុលាការអន្តរជាតិមានវ័យចំណាស់ ចំណែកឯ TIDM ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៦ប៉ុណ្ណោះ។ TIDM បានផ្តិតយកយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ។ ដូច្នេះ TIDM បានយោងទៅយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិនៅក្នុងសាលដីការបស់ខ្លួន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ នៅក្នុងសំណុំរឿង នាវា Saïga (លេខ២) និងបានយោងទៅលើសាលដីកាសម្រេចដោយតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍នៅក្នុងសំណុំរឿងផលប្រយោជន៍មួយចំនួនរបស់អាល្លឺម៉ង់នៅ Heaute Silésie polonaise សាលដីកាសម្រេចដោយយុត្តាធិការដូចគ្នានេះដែរ នៅក្នុងសំណុំរឿង Usine de Chorzow និងសាលដីកាដែលចេញដោយតុលាការយុត្តិធម៌អន្តរជាតិនៅក្នុងសំណុំរឿង Gabcikovo-Nagymaros។

## ២.២- អវត្តមាននៃឯកភាពនៃរឿងក្តី

គេសង្កេតឃើញថា មានវិធាននីតិវិធីនៅក្នុងអត្តបទបង្កើតលក្ខន្តិកៈរបស់យុត្តាធិការ។ វិធាននៃនីតិវិធី និងលក្ខន្តិកៈត្រូវបានធ្វើការចរចារវាងរដ្ឋស្ថាបនិក ឬនៅក្នុងយុត្តាធិការ។ គេបានបង្កើតនូវភាពចម្រុះវប្បធម៌នៅក្នុងនីតិវិធីនោះ។

បទបញ្ញានីតិវិធីទាំងនោះ គឺជាលទ្ធផលនៃការរួមផ្សំនូវប្រព័ន្ធគតិយុទ្ធជាច្រើនខុសៗគ្នា។ សម្រាប់គណៈកម្មការអឺរ៉ុបទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស(CEDH) គឺជាការតែងតាំងចៅក្រមម្នាក់ក្នុងរដ្ឋភាគីមួយ(ចៅក្រម២៧រូប)។ ចំពោះលក្ខខណ្ឌមួយផ្សេងទៀត នេះគឺជាការបង្ហាញនូវប្រព័ន្ធគតិយុត្ត(ប្រព័ន្ធ៥)របស់រដ្ឋនានាដែលពាក់ព័ន្ធ ពោលគឺនៅក្នុងករណីរបស់តុលាការយុត្តិធម៌អន្តរជាតិ TIDM ស្ថាប័នឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក។ លើសពីនេះ មានកត្តា«បុគ្គល» បុគ្គលិកលក្ខណៈ ការបណ្តុះបណ្តាល បទពិសោធន៍របស់បុគ្គលដែលជាសមាសភាពនៃយុត្តាធិការ។ សមាជិកមានបទពិសោធន៍នៅក្នុងយុត្តាធិការអន្តរជាតិមួយ ឬច្រើន(ឧទា-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហរណ៍ ៖ Abi-Saab) ឬមានបទពិសោធន៍មួយនៅក្នុងយុត្តាធិការផ្ទៃក្នុង។ ការអនុវត្តដំណើរការរឿងក្តីខុសគ្នាពីអង្គការមួយទៅអង្គការមួយ។

លក្ខន្តិកៈ និងបទបញ្ជាមិនមានចែងអ្វីៗទាំងអស់នោះឡើយ។ មានសេចក្តីណែនាំផ្ទៃក្នុងដែលត្រូវបានអនុម័តដោយយុត្តាធិការផ្ទាល់(WTO)។

អំណាចនៃការដោះស្រាយដោយប្រើនីតិវិធីផ្ទាល់ខ្លួន គឺជាគោលការណ៍មួយ(ទូទៅ)។ គេឃើញមានសុខដុមនីយកម្ម នៅក្នុងកម្រិតដំណើរការរឿងក្តី ការស្រាវជ្រាវរកនិត្យានុកូលភាព។ រដ្ឋមិនគោរពឡើយ ប្រសិនបើវិធានទាំងនេះគឺជាគោលការណ៍ទូទៅ។ រដ្ឋអាចបន្ទោសចៅក្រមបាន។ ចៅក្រមនៃយុត្តាធិការ គេឱ្យឈ្មោះថា ជាមុខងារតុលាការ។ ចៅក្រមព្យាយាមឱ្យឯករាជ្យ។

# ផ្នែកទី២

## លក្ខណៈវិនិច្ឆ័យចាំបាច់របស់យុត្តាធិការអន្តរជាតិ

### ១- ជំហរនៃបញ្ហា

គេត្រូវតែធ្វើការបែងចែករវាងមុខងាររបស់វិវាទ(មានភាពទូលំទូលាយជាង) និងមុខងារយុត្តាធិការ។ មុខងារវិវាទអាចជាមុខងារយុត្តាធិការផង និងក្រៅយុត្តាធិការផង។

មុខងារវិវាទមានលក្ខណៈទូទៅជាង។ CJCE កំណត់ច្បាប់របស់សហភាពអឺរ៉ុប និងបានទាញចេញជាលក្ខណៈវិនិច្ឆ័យដូចតទៅ ៖

១. ប្រភពស្របច្បាប់របស់ស្ថាប័ន

២. ភាពអចិន្ត្រៃយ៍

៣. ចរិតលក្ខណៈចាំបាច់នៃយុត្តាធិការ

៤. ឯករាជ្យភាពរបស់ខ្លួន ចៅក្រមត្រូវតែមានឯករាជ្យ

៥. ការអនុវត្តវិធានច្បាប់

៦. ធម្មជាតិផ្ទុយគ្នានៃនីតិវិធី

កថាខណ្ឌទី១នៃមាត្រា៦របស់ CEDH កំណត់ពីគោលការណ៍នៃរឿងក្តីប្រកបដោយសមធម៌(រឿងក្តីសាធារណៈ រយៈពេលសមស្រប តុលាការឯករាជ្យ និងមិនលម្អៀងដែលត្រូវបានបង្កើតឡើងដោយច្បាប់ ចរិតលក្ខណៈផ្ទុយគ្នា)។

CEDH គោរពគោលការណ៍ប្រឈមមុខគ្នា។ CEDH ត្រូវបានសម្គាល់ដោយ«តួនាទីយុត្តាធិការរបស់ខ្លួន ៖ វិនិច្ឆ័យសេចក្តីដោយឈរលើច្បាប់ និងក្រោយពីមាននីតិវិធីដែលត្រូវបាន

*រៀបចំ» ( សំណុំរឿងBelibos c. Suisse ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៨ ស៊េរី A លេខ១៣២)។*

## ២- ស្ថាប័នយុត្តាធិការសម្បូណ៌បែប

*គេអាចបែងចែក ៖*

### ២.១- យុត្តាធិការទូទៅនិយមអន្តរជាតិដែលមានគោលដៅសកល និងតំបន់ ៖

*តុលាការយុត្តិធម៌អន្តរជាតិ( និងពីមុនគឺតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍) តុលាការយុត្តិធម៌អាមេរិកកណ្តាល( ១៩៩២) តុលាការយុត្តិធម៌អន្តរ-អាមេរិកាំង តុលាការយុត្តិធម៌អន្តរ-ជាតិអ៊ីស្លាម។*

### ២.២- យុត្តាធិការអន្តរជាតិឯកទេសដែលមានគោលដៅសកល ៖

*សម្រាប់នីតិសមុទ្រគឺ TIDM សម្រាប់នីតិពាណិជ្ជកម្មអន្តរជាតិគឺ ORD នីតិមនុស្សធម៌គឺតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។*

### ២.៣- យុត្តាធិការអន្តរជាតិឯកទេសដែលមានគោលដៅទៅតាមផ្នែកនៃនីតិមនុស្សធម៌ ៖

*TPIY, TPIR តុលាការព្រហ្មទណ្ឌដែលមានលក្ខណៈអន្តរជាតិ( ប្រទេសកម្ពុជា ប្រទេស Sierra Leone ប្រទេសកូសូវ៉ូ ប្រទេសទីម័រខាងកើត)។ តុលាការទាំងនោះស្ថិតនៅក្រោមការលាយឡំគ្នានៃប្រព័ន្ធជាតិ និងប្រព័ន្ធអន្តរជាតិ។*

*នីតិរដ្ឋបាលអន្តរជាតិ ៖ TANU (១៩៩២) TAOIT (១៩២៦) តុលាការរដ្ឋបាលនៃធនាគារពិភពលោក( ១៩៨០ )-ល-។ ( សរុប២៣ស្ថាប័ន)*

### ២.៤- យុត្តាធិការអន្តរជាតិតំបន់ឯកទេសអំពីសិទ្ធិមនុស្ស ៖

*តុលាការ CEDH តុលាការ CIADH (១៩៧៩) តុលាការសិទ្ធិមនុស្ស និងប្រជាជនអាហ្វ្រិក( ១៩៩៨)។ ក្នុងផ្នែកសេដ្ឋកិច្ចនៅអឺរ៉ុបគឺមានតុលាការ CJCE / នៅអាហ្វ្រិកមានតុលាការយុត្តិធម៌ OHADA ( ១៩៩៧) តុលាការយុត្តិធម៌នៃទីផ្សាររួមរបស់អាហ្វ្រិកខាងកើត និងខាងត្បូងតុលាការយុត្តិធម៌នៃសមាគមសេដ្ឋ-កិច្ចនៃរដ្ឋអាហ្វ្រិកកណ្តាល( ១៩៨៣ ) / មជ្ឈិមបូព៌ា ៖ តុលាការយុត្តិធម៌របស់សហភាពនៃក្រុមប្រទេស Maghreb arabe ( ១៩៨៩) ការិយាល័យយុត្តិធម៌សហ-គមន៍អាស៊ីប៉ាស៊ីភិចខាងកើត ( APEC) ( Asian Pacific East Community ) /*

## ២.៥- មជ្ឈត្តការ ៖

*មជ្ឈត្តការអន្តរជាតិទូទៅ ៖ មជ្ឈត្តការ CPA (១៨៩៩) ឬមជ្ឈត្តការចំពោះកិច្ច។*

*មជ្ឈត្តការអន្តរជាតិឯកទេស ៖ មជ្ឈត្តការ CIRDI តុលាការដោះស្រាយជម្លោះរវាងប្រទេសអ៊ីរ៉ាក់ និងសហរដ្ឋអាមេរិក(១៩៨១)។*

*មជ្ឈត្តការអន្តរជាតិតំបន់ ៖ តុលាការផ្សះផ្សា និងតុលាការ OSCE (១៩៩២)គណកម្មការសន្ទានកម្ម ផ្សះផ្សា និងមជ្ឈត្តការ UA (១៩៦៤ សម្រាប់OUA) ប្រព័ន្ធដោះស្រាយជម្លោះតាមមជ្ឈត្តការ NAFTA (១៩៩២) តុលាការមជ្ឈត្តការផ្នែកទីផ្សាររួមនៅអាមេរិកកណ្ដាល(១៩៦០)។*

## ៣- លក្ខណៈវិនិច្ឆ័យនៃយុត្តាធិការអន្តរជាតិ

*វចនានុក្រមSalmon បានផ្ដល់និយមន័យពាក្យយុត្តាធិការអន្តរជាតិថាជា ៖ «ស្ថាប័នមួយដែលមានអំណាចវិនិច្ឆ័យសេចក្ដី ពោលគឺវិនិច្ឆ័យវិវាទរវាងរដ្ឋតាមរយៈសេចក្ដីសម្រេចដែលមានលក្ខណៈជាកាតព្វកិច្ច ទោះជាស្ថាប័នមជ្ឈត្តការ ឬយុត្តាធិការ ឬស្ថាប័នណាមួយផ្សេងទៀតដែលមានអំណាចយុត្តាធិការក៏ដោយ»។ បន្ទាប់មក វចនានុក្រមនេះបន្ថែមជាធាតុបន្ទាប់បន្សំថាជា ៖ «ស្ថាប័នអចិន្ត្រៃយ៍ដែលត្រូវបង្កើតជាដំបូងដោយច្បាប់អន្តរជាតិ និងដែលបានកំណត់សមត្ថកិច្ច និងបទបញ្ជារបស់ស្ថាប័ន ព្រមទាំងមុខងារ រួមជាមួយសមត្ថកិច្ចដែលត្រូវបានកំណត់ជាអរូបីដោយយោងទៅតាមប្រភេទនៃជម្លោះផ្សេងៗ»។ និយមន័យនេះមិនគួរជាទីពេញចិត្តឡើយ។*

*គេអាចបង្កើតលក្ខណៈវិនិច្ឆ័យអន្តោម័ត និងលក្ខណៈវិនិច្ឆ័យសត្យានុម័ត។*

## ៣.១- លក្ខណៈវិនិច្ឆ័យអន្តោម័ត

*លក្ខណៈវិនិច្ឆ័យទូទៅ(នៃយុត្តាធិការ) ៖ អង្គភាពទីបី ការអនុវត្តច្បាប់ ដំណោះស្រាយមានលក្ខណៈជាកាតព្វកិច្ចសម្រាប់គូភាគី។*

*លក្ខណៈវិនិច្ឆ័យអន្តោម័តចម្បងៗ ៖*

- *អន្តរាគមន៍របស់អង្គភាពទីបី ៖ ចៅក្រមឯករាជ្យ ស្ថាប័នអចិន្ត្រៃយ៍។*
- *ស្ថាប័នចេញសេចក្ដីសម្រេចដោយឈរលើច្បាប់ ៖ សេចក្ដីសម្រេចដែលនិយាយពីសិទ្ធិ ប៉ុន្តែគេអាចវិនិច្ឆ័យដោយគោលការណ៍ ex œquo et bono បាន។*
- *សេចក្ដីសម្រេចជាកាតព្វកិច្ចសម្រាប់គូភាគី ៖ ភាពជាកាតព្វកិច្ច អាជ្ញាអង្គជំនុំ។*
- *នីតិវិធីនៃយុត្តាធិការដែលត្រូវបានបង្កើតឡើងទុកមុនជាស្រេច ៖ ការបង្កើតទុកមុននេះអាចជានាដល់នីតិវិធីនៃយុត្តាធិការ។ មជ្ឈត្តការមានភាពទន់ ៖ ការកំណត់វិធាននីតិវិធី។ នីតិវិធីមានការធានានៅចំពោះមុខគូភាគី រឿងក្ដីមានសមធម៌ សម្រាប់ CEDH។*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*មិនថាហៅឈ្មោះបែបណាទេ ទាំងនេះជាគោលការណ៍។*

*ក៏ប៉ុន្តែ មានលក្ខខណ្ឌបន្ថែមផ្សេងៗទៀតរបស់យុត្តាធិការអន្តរជាតិ ៖ មានលក្ខណៈវិនិច្ឆ័យចំនួនពីរ។*

- *បង្កើតដោយកិច្ចអន្តរជាតិមួយ ៖ អាចតាមរយៈសន្ធិសញ្ញា ឬតាមរយៈដំណោះស្រាយមួយ។*
- *វិវាទស្ថិតនៅក្នុងលំដាប់អន្តរជាតិ ៖ ជាតុខាងក្រៅ។*

## ៣.២- លក្ខណៈវិនិច្ឆ័យសត្យានុម័ត

*លក្ខណៈវិនិច្ឆ័យសត្យានុម័តគឺជាចេតនានៃយុត្តាធិការភាវូបនីយកម្ម។*

- *គោលការណ៍ Opinio Juris នៃទំនៀមទម្លាប់ ៖ គឺជាចេតនានៃយុត្តាធិការមួយ។*

*ជាសេចក្តីសន្និដ្ឋាន គេអាចនិយាយបានថា មានយុត្តាធិការជាច្រើនដែលត្រូវបានបង្ហាញ។*

- *យុត្តាធិការអន្តរជាតិមានគោលដៅសកល និងមានសមត្ថកិច្ចទូទៅ ៖ តុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍ តុលាការយុត្តិធម៌អន្តរជាតិ + មជ្ឈត្តការ( ជាពិសេស មជ្ឈត្តការ CIRDI) ៖*
- *យុត្តាធិការអន្តរជាតិមានគោលដៅសកល និងមានសមត្ថកិច្ចពិសេស ៖ TIDM, ORD តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។*
- *យុត្តាធិការអន្តរជាតិមានសមត្ថកិច្ចរឹតត្បិត ៖ TPIY, TPIR*
- *យុត្តាធិការអន្តរជាតិថ្នាក់តំបន់មានសមត្ថកិច្ចស្ទើរតែទូទៅ( ទោះបីជាមូលដ្ឋាននៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅតែមានពិតប្រាកដក្តី) ៖ CJCE។*
- *យុត្តាធិការអន្តរជាតិថ្នាក់តំបន់មានសមត្ថកិច្ចពិសេស ៖ CEDH។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក១៤

# ស្ថានភាពស្ថាប័ន និងចរិតលក្ខណៈអង្គការនៃ យុត្តាធិការអន្តរជាតិ

## ផ្នែកទី១

## ស្ថានភាពស្ថាប័ន

*ការបង្កើតយុត្តាធិការអន្តរជាតិគឺជាកិច្ចមួយសំខាន់ ការបង្កើតនេះនឹងព្យាយាមឱ្យមានផលប៉ះពាល់មួយក្នុងកម្រិតខ្ពស់។ គេបែងចែករវាងយុត្តាធិការដែលត្រូវបានបង្កើតឡើងតាមរបៀបស្វយ័ត និងយុត្តាធិការដែលត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌនៃអង្គការអន្តរជាតិ។*

### ១- យុត្តាធិការស្វយ័ត

*គេអាចលើកឡើងនូវតុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍(ប៉ុន្តែមិនមែនតុលាការយុត្តិធម៌អន្តរជាតិទេ) តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។*

### ១.១- តុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍

*តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ត្រូវបានឯកភាពដោយសង្គមប្រជាជាតិ(SdN)។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍មានស្វយ័តភាពពីសង្គមប្រជាជាតិ(SdN)។ សង្គមប្រជាជាតិបានបង្កើតយុត្តាធិការនេះ ផ្តល់ថវិកា និងតែងតាំងសមាជិកតុលាការ។ ប៉ុន្តែលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍(CPJI) គឺស្វយ័ត។ លក្ខន្តិកៈរបស់ CPJI មិនត្រូវបានបញ្ចូលទៅក្នុងកតិកាសញ្ញាទេ ហើយការចូលរួមរបស់រដ្ឋនៅក្នុងកតិកាសញ្ញាមិនដាក់ជាលក្ខខណ្ឌលើលក្ខន្តិកៈ ហើយលក្ខន្តិកៈក៏មិនដាក់លក្ខខណ្ឌលើរដ្ឋវិញដែរ។ សហរដ្ឋអាមេរិកមិនបានផ្តល់សច្ចា-*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប័នលើកតិកាសញ្ញារបស់សង្គមប្រជាជាតិទេ ហើយចង់ធ្វើឱ្យលក្ខន្តិកៈនេះស្វយ័ត។ លទ្ធភាពនេះហើយធ្វើឱ្យ Monaco និង Lichtensten មិនមែនជាសមាជិករបស់ CPJI។ អ្វីដែលប្លែកនោះគឺ CPJI ត្រូវរលាយបាត់ទៅវិញព្រមពេលជាមួយគ្នានឹងសង្គមប្រជាជាតិដែរ ដោយសារហេតុផលនយោបាយតាមរយៈធន្ទៈប្រានចោលនូវរាល់កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយរដ្ឋទាំងឡាយដែលបរាជ័យនៅក្នុងសង្គ្រាមលោកលើកទីពីរ។

## ១.២- តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ(TIDM)

តុលាការនេះត្រូវបាននបង្កើតឡើងដោយអនុសញ្ញាទីក្រុង Montego Bay ក្នុងឆ្នាំ១៩៨២។ លក្ខន្តិកៈនៃ TIDM ត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធVI។ អាជ្ញាធរបាតសមុទ្រស្ថិតនៅក្នុងសភាពស្ទើរតែមិនមានសកម្មភាព។ TIDM ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាធំៗ។ អនុសញ្ញានេះបានចូលជាធរមាននៅឆ្នាំ១៩៩៦។ ការបោះឆ្នោតជ្រើសតាំងចៅក្រមលើកទីមួយត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៦។ រឿងក្តីទីមួយរបស់តុលាការនេះចាប់ផ្តើមនៅឆ្នាំ១៩៩៧។ តុលាការនេះមានទីតាំងនៅ Hambourg តាំងពីឆ្នាំ២០០០មក។ នៅក្នុងលក្ខន្តិកៈតុលាការ មានមាត្រាជាង១០០ដែលផ្តោតទៅលើការដោះស្រាយជម្លោះ។ មានហេតុផលនយោបាយ ហើយមានការចរចាជាច្រើនតាំងពីឆ្នាំ១៩៧០មក ដោយមានការមិនជឿទុកចិត្តពីសំណាក់រដ្ឋខាងត្បូងចំពោះតុលាការយុត្តិធម៌អន្តរជាតិ។ នៅក្នុងសាលដីកានៅក្នុងសំណុំរឿងស្តីពីតំបន់និរតីអាហ្វ្រិក (Sud-Ouest Africain) តុលាការនេះបានបង្ហាញអំពីទស្សនាទានបែបអភិរក្សស្តីពីសេរីភាពក្នុងការធ្វើនាវាចរណ៍។ តុលាការបានអះអាងលើទស្សនាទាននេះ និងប្រើប្រាស់គោលការណ៍ uti possidetis។ ការព្រមព្រៀងមួយត្រូវបានចរចាដើម្បីស្តាបនាដែលគេហៅថា វេទិកាជ្រើសរើសយុត្តាធិការ(Forum Shopping)។ យោងតាម Forum Shopping រដ្ឋអាចជ្រើសរើសយុត្តាធិការមួយក្នុងចំណោមយុត្តាធិការជាច្រើនដូចជា TIDM តុលាការយុត្តិធម៌អន្តរជាតិ ឬទម្រង់ផ្សេងៗនៃមជ្ឈត្តការ។ ការជ្រើសរើសយកយុត្តាធិការមួយហើយគឺមិនអាចជ្រើសរើសយុត្តាធិការមួយទៀតឡើយ។

## ១.៣- តុលាការឧក្រិដ្ឋកម្មអន្តរជាតិ

គឺជាគំនិតចាស់មួយ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ នៅក្នុងគន្លងរបស់តុលាការទីក្រុង Nuremburg និងទីក្រុង Tokyo ក្នុងការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ គណៈកម្មការនីតិអន្តរជាតិ(CDI)បានសិក្សាលទ្ធភាពក្នុងការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៨៩ ទើបគម្រោងនេះបានចាប់ផ្តើម។ ការងាររៀបចំត្រូវធ្វើឡើងដើម្បីវាយតម្លៃ

គម្រោងគឺ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី (TPIY) និងតុលាការឧក្រិដ្ឋកម្មសម្រាប់Rwanda (TPR) លក្ខន្តិកៈបានសម្រេចឡើងដោយមានគោលដៅអន្តជាតិ។ សន្និសីទបានធ្វើឡើងនៅទីក្រុងរ៉ូម នៅក្នុងទីស្នាក់ការរបស់អង្គការស្បៀងអាហារ និងកសិកម្ម(FAO) និងមានរដ្ឋចំនួន១៦០ អង្គការអន្តរជាតិចំនួន១៧ និងស្ថាប័នជំនាញរបស់អង្គការសហប្រជាជាតិចំនួន១៤បានចូលរួម។ សន្និសីទនេះបានទទួលអង្គការមិនមែនរដ្ឋាភិបាលចំនួន១២៤។ សេចក្តីព្រាងត្រូវបានអនុម័តដោយកុងសង់ស៊ុស(Consensus) នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨។ សហរដ្ឋអាមេរិកបានស្នើសុំឱ្យមានការបោះឆ្នោត ហើយសន្ធិសញ្ញាត្រូវបានអនុម័តដោយ១២០សំឡេងគាំទ្រ៧សំឡេងបដិសេធ(ប្រទេសបារ៉ែន ចិន សហភាពអឺរ៉ុប ឥណ្ឌា អ៊ីស្រាអែល កាតា និងវៀតណាម) ១២សំឡេងអនុប្បវាទដែលភាគច្រើនជាប្រទេសអារ៉ាប់។ នៅឆ្នាំ២០០៤ មានការធ្វើសច្ចាប័នចំនួន៩៧។ បច្ចុប្បន្ននេះ សន្ធិសញ្ញាមានប្រទេសភាគីចំនួន១២០ ហើយប្រទេសជប៉ុន ហ្វីលីពីន បង់ក្លាដេសបានផ្តល់សច្ចាប័ន។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២។ ប្រទេសបារាំងបានផ្តល់សច្ចាប័នដល់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ តាមរយៈច្បាប់ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០ បន្ទាប់ពីបានធ្វើការកែប្រែរដ្ឋធម្មនុញ្ញរបស់ខ្លួន។ លក្ខន្តិកៈទីក្រុងរ៉ូមមានបដិវាដកម្មជាមួយលក្ខន្តិកៈនៃទីក្រុងរ៉ូម ពោលគឺទាក់ទងនឹងការផ្តន្ទាទោសមេដឹកនាំដែលកំពុងកាន់អំណាច។ តុលាការព្រហ្មទណ្ឌអន្តរជាតិនៅតែភ្ជាប់ខ្លួនជាមួយអង្គការសហប្រជា-ជាតិ តាមរយៈកិច្ចព្រមព្រៀងដែលកំណត់ពីតួនាទីរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិដែលជាអាជ្ញាធរមួយក្នុងចំណោមអាជ្ញាធរចំនួនបីដែលអាចដាក់ពាក្យបណ្តឹងទៅរដ្ឋអាជ្ញាបាន។ CIP គឺជាអង្គការអន្តរជាតិដែលមានមុខងារយុត្តាធិការ។

## ២- យុត្តាធិការដែលភ្ជាប់ជាមួយអង្គការអន្តរជាតិ

### ២.១- តុលាការយុត្តិធម៌អន្តរជាតិ(CIJ)

លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិត្រូវបានបញ្ចូលនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ នៅក្នុងមាត្រា៧។ តុលាការយុត្តិធម៌អន្តរជាតិគឺជាស្ថាប័នមួយក្នុងចំណោមស្ថាប័នសំខាន់ៗទាំង៦នៃអង្គការសហប្រជាជាតិ។ តុលាការនេះត្រូវបានបញ្ចូលជាគ្រឹះនៅក្នុងធម្មនុញ្ញមាត្រា៩២នៃធម្មនុញ្ញ។ លក្ខន្តិកៈនៃតុលាការអន្តរជាតិជាឧបសម្ព័ន្ធនៃធម្មនុញ្ញរបស់ UN ដែលជាការពង្រីកទំហំនៃអត្ថបទដើម។ អាស្រ័យហេតុនេះ រដ្ឋទាំងអស់ដែលក្លាយជាសមាជិករបស់អង្គការសហប្រជាជាតិ គឺជាភាគីនៃលក្ខន្តិកៈតាមបែប *ipso jure*។ នេះមិនមានន័យថា គ្រប់រដ្ឋទាំងអស់ដែលជាសមាជិក ត្រូវបានភ្ជាប់ខ្លួនជាមួយតុលាការនោះឡើយ។ ដើម្បីឱ្យតុលាការនេះមានសមត្ថកិច្ចលើរដ្ឋបាន រដ្ឋត្រូវតែអាចបង្ហាញថា ខ្លួនត្រូវបានចងដោយយុត្តាធិការរបស់

*តុលាការ។*

## ២.២- អនុស្សរណៈនៃការយោគយល់គ្នាដែលគ្រប់គ្រងដំណោះស្រាយជម្លោះរបស់អង្គការ WTO

*ការចរចានៅក្នុងជុំ Uruguay (cycle Uruguay) កិច្ចព្រមព្រៀង Marrakech ឆ្នាំ១៩៩៤ បានផ្តល់រូបរាងឱ្យ GATT ដែលត្រូវបានជំនួសដោយអង្គការ WTO។ WTO មានបុគ្គលភាពគតិយុត្ត។ គោលដៅរបស់អង្គការ WTO គឺធ្វើឱ្យមានដំណើរការកិច្ចព្រមព្រៀងពហុភាគី ពាណិជ្ជកម្មនិងសេវាកម្ម នីតិឯកជនអន្តរជាតិ(DPI) និងកិច្ចព្រមព្រៀងពហុភាគីនានាស្តីពីពាណិជ្ជកម្មអាកាសចរណ៍ស៊ីវិល និងលទ្ធកម្មសាធារណៈ។ សហភាពអឺរ៉ុបគឺជាសមាជិករបស់ WTO។ អនុស្សរណៈនេះគឺជាសន្ធិសញ្ញាដែលត្រូវបញ្ចូលនៅក្នុងធម្មនុញ្ញរបស់ WTO។ អនុស្សរណៈនេះមានដំណើរការនៅក្រោមការគាំទ្ររបស់អង្គភាពដោះស្រាយវិវាទ ORD។ អង្គភាព ORD នេះមានសមាសភាពជារដ្ឋសមាជិករបស់WTO។ ជាអង្គភាពនយោបាយ អនុស្សរណៈនេះបង្កើតអង្គភាពបណ្តឹងឧទ្ធរណ៍អចិន្ត្រៃយ៍ និងក្រុមការងារពិសេសចំពោះកិច្ច។*

## ២.៣- យុត្តាធិការព្រហ្មទណ្ឌចំពោះកិច្ច

*TPIY និង TPIR ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ៩៥៥ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ របស់ក្រុមប្រឹក្សាសន្តិសុខ ដោយឈរលើមូលដ្ឋាននៃជំពូកទី VII។*

## ២.៤- តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស(CEDH)

*CEDH ត្រូវបានបង្កើតឡើងនៅក្នុងក្រុមប្រឹក្សាអឺរ៉ុប និងត្រូវបានចុះហត្ថលេខានៅទីក្រុងរ៉ូម នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ ដោយរដ្ឋាភិបាលអឺរ៉ុបចំនួន១១។ អនុសញ្ញានេះចូលជាធរមាននៅឆ្នាំ១៩៥៣ និងដំបូងមានស្ថាប័នចំនួនបី ៖ គណៈកម្មការអឺរ៉ុប (១៩៥៤) គណៈកម្មការសិទ្ធិមនុស្ស CEDH (១៩៥៩) និងគណៈកម្មាធិការរដ្ឋមន្ត្រីនៃក្រុមប្រឹក្សាអឺរ៉ុប។ គណៈកម្មការ CEDH ត្រូវបានបញ្ចូលនៅក្នុងស្ថាប័នរបស់អឺរ៉ុប ហើយមានភាពជិតស្និទ្ធជាមួយក្រុមប្រឹក្សាអឺរ៉ុបជាងក្រុមប្រឹក្សារដ្ឋមន្ត្រី និងគណៈកម្មការ។ តាមរយៈកាអនុម័តពិធីសារលេខ១១ គេបានបង្កើតតុលាការទោលមួយ។*

## ២.៥- តុលាការយុត្តិធម៌សហគមន៍អឺរ៉ុប(CJCE)

*CJCE ជាស្ថាប័នរួមសម្រាប់គ្រប់រដ្ឋទាំងអស់ដែលបានផ្តល់សច្ចាប័ន។ ដើម្បីកែប្រែលក្ខន្តិកៈរបស់ CJCE ត្រូវតែឆ្លងកាត់តាមរយៈដំណើរការរបស់សហគមន៍។ CJCE គឺជាអង្គភាពសមាហ-*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រណោកម្មពិតប្រាកដមួយដែលមានភាពខុសប្លែកពីយុត្តាធិការដទៃទៀត ដោយមានអំណាចតុលាការពិតប្រាកដនៅក្នុងច្បាប់ផ្ទៃក្នុងដែលស្ថិតនៅពីលើរដ្ឋសមាជិក។ រដ្ឋសមាជិកដាច់ខាតត្រូវតែចងដោយ CJCE។*

# ផ្នែកទី២

## ចរិតលក្ខណៈអង្គការ

*គឺភាពអចិន្ត្រៃយ៍ សមាសភាព និងរចនាសម្ព័ន្ធរបស់យុត្តាធិការអន្តជាតិ។*

### ១- ភាពអចិន្ត្រៃយ៍

*ភាពអចិន្ត្រៃយ៍គឺជាចរិតលក្ខណៈមួយរបស់យុត្តាធិការអន្តជាតិ។*

### ១.១- មជ្ឈត្តការ

*លើកលែងតែចំពោះមជ្ឈត្តការ សមាសភាពរបស់មជ្ឈត្តការត្រូវរំលាយវិញនៅចុងបញ្ចប់ ហើយគ្មានភាពអចិន្ត្រៃយ៍នៃយុត្តាធិការព្រហ្មទណ្ឌចំពោះកិច្ចនោះឡើយ។ មជ្ឈត្តការត្រូវបានសម្គាល់តាមរយៈសមាសភាពចំពោះកិច្ច។ ប៉ុន្តែមានតុលាការមជ្ឈត្តការអចិន្ត្រៃយ៍។ អ្វីដែលអចិន្ត្រៃយ៍នៅក្នុងតុលាការនេះ គឺតុលាការមានការិយាល័យក្រឡាបញ្ជីអចិន្ត្រៃយ៍ ហើយតុលាការ CPA នេះមានវិធាននីតិវិធីអចិន្ត្រៃយ៍។ ក៏ប៉ុន្តែចំពោះមជ្ឈត្តករវិញ ការជ្រើសរើសមជ្ឈត្តករនៅតែស្ថិតក្នុងអំណាចរបស់រដ្ឋដដែល។ ទម្រង់នេះខ្វះភាពទន់ភ្លន់សម្រាប់រដ្ឋ។ CPA មិនទទួលបានជោគជ័យខ្លាំងទេ។ ក្នុងរយៈពេល៣៣ឆ្នាំ តុលាការនេះដំណើរការរឿងក្តីបានតែ២០រឿងក្តីប៉ុណ្ណោះ។ ចាប់តាំងពីឆ្នាំ១៩៣៣មក តុលាការនេះគេចលក់ទៅហើយ។ CPA បានព្យាយាមតស៊ូដោយបង្កើតយន្តការរវាងរដ្ឋ និងបុគ្គលឯកជន។ តួអង្គនានាចូលចិត្តដាក់ពាក្យបណ្តឹងទៅតុលាការ CIRDI ជាង។*

*តុលាការ CIRDI – អនុសញ្ញាត្រូវបានចុះហត្ថលេខាក្រោមការឧបត្ថម្ភរបស់ធនាគារពិភពលោក នៅឆ្នាំ១៩៦៥ ពោលគឺជាមជ្ឈត្តការរវាងរដ្ឋ និងសហគ្រាសឆ្លងជាតិ។ តុលាការមិនមានសមត្ថភាពផ្តល់ដំណោះស្រាយឱ្យដល់អ្នកវិនិយោគទេ។ ក្នុងពេលដែលក្រុមហ៊ុនជាតិមានវត្តមាននៅចំពោះមុខ CIRDI ក្រុមហ៊ុននេះត្រូវតែលះបង់នូវការការពារផ្នែកការទូតនៅចំពោះមុខរដ្ឋដើមកំណើត។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.២- CIJ, ORD, CEDH, CJCE

*ភាពអចិន្ត្រៃយ៍ផ្តល់នូវនិរន្តរភាពមួយដែលអនុញ្ញាតឱ្យផ្តល់យុត្តិសាស្ត្រដែលមានលក្ខណៈជាយុត្តាធិការអន្តរជាតិ។ នីតិវិធីត្រូវបានកំណត់រួច ខណៈពេលដែលចំពោះមជ្ឈត្តការវិញ នីតិវិធីត្រូវបានរៀបចំឡើងបន្ទាប់ពីមានជម្លោះ។ ចំពោះតុលាការ CIJ លក្ខន្តិកៈ បទបញ្ញា និងមាត្រា ៣០ តុលាការនេះមានសមត្ថកិច្ច ដើម្បីបំពេញបន្ថែមលើលក្ខន្តិកៈ តាមរយៈបទបញ្ញា។ ភាពអចិន្ត្រៃយ៍កំណត់យុត្តាធិការ និងបទបញ្ញារបស់តុលាការមានអត្ថិភាពមុនជម្លោះ។*

## ១.៣- យុត្តាធិការព្រហ្មទណ្ឌចំពោះកិច្ច ៖ TPIY និង TPIR និងតុលាការកូនកាត់

*សម្រាប់យុត្តាធិការដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ(CS) ជម្លោះដែលប្រព្រឹត្តទៅនៅក្នុងដំណាក់កាលជាក់លាក់ ត្រូវបញ្ចប់ទៅវិញបន្ទាប់ពីមានសេចក្តីសម្រេច។ ការរលាយបាត់ទៅវិញរបស់ TPIY បង្កឱ្យមានបញ្ហា ៖ តើរដ្ឋណាខ្លះដែលនឹងត្រូវទទួលជនជាប់ចោទ ដើម្បីទទួលទោសរបស់ពួកគេ( នៅក្នុងប្រទេសអ៊ីតាលី ហ្វាំងឡង់ និងន័រវេស)។ គេត្រូវតែគ្រោងទុកនូវកិច្ចព្រមព្រៀងទាំងតាំងពីដើម និងនៅចុងបញ្ចប់។ គេក៏ត្រូវគ្រោងនូវកិច្ចព្រមព្រៀងសម្រាប់ការកាពារផ្នែកការទូតរបស់ប្រជាពលរដ្ឋដែលមានសញ្ជាតិផ្សេងក្រៅពីសញ្ជាតិយូកូស្លាវី។ ជនជាប់ចោទអាចទទួលបានការលើកលែងទោស និងការសម្រាលទោស( ការគណនាទោសធៀបទៅនឹងការដាក់ឱ្យស្ថិតក្រោមការតាមដាន ដើម្បីកាត់បន្ថយទោសជាប់ពន្ធនាគារ)។ ការងារនេះត្រូវរៀបចំតាំងពីដើម។ មេធាវីរំពឹងថា ជនជាប់ចោទអាចស្នើសុំឱ្យមានការបន្ថយទោសបាន។ វាអាចនឹងមានកិច្ចព្រមព្រៀង ដើម្បីបន្តវេនគ្នារវាង TPIY, TPIR និង CPI ដើម្បីបន្តដំណើរការរឿងក្តីផ្សេងៗ។*

*ដូច្នេះ តុលាការទាំងនោះមិនអចិន្ត្រៃយ៍ទេហើយវានឹងរលាយបាត់ទៅវិញនៅពេលដែលជម្លោះត្រូវបានបញ្ចប់។*

*ការរលាយទៅវិញនៃ TPIY បង្កឱ្យមានបញ្ហានីតិវិធី។ ឧទាហរណ៍ រដ្ឋអាចទទួលជនជាប់ចោទ ដើម្បីឱ្យពួកគេជម្រះទោសរបស់ពួកគេ( យោងទៅតាមកិច្ចព្រមព្រៀងដែលធ្វើឡើងដោយរដ្ឋទាំងនោះ ៖ ឧទាហរណ៍ ប្រទេសអ៊ីតាលី ហ្វាំងឡង់ ឬន័រវេស សម្រាប់ TPIY ឬប្រទេសបារាំងចាប់តាំងពីមានកិច្ចព្រមព្រៀងខែមីនា ឆ្នាំ២០០៣ សម្រាប់ TPIR)។ ទោះបីជាយ៉ាងណាក្តី ជនជាប់ទោសអាចទទួលបានការលើកលែងទោស ឬសម្រាលទោស តាមរយៈកិច្ចព្រមព្រៀងរបស់តុលាការ( មាត្រា២៨នៃលក្ខន្តិកៈរបស់ TPIY និងមាត្រា២៧របស់ TPIR)។*

*ដូចយុត្តាធិការឧក្រិដ្ឋកម្មចំពោះកិច្ចដែរ យុត្តាធិការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការកូនកាត់មិនមានគោលដៅស្ថិតនៅជាអមតៈនោះឡើយ។ យុត្តាធិការទាំងនោះត្រូវបានបង្កើតឡើង*

ដើម្បីឆ្លើយតបទៅនឹងបញ្ហាពិសេសណាមួយ និងដើម្បីដោះស្រាយជម្លោះពិសេសណាមួយ។ ដូច្នេះ លក្ខណៈមិនអចិន្ត្រៃយ៍របស់វានឹងក្លាយជានិមិត្តសញ្ញារបស់តុលាការទាំងនោះ។

## ២- សមាសភាព

### ២.១- ភាពជាតំណាង

#### ២.១.១- តុលាការយុត្តិធម៌អន្តរជាតិ(CIJ)

មាត្រា២នៃលក្ខន្តិកៈរបស់តុលាការ CIJ ចែងថា «តុលាការគឺជាអង្គចៅក្រមឯករាជ្យដែលត្រូវបានតែងតាំងដោយយោងទៅលើសញ្ជាតិរបស់ពួកគេ ក្នុងចំណោមបុគ្គលដែលមានសីលធម៌ខ្ពស់ និងដែលមានគ្រប់លក្ខខណ្ឌដែលកំណត់ដើម្បីបំពេញមុខងារ នៅក្នុងប្រទេសរបស់ពួកគេរៀងៗខ្លួន ពោលគឺសំខាន់ជាមុខងារយុត្តាធិការ ឬជាអ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ដែលមានសមត្ថភាពពិតប្រាកដនៅក្នុងផ្នែកច្បាប់អន្តរជាតិ»។ បទប្បញ្ញត្តិនេះចែងពីឯករាជ្យភាព សមត្ថភាព និងបទពិសោធន៍។ បទប្បញ្ញត្តិនេះចែងតែប្រភេទមួយក្នុងចំណោមប្រភេទពីរដែលអាចបង្កើតបានជាយុត្តាធិការប៉ុណ្ណោះ។ វាចែងពីចៅក្រមដែលត្រូវបានតែងតាំងដែលមានចំនួនដប់ប្រាំរូប (ដើម្បីបំពេញអាណត្តិរបស់ពួកគេ) ប៉ុន្តែមិនមែនចៅក្រមចំពោះកិច្ចដែលត្រូវបានចាត់តាំងសម្រាប់តែសំណុំរឿងជាក់លាក់មួយនោះឡើយ។

សមត្ថភាពនេះត្រូវបានវាយតម្លៃខុសៗគ្នាទៅតាមប្រទេសនីមួយៗ។ នៅប្រទេសបារាំង គេជ្រើសរើសក្នុងចំណោមអង្គភាពធំៗរបស់រដ្ឋដែលអាចជាទីប្រឹក្សារបស់រដ្ឋ ជាប្រធាននាយកដ្ឋានកិច្ចការច្បាប់នៃក្រសួងការបរទេសដូចជាករណីរបស់ Basdevant, Guy de Lacharrière និងចៅក្រម Guillaume។ គេអាចកត់សម្គាល់ឃើញថា ឯករាជ្យភាពរបស់ចៅក្រម«មានភាពលម្អៀង»។ សម្រាប់រដ្ឋផ្សេងៗទៀត និន្នាការមានភាពខុសៗគ្នា។ នៅចក្រភពអង់គ្លេស គឺលោក Rosalyn Higgins។ មានចំណងមួយរវាងគណៈកម្មការនីតិអន្តរជាតិ(CDI) និងតុលាការយុត្តិធម៌អន្តរជាតិ(CIJ) ពីព្រោះតុលាការយកលំនាំតាមការងាររបស់គណៈកម្មការ CDI ហើយគណៈកម្មការនេះក៏យកលំនាំតាមតុលាការ CIJ វិញដែរ។

#### ២.១.២- តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ(TIDM)

TIDM មានសមាសភាពចៅក្រមចំនួន២១នាក់ដែលត្រូវបានតែងតាំងសម្រាប់រយៈពេល៩ឆ្នាំដែលធ្វើជាតំណាងដោយយោងលើគោលការណ៍ពីរ ៖ គោលការណ៍ប្រព័ន្ធគតិយុត្ត និងគោលការណ៍បែងចែកភូមិសាស្ត្រដោយសមធម៌(យោងតាមមាត្រា២នៃលក្ខន្តិកៈ ចៅក្រមត្រូវមានសមត្ថកិច្ចច្បាស់លាស់ក្នុងនីតិសមុទ្រ)។ គេឃើញមានការធានាដូចគ្នាចំពោះ CIJ។ ក៏មាន

បាតុភូតនៃការចម្ងងរបស់ TIDM ពី CIJ ដែរ។

គេឃើញមាននៅក្នុង TIDM នូវបុគ្គលដែលមានសមត្ថភាពខ្ពស់ត្រដែតក្នុងនីតិសមុទ្រ។ គេឃើញមានអ្នកជំនាញការផ្នែកនីតិអន្តរជាតិ និងនីតិសមុទ្រដែលជាញឹកញាប់ជាអតីតអ្នកចរចាអនុសញ្ញាឆ្នាំ១៩៨២(ជួនកាលជាអតីតរដ្ឋមន្ត្រី)។

## ២.១.៣- អង្គភាពដោះស្រាយជម្លោះ(ORD) នៃអង្គការពាណិជ្ជកម្មពិភពលោក(WTO)

មានសមាជិកបីក្រុមពិសេសដែលត្រូវបានជ្រើសរើស«ដើម្បីធានាឱ្យមានឯករាជ្យភាពរបស់សមាជិក ធានានានាភាពនៃប្រភព ការបណ្ដុះបណ្ដាល និងបទពិសោធន៍» (មាត្រា៨ ៖ ២នៃអនុស្សរណៈ)។ សមាជិកក្រុមពិសេស(GS)មិនត្រូវបានហាមឃាត់មិនឱ្យមានទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋបាលជាតិទេ ប៉ុន្តែពួកគេមិនអាចមានសញ្ជាតិនៃរដ្ឋភាគីឡើយ។

ស្ថាប័នឧទ្ធរណ៍មានសមាជិកចំនួនប្រាំបួននាក់ដែលត្រូវបានតែងតាំងសម្រាប់រយៈពេលបួនឆ្នាំ ប៉ុន្តែរឿងក្ដីត្រូវពិនិត្យដោយផ្នែកមួយដែលមានសមាជិកបីនាក់ដែលសមាសភាពនេះត្រូវកំណត់ទៅតាមប្រព័ន្ធនៃការវិលជុំ។

## ២.១.៤- យុត្តាធិការឧក្រិដ្ឋកម្មចំពោះកិច្ច

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី(TPIY) និងតុលាការឧក្រិដ្ឋកម្មសម្រាប់ Rwanda (TPR) មានសមាសភាពចៅក្រមអចិន្ត្រៃយ៍ចំនួន១១នាក់ បន្ទាប់មក ១៤នាក់ និងទីបញ្ចប់១៦នាក់ដែលត្រូវបានបែងចែកជាបីអង្គជំនុំជម្រះនៃសាលាដំបូង និងសាលាឧទ្ធរណ៍មួយ + ចៅក្រម ad litem ចំនួន៩នាក់ដែលមានជំនាញក្នុងរឿងក្ដីពិសេស។

ការជ្រើសតាំងចៅក្រមសម្រាប់តុលាការ TPI ត្រូវបានធ្វើឡើងសម្រាប់រយៈពេលបួនឆ្នាំ និងអាចបន្តទៀតបាន(គ្មានការកំណត់អាយុ) លើកលែងតែចៅក្រម ad litem ទេដែលត្រូវបានជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំដែលមិនអាចបន្តទៀតបាន។ ចៅក្រមទាំងនោះត្រូវមានសមត្ថភាពក្នុងផ្នែកច្បាប់មនុស្សធម៌ ច្បាប់ព្រហ្មទណ្ឌ និងសិទ្ធិមនុស្ស។ តុលាការ TPI ត្រូវគោរពគោលការណ៍នៃភាពជាតំណាងរបស់ប្រព័ន្ធគតិយុត្ត។ មុនដំបូង តុលាការទាំងពីរត្រូវបានត្រួតត្រាដោយអ្នកជំនាញផ្នែកច្បាប់ព្រហ្មទណ្ឌ។ សំណុំរឿងដែលត្រូវបានធ្វើឡើង បានសង្កត់ធ្ងន់លើវិសមតានេះ ព្រមទាំងភាពមិនគ្រប់គ្រាន់នៃការបណ្ដុះបណ្ដាលចៅក្រម ក្នុងនីតិអន្តរជាតិ។ ជាអាទិ៍ គឺករណីរឿងក្ដី Blaskic នៅឆ្នាំ១៩៩៧ - ១៩៩៨ ដែលក្នុងនោះ ប្រធានតុលាការដែលជាចៅក្រមជនជាតិអាមេរិកាំង Mac Donald បានចេញបញ្ជាចំពោះរដ្ឋមួយ ហាក់បីដូចជាចំពោះបុគ្គលធម្មតាម្នាក់ ដើម្បីស្នើសុំកិច្ចសហប្រតិបត្តការមួយ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**២.១.៥- តុលាការ CPI**

*លក្ខន្តិកៈរបស់ CPI ចែងថា ចៅក្រមនឹងត្រូវជ្រើសរើសក្នុងចំណោមអ្នកដែលមានសីលធម៌ខ្ពស់ និងដែលគេស្គាល់ដោយសារអព្យាក្រឹតភាព និងបូរណភាពរបស់ពួកគេ ហើយបំពេញគ្រប់លក្ខខណ្ឌដែលទាមទារនៅក្នុងរដ្ឋរបស់ពួកគេរៀងៗខ្លួន ដើម្បីបំពេញមុខងារយុត្តាធិការជាន់ខ្ពស់បំផុត(កថាខណ្ឌទី៣ មាត្រា៣៦នៃលក្ខន្តិកៈ)។*

*បុគ្គលទាំងនោះត្រូវមានសមត្ថភាពដូចគ្នានៅក្នុងផ្នែកច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ពោលគឺសមត្ថភាពដែលមានការទទួលស្គាល់ក្នុងវិស័យជាក់លាក់នៃនីតិអន្តរជាតិ ដូចជាច្បាប់មនុស្សធម៌អន្តរជាតិ និងសិទ្ធិមនុស្ស។ អាណត្តិមិនអាចបន្តសាជាថ្មីទេ និងមិនកំណត់អាយុឡើយ។*

*ចៅក្រមត្រូវបានជ្រើសតាំងសម្រាប់អាណត្តិ៩ឆ្នាំ ប៉ុន្តែអាណត្តិនេះមិនអាចបន្តបន្ថែមបានឡើយ(មាត្រា៣៦) លើកលែងតែពួកគេបានបំពេញមុខងារតិចជាងបីឆ្នាំ។ មិនមានការកំណត់អាយុនោះទេ។*

**២.១.៦- CEDH**

*ពិធីសារលេខ១១មានលក្ខណៈស្រដៀងនឹងលក្ខន្តិកៈរបស់តុលាការ CIJ ណាស់។ ចៅក្រមត្រូវតែមានសីលធម៌ខ្ពស់ មានគ្រប់លក្ខខណ្ឌតម្រូវនានា ដើម្បីបំពេញឧត្តមមុខងារយុត្តាធិការ ឬត្រូវតែទីប្រឹក្សាច្បាប់ដែលមានសមត្ថភាពខ្ពស់(មាត្រា២១)។ តុលាការមានចំនួនចៅក្រមស្មើនឹងចំនួនគូភាគីកិច្ចសន្យាជាន់ខ្ពស់បំផុត(៤៧)នៃអនុសញ្ញា(មាត្រា២០)។ ចៅក្រមត្រូវបានជ្រើសតាំងដោយមហាសន្និបាតសភា តាមរយៈបញ្ជីមួយដែលមានសមាជិកបីនាក់ដែលត្រូវបានបង្ហាញដោយរដ្ឋនីមួយៗ។ អាណត្តិរបស់ចៅក្រមមានរយៈពេល៦ឆ្នាំ និងអាចត្រូវបានតែងតាំងសាជាថ្មី។ ចំពោះអាណត្តិដែលមានរយៈពេល៩ឆ្នាំ មិនអាចត្រូវបន្តជាថ្មីទេ ហើយមានការកំណត់អាយុត្រឹម៧០ឆ្នាំ។*

**២.១.៧- CJCE**

*តុលាការ CJCE មានសមាសភាពជាចៅក្រមម្នាក់មកពីរដ្ឋសមាជិកនីមួយៗ ហើយចៅក្រម២៧នាក់ត្រូវបានតែងតាំងដោយកិច្ចព្រមព្រៀងរួមមួយរវាងរដ្ឋាភិបាល សម្រាប់រយៈពេលប្រាំមួយឆ្នាំដែលអាចបន្តជាថ្មីបាន។ មិនមានការកំណត់អាយុនោះឡើយ។ នៅក្នុងតុលាការនោះគេឃើញមានអតីតមេធាវី ចៅក្រម សាស្ត្រាចារ្យច្បាប់ ឬសមាជិកក្រុមប្រឹក្សារដ្ឋ សម្រាប់ប្រទេសបារាំង។*

## ២.២- ឯករាជ្យភាពរបស់ចៅក្រម

### ២.២.១- CIJ – TIDM

*ចៅក្រមសុទ្ធតែមិនអាចត្រូវដកហូតងារបាន មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលផ្តល់ជូនដោយអ្នកដឹកនាំការទូត។ ទីកន្លែងសម្រាប់ធ្វើសេចក្តីសម្រេចរបស់ TIDM គឺនៅសភានៃរដ្ឋភាគីដែលគ្រប់គ្រង TIDM ចំណែកឯ CIJ គឺអង្គការសហប្រជាជាតិ។*

*សមាជិករបស់តុលាការគឺជា«ចៅក្រម»។ ពួកគេមិនតំណាងឱ្យរដ្ឋកំណើតរបស់ពួកគេ និងមិនទទួលការណែនាំពីស្ថាប័ននានារបស់អង្គការសហប្រជាជាតិដែរ។ ដូច្នេះ ចៅក្រមទាំងនោះអាចមានរួមទាំងចៅក្រមចំពោះកិច្ចផងដែរ និងអាចសម្រេចសេចក្តីប្រឆាំងនឹងរដ្ឋនៃសញ្ជាតិដើមរបស់ពួកគេ ឬដែលជាប្រភពនៃការតែងតាំងរបស់ពួកគេ។ គឺចៅក្រមចំពោះកិច្ច Suzanne Bastid។*

*គោលការណ៍មិនអាចដកហូតងារបានមានចែងនៅក្នុងលក្ខន្តិកៈ។ ប៉ុន្តែ ចៅក្រមអាចត្រូវដកហូតពីមុខងារដោយស្ថាប័នដែលតែងតាំងពួកគេ(អង្គមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខ)។ មានតែតុលាការទេដែលត្រូវបានអនុញ្ញាតឱ្យធ្វើការវាយតម្លៃថា ចៅក្រមណាម្នាក់លែង«ឆ្លើយតបទៅនឹងលក្ខខណ្ឌដែលតម្រូវ» ដោយសេចក្តីសម្រេចជាឯកច្ឆន្ទ(មាត្រា១៨នៃលក្ខន្តិកៈ)។ នៅក្នុងមុខតំណែងរបស់ពួកគេ ចៅក្រមមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិការទូត(មាត្រា១៩នៃលក្ខន្តិកៈ)។*

*មាត្រា១៦នៃលក្ខន្តិកៈចែងពីវិសមិតភាព ៖ មុខងារសាធារណៈ ឬមុខងាររដ្ឋបាល ការកាន់កាប់មុខងារវិជ្ជាជីវៈក្រៅពីមុខងារជាសមាជិករបស់តុលាការ។ មាត្រា១៧ច្រានចោលយ៉ាងច្បាស់ក្រឡែតនូវការបំពេញមុខងារជាភ្នាក់ងារ ទីប្រឹក្សា ឬមេធាវី។ ចៅក្រមអាចជាសមាជិកនៃគណៈកម្មការស៊ើបអង្កេតមួយ ឬគណៈកម្មការប្រភេទជាយុត្តាធិការមួយ។ ឧទាហរណ៍ ៖ ចៅក្រម Rosalyn Higgins នៅក្នុងរឿងក្តី Lockerbie គឺប្រធានជាអ្នកវិនិច្ឆ័យសេចក្តី។*

### ២.២.២- អនុស្សរណៈនៃការយោគយល់គ្នាដែលគ្រប់គ្រងដំណោះស្រាយវិវាទរបស់ WTO

*អនុស្សរណៈនេះរួមមានកាតព្វកិច្ចស្តីពីឥរិយាបថមួយចំនួន ចំពោះកាទទួលខុសត្រូវរបស់បុគ្គលដែលត្រូវបានអំពាវនាវឱ្យចូលរួមដោះស្រាយវិវាទ កាតព្វកិច្ចរក្សាការសម្ងាត់ពាក់ព័ន្ធនឹងវត្តមាន និងការពិភាក្សាគ្នាមុននឹងចេញសេចក្តីសម្រេចឯករាជ្យភាព និងអព្យាក្រឹតភាព។*

*មិនមានគោលការណ៍ច្រានចោលជនជាតិណាទេ(មាត្រា១៧.៣នៃអនុស្សរណៈ)។ មានវិធានឥរិយាបថពាក់ព័ន្ធនឹងអនុស្សរណៈដែលនឹងត្រូវបំពេញបន្ថែមលើអនុស្សរណៈនេះ។*

*វិធានទាំងនេះពាក់ព័ន្ធនឹងបុគ្គលទាំងអស់ដែលត្រូវបានអំពាវនាវឱ្យចូលរួមក្នុងការដោះស្រាយជម្លោះ និងបញ្ជាក់ពីបែបបទនៃការគោរពកាតព្វកិច្ចដែលមានចែងនៅក្នុងអនុស្សរណៈនេះ។*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សមាជិករបស់អគ្គលេខាធិការដ្ឋាន(GS)ត្រូវបានជ្រើសរើសដោយរដ្ឋនានា។ ដូច្នេះវាគឺជាការជំរុញមួយដែលបំពេញចិត្តដល់រដ្ឋ។ នេះគឺជា«កង់ច្រវាក់ទន់ខ្សោយ» បើនិយាយអំពីឯករាជ្យភាព និងភាពមិនលម្អៀងនៃក្រុមការងារពិសេស។ មានសំណើឱ្យបង្កើតអង្គអចិន្ត្រៃយ៍មួយដែលមានអ្នកជំនាញការចន្លោះពី១៨ទៅ២៤នាក់ ដើម្បីបង្កើតGS។*

### ២.២.៣- យុត្តាធិការព្រហ្មទណ្ឌ

*តុលាការចំពោះកិច្ចទទួលបាននូវការធានាអព្យាក្រឹតភាព និងឯករាជ្យភាព។ មាត្រា១៣នៃលក្ខន្តិកៈរបស់ TPIY (១២នៃលក្ខន្តិកៈរបស់ TPIR)។ ចៅក្រមត្រូវបានជ្រើសតាំងដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅលើបញ្ជីដែលបង្ហាញដោយក្រុមប្រឹក្សាសន្តិសុខ។ ឯករាជ្យភាពរបស់រដ្ឋអាជ្ញាត្រូវតម្រូវឱ្យមាន និងត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសន្តិសុខ តាមសំណើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ។*

### ២.២.៤- CPI

*ឯករាជ្យភាពត្រូវបានចែងនៅក្នុងមាត្រា៤០នៃលក្ខន្តិកៈរបស់ CPI ៖ «ចៅក្រមបំពេញមុខងារ ដោយឯករាជ្យ»។ ពួកគេមានវិសមិតភាពជាមួយមុខងារផ្នែកយុត្តាធិការ ឬអាចធ្វើឱ្យមានការសង្ស័យពីភាពឯករាជ្យរបស់ពួកគេ។ មាត្រា៤១ចែងអំពីនីតិវិធីនៃការដោះបន្ទុក និងការបដិសេធចៅក្រម(អំណាចស្នើសុំដកខ្លួនពីតុលាការ)។ មុខងាររបស់ចៅក្រមត្រូវបានការពារ និងទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ។*

### ២.២.៥- CEDH – CJCE

*តុលាការទាំងនេះមានការធានាដូចគ្នាអំពីអព្យាក្រឹតភាព និងឯករាជ្យភាពជាសកលសម្រាប់ចៅក្រម។ ចៅក្រមមិនអាចអនុវត្តសកម្មភាពណាមួយដែលមានវិសមិតភាពជាមួយកាតព្វកិច្ចនៃឯករាជ្យភាពឡើយ។ ពួកគេមិនអាចត្រូវដកហូតមុខងារ និងទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលភ្ជាប់ជាមួយនឹងស្ថាប័នដើមរបស់ពួកគេ។*

## ២.៣- ការជ្រើសតាំង និងការតែងតាំងចៅក្រម

### ២.៣.១- តុលាការយុត្តិធម៌អន្តរជាតិ

*តុលាការមានចៅក្រមពីរប្រភេទ ៖ ចៅក្រមតែងតាំង និងចៅក្រមចំពោះកិច្ច។ ចៅក្រមប្រភេទទីមួយសំខាន់ជាងគេ - មានចៅក្រមដប់ប្រាំរូប។ បែបបទនៃការជ្រើសតាំងគឺស្មុគស្មាញមកពី*

*បែបបទនៃការជ្រើសតាំងចៅក្រមរបស់ CPJI។ យន្តការនៃការបោះឆ្នោតពីរលើកធ្វើឱ្យមានអន្តរាគមន៍ពីអង្គមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខក្នុងពេលជាមួយគ្នា និងដោយឯករាជ្យ។ ដើម្បីអាចត្រូវបានជ្រើសតាំង រាល់បេក្ខជនត្រូវតែទទួលបានការគាំទ្រភាគច្រើនដាច់ខាតនៅក្នុងស្ថាប័ននីមួយៗ។*

*អាណត្តិមានរយៈពេល៩ឆ្នាំ ប៉ុន្តែការបន្តអាណត្តិជាថ្មីត្រូវធ្វើឡើងទៅតាមការផ្លាស់គ្នាទៅវិញទៅមកចំនួនមួយភាគបី រៀងរាល់បីឆ្នាំម្តង។ នេះគឺដើម្បីធានានិរន្តរភាពក្នុងគោលដៅបញ្ចៀសការផ្លាស់ប្តូរយ៉ាងគំហុកនៅក្នុងសមាសភាពរបស់ស្ថាប័ន។ ចៅក្រមមិនតំណាងឱ្យរដ្ឋដែលចៅក្រមមានសញ្ជាតិឡើយ។*

*នៅក្នុងសម្មតិកម្មដែលរដ្ឋភាគីជម្លោះមួយមានចៅក្រមដែលមានសញ្ជាតិដូចខ្លួន ខណៈដែលភាគីមួយ ឬគូភាគីផ្សេងទៀតមិនមានចៅក្រមដែលមានសញ្ជាតិខ្លួន គេត្រូវរកដំណោះស្រាយមួយដែលទាមទារឱ្យមានការតែងតាំងចៅក្រមចំពោះកិច្ច ជាជាងការព្យាយាមដកចៅក្រមនេះចេញ ពោលគឺជាការតែងតាំងចៅក្រមម្នាក់ដែលមានបេសកកម្មកំណត់ ចំពោះជម្លោះជាក់លាក់មួយ និងចំពោះរឿងក្តីដែលកើតឡើង។ គេត្រូវដកចៅក្រមម្នាក់ចេញពីរឿងក្តី ដោយដាក់ជំនួសដោយចៅក្រមចំពោះកិច្ច យោងតាមមាត្រា១៧ ឬ២៤នៃលក្ខន្តិកៈដែលនាំឱ្យចៅក្រមនោះអាចដកខ្លួនចេញដោយខ្លួនឯង។*

### ២.៣.២- TIDM

*ការបោះឆ្នោតជ្រើសតាំងអនុញ្ញាតឱ្យតែងតាំងចៅក្រមរបស់ TIMD។ ចៅក្រមចំនួន២១នាក់ត្រូវបានតែងតាំងដោយសន្និបាតរបស់រដ្ឋភាគីនៃអនុសញ្ញា។ រដ្ឋភាគីនីមួយៗអាចតែងតាំងបេក្ខជនពីររូប។ TIDM មិនអាចមានចៅក្រមពីររូបដែលមានសញ្ជាតិដូចគ្នានោះឡើយ។ ការរឹតត្បិត ៖ សមាជិក៣រូប សម្រាប់ក្រុមភូមិសាស្ត្រនីមួយៗដែលត្រូវកំណត់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ AGNU (អាហ្វ្រិក អាស៊ី អឺរ៉ុបខាងខាងកើត អាមេរិកឡាទីន និងការ៉ាអ៊ីប អឺរ៉ុបខាងលិច និងរដ្ឋដទៃទៀត)។ សមាជិកនៃតុលាការនេះត្រូវបានជ្រើសតាំង សម្រាប់រយៈពេល ៩ឆ្នាំ ហើយអាចជ្រើសតាំងសាជាថ្មីបាន។*

### ២.៣.៣- អនុស្សរណៈរបស់ WTO

*ប្រព័ន្ធនេះមានភាពខុសពីគេ និងធ្វើឱ្យមានមន្ទិលសង្ស័យអំពីលក្ខណៈយុត្តាធិការនៃស្ថាប័ននេះ។ ផ្ទុយមកវិញ មិនមានឆន្ទៈបង្កើតឱ្យមានប្រព័ន្ធតំណាងនៃប្រព័ន្ធគតិយុត្តសំខាន់ៗនោះទេ ប៉ុន្តែមានការតម្រូវឱ្យការបែងចែកភូមិសាស្ត្រ សម្រាប់សមាជិកទាំងអស់នៃស្ថាប័នបណ្តឹងឧទ្ធរណ៍*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យោងតាមមាត្រា១៧:៣នៃអនុស្សរណៈយោគយល់គ្នា។ សមាសភាពរបស់ស្ថាប័នបណ្តឹងឧទ្ធរណ៍ជាតំណាងសមាសភាពរបស់ WTO។ មានប្រព័ន្ធចំនួន៥ គឺប្រព័ន្ធរ៉ូម៉ាំង-អាល្លឺម៉ង់ (Romano-germanique) ប្រព័ន្ធខុម៉ិនឡ (Common law) ប្រព័ន្ធចិន ឥណ្ឌា និងប្រព័ន្ធអ៊ីស្លាម។

មានដំណាក់កាលដំបូង និងដំណាក់កាលឧទ្ធរណ៍។

សម្រាប់ដំណាក់កាលដំបូង វាគឺជា«ការផ្សះផ្សា»ដែលសំអាងលើការតែងតាំងអ្នកជំនាញការសម្រាប់ក្រុមពិសេសនីមួយៗ ៖ អ្នកជំនាញការបីនាក់( លើកលែងតែភាគីសម្រេចជ្រើសរើសអ្នកជំនាញការ៥នាក់)។ អ្នកជំនាញការមិនត្រូវមានសញ្ជាតិរបស់គូភាគីនៃជម្លោះឡើយ។ មាន«អានុភាពនៃការបណ្តេញចេញ» សម្រាប់សហភាពអឺរ៉ុប ព្រោះថា សញ្ជាតិចំនួន២៧ត្រូវបានបដិសេធចេញ( មាត្រា៨-៣នៃអនុស្សរណៈ)។ មានបញ្ជីអ្នកជំនាញការអចិន្ត្រៃយ៍ដូចករណី CPA ដែរ។ ប៉ុន្តែ ក៏មានរួចមកហើយនូវបញ្ជីនៃអ្នកជំនាញការដែលស្នើឡើង ដោយអគ្គលេខាធិការដ្ឋាននៃអង្គការ WTO ហើយរដ្ឋអាចព្រមព្រៀងគ្នាជ្រើសតាំងអ្នកជំនាញការផ្សេងៗទៀតបាន។ ប្រសិនបើរដ្ឋមិនអាចព្រមព្រៀងគ្នាបានទេ អគ្គនាយកនឹងតែងតាំងអ្នកជំនាញការ។

សម្រាប់ស្ថាប័នឧទ្ធរណ៍ ស្ថាប័នអចិន្ត្រៃយ៍ គឺអង្គភាព ORD ដែលបង្កើត និងចាត់តាំងសមាជិកស្ថាប័នឧទ្ធរណ៍ ឈរលើមូលដ្ឋាននៃសំណើរួមរបស់អគ្គនាយករបស់ WTO ប្រធានអង្គភាពដោះស្រាយវិវាទ ប្រធានអគ្គក្រុមប្រឹក្សា និងប្រធានក្រុមប្រឹក្សាតាមវិស័យបីផ្សេងទៀត (GATT, GATS, TRIPS)។

ពួកគេត្រូវបានតែងតាំងសម្រាប់អាណត្តិ៤ឆ្នាំ គឺមិនមែនជ្រើសតាំងទេ និងមានចំនួន៧នាក់។ មានគោលការណ៍នៃភាពជាតំណាងរបស់ WTO។ សមាជិកទាំង៧រូប មានប្រភពចេញពីសហភាពអឺរ៉ុប(EU) ប្រទេសនូវែលហ្សេឡង់ អាល្លឺម៉ង់ អេហ្ស៊ីប ហ្វីលីពីន អ៊ុយរ៉ាហ្គាយ និងជប៉ុន។

## ២.៣.៤- យុត្តាធិការព្រហ្មទណ្ឌចំពោះកិច្ច

សម្រាប់ TPIY និង TPIR ចៅក្រម( ១៦នាក់នៅក្នុង TPIY)ត្រូវបានតែងតាំងដោយមហាសន្និបាតអង្គការសហប្រជាជាតិ សម្រាប់រយៈពេលមួយអាណត្តិដែលមានរយៈពេល៤ឆ្នាំ ហើយអាចជ្រើសតាំងសាជាថ្មីបាន។ សម្រាប់ចៅក្រម ad litem ៩រូប ពួកគេចូលរួមជាមួយក្រុមចៅក្រម២៧នាក់ដែលត្រូវបានតែងតាំងដោយមហាសន្និបាត សម្រាប់មួយអាណត្តិដែលមានរយៈពេល៤ឆ្នាំ ហើយមិនអាចជ្រើសតាំងជាថ្មីបានទេ។ មានការគោរពគោលការណ៍នៃការបែងចែកភូមិសាស្ត្រ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ២.៣.៥- តុលាការឧក្រិដ្ឋកម្មអន្តរជាតិ CPI

*គឺសភារបស់រដ្ឋភាគីនៃលក្ខន្តិកៈដែលតែងតាំងចៅក្រមចំនួន១៨នាក់របស់ CPI។ អាណត្តិមានរយៈពេល៩ឆ្នាំ និងមិនអាចបន្តបាន។ តុលាការនេះមានប្រធានមួយរូប អង្គជំនុំជម្រះកិច្ចការបឋមមួយ( ជាផ្នែកថ្មីស្រឡាងបង្កស់ដែលជាលទ្ធផលនៃការទាមទារ(lobby)របស់បារាំង ដើម្បីទប់ទល់នឹងលំនឹងប្រព័ន្ធព្រហ្មទណ្ឌនៃប្រព័ន្ធច្បាប់ Common Law។ មានពេលវេលាក្នុងការស៊ើបអង្កេត លំដាប់លំដោយនៃបណ្តឹង - ដែលជារឿងសម្ងាត់ និងពេលវេលាសម្រាប់សវនាការ) អង្គជំនុំជម្រះដំបូងមួយ និងអង្គជំនុំជម្រះឧទ្ធរណ៍មួយ។*

*រដ្ឋអាជ្ញា និងរដ្ឋអាជ្ញារងក៏នឹងត្រូវតែងតាំងដោយសភានៃរដ្ឋភាគី តាមសំឡេងភាគច្រើនដាច់ខាត និងដោយការបោះឆ្នោតដោយសម្ងាត់( កថាខណ្ឌទី៤ មាត្រា៤នៃលក្ខន្តិកៈ)។ មុខងាររបស់រដ្ឋអាជ្ញាតម្រូវឱ្យមានឯករាជ្យភាពជាចាំបាច់។ រដ្ឋអាជ្ញាគឺជាមុខងារឯករាជ្យនៃតុលាការ ពោលគឺចៅក្រមជាអ្នកសម្រេចសេចក្តី។ ជនជាតិអាហ្សង់ទីន លោក Ocampo ត្រូវបានតែងតាំងក្នុងតួនាទីនេះ។ លោកត្រូវបានគេទទួលស្គាល់ ដោយសារគោលជំហរវិជ្ជមានរបស់លោក ចំពោះនិទ្ទណ្ឌភាពនៃឧក្រិដ្ឋជននៅប្រទេសអាហ្សង់ទីន។*

### ២.៣.៦- CEDH –CJCE

*ចំនួនចៅក្រមស្មើនឹងចំនួនរដ្ឋ ក៏ប៉ុន្តែមិនមានការរឹតត្បិតផ្នែកសញ្ជាតិនោះទេ។ ចៅក្រមត្រូវបានជ្រើសតាំងសម្រាប់រយៈពេល៩ឆ្នាំ និងមិនអាចបន្តបាន ដោយសន្និបាតសភានៃក្រុមប្រឹក្សាអឺរ៉ុប( ពិធីសារ១៤)។ CJCE គឺជាប្រព័ន្ធដែលមានលក្ខណៈបង្វិលបង្វិ។*

*សម្រាប់ CJCE នេះជាប្រព័ន្ធដែលកាន់តែមានលក្ខណៈបង្វិលបង្វិ ហើយចៅក្រមមួយរូបត្រូវតែងតាំងដោយរដ្ឋនីមួយៗតាមរយៈកិច្ចព្រមព្រៀងរួមដោយរដ្ឋ សម្រាប់អាណត្តិ៩ឆ្នាំដែលអាចបន្តបាន។*

## ២.៤- រចនាសម្ព័ន្ធរបស់យុត្តាធិការអន្តរជាតិ

### ២.៤.១- CIJ- TIDM

*តុលាការគឺជាអង្គភាពមួយដែលមានចៅក្រមចំនួន១៥នាក់ មានទីស្នាក់ការនៅទីក្រុងឡាអេនៅវិមានសន្តិភាព។ វាគឺជាស្ថាប័នមួយដែលអនុវត្តកេតនភណ្ឌរបស់ខ្លួនជាធម្មតានៅក្នុងអង្គប្រជុំពេញអង្គ( មាត្រា២៣ និង២៥នៃលក្ខន្តិកៈ)។ កូរ៉ុមត្រូវមានចៅក្រម៩លើ១៥នាក់ មិនរាប់បញ្ចូលចៅក្រមចំពោះកិច្ចទេ។*

*កូរ៉ុមនៃអង្គប្រជុំពេញអង្គសម្រាប់ TIDM គឺដូចគ្នា ៖ ចៅក្រម១១នាក់ក្នុងពេលដែលបង្កើត*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អង្គជំនុំជម្រះពេញអង្គ ត្រូវមានចៅក្រមចំនួន២១នាក់។

តុលាការអាចសម្រេចបង្កើតអង្គជំនុំជម្រះនានាបាន។ កថាខណ្ឌទី១ មាត្រា២៦ ចែងពីការបង្កើតអង្គជំនុំជម្រះដែលមានចៅក្រមចំនួន៣នាក់យ៉ាងតិច ដើម្បីដោះស្រាយរឿងក្ដីទៅតាមប្រភេទ។ វាគឺជារឿងក្ដីធម្មតា និងដែលអាចជារឿងដែលកើតម្ដងហើយម្ដងទៀត។ ឧទាហរណ៍នៃរឿងក្ដីស្ដីពីការងារ ឬរឿងក្ដីស្ដីពីការឆ្លងកាត់ ឬគមនាគមន៍ត្រូវបានលើកឡើង។ ការបង្កើតអង្គជំនុំជម្រះប្រភេទនេះធ្លាប់បានចាត់ទុកថា ជារឿងសាមញ្ញនៃយុត្តាធិការដែលមិនត្រូវបានបង្កើតឡើង។

ទើបតែនៅក្នុងឆ្នាំ១៩៩៣ប៉ុណ្ណោះដែលតុលាការបានបង្កើតអង្គជំនុំជម្រះជាលើកទីមួយបំផុត។ តុលាការនេះបានសម្រេចបង្កើតអង្គជំនុំជម្រះពិសេសទទួលបន្ទុកផ្នែកបរិស្ថាន។ តុលាការចង់បង្ហាញពីផលប្រយោជន៍របស់តុលាការ និងរំឭកដល់រដ្ឋនានាថា តុលាការបើកចំហសម្រាប់ជម្លោះ«បែបទំនើប»។ អង្គជំនុំជម្រះនេះមានចៅក្រមចំនួនប្រាំពីររូប និងត្រូវបានផ្លាស់ប្ដូរយ៉ាងទៀងទាត់ និងមិនបានទទួលបណ្ដឹងណាមួយឡើយ។ សំណុំរឿងដែលអាចត្រូវបានដាក់ជូនដោយផ្ទាល់ជាងគេ គឺសំណុំរឿង Gabcikovo - Nagymaros ដែលត្រូវបានវិនិច្ឆ័យដោយក្រុមប្រឹក្សាពេញអង្គ។

យោងតាមមាត្រា២៩នៃលក្ខន្តិកៈ អង្គជំនុំជម្រះដែលមានចៅក្រមចំនួន៥នាក់ដែលតម្រូវឱ្យវិនិច្ឆ័យតាមនីតិវិធីសង្ខេបដែលតុលាការត្រូវតែបង្កើតជារៀងរាល់ឆ្នាំ ដើម្បីអាចឱ្យមាន«ការចាត់ការរហ័សទៅលើរឿងក្ដីនានា»។

រូបមន្តដែលមានភាពទន់ភ្លន់ជាងគេត្រូវបានចែងដោយកថាខណ្ឌទី២ មាត្រា២៦នៃលក្ខន្តិកៈដែលអនុញ្ញាតឱ្យបង្កើតអង្គជំនុំជម្រះមួយសម្រាប់រឿងក្ដីជាក់លាក់មួយ។ នៅពេលដែលសំណុំរឿងជាក់លាក់នេះត្រូវបានបញ្ចប់ តុលាការនេះត្រូវរំលាយខ្លួនវិញ។

ការប្រើប្រាស់ទម្រង់រឹតត្បិតរបស់សាលក្រមត្រូវតម្រូវទៅតាមការចង់បានរបស់គូភាគី ហើយចំនួនចៅក្រមដែលជាសមាសភាពអង្គជំនុំជម្រះនេះ ត្រូវកំណត់ដោយការព្រមព្រៀងជាមួយគូភាគីទាំងអស់(ក្នុងការអនុវត្ត ចំនួនដែលគេជ្រើសរើស ជានិច្ចកាល គឺចៅក្រមចំនួន៥នាក់)។ គេអាចលើកឡើងពីរឿងក្ដីដែលត្រូវបានចាត់ការទៅតាមទម្រង់នេះបានដូចខាងក្រោម ៖

- ការរំលាយព្រំដែនសមុទ្រ នៅក្នុងតំបន់ Golfe du Maine រវាងសហរដ្ឋអាមេរិក និងប្រទេសកាណាដា(សាលក្រមចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៨៤)។ នេះគឺជាអង្គជំនុំជម្រះដែលមានចៅក្រមចំនួន៥នាក់។

- រឿងក្ដី Elettronica Silcula S.p.A (ELSI) រវាងសហរដ្ឋអាមេរិក និងប្រទេសអ៊ីតាលី (សាលក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩)។

ចំពោះ TIDM ប្រព័ន្ធនៃអង្គជំនុំជម្រះរបស់ TIDM មានលក្ខណៈស្មុគស្មាញ។ តុលាការមានសមាសភាពដូចខាងក្រោម ៖

- អង្គជំនុំជម្រះពិសេសដែលត្រូវបានបង្កើតឡើងដោយការផ្តួចផ្តើមរបស់តុលាការ ឬតាមសំណើរបស់គូភាគី។ ដូច្នេះអង្គជំនុំជម្រះចំនួនបីត្រូវបានបង្កើតឡើង ៖

• អង្គជំនុំជម្រះនីតិវិធីសង្ខេបមួយ( មាត្រា១៥.៣ និង១៥.៤នៃលក្ខន្តិកៈ) ដែលមានចៅក្រមចំនួន៥រូប(រួមទាំងប្រធាន និងអនុប្រធាន) និងដែលវិនិច្ឆ័យដោយសង្ខេប ទៅតាមការស្នើសុំរបស់គូភាគី។

• អង្គជំនុំជម្រះសម្រាប់ដោះស្រាយជម្លោះពាក់ព័ន្ធទៅនឹងការនេសាទ( មាត្រា១៥.១នៃលក្ខន្តិកៈ)ដែលមានសមាជិកចំនួន៧រូប។

• អង្គជំនុំជម្រះមួយសម្រាប់ដោះស្រាយជម្លោះពាក់ព័ន្ធទៅនឹងមជ្ឈដ្ឋានសមុទ្រ( មាត្រា១៥.១នៃលក្ខន្តិកៈ)ស្តីពីការការពារ និងអភិរក្សមជ្ឈដ្ឋានសមុទ្រដែលមានចៅក្រមចំនួន៧រូប។

- មានអង្គជំនុំជម្រះដែលត្រូវបានកំណត់ដោយមាត្រា១៥:២ ដើម្បីដោះស្រាយជម្លោះជាក់លាក់នានា( ដូច CIJ ដែរ)។ សមាសភាពនៃអង្គជំនុំជម្រះទាំងនេះត្រូវកំណត់ដោយតុលាការដោយមានការព្រមព្រៀងជាមួយគូភាគី។ នេះគឺជាអង្គជំនុំជម្រះមួយដែលត្រូវបានបង្កើតឡើងនៅក្នុងសំណុំរឿងទាក់ទងទៅនឹងការអភិរក្ស និងការធ្វើអាជីវកម្មប្រកបដោយនិរន្តរភាពលើ stock espadon នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកភាគអាគ្នេយ៍( ប្រទេស Chili/CE)។ អង្គជំនុំជម្រះនេះមានចៅក្រម៥រូបដែលម្នាក់ជាចៅក្រមចំពោះកិច្ច ប៉ុន្តែអង្គជំនុំជម្រះនេះនៅតែមិនសូវមានដំណើរការ។

- អង្គជំនុំជម្រះពិសេសមួយដែលជាតុលាការឯករាជ្យមួយប្រភេទនៅក្នុង TIDM ៖ គឺអង្គជំនុំជម្រះសម្រាប់ដោះស្រាយជម្លោះពាក់ព័ន្ធនឹងបាតសមុទ្រ( មាត្រា១៤នៃលក្ខន្តិកៈ និងផ្នែកទី XIនៃអនុសញ្ញា)។ អង្គជំនុំជម្រះនេះទទួលបន្ទុកបញ្ហានានាដែលប៉ះពាល់នឹងបាតសមុទ្រនៃតំបន់អន្តរជាតិ និងមានចៅក្រម១១នាក់( ចំនួនកូរ៉ុមគឺចៅក្រម៧នាក់)។

## ២.៤.២- អនុស្សរណៈដែលគ្រប់គ្រងដំណោះស្រាយជម្លោះរបស់ WTO

សមាសភាពសម្រាប់សំណុំរឿងនីមួយៗគឺត្រូវមានសមាជិក៣ក្នុងចំណោម៧នាក់។ ប៉ុន្តែស្ថាប័នបណ្តឹងឧទ្ធរណ៍ប្រជុំគ្នាជាទៀងទាត់ក្នុងសម័យប្រជុំ«ពេញអង្គ»ដែលមានសមាជិក៧នាក់ដើម្បីស្វែងរកចេតនា និងដើម្បីធ្វើសង្គតិភាពយុត្តិសាស្ត្រ។

## ២.៤.៣- យុត្តាធិការព្រហ្មទណ្ឌចំពោះកិច្ច

ប្រព័ន្ធអង្គជំនុំជម្រះ TPIY និង TPIR មិនអាចប្រៀបធៀបជាមួយ CIJ បានឡើយ។ នៅ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំពោះមុខ CIJ និង TIDM អង្គជំនុំជម្រះត្រូវបានគ្រោងទុកថាជាក្រុមពិសេសដែលអាចជួយសម្រាលយុត្តាធិការបាន។ សម្រាប់យុត្តាធិការព្រហ្មទណ្ឌចំពោះកិច្ច អង្គជំនុំជម្រះទាំងនោះបង្កើតឱ្យមាននូវរចនាសម្ព័ន្ធជាមូលដ្ឋាននៅក្នុងយុត្តាធិការព្រហ្មទណ្ឌ។

សម្រាប់ TPIY អង្គជំនុំជម្រះមានសមាសភាពជាចៅក្រមអចិន្ត្រៃយ៍ចំនួន១៦រូបដែលត្រូវបែងចែកជាអង្គជំនុំជម្រះដំបូងចំនួន៣ និងអង្គជំនុំជម្រះឧទ្ធរណ៍១។ អង្គជំនុំជម្រះជាន់ដំបូងនីមួយៗមានចៅក្រមអចិន្ត្រៃយ៍ចំនួនបីរូប និងមានចៅក្រម ad litem យ៉ាងច្រើនបំផុតចំនួន៦រូបដែលវិនិច្ឆ័យនៅក្នុងអង្គជំនុំជម្រះចម្រុះ(ចៅក្រមអចិន្ត្រៃយ៍ម្នាក់ និង ad litem ២នាក់ ឬចៅក្រមអចិន្ត្រៃយ៍ពីរនាក់ និងចៅក្រម ad litem ម្នាក់)។

អង្គជំនុំជម្រះឧទ្ធរណ៍ធ្លាប់ជាអង្គជំនុំជម្រះរួមរវាងតុលាការពីរគឺ TPIY និង TPIR។ អង្គជំនុំជម្រះនេះមានចៅក្រមអចិន្ត្រៃយ៍ចំនួន៧រូប ៖ ចៅក្រម៥រូបមកពី TPIY និងពីរនាក់មកពី TPIR។ ក៏ប៉ុន្តែ រឿងក្តីឧទ្ធរណ៍នីមួយៗត្រូវវិនិច្ឆ័យសេចក្តីដោយចៅក្រមតែ៥រូបប៉ុណ្ណោះ។

ការិយាល័យរដ្ឋអាជ្ញាមានបេសកកម្មស៊ើបអង្កេតលើសំណុំរឿង បង្កើតកិច្ចចោទប្រកាន់ និងអនុវត្តបណ្តឹង។ រដ្ឋអាជ្ញាទីមួយគឺ Goldstone បន្ទាប់មកគឺស្ត្រីជនជាតិកាណាដា គឺលោកស្រី Louise Arbour បន្ទាប់មកទៀតស្ត្រីជនជាតិស្វីស លោកស្រី Carla Del Ponte និងចុងបញ្ចប់ជនជាតិប៊ែលហ្ស៊ិក លោក Serge Brammertz ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨មក។

រដ្ឋអាជ្ញាត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសន្តិសុខ។ ចាប់ពីពេលនេះតទៅ តុលាការនីមួយៗមានរដ្ឋអាជ្ញាផ្ទាល់ខ្លួន គឺចាប់ពីខែកញ្ញា ឆ្នាំ២០០៣មក(សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ) ៖ លោក Serge Brammertz សម្រាប់ TPIY ហើយលោក Haasan Boubaka Jalow សម្រាប់ TPIR (ដែលត្រូវបានតែងតាំងជាថ្មីនៅក្នុងមុខងាររបស់លោក នៅខែកញ្ញា ឆ្នាំ២០០៧)។

### ២.៤.៤- CPI

រចនាសម្ព័ន្ធរបស់តុលាការមានលក្ខណៈថ្មីបំផុត និងមានចៅក្រមចំនួន១៨រូបដែលត្រូវបានជ្រើសតាំងដោយសន្និបាតនៃរដ្ឋភាគី សម្រាប់រយៈពេលប្រាំបួនឆ្នាំដែលមិនអាចបន្តជាថ្មីបាន (មាត្រា៣៦) ហើយមានទីស្នាក់ការនៅទីក្រុងឡាអេ។ ប៉ុន្តែ តុលាការនេះអាចតាំងទីស្នាក់ការនៅកន្លែងផ្សេងទៀតបាន(មាត្រា៣)។ តុលាការនេះរួមមាន ៖ (i) ទីស្នាក់ការប្រធានមួយ (ii) ផ្នែកបឋមមួយ(ដែលនឹងអនុញ្ញាតឱ្យធានានូវដំណាក់កាលស៊ើបអង្កេត។ សំណើរបស់បារាំងនេះមានគោលបំណងធានាតុល្យភាពជាមួយប្រព័ន្ធច្បាប់ anglo-saxon ជាពិសេសពាក់ព័ន្ធនឹងតួនាទីដ៏ខ្លាំងលើសលុបរបស់រដ្ឋអាជ្ញានៅក្នុងប្រព័ន្ធនេះ) ផ្នែកដំបូង និង(iii) ផ្នែកឧទ្ធរណ៍មួយ (មាត្រា៣៤)។ ការិយាល័យរដ្ឋអាជ្ញាព្រមទាំងក្រឡាបញ្ជីមកបំពេញស្ថាប័នទាំងនេះ។ នេះគឺជា

ស្ថាប័នអចិន្ត្រៃយ៍មួយ។

ក្នុងពេលដែលតុលាការបើកសវនាការពេញអង្គត្រូវមានសមាជិកពីរភាគបីនៃចៅក្រម ពោលគឺត្រូវមានចៅក្រម១២រូប( លើ១៨រូប)។

**២.៤.៥- CEDH – CJCE**

ប្រឈមមុខទៅនឹងការកើនឡើងចំនួនចៅក្រម នៅក្នុងយុត្តាធិការអឺរ៉ុប ចៅក្រមកម្របើកសវនាការពេញអង្គណាស់។ មានក្រុមប្រឹក្សាអន្តរការី និងដែលមានឯកសិទ្ធិរឹតត្បិត ប៉ុន្តែក៏មានផងដែរនូវក្រុមប្រឹក្សាពេញអង្គ។ នេះគឺជាសញ្ញាមួយដែលបង្ហាញថា សមាហរណកម្មមិនទាន់ត្រូវបានបញ្ចប់នៅឡើយ ហើយរចនាសម្ព័ន្ធយុត្តាធិការទាំងនេះស្តែងឡើងតាមរយៈអន្តរពាគមន៍និយមរបស់រដ្ឋនានា។ នេះគឺជាទិកភាពរបស់យុត្តាធិការទាំងនេះរវាងរដ្ឋ និងឯកត្តជន។

CJCE អាចបើកសវនាការពេញអង្គ និងជាអង្គជំនុំជម្រះធំបាន( ចៅក្រម១៣រូប) ឬជាអង្គជំនុំជម្រះចង្អៀតដែលមានចៅក្រម៥ ឬ៣នាក់បាន។ តុលាការនេះបើកកិច្ចប្រជុំជាអង្គជំនុំជម្រះធំក្នុងពេលដែលរដ្ឋ ឬស្ថាប័នណាមួយស្នើសុំសម្រាប់រឿងក្តីស្មុគស្មាញ ឬសំខាន់ៗ។ សំណុំរឿងដទៃទៀតត្រូវពិនិត្យដោយអង្គជំនុំជម្រះដែលមានចៅក្រម៣ ឬ៥នាក់។ តុលាការអាចបើកកិច្ចប្រជុំពេញអង្គ នៅក្នុងករណីពិសេស ដែលមានចែងនៅក្នុងសន្ធិសញ្ញា( ឧទាហរណ៍ ៖ ការលាឈប់ពីតំណែងរបស់ស្នងការអឺរ៉ុប ឬអន្តរការីម្នាក់) ឬដោយសារមានសំណុំរឿងពិសេសមួយ។ ដូច្នេះ កូរ៉ុមនៃសន្និបាតពេញអង្គត្រូវមានចៅក្រមចំនួន១៥រូប។

ជាការកម្រដែល CJCE បើកកិច្ចប្រជុំពេញអង្គ។ តុលាការបើកកិច្ចប្រជុំញឹកញាប់បំផុតជាអង្គជំនុំជម្រះធំដែលមានចៅក្រមចំនួន១៣នាក់( ប្រធានអង្គជំនុំជម្រះដែលមានសមាជិក៣នាក់ត្រូវបានជ្រើសតាំង សម្រាប់រយៈពេល១ឆ្នាំ ចំណែកប្រធានអង្គជំនុំជម្រះដែលមានសមាជិកប្រាំនាក់ ត្រូវជ្រើសតាំងសម្រាប់រយៈពេល៣ឆ្នាំ)។

នៅក្នុង CEDH កិច្ចប្រជុំពេញអង្គរបស់ចៅក្រមមិនត្រូវបានចែងនោះទេ។ គឺជាការប្រជុំរបស់អង្គជំនុំជម្រះធំដែលមានចៅក្រម១៧រូប(រួមទាំងប្រធាន អនុប្រធាន និងប្រធានផ្នែកទាំងពីរ)។ ការបង្កើតរចនាសម្ព័ន្ធមានលក្ខណៈស្មុគស្មាញ និងទាមទារឱ្យមានប្រព័ន្ធអង្គជំនុំជម្រះរឹតត្បិត។

តុលាការត្រូវបែងចែកជាបួនផ្នែក ៖ ពីរផ្នែកត្រូវដឹកនាំដោយអនុប្រធាន ចំណែកឯពីរផ្នែកទៀតត្រូវបានដឹកនាំដោយប្រធានផ្នែក។ នៅក្នុងផ្នែកនីមួយៗមានគណៈកម្មាធិការដែលមានចៅក្រម៣នាក់ដែលត្រូវបានចាត់តាំងសម្រាប់រយៈពេល១២ខែ។ អង្គជំនុំជម្រះទាំងអស់មានសមាជិកចំនួន៧រូប ហើយអង្គជំនុំជម្រះធំមានសមាជិកចំនួន១៧រូប។

# ជំពូក១៥
# យុត្តាធិការជាកាតព្វកិច្ច និងយុត្តាធិការតាមការព្រមព្រៀង

## ផ្នែកទី១
## មូលដ្ឋានគ្រឹះនៃយុត្តាធិការ

*ចំណោទបញ្ហាគឺភាពផ្ទុយគ្នារវាងយុត្តាធិការតាមការព្រមព្រៀង និងយុត្តាធិការជាកាតព្វកិច្ច។ ត្រូវបែងចែករវាងយុត្តាធិការអន្តររដ្ឋ និងយុត្តាធិការផ្សេងទៀត។ ORD គឺជាករណីដ៏គួរឱ្យចាប់អារម្មណ៍នៃយុត្តាធិការអន្តររដ្ឋជាកាតព្វកិច្ច។ ចរិតលក្ខណៈដែលបែងចែកយុត្តាធិការស្ថិតនៅចន្លោះចរិតលក្ខណៈតាមការព្រមព្រៀង ឬមិនព្រមព្រៀងនៃយុត្តាធិការ។*

*សម្រាប់មជ្ឈត្តការ បញ្ហាគឺការទទួលយករបស់បណ្តារដ្ឋដែលជាផ្នែកដ៏សំខាន់មួយនៃការបង្កើតតុលាការមជ្ឈត្តការ។ បណ្តារដ្ឋជាភាគីត្រូវដោះស្រាយបញ្ហារបស់ខ្លួន គឺរដ្ឋត្រូវព្រមព្រៀងគ្នា។*

*សម្រាប់យុត្តាធិការជាកាតព្វកិច្ច ត្រូវមានការទទួលយកយុត្តាធិការ(មានន័យថាទទួលយក «សមត្ថកិច្ច»)។ គឺជាការទទួលយកក្នុងអាទិកាល សម្រាប់ប្រភេទដែលត្រូវបានបញ្ជាក់ច្បាស់លាស់នៃវិវាទជាយថាហេតុ។ សម្រាប់យុត្តាធិការតាមការជ្រើសរើស សមត្ថកិច្ចត្រូវបានព្រមព្រៀងម្តងមួយករណីៗ និងក្រោយការកើតឡើងនូវវិវាទ។*

*តាមច្បាប់ក្នុងប្រទេស យុត្តាធិការមានលក្ខណៈជាកាតព្វកិច្ច និងគ្របដណ្តប់លើបញ្ហាទាំងអស់។ ដោយហេតុនេះហើយទើបជាដំបូង យើងគិតថា យើងនឹងចាប់ផ្តើមពីយុត្តាធិការជាកាតព្វកិច្ច ចំណែកយុត្តាធិការតាមការជ្រើសរើសមានលក្ខណៈបណ្តោះអាសន្ន។ នៅពេលដែលយុត្តាធិការអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើងភ្លាម(CPJI) គេបានពិចារណាថានឹងឆ្ពងឱ្យផុតដំណាក់កាលនឹងផ្តល់បន្ថែម ដោយបង្កើតយុត្តាធិការជាកាតព្វកិច្ច។ ប៉ុន្តែ សម្រាប់តុលាការ គេ*


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មិនអាចឈានទៅដល់ការទទួលស្គាល់យុត្តាធិការជាកាតព្វកិច្ចនេះបានឡើយ ទាំងនៅឆ្នាំ១៩២១ ទាំងនៅឆ្នាំ១៩៤៥។ ដូច្នេះ ត្រូវមានការព្រមព្រៀងជាមុនម្តងមួយករណីៗ។

ភាពផ្ទុយគ្នារវាងយុត្តាធិការជាកាតព្វកិច្ច និងតាមការជ្រើសរើសមិនអាចសង្ខេបត្រឹមបញ្ហានៃការទទួលយកសន្ធិសញ្ញាដែលបង្កើតយុត្តាធិការបានឡើយ។ យុត្តាធិការត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញា។ ដូច្នេះរដ្ឋនីមួយៗមានសេរីភាពក្នុងការចូលជាសមាជិក ឬមិនចូល។

បញ្ហានៃភាពផ្ទុយគ្នា គឺជាដំណាក់កាលក្រោយ។ តាមការពិត យុត្តាធិការក្លាយទៅជាកាតព្វកិច្ចសម្រាប់ភាគីនៃសន្ធិសញ្ញា។ ជាញឹកញាប់ គេអាចមានជម្រើសមួយរវាងការទទួលយក ឬមិនទទួលយកយុត្តាធិការជាកាតព្វកិច្ច(CIJ) ឬរវាងសាលាក្តីផ្សេងៗ(TIDM)។ ក៏ប៉ុន្តែ ចាប់ពីអំណេះនេះទៅ យុត្តាធិការជាច្រើនមានលក្ខណៈជាកាតព្វកិច្ច នៅក្នុងប្រព័ន្ធអនុសញ្ញាណាមួយ (យុត្តាធិការព្រហ្មទណ្ឌ ៖ CPI, ORD, CJCE, CEDH ចាប់តាំងពីពិធីសារលេខ១១)។ យុត្តាធិការទាំងនេះមានលក្ខណៈជាកាតព្វកិច្ចសម្រាប់បណ្តារដ្ឋជាភាគី។

## ១- យុត្តាធិការតាមការព្រមព្រៀង ៖ CIJ

គោលការណ៍នៅទីនេះ គឺជាគោលការណ៍នៃការព្រមព្រៀង។ បណ្តារដ្ឋទាំងឡាយមិនបានត្រៀមខ្លួនទទួលស្គាល់សមាហរណកម្មបែបនេះឡើយ ហើយក្នុងគ្រប់ករណីទាំងអស់ដោយគ្មានការលើកលែង យុត្តាធិការរបស់តុលាការគឺជាយុត្តាធិការតាមការព្រមព្រៀង។ រដ្ឋអាចត្រូវបានប្តឹងទៅ CIJ បានលុះត្រាតែរដ្ឋនោះយល់ព្រមទទួលយកសមត្ថកិច្ចរបស់ CIJ។ តុលាការបានរំឭកយ៉ាងម៉ឺងម៉ាត់ជាច្រើនដង(ឧទាហរណ៍ សូមមើល CPJI រោងចក្រ Chorzow សាលដីកា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩២៨ ៖ ស៊េរីក លេខ១៧ ទំព័រ៣៧)។ ដើម្បីផ្ទៀងផ្ទាត់អត្ថិភាពនៃការព្រមព្រៀងនេះ តុលាការធ្វើការពិនិត្យបញ្ហាបឋមដែលចៅក្រមអាចលើកឡើងដោយបញ្ញត្តិ (ចៅក្រមអាចលើកឡើងដោយខ្លួនឯង ដោយមិនចាំបាច់មានការស្នើសុំពីគូភាគី)។

ផ្ទុយទៅវិញ ការព្រមព្រៀងរបស់ភាគីម្ខាងទៀតមិនមានការចាំបាច់ឡើយ ដើម្បីដាក់ជូនតុលាការនៅក្នុងទម្រង់មុននៃការប្តឹង(ការលើកលែងជាមុន) ដើម្បីដាក់ជូនតុលាការនូវពាក្យបណ្តឹងសុំឱ្យបកស្រាយ ឬដាក់ពាក្យបណ្តឹងសើរើដោយផ្អែកលើមាត្រា៦០ និង៦១នៃលក្ខន្តិកៈ (បណ្តឹងសើរើ និងបណ្តឹងសុំឱ្យបកស្រាយនៅក្នុងរឿងក្តីខ្ពង់រាបបាតសមុទ្ររវាងប្រទេសទុយនីស៊ី និងលីប៊ី សាលដីកា ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៥ ៖ សៀវភៅរឿងក្តី ទំព័រ២១៦)។ ឧទាហរណ៍មួយទៀត ពាក្យបណ្តឹងរបស់ព្រះរាជាណាចក្រកម្ពុជាសុំឱ្យបកស្រាយសាលក្រមក្នុងរឿងក្តីប្រាសាទព្រះវិហារ។

បច្ចេកទេសផ្សេងៗត្រូវបានប្រើប្រាស់ ដើម្បីបង្កើតយុត្តាធិការជាកាតព្វកិច្ច។ លក្ខខណ្ឌដែល

អាចមាននៃការបង្ហាញការយល់ព្រមមានច្រើនខុសៗគ្នា។ ដូច្នេះ ការយល់ព្រមអាចកើតឡើង ៖

ក- តាមរយៈកិច្ចសម្របសម្រួលដែលធ្វើឡើងដើម្បីបញ្ហានេះដោយគូភាគី បន្ទាប់ពីមានវិវាទកើតឡើងដែលជាស្ថានភាពដ៏សាមញ្ញជាងគេបំផុតសម្រាប់តុលាការ។ គឺត្រូវចុះកិច្ចព្រមព្រៀងមួយរវាងរដ្ឋពីរ ឬច្រើនដែលមានវិវាទ ដើម្បីបញ្ជូនរឿងក្តីទៅតុលាការ។ កិច្ចសម្របសម្រួលមានចែងនៅក្នុងមាត្រា៤០នៃលក្ខន្តិកៈ និងត្រូវបានបើកសិទ្ធិដោយមាត្រា៣៦ វាក្យខណ្ឌទី១ឱ្យដាក់ជូនតុលាការនូវរឿងក្តីទាំងអស់ដែលគូភាគីមានបំណងចង់ដាក់។

អត្ថប្រយោជន៍នៃកិច្ចសម្របសម្រួលគឺត្រូវជៀសវាងការប៉ុនប៉ងរាំងស្ទះនីតិវិធីឧប្បត្តិហេតុ។ មានរឿងក្តីជាងហាសិបដែលត្រូវបានដាក់ទៅតុលាការតាមកិច្ចសម្របសម្រួល ៖ ខ្ពង់រាបបាតសមុទ្រនៃសមុទ្រខាងជើង(ឆ្នាំ១៩៦៩) ខ្ពង់រាបបាតសមុទ្រប្រទេសទុយនីស៊ី-លីប៊ី(ឆ្នាំ១៩៨២) វិវាទដែនដីប្រទេសឆាត-លីប៊ី ឬគម្រោង Gabcikovo-Nagymaros ប្រទេសហុងគ្រី-ស្លូវ៉ាគី(ឆ្នាំ១៩៩៧)។

ខ- តាមរយៈការបញ្ចូលខចែងស្តីពីកិច្ចសម្របសម្រួលមួយនៅក្នុងសន្ធិសញ្ញាដោយឡែក (សន្ធិសញ្ញាទ្វេភាគី ឬពហុភាគីចំនួន២៦០ដែលរួមមានខចែងស្តីពីកិច្ចសម្របសម្រួលមួយផង ឧទាហរណ៍ ពិធីសារឆ្នាំ១៩៦៣ ស្តីពីអនុសញ្ញាស្តីពីទំនាក់ទំនងផ្នែកកុងស៊ុល)។ សន្ធិសញ្ញាទាំងនេះដែលមានខចែងស្តីពីកិច្ចសម្របសម្រួលទាំងនេះ គឺជាសន្ធិសញ្ញាចាស់ៗដែលកំណត់សមត្ថកិច្ចរបស់ CPJI មុនសង្គ្រាម និងដែលមិនត្រូវបានលុបចោលចាប់តាំងពីពេលនោះមក។ អាស្រ័យតាមការបន្តវេនរបស់ CIJ ពី CPJI សន្ធិសញ្ញាទាំងនេះនៅតែមានសុពលភាពដដែល។

អនុសញ្ញាពាក់ព័ន្ធភាគច្រើនគឺជាអនុសញ្ញាស្តីពីពាណិជ្ជកម្មរវាងរដ្ឋ និងរដ្ឋ។ ប៉ុន្តែ និន្នាការថ្មីៗនេះគឺស្ថិតលើសមត្ថកិច្ចរបស់ CIJ សម្រាប់អនុសញ្ញាពហុភាគីដ៏ទូលំទូលាយ។ ជាក់ស្តែង យើងឃើញសមត្ថកិច្ចរបស់តុលាការសម្រាប់អនុសញ្ញាឆ្នាំ១៩៨០ស្តីពីការអភិរក្សសត្វ និងរុក្ខជាតិនៅតំបន់អង់តាកទិក អនុសញ្ញាឆ្នាំ១៩៨៨ ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរថ្នាំលើកកម្លាំង និងសារធាតុមានឥទ្ធិពលលើផ្លូវចិត្តដោយខុសច្បាប់ ឬអនុសញ្ញាឆ្នាំ១៩៨៩ ប្រឆាំងនឹងជ្រើសរើស និងប្រើប្រាស់ទាហានស៊ីឈ្នួល។ អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ ស្តីពីសិទ្ធិលើសន្ធិសញ្ញា បញ្ជាក់ពីលទ្ធភាពប្តឹងទៅតុលាការនៅក្នុងមាត្រា៦៦នៃអនុសញ្ញានេះ ក្នុងករណីមានវិវាទពាក់ព័ន្ធនឹងច្បាប់ដាច់ខាត(ជាមួយនឹងលទ្ធភាពជាជម្រើសដែលបើកទ្វារឱ្យមានមជ្ឈត្តការ)។

សមត្ថកិច្ចរបស់តុលាការមានចែងនៅក្នុងសន្ធិសញ្ញា។ ប្រទេសលីប៊ីបានផ្អែកលើខចែងមួយនៃអនុសញ្ញាទីក្រុងម៉ុងរ៉េអាល់ ឆ្នាំ១៩៧១ ស្តីពីការបង្ក្រាបអំពើខុសច្បាប់មានការដឹកនាំប្រឆាំងនឹងសន្តិសុខអាកាសចរណ៍ស៊ីវិល ដើម្បីប្តឹងទៅតុលាការនៅក្នុងវិវាទរវាងប្រទេសលីប៊ី និងសហរដ្ឋអាមេរិក និងរវាងប្រទេសលីប៊ី និងព្រះរាជាណាចក្រអង់គ្លេសនៅក្នុងរឿងក្តីឈ្មោះថា

Lockerbie (គឺបត្យាប័ន)។

គ- តាមរយៈការចូលរួមនៅក្នុងអនុសញ្ញាដែលផ្តោតលើការដោះស្រាយវិវាទ។ វាមិនមែនជាខចែងស្តីពីកិច្ចសម្របសម្រួលទេ ព្រោះថា សន្ធិសញ្ញាទាំងមូលមានកម្មវត្ថុលើកឡើងនូវបញ្ហានៃការដោះស្រាយវិវាទ។ អានុភាពទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការនៅដដែល។ គឺពិធីសារទីក្រុងប៉ារីស ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៥៤ ដែលកែប្រែសន្ធិសញ្ញា ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៤៨ ស្តីពីការបង្កើត UEO ទេដែលចែងអំពីឧបាស្រ័យទៅ CIJ ឬអនុសញ្ញាអឺរ៉ុបស្តីពីការដោះស្រាយវិវាទ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៥៧។

ឃ- តាមរយៈសេចក្តីប្រកាសតាមការជ្រើសរើសអំពីយុត្តាធិការជាកាតព្វកិច្ច។

សេចក្តីប្រកាសជាឯកតោភាគីនេះជាញឹកញាប់បំផុត(យោងតាមមាត្រា៣៦ វាក្យខណ្ឌទី៣) មានការបញ្ជាក់ចំនួន២ ៖ (i) វាបញ្ជាក់ពីប្រភេទវិវាទដែលដាក់ទៅតុលាការ រយៈពេលសុពលភាពនៃសេចក្តីប្រកាស(ជាទូទៅ៥ ឬ១០ឆ្នាំ) ព្រមទាំងកាលកំណត់នៃការជូនដំណឹងជាមុន ជាយថាហេតុក្នុងករណីលុបចោល និង (ii) វាបង្ហាញឱ្យឃើញនូវលក្ខខណ្ឌទៅវិញទៅមក។ នៅក្នុងសាលដីកាមួយ CIJ បានលើកឡើងនូវសេចក្តីប្រកាសនេះ(រឿងក្តីប្រាសាទព្រះវិហារ ការលើកលែងជាមុន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៦១)។ តុលាការបានច្រានចោលពាក្យបណ្តឹងរបស់ប្រទេសថៃ ដោយបញ្ជាក់ថា គោលការណ៍ទម្រង់និយមមិនមានការចាំបាច់ទេ ហើយចំណុចតែមួយគត់ដែលចាំបាច់គឺការប្តេជ្ញាចិត្តរបស់រដ្ឋ។ ប្រទេសថៃបញ្ជាក់ថា សេចក្តីប្រកាសរបស់ខ្លួនមានកម្រិត។ សេចក្តីប្រកាសតាមការជ្រើសរើសនេះដាក់កម្រិតលទ្ធភាពធ្វើសកម្មភាព តុលាការនឹងស្វែងរកមធ្យោបាយស្នើសុំការបញ្ជាក់ តុលាការបានបញ្ជាក់លក្ខណៈអំពីការលើកលែងជាមុន។

ឧទាហរណ៍ សេចក្តីប្រកាសបែបនេះអាចមិនបញ្ជាក់អំពីរយៈពេលសុពលភាពនៃសេចក្តីប្រកាស លក្ខខណ្ឌ ឬវិស័យដែលសេចក្តីប្រកាសត្រូវបានអនុវត្ត។ ដូចនីតិអន្តរជាតិជាញឹកញាប់ដែរ គឺចេតនារបស់គូភាគីដែលនឹងមានភាពលុបលើទម្រង់។ ដូច្នេះ សេចក្តីប្រកាសមានសារៈសំខាន់ ផ្ទុយទៅវិញ គឺតុលាការទេដែលត្រូវស្វែងរកឥទ្ធិពលនៃសេចក្តីប្រកាស។

ក្នុងផ្នែកគតិយុត្ត យើងអាចចាត់ទុកថា សេចក្តីប្រកាសទាំងនេះស្ថិតក្រោមលក្ខខណ្ឌកំហិតពីរ ៖ (i) លក្ខខណ្ឌបដិការជាមួយរដ្ឋផ្សេងទៀត(ពាក់ព័ន្ធនឹងសេចក្តីប្រកាសជាកាតព្វកិច្ច ខ្ញុំទទួលយកសមត្ថកិច្ចរបស់តុលាការ ប្រសិនបើគូបដិបក្សទទួលយកសមត្ថកិច្ចរបស់តុលាការ) និង (ii) លទ្ធភាពបញ្ចេញលក្ខខណ្ឌនៅពេលទទួលយកយុត្តាធិការរបស់តុលាការ។ តុលាការមានវិធីសាស្រ្តផ្អែកលើហេតុការណ៍ ពាក់ព័ន្ធនឹងបញ្ហានៃការយល់ព្រមទទួលយកយុត្តាធិការរបស់ខ្លួន ជាពិសេស ព្រោះថា «ទាំងលក្ខន្តិកៈ ទាំងបទបញ្ជាផ្ទៃក្នុង មិនទាមទារឱ្យបង្ហាញការយល់ព្រមនេះនៅក្នុងទម្រង់មួយជាកំណត់ឡើយ»(ដៃសមុទ្រ Corfou សាលដីកាចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៩៤៨ ៖ សៀវភៅរឿងក្តី ទំព័រ២៧)។

## ២- ការជ្រើសរើសក្នុងចំណោមយុត្តាធិការនៅក្នុងប្រព័ន្ធស្មុគស្មាញនៃនីតិសមុទ្រ(ប្រព័ន្ធកូនកាត់)

*យោងតាមមាត្រា២៨៧នៃអនុសញ្ញាស្តីពីនីតិសមុទ្រ រដ្ឋទាំងឡាយមានសិទ្ធិជ្រើសរើសសាលាក្តី(ចៅក្រម) ដើម្បីដោះស្រាយវិវាទរបស់ខ្លួនទាក់ទងនឹងនីតិសមុទ្រ(គឺជា Forum Shopping ដ៏ល្បី)។ រដ្ឋទាំងឡាយអាចជ្រើសរើសយុត្តាធិការដែលខ្លួនចូលចិត្ត។ ប៉ុន្តែ រដ្ឋទាំងនោះមានកាតព្វកិច្ចត្រូវជ្រើសរើស និងប្រសិនបើមិនបានជ្រើសរើសទេ ជម្រើស(ការជ្រើសរើសមជ្ឈត្តការ) ត្រូវបានកំណត់ឱ្យរដ្ឋទាំងនោះ។*

*ប៉ុន្តែ មានវិវាទមួយចំនួនដែល TIDM មានកាតព្វកិច្ចត្រូវដោះស្រាយ សមត្ថកិច្ចជាកាតព្វកិច្ច ៖ វាគឺជាវិវាទបន្ទាន់ និងវិស័យដោយឡែកមួយចំនួន។*

## ២.១- យុត្តាធិការជាកាតព្វកិច្ចសម្រាប់ករណីបន្ទាន់ និងបាតសមុទ្រ

*នៅក្នុងស្ថានភាពបន្ទាន់ សមត្ថកិច្ចរបស់ TIDM មិនអាស្រ័យលើការយល់ព្រមរបស់រដ្ឋទេ ហើយមានមូលដ្ឋានរបស់ខ្លួននៅក្នុងការចុះហត្ថលេខាលើអនុសញ្ញាផ្ទាល់។ ករណីបន្ទាន់អាចកើតឡើងក្នុងនីតិវិធីចំនួនពីរ ៖ «ការលើកលែងភ្លាមៗ»(ការរឹបអូសនាវា និងទំនិញ) និង «វិធានការរក្សាការពារ»។*

*សម្រាប់ការលើកលែងនាវា និងក្រុមនាវិកភ្លាមៗ(មាត្រា២៩២)នៃអនុសញ្ញាដែលជាឯកសារយោង ៖ ត្រូវឱ្យគេដោះលែងតាមផ្លូវគតិយុត្ត និងយ៉ាងឆាប់រហ័សនូវនាវា និងក្រុមនាវិក នៅពេលវិវាទណាមួយកើតឡើងរវាងរដ្ឋជាប់ឆ្នេរ និងនាវាបរទេស ជាពិសេសនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ ដូច្នេះ «រដ្ឋម្ចាស់ទង់ជាតិ ឬក្នុងនាមរដ្ឋ»អាចប្តឹងទៅ TIDM ជាឯកតោភាគី ក្រោយកាលកំណត់១០ថ្ងៃ បន្ទាប់ពីការចាប់នាវា។ ដោយបាននិយាយបែបនេះ គូភាគីនៅតែមានសេរីភាពជានិច្ចក្នុងការដាក់វិវាទនេះទៅកាន់យុត្តាធិការមួយផ្សេងទៀត ឬចរចាគ្នាដោយផ្ទាល់(មាត្រា២៩២ វាក្យខណ្ឌទី១) ប៉ុន្តែ គ្មានការយល់ព្រមបន្ថែមណាមួយត្រូវបានតម្រូវឡើយ ក្នុងករណីរដ្ឋម្ចាស់ទង់ជាតិចង់ប្តឹងទៅ TIDM។ យើងមិនចាំបាច់ធ្វើសេចក្តីប្រកាសការយល់ព្រមឡើយ។*

*ជាការពិតណាស់ នីតិវិធីនេះត្រូវបានកំណត់នៅក្នុងវិស័យយ៉ាងជំនាញ និងច្បាស់លាស់ដែលអចលនកម្មត្រូវគ្នានឹងស្ថានភាពដែលចែង«ដោយបទប្បញ្ញត្តិនៃអនុសញ្ញា»(មាត្រា២៩២ ដែលយោងជាពិសេសដល់សមាត្រា៧៣ស្តីពីការការពារធនធានជីវសាស្ត្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ)។ ប៉ុន្តែ ដូចនៅក្នុងរឿងក្តី Saiga ដែរ គ្មានអ្វីរារាំងគូភាគីមិនឱ្យប្តឹងដល់អង្គសេចក្តីនៃរឿងក្តីនៅចំពោះមុខ TIDM ឬនៅចំពោះមុខយុត្តាធិការផ្សេងទៀតឡើយ។ នៅពេលដែលមាន*

*វិធានការលើកលែងភ្លាមៗ យុត្តាធិការនោះត្រូវមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដល់អង្គសេចក្តី។ ភាគីទាំងអស់នៃ CMB ទទួលយកយុត្តាធិការនៃ TIDM សម្រាប់ការលើកលែងភ្លាមៗ។*

*សម្មតិកម្មមួយទៀតនៃយុត្តាធិការជាកាតព្វកិច្ចគឺសម្មតិកម្មវិធានការរក្សាការពារ ទម្រាំដល់ពេលបង្កើតតុលាការមជ្ឈត្តការ( មាត្រា២៩០ វាក្យខណ្ឌទី៥)។ គំនិតគឺថា គូភាគីដែលចង់ប្តឹងទៅតុលាការមជ្ឈត្តការណាមួយដើម្បីជំនុំជម្រះវិវាទរបស់ខ្លួន ត្រូវទទួលបានពេលវេលាជាក់លាក់មួយសម្រាប់ការបង្កើតតុលាការមជ្ឈត្តការនេះ។ យ៉ាងណាមិញ ពេលខ្លះ ករណីបន្ទាន់តម្រូវឱ្យមានវិធានការភ្លាមៗ។ វាគឺជាតួនាទីរបស់ TIDM។ ប៉ុន្តែ TIDM ណែនាំឱ្យនៅបន្ត ប្រសិនបើមិនដូច្នេះទេ មានហានិភ័យនៃការដកភារកិច្ច( ការចោទប្រកាន់ឡើងវិញ)។ ដូច្នេះ យើងស្ថិតនៅក្នុងស្ថានភាពចម្លែកដែលយុត្តាធិការនឹងមានសមត្ថកិច្ចជាកាតព្វកិច្ច ដើម្បីប្រកាសវិធានការបន្ទាន់ ប៉ុន្តែ ដែលយុត្តាធិការអាចត្រូវបានដកចេញ( ការចោទប្រកាន់ឡើងវិញ)ពីរឿងក្តីនេះ ដើម្បីជំនុំជម្រះដល់អង្គសេចក្តី។ ប៉ុន្តែ ជាសំខាន់ត្រូវបញ្ជាក់ថា យុត្តាធិការ«អាច»ត្រូវបានដកភារកិច្ច( ការជំទាស់)បាន ព្រោះគូភាគីក៏អាចជ្រើសរើសប្តឹងទៅ TIDM សម្រាប់ការជំនុំជម្រះដល់អង្គសេចក្តីបានដែរ។ រឿងក្តី Saiga ដែលក្នុងនោះ នៅទីបំផុត TIDM ត្រូវបានជ្រើសរើសដើម្បីជំនុំជម្រះដល់អង្គសេចក្តី( ចំណែកជម្រើសទីមួយផ្តោតទៅលើមជ្ឈត្តការ)។*

*សេចក្តីសម្រេចមួយដែលធ្វើឡើងមុនវិធានការរក្សាការពារ អាចត្រូវបានជំទាស់នៅពេលបន្ទាប់ ដោយចៅក្រមដែលជំនុំជម្រះដល់អង្គសេចក្តី។ ប៉ុន្តែ ក្នុងរឿងក្តីត្រីតុងព្រុយខៀវដែលនៅទីបំផុត តុលាការមជ្ឈត្តការត្រូវបានជ្រើសរើស ដើម្បីជំនុំជម្រះរឿងក្តីនេះដល់អង្គសេចក្តី តុលាការដែលនឹងលុបចោលវិធានការរក្សាការពារដែលប្រកាសដោយ TIDM បានវាយតម្លៃខ្លួនឯងថាគ្មានសមត្ថកិច្ច។*

*TIDM ក៏អាចមានសមត្ថកិច្ចជាកាតព្វកិច្ចផងដែរសម្រាប់វិវាទដែលទាក់ទងនឹងបាតសមុទ្រ។ ត្រូវមានយុត្តាធិការជាកាតព្វកិច្ចមួយ ដើម្បីជំនុំជម្រះវិវាទប្រភេទនេះដែលទាក់ទងនឹងបេតិកភណ្ឌរួមរបស់មនុស្សជាតិដែលត្រូវបានគ្រប់គ្រងដោយអាជ្ញាធរ មាត្រា១៨៧។*

## ២.២- ការជ្រើសរើសសមត្ថកិច្ចជាកាតព្វកិច្ច ឬតាមការព្រមព្រៀង

*សូមមើលចំណុចនេះនៅមាត្រា២៨៧ និង Forum Shopping ដែលអនុញ្ញាតឱ្យរដ្ឋណាមួយជ្រើសរើសយុត្តាធិការណាមួយ។ ការជ្រើសរើសនេះធ្វើឡើងតាមរយៈសេចក្តីប្រកាសនៅពេលចុះហត្ថលេខា នៅពេលផ្តល់សច្ចាប័ន នៅពេលចូលជាសមាជិក ឬនៅពេលក្រោយ រវាង TIDM, CIJ មជ្ឈត្តការទូទៅនៃឧបសម្ព័ន្ធទី៧ ឬមជ្ឈត្តការពិសេសនៃឧបសម្ព័ន្ធទី៨( ការនេសាទ ការការពារមជ្ឈដ្ឋានសមុទ្រ ការស្រាវជ្រាវវិទ្យាសាស្ត្រ ការធ្វើនាវាចរណ៍)។ បច្ចេកទេសបម្រុង។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រសិនបើគ្មានសេចក្ដីប្រកាសទេ ឬក្នុងករណីសេចក្ដីប្រកាសមានភាពផ្ទុយគ្នា មជ្ឈត្តការនឹងត្រូវអនុម័តយក។ ដូច្នេះ ការមិនជ្រើសរើសគឺជាទម្រង់មួយនៃការជ្រើសរើស ហើយ«ការជ្រើសរើសដែលមានតម្លៃគតិយុត្តទាបជាងគេ(បញ្ជាក់ប្រាប់អ្នកតិចតួច គឺមជ្ឈត្តការ)» មានប្រៀបជាងគេ។

នៅឆ្នាំ២០០៤ ក្នុងចំណោមរដ្ឋជាភាគីទាំង១៤៥នៃអនុសញ្ញា មានតែរដ្ឋចំនួន៣២ប៉ុណ្ណោះបានធ្វើការជ្រើសរើសយល់ស្រប ចំណែករដ្ឋផ្សេងទៀត ពេលខ្លះបានស្នើសុំលទ្ធភាពជាច្រើនព្រោះថាមាត្រា២៨៧ក៏អនុញ្ញាតឱ្យជ្រើសរើសសាលាក្ដី(យុត្តាធិការ)ច្រើនទៅតាមប្រភេទវិវាទដែរ។ ចំណុចនេះមានន័យថា សម្រាប់រដ្ឋភាគច្រើន ការជ្រើសរើសដោយកំបាំងមុខគឺការជ្រើសរើសមជ្ឈត្តការក្នុងករណីមានវិវាទ។

តាមរយៈអនុសញ្ញាដែលមានមុន ឬក្រោយពេលប្ដឹងទៅ TIDM រដ្ឋទាំងឡាយមានសេរីភាពក្នុងការជ្រើសរើសដោះស្រាយវិវាទតាមការចរចា។ កាតព្វកិច្ចតែមួយគត់គឺថា វិវាទត្រូវបានដោះស្រាយ។ វិវាទទាំងអស់ត្រូវតែដោះស្រាយ ប៉ុន្តែ រដ្ឋទាំងឡាយត្រូវជ្រើសរើសរបៀបនៃការដោះស្រាយ។

យើងកត់សម្គាល់ឃើញថា ទស្សនៈដែលមានប្រៀបសម្រាប់នីតិសមុទ្រមានពីរគឺ ៖ រាល់វិវាទទាំងអស់ត្រូវតែដោះស្រាយជាដាច់ខាត ប៉ុន្តែ រដ្ឋទាំងឡាយមានសេរីភាពក្នុងការជ្រើសរើសរបៀបនៃការដោះស្រាយ។ គឺក្នុងន័យនេះហើយដែលយើងអាចលើកឡើងពីការជ្រើសរើសដោយសេរីនូវសមត្ថកិច្ចជាកាតព្វកិច្ច។

| យុត្តាធិការតាមការព្រមព្រៀង<br>(មុនពេលមានវិវាទកើតឡើង) | ជាកាតព្វកិច្ច<br>(ក្រោយពេលមានវិវាទកើតឡើង) |
|---|---|
| CIJ, TIDM | CPI |

# ផ្នែកទី២

## យុត្តាធិការជាកាតព្វកិច្ច

គោលការណ៍ - មានការយល់ព្រមរបស់រដ្ឋជានិច្ចចំពោះយុត្តាធិការតាមការព្រមព្រៀង និងយុត្តាធិការជាកាតព្វកិច្ច។ គោលការណ៍អធិបតេយ្យភាព។

គឺជាសម្មតិកម្មថា បណ្ដារដ្ឋជាភាគីនៃអនុសញ្ញាដែលមានគម្រោងចង់បានប្រព័ន្ធដោះស្រាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*វិវាទ មិនមានជម្រើស ហើយការប្តឹងទៅយុត្តាធិការណាមួយដែលបង្កើតឡើងដោយអនុសញ្ញាត្រូវបានធ្វើឡើងជាស្វ័យប្រវត្តិ។ រដ្ឋទាំងឡាយមិនចាំបាច់ផ្តល់ការយល់ព្រមថែមទៀតចំពោះសមត្ថកិច្ចនៃតុលាការនេះឡើយ។*

## **១- អនុស្សរណៈដែលគ្រប់គ្រងលើ RDOMC**

*ORD តំណាងឱ្យស្ថានភាពមួយដែលមានលក្ខណៈសាមញ្ញតាមច្បាប់ក្នុងប្រទេស ប៉ុន្តែមានលក្ខណៈដើមនៅក្នុងក្របខ័ណ្ឌនៃវិវាទអន្តររដ្ឋ។ យុត្តាធិការនៃ ORD មានលក្ខណៈជាកាតព្វកិច្ចដោយផ្ទាល់។ ដូច្នេះ មិនចាំបាច់មានការយល់ព្រមបន្ថែមឡើយ សម្រាប់បណ្តារដ្ឋជាសមាជិកនៃ WTO។ ចាប់ពីពេលដែលរដ្ឋក្លាយជាសមាជិកនៃ WTO រដ្ឋនោះត្រូវស្ថិតក្រោមយុត្តាធិការនៃ ORD។ ដូច្នេះ យុត្តាធិការគឺជាផ្នែកមួយនៃ«កញ្ចប់» យោងតាមគោលការណ៍នៃកិច្ចព្រមព្រៀងតែមួយដែលហាមប្រាមការជ្រើសរើសក្នុងចំណោមមែកជាងផ្សេងៗនៃ WTO។*

*យុត្តាធិការរបស់ ORD មិនត្រឹមតែជាកាតព្វកិច្ចប៉ុណ្ណោះទេ ប៉ុន្តែម្យ៉ាងទៀត មានលក្ខណៈផ្តាច់មុខ។ មាត្រា២៣.១នៃអនុស្សរណៈ ៖ រដ្ឋមួយមិនអាចក្លាយជាសមាជិកនៃ WTO បានទេ ប្រសិនបើមិនបានចូលជាសមាជិកនៃអនុស្សរណៈទេនោះ។ រដ្ឋណាមួយដែលរងគ្រោះដោយសារមហន្តរាយនៅក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ឬដោយសារការរំលោភបំពានកាតព្វកិច្ច មិនអាចព្យាយាមទាមទារសំណងជួសជុលការខូចខាតតាមរយៈស្ថាប័នណាមួយផ្សេងពីស្ថាប័ន ORD បានឡើយ។ រដ្ឋអាចប្តឹងទៅ ORD ជាឯកតោភាគីបាន។ ដូច្នេះ ORD ជាយន្តការមួយនៃយុត្តាធិការជាកាតព្វកិច្ច។*

*នីតិវិធីចាប់ផ្តើមយ៉ាងត្រឹមត្រូវតាមទម្រង់ តាមរយៈការដាក់ពាក្យបណ្តឹងនៅ ORD។ មានដំណាក់កាលពិគ្រោះយោបល់មួយដែលក្នុងអំឡុងពេលនោះ គូភាគីត្រូវសាកល្បងចរចាគ្នា និងឈានដល់ដំណោះស្រាយមួយដែលអាចទទួលយកបានទៅវិញទៅមក។ មិនមានលទ្ធភាពនៃការប្តឹងច្រើនទេ គឺមានទម្រង់តែមួយគត់ គឺត្រូវដាក់ពាក្យបណ្តឹង។ ដោយសារយុត្តាធិការមានលក្ខណៈជាកាតព្វកិច្ច ចុងចម្លើយនឹងត្រូវឆ្លើយតបនឹងយុត្តាធិការនេះ និងអាចគ្រាន់តែសាកល្បងចរចាស្វែងរកច្រកចេញពីវិវាទដោយសន្តិវិធីប៉ុណ្ណោះ។*

## **២- CJCE និង CEDH**

*យុត្តាធិការនៃ CJCE មានលក្ខណៈជាកាតព្វកិច្ច ចំពោះរដ្ឋជាសមាជិកទាំងអស់នៃសហភាពអឺរ៉ុប ដោយមិនចាំបាច់មានការយល់ព្រមដោយឡែកនៅពេលក្រោយឡើយ។ ដូច្នេះ ស្ថាប័នសហគមន៍ បណ្តារដ្ឋ ព្រមទាំងបុគ្គលម្នាក់ៗ(នីតិបុគ្គល ឬរូបវន្តបុគ្គល) នៅក្នុងក្របខ័ណ្ឌមួយ*

ចំនួនអាចដំណើរការជាឯកតោភាគី ដើម្បីប្ដឹងទៅ CJCE។

សម្រាប់ CEDH យុត្តាធិការតាមការព្រមព្រៀង មុនពិធីសារលេខ១១ ក្រោយពិធីសារ យុត្តាធិការនេះមានលក្ខណៈជាកាតព្វកិច្ច។ កាលពីមុន គណៈកម្មការបានត្រួតពិនិត្យពាក្យបណ្ដឹង។ បច្ចុប្បន្ន គឺតុលាការ។ មុនពេលធ្វើដូច្នេះ ការទទួលស្គាល់សិទ្ធិប្ដឹងជាលក្ខណៈបុគ្គលមានលក្ខណៈតាមការជ្រើសរើស និងអាស្រ័យលើការទទួលយកដោយរដ្ឋពាក់ព័ន្ធ(រដ្ឋដែលបញ្ជាក់ដោយពលរដ្ឋរបស់ខ្លួន) និងលើការទទួលយកពិធីសារតាមការជ្រើសរើស(លេខ៩)។ នៅពេលនោះ ការត្រួតពិនិត្យត្រូវបានធ្វើឡើងដោយគណៈកម្មការដែលធ្វើការសម្រេចចិត្តលើភាពអាចទទួលយកបាន និងស្នើឡើងនូវការដោះស្រាយដោយការស្រុះស្រួលគ្នា។

ពិធីសារលេខ១១ - ចូលជាធរមាននៅឆ្នាំ១៩៩៨ - ផ្លាស់ប្ដូរលក្ខណៈនេះទាំងស្រុង ព្រោះថា គណៈកម្មការបានប្ដូរទៅជាតុលាការតែមួយដែលរៀបចំរចនាសម្ព័ន្ធឡើងវិញ។ គឺតុលាការខ្លួនឯងដែលបានបង្កើតនីតិវិធីត្រួតពិនិត្យ(ភាពអាចទទួលយកបាននៃពាក្យបណ្ដឹង) ប៉ុន្តែ ការធ្វើបែបនេះមិនផ្លាស់ប្ដូរបញ្ហាចោទឡើយ ៖ តុលាការប្រចាំ Strasbourg បានក្លាយជាយុត្តាធិការជាកាតព្វកិច្ច សម្រាប់បណ្ដារដ្ឋជាសមាជិក និងពលរដ្ឋនៃរដ្ឋទាំងនោះ។

## ៣- យុត្តាធិការព្រហ្មទណ្ឌ

ប្រការដែល TPIY និង TPIR ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ យោងតាមជំពូកទី៧ កំណត់ភាពជាកាតព្វកិច្ចនៃស្ថាប័នទាំងនេះ។ លិខិតបង្កើតសាលាក្ដី សេចក្ដីសម្រេចរបស់ TPIY និង TPIR មានលក្ខណៈជាកាតព្វកិច្ច។ ការយល់ព្រមឱ្យមានតុលាការព្រហ្មទណ្ឌគឺគ្រាន់តែជាការបដិសេធអត្ថិភាពនៃតុលាការនេះប៉ុណ្ណោះ។ ដូច្នេះ បុគ្គលដែលត្រូវបានចោទប្រកាន់មិនមានជម្រើសអ្វីឡើយ។ កាតព្វកិច្ចសហប្រតិបត្តិការ(ដែលអាចប្រែប្រួលអង្គហេតុតាមតម្រូវការ)ត្រូវបានកំណត់ដូចគ្នាចំពោះរដ្ឋទាំងអស់ និងតម្រូវឱ្យរដ្ឋទាំងអស់ជួយដល់សាលាក្ដីទាំងនេះ។ ក៏ប៉ុន្តែ ចំណុចនេះមិនមានន័យថា សមត្ថកិច្ចរបស់តុលាការមិនអាចប្រកែកបានដូចត្រូវបានបញ្ជាក់ដោយសាលដីកា Tadic ឆ្នាំ១៩៩៥ ឡើយ។ ប៉ុន្តែ ចំណុចនេះមិនយកអ្វីពីលក្ខណៈជាកាតព្វកិច្ចជាមូលដ្ឋាននៃយុត្តាធិការឡើយ។ ប៉ុន្តែ មានព្រំដែននៃយុត្តាធិការព្រហ្មទណ្ឌអន្តរជាតូបនីយកម្ម ព្រោះមានសមត្ថកិច្ចតាមបុគ្គល(ឥស្សរជន និងអ្នកមានការទទួលខុសត្រូវខ្ពស់) តាមសត្យានុម័ត(ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) តាមពេលវេលា(រវាងឆ្នាំ១៩៧៥-៧៩) ឬតាមដែនដី(នៅប្រទេសកម្ពុជា)ដែលអាចចោទឡើង។ ព្រះមហាក្សត្រមិនមានអភ័យឯកសិទ្ធិនៅចំពោះមុខ CPI ទេ។

កាតព្វកិច្ចចំពោះមុខ ៖ ជាមួយ CPI យើងមានបញ្ហា គឺថា រដ្ឋមួយមិនមែនជាភាគីទេ។

សហរដ្ឋអាមេរិកមិនមែនជាភាគីទេ សហរដ្ឋអាមេរិកបានចុះហត្ថលេខាលើសន្ធិសញ្ញា ប៉ុន្តែមិនបានផ្តល់សច្ចាប័នទេ។ សហរដ្ឋអាមេរិកបានចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគី គឺសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា។

មានតែរដ្ឋអាជ្ញាទេអាចចាប់ផ្តើមការប្តឹងបាន។ ទាំងជនរងគ្រោះ ទាំងរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាលមិនអាចចាប់ផ្តើមការប្តឹងបានឡើយ។ ប៉ុន្តែ ពួកគេអាចផ្តល់ព័ត៌មានដែលរដ្ឋអាជ្ញាវាយតម្លៃនៅក្នុងឱកាសនៃការប្តឹង មាត្រា១៨នៃលក្ខន្តិកៈរបស់ TPIY និងមាត្រា១៧នៃលក្ខន្តិកៈរបស់ TPIR។

ជនរងគ្រោះអាចជូនដំណឹងដល់រដ្ឋអាជ្ញាអំពីជាតុជាក់ស្តែង។ ជនរងគ្រោះមិនអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ។ ពួកគេអាចធ្វើជាសាក្សីបាន។ ពួកគេអាចផ្ញើទៅអ្នកជូនយោបល់តុលាការ( សេចក្តីសន្និដ្ឋាន – sarna – ដែលសរសេរដោយជនរងគ្រោះ តុលាការមានករណីយកិច្ចស្នើសុំឱ្យជនរងគ្រោះ ឬ NGO ឬអ្នកជំនាញច្បាប់រួមចំណែកនៅក្នុងអ្នកជូនយោបល់តុលាការ)ដែលមានចែងនៅក្នុងមាត្រា៧៥នៃបទបញ្ជារបស់ TPIY។

TPIY និង TPIR អាចតម្រូវឱ្យរដ្ឋទាំងឡាយគោរពតាម ផ្ទុយទៅវិញ សម្រាប់រដ្ឋទាំងឡាយ CPI ត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញា។ ប្រការនេះធ្វើឱ្យមានសម្មតិកម្មជាច្រើន។

- ចំពោះបណ្តារដ្ឋដែលបានផ្តល់សច្ចាប័នលើលក្ខន្តិកៈក្រុងរ៉ូម យុត្តាធិការនឹងមានលក្ខណៈជាកាតព្វកិច្ច។

- ផ្ទុយមកវិញ បញ្ហារបស់ពលរដ្ឋនៃបណ្តារដ្ឋដែលមិនបានផ្តល់សច្ចាប័នលើលក្ខន្តិកៈនេះ ប៉ុន្តែដែលអាចនឹងត្រូវបានជំនុំជម្រះ បានចោទឡើង។ ជាការពិតណាស់ យន្តការសហប្រតិបត្តិការអនុញ្ញាតឱ្យរដ្ឋណាមួយទទួលយកយុត្តាធិការរបស់តុលាការចំពោះរឿងក្តីណាមួយ និងអនុញ្ញាតឱ្យរដ្ឋនោះ( ក៏ដូចជារដ្ឋផ្សេងទៀតដែលមិនមែនជាសមាជិកដែរ) សហប្រតិបត្តិការជាមួយ CPI។

- បញ្ហាបានចោទឡើងថែមទៀត ចំពោះបណ្តារដ្ឋដែលមិនបានទទួលយកលក្ខន្តិកៈក្រុងរ៉ូម និងដែលមិនចង់សហប្រតិបត្តិការ ឬថែមទាំងប្រឆាំងយ៉ាងច្បាស់ទៅនឹង CPI ដូចជាសហរដ្ឋអាមេរិកជាដើម។ ដូច្នេះ វាច្បាស់ណាស់ថា សមត្ថកិច្ចរបស់តុលាការមានអត្ថិភាព( សូមមើលខាងក្រោមបញ្ហានៃសមត្ថកិច្ចតាមបុគ្គល) និងថា យុត្តាធិការរបស់តុលាការនឹងមានលក្ខណៈជាកាតព្វកិច្ច មានន័យថា ដោយមិនមានការយល់ព្រម សម្រាប់សេណារីយ៉ូនេះដែលមិនឈប់ចោទជាបញ្ហា និងដែលជាឧបសគ្គសំខាន់នៃការផ្តល់សច្ចាប័នរបស់រដ្ឋជាច្រើនដែលក្នុងនោះមានសហរដ្ឋអាមេរិកផងដែរ។

# ផ្នែកទី៣
# យុត្តាធិការជាភាគពូកិច្ច ឬយុត្តាធិការតាមការព្រមព្រៀង
# ទៅតាមឋានៈអ្នកទទួលការជំនុំជម្រះ

*បញ្ហាត្រូវបានបង្ហាញរវាងយុត្តាធិការមានអ្នកទទួលការជំនុំជម្រះតែមួយ និងយុត្តាធិការមានអ្នកទទួលការជំនុំជម្រះច្រើន។*

## ១- យុត្តាធិការមានអ្នកទទួលការជំនុំជម្រះតែមួយ

### ១.១- *CIJ* ៖ យុត្តាធិការតាមការព្រមព្រៀងមានអ្នកទទួលការជំនុំជម្រះតែមួយ

*មាត្រា៣៤នៃលក្ខន្តិកៈ ៖ មានតែរដ្ឋប៉ុណ្ណោះមាន«សមត្ថភាពបង្ហាញខ្លួននៅចំពោះមុខតុលាការ»។ ទាំងបុគ្គលឯកជន ទាំងអង្គការអន្តរជាតិមិនអាចក្លាយជាភាគីនៃនីតិវិធីយុត្តាធិការរបស់តុលាការបានឡើយ។ ពាក់ព័ន្ធនឹងសមត្ថកិច្ចពិគ្រោះយោបល់ អង្គការអន្តរជាតិ ក្រុមប្រឹក្សាសន្តិសុខអាចស្នើសុំយោបល់ពីតុលាការ។ ស្ថានភាពនេះត្រូវបានពន្យល់ដោយការមិនទុកចិត្តរបស់រដ្ឋទាំងឡាយចំពោះអង្គការអន្តរជាតិ។ រដ្ឋទាំងអស់មានការខ្លាចក្រែងថា អង្គការអន្តរជាតិអាចប្តឹងទៅ CIJ ដើម្បីទៅដល់ដីរបស់រដ្ឋស្ថាបនិក។ វិវាទមួយចំនួនដែលពាក់ព័ន្ធជាមួយអង្គការអន្តរជាតិ អាចត្រូវបានចាត់ចែងតាមរយៈនីតិវិធីពិគ្រោះយោបល់។ កំណើនអង្គការអន្តរជាតិបង្កើនហានិភ័យដែលអង្គការទាំងនោះមានការពាក់ព័ន្ធ ឬជាដើមចមនៃវិវាទដែលដំណោះស្រាយមិនអាចត្រូវបានស្វែងរកតាមផ្លូវតុលាការ ឬមជ្ឈត្តការបានឡើយ។ នៅក្នុងរឿងក្តី Kosovo ដោយសារគ្មានអំណាចក្នុងការចោទប្រកាន់លើទំនួលខុសត្រូវរបស់ OTAN ដោយសារការទម្លាក់គ្រាប់បែក ប្រទេសយូហ្គោស្លាវី(ស៊ែប៊ី-ម៉ុងតេនេហ្គ្រោ) បានដាក់បណ្តឹងប្តឹងរដ្ឋជាសមាជិកទាំងអស់ដែលពាក់ព័ន្ធ ពោលគឺពាក្យបណ្តឹងចំនួនដប់។*

*ជាដំបូង បណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ មានសិទ្ធិប្តឹងទៅកាន់តុលាការយ៉ាងពេញច្បាប់ ដរាបណាបណ្តារដ្ឋទាំងនោះគឺជាភាគីនៃលក្ខន្តិកៈដោយស្វ័យប្រវត្តិក្នុងឋានៈជាឧបសម្ព័ន្ធនៃធម្មនុញ្ញ។ រដ្ឋត្រូវធ្វើសេចក្តីប្រកាសជាឯកតោភាគីមួយអំពីសមត្ថកិច្ច។ បញ្ហាបានលេចឡើងនៅក្នុងរឿងក្តីនៃភាពស្របច្បាប់នៃការប្រើប្រាស់កម្លាំងដែលបានដាក់ប្រទេសយូហ្គោ-ស្លាវីឱ្យប្រឈមមុខជាមួយបណ្តារដ្ឋដែលបានធ្វើការវាយប្រហារតាមផ្លូវអាកាសទៅលើកូសូវ៉ូ។*

*បណ្តារដ្ឋមិនមែនជាសមាជិកនៃអង្គការសហប្រជាជាតិ អាចចូលជាសមាជិកនៃលក្ខន្តិកៈ*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*និងដាក់រឿងក្តីទៅកាន់តុលាការ តាមលក្ខខណ្ឌដែលកំណត់ដោយក្រុមប្រឹក្សាសន្តិសុខ(ចាប់ពីពេលនេះទៅ រដ្ឋស្ទើរតែទាំងអស់ក្នុងពិភពលោកគឺជាសមាជិកនៃអង្គការសហប្រជាជាតិ)។*

*ជាចុងក្រោយ បណ្តារដ្ឋមិនមែនជាសមាជិក និងមិនមែនជាភាគីនៃលក្ខន្តិកៈក៏អាចប្តឹងទៅកាន់តុលាការបានដែរ។ CIJ បានអនុម័តយកទស្សនាទានដ៏គួរឱ្យស្វាគមន៍មួយដោយទទួលស្គាល់ថា «ពាក្យបណ្តឹងអាចត្រូវបានដាក់យ៉ាងមានសុពលភាពដោយរដ្ឋណាមួយប្រឆាំងនឹងរដ្ឋមួយទៀតដែលប្រសិនបើមិនមែនជាភាគីនៃលក្ខន្តិកៈ គឺជាភាគីនៃបញ្ញត្តិបែបនេះ(ឧទាហរណ៍ ខចែងស្តីពីកិច្ចសម្របសម្រួលដែលចែងអំពីសមត្ថកិច្ចរបស់តុលាការ)នៃសន្ធិសញ្ញាជាធរមាន និងឯករាជ្យពីលក្ខខណ្ឌដែលគ្រប់គ្រងដោយក្រុមប្រឹក្សាសន្តិសុខនៅក្នុងសេចក្តីសម្រេចលេខ៩ (ឆ្នាំ១៩៤៦)» (រឿងក្តីប្រល័យពូជសាសន៍នៅប្រទេសបូស្នី/យូហ្គោស្លាវី ដីកា ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៣ ៖ សៀវភៅរឿងក្តី ទំព័រ១៤៤ កថាខណ្ឌទី១៩)។*

## ១.២- យុត្តាធិការព្រហ្មទណ្ឌ ៖ យុត្តាធិការជាកាតព្វកិច្ចមានអ្នកទទួលការជំនុំជម្រះតែមួយ(ប្រភេទ)

*បញ្ហា«អ្នកទទួលការជំនុំជម្រះ»ចោទឡើងខុសគ្នាយ៉ាងខ្លាំងចំពោះយុត្តាធិការព្រហ្មទណ្ឌ។ វាលែងមានបញ្ហាតុលាការតាមការជ្រើសរើស ឬស្ម័គ្រចិត្តទៀតហើយ(ទោះបីជាបុគ្គលដែលអាចទទួលការចោទប្រកាន់ អាចបង្ហាញខ្លួនដោយឯកឯងនៅចំពោះមុខយុត្តាធិការទាំងនេះក៏ដោយ)។ បុគ្គលម្នាក់ៗនឹងត្រូវបានជំនុំជម្រះពីបទប្រព្រឹត្តហិង្សាធ្ងន់ធ្ងរ តាមទម្រង់នៃតុលាការព្រហ្មទណ្ឌបុរាណ។ ប្រការនេះស្ថិតក្រោមសមត្ថកិច្ចតាមបុគ្គល។ រដ្ឋទាំងឡាយព្យាយាមកម្រិតចំនួនបុគ្គលដែលស្ថិតក្រោមយុត្តាធិការព្រហ្មទណ្ឌ។*

*យុត្តាធិការមួយចំនួនចង់ជំនុំជម្រះតែអ្នកទទួលខុសត្រូវសំខាន់ៗប៉ុណ្ណោះ ទោះបីជា«ប្រភេទនេះ» ពេលខ្លះត្រូវធ្វើការបកស្រាយក៏ដោយ ៖ គឺករណីតុលាការសម្រាប់សាលាក្តីសេរ៉ាលេអូន សាលាក្តីសម្រាប់ប្រទេសកម្ពុជា និងផ្ទុយមកវិញ តាមទ្រឹស្តី វាមិនអាចជាករណីសាលាក្តីសម្រាប់ប្រទេសកូសូវ៉ូ ឬសាលាក្តីនៃប្រទេសបូស្នីឡើយ ព្រោះថា សាលាក្តីទាំងនេះត្រូវបានបង្កើតឡើងគ្រាន់តែដើម្បីបើកផ្លូវឱ្យ TPIR ប៉ុណ្ណោះ(យ៉ាងហោចណាស់ យ៉ាងច្បាស់សម្រាប់សាលាក្តីនៃប្រទេសបូស្នី)។ វាគឺជាករណីនៃ TPIY ដែលដោយមានឆន្ទៈជំនុំជម្រះបុគ្គលទាំងអស់ដែលពាក់ព័ន្ធ ចាប់ពីពេលនេះទៅបានបែរទៅរកការជំនុំជម្រះតែមួយលើអ្នកទទួលខុសត្រូវសំខាន់ៗ តួយ៉ាង TPIR មាននិន្នាការទុកដោតវាសនារបស់អ្នកអនុវត្តឱ្យតុលាការក្នុងស្រុកនៃប្រទេសរ៉ាវ៉ាន់ដា(តាមប្រព័ន្ធតុលាការតាមមូលដ្ឋាន AC)។*

*សម្រាប់ CPI អ្វីៗគឺខុសគ្នា មានសមត្ថកិច្ចដើម្បីជំនុំជម្រះបុគ្គលទាំងអស់ដោយគ្មានការរើសអើង ព្រោះ CPI មិនកម្រិតបញ្ជីឈ្មោះបុគ្គលដែលខ្លួនបានចោទប្រកាន់(ប្រមុខរដ្ឋក្នុងតួនាទី*

*ព្រះមហាក្សត្រ ទាហាន ចារីផ្ទាល់និងមិនផ្ទាល់) ឬតុលាការសម្រាប់ប្រទេសទីម័រ។ ប៉ុន្តែ មានតែរូបវន្តបុគ្គលប៉ុណ្ណោះ(តុលាការមិនមានសមត្ថកិច្ចសម្រាប់បុគ្គលអាយុក្រោម១៨ឆ្នាំទេ[មាត្រា២៦]) តុលាការមិនអាចជំនុំជម្រះនីតិបុគ្គល និងរដ្ឋខ្លួនឯងបានឡើយ។ គួរកត់សម្គាល់ថា មាត្រា២៧ចែងថា «...ឋានៈផ្លូវការរបស់ប្រមុខរដ្ឋ ឬរដ្ឋាភិបាល(...) មិនលើកលែងបុគ្គលពីទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ខ្លួនឡើយ ទោះជាក្នុងករណីណាក៏ដោយ ពាក់ព័ន្ធនឹងលក្ខន្តិកៈនេះដូចគ្នាដែរ ឋានៈនេះមិនមែនជាមូលហេតុកាត់បន្ថយទោសក្នុងកម្រិតនោះឡើយ»។ ដូចគ្នាដែរ ទំនួលខុសត្រូវរបស់មេទ័ព និងថ្នាក់លើបន្ទាប់ផ្សេងទៀតត្រូវបានបញ្ជាក់យ៉ាងទូលំទូលាយនៅក្នុងមាត្រា២៨។*

## ២- យុត្តាធិការ«មានអ្នកទទួលការជំនុំជម្រះច្រើន»

## ២.១- *ORD* ៖ យុត្តាធិការជាកាតព្វកិច្ច និងមានអ្នកទទួលការជំនុំជម្រះច្រើន

*វិវាទដែលត្រូវចាត់ការ មានលក្ខណៈអន្តររដ្ឋ។ គឺជាតួអង្គឯកជន។ បណ្តារដ្ឋជាសមាជិកមិនបានអនុញ្ញាតឱ្យតួអង្គឯកជនប្តឹងទៅ WTO ឡើយ។ តួអង្គឯកជនអាចបញ្ជូនអ្នកជូនយោបល់តុលាការដែលជាគោលការណ៍ បានមកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលការពារបរិស្ថាន។*

*រដ្ឋទាំងឡាយនៅតែត្រូវបានចងជាប់ជាមួយលក្ខណៈអន្តររដ្ឋនៃនីតិវិធី។ ប្រសិនបើយើងលើកលែងប្រការដែលរដ្ឋអាចធ្វើឧបាស្រ័យទៅក្រុមប្រឹក្សាឯកជន(ចំណុចនេះត្រូវបានពិភាក្សានៅក្នុងរឿងក្តីរបស់សហគមន៍អឺរ៉ុប - របបដែលអនុវត្តចំពោះការនាំចូល ការលក់ និងការចែកចាយផ្លែចេក) ការចូលរួមរបស់បុគ្គលឯកជននៅក្នុងនីតិវិធីត្រូវបានកម្រិតត្រឹមលទ្ធភាពក្នុងការបញ្ជូនសារណាទៅស្ថាប័នជំនុំជម្រះហៅថា អ្នកជូនយោបល់តុលាការ ដែលស្ថាប័ននេះចាត់ចែងដោយសេរី។ ក្នុងការអនុវត្តជាក់ស្តែង អ្នកជូនយោបល់តុលាការទាំងនេះបានមកជាសំខាន់ពីសមាគមវិជ្ជាជីវៈនៃផលិតករ ឬអង្គការមិនមែនរដ្ឋាភិបាលដែលការពារបរិស្ថាន ឬសិទ្ធិមនុស្ស។*

*ការរឹតត្បិតនេះអាចត្រូវបានពន្យល់ដោយការរារែករបស់រដ្ឋមួយចំនួន ជាពិសេស ប្រទេសកំពុងអភិវឌ្ឍ។ ការរារែកនេះបានស្តែងឡើងយ៉ាងគួរឱ្យកត់សម្គាល់ នៅពេលស្ថាប័នឧទ្ធរណ៍បានសម្រេចចិត្តពឹងពាក់អ្នកជូនយោបល់តុលាការនៅក្នុងរឿងក្តីអាម្យង់។ ការពន្យល់ផ្សេងទៀតគឺថា រដ្ឋទាំងឡាយនៅតែចាប់អារម្មណ៍ខ្លាំងលើភាពសម្ងាត់នៃនីតិវិធី។*

*ហេតុអ្វីអ្នកទទួលការជំនុំជម្រះច្រើន ព្រោះអង្គការអន្តរជាតិក៏មានលទ្ធភាពទទួលបាននីតិវិធីរបស់ WTO ដែរ ឧទាហរណ៍ CE។ មិនមានលក្ខខណ្ឌតម្រូវនៃផលប្រយោជន៍ក្នុងការធ្វើសកម្មភាពដែលរដ្ឋដើមបណ្តឹងត្រូវផ្តល់ភស្តុតាងឡើយ។ ពាក្យបណ្តឹងត្រូវផ្អែកលើប្រការដែល*

រដ្ឋ«ចាត់ទុកថា អត្ថប្រយោជន៍ដែលកើតឡើងចំពោះខ្លួនដោយផ្ទាល់ ឬដោយប្រយោលពីកិច្ចព្រមព្រៀងខាងលើ ត្រូវបានស្រុះស្រួលគ្នាតាមរយៈវិធានការរបស់រដ្ឋជាសមាជិកផ្សេងទៀត» (មាត្រា៣:៣នៃអនុស្សរណៈ)។ ដើម្បីធ្វើសកម្មភាព សមាជិកណាមួយគ្រាន់តែមានផលប្រយោជន៍ពាណិជ្ជកម្មជាសក្តានុពល ដើម្បីអាចធ្វើសកម្មភាពប៉ុណ្ណោះ(វិធានដែលកំណត់នៅក្នុងរឿងក្តីរបស់សហគមន៍អឺរ៉ុប - របបដែលអនុវត្តចំពោះការនាំចូល ការលក់ និងការចែកចាយផ្លែចេក)។ ត្រូវចងភ្ជាប់ជាមួយប្រការដែលដើមបណ្តឹងនៅក្នុងនីតិវិធីនេះមិនដែលបញ្ជាក់ថាបានទទួលរង ឬទទួលរងមហន្តរាយពាណិជ្ជកម្មឡើយ។ ដើមបណ្តឹងគ្រាន់តែត្រូវបញ្ជាក់អំពីអត្ថិភាពនៃការរំលោភបំពានច្បាប់របស់ WTO ប៉ុណ្ណោះ។ ការរំលោភបំពាននេះគឺជាការសន្មតជាស្វ័យប្រវត្តិនូវការបាត់បង់ ឬនៃការកាត់បន្ថយអត្ថប្រយោជន៍។

នីតិវិធីឧទ្ធរណ៍ត្រូវបានបើកផ្លូវឱ្យតែគូភាគីនៃតុលាការដំបូងប៉ុណ្ណោះ។

ទីពីរ បណ្តារដ្ឋដែលចាប់អារម្មណ៍នឹងនីតិវិធីមានលទ្ធភាពស្នើសុំឋានៈជាតតិយភាគីដែលក្នុងការអនុវត្តជាក់ស្តែងមានភាពញឹកញាប់គួរសម ជាពិសេសពីសំណាក់មហាអំណាចពាណិជ្ជកម្មធំៗ។ តតិយភាគីទាំងនេះត្រូវលើកឡើងនូវផលប្រយោជន៍ពាណិជ្ជកម្មសំខាន់។ រដ្ឋជាតតិយភាគីនឹងធ្វើអន្តរាគមន៍ ប៉ុន្តែមិនមានលទ្ធភាពទទួលបាននីតិវិធីទាំងស្រុងដែលត្រូវបានកម្រិតដោយអនុស្សរណៈឡើយ។

ទីបី នីតិវិធីត្រូវបានបិទផ្លូវចំពោះបុគ្គលឯកជនក្នុងឋានៈជាភាគី។ ប៉ុន្តែ បុគ្គលឯកជនអាចពន្យល់អំពីការយល់ឃើញរបស់ខ្លួន តាមរយៈសារណារបស់អ្នកជូនយោបល់តុលាការ។ ត្រង់ចំណុចនេះទៀត វិធានគឺដូចគ្នានៅថ្នាក់ឧទ្ធរណ៍។

## ២.២- យុត្តាធិការអឺរ៉ុប (CEDH និង CJCE) ៖ យុត្តាធិការជាកាតព្វកិច្ច និងមានអ្នកទទួលការជំនុំជម្រះច្រើន

យុត្តាធិការអឺរ៉ុបមានលក្ខណៈសម្បូរបែបជាងគេ និងប្រែប្រួលជាងគេ ពាក់ព័ន្ធនឹងអ្នកទទួលការជំនុំជម្រះ(ទោះបីជាមានឧទាហរណ៍ជាក់លាក់នៃបាតសមុទ្រក៏ដោយ)។ ជាការពិតណាស់ រដ្ឋ នីតិបុគ្គល និងស្ថាប័នរៀបចំអាចទទួលយកយុត្តាធិការទាំងនេះបាន។ CJCE មានលក្ខណៈពេញលេញជាងគេបំផុតនៅក្នុងវិស័យនេះ។

ស្ថាប័នសហគមន៍(ក្រុមប្រឹក្សា គណៈកម្មការ សភា ព្រមទាំងធនាគារកណ្តាលអឺរ៉ុប សូម្បីតែតុលាការគណនី) និងរដ្ឋទាំងឡាយភាគច្រើនប្តឹងទៅ CJCE។ ស្ថាប័នសហគមន៍ និងរដ្ឋទាំងនោះមានវិធីប្តឹងច្រើនយ៉ាង។

- ឧបាស្រ័យសុំលុបចោល ៖ ដើមបណ្តឹងប្តឹងសុំលុបចោលលិខិតរបស់ស្ថាប័ន(បទបញ្ជា

សេចក្ដីណែនាំ សេចក្ដីសម្រេច)។

- ឧបាស្រ័យអសាធនភាព ៖ ឧបាស្រ័យនេះអនុញ្ញាតឱ្យតុលាការយុត្តិធម៌ត្រួតពិនិត្យនិត្យានុកូលភាពនៃអសកម្មភាពនៃស្ថាប័នសហគមន៍។

- ការបញ្ជូនត្រលប់បន្ទាន់បង្គំ ៖ ការបញ្ជូនត្រលប់បន្ទាន់បង្គំមានលក្ខណៈដាក់លាក់ក្នុងនីតិសហគមន៍។ គឺជាករណីដែលក្នុងនោះចៅក្រមជាតិអាចបែរទៅរកតុលាការយុត្តិធម៌ ដើម្បីស្នើសុំឱ្យបញ្ជាក់ចំណុចបកស្រាយនៃនីតិសហគមន៍ ដើម្បីអនុញ្ញាតឱ្យខ្លួនផ្ទៀងផ្ទាត់អនុលោមភាពតាមនីតិនេះនៃច្បាប់ជាតិរបស់ខ្លួន។

បុគ្គលម្នាក់ៗអាចប្ដឹងទៅតុលាការក្រោមលក្ខខណ្ឌមួយចំនួនបាន។

CEDH ខុសប្លែកពីគេដោយសារសមត្ថកិច្ចយុត្តាធិការជាកាតព្វកិច្ចដែល CEDH អនុវត្តទៅលើការប្ដឹងរបស់រដ្ឋ ក៏ដូចជាទៅលើការប្ដឹងរបស់បុគ្គលម្នាក់ៗ។ រដ្ឋណាមួយអាចប្ដឹងរដ្ឋមួយផ្សេងទៀតបាន។ សិទ្ធិឧបាស្រ័យរបស់រដ្ឋ( មាត្រា២៤)ត្រូវបានបើកចំពោះរដ្ឋទាំងអស់ប្រឆាំងនឹងរដ្ឋណាមួយ និងអាច បើមានការចាំបាច់ មានទម្រង់ជាបណ្ដឹងអាជ្ញា។ រឿងក្ដីល្បីជាងគេគឺរឿងក្ដីប្រឆាំងនឹងការធ្វើទារុណកម្ម ៖ ដែលប្ដឹងដោយប្រទេសបារាំង ន័រវែស ដាណឺម៉ាក ស៊ុយអែត ហូឡង់ ប្រឆាំងនឹងប្រទេសតួគីនៅឆ្នាំ១៩៨៣។ ក៏ប៉ុន្តែ មានតែរឿងក្ដីរវាងប្រទេសអៀរឡង់ និងព្រះរាជាណាចក្រអង់គ្លេសដែលប្ដឹងនៅឆ្នាំ១៩៧១ប៉ុណ្ណោះ បានធ្វើឱ្យមានសាលដីកាចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨។ CEDH ត្រូវបានគេស្គាល់ដោយសារសិទ្ធិប្ដឹងរបស់បុគ្គលម្នាក់ៗប្រឆាំងនឹងរដ្ឋ( មាត្រា២៥)។

ត្រូវរំឭកឡើងវិញផងដែរថា ការប្ដឹងទៅ CEDH នាំឱ្យរលត់ផ្លូវឧបាស្រ័យក្នុងប្រទេសដែលជាលក្ខខណ្ឌនៃភាពអាចទទួលយកបាននៃពាក្យបណ្ដឹង។ ត្រង់ចំណុចនេះទៀតសោត ពិធីសារលេខ១៤ព្យាករណ៍ថា ពាក្យបណ្ដឹងអាចត្រូវបានបដិសេធផងដែរ ប្រសិនបើដើមបណ្ដឹងមិនបានទទួលរងមហន្តរាយធំដុំទេ។ មានកាលកំណត់ចំនួន៦ខែសម្រាប់ដាក់ពាក្យបណ្ដឹង។

## ២.៣- TIDM ៖ ប្រព័ន្ធកូនកាត់នៃយុត្តាធិការជាកាតព្វកិច្ច និងតាមការព្រមព្រៀងមានអ្នកទទួលការជំនុំជម្រះច្រើន

គឺជាយុត្តាធិការអន្តររដ្ឋ ដូចគ្នានឹងតុលាការយុត្តិធម៌អន្តរជាតិដែរ ព្រោះថា យុត្តាធិការនេះអាចមានសមត្ថកិច្ចជំនុំជម្រះវិវាទដែលត្រូវបានដាក់មកដោយរដ្ឋទាំងឡាយ។ ក៏ប៉ុន្តែ យុត្តាធិការនេះមានលក្ខណៈពិសេសមួយចំនួន ព្រោះថា យុត្តាធិការនេះក៏ទទួលបុគ្គលឯកជនក្នុងករណីមួយចំនួនផងដែរ( អង្គជំនុំជម្រះដើម្បីដោះស្រាយវិវាទទាក់ទងនឹងបាតសមុទ្រ) ព្រមទាំងអង្គការអន្តរជាតិ( សហគមន៍អឺរ៉ុបដែលបានបញ្ជូនវិវាទរួចហើយទៅកាន់ TIDM ជាមួយនឹង

*រឿងក្ដីដែលពាក់ព័ន្ធនឹងការអភិរក្ស និងការធ្វើអាជីវកម្មយូរអង្វែងនូវស្តុកត្រីអេស្ប៉ាដុង នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិចភាគអាគ្នេយ៍ដែលតទល់ជាមួយប្រទេសឈីលី)។ គឺជាការចូលទៅក្នុងវិវាទរបស់អង្គការអន្តរជាតិ ជាអ្វីដែល CIJ មិនអាចទទួលយក អនុលោមតាមមាត្រា៣៤នៃលក្ខន្តិកៈរបស់ខ្លួនដែលរក្សាសាលាក្តីរបស់ខ្លួននៅក្នុងរដ្ឋទាំងឡាយ។ ដូចគ្នាដែរ រឿងក្តីនេះនឹងអនុញ្ញាតឱ្យតុលាការបង្កើតជាលើកដំបូងនូវអង្គជំនុំជម្រះពិសេសទទួលបន្ទុកដោះស្រាយវិវាទ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក១៦
# សមត្ថកិច្ច និងភាពអាចទទួលយកបាននៅចំពោះមុខយុត្តាធិការអន្តរជាតិ

## ផ្នែកទី១
## សមត្ថកិច្ច

*បញ្ហាសមត្ថកិច្ចរបស់យុត្តាធិការគឺជាបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ជាងគេបំផុតនានា។ រដ្ឋចុងចម្លើយ(ត្រូវបានចោទប្រកាន់)តែងតែប្ដឹងជំទាស់នឹងសមត្ថកិច្ចរបស់យុត្តាធិការជាញឹកញាប់ ដើម្បីរារាំងកុំឱ្យរឿងក្ដីបន្តទៅមុខរួច។*

*សមត្ថកិច្ចរបស់យុត្តាធិការតំណាងឱ្យការផ្ដល់នីតិសម្បទាដល់យុត្តាធិការអន្តរជាតិក្នុងការស៊ើបសួរ និងជំនុំជម្រះរឿងក្ដី។ គឺយុត្តាធិការខ្លួនឯងផ្ទាល់ដែលនឹងសម្រេចចិត្តអំពីសមត្ថកិច្ចរបស់ខ្លួនផ្ទាល់ ៖ «សមត្ថកិច្ចនៃសមត្ថកិច្ចរបស់ខ្លួន» យោងតាមមាត្រា៣៦.៦នៃលក្ខន្តិកៈ។*

### ១- ទម្រង់ផ្សេងៗនៃសមត្ថកិច្ច
### ១.១- ក្របខ័ណ្ឌទូទៅ

*សម្រាប់ CIJ ការក្លាយជាភាគីនៃលក្ខន្តិកៈអនុញ្ញាតឱ្យរដ្ឋទាំងឡាយដាក់វិវាទទៅតុលាការ ប៉ុន្តែមិនបង្ខំឱ្យរដ្ឋធ្វើដូច្នេះទេ។ គោលការណ៍គឺ និងនៅតែជា យុត្តាធិការវិវាទរបស់តុលាការគឺតាមការព្រមព្រៀង។ ដូច្នេះ សមត្ថកិច្ចរបស់តុលាការសន្មតអត្ថិភាពនៃការសន្យាផ្នែកយុត្តាធិការពីសំណាក់បណ្ដារដ្ឋពាក់ព័ន្ធ។ សមត្ថកិច្ចនេះនឹងរកឃើញព្រំដែនរបស់ខ្លួននៅក្នុងព្រំដែនដែលត្រូវបានផ្ដល់ដល់វិសាលភាពនៃការសន្យានេះ។ ព្រំដែនទាំងនេះអាចមានប្រភេទតាមបុគ្គលសត្យានុម័ត តាមពេលវេលា ឬតាមទីកន្លែង។*

*ប្រសិនបើមិនមានព្រំដែនពាក់ព័ន្ធនឹងសមត្ថកិច្ចសត្យានុម័តរបស់តុលាការ(វិស័យដែល*

*ក្នុងនោះតុលាការអាចជំនុំជម្រះបាន)ទេ គឺជាសមត្ថកិច្ចទូលំទូលាយ មាត្រា៣៨។ ព្រំដែនពិតប្រាកដមានលក្ខណៈវិនិច្ឆ័យចំនួនពីរ ៖ តើនរណាប្ដឹងទៅតុលាការ មានន័យថា សមត្ថកិច្ចតាមបុគ្គល និងម្យ៉ាងទៀត តើតុលាការត្រូវបានប្ដឹងយ៉ាងដូចម្ដេច របៀបប្ដឹងដែលអាចមាន។*

*តាមរបៀបដូចគ្នា វាមិនសូវចាំបាច់ដែលត្រូវពិភាក្សាអំពី TIDM ឬ ORD ឡើងវិញទេ ព្រោះថា ដោយលើកឡើងអំពីអ្នកទទួលការជំនុំជម្រះដែលអាចមាន យើងបានលើកឡើងរួចហើយអំពីសមត្ថកិច្ចរបស់យុត្តាធិការទាំងនេះ។ គ្រាន់តែចងចាំថា ៖*

*TIDM មានសមត្ថកិច្ច យោងតាមមាត្រា២៨៨នៃអនុសញ្ញាឆ្នាំ១៩៨២លើរាល់វិវាទទាំងអស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញាក្រុងម៉ុងតេហ្គោបេ។ ORD មានសមត្ថកិច្ចដោយផ្អែកលើមាត្រា២៣ៈ១នៃអនុស្សរណៈ ចាប់ពីពេលដែលរដ្ឋណាមួយអះអាងថាខ្លួនគឺជាជនរងគ្រោះនៃមហន្តរាយនៅក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ឬនៃការរំលោភបំពានកាតព្វកិច្ច។*

## ១.២- យុត្តាធិការព្រហ្មទណ្ឌ

*យើងនឹងបែងចែកស្ថានភាពរបស់ TPIY ពីស្ថានភាពរបស់ CPI។*

### ១.២.១- TPIY

*ជារួម TPIY មានសមត្ថកិច្ចស្របតាមនីតិអន្តរជាតិមនុស្សធម៌តាមទម្លាប់ដែលនីតិនេះត្រូវបានចែងនៅក្នុងអត្ថបទផ្សេងៗ ៖ អនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (នីតិសង្គ្រាម) អនុសញ្ញាក្រុងឡាអេ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩០៧ អនុសញ្ញាស្ដីពីការទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨(ដែលចែងអំពីតុលាការដែលមិនដែលត្រូវបានបង្កើតឡើងទាល់តែសោះ) និងលក្ខន្តិកៈរបស់តុលាការក្រុងនុយរ៉េមប៊ែរ ដែលបានមកពីកិច្ចព្រមព្រៀងក្រុងឡុងដ៍ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៤៥(អត្ថបទតែមួយគត់ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។*

*សមត្ថកិច្ចផ្សេងៗរបស់តុលាការ តាមការបែងចែកតាមទឹកដី តាមពេលវេលា សត្យានុម័ត និងតាមបុគ្គល។*

*សមត្ថកិច្ចតាមទឹកដី ៖ តុលាការមានសមត្ថកិច្ចលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅលើដែនដីនៃអតីតប្រទេសយូហ្គោស្លាវី។*

*សមត្ថកិច្ចតាមពេលវេលា ៖ តុលាការមានសមត្ថកិច្ចតែលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩១ដែលយោងតាមក្រុមប្រឹក្សាសន្តិសុខ សម្គាល់នូវការចាប់ផ្ដើមនៃអរិភាព(កាលបរិច្ឆេទសំខាន់គឺកាលបរិច្ឆេទថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩១)។*


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សមត្ថកិច្ចសត្យានុម័ត ៖ ឧក្រិដ្ឋកម្មទាំងអស់នៅក្នុងអនុសញ្ញា គឺជាសមត្ថកិច្ចរបស់តុលាការ។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានពណ៌នានៅក្នុងអនុសញ្ញាធំៗដែលយើងបានលើកឡើងកាលពីខាងដើម។ អនុសញ្ញាទាំងបួនធ្វើជាមូលដ្ឋាន។ ប៉ុន្តែ ទោះបីជារដ្ឋទាំងឡាយមិនមែនជាភាគីនៃអនុសញ្ញានេះក៏ដោយ ក៏តុលាការមានសមត្ថកិច្ចដែរ ព្រោះក្រុមប្រឹក្សាសន្តិសុខបានយកចិត្តទុកដាក់ (នៅក្នុងលក្ខន្តិកៈ)ក្នុងការបញ្ជាក់ទទួលយកលក្ខណៈជាទម្លាប់នៃការទទួលស្គាល់ឧក្រិដ្ឋកម្មដែលមាននៅក្នុងអនុសញ្ញាផ្សេងៗ។

អនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ គឺជាមូលដ្ឋាននៃនីតិមនុស្សធម៌អន្តរជាតិ។ អនុសញ្ញាទាំងនេះលើកឡើងពីសារៈសំខាន់នៃវិធាន ដែលអាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ។ ការយល់ឃើញរបស់ពួកគេមានលក្ខណៈតែមនុស្សធម៌ប៉ុណ្ណោះ និងមានគោលបំណងការពារបុគ្គលប្រភេទមួយចំនួន។ អនុសញ្ញាទាំងនេះផ្តោតលើអ្នករបួស និងអ្នកជំងឺនៃកងកម្លាំងប្រដាប់អាវុធក្នុងយុទ្ធនាការ។ អ្នករងរបួស អ្នកជំងឺ និងអ្នកលិចកប៉ាល់នៃកងកម្លាំងជើងទឹក។ ការប្រព្រឹត្តចំពោះជនជាប់ឃុំដោយសារសង្គ្រាម និងការការពារជនស៊ីវិលក្នុងសម័យសង្គ្រាម។

អនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩០៧(IV) ស្តីពីការរំលោភច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមលើដី គឺជាអ្វីដែលគេហៅថា «នីតិអាជ្ញាសឹក»។ មានចំណុចដូចគ្នាជាមួយនឹងអនុសញ្ញាក្រុងហ្សឺណែវ។ ប៉ុន្តែ អនុសញ្ញាក្រុងឡាអេយកចិត្តទុកដាក់ខ្លាំងជាពិសេសទៅលើយុទ្ធការី។ អនុសញ្ញាក្រុងឡាអេទទួលស្គាល់ជាពិសេសថា ការប្រើប្រាស់វិធីសាស្រ្តមួយចំនួនត្រូវបានហាមឃាត់។ មាត្រា៣នៃលក្ខន្តិកៈរបស់តុលាការដកស្រង់នូវការរំលោភបំពានសំខាន់ៗ ៖ ការប្រើប្រាស់អាវុធជាតិគីមី ការបំផ្លិចបំផ្លាញទីក្រុង ឬភូមិនានាដោយគ្មានហេតុផល ការទម្លាក់គ្រាប់បែក ឬការវាយប្រហារទីក្រុង ឬភូមិនានាដែលគ្មានការការពារ ការបំផ្លិចបំផ្លាញសំណង់អគារសាសនាបូជនីយដ្ឋានប្រវត្តិសាស្រ្ត គ្រឹះស្ថានអប់រំដោយគ្មានមូលហេតុ និងជារួម ការប្លន់ទ្រព្យសម្បត្តិសាធារណៈ ឬឯកជន។

អនុសញ្ញាឆ្នាំ១៩៤៨ស្តីពីការបង្ការ និងការបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានលក្ខណៈទូលំទូលាយណាស់។ អំពើប្រល័យពូជសាសន៍អាចត្រូវបានផ្តន្ទាទោស ប្រសិនបើវាកើតឡើងក្នុងពេលមានសន្តិភាព ឬសង្គ្រាម។ ការញុះញង់ឱ្យមានអំពើបែបនេះ ការប៉ុនប៉ង ឬការសមគំនិតដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ អាចត្រូវបានផ្តន្ទាទោស។

សមត្ថកិច្ចតាមបុគ្គល ៖ TPIY មិនជំនុំជម្រះរដ្ឋទេ ប៉ុន្តែជំនុំជម្រះតែបុគ្គលដែលអាចផ្តន្ទាទោសប៉ុណ្ណោះ។ គឺត្រូវជំនុំជម្រះបុគ្គលដែលត្រូវបានសន្មតថាជាអ្នកទទួលខុសត្រូវចំពោះការរំលោភបំពានធ្ងន់ធ្ងរលើនីតិអន្តរជាតិមនុស្សធម៌។ បញ្ហាគឺត្រូវដឹងថា តើនរណាអាចជា«បុគ្គលដែលត្រូវបានសន្មតថា ជាអ្នកទទួលខុសត្រូវ»។ ក្នុងស្ថានភាពបច្ចុប្បន្ននៃនីតិអន្តរជាតិ គេមិន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាចជំនុំជម្រះរដ្ឋបានឡើយ។ គេអាចជំនុំជម្រះបានតែបុគ្គលដាច់ដោយឡែកពីគ្នាប៉ុណ្ណោះ។ ក្នុងន័យនេះ ការទទួលខុសត្រូវរួមគ្នាត្រូវបានច្រានចោល។ តុលាការមិនជំនុំជម្រះដោយកំបាំងមុខទេ សូម្បីតែបច្ឆាមរណៈក៏ដោយ។

យោងតាមមាត្រា៧នៃលក្ខន្តិកៈរបស់តុលាការ បុគ្គលទាំងនេះអាចជាបុគ្គលដែលបានរៀបចំផែនការញុះញង់ឱ្យប្រព្រឹត្ត បង្គាប់ ឬប្រព្រឹត្តឧក្រិដ្ឋកម្មខាងលើ។ ចំណុចនេះអាចរួមបញ្ចូលអ្នកធ្វើការសម្រេចចិត្តខាងនយោបាយ(ឧទាហរណ៍ Karadzic) ថ្នាក់លើផ្ទាល់ដែលបានចេញបញ្ជា(ឧទាហរណ៍ Mladic) ឬអ្នកក្រោមបង្គាប់ ឬអ្នកអនុវត្ត(គឺជាករណី Tadic)។ ដូច្នេះជាសកល ប្រហែលជាមានការទទួលខុសត្រូវចំនួនបីកម្រិតដែលក្តោបជាចុងក្រោយលើតួអង្គទាំងអស់ដែលអាចមាននៃសោកនាដកម្មនេះ។

អ្នកធ្វើសេចក្តីសម្រេចចិត្តគឺជាអ្នកដែលបានរៀបចំផែនការឧក្រិដ្ឋកម្មប្រកបដោយសម្បជញ្ញៈដើម្បីសម្រេចគោលដៅនយោបាយប្រកបដោយសម្បជញ្ញៈ ៖ ប្រមុខរដ្ឋ អ្នកអនុវត្តអំណាចរដ្ឋាភិបាល ឬមន្ត្រីជាន់ខ្ពស់។ ដូច្នេះ មិនមែនជាតួអង្គផ្ទាល់នៃឧក្រិដ្ឋកម្មទេ ប៉ុន្តែជាតួអង្គប្រយោល។

ចំពោះការបញ្ជាតាមឋានានុក្រម គឺត្រូវរួមបញ្ចូលទាំងអ្នកដែលបានចេញបញ្ជាដោយផ្ទាល់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ តាមរបៀបដូចគ្នានឹងអ្នកដែលបានអនុវត្តបញ្ជាដែរ។ ការធ្វើដូច្នេះផ្តោតទៅលើការបញ្ជាផ្នែកយោធាផង លើស្ថាប័ននៃការបញ្ជាស៊ីវិលផង។

## ១.២.២- តុលាការឧក្រិដ្ឋកម្មអន្តរជាតិ

ការពិភាក្សាបានផ្តោតទៅលើបញ្ហាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ។ យើងសង្កេតឃើញនូវភាពស្រដៀងគ្នាមួយចំនួនជាមួយនឹង TPIY សម្រាប់សមត្ថកិច្ចតាមបុគ្គល។ CPI មានសមត្ថកិច្ចធ្វើការចោទប្រកាន់រាល់បុគ្គលដែលជាប្រមុខរដ្ឋ ឬព្រះមហាក្សត្រដោយផ្ទាល់ ឬប្រយោល។

ពាក់ព័ន្ធនឹងសមត្ថកិច្ចតាមពេលវេលា តុលាការមានសមត្ថកិច្ចតែទៅលើអំពើដែលបង្កើតបានជាឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួនដែលត្រូវបានប្រព្រឹត្តក្រោយការចូលជាធរមាននៃលក្ខន្តិកៈរបស់ខ្លួនប៉ុណ្ណោះ(មាត្រា១១)។

សមត្ថកិច្ចតាមទីកន្លែងគឺអាស្រ័យលើការយល់ព្រមទទួលយករបស់រដ្ឋទាំងឡាយ។ ជាការពិតណាស់ រដ្ឋមួយដែលក្លាយជាភាគីនៃលក្ខន្តិកៈយល់ព្រមទទួលយកសមត្ថកិច្ចរបស់តុលាការចំពោះឧក្រិដ្ឋកម្មដែលត្រូវបានកំណត់ដោយលក្ខន្តិកៈរបស់ខ្លួន។ អាស្រ័យតាមការចោទប្រកាន់ដែលធ្វើឡើង ប្រសិនបើការយល់ព្រមទទួលយករបស់រដ្ឋមិនមែនជាភាគីនៃលក្ខន្តិកៈមានភាពចាំបាច់ រដ្ឋនោះអាច តាមរយៈសេចក្តីប្រកាសដែលដាក់នៅការិយាល័យក្រឡាបញ្ជី យល់ព្រមទទួលយកតុលាការនេះ។ ដូច្នេះ រដ្ឋដែលបានយល់ព្រមទទួលយកសមត្ថកិច្ចនេះ ត្រូវសហ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រតិបត្តិការជាមួយតុលាការ។ តុលាការមិនមានសមត្ថកិច្ចសកលទេ ប៉ុន្តែតុលាការគឺអាស្រ័យលើរដ្ឋនៃសញ្ជាតិរបស់បុគ្គលដែលត្រូវបានចោទប្រកាន់ និង/ឬលើរដ្ឋនៃទីកន្លែងប្រព្រឹត្តបទល្មើស។

សមត្ថកិច្ចសត្យានុម័ត តុលាការមានសមត្ថកិច្ច ដូចមានចែងដោយលក្ខន្តិកៈរបស់ខ្លួន ៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មឈ្លានពាន។ ឧក្រិដ្ឋកម្មខាងលើមិនមានអាជ្ញាយុកាលទេ( មាត្រា២៩)។

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានឱ្យនិយមន័យថា ជាអំពើដែលប្រព្រឹត្តក្នុងចេតនាបំផ្លាញក្រុមពលរដ្ឋ ក្រុមជនជាតិភាគតិច ឬក្រុមសាសនាទាំងអស់ ឬមួយផ្នែក តាមរយៈការសម្លាប់ ការវាយប្រហារដល់បូរណភាពផ្លូវកាយ ឬផ្លូវចិត្ត ការដាក់លក្ខខណ្ឌនៃការរស់នៅអមនុស្សធម៌ វិធានការដែលមានគោលដៅរាំងការកើត ឬការផ្ទេរកូនដោយបង្ខំ( មាត្រា៦)។

មាត្រា៧ចែងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្តោតលើប្រភេទអំពើដែលប្រព្រឹត្តដោយដឹងព្រឹត្តិការណ៍ ក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ប្រឆាំងនឹងប្រជាជនស៊ីវិល។ អំពើទាំងនេះអាចជាឃាតកម្ម ការសម្លាប់ផុតពូជ ការបង្ក្រាបឱ្យទៅជាទាសករ ការជម្លៀស ឬការផ្ទេរប្រជាជនដោយកម្លាំង ការឃុំឃាំង ការរំលោភសន្ថវៈ ទាសភាពផ្លូវភេទ អំពើពេស្យាកម្មបង្ខំ ការមានគភ៌ដោយបង្ខំ ការធ្វើឱ្យគ្មានកូនដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬការញែកពូជសាសន៍។

ឧក្រិដ្ឋកម្មសង្គ្រាមសំដៅដល់អំពើដែលផ្ទុយនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ឬច្បាប់ និងទំនៀមទម្លាប់សង្គ្រាមជាធរមានផ្សេងទៀតនៅក្នុងច្បាប់អន្តរជាតិ ៖ ឃាតកម្ម ការធ្វើទារុណកម្ម ការប្រព្រឹត្តមកលើខ្លួនដោយអមនុស្សធម៌ ការជម្លៀស ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ការចាប់ចំណាប់ខ្មាំង ការវាយប្រហារទៅលើប្រជាជនស៊ីវិល ទាហាននៅក្រៅសមរភូមិ ការបំផ្លាញទ្រព្យសម្បត្តិ និងការលួចប្លន់ ការរំលោភសន្ថវៈ និងអំពើហិង្សាផ្លូវភេទ ការចាប់កូនក្មេងអាយុក្រោមដប់ប្រាំឆ្នាំធ្វើទាហាន។ វាអាចជាអំពើនៅដាច់ដោយឡែក។

ឧក្រិដ្ឋកម្មឈ្លានពានមានចែងនៅក្នុងលក្ខន្តិកៈនេះ។ និយមន័យនៃពាក្យ«ឈ្លានពាន» តែងតែបង្កឱ្យមានប្រធានបទនៃការពិភាក្សារវាងរដ្ឋ និងរដ្ឋ។

សមត្ថកិច្ចតាមបុគ្គល ៖ មានតែរូបវន្តបុគ្គលប៉ុណ្ណោះត្រូវបានផ្តោត លើកលែងនីតិបុគ្គល និងរដ្ឋ( មាត្រា២៨)។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិមិនជំនុំជម្រះដោយកំបាំងមុខទេ។

## ២- បញ្ហានៃការលើកលែងជាមុនក្នុងផ្នែកវិវាទ

## ២.១- បញ្ហាផ្សព្វផ្សាយការលើកលែងជាមុន

បញ្ហាការលើកលែងជាមុនមានសារៈសំខាន់បំផុតនៅក្នុងក្របខ័ណ្ឌនៃយុត្តាធិការអន្តរជាតិ

ព្រោះរដ្ឋអាចជំទាស់បាន។ CIJ ត្រូវបានសម្គាល់ដោយសមត្ថកិច្ចដែលត្រូវបានព្រមព្រៀង។

ចំពោះយុត្តាធិការដូច ORD ជាដើម ការលើកលែងជាមុនមិនសំខាន់ទេ ព្រោះវាចារឹកនៅក្នុងអនុសញ្ញា។

ផ្ទុយមកវិញ អញ្ញត្រកម្មនេះចោទឡើងនៅចំពោះមុខ TIDM ព្រោះវាមានឱកាសនៅក្នុងរឿងក្ដីជាច្រើនក្នុងការលើកឡើងនូវបញ្ហាសមត្ថកិច្ចជាដំបូងបំផុត។ ជាក់ស្ដែង នៅក្នុងសាលដីការបស់ខ្លួនចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៩៧ ក្នុងរឿងក្ដី Saiga TIDM ពិចារណាយ៉ាងយូរទៅលើសមត្ថកិច្ចរបស់ខ្លួន ព្រោះការអនុវត្តមាត្រា២៩២ សន្មតថា TIDM ពិនិត្យមើលសមត្ថកិច្ចនេះ។ ក្នុងករណីពិសេសនេះ TIDM វិនិច្ឆ័យថា ខ្លួនមានសមត្ថកិច្ច ព្រោះថា ពាក្យបណ្ដឹងដែលផ្អែកលើមាត្រា២៩២អាចត្រូវបានប្ដឹងទៅតុលាការក្នុងរយៈពេលដប់ថ្ងៃ គិតចាប់ពីពេលចាប់នាវាដែលជាករណីនេះ។

យុត្តាធិការព្រហ្មទណ្ឌមិនព្រងើយកន្តើយចំពោះការលើកលែងអសមត្ថកិច្ចទេ ប៉ុន្តែការលើកលែងនេះមិនបង្ហាញឡើងតាមរបៀបនេះឡើយ ព្រោះបញ្ហាសមត្ថកិច្ចកើតឡើងក្នុងអំឡុងពេលរឿងក្ដី និងមិនដូចដំណាក់កាលដាច់ដោយឡែកពីគ្នាទេ។

នៅចំពោះមុខយុត្តាធិការអឺរ៉ុប ជាថ្មីម្ដងទៀត បញ្ហាការលើកលែងជាមុនមិនចោទឡើងបែបនេះទេ។ ម៉្យាង ជាចុងក្រោយ CEDH មានសមត្ថកិច្ចជំនុំជម្រះតែបញ្ហាជាក់ស្ដែងនៃភាពអាចទទួលយកបាននៃពាក្យបណ្ដឹងដាច់ដោយឡែកប៉ុណ្ណោះ ហើយប្រព័ន្ធត្រួតពិនិត្យរបស់ខ្លួនមិនមែនជាប្រព័ន្ធអញ្ញត្រកម្មជាមុនទេ។ ម៉្យាងទៀត CJCE ក្នុងឋានៈជាយុត្តាធិការជាកាតព្វកិច្ចក៏មិនប្រឈមមុខនឹងបញ្ហាច្បាស់លាស់នេះដែរ។ ត្រង់ចំណុចនេះទៀតសោត និងក៏ដូចជាសម្រាប់ CEDH ដែរ វាមានភាពសមស្របក្នុងការពិចារណាទៅលើបញ្ហានៃភាពអាចទទួលយកបាននៃពាក្យបណ្ដឹងជាងទៅលើអសមត្ថកិច្ច ព្រោះអសមត្ថកិច្ចមិនដែលត្រូវបានលើកឡើងឡើយ ដូចត្រូវបានបញ្ជាក់ដោយការសិក្សាអំពីវិវាទសហគមន៍។

## ២.២- ការលើកលែងជាមុននៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ

តុលាការអាចមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីមួយបាន លុះត្រាតែលក្ខខណ្ឌដែលចោទឡើងដោយលក្ខន្តិកៈរបស់ខ្លួនក៏ដូចជាដោយភាគីមានភាពគួរឱ្យពេញចិត្ត។ ការពិនិត្យមើលបញ្ហាទាំងនេះដែលធ្វើឡើងតាមការស្នើសុំរបស់គូភាគី ឬតាមការកំណត់របស់តុលាការ ត្រូវធ្វើឡើងជាបឋម ក្រោមទម្រង់ជាបញ្ហា ឬអញ្ញត្រកម្ម(អញ្ញត្រកម្មគឺត្រូវបដិសេធសមត្ថកិច្ច)។

ក្នុងចំណោមរឿងក្ដីទាំងអស់ រឿងក្ដីជិតបីភាគបួនដែលដាក់មកតាមរយៈពាក្យបណ្ដឹង បានជួបប្រទះនឹងការលើកលែងជាមុន និងមួយភាគបីក្នុងចំណោមនោះមិនអាចឆ្លងផុតឧបសគ្គនេះ

បានឡើយ។ ពាក្យបណ្ដឹង(ធ្វើឡើងជាឯកតោភាគី)។

យោងតាមអ្វីដែលតុលាការបានសម្រេច និងចុះនៅក្នុងបទបញ្ជារបស់ខ្លួន(មាត្រា៧៩ កថាខណ្ឌទី៣) ការបញ្ចូលការលើកលែងជាមុនអាចធ្វើឱ្យនីតិវិធីដល់អង្គសេចក្ដី(បញ្ហាអង្គច្បាប់) ត្រូវបានផ្អាករហូតទាល់តែនីតិវិធីនេះត្រូវបានប្រកាស។ លិខិតបញ្ចូលការលើកលែងត្រូវគោរពតាមទម្រង់(នីតិវិធី)ដែលចាំបាច់(សូមមើលមាត្រា៧៩នៃបទបញ្ជា និងសៀវភៅលេខ៣០)។

ប៉ុន្តែ វិធាននៃចរិតលក្ខណៈជាមុនជួបនឹងការលើកលែងមួយ គឺការលើកលែងនៃសេចក្ដីសម្រេចដល់អង្គសេចក្ដី។ សេចក្ដីសម្រេចនេះអាចកើតឡើងពីការព្រមព្រៀងគ្នារវាងគូភាគីដែលមានបំណងចង់ឱ្យការលើកលែងត្រូវបានសម្រេចសេចក្ដីនៅក្នុងពេលពិនិត្យដល់អង្គសេចក្ដី។ មាត្រា៧៩ កថាខណ្ឌទី៨នៃបទបញ្ជាចែងថា តុលាការផ្ដល់អានុភាពដល់កិច្ចព្រមព្រៀងបែបនោះ។ ប៉ុន្តែ ការវិវត្តនៃតួនាទីរបស់តុលាការហាក់ដូចជាដើរទៅតាមទិសនៃការលើកលែងទាំងស្រុង យ៉ាងហោចណាស់នៃការកំហិតយ៉ាងដាច់ខាតនៃសម្មតិកម្មនៃសេចក្ដីសម្រេចអំពីការលើកលែងជាមុនដល់អង្គសេចក្ដី។ តាមពិត គុណវិបត្តិនៃការអនុវត្តនេះបានលេចឡើងយ៉ាងច្បាស់ ដោយបណ្ដាលឱ្យមានប្រតិកម្មជាគោលការណ៍។ ជាការពិតណាស់ វាមានភាពងាយស្រួលក្នុងការដឹងអំពីការវិនិច្ឆ័យខុសលើស្ថានភាពរបស់តុលាការ ក្នុងករណីដែលបន្ទាប់ពីបានភ្ជាប់ការលើកលែងជាមុនដល់អង្គសេចក្ដីរួច និងបានដាក់ដំណាក់កាលបន្ថែមនៃនីតិវិធី តុលាការអាចកាត់សេចក្ដីលើរឿងក្ដីតែអាស្រ័យតាមការលើកលែងជាមុននេះប៉ុណ្ណោះ និងដោយរក្សាការលើកលែងជាមុននេះដូច្នេះ ប្រានចោលពាក្យបណ្ដឹង។ ការលើកលែងជាមុននេះត្រូវបានបង្ហាញយ៉ាងគួរឱ្យភ្ញាក់ផ្អើលដោយរឿងក្ដី Barcelona Traction និងត្រូវបានបដិសេធយ៉ាងទូលំទូលាយនៅពេលនោះ។

# ផ្នែកទី២

## ភាពអាចទទួលយកបាន

ភាពអាចទទួលយកបានមិនចោទជាបញ្ហាធ្ងន់ធ្ងរ ដូចនៅតុលាការយុត្តិធម៌អន្តរជាតិទេ។ យុត្តាធិការផ្សេងៗនឹងមិនត្រូវបានពិនិត្យពិចារណាឡើយ ព្រោះបញ្ហានៃភាពអាចទទួលយកបានមិនចោទឡើង ឬមិនបានចោទឡើងនៅក្នុងយុត្តិសាស្ត្របច្ចុប្បន្នឡើយ។ ដូច្នេះ វាសមស្របសម្រាប់ TIDM ព្រមទាំង ORD។

ភាពអចិន្ត្រៃយ៍ សមាសភាព និងរចនាសម្ព័ន្ធនៃយុត្តាធិការអន្តរជាតិ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១- ភាពអាចទទួលយកបាននៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ

*មូលហេតុដែលអាចជំទាស់នឹងប្រការដែលតុលាការមានសមត្ថកិច្ចលើរឿងក្តីមានច្រើន និង ចម្រុះ។ មូលហេតុមួយចំនួនមានលក្ខណៈនីតិវិធី។ មូលហេតុមួយចំនួនទៀតមានការទាក់ទង នឹងកម្មវត្ថុនៃពាក្យបណ្តឹង(ដែលយុត្តាធិការអន្តរជាតិត្រូវកាត់សេចក្តី)។ ទោះបីជាយ៉ាងណាក៏ ដោយ គឺនៅក្នុងសម្មតិកម្មនៃការប្តឹងតាមរយៈពាក្យបណ្តឹងទើបតុលាការអាចពិនិត្យមើលការ បំពេញតាមលក្ខខណ្ឌនៃភាពអាចទទួលយកបាន។ យើងអាចលើកឡើងនូវចំណុចសំខាន់ដូច តទៅ ៖*

*- ភាពជាន់គ្នានៃសមត្ថកិច្ច ៖ ការលើកលែងនៃភាពជាន់គ្នានៃសមត្ថកិច្ច មានគោលបំណង បញ្ចៀសទំនាស់នៃសេចក្តីសម្រេចរបស់ចៅក្រម។ មានន័យថា សាលាក្តីមួយទៀតផ្សេងពីតុលាការ បានទទួលពាក្យបណ្តឹងចំពោះវិវាទដដែលរួចហើយ។ ភាពជាន់គ្នានៃសមត្ថកិច្ច មានគោលបំណង កំហិតទំនាស់នៃសេចក្តីសម្រេចរបស់ចៅក្រមរវាងសាលាក្តីដែលបានទទួលពាក្យបណ្តឹងមុន តុលាការ និងតុលាការ។*

*- ការហួសសិទ្ធិប្តឹងដោយសារការយឺតយ៉ាវ ៖ កាលកំណត់បានបញ្ចប់។ លក្ខន្តិកៈរបស់ តុលាការមិនចែងអំពីកាលកំណត់នៃការហួសសិទ្ធិប្តឹង សម្រាប់ការដាក់ពាក្យបណ្តឹងឧបាស្រ័យ ទេ ប៉ុន្តែ រដ្ឋទាំងឡាយអាចបញ្ចូលកាលកំណត់ប្រភេទនេះនៅក្នុងសេចក្តីប្រកាសរបស់ខ្លួននៃ មាត្រា៣៦ កថាខណ្ឌទី២ ឬនៅក្នុងកិច្ចសម្របសម្រួល។ ប្រសិនបើដើមបណ្តឹងមិនប្តឹងទៅតុលាការ ក្នុងរយៈពេលសមស្រប ចុងចម្លើយអាចលើកឡើងនូវបញ្ហាការហួសសិទ្ធិប្តឹងដោយផ្អែកលើគោល-ការណ៍នៃការមិនទទួលបណ្តឹង(អ្នកមិនអាចស្នើសុំអ្វីដែលអ្នកបានសំអាង ឬដែលអ្នកបានផ្តល់ ការយល់ព្រមបានឡើយ។ មានន័យថា ដើមបណ្តឹងបានបង្កើតឱ្យមានស្ថានភាពមួយដែលនៅក្នុង នោះចុងចម្លើយជឿដោយសុទ្ធចិត្តថា វិវាទប្រហែលជាលែងប្តឹងទៅតុលាការទៀតហើយ)។*

*- ការយល់ព្រម ៖ នៅក្នុងរឿងក្តីដែលល្បីគួរសម គឺរឿងក្តីសាលក្រមរបស់មជ្ឈត្តករដែល ប្រកាសដោយព្រះមហាក្សត្រអេស្ប៉ាញ ក្នុងឆ្នាំ១៩០៦(សាលដីកាចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៦០) រវាងប្រទេសនីការ៉ាហ្គ័រ និងប្រទេសហុងឌុយរ៉ាស។ តុលាការទទួលស្គាល់ថា ការយល់ព្រមទទួល យកអស់រយៈពេលជាច្រើនឆ្នាំនូវសាលក្រមដែលមិនត្រូវបានជំទាស់ រារាំងដើមបណ្តឹងមិនឱ្យ ជំទាស់នឹងសុពលភាពរបស់សាលក្រមនោះឡើយ។ តុលាការបដិសេធពាក្យបណ្តឹងរបស់ប្រទេស នីការ៉ាហ្គ័រថា មិនអាចទទួលយកបាន ដោយមូលហេតុថា ប្រទេសនេះបានយល់ព្រម។*

*- ការលើកលែងនៃភាពមិនអាចទទួលយកបានដែលផ្អែកលើលក្ខណៈឯកជននៃវិវាទ ៖ ប្រហែលជាការលើកលែងចំពោះភាពមិនអាចទទួលយកបានដែលកើតឡើងញឹកញាប់ជាងគេ បំផុត។ ការលើកលែងនេះអាចផ្អែកលើលក្ខណៈជាតិនៃការទាមទារ ឬលើការមិនផុតរលត់នៃផ្លូវ*

ឧបាស្រ័យក្នុងប្រទេស។

## ២- ភាពអាចទទួលយកបាននៅចំពោះមុខ CEDH

បញ្ហានៃភាពអាចទទួលយកបាននៅចំពោះមុខ CEDH មានលក្ខណៈសំខាន់ជាមូលដ្ឋាន ព្រោះពាក្យបណ្ដឹងប្រហែល៩០%ត្រូវបានវិនិច្ឆ័យថាមិនអាចទទួលយកបាន។ មុនពេលមានពិធីសារលេខ១១ មានប្រព័ន្ធត្រួតពិនិត្យមួយរួចជាស្រេចតាមរយៈគណៈកម្មការ។ ចាប់តាំងពីពិធីសារលេខ១១ អត្ថិភាពរបស់តុលាការតែមួយបញ្ជូនបញ្ហានេះទៅដោះស្រាយនៅយុត្តាធិការ។

មូលហេតុនៃភាពមិនអាចទទួលយកបានមានភាពល្បីល្បាញ និងស្រដៀងគ្នាគួរសម ៖ សារៈសំខាន់ស្ថិតនៅលើការមិនផុតរលត់នៃផ្លូវឧបាស្រ័យក្នុងប្រទេសដែលត្រូវបានពិនិត្យយ៉ាងតឹងរ៉ឹងដោយតុលាការ ប៉ុន្តែលក្ខខណ្ឌផ្សេងទៀតត្រូវបានតម្រូវ ក្នុងនោះលក្ខខណ្ឌមួយចំនួនគឺជាលក្ខខណ្ឌសមត្ថកិច្ចនៅយុត្តាធិការផ្សេងទៀត។

ជាក់ស្តែង សមត្ថកិច្ចតាមទីកន្លែង សមត្ថកិច្ចតាមសត្យានុម័ត សមត្ថកិច្ចតាមពេលវេលា ឬសមត្ថកិច្ចតាមបុគ្គល គឺជាលក្ខខណ្ឌជាក់ស្តែងនៃភាពអាចទទួលយកបាន។ សមត្ថកិច្ចតាមទីកន្លែងអាចឱ្យផ្ទៀងផ្ទាត់ថា អំពើមានកំហុសត្រូវបានប្រព្រឹត្តនៅក្នុងដែនដីនៃរដ្ឋ ឬដោយភ្នាក់ងាររបស់រដ្ឋនោះ។ សមត្ថកិច្ចតាមសត្យានុម័តអាចឱ្យផ្ទៀងផ្ទាត់ថា អំពើដែលបានអះអាងគឺរំលោភលើ CEDH។

សំខាន់ជាងនេះ ព្រោះត្រូវបានផ្ទៀងផ្ទាត់ជាប្រព័ន្ធ គឺលក្ខខណ្ឌតាមពេលវេលា ៖ ពាក្យបណ្ដឹងត្រូវតែដាក់ក្នុងរយៈពេលប្រាំមួយខែ គិតចាប់ពីពេលធ្វើសេចក្ដីសម្រេចក្នុងប្រទេសជាស្ថាពរដែលត្រូវបានចោទប្រកាន់(មាត្រា២៦)។ ចាប់ពីពេលនោះមក យើងបានស្គាល់យុត្តិសាស្ត្រដែលគ្របដណ្ដប់លើបញ្ហានៃចំណុច e ចេញពីកាលកំណត់៦ខែ។

ជាចុងក្រោយ លក្ខខណ្ឌសំខាន់នៃភាពអាចទទួលយកបានស្ថិតនៅលើបញ្ហានៃការផុតរលត់ផ្លូវឧបាស្រ័យក្នុងប្រទេស(មាត្រា២៦)។ ក៏ស្តុតាងនេះដាក់ទម្ងន់ទៅលើដើមបណ្ដឹង។ រាល់បញ្ហាគឺត្រូវដឹងថា «តើឧបាស្រ័យមួយណា»ត្រូវផុតរលត់? យុត្តិសាស្ត្រមានលក្ខណៈទូលំទូលាយណាស់ ប៉ុន្តែយើងអាចយល់ឃើញថា ជាសកល CEDH នៅជាប់ជាមួយនឹង«ឧបាស្រ័យបានការ»។

ជាចុងក្រោយ CEDH បដិសេធពាក្យបណ្ដឹងដែលមានលក្ខណៈរំលោភបំពាន ឬគ្មានមូលដ្ឋានគ្រប់គ្រាន់(មាត្រា២៧)។

# ជំពូក១៧
# ធាតុបង្កើត និងការស៊ើបសួររបស់តុលាការ៖ ការធានានីតិវិធី

## ផ្នែកទី១
## លក្ខណៈសាធារណៈនៃនីតិវិធី

*ប្រសិនបើយើងទទួលយកជាការធានានីតិវិធីយោងនូវការផ្សព្វផ្សាយនីតិវិធី ភាពចាប់រហ័សនៃនីតិវិធី និងលក្ខណៈសមធម៌របស់វា ត្រង់នេះម្តងទៀត យុត្តាធិការអន្តរជាតិមានលក្ខណៈពិសេសមួយចំនួន ដោយដឹងថា គ្មានយុត្តាធិការអន្តរជាតិណាមួយមិនមានលក្ខណៈពិសេសទាំងអស់ឡើយ។*

*ជាទូទៅ តុលាការនេះងាយទទួលបានណាស់(សវនាការសាធារណៈនៅ CIJ, TIDM, TPI, CEDH-ល-)។ មានតែ ORD ប៉ុណ្ណោះឃ្លាតឆ្ងាយយ៉ាងច្បាស់ និងដោយចេតនាពីលក្ខខណ្ឌតម្រូវនេះដែលនៅក្នុង ORD ការរក្សាការសម្ងាត់គឺផ្ទុយនឹងវិធាន(ព្រោះសមាសភាពជំនុំជម្រះប្រភេទនៃរឿងក្តី និងពាក្យពេចន៍នៃពាក្យបណ្តឹងត្រូវបានស្គាល់)។ ការរក្សាការសម្ងាត់នេះគឺជាអំណះអំណាងមួយដែលត្រូវបានលើកឡើង ដើម្បីជំទាស់នឹងឋានៈយុត្តាធិការរបស់តុលាការ។ ទោះជាយ៉ាងណាក៏ដោយ ចំណុចនេះកំពុងត្រូវបានពិភាក្សាក្នុងក្របខ័ណ្ឌនៃដំណើរការពិនិត្យឡើងវិញនូវយន្តការ ចាប់តាំងពីសន្និសីទក្រុងដូហា និងផលប្រយោជន៍នៃការប្រកាសនីតិវិធីសាធារណៈនេះ ជាពិសេសក្នុងផ្នែកធម្មានុរូបភាព។ ជាគោលការណ៍ ការពិនិត្យឡើងវិញនេះត្រូវសម្រេចនៅខែឧសភា ឆ្នាំ២០០៣។ ប៉ុន្តែ រហូតមកទល់ពេលនេះ វានៅតែមិនបានបញ្ចប់(និងបម្រុងនឹងមិនបញ្ចប់ទាល់តែសោះ)។ អ្នកដែលយល់ថា លក្ខណៈសាធារណៈនៃនីតិវិធីគឺជាភ័ស្តុតាងនៃការបើកទៅរកលទ្ធិប្រជាធិបតេយ្យនៃ WTO កំពុងប្រឆាំងនឹងអ្នកដែលការពារការសម្ងាត់ទុកជាលក្ខខណ្ឌសំខាន់ ដើម្បីអនុញ្ញាតឱ្យមានការដោះស្រាយវិវាទដែលព័ត៌មានពាណិជ្ជ-*


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កម្មសំខាន់ៗតែងតែចោទឡើងជាញឹកញាប់។

# ផ្នែកទី២

## ភាពល្បីល្បាញនៃនីតិវិធី

ផ្ទុយទៅវិញ ORD គឺជាស្ថាប័នគំរូជាងគេលើផ្នែកភាពល្បីល្បាញនៃនីតិវិធីដែលយើងអាច និងត្រូវពន្យល់តាមការដែលនីតិវិធីត្រូវបានរឹតបន្តឹងដោយកាលកំណត់តឹងរ៉ឹងដែលមានចែងយ៉ាងច្បាស់លាស់ ដោយអនុស្សរណៈនៃការយោគយល់ស្តីពីការដោះស្រាយវិវាទ។ ប្រសិនបើកាលកំណត់ទាំងនេះនៅតែមិនត្រូវបានគោរពតាមឱ្យបានពេញលេញទេ ការកន្ទងហួសនៅតែជាវិសាលភាពមានកម្រិត និងពាក់ព័ន្ធជាសំខាន់នូវស្ថាប័នដំបូង។

TIDM ក៏ត្រូវបានស្តីបន្ទោសតិចតួចផងដែរ ក្នុងវិស័យនេះ ដែលអាចយល់បាន សម្រាប់យុត្តាធិការមួយដែលមិនសូវធំទទឹងទទែង ប៉ុន្តែ ដែលជាសំខាន់ត្រូវមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងបន្ទាន់។

លក្ខណៈសមស្របនៃកាលកំណត់នៃការជំនុំជម្រះបានចោទឡើងកាន់តែខ្លាំង ចំពោះយុត្តាធិការផ្សេងទៀត។ ដូច្នេះ យើងដឹងថា កាលកំណត់(យូរជាងបួនឆ្នាំ)ដែលចាំបាច់ដើម្បីឱ្យរឿងក្តីមួយដែលត្រូវបានដាក់នៅស្ត្រាស្បួរ ត្រូវបានជំនុំជម្រះ គឺជាមូលហេតុដ៏សំខាន់មួយនៃកំណែទម្រង់ដែលត្រូវបានពន្យល់នៅក្នុងពិធីសារលេខ១១។ ការកកស្ទះបច្ចុប្បន្នរបស់ CEDH ធ្វើឱ្យមានការពិចារណាជាថ្មីអំពីកំណែទម្រង់ថ្មី។ ដូចគ្នាដែរ កាលកំណត់យូរៗដើម្បីបញ្ចប់រឿងក្តីដែលដាក់នៅ TPI តែងតែត្រូវបានបដិសេធជាញឹកញាប់។ វាក៏ជាទម្លាប់ផងដែរដែលត្រូវបញ្ជាក់ថា CIJ ជំនុំជម្រះយ៉ាងយឺតយ៉ាវបំផុត។

តាមការពិត បញ្ហាចោទឡើងលើផ្នែកផ្សេងគ្នាគួរសម សម្រាប់យុត្តាធិការផ្សេងៗទាំងនេះ។ CIJ ហាក់ដូចជាយឺត ប៉ុន្តែ មិនត្រូវភ្លេចទេថា ដោយមិនអាស្រ័យលើការពេញពាសនៃបញ្ជីរឿងក្តីរបស់យុត្តាធិការ ចំណុចនេះគឺដោយសារអ្នកទទួលការជំនុំជម្រះខ្លួនឯងដែលតែងតែទាមទារការពន្យារពេលកាលកំណត់នៃនីតិវិធី ជាពិសេសក្នុងដំណាក់កាលសរសេរ ទោះបីជាបញ្ជីរឿងក្តីរបស់យុត្តាធិការនេះបច្ចុប្បន្នកំពុងពេញណែនក៏ដោយ។ តាមការយល់ឃើញនេះ ការសង្កេតឃើញចំនួនពីរត្រូវធ្វើឡើងទៅលើភាពអាចទុកចិត្តបានរបស់តុលាការ។ ម្យ៉ាង រឿងក្តីថ្មីៗបានបង្ហាញថា រឿងក្តីអាចមានភាពល្បីល្បាញបំផុត(រឿងក្តី Bréard, La Grand ឬ Avena ដែលក្នុង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រឿងក្ដីនោះតុលាការបានជំនុំជម្រះតែប៉ុន្មានថ្ងៃ ឬតែប៉ុន្មានម៉ោង)។ ម្យ៉ាងទៀត CIJ បានបង្កើតក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះនូវគោលនយោបាយយុត្តាធិការពិតប្រាកដមួយដែលមានគោលដៅកំហិតវិសាលភាពនៃនីតិវិធី(ចំនួន និងទំហំនៃឯកសារសរសេររយៈពេលយូរ និងចំនួនជុំនៃការជជែកតទល់ កាលកំណត់សម្រាប់នីតិវិធីឧប្បត្តិហេតុមួយចំនួន)ដែលអាចឱ្យបង្កើនល្បឿននៃការជំនុំជម្រះ។ វានៅតែថា អ្នកទទួលការជំនុំជម្រះខ្លួនឯងផ្ទាល់មិនជាប្រញាប់ប្រញាល់ជាពិសេស ប្រសិនបើពួកគេស្វែងរកស្របគ្នា និងតាមការពិត ទៅតាមអាទិភាពនូវការដោះស្រាយតាមការចរចាដែលនីតិវិធីរបស់តុលាការគឺជាការជំរុញ។ នៅចំណុចនេះ មានការពិតជាលក្ខណៈអន្តរជាតិមួយដែលមិនអាចព្រងើយកន្តើយបាន។

បញ្ហាចោទឡើងក្នុងផ្នែកផ្សេងគ្នាជាមូលដ្ឋានទាក់ទងនឹងយុត្តាធិការដូចជា CEDH ឬ TPI ដែលភាពយឺតយ៉ាវគឺជាឧបសគ្គដ៏ចម្បងនៃភាពជាក់ស្ដែងនៃយុត្តិធម៌ដែលស្ថាប័នទាំងនេះត្រូវបានសន្មតថា នឹងផ្ដល់ និងដែលពាក់ព័ន្ធផងដែរ និងសំខាន់បំផុតជាមួយនឹងបុគ្គលម្នាក់ៗ។

# ផ្នែកទី៣
## សមធម៌នៃនីតិវិធី

ជាចុងក្រោយ ពាក់ព័ន្ធនឹងសមធម៌នៃនីតិវិធី វាប្រហែលជាចំណុចដែលយុត្តាធិការអន្តរជាតិខិតជិតគ្នាជាងគេនៃស្តង់ដារដែលត្រូវគ្នានឹងគំរូជាសកលដែលត្រូវបានយល់ថារួមបញ្ចូលទាំងលក្ខខណ្ឌតម្រូវនៃការផ្ដល់ហេតុផលដល់សេចក្ដីសម្រេច និងលក្ខខណ្ឌតម្រូវនៃសមភាពសព្វាវុធ។

សារៈសំខាន់នៃកាតព្វកិច្ចផ្ដល់ហេតុផលត្រូវបានបញ្ជាក់ដោយប្រការដែលវាមានវត្តមានជាទូទៅនៅក្នុងលក្ខន្តិកៈរបស់យុត្តាធិការអន្តរជាតិ។ ទោះបីជាវត្តមានជាក់ស្ដែងរបស់យុត្តាធិការអន្តរជាតិត្រូវបានធ្វើឱ្យសមហេតុផលដោយមិនស្មើភាពទៅតាមលក្ខន្តិកៈ និងបទបញ្ញានីតិវិធីក៏ដោយ(សូមមើលមាត្រា៥៦នៃលក្ខន្តិកៈរបស់ CIJ មាត្រា១២:៧នៃអនុស្សរណៈ WTO មាត្រា៤៥នៃ CEDH មាត្រា៣០នៃលក្ខន្តិកៈរបស់ TIDM-ល-) សេចក្ដីសម្រេចរបស់យុត្តាធិការអន្តរជាតិទាំងអស់ មិនត្រឹមតែត្រូវបានបញ្ជាក់ហេតុផលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានបញ្ជាក់ហេតុផលជាទូទៅយ៉ាងច្រើនលើសលុប ឬលើសពីលើសលុបទៅទៀត(ដែលមិនតែងតែជាករណីនៃយុត្តាធិការក្នុងប្រទេសទេ។ ឧទាហរណ៍ ក្រុមប្រឹក្សារដ្ឋនៅប្រទេសបារាំង)។ ក្នុងន័យនេះការពន្យល់ប្រហែលជាមានលក្ខណៈ«សង្គមសាស្ត្រ»ជាងគតិយុត្ត។ ភាពចម្រុះនៃសមាសភាព


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់យុត្តាធិការ ភាពចម្រុះនៃប្រពៃណីគតិយុត្តដែលត្រូវបានតំណាង ដាក់ទម្ងន់ដល់ការបញ្ជាក់ហេតុផលលម្អិតដូចធន្ទៈក្នុងការបង្ហាញដល់អ្នកទទួលការជំនុំជម្រះថា អំណះអំណាងរបស់ពួកគេប្រសិនបើមិនបានទទួលទេ ត្រូវបានស្តាប់។ លើសពីនេះទៀត ក្នុងយុត្តាធិការអន្តរជាតិភាគច្រើន ចៅក្រមដែលខ្វែងគំនិតគ្នាទាំងស្រុង ឬមួយផ្នែកជាមួយនឹងដំណោះស្រាយដែលបានអនុម័ត មានសិទ្ធិធ្វើឱ្យគេដឹងអំពីការយល់ឃើញរបស់ខ្លួនតាមរបៀបដាច់ដោយឡែកពីគ្នា។

វិធីសាស្ត្រសមភាពសព្វាវុធគឺខុសគ្នាទាំងស្រុង អាស្រ័យលើថា តើយុត្តាធិការទទួលបន្ទុកលើវិវាទអន្តររដ្ឋ ឬវិវាទចម្រុះ។

ក្នុងករណីទីមួយ សមភាពសព្វាវុធ និយាយឱ្យច្បាស់ គឺជាគំនិតបុរាណ ឬនិយាយម្យ៉ាងទៀត ជាគំនិតដែលមិនអាចផ្តាច់ពីគ្នាបាន។ វាគ្រាន់តែជាការបកស្រាយដោយឡែកនៃលក្ខខណ្ឌតម្រូវនៃសមភាពដែលគោលការណ៍អធិបតេយ្យភាពមាន ហើយចៅក្រមផ្តោតការយកចិត្តទុកដាក់យ៉ាងម៉ត់ចត់ដល់ការគោរពនីតិវិធីនៃសមភាពនេះ។ មានន័យថា សមភាពអធិបតេយ្យមិនត្រូវគ្នានឹងសមភាពអំណាចឡើយ ហើយគេដឹងថា នៅក្នុងយុត្តាធិការអន្តរជាតិ រដ្ឋទាំងអស់មិនមានមធ្យោបាយដូចគ្នា ទាំងមនុស្ស(ជំនាញ) ទាំងហិរញ្ញវត្ថុ ដើម្បីដឹកនាំនីតិវិធី ឬប្រឈមមុខនឹងនីតិវិធី(នៅក្នុងស្ទើរតែគ្រប់ករណី មានយន្តការជំនួយដែលស្រដៀងគ្នាដោយផ្ទាល់ខ្លាំង ឬតិច(និងរាល់សមាមាត្រដែលត្រូវបានរក្សា ព្រោះយើងមានរឿងទាក់ទងជាមួយរដ្ឋ) ជាមួយនឹងជំនួយរបស់តុលាការ។ CIJ មានមូលនិធិជំនួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍ។ នៅ WTO បញ្ហាស្ថិតនៅក្នុងបញ្ហាដែលមានលក្ខណៈសកលជាងនៃការចូលរួមជាក់ស្តែងរបស់រដ្ឋក្រីក្រជាងគេនៅក្នុងការរៀបចំ។ ឧទាហរណ៍ មានតែរដ្ឋដែលមានអំណាចពាណិជ្ជកម្មប៉ុណ្ណោះ រួមទាំងក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ បានចូលរួមនៅក្នុងការដោះស្រាយវិវាទ។ ប៉ុន្តែ មានលទ្ធភាពផ្តល់ជំនួយ តាមរយៈសមាគមដែលត្រូវបានផ្តល់ឧបត្ថម្ភកធន)។ ប៉ុន្តែ យើងនឹងមិនភ្លេចទេថា បញ្ហាមិនចោទឡើង សូម្បីតែចំពោះរដ្ឋដែលក្រីក្រជាងគេបំផុតក៏ដោយ តាមរបៀបដូចគ្នានឹងបុគ្គលឡើយ។

នៅចំពោះមុខយុត្តាធិការដែលមានសមត្ថកិច្ចជំនុំជម្រះវិវាទចម្រុះ បញ្ហាសមភាពសព្វាវុធចោទឡើងស្ទើរតែដូចគ្នានឹងនៅចំពោះមុខយុត្តាធិការក្នុងប្រទេសដែលមានសមត្ថកិច្ចជំនុំជម្រះវិវាទប្រភេទដូចគ្នា។ ប្រសិនបើដំណោះស្រាយដែលចង់បាន មានប្រភេទដូចគ្នា ដំណោះស្រាយនោះអាចជំរុញឱ្យមានការពិបាកជាពិសេស និងជាកត្តាបង្កើតចំណាយយ៉ាងច្រើន។ ជំនួយរបស់តុលាការក្នុងក្របខ័ណ្ឌនៃ TPI ផ្តល់ការបង្ហាញជាគំរូយ៉ាងពិសេសមួយ ព្រោះការរៀបចំរបស់ខ្លួនជំពប់នឹងអវត្តមាននៃស្ថាប័នដៃគូសន្ទនា ស្មើនឹងគណៈមេធាវី និងព្រោះវាចោទជាបញ្ហានៃការត្រួតពិនិត្យ និងគ្រប់គ្រងចំណាយពាក់ព័ន្ធ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក១៨
# ផ្លូវឧបាស្រ័យ

## ផ្នែកទី១
## តុលាការយុត្តិធម៌អន្តរជាតិ

### ១- ពាក្យបណ្ដឹងសុំឱ្យបកស្រាយ និងពាក្យបណ្ដឹងសុំសើរើ

*គូភាគីអាចដាក់ពាក្យបណ្ដឹងសុំឱ្យបកស្រាយ ឬក្នុងលក្ខខណ្ឌមួយចំនួន ពាក្យបណ្ដឹងសុំសើរើ។ តុលាការវិនិច្ឆ័យលើកម្មវត្ថុរបស់ខ្លួនតាមសាលដីកា(លក្ខន្តិកៈ មាត្រា៦០-៦១ បទបញ្ជា មាត្រា៩៨-១០០)។ សម្មតិកម្មទាំងនេះនៅតែកម្រ ប៉ុន្តែសក្តិសមនឹងត្រូវបានលើកឡើង។*

*ជាការពិតណាស់ ការបូកសរុបនីតិវិធីសើរើ និងបកស្រាយនៅ CIJ ត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័ស។ យើងអាចលើកឡើងថា ៖ ពាក្យបណ្ដឹងសុំឱ្យបកស្រាយចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥០ ក្នុងរឿងក្តីសិទ្ធិជ្រកកោន(សាលដីកាចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៥០) ពាក្យបណ្ដឹងសុំសើរើ និងសុំឱ្យបកស្រាយសាលដីកាចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៨២ ក្នុងរឿងក្តីខ្ពង់រាបបាតសមុទ្រ (ប្រទេសទុយនីស៊ី/លីប៊ី) (សាលដីកាចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៥) ពាក្យបណ្ដឹងសុំឱ្យបកស្រាយសាលដីកាចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៨ ក្នុងរឿងក្តីព្រំដែនគោក និងសមុទ្ររវាងប្រទេសកាមេរូន និងនីហ្សេរីយ៉ា (សាលដីកាចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩) ពាក្យបណ្ដឹងសុំសើរើដែលដាក់ដោយប្រទេសយូហ្គោស្លាវី ក្នុងរឿងក្តីប្រល័យពូជសាសន៍ បូស្នី/យូហ្គោស្លាវី ទាក់ទងនឹងសាលដីកាស្តីពីការលើកលែងជាមុន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦(សាលដីកាចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៣) និងពាក្យបណ្ដឹងសុំសើរើសាលដីកាចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩២ ពាក់ព័ន្ធនឹងវិវាទព្រំដែនរវាងប្រទេសអែលសាល់វ៉ាឌ័រ/ហុងឌុយរ៉ាស(សាលដីកាចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣)។*

## ២- ពាក្យបណ្ដឹងសុំឱ្យបកស្រាយ

ក្នុងករណីជំទាស់លើអត្ថន័យ និងវិសាលភាពនៃសាលដីកា តុលាការមានកាតព្វកិច្ចត្រូវបកស្រាយតាមការស្នើសុំរបស់រាល់ភាគីទាំងអស់។ ពាក្យបណ្ដឹងសុំឱ្យបកស្រាយត្រូវដាក់ដោយយោងតាមកិច្ចសម្របសម្រួលរវាងគូភាគី ឬតាមពាក្យបណ្ដឹងរបស់ភាគីមួយ ឬច្រើន។ ពាក្យបណ្ដឹងសុំឱ្យបកស្រាយត្រូវបានដាក់ដោយប្រទេសកូឡុំប៊ី ពាក់ព័ន្ធនឹងសាលដីកាដែលប្រកាសដោយតុលាការ ក្នុងរឿងក្ដីសិទ្ធិជ្រកកោន(ប្រទេសកូឡុំប៊ីប្រឆាំងនឹងប្រទេសប៉េរូ) នៅឆ្នាំ១៩៥០។ ពាក្យបណ្ដឹងត្រូវបានដាក់ផងដែរដោយប្រទេសទុយនីស៊ី នៅឆ្នាំ១៩៨៤ ពាក់ព័ន្ធនឹងសាលដីកាដែលប្រកាសដោយតុលាការ ក្នុងរឿងក្ដីខ្ពង់រាបបាតសមុទ្រ ប្រឆាំងនឹងប្រទេសលីប៊ី(ឆ្នាំ១៩៨២) ប៉ុន្តែពាក្យបណ្ដឹងនេះក៏ជាពាក្យបណ្ដឹងសុំសើរើផងដែរ។ ពាក្យបណ្ដឹងបែបនេះអាចធ្វើទៅបានដើម្បីសុំយោបល់ប្រឹក្សា ៖ គឺជាករណីក្នុងឆ្នាំ១៩៥៥ សម្រាប់យោបល់ឆ្នាំ១៩៥០ ពាក់ព័ន្ធនឹងរឿងក្ដីអាហ្វ្រិចភាគនិរតីដែលតុលាការបានកត់សម្គាល់ថា គេបានសុំឱ្យខ្លួនធ្វើតែ«ការបកស្រាយត្រឹមត្រូវ»នៃយោបល់ពីមុនប៉ុណ្ណោះ។ បញ្ហាបានចោទឡើងម្ដងទៀតនៅឆ្នាំ១៩៥៦ ហើយតុលាការបានប្រកាន់យកជំហរដដែល។

ការបកស្រាយសេចក្ដីសម្រេចមិនប៉ះពាល់ដល់អាជ្ញាអស្គជំនុំទេ។ មិនត្រូវត្រលប់ទៅមើលអ្វីដែលត្រូវបានជំនុំជម្រះរួចនោះទេ ប៉ុន្តែគ្រាន់តែបកស្រាយប៉ុណ្ណោះ។ ការបកស្រាយមិននាំឱ្យមានការវាយតម្លៃផ្សេងលើអង្គហេតុ ឬអង្គច្បាប់ដែលអនុវត្តចំពោះសាលដីកាទេ។ ពិសេសជាងនេះទៅទៀត ការបកស្រាយមិនអាចពិចារណាលើអង្គហេតុថ្មីដែលមិនត្រូវបានលើកឡើងនៅក្នុងពេលមានរឿងក្ដី ឬអង្គហេតុដែលកើតឡើងក្រោយពេលមានសាលដីកាឡើយ។ ដូច្នេះ វាគ្រាន់តែត្រូវ«បំភ្លឺអត្ថន័យ និងវិសាលភាពនៃអ្វីដែលត្រូវបានសម្រេចដោយមានអានុភាពកាតព្វកិច្ចតាមសាលដីកា» ទៅតាមសំនួនវោហាស័ព្ទដែលត្រូវបានប្រើប្រាស់នៅក្នុងពាក្យបណ្ដឹងពាក់ព័ន្ធនឹងរឿងក្ដីសិទ្ធិជ្រកកោនប៉ុណ្ណោះ។ យុត្តិសាស្ត្រនេះមានលក្ខណៈអចិន្ត្រៃយ៍ ចាប់តាំងពីការបកស្រាយដែលត្រូវបានស្នើសុំនៅក្នុងពេល CPJI (ការបកស្រាយសាលដីកាពាក់ព័ន្ធនឹងសន្ធិសញ្ញាក្រុង Neuilly សាលដីកាចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩២៥)។

ក្នុងរឿងក្ដីសិទ្ធិជ្រកកោន តុលាការបានច្រានចោលពាក្យបណ្ដឹង។ ផ្ទុយទៅវិញ នៅក្នុងសាលដីការបស់ខ្លួនឆ្នាំ១៩៨៥ ស្ដីពីរឿងក្ដីខ្ពង់រាបបាតសមុទ្រ តុលាការបានប្រកាសទទួលយកពាក្យបណ្ដឹងសុំឱ្យបកស្រាយ។ ដូច្នេះ តុលាការបានបញ្ជាក់នូវការកំណត់ព្រំប្រទល់ខ្ពង់រាបនៅក្នុងតំបន់មួយចំនួនតាមការស្នើសុំ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣- ពាក្យបណ្ដឹងសុំសើរើ

*ការសើរើសាលដីកាអាចត្រូវបានស្នើសុំទៅតុលាការបាន លុះត្រាតែមានការរកឃើញអង្គហេតុដែលអាចមានឥទ្ធិពលសំខាន់ និងដែលមុនពេលប្រកាសសាលដីកា មិនត្រូវបានដឹងដោយតុលាការ និងភាគីដែលស្នើសុំឱ្យសើរើ ដោយភាគីនោះមិនមានចេតនាព្រងើយកន្ដើយចំពោះអង្គហេតុនោះ និងមិនមានការធ្វេសប្រហែសដែលធ្វើឱ្យភាគីនោះព្រងើយកន្ដើយចំពោះអង្គហេតុ។ ការស្នើសុំនេះត្រូវបានដាក់តាមពាក្យបណ្ដឹង។ ពាក្យបណ្ដឹងត្រូវធ្វើឡើងយ៉ាងយូរបំផុតប្រាំមួយខែក្រោយការរកឃើញអង្គហេតុ និងក្នុងរយៈពេលដប់ឆ្នាំបន្ទាប់ពីការប្រកាសសាលដីកា(រយៈពេលអាជ្ញាយុកាលនេះត្រូវបានរិះគន់ផងដែរថាមិនមានលក្ខណៈតថភាព ព្រោះតុលាការត្រូវវិនិច្ឆ័យតែម្នាក់ឯងអំពីពេលវេលាសមស្របក្នុងការបើករឿងក្ដីឡើងវិញ ទោះបីជាមានកាលកំណត់បែបណាក៏ដោយ)។ ម្យ៉ាងទៀត តុលាការអាចដាក់ការសើរើឱ្យស្ថិតក្រោមការអនុវត្តសាលដីកា (មាត្រា៦១-៣)។*

*យើងយល់អំពីចំណុចនេះ នីតិវិធីនេះមានលក្ខណៈពិសេស ព្រោះស្ថិរភាពរបស់តុលាការត្រូវបានចោទឡើង។ ដូច្នេះ អង្គហេតុថ្មីនេះត្រូវតែអាច«ធ្វើឱ្យរញ្ជួយ»សាលដីកាដែលត្រូវបានប្រកាសកាលពីមុន។ នីតិវិធីនេះមិនមានអានុភាពទៅលើយោបល់ពិគ្រោះឡើយ ព្រោះតុលាការមិនប្រកាសអំពីអង្គហេតុដែលអាចនាំឱ្យមានការសើរើទេ។*

*ចាប់តាំងពីការបង្កើត CIJ មក មានពាក្យបណ្ដឹងតិចតួចត្រូវបានធ្វើឡើង។ យើងអាចលើកឡើងនូវពាក្យបណ្ដឹងរបស់ប្រទេសទុយនីស៊ី ក្នុងឆ្នាំ១៩៨៤ ក្នុងរឿងក្ដីខាងលើ ដោយមានទំនាក់ទំនងជាមួយពាក្យបណ្ដឹងសុំឱ្យបកស្រាយ។ តុលាការបានទទួលយកពាក្យបណ្ដឹងសុំឱ្យបកស្រាយ។ ផ្ទុយទៅវិញ តុលាការបានបដិសេធពាក្យបណ្ដឹងសុំសើរើទាក់ទងនឹងការកែសម្រួលកំហុសធ្ងន់ធ្ងរដែលត្រូវបានស្នើសុំដោយប្រទេសទុយនីស៊ី។ តុលាការបានយល់ឃើញថា ចំណុចនេះមិនបានកែប្រែទិន្នន័យនៃសេចក្ដីសម្រេចមុនរបស់ខ្លួនឡើយ។ នៅឆ្នាំ២០០៣ តុលាការបានប្រានចោលម្ដងទៀតនូវពាក្យបណ្ដឹងសុំសើរើចំនួនពីរ នៅក្នុងរឿងក្ដីប្រល័យពូជសាសន៍ ប្រទេសបូស្នី/យូហ្គោស្លាវី ពាក់ព័ន្ធនឹងសាលដីកាស្ដីពីការលើកលែងជាមុនចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦ (សាលដីកាចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៣) និងសម្រាប់ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសាលដីកាចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩២ ទាក់ទងនឹងវិវាទព្រំដែនរវាងប្រទេសអែលសាល់វ៉ាឌ័រ/ហុងឌុយរ៉ាស (សាលដីកាចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣)។*

# ផ្នែកទី២
## តុលាការអន្តរជាតិស្តីពីនីតិសមុទ្រ

*គ្រាន់តែត្រូវបញ្ជាក់ឱ្យបានឆាប់រហ័សថា បទប្បញ្ញត្តិពាក់ព័ន្ធនឹងការបកស្រាយ និងការសើរើមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងបទប្បញ្ញត្តិរបស់ CIJ។ បញ្ហាបកស្រាយត្រូវបានបញ្ជាក់នៅក្នុងមាត្រា៣៣នៃលក្ខន្តិកៈ បញ្ហាសើរើត្រូវបានបង្កើតនៅក្នុងបទបញ្ជា។*

# ផ្នែកទី៣
## យុត្តាធិការព្រហ្មទណ្ឌ

### ១- សាលាក្តីចំពោះកិច្ច

*នៅទីនេះ បណ្តឹងឧទ្ធរណ៍អាចធ្វើទៅបាន និងផ្អាកការអនុវត្តសាលក្រមសាលាក្តីដំបូង (មាត្រា២៥នៃលក្ខន្តិកៈរបស់ TPIY និងមាត្រា២៤នៃលក្ខន្តិកៈរបស់ TPIR)។ គឺជា ការអនុវត្តការធានាបុរាណ ក្នុងរឿងព្រហ្មទណ្ឌនូវសិទ្ធិក្នុងការទទួលបានការពិនិត្យរឿងក្តីជាលើកទីពីរលើអង្គហេតុ និងអង្គច្បាប់ ដោយចៅក្រមផ្សេងទៀត។ រឿងក្តីឧទ្ធរណ៍ដែលត្រូវអនុវត្តក្នុងរយៈពេល ១៥ថ្ងៃក្រោយពេលប្រកាសសាលក្រម(មាត្រា១០៨នៃបទបញ្ជារបស់ TPIY) ត្រូវបានកំហិតត្រឹមបទចោទប្រកាន់ចំនួនពីរ។*

*ជាដំបូង គូភាគីអាចលើកឡើងនូវការភ័ន្តច្រឡំច្បាប់ដែលធ្វើឱ្យសាលក្រមអសុពលភាព ប្រសិនបើការភ័ន្តច្រឡំនេះត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះឧទ្ធរណ៍។ ជាសំខាន់វាគឺជាការរំលោភលើលក្ខន្តិកៈរបស់តុលាការ និងលក្ខន្តិកៈរបស់ RPP។ គូភាគីក៏អាចលើកឡើងនូវការភ័ន្តច្រឡំអង្គហេតុដែលអាចបណ្តាលឱ្យមានការបដិសេធយុត្តិធម៌ផងដែរ។ តាមការពិត តាមបែបបុរាណ គឺត្រូវអនុញ្ញាតឱ្យចៅក្រមឧទ្ធរណ៍ផ្ទៀងផ្ទាត់ថា ចៅក្រមដំបូងមិនបានប្រព្រឹត្តការភ័ន្តច្រឡំនៅក្នុងការវាយតម្លៃអង្គហេតុ ដើម្បីប្រកាសការកាត់ទោស ឬការដោះលែងឡើយ។ ផ្ទុយទៅវិញ ពាក្យបណ្តឹងឧទ្ធរណ៍នៃបញ្ហា(បន្ទាន់បន្ទំ) សមត្ថកិច្ចមិនត្រូវបានពិចារណាតាមរបៀបដូចគ្នានៅក្នុងការដោះស្រាយនីតិវិធីរបស់សាលាក្តីទាំងពីរឡើយ។ ក្នុងពេលដែលតុលាការសម្រាប់ប្រទេសរវ៉ាន់ដាមិនទទួលស្គាល់ តុលាការសម្រាប់អតីតប្រទេសយូហ្គោស្លាវីទទួលយកពាក្យបណ្តឹងឧទ្ធរណ៍ចំពោះការលើកលែងអសមត្ថកិច្ច ព្រមទាំងចំពោះវិការទម្រង់នៅក្នុងកិច្ចចោទប្រកាន់ ប៉ុន្តែ*

លុះត្រាតែចៅក្រមចំនួនបីរូបនៃអង្គជំនុំជម្រះឧទ្ធរណ៍ឯកភាព(មាត្រា៧២នៃបទបញ្ជារបស់ TPIY)។ វិធាននីតិវិធីគឺជាវិធានដែលត្រូវបានអនុវត្តតាមនៅក្នុងសាលាក្តីដំបូង។ កាលកំណត់ដ៏តឹងរ៉ឹងត្រូវបានកំណត់សម្រាប់ការដាក់សារណា(៩០ថ្ងៃសម្រាប់ដើមបណ្តឹងឧទ្ធរណ៍ ៣០ថ្ងៃសម្រាប់ចុងចម្លើយឧទ្ធរណ៍ជាការឆ្លើយតប)។ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពល្បីល្បាញ និងដោយសារការពេញណែនរបស់អង្គជំនុំជម្រះឧទ្ធរណ៍ បទបញ្ជានីតិវិធីត្រូវបានកែប្រែជាច្រើនដង ដើម្បីផ្តល់ដល់ចៅក្រមឧទ្ធរណ៍នូវមធ្យោបាយបង្កើនល្បឿនការប្រព្រឹត្តទៅនៃនីតិវិធី។ ប៉ុន្តែមធ្យោបាយផ្តល់ភស្តុតាងថ្មីត្រូវបានអនុញ្ញាត បន្ទាប់ពីការដាក់ពាក្យបណ្តឹងនៅការិយាល័យក្រឡាបញ្ជី និងលុះត្រាតែផលប្រយោជន៍នៃយុត្តិធម៌បញ្ជា(មាត្រា១១៥នៃបទបញ្ជារបស់ TPIY)។ មធ្យោបាយនេះនឹងត្រូវបានជូនដំណឹងដល់ភាគីបដិបក្ខយ៉ាងតិច១៥ថ្ងៃមុនសវនាការ។ ផ្ទុយទៅវិញ តុលាការអាចមានសមត្ថកិច្ចជំនុំជម្រះតែអង្គហេតុដែលត្រូវបានវាយតម្លៃដោយចៅក្រមដំបូងប៉ុណ្ណោះ។ បណ្តឹងឧទ្ធរណ៍មិនប្រាកដថាត្រូវពិនិត្យដោយសាលាឧទ្ធរណ៍ឡើយ។ ជាការពិតណាស់ សាលាឧទ្ធរណ៍អាចជំនុំជម្រះដោយខ្លួនឯង ឬបញ្ជូនរឿងក្តីទៅចៅក្រមសាលាដំបូង នៅក្នុងអង្គជំនុំជម្រះដែលមានសមាសភាពផ្សេង។ ជាទូទៅ យើងកត់សម្គាល់ឃើញថា សាលាក្តីចំពោះកិច្ចមានឆន្ទៈត្រួតពិនិត្យយ៉ាងតឹងរ៉ឹងលើនីតិវិធីឧទ្ធរណ៍នេះ ដោយផ្អែកលើយុត្តិសាស្ត្រដែលមានលក្ខណៈរឹតត្បិតខ្លាំង។

សិទ្ធិដកខ្លួនចេញពីសាលក្រមក្នុងករណីកើតមានអង្គហេតុថ្មីក៏ត្រូវបានចែងផងដែរ(មាត្រា២៦នៃលក្ខន្តិកៈរបស់ TPIY និងមាត្រា២៥នៃលក្ខន្តិកៈរបស់ TPIR)។ គឺជាឧបាស្រ័យសើរើ។ មាត្រា១២០នៃបទបញ្ជារៀបចំឧបាស្រ័យសើរើនេះ ក្នុងករណីរកឃើញអង្គហេតុ(សំខាន់)ថ្មីដែលអាចចោទជាបញ្ហាដល់សាលក្រមដែលបានប្រកាស និងដែលត្រូវបានព្រងើយកន្តើយដោយអ្នកដែលបានលើកឡើង។ ប៉ុន្តែ សាលក្រមនេះក៏ត្រូវចូលជាស្ថាពរផងដែរ មានន័យថា កាលកំណត់ប្តឹងឧទ្ធរណ៍បានផុតកំណត់ ឬប្រសិនបើការប្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើង មានន័យថា សាលក្រមឧទ្ធរណ៍ត្រូវបានប្រកាស។ ក្នុងករណីដែលការប្តឹងឧទ្ធរណ៍នៅតែអាចធ្វើទៅបាន ឧបាស្រ័យសុំសើរើត្រូវបានលើកលែងមិនរាប់បញ្ចូល។ កាលកំណត់ប្តឹងមិនដូចគ្នាទៅតាមគូភាគីទេ។ ជាការពិត រដ្ឋអាជ្ញាអាចធ្វើសកម្មភាពតែនៅក្នុងឆ្នាំនៃការប្រកាសសាលក្រមប៉ុណ្ណោះ។ ចំណុចនេះមានន័យយ៉ាងជាក់លាក់ថា ប្រសិនបើយើងសន្មតថា ជនជាប់ចោទម្នាក់ដែលត្រូវបានដោះលែង ឬថា ធាតុថ្មីមួយអនុញ្ញាតឱ្យកាត់ទោសជនជាប់ចោទនោះ ក្រោយរយៈពេលមួយឆ្នាំ មាន«ការលើកលែងទោសទូទៅ»ជាក់ស្តែងមួយប្រភេទ។ ផ្ទុយទៅវិញ ជនជាប់ចោទមិនត្រូវបានរាំងនៅក្នុងកាលកំណត់ណាមួយឡើយ។ ដូច្នេះ យើងត្រូវយល់អំពីវិធាន ៖ ជនជាប់ចោទដែលត្រូវបានកាត់ទោស ត្រូវអាចឱ្យគេប្រកាសថាខ្លួនគ្មានទោសបានគ្រប់ពេលវេលា។ ចាប់ពីពេលនោះ បញ្ហា

មួយបានចោទឡើង ៖ តើពេលណាក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិសម្រេចចិត្ត លុបចោលយុត្តាធិការចំពោះកិច្ចទាំងនេះ? យើងអាចគិតថា តុលាការឧក្រិដ្ឋកម្មអន្តរជាតិអាច បង្កើតជាស្ថាប័នឧទ្ធរណ៍ ដូចក្នុងករណីការបន្ធូរបន្ថយទោស។ ប៉ុន្តែ យើងត្រូវតែចែងឱ្យបាន ច្បាស់លាស់ផងដែរ។ នីតិវិធីគឺសាមញ្ញ។ នីតិវិធីចាប់ផ្តើមដោយការពិនិត្យភាពត្រឹមត្រូវនៃអង្គហេតុ ថ្មីនៅក្នុងសវនាការបឋមដោយចៅក្រមដែលបានជំនុំជម្រះជាលើកដំបូង។ ប្រសិនបើចៅក្រម ទាំងនេះភាគច្រើនយល់ឃើញថា អង្គហេតុថ្មីគឺជាធាតុសំខាន់នៃការសម្រេចចិត្ត អង្គជំនុំជម្រះ (ឧទ្ធរណ៍ ឬដំបូងទៅតាមករណីជាក់ស្តែង) អាចសើរើសាលក្រមបាន បន្ទាប់ពីស្តាប់ចម្លើយ គូភាគីអំពីអង្គហេតុថ្មី។

## ២- តុលាការឧក្រិដ្ឋកម្មអន្តរជាតិ

សិទ្ធិទទួលបានយុត្តាធិការពីរកម្រិតក៏ត្រូវបានគ្រោងនៅក្នុងអត្ថបទគ្រឹះនៃ CPI ផងដែរ។ ការប្តឹងឧទ្ធរណ៍អាចធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចស្តីពីពិរុទ្ធភាព ឬទោស(មាត្រា៨១នៃលក្ខន្តិកៈ) ឬប្រឆាំងនឹងសេចក្តីសម្រេចផ្សេងទៀត(មាត្រា៨២)។ វាជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ដំបូង - មិនមែនអង្គជំនុំជម្រះឧទ្ធរណ៍ទេ - ក្នុងការកំណត់ប្រភេទនៃបណ្តឹងឧទ្ធរណ៍។ ក្នុងករណី បណ្តឹងឧទ្ធរណ៍អំពីពិរុទ្ធភាព ឬទោស រដ្ឋអាជ្ញាអាចលើកឡើងនូវកំហុសនីតិវិធី ការភ័ន្តច្រឡំ អង្គហេតុ ឬការភ័ន្តច្រឡំអង្គច្បាប់។ បុគ្គលដែលត្រូវបានប្រកាសថា មានពិរុទ្ធ អាចប្តឹងឧទ្ធរណ៍ ដោយសារមូលហេតុដដែលដែលត្រូវបន្ថែមនូវ«រាល់កាលៈទេសៈផ្សេងទៀតដែលអាចប៉ះពាល់ ដល់សមធម៌ ឬប្រក្រតីភាពនៃនីតិវិធី ឬសេចក្តីសម្រេច»(មាត្រា៨១ វាក្យខណ្ឌទី១b)។ម្យ៉ាងវិញ ទៀត រដ្ឋអាជ្ញាអាចប្តឹងឧទ្ធរណ៍ជំទាស់នឹងទោសដែលត្រូវបានប្រកាសដោយសារមិនគោរពតាម គោលការណ៍សមាមាត្រភាពរវាងទោសនេះ និងឧក្រិដ្ឋកម្ម(មាត្រា៨១ វាក្យខណ្ឌទី២a)។ ប៉ុន្តែ បណ្តឹងឧទ្ធរណ៍ទាំងពីរប្រភេទនេះដែលមានចែងនៅក្នុងមាត្រា៨១ មិនត្រូវបានចែកដាច់ពីគ្នាទេ។ ពេលប្តឹងឧទ្ធរណ៍ប្រឆាំងនឹងទោសដែលត្រូវបានប្រកាស ប្រសិនបើតុលាការយល់ឃើញថា មាន មូលហេតុនៃការលុបចោលនូវពិរុទ្ធភាព តុលាការអាចអញ្ជើញគូភាគីឱ្យលើកឡើងនូវមូលហេតុ នេះ(មាត្រា៨១ វាក្យខណ្ឌទី២b)។ ផ្ទុយមកវិញ នៅពេលប្តឹងឧទ្ធរណ៍អំពីពិរុទ្ធភាព ប្រសិនបើ តុលាការយល់ឃើញថា មានមូលហេតុដែលបញ្ជាក់អំពីការកាត់បន្ថយទោស តុលាការអាច ចាត់ការតាមរបៀបដូចគ្នា(មាត្រា៨១ វាក្យខណ្ឌទី២c)។ បណ្តឹងឧទ្ធរណ៍មិនមានអានុភាពផ្អាក ការអនុវត្តចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថាមានទោសឡើយ។ បុគ្គលនេះនៅជាប់ឃុំ ដដែល លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់អង្គជំនុំជម្រះដំបូង(មាត្រា៨១ វាក្យខណ្ឌទី ៣a)។ ផ្ទុយទៅវិញ ក្នុងករណីដោះលែង ជនជាប់ចោទត្រូវបានដោះលែងឱ្យមានសេរីភាពភ្លាមៗ

លើកលែងតែអង្គជំនុំជម្រះដំបូងសម្រេចចិត្តផ្សេងពីនេះ តាមការស្នើសុំរបស់រដ្ឋអាជ្ញា«ក្នុងកាលៈទេសៈពិសេស និងអាស្រ័យតាមលទ្ធភាពនៃការរត់គេច ភាពធ្ងន់ធ្ងរនៃបទល្មើស និងឱកាសមើលឃើញបណ្តឹងឧទ្ធរណ៍សម្រេចជោគជ័យ»(មាត្រា៨១ វាក្យខណ្ឌទី៣c)។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចផ្សេងទៀត(មាត្រា៨២) ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍អំពីសមត្ថកិច្ច ភាពអាចទទួលយកបាន ដីកាដោះលែងឱ្យមានសេរីភាព ឬដីកាបដិសេធ-ល-។ នីតិវិធីឧទ្ធរណ៍ត្រូវបានរៀបរាប់នៅក្នុងមាត្រា៨៣នៃលក្ខន្តិកៈ។ បណ្តឹងឧទ្ធរណ៍ត្រូវបានពិនិត្យដោយអង្គជំនុំជម្រះឧទ្ធរណ៍ដែលមានអំណាចគ្រប់បែបយ៉ាងរបស់អង្គជំនុំជម្រះដំបូង។ ប្រសិនបើអង្គជំនុំជម្រះឧទ្ធរណ៍យល់ឃើញថា នីតិវិធីមានវិការៈ ឬប្រសិនបើមានការភ័ន្តច្រឡំអង្គហេតុ ឬអង្គច្បាប់ អង្គជំនុំជម្រះឧទ្ធរណ៍អាចលុបចោល ឬកែប្រែការកាត់ទោស ឬបញ្ជូនករណីនេះទៅកាន់អង្គជំនុំជម្រះដំបូងផ្សេង។ ក្នុងករណីទាំងពីរ អង្គជំនុំជម្រះឧទ្ធរណ៍ក៏អាចស្នើសុំឱ្យអង្គជំនុំជម្រះដែលបានចេញសេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍ធ្វើការពន្យល់លើបញ្ហាអង្គហេតុ ហើយថែមទាំងអាចស្នើសុំជាតុភ័ស្តុតាង ដើម្បីកាត់សេចក្តី។ សាលដីកាអាចត្រូវបានប្រកាសដោយមិនមានវត្តមានរបស់ជនជាប់ចោទ(មាត្រា៨៣ វាក្យខណ្ឌទី៥)។

ឧបាស្រ័យសុំសើរើក៏ត្រូវបានពិចារណាផងដែរ។ បុគ្គលដែលត្រូវបានកាត់ទោស ឬប្រសិនបើជននោះស្លាប់ ទាយាទរបស់ជននោះ ឬរាល់បុគ្គលដែលជននោះបានប្រគល់អាណត្តិឱ្យពេលគាត់នៅរស់ដើម្បីគោលបំណងនេះ ព្រមទាំងរដ្ឋអាជ្ញាដែលបំពេញកិច្ចក្នុងនាមបុគ្គលនោះ អាចស្នើសុំឱ្យសើរើរឿងក្តីនៅអង្គជំនុំជម្រះដំបូង ដោយសារមូលហេតុជាច្រើន។ អាចដោយសារការរកឃើញអង្គហេតុថ្មីដែលមិនត្រូវបានដឹងនៅពេលមានរឿងក្តី ដែលកាលៈទេសៈនេះមិនមែនកើតឡើងដោយសារដើមបណ្តឹង និងដែលប្រសិនបើវាត្រូវបានបញ្ជាក់នៅពេលមានរឿងក្តី«ទំនងជាបានបណ្តាលឱ្យមានសាលក្រមផ្សេង»(មាត្រា៨៤ វាក្យខណ្ឌទី១a)។ ឬដោយសារការរកឃើញថា ជាតុភ័ស្តុតាងសំខាន់មួយដែលត្រូវបានទទួលយកនៅក្នុងពេលមានរឿងក្តី និងដែលដោយផ្អែកលើជាតុនោះ ពិរុទ្ធភាពត្រូវបានបញ្ជាក់ គឺមិនត្រឹមត្រូវ ក្លែងក្លាយ ឬក្លែងបន្លំ(មាត្រា៨៤ វាក្យខណ្ឌទី១b)។ ឬជាចុងក្រោយ អាចដោយសារកំហុសធ្ងន់ធ្ងរ ឬការរំលោភបំពានធ្ងន់ធ្ងរលើករណីយកិច្ចរបស់ចៅក្រមម្នាក់ ឬច្រើននាក់ដែលបានចូលរួមនៅក្នុងការសម្រេចសេចក្តីអំពីពិរុទ្ធភាព ឬបានបញ្ជាក់ការដាក់បន្ទុក។ កំហុស ឬការរំលោភត្រូវតែមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថា ចៅក្រមត្រូវបានដកចេញពីមុខងារ(មាត្រា៨៤ វាក្យខណ្ឌទី១c)។ មិនមានកាលកំណត់ណាមួយត្រូវបានកំណត់ ហើយពាក្យបណ្តឹងត្រូវបានដាក់ទៅអង្គជំនុំជម្រះឧទ្ធរណ៍ដើម្បីជំនុំជម្រះលើមូលដ្ឋានត្រឹមត្រូវនៃពាក្យបណ្តឹងនោះ។ ប្រសិនបើអង្គជំនុំជម្រះឧទ្ធរណ៍វិនិច្ឆ័យថាគ្មានមូលដ្ឋាន អង្គជំនុំជម្រះឧទ្ធរណ៍នឹងច្រានចោលពាក្យបណ្តឹងនោះ។ ប្រសិនបើអង្គជំនុំជម្រះ

ឧទ្ធរណ៍យល់ឃើញថា មានមូលដ្ឋានផ្អែកលើមូលហេតុត្រឹមត្រូវ អង្គជំនុំជម្រះឧទ្ធរណ៍អាចទទួលបន្ទុករឿងក្តី ឬបញ្ជូនទៅអង្គជំនុំជម្រះដំបូងដែលបានចេញសេចក្តីសម្រេច ឬប្តឹងទៅអង្គជំនុំជម្រះដំបូងផ្សេងទៀត។ ក្នុងករណីទាំងបី គឺត្រូវកំណត់ថា តើសាលក្រមត្រូវសើរើឬយ៉ាងណា បន្ទាប់ពីស្តាប់ចម្លើយគូភាគីរួច។

# ផ្នែកទី៤

## អង្គដោះស្រាយវិវាទនៃអង្គការពាណិជ្ជកម្មពិភពលោក

ដំណាក់កាលទីពីរនៃនីតិវិធីតំណាងឱ្យការបង្កើតដំណាក់កាលឧទ្ធរណ៍ដែលបង្ហាញយ៉ាងច្បាស់នូវយុត្តាធិការកម្មនីតិវិធី។ ដំណាក់កាលនេះត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹង។ កាលកំណត់ត្រូវបានចែងយ៉ាងណាដើម្បីផ្តល់ចម្លើយឱ្យបានលឿន។ កត្តានេះអាចប្រែប្រួលចន្លោះពី៦០(ពេលខ្លះតិចជាងនេះ)ទៅ៩០ថ្ងៃ។

ORD ត្រូវបានប្រគល់ការកិច្ចឱ្យចាត់តាំងសមាជិកអង្គជំនុំជម្រះឧទ្ធរណ៍។ ការចាត់តាំងនេះត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៥ បន្ទាប់ពីការជជែកដេញដោលជាច្រើន និងយ៉ាងសកម្មដែលបានចំណាយពេលជិតមួយឆ្នាំ។ តាមការពិត គឺត្រូវគោរពតាមគោលការណ៍ភាពជាតំណាងមួយចំនួននៃសមាសភាពរបស់ WTO។ សមាជិកអង្គជំនុំជម្រះឧទ្ធរណ៍មានចំនួន៧រូប និងមានអាណត្តិចំនួនបួនឆ្នាំ។ អនុស្សរណៈចែងថា ត្រូវតែជាបុគ្គលដែលសិទ្ធិអំណាចរបស់ពួកគេត្រូវបានទទួលស្គាល់ និងដែលបានបង្ហាញថា ចេះច្បាប់ពាណិជ្ជកម្មអន្តរជាតិ និងបញ្ហាទាក់ទងនឹងកិច្ចព្រមព្រៀងរបស់ WTO។ ប៉ុន្តែ ការចាត់តាំងសមាជិកមានលក្ខណៈម៉ត់ចត់ដែលសម្គាល់នូវសារៈសំខាន់ និងបញ្ហាប្រឈមនៃនីតិវិធីឧទ្ធរណ៍នេះ។

សមាជិកទាំងបីរូបដែលអង្គុយដើម្បីជំនុំជម្រះរឿងក្តី ត្រូវបានជ្រើសរើសដោយចាប់ឆ្នោត។ ការធ្វើដូច្នេះកាត់បន្ថយគួរឱ្យកត់សម្គាល់នូវភាពជាតំណាង ធៀបនឹង WTO ប៉ុន្តែ ពង្រឹងលក្ខណៈយុត្តាធិការ។ មិនមានយន្តការស្រដៀងនឹងយន្តការនៃការចាត់តាំងចៅក្រមចំពោះកិច្ចដូចនៅ CIJ ទេ។

អង្គជំនុំជម្រះនេះកម្រិតការពិនិត្យរបស់ខ្លួនត្រឹមតែបញ្ហាអង្គច្បាប់ប៉ុណ្ណោះ។ ដូច្នេះ វាគឺជាតក្កវិជ្ជាដែលស្រដៀងនឹងតក្កវិជ្ជានៃការប្តឹងទៅតុលាការកំពូលតាមនីតិក្នុងប្រទេសដែរ។ ចំណុចនេះមានន័យថា ការវាយតម្លៃសេដ្ឋកិច្ច ឬអង្គហេតុដែលក្រុមអ្នកជំនាញបានធ្វើ មិនត្រូវបានពិនិត្យមើលឡើងវិញឡើយ។ ផ្ទុយទៅវិញ នៅក្នុងវិស័យគតិយុត្ត អង្គជំនុំជម្រះឧទ្ធរណ៍មានសេរី

ភាពពេញទី។ អង្គជំនុំជម្រះឧទ្ធរណ៍អាចបញ្ជាក់សការអះអាងរបស់ក្រុមពិសេសទាំងស្រុង។ របាយការណ៍ដែលបង្កើតឡើងដោយអង្គជំនុំជម្រះឧទ្ធរណ៍ត្រូវបានបញ្ជូនទៅ ORD។

ORD ត្រូវបានប្រគល់ភារកិច្ចជាផ្លូវការឱ្យទទួលបន្ទុកលើរបាយការណ៍ និងផ្តល់តម្លៃគតិយុត្តឱ្យវា។ ត្រូវកត់សម្គាល់ថា អង្គជំនុំជម្រះឧទ្ធរណ៍មិនអាចផ្តល់អានុភាពដល់សេចក្តីសម្រេចរបស់ខ្លួនដោយខ្លួនឯងបានឡើយ។ របាយការណ៍នឹងត្រូវសន្មតជាស្វ័យប្រវត្តិថាត្រូវបានអនុម័ត លើកលែងតែកុងសង់ស៊ុសត្រូវបានធ្វើឡើងប្រឆាំងនឹងការអនុម័តរបាយការណ៍ក្នុងរយៈពេល៣០ ថ្ងៃ បន្ទាប់ពីការចែកចាយរបាយការណ៍។ ត្រង់ចំណុចនេះទៀត គឺជាកុងសង់ស៊ុសអវិជ្ជមានដែលពិបាកក្នុងការពិចារណា ព្រោះវាអាចត្រូវបានបំផ្លាញដោយការជំទាស់ច្បាស់លាស់។ ករណីដែលរបាយការណ៍នឹងមិនត្រូវបានអនុម័ត គួរតែកម្របំផុត។

ដូច្នេះ ប្រព័ន្ធត្រូវបានបង្កើតឡើង ដើម្បីផ្តល់ហេតុផលដល់អង្គជំនុំជម្រះឧទ្ធរណ៍។ ដោយហេតុថា អង្គជំនុំជម្រះនេះធ្វើសេចក្តីសម្រេចតែក្នុងផ្នែកអង្គច្បាប់។ ប្រការនេះបណ្តាលឱ្យមានយុត្តាធិការកម្មប្រព័ន្ធ ព្រោះអង្គជំនុំជម្រះមានដំណើរការដូចយុត្តាធិការដែរ ព្រោះដំណាក់កាលទីពីរនេះមិនមែនជានីតិវិធីផ្សះផ្សាថ្មីទេ។ ប៉ុន្តែ នៅតែមានបញ្ហាដំណោះស្រាយដែលមិនមានលក្ខណៈជាកាតព្វកិច្ចដោយខ្លួនឯង ដោយគ្មានអន្តរាគមន៍របស់ ORD។ ប្រការនេះគឺជាភាពដើម និងបញ្ចុះតម្លៃវិសាលភាពយុត្តាធិការបន្តិចបន្តួចរបស់អង្គជំនុំជម្រះឧទ្ធរណ៍ដោយផ្តល់តែតួនាទីនៅសល់ទៅឱ្យ ORD ប៉ុណ្ណោះ ព្រោះការអនុម័តលើរបាយការណ៍ស្ទើរតែមានលក្ខណៈស្វ័យប្រវត្តិ។ ត្រូវកត់សម្គាល់ផងដែរថា ដំណោះស្រាយលើអង្គច្បាប់អាចបំពេញចិត្តគូភាគីតិចជាងដំណោះស្រាយដែលស្នើឡើងដោយក្រុមអ្នកជំនាញ។ ដូច្នេះ មានលទ្ធភាពថា ការដោះស្រាយនេះមានលក្ខណៈ«បំបាក់ទឹកចិត្ត»ខ្លាំងជ្រុល និងជំរុញឱ្យមានប្រតិបត្តិការ។ ក្នុងការអនុវត្តជាក់ស្តែង ប្រការនេះមិនទំនងជាកើតឡើងឡើយ។

## ១- កាតព្វកិច្ចរបស់ CIJ

តុលាការយុត្តិធម៌អន្តរជាតិត្រូវបានអនុញ្ញាតឱ្យមានសមត្ថកិច្ចលើរឿងក្តីចំនួនពីរប្រភេទ ៖ រឿងក្តីវិវាទ និងនីតិវិធីពិគ្រោះយោបល់។ ប៉ុន្តែ តុលាការអាចចេញសេចក្តីសម្រេចប្រភេទផ្សេងទៀត ៖ វិធានការរក្សាការពារ ការលើកលែងជាមុន បណ្តឹងតប បណ្តឹងអន្តរាគមន៍ ការបញ្ជូនពិសេសទៅជំនុំជម្រះនៅតុលាការ និងការដកពាក្យបណ្តឹង។

### ១.១- មុខងារពិគ្រោះយោបល់

យោបល់ពិគ្រោះមិនមានលក្ខណៈចាប់បង្ខំ ឬមានអាជ្ញាអង្គជំនុំទេ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យោងតាមវាក្យខណ្ឌទី២នៃមាត្រា៩៦នៃធម្មនុញ្ញ មហាសន្និបាតអាចអនុញ្ញាតឱ្យស្ថាប័នផ្សេងទៀតនៃអង្គការ ឬស្ថាប័នជំនាញស្នើសុំយោបល់ពិគ្រោះអំពី«បញ្ហាគតិយុត្តដែលចោទឡើងក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ស្ថាប័នទាំងនោះ»។

## ១.២- វិធានការរក្សាការពារ

ក្នុងដំណាក់កាលបឋមនៃស្ថាប័ន តុលាការត្រូវបានអនុញ្ញាតឱ្យបង្គាប់ឱ្យភាគីម្ខាង ឬភាគីទាំងពីររក្សាស្ថានភាពដដែលរហូតដល់ពេលតុលាការចេញសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន។ យោងតាមវាក្យខណ្ឌទី១នៃមាត្រា៤១នៃលក្ខន្តិកៈរបស់ខ្លួន «ប្រសិនបើតុលាការយល់ឃើញថាកាលៈទេសៈតម្រូវ តុលាការមានអំណាចបញ្ជាក់ថា តើវិធានការរក្សាការពារណាខ្លះតាមច្បាប់របស់ភាគីនីមួយៗត្រូវអនុវត្តជាបណ្តោះអាសន្ន»។ ភាគីណាមួយដែលស្នើសុំឱ្យតុលាការបញ្ជាក់អំពីវិធានការរក្សាការពារត្រូវបញ្ជាក់ថា ៖ ទីមួយ តុលាការជាជំបូងបំផុត មានសមត្ថកិច្ចទទួលបន្ទុកលើរឿងក្តី ទីពីរ មានទំនាក់ទំនងរវាងច្បាប់ដែលភាគីចង់ឃើញការពារ និងវិធានការដែលស្នើសុំ និងទីបី មានលទ្ធភាពដែលបម្រុងនឹងកើតឡើងនៃការខូចខាតដែលមិនអាចជួសជុលបាន។

បញ្ហានេះក៏បានចោទឡើងនាពេលថ្មីៗនេះផងដែរនៅពេលពិនិត្យមើលពាក្យបណ្តឹងសុំឱ្យបញ្ជាក់វិធានការរក្សាការពារដែលត្រូវបានដាក់នៅក្នុងរឿងក្តីទាក់ទងនឹងពាក្យបណ្តឹងសុំឱ្យបកស្រាយសាលដីកាចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ក្នុងរឿងក្តីប្រាសាទព្រះវិហារ(ប្រទេសកម្ពុជាជាមួយប្រទេសថៃ)។ តុលាការបានសន្និដ្ឋានថា ដរាបណាសិទ្ធិដែលត្រូវបានទាមទារដោយប្រទេសកម្ពុជា ផ្អែកលើសាលដីកាដែលតុលាការបានប្រកាសនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ក្នុងរឿងក្តីប្រាសាទព្រះវិហារ ដូចដែលត្រូវបានបកស្រាយដោយប្រទេសកម្ពុជា សិទ្ធិទាំងនេះអាចទទួលយកបាន។

## ការលើកលែងជាមុន

យោងតាមមាត្រា៧៩នៃបទបញ្ជា ក្នុងរយៈពេលបីខែបន្ទាប់ពីការដាក់សារណា ចុងចោទអាចបង្ហាញជាលាយលក្ខណ៍អក្សរនូវការលើកលែងមិនទទួលស្គាល់សមត្ថកិច្ចរបស់តុលាការ ឬបដិសេធភាពអាចទទួលយកបាននៃពាក្យបណ្តឹង។ នៅពេលការលើកលែងជាមុនត្រូវបានលើកឡើង តុលាការផ្អាករាល់ការពិនិត្យរឿងក្តីដល់អង្គសេចក្តី រហូតដល់ត្រូវបានធានាអំណាចមានសមត្ថកិច្ចលើរឿងក្តី។

បន្ទាប់ពីបានស្តាប់ការយល់ឃើញរបស់ភាគីទាំងពីរស្តីពីការលើកលែងជាមុន តុលាការប្រកាសសាលដីកាមួយដែលក្នុងនោះតុលាការទទួលយកការលើកលែង ច្រានចោលការលើកលែង ឬប្រកាសថា ការលើកលែងនេះមិនមាន«លក្ខណៈជាមុនដាច់ខាត»ទេ។ ត្រង់ចំណុចនេះ វាគឺ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជារូបមន្តថ្មីដែលបញ្ចូលនៅក្នុងបទបញ្ជារបស់តុលាការ ដូចដែលត្រូវបានកែប្រែនៅឆ្នាំ១៩៧៨ ដែលមិនមានផលវិបាក។

ចាប់តាំងពីឆ្នាំ១៩៧២ ជាច្រើនដង តុលាការបានកំណត់ថា ការលើកលែងជាមុនមិនមាន «លក្ខណៈជាមុនដាច់ខាត»ទេ។ ក្នុងរឿងក្ដីសកម្មភាពយោធា និងអមយោធានៅប្រទេសនីការ៉ាហ្គ័រ និងប្រឆាំងនឹងប្រទេសនេះ តុលាការបានវិនិច្ឆ័យថា ការលើកលែងដែលលើកឡើងដោយសហរដ្ឋអាមេរិក មានលក្ខណៈពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងខ្លឹមសារ និងអង្គសេចក្ដីនៃវិវាទដែលការលើកលែងមិនមានលក្ខណៈជាមុនដោយខ្លួនឯងឡើយ និងដែលការលើកលែងមិនបានរារាំងទៅនឹងប្រការដែលតុលាការមានសមត្ថកិច្ចលើបណ្ដឹងដែលដាក់មកដោយប្រទេសនីការ៉ាហ្គ័រឡើយ។

## ២- បណ្ដឹងតប

បណ្ដឹងតបត្រូវតែដាក់នៅក្នុងប្រតិសារណារបស់ចុងចម្លើយអំពីអង្គសេចក្ដី។ វាគឺជា«លិខិតគតិយុត្តស្វយ័តដែលមានកម្មវត្ថុដាក់ការទាមទារថ្មីដល់ចៅក្រម»ដែលត្រូវ«ភ្ជាប់»ជាមួយនឹងបណ្ដឹងដើម «ក្នុងលក្ខខណ្ឌដែលដើមបណ្ដឹងឆ្លើយតបនឹងវាដែលត្រូវបានធ្វើឡើង«ជាការឆ្លើយតប»។

ដូចដែលវាក្យខណ្ឌទី១នៃមាត្រា៨០នៃបទបញ្ជាបានបញ្ជាក់ស្រាប់ «តុលាការអាចមានសមត្ថកិច្ចជំនុំជម្រះលើបណ្ដឹងតបតែក្នុងករណីដែលបណ្ដឹងតបនេះគឺជាសមត្ថកិច្ចរបស់ខ្លួន និងមានការទាក់ទងផ្ទាល់ជាមួយនឹងកម្មវត្ថុនៃបណ្ដឹងរបស់ភាគីបដិបក្ខប៉ុណ្ណោះ»។ នីតិវិធីនៃបណ្ដឹងតបមានគោលដៅ«សម្រេចការសន្សំសំចៃរឿងក្ដី ដោយអនុញ្ញាតឱ្យចៅក្រមមានការយល់ឃើញរួមអំពីការទាមទារនីមួយៗរបស់គូភាគី និងសម្រេចសេចក្ដីកាន់តែស៊ីចង្វាក់គ្នា»។

## ៣- អន្តរាគមន៍

នីតិវិធីឧប្បត្តិហេតុប្រភេទទីបួនគឺអន្តរាគមន៍របស់រដ្ឋនៅក្នុងរឿងក្ដីកំពុងជំនុំជម្រះរវាងរដ្ឋផ្សេងៗ។ នីតិវិធីនេះអនុញ្ញាតឱ្យរដ្ឋដែលធ្វើអន្តរាគមន៍ធ្វើការបង្ហាញដល់តុលាការនូវការសង្កេតរបស់ខ្លួនអំពីទិដ្ឋភាពពិសេសនៃរឿងក្ដី។ លក្ខន្តិកៈរបស់តុលាការចែងអំពីអន្តរាគមន៍ចំនួនពីរប្រភេទ។ ទីមួយ យោងតាមមាត្រា៦២នៃលក្ខន្តិកៈ «នៅពេលរដ្ឋមួយយល់ឃើញថា នៅក្នុងវិវាទមួយ ផលប្រយោជន៍គតិយុត្តគឺជាបញ្ហាសម្រាប់ខ្លួន រដ្ឋនោះអាចផ្ញើពាក្យស្នើសុំទៅតុលាការដើម្បីធ្វើអន្តរាគមន៍»។ ទីពីរ យោងតាមមាត្រា៦៣នៃលក្ខន្តិកៈ នៅពេលរឿងក្ដីមួយពាក់ព័ន្ធនឹងការបកស្រាយអនុសញ្ញា ក្រឡាបញ្ជីនឹងជូនដំណឹងដល់រដ្ឋទាំងអស់ដែលជាភាគីនៃអនុសញ្ញានោះដែលបន្ទាប់មកមានសិទ្ធិធ្វើអន្តរាគមន៍នៅក្នុងរឿងក្ដី។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឯកសារយោង

## ឯកសារជាសៀវភៅ

### ១- ឈ្មោះសៀវភៅយោងជាភាសាខ្មែរ


- *រាជរដ្ឋាភិបាលកម្ពុជា: គោលនយោបាយជាតិប្រជាជនភ្នំពេញឆ្នាំ2003*
- *ហង់ជួន ណារ៉ុន ៖ ម៉ាក្រូសេដ្ឋកិច្ចភ្នំពេញគ្រឹះស្ថានបោះពុម្ពព្រះវិហារឆ្នាំ2009*
- *ហង់ជួន ណារ៉ុន ៖ ហិរញ្ញវត្ថុសាធារណៈ ភ្នំពេញគ្រឹះស្ថានបោះពុម្ពផ្សាយព្រះវិហារឆ្នាំ2009*


### ២- ឈ្មោះសៀវភៅជាភាសាបរទេស


- APOLLIS (G.), *Les frontières maritimes en droit international : Mutations et Perspectives,* Rapports économiques et juridiques no 7-1979. Centre national pour l'exploitation des océans.

- AURESCU (de B.) et PELLET (A.) (dir.), *Actualités du droit des fleuves internationaux*, Paris, Pedone, 2010.

- BARDONNET (D.) ET VIRALLY (M.) (dir.), *Le nouveau droit de la mer*, Paris, Pedone, 1983.

- BASTID (S.), *Les traités dans la vie internationale. Conclusions et effets*, Paris, Economica, 1985.

- BEAUDOUIN (A.), *Uti possidetiset sécession*, Paris, Dalloz, 2011.

- BEURIER (J.-P.) ET KISS (A.), *Droit international de l'environnement*, 4e édition, Paris, Pedone, 2010.

- BEURIER (J-P.), CHAUMETTE (P.), PROUTIERE-MAULOIN (G.), *Droits maritimes. Tome III. Exploitation et protection de l'océan*, Paris, Editions Juris-service, 1998.

- BIRNIE (P.) et BOYLE (A.), *International Law and the Environment*, Oxford University Press, 2002.

- BLANCHARD (M.), *Vietnam-Cambodge : une frontière contestée*, L'Harmattan, 1999.

- BLUM (Y. Z.), *Historic Titles in International Law*, La Haye, Nijhoff, 1965.

- CARREAU (D.), *Droit international*, 10e édition, Paris, Pedone, 2009.




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- CARROZ (J.), *Le droit et la mer,* Mélanges offerts à la mémoire de Jean Carroz, Rome,Organisation des Nations Unies pour l'alimentation et l'agriculture, 1987.

- CATALDI (G.), *La Méditerranée et le droit de la mer à l'aube du XXIème siècle*, Bruxelles, Bruylant, 2002.

- CHARNEY (J.) et ALEXANDER (L.) (eds), *International Maritime Boundaries*, Volume I, Dordrecht, Martinus Nijhoff, 1993.

- CHARNEY (J.) et ALEXANDER (L.) (eds), *International Maritime Boundaries*, Volume II, Dordrecht, Martinus Nijhoff, 1993.

- CHARNEY (J.) et ALEXANDER (L.) (eds), *International Maritime Boundaries*, Volume III, Dordrecht, Martinus Nijhoff, 1998.

- CHARNEY (J.) et SMITH (R.) (eds), *International Maritime Boundaries*, Volume IV, Dordrecht, Martinus Nijhoff, 2002.

- CHARPENTIER (J.), *La reconnaissance internationale et l'évolution du droit des gens*, Paris, Pedone, 1956.

- CHURCHILL (R.) et LOWE (A.), *The Law of the Sea*, Juris Publishing, Manchester University Press, 1999.

- COLSON (D.) et SMITH (R.) (eds), *International Maritime Boundaries*, Volume V, Dordrecht, Martinus Nijhoff, 2005.

- COMBACAU (J.) et SUR (S.), *Droit international public*, 8e édition,Paris, Montchrestien, 2008.

- COMBACAU (J.), *Le droit international de la mer*, Paris, P.U.F., Que sais-je ?, 1985.

- CORNU (G.), *Vocabulaire juridique*, Paris, P.U.F., 1987.

- DAILLIER (P.), FORTEAU (M.) et PELLET (A.), *Droit international public (Nguyen Quoc Dinh)*, 8e édition, Paris, L.G.D.J., 2009.

- DECAUX (E.), *Droit international public*, Paris, Dalloz, 2010, 7e édition.

- DEJEAN-PONS (M.), *La Méditerranée en droit international de l'environnement*, Paris,Economica, 1990.

- DUPUY (R.J.), *L'océan partagé ; analyse d'une négociation (Troisième Conférence des Nations Unies sur le droit de la mer)*, Paris, Pedone, 1979.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- DUPUY (P-M.) et KERBRAT (Y.), *Droit international public*, 10e édition, Paris, Dalloz, 2010.

- DUPUY (R.J.) etVIGNES (D.), *Handbook on the New Law of the Sea*, ADI, Martinus Nijhoff, 1991-1993, 2 tomes.

- DUPUY (R.J.) et VIGNES (D.), *Traité du nouveau droit de la mer*, Bruxelles, Bruylant, Paris, Economica, 1985.

- EISEMANN (P.M.) et PAZARTZIS (P), *La jurisprudence de la Cour internationale de justice*, Ed. Pédone, 2008.

- EISEMANN (P.M.), *La Convention des Nations Unies sur le droit de la mer (10 décembre 1982)*, Paris, La documentation française, 1983.

- FITZMAURICE (M.) et SZUNIEWICZ (M.) (eds.), *Exploitation of Natural Resources in the 21st Century*, La Haye, Kluwer Law International, 2003.

- FRANCALANCI (G.) et SCOVAZZI (T.) (eds), *Lines in the Sea*, Dordrecht, Nijhoff, 1994.

- FRANCKX (E.), *La zone économique exclusive et la Convention des Nations Unies sur ledroit de la mer, 1982-2000 : un premier bilan de la pratique des Etats*, Bruxelles, Bruylant, 2003.

- FOUCHER (M.), *L'invention des frontières*, Paris, FEDN, 1986.

- FOUCHER (M.), *Front et frontières – un tour du monde géopolitique*, Paris, Fayard, 1991.

- FOUCHER (M.), *L'Obsession des frontières*, Paris, Perrin, 2007.

- FOX (H.) (eds), *Joint Development of Offshore Oil and Gas: A Model Agreement for States for Joint Development with Explanatory Commentary*, Volumes I and II, (1989 and 1990).

- GIDEL (G.), *Le droit international public de la mer. Le temps de paix, tome III, La mer territoriale et la zone contiguë, fascicule II*, Paris, Libraire Edouard Duchemin, 1981.

- GOUR(C-G.), *Institutions Constitutionnelles et Politiques du Cambodge*. Paris, Dalloz, 1965.

- HORCHANI (F.), *Règlement pacifique des différends internationaux*, Bruxelles, Bruylant, 2002.

- INDEMER, *Les zones maritimes en Méditerranée, Actes du colloque de Monaco, 4-6 octobre 2001*, n°6, 2001.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- INDEMER, *Le processus de délimitation maritime : étude d'un cas fictif, colloque international, Monaco 27-29 mars 2003*, Paris, Pedone, 2004.

- INDEMER et ACADÉMIE DE LA MER, *Le plateau continental étendu aux termes de la convention des Nations Unies sur le droit de la mer, du 10 décembre 1982 : optimisation de la demande*, Paris, Pedone, 2004.

- INDEMER et UNIVERSITÉ MOULAY ISMAÏL, *Le plateau continental dans ses rapports avec la zone économique exclusive. Symposium international de Meknès, 28 et 29 janvier 2005*, Paris, Pedone, 2006.

- JAGOTA (S.P.), *Maritime boundary, Dordrecht*, Boston, Nijhoff, 1985.

- JAYEWARDENE (H.W.), *The Regime of Islands in International Law*, Dordrecht, Nijhoff.

- JENNINGS (R.Y.), *The Acquisition of Territory in International Law*, Manchester, Manchester University Press, 1963.

- KELSEN (H.), *Principles of International Law*, New York, Holt,Rinchart and Winston, 2nd edition, revised and edited by Robert W. Tucker, 1966.

- KIRCHNER (A.), *Internation Marine Environmental Law: Institutions, Implementation and Innovations*, La Haye, Kluwer Law International, 2003.

- KISS (A), BEURIER (J-P), *Droit international de l'environnement, 4e édition*, Paris, Pedone, 2010.

- KITTICHAISAREE (K), *The Law of the Sea and Maritime Boundary Delimitation in Southeast Asia*, Oxford University Press, Singapore, 1987.

- KNIGHT (G.) AND CHIU (H.), *The International Law of the Sea: Cases, Documents, and Readings*, London and New York, Elsevier Applied Science and Unifo Publishers, 1990.

- KOLB (R.), *Case Law on Equitable Maritime Delimitation: Digest and Commentaries*, The Hague, Nijhoff, 2003.

- KOLB (R.), *Les cours généraux de droit international public de l'Académie de La Haye*, Bruxelles, Bruylant, 2003.

- KOHEN (M.), *Possession contestée et souveraineté territoriale*, Paris, PUF, 1997.

- LABRECQUE (G.), *Les frontières maritimes internationales, 2e edition*, Paris,


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

L'Harmattan, 2004.

- LABRECQUE (G.), *Les différends internationaux en Asie*, Paris, L'Harmattan, 2007.

- LABRECQUE (G.), *Les différends territoriaux en Afrique*, Paris, L'Harmattan, 2007.

- LAFONT (P.-B.), *Les frontières du Vietnam. Histoire des frontières de la Péninsule indochinoise*, Paris, L'Harmattan, 1999.

- LAPRADELLE (P. de), *La Frontière, Paris*, Les éditions internationales, 1928.

- LAUTERPACHT (H.), *Recognition in International Law*, University Press, Cambridge, 1948.

- LAUTERPACHT (H.), *Private Law Sources and Analogies of International Law*, London, Longmans, Green and co., 1927.

- LEVY (J. P.), *La conférence des Nations Unies sur le droit de la mer, histoire d'une négociation singulière*, Paris, Pedone, 1983.

- LUCCHINI (L.) et QUENEUDEC (J-P.), *La Mer et son droit, mélanges offerts à Laurent Lucchini et Jean-Pierre Quéneudec*, Paris, Pedone, 2003.

- LUCCHINI (L.) et VOELCKEL (M.), *Droit de la mer, tome. I, la mer et son droit, les espaces maritimes*, Paris, Pedone, 1990.

- LUCCHINI (L.) et VOELCKEL (M.), *Droit de la mer, tome II, délimitation, navigation et pêche, vol. 2 : navigation et pêche*, Paris, Pedone, 1996.

- NATIONS UNIES, *Manuel sur ladelimitation des frontières maritimes*, New York, 1996.

- LABRECQUE (G.), *Les frontières maritimes internationales, 2e edition*, Paris, L'Harmattan, 2004.

- LANG (J.), *Le plateau continental de la mer du Nord*, Paris, L.G.D.J., 1970.

- LOWE (A.V.) AND CHURCHILL (R.R.), *The Law of Sea, 3rdedition*, Juris Publishing, Manchester University Press, 1999.

- MEYER(Ch.), *Derrière le sourire khmer*. Paris, Plon, 1971.

- NGUYEN HONG THAO, *Le Vietnam et ses différends maritimes dans la Mer de Bien Dong (Mer de Chine méridionale)*, Paris, Pedone, 204.

- NORDQUIST (N.H.), *United Nations Convention on the Law of the Sea, a commentary, volume II, Articles 1 to 85*, Boston, Martinus Nijhiff Publishers, 1993.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- NORDQUIST (N.H.), *United Nations Convention on the Law of the Sea, a commentary, volume III, Articles 86 to 132*, Boston, Martinus Nijhiff Publishers, 1995.

- NORDQUIST (M.H.), *Legal and Scientific Aspects of Continental Shelf*, Martinus Nijhiff Publishers, 2004.

- NORDQUIST (M.H.), NORTON MOORE (J.) et MAHMOUDI (S.), *The Stockholm declaration of law of the marine environment*, Kluwer Law International, 2003.

- NUNO MARQUES ANTUNES, *Towards the Conceptualisation of Maritime Delimitation: Legal and Technical Aspects of a Political Process*, Leiden, Nijhoff, 2003.

- ODA (S.), *Liber Amicorum Judge Shigeru Oda, volume 2,* La Haye, Kluwer Law International, 2002.

- ORREGO VICUNA (F.), *The Exclusive Economic Zone, Regime and Legal Nature under International Law*, Cambridge, Cambridge Studies in International and Comparative Law, 1989.

- PANCRACIO (J-P.), *Droit de la mer, 1er édition*, Paris, Dalloz, 2010.

- PAZARTZIS (P.), *Les engagements internationaux en matière de règlement pacifique des différends entre États*, Paris, L.G.D.J., 1992.

- PHARAND (D.) AND LEANZA (U.), *The Continental Shelf and the Exclusive Economic Zone: Delimitation and Legal Regime*, Dordrecht, Boston, London, Martinus Nijhiff Publishers, 1995.

- POP (I.), *Voisinage et bon voisinage en droit international*, Paris, Pedone, 1980.

- REUTER (P.), *Introduction au droit des traités, 2e édition*, Paris, PUF, 1985.

- ROTHWELL (D.) etSTEPHENS (T.), *The International Law of the Sea*, Hart Publishing, Oxford and Portland, Oregon, 2010.

- ROUSSEAU (C.), *Droit international public, Tome III, les compétences*, Paris, Sirey, 1977.

- ROUSSEAU (C.), *Droit international public, Tome IV, les relations internationales*, Paris, Sirey, 1980.

- ROZAKIS (C.L.) et STEPHANOU (C.A.), *The new law of the sea*, Amsterdam, Selected and edited papers of the Athens colloquium on the law of the sea – 1982, 1983.

- SALMON (J.), *Dictionnaire de droit international public*, Bruylant, Bruxelles, 2001.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- SANTULLI (C.), *Droit du contentieux international*, Paris, Montchrestien, 2005.

- SCHRIJVER (N), *Sovereignty over natural ressources: balancing rights and duties*, Cambridge University press, 1997.

- SCOVAZZI (T), *Marine specially protected areas: The general aspects and the Mediterranean regional system*, La Haye, Kluwer law international, 1999.

- SIDDAYAO (C. M.), *The off-shore petroleum resources of South-East Asia: potential conflict situations and related economic consideration*, Oxford University Press for the Institute of Southeast Asian Studies, Singapore, 1978.

- SOCIETE FRANÇAISE DE DROIT INTERNATIONAL, *La Frontière, colloque de Poitiers*, Paris, Pedone, 1980.

- SOCIETE FRANÇAISE DE DROIT INTERNATIONAL, *Perspectives du droit de la mer à l'issue de la Troisième Conférence des Nations Unies*, Paris, Pedone, 1984.

- SOCIETE FRANÇAISE DE DROIT INTERNATIONAL, *La juridictionalisation du droit international*, colloque de Lille, Paris, Pedone, 2003.

- SHAW (M.), *International Law*, Cambridge, Sixth edition, Cambridge University Press, 2008.

- SURYA (S.), *Territorial Acquisition, Disputes and International Law*, La Haye, Nijhoff, 1997.

- TANAKA (Y.), *Predictability and flexibility in the Law of Maritime Delimitation*, Oxford and Portland, Oregon, 2006.

- TANJA (G.), *The Legal Determination of International Maritime Boundaries*, Deventer ; Boston, Kluwer Law and Taxation Publishers, 1990.

- TRIGGS (G.), *International Law:Contemporary Principles and Practices*, 2nd edition, LexisNexis Butterworths, Australia, 2011.

- VERHOEVEN (J.), *La reconnaissance internationale dans la pratique contemporaine*, Paris, Pedone, 1975.

- VICUNA (F.), *The Exclusive Economic Zone*, Oregon, 1989.

- VISSCHER (Ch. de), *Les effectivités en droit international*, Paris, Pedone, 1967.

- VISSCHER (Ch. de), *Problèmes de confins en droit international public*, Paris, Pedone, 1969.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- VISSCHER (Ch. de), *Théories et réalités en droit international public*, 4e éd., Paris, Pedone, 1970.

- WECKEL (P.) (dir.), *Le juge international et l'aménagement de l'espace: la spécificité du contentieux territorial*, Paris, Pedone, 1998.

- WEIL (P.), *Perspectives du droit de la délimitation maritime*, Paris, Pedone, 1988.

- WEIL (P.), *Écrits de droit international*, Paris, PUF, 2000.

## គេហទំព័រ

•http://www.mbendi.com/indy/oilg/ogus/as/my/p0005.thm.

• http://www.un.org/Depts/los/LEGISLATIONANDTREATIES/claims.htm

• http://www.un.org/french/law/los/index.htm

•http://www.gregcroft.com/thailand.ivnv



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៥នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកជានាភ៉ប់រងពីវិទ្យាស្ថានជានាភ៉ប់រង(CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានជានាភ៉ប់រងម៉ាឡេស៊ី(MII)នៅឆ្នាំ២០០៨។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅកម្ពុជា និងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិត្យសភា Rhodes ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពី ឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបូកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះលោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសីទអន្តរជាតិ ដូចជាមហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិកាអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃក្រោមចំណងជើងថា «Cambodian Economy: Charting the Course for a Bright Future» ត្រូវបានជ្រើសរើសបោះពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ«គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា នាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា( ទសវត្សរ៍ឆ្នាំ១៩៨០)»។

# ស្នាដៃរបស់អ្នកនិពន្ធ

១- ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩
២- ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩
៣- ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩
៤- ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ - ឆ្នាំ២០១៣
៥- សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥
៦- កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦
៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា នាសម័យទំនើប នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា( ទសវត្សរ៍ឆ្នាំ១៩៨០ ) - ឆ្នាំ២០១៧
៨- L'Économie du Cambodge : La lutte pour le développement, 2005
៩- Essais économiques, 2007
១០- L'économie du Cambodge: Nouvelles frontières du développement socio-économique, 2010
១១- Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012
១២- Les finances publiques du Cambodge, 2007
១៣- Cambodia: Recent Macroeconomic and Financial Sector Development, 2008
១៤- Three Essays on Macroeconomic Management of Cambodia, 2008
១៥- Introduction to Insurance, 2008
១៦- Public Finance in Cambodia, 2009
១៧- Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia